# ជំពូក ៧

# ហេតុប៉ះពាល់បរិស្ថានសំខាន់ៗ និង វិធានការកាត់បន្ថយ

# POTENTIAL ENVIRONMENTAL IMPACTS AND MITIGATION MEASURES

Draft

Draft

# ជំពូកទី ៧

## ៧.១ ហេតុប៉ះពាល់បរិស្ថានសំខាន់ៗនិងវិធានការកាត់បន្ថយនៃហេដ្ឋារចនាសម្ព័ន្ធទំនប់វារីអគ្គិសនី

ការសិក្សានេះយោងតាមអនុក្រឹត្យស្តីអំពីកិច្ចដំណើរ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលចុះហត្ថលេខាដោយប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចូលជាធរមាននៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩។ គម្រោងវិនិយោគសាងសង់វារីអគ្គិសនីពោធិ៍សាត់ របស់ក្រុមហ៊ុនកូរ៉េ និងចិន បានចុះធ្វើការសិក្សាស្រាវជ្រាវ និងរៀបចំរបាយការណ៍ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ (ESIA) ចាប់ពីថ្ងៃទី ១០ ខែកុម្ភៈ ដល់ ថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ២០១២ រួចធ្វើបច្ចុប្បន្នភាព ខែកញ្ញា ឆ្នាំ២០១៥ និង ខែតុលា ដល់ខែវិច្ឆិកា ឆ្នាំ២០១៧ នេះ ធ្វើបច្ចុប្បន្នភាព សិក្សាផលប៉ះពាល់ អចលនទ្រព្យរបស់ប្រជាពលរដ្ឋក្នុងតំបន់គម្រោងឡើងវិញ។

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសង្គម (ESIA) នេះគឺជាការអង្កេតសិក្សាស្រាវជ្រាវដើម្បីរក និងកំណត់ហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងបរិស្ថានសង្គមក្នុងដំណាក់មុនសាងសង់គម្រោង (Pre-Project Construction) សាងសង់ (Project Construction) ប្រតិបត្តិ និងថែទាំគម្រោង (Project Operation & Maintenance) ហើយនិងដំណាក់កាលបិទគម្រោង (Project Closure)។ ហេតុប៉ះពាល់បរិស្ថានទាំងនោះ ត្រូវរកវិធានការកាត់បន្ថយឱ្យដល់កម្រិតអប្បបរមា និងធ្វើផែនការគ្រប់គ្រងបរិស្ថាននៃដំណាក់កាលរបស់គម្រោងនីមួយៗ ទាំងនោះដោយមានការអនុវត្តពីម្ចាស់គម្រោង រួមកិច្ចសហការត្រួតពិនិត្យពីបណ្តាស្ថាប័នជំនាញពាក់ព័ន្ធ ដូចជាមន្ទីរបរិស្ថានខេត្ត, មន្ទីរ រ៉ែ និងថាមពលខេត្ត, មន្ទីរធនធានទឹក និងឧតុនិយម, មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្ត, មន្ទីររៀបចំដែនដីនគរ រូបនីយកម្ម សំណង់និងសុរិយោដីខេត្ត, អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់, ដោយមានការគ្រប់គ្រងតាមខ្សែបណ្តោយ ពីក្រសួងបរិស្ថាន, ក្រសួង រ៉ែ និងថាមពល, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងរៀបចំដែនដីនគររូប នីយកម្ម និងសំណង់។ ក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនេះ ក្រុមការងារ SAWAC បានប្រើប្រាស់តារាង Checklist ដើម្បីកំណត់ទំហំនៃការប៉ះពាល់ រួចជ្រើសយកការវាយតម្លៃហេតុប៉ះពាល់បរិស្ថានអវិជ្ជមានណា ដែលមានកម្រិត តិច មធ្យម និងខ្លាំង មកធ្វើវិធានការកាត់បន្ថយហេតុប៉ះពាល់ទាំងនេះឱ្យដល់កម្រិតអប្បបរមា។

Draft

## ៧.២ វិធីសាស្ត្រនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនេះ

វិធីសាស្ត្រនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ (ESIA) សម្រាប់គម្រោងវារីអគ្គិសនីនេះ គឺជាការពិនិត្យលើរាល់សកម្មភាពនៃគម្រោង ដែលបានស្នើឡើង ដើម្បីកំណត់នូវបញ្ហាសំខាន់ៗលើបរិស្ថានធម្មជាតិ ដោយផ្តោតសំខាន់ទៅលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងបរិស្ថានសង្គម ដោយផ្តោតសំខាន់ទៅលើធនធានសេដ្ឋកិច្ច និងសង្គម រួមទាំងសុខភាព រួមទាំងសុខុមាលភាពសាធារណៈ។ នៅក្នុងជំពូកនេះអាចជួយក្នុងការកំណត់លម្អិតនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដោយផ្តោតទៅលើបញ្ហាសំខាន់ៗដែល ពាក់ព័ន្ធមនុស្ស និងបរិស្ថាន។

នៅក្នុងចំណុចនេះ បញ្ជីតារាងកំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន (Checklist) របស់ក្រសួងបរិស្ថានត្រូវបានប្រើប្រាស់ សម្រាប់កំណត់នូវបញ្ហាសំខាន់ៗ ដែលជះឥទ្ធិពលទៅលើបរិស្ថាន និងសង្គមទាំងនៅក្នុងដំណាក់កាលសាងសង់ ដំណាក់កាលប្រតិបត្តិគម្រោង និងដំណាក់កាលបញ្ចប់គម្រោង (តារាង ៧-៣)។ ជាងនេះទៅទៀត បញ្ជីតារាង (Checklist) គម្ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្នុងការកំណត់កាសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (តារាង ៧-១) ក៏យកមកប្រើ ដើម្បីកំណត់នូវការសិក្សាតាមផ្នែក និងតំបន់នីមួយៗ ឱ្យចំគោលដៅនៃគម្រោង និងតំបន់ដែលរងការប៉ះពាល់ដោយសារវាផងដែរ។

## ៧.៣ ការកំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

កិច្ចដំណើរការនៃការកំណត់ទំហំ (Scoping) នៃហេតុប៉ះពាល់បរិស្ថាន និងសង្គម គឺជាការបរិយាយបញ្ហាមួយបន្ទាប់ពីដំណាក់កាលនៃការធ្វើចំណាត់ថ្នាក់គម្រោង (Screening) ដែលក្នុងនោះរួមមាន៖

- លក្ខណៈផលប៉ះពាល់ និងឥទ្ធិពលទៅលើបរិស្ថាន និងសង្គមពីសកម្មភាពគម្រោង
- ទីតាំងគម្រោងនិងតំបន់ជិតខាង ដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលពីសកម្មភាពគម្រោង។

ទីតាំងសិក្សាដែលត្រូវកំណត់ទំហំផលប៉ះពាល់នៅក្នុងបរិវេណជុំវិញទីតាំងគម្រោងប្រមាណជា១,៥គីឡូម៉ែត្ររួមមាន៖

**ក-ធនធានរូបសាស្ត្រ**

- ការសិក្សាអំពីការប្រែប្រួលសណ្ឋានដី និងការហូរច្រោះដី
- ការសិក្សាអំពីហេតុប៉ះពាល់ដល់ប្រព័ន្ធជលសាស្ត្រ របស់ស្ទឹងឬស្សីជ្រុំ(កណ្ដាល)
- ការសិក្សាអំពីហេតុប៉ះពាល់ដល់គុណភាពទឹកស្ទឹងឬស្សីជ្រុំ(កណ្ដាល)
- ការសិក្សាអំពីហេតុប៉ះពាល់ដល់គុណភាពខ្យល់
- ការសិក្សាអំពីការរំខានដោយសំឡេង និងរំញ័រ។

**ខ-ធនធានជីវសាស្ត្រ**

- ការសិក្សាអំពីហេតុប៉ះពាល់ទៅលើធនធានព្រៃឈើ និងសត្វព្រៃ
- ការសិក្សាអំពីហេតុប៉ះពាល់ទៅដល់ជីវៈចម្រុះក្នុងទឹក ពិសេសធនធានមច្ឆជាតិ ដែលនៅស្ទឹងពោធិ៍សាត់
- ការសិក្សាអំពីហេតុប៉ះពាល់ដល់តំបន់ការពារធម្មជាតិ ឬ តំបន់អភិរក្ស ឬឧទ្យានជាតិ ឬតំបន់ព្រៃការពារ។

**គ-ធនធានសេដ្ឋកិច្ចនិងសង្គម**

- ការសិក្សាអំពីហេតុប៉ះពាល់ទៅលើជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋានរួមមាន ចំណុចស្ទឹងថ្មី ដូននាគ តាំងយ៉ និងទូលគ្រួស ស្ថិតក្នុងឧបសម្ព័ន្ធភូមិស្ទឹងថ្មី ឃុំប្រហោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ដែលស្ថិតក្នុងតំបន់គម្រោង។ ការសិក្សានេះមាន ដូចជា ការប្រកបមុខរបរលក់ដូរ ការនេសាទជាលក្ខណៈគ្រួសារ ប្រកបមុខរបរធ្វើស្រែ ចំការជាដើម។
- ការសិក្សាការប៉ះពាល់ទៅលើអចលនៈវត្ថុ (ផ្ទះ ដីភូមិ ដីកសិកម្ម ដីបុស្ស និងដំណាំឈើហូបផ្លែ) របស់ប្រជាពលរដ្ឋក្នុងតំបន់គម្រោង(ក្នុងចំណុចទាំង៤ខាងលើ)។
- ការសិក្សាការប៉ះពាល់ទៅលើអចលនៈវត្ថុសាធារណៈ ដូចជា ផ្លូវថ្នល់ ផ្លូវចេញចូលតំបន់ជាដើម។
- ការសិក្សាអំពីហេតុប៉ះពាល់ដល់ការប្រើប្រាស់ទឹករបស់សហគមន៍មូលដ្ឋាន
- ការសិក្សាអំពីហេតុប៉ះពាល់ដល់សុខភាព និងសុវត្ថិភាពរបស់បុគ្គលិក-កម្មករនៅពេលបំពេញការងារ
- ការសិក្សាអំពីហេតុប៉ះពាល់ដល់សុខភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ដែលរស់នៅ និងចេញចូលក្នុងតំបន់គម្រោងរកអនុផលព្រៃឈើ និងនេសាទ។
- សិក្សា និងបញ្ហាចរាចរណ៍ពីការដឹកជញ្ជូនសម្ភារសំណង់
- ការសិក្សាអំពីហេតុប៉ះពាល់ដល់ប្រពៃណី និងវប្បធម៌របស់ប្រជាពលរដ្ឋមូលដ្ឋាន ជាពិសេសជនជាតិដើមភាគតិច
- ការសិក្សាអំពីហេតុប៉ះពាល់ដល់សម្បត្តិវប្បធម៌ សំណង់ប្រវត្តិសាស្ត្រ និងតំបន់ទេសចរណ៍។
- ការសិក្សាអំពីហានិភ័យ ដែលអាចកើតមានឡើងដោយថាហេតុទៅលើគម្រោង ឬដោយសារគម្រោង។

Draft

**តារាង ៧-១**: Checklist **សម្រាប់គម្រោងវារីអគ្គិសនី**

| ក ទីតាំងគម្រោង: (អានទី១ ២ និងហេដ្ឋារចនាសម្ព័ន្ធ)<br>តើតំបន់គម្រោងនៅក្នុងឬកៀកតំបន់បរិស្ថានសំខាន់ៗដែរទេ ? | មាន | គ្មាន | កត់សម្គាល់ |
|---|---|---|---|
| • ទីតាំងបេតកវប្បធម៌ | | ✓ | |
| • តំបន់ការពារ អភិរក្ស | ✓ | | ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍(ប្រហោយ)និងព្រៃការពារក្រវាញកណ្ដាល និងដែនជម្រកសត្វព្រៃភ្នំសំកុស។ |
| • តំបន់ដីសើម តំបន់ព្រៃលិចទឹក | ✓ | | តំបន់ព្រៃលិចទឹកតាមដងស្ទឹងពោធិ៍សាត់ ។ |

| | | | |
|---|---|---|---|
| • ព្រៃកោងកាង | | ✓ | គ្មានព្រៃកោងកាងនៅខាងក្រោមគម្រោងទេ។ |
| • មាត់ពាម (តំបន់ទឹកភ្លាវ) | | ✓ | គ្មានតំបន់ទឹកភ្លាវ និងមាត់ពាមនៅខាងក្រោមគម្រោងទេ |
| • តំបន់ទ្រនាប់នៃតំបន់ការពារ/អភិរក្ស | ✓ | | ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍(ប្រមោយ) និងព្រៃការពារក្រវាញកណ្តាល និងដែនជម្រកសត្វព្រៃភ្នំសំកុស។ |
| • តំបន់ពិសេសសម្រាប់ការពារ/អភិរក្សជីវចំរុះ | ✓ | | ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍(ប្រមោយ) និងព្រៃការពារក្រវាញកណ្តាល និងដែនជម្រកសត្វព្រៃភ្នំសំកុស។ |
| ខ ផលប៉ះពាល់បរិស្ថានសំខាន់ៗ<br>តើគម្រោងនឹងបង្កឱ្យ...... | | | |
| • បាត់បង់សម្បត្តិអេកូឡូស៊ីដ៏មានតម្លៃដោយសារការលិច លង់តំបន់ កសិកម្ម/ព្រៃឈើ, ជម្រកសត្វព្រៃ, រំខានដល់ត្រី ពង/បង្កកំនើត និងឧបសគ្គដល់ផ្លូវបំលាស់ទីរបស់ត្រីដែរទេ? | ✓ | | លិចលង់តំបន់ព្រៃឈើ និងជម្រកសត្វព្រៃក្នុងអាងទឹកផ្នែក ខាងលើទំនប់ (តំបន់អាង)។ |
| • បាត់បង់វត្ថុបុរាណ , រូបសំណាកប្រវត្តិសាស្ត្រ រូបសំណាក វប្បធម៌ ដែរទេ? | | ✓ | តំបន់គម្រោងមិនមាន វត្ថុបុរាណ ប្រាសាទបុរាណ , រូបសំណាកប្រវត្តិសាស្ត្រ ឬរូបសំណាក វប្បធម៌ ទេ។ |
| • មានការផ្លាស់ទី ឬការតាំងលំនៅឡើងវិញរបស់ប្រជាជនដោយ មិនស្ម័គចិត្ត ដែរទេ? | ✓ | | ក្នុងតំបន់អាងមានដីរបស់ប្រជាពលរដ្ឋចំនួន ២៣២៩.២៥ ហ ត ជារបស់៣៤៧គ្រួសារ ។ |
| • ការរំខាន/ឧបសគ្គដល់ក្រុមកុលសម្ព័ន្ធ/ប្រជាជនអន្តោប្រាម ដែរ ទេ? | | ✓ | |
| • ការថយចុះបរិស្ថានចេញពីកំនើនការកាន់កាប់ដីព្រៃឈើ ដែរទេ? | ✓ | | នឹងមានការកើនឡើងនៃអ្នកចំណូលថ្មី ធ្វើចំការ ជំណាំ រកអនុផលព្រៃឈើ ការតាំងលំនៅដ្ឋាន។ល។ នៅទីនោះពីព្រោះមានផ្លូវ។ អាចបាត់ព្រៃឈើក្បែតំបន់គម្រោងដោយសារជនឆ្លៀតឱកាសដើម្បីកេងចំណេញដោយសារខ្លួនបានអាជ្ញា បណ្ណ័នាំឈើចេញពីតំបន់ព្រៃនេះ។ |
| • ទំនាស់លើសិទ្ធិផ្គត់ផ្គង់ទឹក និងទំនាស់នានាទាក់ទិននឹងសង្គមដែរ ទេ? | ✓ | | អាចមានទំនាស់ក្នុងការប្រើប្រាស់ទឹកព្រោះនៅតំបន់ខាងក្រោមទំនប់ ដែលមានសំណង់ធារាសាស្ត្រ២កន្លែង។ |
| • មានការថយចុះទិន្នផលត្រី និងការបន្តពូជរបស់ត្រី ដែរ ឬទេ? ក្រោយពីមានការសាងសង់វារីអគ្គិសនីនោះ។ | ✓ | | អាចមានផលប៉ះពាល់ដល់ចរាចរត្រី ក្នុងការបន្តពូជរបស់ ប្រភេទត្រីមួយចំនួន ដែលរស់នៅតំបន់ស្ទឹងពោធិ៍សាត់ ដូចជា ត្រីខ្មៅ ត្រីខ្លា និងប្រភេទ កម្រផ្សេងទៀត ជាពិសេសសត្វកន្ធាយ។ |
| • ដំណើររីកសាយនៃរាវីជាតិឥតប្រយោជន៍ក្នុងអាងនិងនៅ ខ្សែទឹក ខាងក្រោមធ្វើឱ្យថយចុះដែរឬទេ? | ✓ | | អាចនឹងមានរាវីជាតិឥតប្រយោជន៍ (ពើក, ចក ជាដើម) ក្នុងអាងស្តុកទឹកនៅប៉ុន្មានឆ្នាំបន្តបន្ទាប់ទៀត។ |
| • មានជំរាបទឹកចេញពីកន្លែងផ្សេង ៗទៀតដែរឬទេ?ក្រោយពីមានការ សាងសង់វារីអគ្គិសនីនោះ។ | ✓ | | អាចមានជំរាបតាមជ្រលងភ្នំ ឬអាចមាននៅតាមកន្លែងខ្លះ នៃស្រទាប់ដីរបស់អាងស្តុក ។ |
| • ការស៊ីច្រោះដីបាតស្ទឹង នៅខាងក្រោមទំនប់ដែរទេ ? | ✓ | | អាចនឹងមានការហូរច្រោះ ព្រោះតំបន់ស្ទឹងពោធិ៍សាត់ មានល្បាយ ដីខ្សាច់ ជាមួយថ្ម ។ |
| • កំណើនឧប្បត្តិហេតុនៃជម្ងឺកើតពីទឹក ឬជំងឺទាក់ទងនឹងទឹកដែរទេ ? | ✓ | | ដោយសារការលូយនៃរុក្ខជាតិក្នុងអាងទឹកបង្កើនជម្រក សត្វមូសនឹងអាចកើតមានសត្វល្អិតចង្រៃមួយចំនួនទៀតដែលពីមុនគ្មាន ។ |
| • ការបាត់បង់អុកស៊ីសែនក្នុងទឹក ដោយសារការពុករលួយ យ៉ាង ច្រើននៃរុក្ខជាតិ ធ្វើឱ្យត្រីងាប់ ការរីកដាល Algae បង្កឱ្យមាន រុក្ខជាតិទឹក (Hydrophyte) ដែរទេ ? | ✓ | | អាចនឹងកើតមានបាតុភូតនេះក្នុងអាងស្តុកទឹក (ពើក, ចកជា ដើម) នៅប៉ុន្មានឆ្នាំបន្តទៀតហើយវាក៏អាចកើតមានរឿង រហូតនៅតាមតំបន់នៃអាង។ |
| • មានការថយចុះគុណភាពទឹកក្នុងអាង ដែរទេ ? | ✓ | | ជាទូទៅអាចនឹងមានក្នុងអាងស្តុកទឹកនៅប៉ុន្មានឆ្នាំដំបូង។ |
| • មានការផ្លាស់ប្តូរធនធនធាផលផលដែរឬទេ ? បើសិនមានការប្រែប្រួលចរន្តទឹកនៅផ្នែកខាងក្រោមអាងនៅពេល មានការកើន ឡើង នៃកម្រិតកម្ពស់ទឹកនៅផ្នែកខាងលើអាង ព្រមទាំងមាន ការថយចុះ គុណភាពទឹកនោះ។ | ✓ | | នឹងធ្វើឱ្យ ទិន្នផលត្រីថយចុះនៅដំណាក់កាលសាងសង់គម្រោង ហើយវាអាចនឹងកើនឡើងវិញនៅក្នុងដំណាក់កាល ប្រតិបត្តិ ថែទាំគម្រោង។ |
| • បាត់បង់ប្រភេទត្រីបំលាស់ទីដោយសារការរាំងបង្ខាត់ នៃទំនប់ នេះដែរទេ ? | ✓ | | យោងតាមប្លង់គម្រោងពុំឃើញមានកន្លែងឱ្យត្រីឆ្លងកាត់ពី ខ្សែទឹកក្រោមទៅខ្សែទឹកខាងលើឡើយ ដែលជាហេតុធ្វើឱ្យ មានការផ្លាស់ប្តូរចរាចររបស់ត្រី ដោយសារ ការសាងសង់ ទំនប់វារីអគ្គិសនីនេះ។ |

Draft

| | | | |
|---|---|---|---|
| • ការរងកករដីនៅក្នុងអាង និងការបាត់បង់សមត្ថភាពស្តុកទឹកដែរទេ ? | ✓ | | នៅក្នុងគំនូរបច្ចេកទេសមិនឃើញមាន សំណង់សម្រាប់ធ្វើ ការលាងកករដីចេញពីអាងទេ។ |
| • ការផ្លាស់ប្តូរសីតុណ្ហភាពទឹក នៅពេលកើតមានចរន្តទឹកវិលវល់ កករ ក្នុងអាង ដែរឬទេ? | ✓ | | ធ្វើឱ្យគុណភាពទឹកមានលក្ខណៈខុសគ្នាទៅតាមស្រទាប់ទឹក។ កន្លែងខ្លះអាចមានល្បប់ក្នុងចរន្តទឹកភាពរលាយអុកស៊ី សែនទាប និងកម្រិតជាតិដែក និងម៉ង់កាណែសខ្ពស់។ |
| • បន្ថយទំនាបលិចទឹកសម្រាប់កសិកម្ម ដែរឬទេ ? | ✓ | | ក្នុងតំបន់អាងមានដីរបស់ប្រជាពលរដ្ឋចំនួន ២៣២៩.២៥ ហ.ត ជារបស់៣៤៧គ្រួសារ ។ |
| • ការតាំងលំនៅឋានថ្មីរបស់ប្រជាពលរដ្ឋ ដែលរងការប៉ះពាល់ដោយ សារគម្រោងធ្វើឱ្យបាត់បង់ធនធានធម្មជាតិដែរទេ ? | ✓ | | នៅកន្លែង ដែលតាំងលំនៅឋានថ្មី ត្រូវការផ្ទៃដី ១៩០.៤៥ហ.ត ដែលមានព្រៃឈើ ៣៨,៥ ហ.ត។ |

# ៧.៤ ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន និង វិធានការកាត់បន្ថយ

## ៧.៤.១ ដំណាក់កាលរចនាគម្រោងមុនប្រតិបត្តិគម្រោង

ក្នុងដំណាក់កាលនេះគម្រោងពុំមានសកម្មភាព ដែលបង្កឱ្យមានផលប៉ះពាល់ធំដុំឡើយ។ ដំណាក់កាលរចនាគម្រោងគឺ មានអ្នកជំនាញការតាមផ្នែកបច្ចេកទេស ធ្វើការសិក្សាស្រាវជ្រាវទៅតាមជំនាញបច្ចេកទេសរៀងៗខ្លួន ដើម្បីរចនាប្លង់គម្រោងតាមសមាស ភាពនីមួយៗ។ ប៉ុន្តែក្តារគ្រោងរចនាគម្រោងនេះសំខាន់ណាស់ក្នុងការគ្រោងសំណង់ និងចាត់ចែងធារទឹកសម្រាប់រក្សាលំនឹងបរិស្ថាន និងរៀបចំផែនការការពារបរិស្ថាន រួមទាំងផែនការផ្លាស់ប្តូរលំដ្ឋានថ្មីរបស់ប្រជាពលរដ្ឋដែលប៉ះពាល់ផងដែរ នៅដំណាក់កាលសាងសង់គម្រោង និងដំណាក់កាលប្រតិបត្តិគម្រោង ការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ ដល់ធនធានបរិស្ថាន និងសង្គម ដោយសារ ការរចនាហេដ្ឋារចនាសម្ព័ន្ធគម្រោងរួមមានដូចតទៅៈ

**ក. ធនធានរូបសាស្ត្រ**

**ក.១ សណ្ឋានដី និងឋានលេខា**

➢ ហេតុប៉ះពាល់អវិជ្ជមាន

សណ្ឋានដី និងឋានលេខា គឺជាសណ្ឋាន ទ្រង់ទ្រាយ នៃផែនដី។ ការគ្រោងគម្រោងមិនបានត្រឹមត្រូវអាចមានការប៉ះពាល់ដល់សណ្ឋាន ទ្រង់ទ្រាយដីក្នុងតំបន់សាងសង់ ដូចជាការកាយជញ្ជាំងភ្នំដើម្បីពង្រាបធ្វើផ្លូវចេញចូល ការជីករណ្តៅដីរណ្តៅកន្លែងយកថ្ម ការចាក់គរដីស្អុយ និងថ្ម ដែលជញ្ជាំងនៃកន្លែងទាំងនេះ មិនមានជម្រាលជើងទេរច្បាស់លាស់ទៅតាមបទដ្ឋានដី និងថ្ម នាំឱ្យបាក់ដី បាក់ថ្មខូចសណ្ឋាន ទ្រង់ទ្រាយដីក្នុងតំបន់ដែលនឹងត្រូវសាងសង់។ ឧទាហរណ៍ ការជីករណ្តៅដីល្បាយខ្សាច់ ត្រូវមានជើងទេរនៃជញ្ជាំង ១/២ ចំពោះដីឥដ្ឋ ១/១,៥ ជាដើម។ បើមិនអញ្ចឹងទេ នាំឱ្យមានការបាក់ដី រាលទៅតំបន់ជុំវិញ។ ម្យ៉ាងទៀត ការចាក់គរសំណង់ដីនិងថ្មខ្ពស់ជាង ៣ ម វាលធ្វើឱ្យមានការបាក់រាលគំនរដីឬថ្មនោះទៅតំបន់ជុំវិញលប់ពីលើដីមានជីជាតិ លុបគល់ឈើបណ្តាលឱ្យងាប់ឈើនោះផងដែរ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវគ្រោងរចនាប្លង់គម្រោងលម្អិតឱ្យមានជើងទេរ និងជម្រាលជញ្ជាំងកន្លែងកាយដី ជញ្ជាំងរណ្តៅដីរណ្តៅកន្លែងយកថ្ម កន្លែងចាក់ដីស្អុយនិងថ្ម ត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសរបស់ប្រភេទដីនិងថ្ម ដែលមាននៅតំបន់គម្រោងដោយខ្ទង់សិក្សាដី និងថ្មឱ្យបានច្បាស់លាស់ ដូចជា ដីល្បាយខ្សាច់ ត្រូវមានជើងទេរនៃជញ្ជាំង 1:2 ចំពោះដីឥដ្ឋ 1:1.5 ថ្មផុយពី 1:1 ទៅ 1:1.5 ថ្ម 1: 0.5 ទៅ 1:1 ជាដើម ដើម្បីកុំឱ្យមានការបាត់ដី ឬបាក់ថ្ម លប់លើដីចាស់ដែលមានជុំវិញតំបន់នេះ។

**ក.២ ប្រព័ន្ធជលសាស្ត្រ (អូរ ស្ទឹង)**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ការគ្រោងគម្រោងមិនបានត្រឹមត្រូវហានការប៉ះពាល់ដល់ប្រព័ន្ធជលសាស្ត្រ និងជីវៈចំរុះក្នុងស្ទឹងពោធិ៍សាត់នៅផ្នែកខាងក្រោម កន្លែងសាងសង់ទំនប់នេះដោយខ្វះទឹក និងមិនបានគិតគូរអំពីការធ្វើសំណង់បន្ថែម ដើម្បីបញ្ចេញទឹកមកខាងក្រោមតំបន់ទំនប់មេ នៅពេលប្រតិបត្តិ និងថែទាំគម្រោង។

ប៉ះពាល់ដល់ចរាចរត្រី ព្រៃលិចទឹកតាមមាត់ស្ទឹង និងសត្វទឹក ដោយសារការគ្រោងទំនប់កាត់ស្ទឹងនេះ ដោយមិនមានការបង្ហូរទឹកមកតំបន់ខាងក្រោមទំនប់ គ្រប់គ្រាន់សម្រាប់ការពារប្រព័ន្ធជីវៈចំរុះរបស់កំណាត់ស្ទឹងនេះ ហើយនិងអាចធ្វើឱ្យបង្អាក់ដំណើរត្រីនៅខាងក្រោមឡើងទៅតំបន់ខាងលើ ដើម្បីពងកូនទៀតផង។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវគ្រោងរចនាប្លង់គម្រោងឱ្យមានសំណង់ និងទ្វារទឹកដែលអាចបញ្ចេញទឹកមកខាងក្រោម នៃទំនប់ទំនប់នេះ ដើម្បីរក្សាលំនឹងធនធានបរិស្ថានស្ទឹងពោធិ៍សាត់ មានដូចតទៅៈ

1. <u>តំបន់១</u>: នៅខាងក្រោមតំបន់ទំនប់ ដល់អាគារថាមពល តាមដងស្ទឹងមានចម្ងាយប្រមាណ៩,២គ.ម។ នៅតំបន់នេះ ក្រុមហ៊ុន នឹងធ្វើការបញ្ចេញទឹកពីអាងចំនួន១,៣ម$^{៣}$/វិន.ឥតដាច់ទាំងប្រាំង និងវស្សា។ ប៉ុន្តែនៅ២ឆ្នាំដំបូងក្នុងរយៈពេលប្រតិបត្តិ និងថែទាំគម្រោង ក្រុមហ៊ុនត្រូវធ្វើការបិទទ្វារទឹក ដើម្បីបំពេញអាងក្នុងនោះនៅឆ្នាំទី១ ត្រូវការរយៈពេលពី៥ទៅ៨ខែ ក្នុងការ បំពេញទឹកក្នុងអាងឱ្យដល់នីវ៉ូ EL: ១៨០ម ដើម្បីដំណើរការទួរ២ប៊ីន (៨០ MW)។ នោះមានន័យថា ៥ខែដំបូងនៃឆ្នាំទី១នេះ មិនមានទឹកគ្រប់គ្រាន់សម្រាប់រក្សាជីវៈចំរុះនារដូវវស្សានោះទេពោល គឺមានតែ ១,៣ម$^{៣}$/វិន. និងលំហូរធម្មជាតិពីទឹក ភ្លៀងក្នុងតំបន់តែប៉ុណ្ណោះ។ យោងតាមលំហូរធារទឹកនៃរយៈពេលកត់ត្រា ៣០ឆ្នាំ (មើលតារាង ៥-១១) បញ្ជាក់ថា នៅរដូវវស្សាចាប់ពី ខែឧសភា ដល់ខែតុលា ស្ទឹងពោធិ៍សាត់មាន លំហូរអប្បបរមា ០,៦ម$^{៣}$/វិន. ហើយអតិបរមា ៣៨៩.២ ម$^{៣}$/វិន.។ ដូចនេះក្នុងរយៈពេល ៥ខែ ដំបូងនៃឆ្នាំទី១ ក្រុមហ៊ុនធ្វើការបញ្ចេញទឹកមកខាងក្រោមទំនប់យ៉ាងហោចណាស់ឱ្យបាន ១,៣ម$^{៣}$/វិន.ដែរ។ បើធ្វើដូចនេះមានន័យថាៈ នៅរដូវវស្សា តំបន់នេះមានលំហូរ លើស <u>១,៣ ម$^{៣}$/វិន.</u> ហើយរដូវប្រាំង ពី<u>១,៣ម</u>$^{៣}$/វិន នៅរយៈពេល២ឆ្នាំ ដំបូង។ ចាប់ពីឆ្នាំទី៣ ទៅនឹងមានទឹកបន្ថែមនារដូវវស្សាដោយសារ ការហៀរទឹក ចេញតាមទំនប់បង្ហៀរ។
2. <u>តំបន់២</u>: គឺតំបន់ក្រោមអាគារថាមពល (PH) តាមដងស្ទឹងពោធិ៍សាត់មានទំនប់សំណង់ធារាសាស្ត្រដំណាក់ឈើក្រំ (កំពង់សាងសង់ ចម្ងាយ ៦២គ.ម) ដំណាក់អំពិល ចម្ងាយ ប្រមាណ១០៣ គ.ម ដែលទទួលយកទឹក ពីគម្រោងនេះ។ នៅដំណាក់កាលប្រតិបត្តិថែទាំគម្រោង និងមានការខ្វះទឹក នៅពេល ដែលក្រុមហ៊ុនធ្វើការបិទទំនប់ដើម្បីតម្កល់ទឹកនៅឆ្នាំទី១ ដូចនេះក្រុមហ៊ុនត្រូវព្រលែងទឹកនៅរដូវវស្សាយ៉ាងហោច៤០ម$^{៣}$/វិន. និងរដូវប្រាំង <u>១,៣ម$^{៣}$/វិន.</u> តាមបំពង់បង្ហូរទឹកបរិស្ថាន ពីព្រោះប្រព័ន្ធធារាសាស្ត្រនៅដំណាក់ឈើក្រំ និងដំណាក់អំពិលនេះត្រូវការទឹកស្រោចស្រពនៅរដូវវស្សា និងប្រាំង (មើលតារាង៥-១១ លំហូរធាទឹកជាមធ្យមគឺ៤២.៤ ម$^{៣}$/វិន.)។ ដូចនេះ ចំពោះការខ្វះទឹកសម្រាប់ រក្សាជីវៈចំរុះ និងតំរូវការទឹកសម្រាប់ស្រោចស្រពនោះ គឺត្រូវបានកាត់បន្ថយអាចទទួលយកបាន បើក្រុមហ៊ុនអនុវត្តតាម ការគ្រប់គ្រងទឹកខាងលើ។ នៅពេលដែលនីវ៉ូទឹកក្នុងអាងឡើងដល់កម្រិតអាចដំណើរការទួរប៊ីននោះក្រុមហ៊ុន នឹងដំណើរការទួរប៊ីន១ ដែលមានធារទឹក ៤០ម$^{៣}$/វិន. និងរហូតដល់ដំណើរការទាំង២ទួប៊ីន ដែលត្រូវបញ្ចេញធារទឹកសរុប៨០ម$^{៣}$/វិន.។ នៅរដូវវស្សាតំបន់នេះ យ៉ាងហោចណាស់ ត្រូវព្រលែងទឹក៤០ម$^{៣}$/វិន. បើមិនដូច្នេះទេនោះ នឹងធ្វើឱ្យមានខ្វះខាតក្នុងការផ្គត់ផ្គង់ទឹក មកតំបន់ធារាសាស្ត្រដំណាក់ឈើក្រំ និងដំណាក់អំពិលជាមិនខាន។ ចំណែកឯ នៅរដូវប្រាំង ការផលិតអគ្គិសនី ដែលដំណើរការបើកទួរប៊ីន២ មានធារទឹកសរុប ប្រមាណ ៨០ម$^{៣}$/វិន. នោះ អាចផ្ដល់ទឹកគ្រាន់ ដល់ប្រព័ន្ធធារាសាស្ត្រទាំងនេះ នៅរដូវប្រាំងមិនខ្វះទឹកដូចដំណាក់កាលមុនសាងសង់គម្រោងទៀតឡើយ។ ***សម្គាល់:*** *នៅដំណាក់កាលប្រតិបត្តិថែទាំ គម្រោង នៅរដូវប្រាំង យោងតាម EDC ចង់បានអគ្គិសនី ២៤ម៉ោង លើ ៦ ខែ នៅរដូវបាំង នោះនឹងមានធារទឹក ៨០ម$^{៣}$ វិន. បើប្រៀបធៀប ធារទឹកស្ទឹងពោធិ៍សាត់នៅទីតាំងទំនប់មេ មានប្រហាក់ប្រហែល ធារទឹកក្នុងខែ ឧសភា មិថុនា និងកក្កដា មើលតារាង៥-១១។*

ក.៣ ការហូរច្រោះដី

➢ ហេតុប៉ះពាល់អវិជ្ជមាន

Draft

ដូចគ្នានិងសណ្ឋានដី ដែលនៅក្នុងដំណាក់កាលនេះការហូរច្រោះដីពុំមានទេ ដោយសារក្រុមហ៊ុនពុំបានឈូសឆាយ និងពង្រាបដីដើម្បីសិក្សាឡើយ។ ទោះជាយ៉ាងនេះក៏ដោយ បើគម្រោងមិនរៀបចំប្លង់នៃការជីកដី ធ្វើជើងទេមិនត្រឹមត្រូវនោះ ពេលសាងសង់គម្រោង នាំឱ្យមានការ បាក់ជញ្ជាំងដី ធ្វើឱ្យស្ទះការងារសាងសង់ និងអាចនាំគ្រោះថ្នាក់ដល់មនុស្សសត្វទៀតផង។

ម៉្យាងទៀត មានផលប៉ះពាល់ខ្លះៗដល់គុណភាពដីបណ្តាលមកពីការហៀរ ឬកំពប់ប្រេង និងការបោះសំណល់ផ្សេងៗ ដោយបុគ្គលិក/កម្មកររបស់គម្រោងក្នុងពេលសិក្សានោះ។

- វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវគ្រោងការងារដី ដូចជាការកាយយកជញ្ជាំងភ្នំធ្វើផ្លូវ ធ្វើរហដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនី ជទេទៀត ត្រូវមានជើង ទេត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស និងមានដាក់របាំងការពារបាក់ដីនៅតាមដងផ្លូវដែលមានចំណោតខ្ពស់ រួមទាំងបាញ់បាយអនៅ ជញ្ជាំងចំណោតខ្ពស់ៗទាំងនោះទៀតផង។

ក្រុមហ៊ុនត្រូវមានការស្តុកប្រេងឥន្ធនៈ ឱ្យបានត្រឹមត្រូវតាមបទដ្ឋានសុវត្ថិភាពដល់បរិស្ថាន ដោយប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និង រថយន្តដឹកជញ្ជូនដែលមានគុណភាពល្អមិនលេចហូរប្រេងមកលើដីក្នុងតំបន់គម្រោងឡើយ។

ជាងនេះទៅទៀតក្រុមហ៊ុនមានការគ្រប់គ្រងសំណល់ប្រេងឱ្យបានត្រឹមត្រូវ។ រីឯសំណល់រឹង ចេញពីកន្លែងស្នាក់នៅរបស់កម្មករ/បុគ្គលិកវិញក្រុមហ៊ុនរៀបចំធុងសម្រាមនិងរៀបចំកន្លែងទុកដាក់សម្រាមនៅទីតាំងដែលមានសុវត្ថិភាពល្អ។

### ក.៤ ការរញ្ជួយដី

ក្នុងដំណាក់កាលនេះមិនមានប្រើគ្រឿនផ្ទុះ ដឹកសម្ភារធ្ងន់ៗ ដែលនាំឱ្យមានការរញ្ជួយទេ។ ប៉ុន្តែត្រូវគ្រោងគ្រឿងផ្ទុះដែលមាន សំឡេង ការរញ្ជួយតិច និងមានកន្លែងទុកដាក់ ដោយមានដាក់បារ៉ីពន្ធ័ជុំវិញ ការពារពេលមានគ្រោះថ្នាក់ចៃដន្យណាមួយកើតឡើងនោះ។ ជាងនេះទៅទៀត គម្រោងត្រូវគ្រោងរកអ្នកយាម(សន្តិសុខ) ឱ្យបានហ្មត់ចត់ ជៀសវាងការលួច ឬបាត់បង់គ្រឿនផ្ទុះ ដែលនាំឱ្យកើតមានការប្រើប្រាស់ ជាតិផ្ទុះខុសច្បាប់ នឹងអាចបង្កឱ្យមានអសន្តិសុខសង្គម និងមានការបាត់បង់អាយុជីវិតមនុស្ស និងសត្វផងដែរ។

### ក.៥ គុណទឹក (ទឹកលើដី និងក្រោមដី)

- ហេតុប៉ះពាល់អវិជ្ជមាន

នៅខណៈពេលនៃការសិក្សានេះដែរ ប្រភពទឹកនៃស្ទឹងពោធិ៍សាត់ និងទឹកក្រោមដីក្នុងតំបន់សិក្សាមានផលប៉ះពាល់តិចតួច ដោយសារការបង្ហូរសំណល់រាវចេញពីផ្ទះបាយ និងការបន្ទោរបង់របស់បុគ្គលិក-កម្មករគម្រោងចូលក្នុងទឹក។ តែពេលសាងសង់គម្រោងដែលមានបុគ្គលិក-កម្មកររហូតដល់៤០០នាក់ ដែលអាចបំពុលគុណភាពទឹកដោយសារសំណល់រឹង-រាវ ការបោកគក់ ការចុះងូត ឬបង្ហូរទឹកចូលស្ទឹងដោយផ្ទាល់។

- វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវគ្រោងសាងសង់បង្គន់អនាម័យ ដោយជីករណ្តៅដាក់លូ ដើម្បីស្តុកលាមកមានជម្រៅពី ២,៥ម ទៅ ៣,៥ម ដើម្បីសំលាប់មេរោគ។ ចំពោះសំណល់ផ្ទះបាយវិញ គឺមិនបង្ហូរ ឬចាក់ចូលទៅក្នុងស្ទឹងពោធិ៍សាត់ទេគឺជីករណ្តៅជម្រៅ១-២ម ទំហំ ៤-៦ម ដើម្បី ធ្វើឱ្យសំណល់នោះ ក្លាយជាជីកំប៉ុស៍បានថែមទាំងមានធុងទុកសម្រាប់ដាក់សម្រាម និងកន្លែងដុតសម្រាមចោលដោយសុវត្ថិភាព។

ក្រុមហ៊ុនត្រូវធ្វើការណែនាំបុគ្គលិក/កម្មករគម្រោងឱ្យយល់ដឹងអំពីអនាម័យស្គាល់នូវកន្លែងទុកដាក់សម្រាម ដែលក្រុមហ៊ុនបានរៀបចំកសាងក្នុងទីតាំងស្នាក់នៅរបស់គម្រោង។

### ក. ៦ គុណខ្យល់

- ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលមុនប្រតិបត្តិថែទាំគម្រោងនេះ មានការបំពុលតិចតួច ដោយសារមានផ្សែង ដែលចេញពីគ្រឿងយន្តដែលយក មកសិក្សាគម្រោង ដូចជា ម៉ាស៊ីនខួងដីសម្រាប់សិក្សារំពីគ្រឹះទំនប់ រថយន្ត ម៉ូតូ ជាដើម សម្រាប់ដឹកជញ្ជូនជាដើម។



Draft

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនប្រើម៉ាស៊ីន និងគ្រឿងយន្ត ដែលមានគុណភាពល្អ និងមានបំពង់ស៊ីម៉ុងសម្រុកជិតល្អ ដើម្បីកាត់បន្ថយការបញ្ចេញផ្សែង។

ក្រុមហ៊ុនប្រើប្រេងឥន្ធនៈ ដែលមានគុណភាពល្អ ដែលមានចំហេះសប់ឥតនាំឱ្យមានផ្សែងតិច។

**ក. ៧ គុណភាពដី**

➢ ហេតុប៉ះពាល់អវិជ្ជមាន

មានការបំពុលដីតិចតួចបណ្តាលមកពីការហៀរ ឬកំពប់ប្រេង និងការបោះសំណល់ផ្សេងៗដោយបុគ្គលិក/កម្មកររបស់ គម្រោងក្នុងពេលសិក្សានោះ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវមានការស្តុកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវតាមបទដ្ឋានសុវត្ថិភាព ដល់បរិស្ថានដោយប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និង រថយន្តដឹកជញ្ជូន ដែលមានគុណភាពល្អមិនលេចហូរប្រេងមកលើដីក្នុងតំបន់គម្រោងឡើយ។

ជាងនេះទៅទៀត ក្រុមហ៊ុនត្រូវមានការគ្រប់គ្រងសំណល់ប្រេងឱ្យបានត្រឹមត្រូវ។ រីឯសំណល់រឹងចេញពីកន្លែងស្នាក់នៅរបស់កម្មករ/បុគ្គលិករីញក្រុមហ៊ុន ត្រូវរៀបចំធុងសម្រាម និងរៀបចំកន្លែងទុកដាក់សម្រាមនៅទីតាំងដែលមានសុវត្ថិភាពល្អ។

**ក. ៨ សំឡេង និងរំញ័រ**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលគ្រោងរចនាគម្រោងនេះ មានការប៉ះពាល់តិចតួច ដោយសារមានការខួងដីសម្រាប់សិក្សាអំពីគ្រឹះទំនប់ ហើយសកម្មភាពនៃការខួងដីនេះ ត្រូវការកម្មករជាច្រើននាក់បង្កឱ្យមានសំឡេងអ៊ូរអរ និងសន្ទឹកសំឡេងម៉ាស៊ីនបង្កឱ្យមានការរំខាន ដល់ សត្វព្រៃ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនប្រើម៉ាស៊ីនខួងដី ដែលមានកម្រិតរញ្ជួយ និងសំឡេងតិច ដើម្បីកាត់បន្ថយសំឡេង និងរំញ័រ ដែលរំខានដល់សត្វព្រៃ។

ក្រុមហ៊ុនមិនធ្វើការពេលយប់ទេ ដើម្បីកាត់បន្ថយការរំខានដល់សត្វព្រៃ។

ក្រុមហ៊ុនអប់រំកម្មកររបស់គម្រោងមិនឱ្យមានការស្រែក ឬជជែកគ្នាខ្លាំងៗ រំខានដល់សត្វព្រៃ។

**ខ. ធនធានជីវសាស្ត្រ**

**ខ.១ ជីវសាស្ត្រដែលរស់នៅក្នុងទឹក /មច្ឆជាតិ**

➢ ហេតុប៉ះពាល់អវិជ្ជមាន

យោងតាមគម្រោងប្លង់សម្រាប់ការសាងសង់ទំនប់វារីអគ្គិសនីស្ទឹងពោធិ៍សាត់នេះ គឺពុំមានរចនាប្លង់គម្រោងសម្រាប់ឱ្យត្រី ឆ្លងកាត់ នោះទេ ដែលជាហេតុធ្វើឱ្យមានបញ្ហាប៉ះពាល់ដល់ចរាចរត្រី និងសត្វរស់នៅក្នុងទឹក នៅពេលដែលគម្រោងទាំងមូលនឹងសាងសង់ និងដំណើរការ។ ជាងនេះទៅទៀត តាមអន្លង់មួយចំនួនដូចជាអន្លង់ជ្រៅ អន្លង់បឹងជាដើមមានក្រពើភ្នំរស់នៅដូចនេះពេលសាងសង់ និងតម្កល់ទឹកក្នុងអាង មានផលប៉ះពាល់ដល់ក្រពើទាំងនេះ។

ប៉ះពាល់ ដល់ពពួកមច្ឆជាតិ ដោយសារ ការចាក់សំណល់ដី ថ្ម ចូលក្នុងស្ទឹង ធ្វើលប់អន្លង់ដែលជាជម្រករបស់ពពួកវា និងបំពុលគុណភាពទឹក ដោយសារដី ថ្មទាំងនេះផងដែរ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនមានវិធានការ ដើម្បីជំនួសសំណង់សិល្បការសម្រាប់ឱ្យត្រីឆ្លងកាត់នេះ ដោយមានគម្រោងព្រលែងកូនត្រី (រើសពូជក្នុងតំបន់) និងមានមូនិធិសម្រាប់សង្គ្រោះសត្វក្រពើភ្នំ រួចធ្វើការព្រលែងត្រីទាំងនេះ ចូលក្នុងអូរស្ទឹងធម្មជាតិ ដែលមានលក្ខណៈទីជម្រកប្រហាក់ប្រហែលគ្នា ដោយធ្វើការសហការជាមួយរដ្ឋបាលជលផល។

Draft

*(សម្គាល់: ចំពោះតម្លៃនៃសំណង់សម្រាប់ត្រីឆ្លងកាត់បានមានតម្លៃរាប់លានដុល្លារ ដែលធ្វើឱ្យតម្លៃដើមរបស់អគ្គិសនីកើនខ្ពស់ផងដែរធ្វើឱ្យប៉ះពាល់ដល់តម្លៃអគ្គិសនីរបស់អ្នកប្រើប្រាស់)។*

ម្ចាស់គម្រោង ត្រូវដាក់បញ្ចូលក្នុងកិច្ចសន្យាម៉ៅការសងសង់ (ចោះរូងទូនេល សាងសង់អាគារថាមពល។ល។) ដោយមិនឱ្យយកសំណល់ ថ្ម ដី ចាក់តាមមាត់ច្រាំងនៃស្ទឹងពោធិ៍សាត់ នាំឱ្យលប់អន្លង់នានា និងប៉ះពាល់គុណភាពទឹក ប៉ះពាល់ដល់ជីវៈរស់នៅក្នុងទឹក មច្ឆជាតិជាដើម។ ទីតាំងចាក់សំណល់ ដីនិងថ្ម មានចែងក្នុង ជំពូក ៨ចំណុច ៨.៣ និងផែនទី ៣ ត្រូវគ្រោងឱ្យឆ្ងាយពីមាត់ច្រាំងស្ទឹងយ៉ាងហោចណាស់១៥០ម ផងដែរ។

### ខ.២ ព្រៃការពារ/ តំបន់ការពារ/ ឧទ្យានជាតិ

➢ ហេតុប៉ះពាល់អវិជ្ជមាន

ការគ្រោងរចនាគម្រោងដូចជាប្លង់សម្រាប់សាងសង់ទំនប់ទឹក អាងទឹក អាគារថាមពល បំពង់ទូនេល និងហេដ្ឋារចនាសម្ព័ន្ធនានារបស់គម្រោងវារីអគ្គិសនីពោធិ៍សាត់១នេះ ស្ថិតក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍(ប្រមោយ) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ៤.១៩៩,២ ហ.ត, ស្ថិតនៅក្នុងតំបន់ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល ៣៩៩,៧ហ.ត និងដែនជម្រកសត្វព្រៃភ្នំសំកុសប្រមាណ ៤.៧៥៦,១ហ.ត ដែលជារបស់ក្រសួងបរិស្ថាន ហើយតំបន់ ដែនជម្រកសត្វព្រៃភ្នំសំកុស បានបែងចែកជា ៤តំបន់ដូចខាង ៖

| # | ប្រភេទតំបន់ | ផ្ទៃ (ហ.ត) |
|---|---|---|
| 1 | តំបន់ប្រើប្រាស់ដោយចីរភាព (តំបន់សហគមន៍ | 250.77 |
| 2 | តំបន់ការពារដោយសហគមន៍ | 106.64 |
| 3 | តំបន់អភិរក្ស | 3291.98 |
| 4 | តំបន់ស្នូល | 1171.86 |
| | ផ្ទៃដីសរុប | 4821.25 |

ចំណែកឯសកម្មភាពសិក្សាគម្រោងនៅក្នុងដំណាក់កាលមុនសាងសង់គម្រោងនេះ មានការប៉ះពាល់ដល់ព្រៃការពារនេះខ្លះៗ ដែរ ដោយសារតែសកម្មភាពសិក្សាគម្រោង ដូចជាការកាប់ព្រៃឈើធ្វើផ្លូវចូល (មិនឈូសឆាយទេ) ការខួងសិក្សា ដីថ្ម ដើម្បីគ្រឹះ សំណង់ការវាស់ធារទឹកការធ្វើឋានលេខាជាដើម។

ដោយសារសកម្មភាពសិក្សា គម្រោងនឹងបង្កឱ្យមានផលប៉ះពាល់ដល់អេកូឡូស៊ី ដូចជា: សំឡេងពីគ្រឿងចក្រ ភាពខ្ទៀវខ្ទារ នៃក្រុមបុគ្គលិក-កម្មករការទន្ទ្រានចូលក្នុងព្រៃពីក្រុមបុគ្គលិក-កម្មករក្រោយពីការងារ ដើម្បីរកអនុផលព្រៃឈើ ឬចាប់សត្វ ឬ ការជួញដូរសត្វព្រៃសម្រាប់ធ្វើម្ហូប និងកាប់ឈើលក់ឱ្យឈ្មួញជាដើម។ល។

ក្រុមហ៊ុនបានគ្រោងសំណង់ទំនប់ និងទូនេល អាគារថាមពល ផ្លូវចូល អាងទឹក ដូចជាគ្រោងការតម្កល់ទឹកនៅអាងកម្រិតនីវ៉ូធម្មតា ១៨០ម តំបន់នេះយើងដាក់ជាតំបន់១ ដើម្បីងាយស្រួលសិក្សាតំបន់អាងនេះមានផ្ទៃក្រឡាមាន៨.៥៩១ហ.ត ដែលក្នុងនោះ មានព្រៃស្រោង ៧៣៥ហ.ត ព្រៃពាក់កណ្តាលស្រោង៨៤៧,៦ហ.ត និងព្រៃល្បោះ៤.២៥៣ហ.ត ចំណែកឯតំបន់២,៣ និង៤ មានចែងក្នុងជំពូក ៥ ចំណុច ៥.១.២.១ ព្រៃឈើ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនបានគិតគូរយ៉ាងហ្មត់ចត់ អំពីករណីនៃការគ្រោងគម្រោងនេះ ដោយធ្វើការប្រៀបធៀប ៣ ករណីទៅនឹងតម្លៃសេដ្ឋកិច្ច រួមទាំងបរិស្ថាន និងគ្រោងហេដ្ឋារចនាសម្ព័ន្ធគម្រោងមួយចំនួន ដូចជាការជ្រើសយកវិធីចោះរន្ធទូនេលក្រោមដីដោយមិនប្រើការ ជីកប្រឡាយនាំទឹក ដែលធ្វើឱ្យបាត់បង់គម្របព្រៃឈើច្រើន។ ជាងនេះទៅទៀត ក្រុមហ៊ុនបានដាក់បញ្ជាឱ្យកាប់តែព្រៃក្នុងកន្លែងសាងសង់ហេដ្ឋាចេនាសម្ព័ន្ធគម្រោងជាក់ស្តែងប៉ុណ្ណោះ ទោះបីជាខ្លួនបានគ្រោងព្រំប្រទល់តំបន់នោះក៏ដោយ (មើលផែនទី ៥ ក្នុងឧបសម្ព័ន្ធ ៨)។

ក្រុមហ៊ុន បានកំណត់ពេលវេលាធ្វើការតែពេលថ្ងៃសម្រាប់ការងារទាំងឡាយណា ដែលបង្កសំឡេង និងរំញ័រ ដើម្បីកុំឱ្យមានការរំខាន ឬផ្អើលសត្វព្រៃក្នុងតំបន់គម្រោង និងតំបន់ក្បែរខាង។

ក្រុមហ៊ុនធ្វើការអប់រំដល់កម្មករគម្រោងមិនឱ្យធ្វើការទន្ទ្រានព្រៃក្នុងតំបន់គម្រោងដើម្បីចាប់ ឬបរបាញ់សត្វព្រៃ ឬជួញដូរសត្វព្រៃសម្រាប់ធ្វើម្ហូប និងកាប់ព្រៃឈើលក់ឱ្យឈ្មួញឡើយ ហើយដាក់វិន័យយ៉ាងតឹងរ៉ឹងដល់ពួកគេ ដែលប្រព្រឹត្តខុសទៅនឹងបម្រាមនេះ។

Draft

រីឯស្បៀង និងម្ហូបអាហារក្រុមហ៊ុនមិនទិញសាច់សត្វព្រៃទេឬម្ហូបអាហារណាដែលពាក់ព័ន្ធសត្វព្រៃ។ ក្រុមហ៊ុននាំស្បៀងពីទីរួមស្រុកវាលវែង ឬពីក្រុងពោធិ៍សាត់។

ជាងនេះទៅទៀត ក្រុមហ៊ុនធ្វើការអប់រំដល់បុគ្គលិក-កម្មករគម្រោងឱ្យយល់ពីច្បាប់នៃការគ្រប់គ្រង់ថែរក្សាធនធាន និង សត្វព្រៃនៅក្នុងតំបន់ការពារ (ដែនជម្រកសត្វព្រៃ និងឧទ្យានជាតិ) និងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍។

**<u>បញ្ជាក់</u>:** ព្រៃឈើនៅក្នុងតំបន់គម្រោងសរុបមាន ៦.៤៣៨,៤១ហ.ត ហើយប៉ះពាល់តែ ៦.០០៧,២៤ហ.តតែប៉ុណ្ណោះ ដែលក្នុងនោះមាន<u>ព្រៃស្រោង ៨៦៥,៤៩ហ.ត ព្រៃពាក់កណ្តាលស្រោង ៨៥០,២៥ ហ.ត និងព្រៃល្បោះ ៤.២៩១,៥ ហ.ត</u> (តំបន់អាង មានព្រៃស្រោង ៧៣៥ហ.ត ព្រៃពាក់កណ្តាលស្រោង ៨៤៧,៦ហ.ត និងព្រៃល្បោះ ៤.២៥៣ ហ.ត ត្រូវធ្វើការកាប់ចេញ និងដាក់ដេញថ្លៃឈើនៅក្នុងអាងដោយយកថវិកាចូលជាថវិការដ្ឋ។ ចំណែកឯដីព្រៃឈើនៅក្នុងតំបន់ហេដ្ឋារចនាសម្ព័ន្ធគម្រោងដទៃទៀត ដូចមានបង្ហាញក្នុងតារាង ៥-១៩, ៥-២០, ៥-២១, ៥-២២ ក្នុងជំពូក៥ មិនចាំបាច់កាប់ទាំងអស់នោះទេ ពោលគឺក្រុមហ៊ុន ត្រូវកាប់សំអាតនៅកន្លែងធ្វើផ្លូវចេញចូល ពេលសាងសង់គម្រោង និងសង់កន្លែងស្នាក់នៅកន្លែងចាក់សំណល់ដី និងថ្ម កន្លែងលាយបេតុងជាដើម តែប៉ុណ្ណោះ។

***សម្គាល់:*** *- ការចាត់ចែងកាប់សំអាតឈើរបៀបនេះអាចនឹងត្រូវបានកាត់បណ្តាយការកាប់រានដីព្រៃឈើបានប្រមាណជា៤៣១,១៧ហ.តក្នុងតំបន់គម្រោង។*

*- ដង់ស៊ីតេមាឌជាមធ្យមដែលសិក្សាដោយក្រុមការងារ SAWAC មានព្រៃស្រោង (ɸ≥300mm) ២២,៦៣ ម$^{3}$ ហ.ត ព្រៃពាក់កណ្តាល ស្រោង (ɸ≥300mm) ៣៣,៨១ ម$^{3}$ ហ.ត និងព្រៃល្បោះ(ɸ≥300mm) ៤៧,៣៦ ម$^{3}$ ហ.ត ហើយដង់ស៊ីតេមាឌឈើជាមធ្យម សម្រាប់ មុខឈើ ɸ≥100mm គឺ៥១,៥៦ ម$^{3}$ ហ.ត ហើយɸ≥300mm គឺ៦៨ម$^{3}$ ហ.ត លម្អិតមើលជំពូក ៥ ចំណុច ៥.១.២.១ ព្រៃឈើ និងចំណុច២-សន្និដ្ឋាន។*

## ខ.៣ ធនធានព្រៃឈើ និងជម្រកសត្វព្រៃ

➢ ហេតុប៉ះពាល់អវិជ្ជមាន

នៅក្នុងដំណាក់គ្រោងរចនានេះ អាចប៉ះពាល់ដល់ធនធានព្រៃឈើខ្លះដែរ ដោយសារការកាប់កូនឈើធ្វើស្ពាន និងរានព្រៃ ធ្វើផ្លូវចូលទៅសិក្សាគម្រោង។ ម្យ៉ាងវិញទៀតវាអាចរំខានដល់ជម្រកសត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គម្រោងដោយសារសកម្មភាព សិក្សាគម្រោង។

អាចមានការបរបាញ់ ឬជួញដូរសត្វព្រៃ និងកាប់ឈើខុសច្បាប់ពីសំណាក់កម្មករគម្រោង ដែលធ្វើប៉ះពាល់ដល់ជម្រកសត្វព្រៃ។

ទោះជាយ៉ាងនេះក៏ដោយ នៅដំណាក់កាលសាងសង់ ផ្ទៃដីគម្រោងមាន៩.៣៥៥ហ.ត ហើយប៉ះពាល់ព្រៃឈើ ៦,០០៧,២៤ហ.ត ក្នុងការសាងសង់ ហេដ្ឋារចនាសម្ព័ន្ធគម្រោងវារីអគ្គិសនីនេះ ហេតុដូច្នេះហើយ ក្រុមហ៊ុនត្រូវត្រៀមទាក់ទង និងស្ថាប័ន មន្ទីរ និងក្រសួងពាក់ពន្ធ័សម្រាប់ធ្វើការកាប់សំអាតព្រៃឈើទាំងនោះចេញ ហើយឈើនៅក្នុងអាងដាក់ដេញថ្លៃជាសាធារណៈ ដោយយកថវិកាចូលរដ្ឋ។

Draft

មួយវិញទៀត ការបោះបង្គោលព្រំអាង និងតំបន់ដែលត្រូវសម្អាតមិនបានត្រឹមត្រូវ នាំឱ្យមានការកាប់ឈើលើសពីទីតាំងកំណត់ នាំឱ្យប៉ះពាល់ដល់ធនធានព្រៃឈើ និងជម្រកសត្វព្រៃបន្ថែមទៀត។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ដើម្បីកាប់ឆ្ការព្រៃឈើធ្វើផ្លូវ និងប្រើប្រាស់ឈើសម្រាប់សាងសង់ស្ពានឆ្លងកាត់បណ្តោះអាសន្ន។

ក្រុមហ៊ុនធ្វើការបោះជំរុំការងារនៅនឹងកន្លែង ជៀសវាងការដឹកសម្ភារការងារចុះឡើងបង្កការរំខានដល់ការរស់នៅរបស់សត្វព្រៃ ។

ក្រុមហ៊ុនត្រូវកំណត់ពេលវេលាធ្វើការតែពេលថ្ងៃ ដើម្បីមិនឱ្យរំខានសត្វព្រៃ។

ក្រុមហ៊ុនត្រូវធ្វើការសហការជាមួយជំនាញរដ្ឋបាលព្រៃឈើដើម្បី ជួយណែនាំដល់បុគ្គលិក-កម្មករ គម្រោងឱ្យមានការយល់ដឹងអំពី ការការពារ និងអភិរក្សព្រៃឈើ និងសត្វព្រៃ។

ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថាន ដើម្បីកាប់ឈើក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំសំកុស ដែលមានដីព្រៃឈើ ៤.១៤២ហ.ត និងតំបន់ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាលចំនួន១៣៧ហ.ត ក្នុងដំណាក់កាលសាងសង់គម្រោង។

ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទដើម្បីកាប់ឈើក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ៣៤៨៣ ហ.ត ក្នុងដំណាក់កាលសាងសង់គម្រោង។

ក្រុមហ៊ុនធ្វើការសហការជាមួយជំនាញរដ្ឋបាលព្រៃឈើ ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល និងដែនជម្រកសត្វព្រៃភ្នំសំកុស ដើម្បីទប់ស្កាត់បទល្មើសព្រៃឈើ និងសត្វព្រៃ។

ក្រុមហ៊ុនធ្វើលក្ខខណ្ឌការងារឱ្យអ្នកម៉ៅការសម្អាតអាងដោយមានការបោះបង្គោលព្រំ ក្នុងការកាប់សម្អាតផ្ទៃអាងឱ្យបានច្បាស់ គឺចម្ងាយពីគ្នា៥០មមួយ ដោយប្រើឧបករណ៍ឋានលេខា ដើម្បីបញ្ជាក់កម្រិតនីវ៉ូអាង ១៨០ម ដែលត្រូវសម្អាតជាងវាងការកាប់ឈើលើសតំបន់កំណត់។

## ខ.៤ ជីវសាស្ត្រសត្វព្រៃ

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលរចនាគម្រោងនេះ មានការប៉ះពាល់ដល់ជីវសាស្ត្រសត្វព្រៃខ្លះដែរ ដោយសារសកម្មភាពសិក្សាគម្រោង។

អាចមានការបរបាញ់ ឬជួញដូរសត្វព្រៃ និងកាប់ឈើខុសច្បាប់ពីសំណាក់កម្មករគម្រោង និងអ្នកចំណូលថ្មី។

ដូចចំណុច ខ.៣ដែរ នៅតំបន់គម្រោង គឺស្ថិតក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំសំកុស ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល និងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដូចនេះមានការប៉ះពាល់ដល់តំបន់ការពារទាំងនេះ ដែលមានសត្វរស់នៅច្រើន (ដូចមានចែងក្នុងជំពូក៥ខាងលើ) ដោយសារការរុករាន របស់អ្នកចំណូលថ្មី។

ក្នុងតំណាក់កាលសាងសង់គម្រោង មានសកម្មភាពកាប់ឆ្ការគម្របព្រៃឈើ ការឈូសឆាយដី ការបំផ្ទុះថ្ម ការដឹកជញ្ជូនសម្ភារសាងសង់នឹងនាំឱ្យមានការភ័យខ្លាច និងបង្អាក់ការបំលាស់ទី ដល់សត្វព្រៃទាំងនោះ ជាពិសេសប្រភេទជិតផុតពូជ (តាមបញ្ជីក្រហម IUCN ពង្រូល) ប្រភេទកំពុងរងគ្រោះ (ទន្សោង ឈ្លូសយក្ស គេរោមច្រមុះ ទោចម្កុដ ខ្លាត្រី) ដោយសារមានសំឡេងរំខានខ្លាំងៗ ចេញពីម៉ាស៊ីនគ្រឿងយន្តគ្រឿងផ្ទុះ សំឡេងខ្សៀវខ្សាររបស់បុគ្គលិក-កម្មករគម្រោង និងការព័ទ្ធកាប់បំផ្លាញជម្រកវា។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវបោះជំរុំការងារនៅនឹងកន្លែង ជៀសវាងការដឹកសម្ភារការងារចុះឡើង បង្កការរំខានដល់ការរស់នៅរបស់សត្វព្រៃ។

ក្រុមហ៊ុនត្រូវកំណត់ពេលវេលាធ្វើការតែពេលថ្ងៃ ដើម្បីមិនឱ្យរំខានសត្វព្រៃ។

ក្រុមហ៊ុនត្រូវធ្វើការសហការជាមួយជំនាញរដ្ឋបាលព្រៃឈើ ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល និងដែនជម្រកសត្វព្រៃភ្នំសំកុសជួយណែនាំដល់បុគ្គលិក-កម្មករ គម្រោងឱ្យមានការយល់ដឹងអំពីការការពារ និងថែរក្សាសត្វព្រៃ។

ចំពោះម្ហូបអាហារក្រុមហ៊ុនមិនត្រូវទិញសាច់សត្វព្រៃទេ ឬម្ហូបអាហារណាដែលពាក់ព័ន្ធសត្វព្រៃ។ ក្រុមហ៊ុនទិញ និងនាំស្បៀង ពីក្រុងពោធិ៍សាត់ ឬទីរួមស្រុកវាលវែង ដើម្បីផ្គត់ផ្គង់ការដ្ឋាន។

ក្រុមហ៊ុនគ្រោងថវិកាការពារបរិស្ថានសរុបចំនួន ៨.៦៨៩.៣៧៦ដុល្លារអាមេរិក ដើម្បីការពារបរិស្ថានរួមទាំងការឧបត្ថម្ភដល់អ្នកល្បាត ការព្រលែងកូនត្រីដែលងាយរងគ្រោះថ្នាក់ និងមានមូលនិធិសង្គ្រោះក្រពើភ្នំ ការដោះស្រាយផលប៉ះពាល់ដីធ្លី ផ្ទះសម្បែងជាដើម។ល។ (លម្អិតមើលតារាង៨-៣)។

ម្ចាស់គម្រោង នឹងធ្វើលក្ខខណ្ឌការងារឱ្យអ្នកម៉ៅការ ត្រូវបង្កលក្ខណៈឱ្យមានការបម្លាស់ទីរបស់សត្វព្រៃដូចជាៈ ការកាប់សម្អាតព្រៃឈើបាតអាង គឺកាប់សម្អាតឈើពីមាត់ស្ទឹងឡើងទៅលើ ដើម្បីឱ្យសត្វព្រៃអាចបម្លាស់ទីចូលទៅតំបន់ភ្នំបានផង និងមិនត្រូវឱ្យកម្មករកាប់ផ្តាច់ជាគន្លងព័ទ្ធជុំវិញ(ដូចជាកោះ)ដែលបង្ខាំងសត្វព្រៃនៅកណ្តាលនោះទេ។

## គ. ធនធានសេដ្ឋកិច្ចសង្គម

## គ.១ ការប្រើប្រាស់ដី និង ការតាំងលំនៅដ្ឋានឡើងវិញ

➢ ហេតុប៉ះពាល់អវិជ្ជមាន

ការអភិវឌ្ឍគម្រោងវារីអគ្គិសនីនេះ ត្រូវការផ្ទៃដីសរុប ៩.៣៥៥ហ.ត ចែកជា៤តំបន់គឺ តំបន់១ ជាតំបន់អាងដែលមានផ្ទៃដី៨.៥៩១ហ.ត ក្នុងនោះមានការប៉ះពាល់ការប្រើប្រាស់ដី របស់ប្រជាពលរដ្ឋចំនួន ២៣២៩.២៥ហ.ត (ដីកសិកម្ម ៩៣២.១២ ហ.ត ដីបុស្ស១.០៦៨,៣៩ហ.ត និងដីលំនៅដ្ឋាន ៣៨,៤៤ហ.ត) ជារបស់៣៤៧គ្រួសារ។



Draft

តំបន់១ជាតំបន់អាងនេះ ក៏មានការប៉ះពាល់ដីសហគមន៍តំបន់ការពារធម្មជាតិស្រែពាំង ៣៤១,៧៣ហ.ត ត្រូវជា ៦៨%(ផ្ទៃដីសរុប៤៩៩ហ.ត) និងដីសហគមន៍តំបន់ការពារធម្មជាតិស្ទឹងថ្មី ៩,៨៩ ហ.តត្រូវជា ២% (ផ្ទៃដីសរុប៤៦៣,៤ហ.ត) ផងដែរ។ ចំណែកឯ តំបន់២ តំបន់៣ និងតំបន់៤ មិនមានការប៉ះពាល់ដល់ដីប្រជាពលរដ្ឋទេ។ ***សម្គាល់៖*** *នៅក្នុងដីសហគមន៍តំបន់ការពារធម្មជាតិស្ទឹងថ្មីនៃតំបន់អាង មានដីពលរដ្ឋ៩,៨៩ហ.ត។*

ជាងនេះទៅទៀត អាចនឹងមានអ្នកឆ្លៀតឱកាសមកពីខាងក្រៅមកចាប់ដីបោះតាំងលំនៅឋានថ្មីនៅ ក្នុងតំបន់គម្រោង បន្ទាប់ពីទទួលព័ត៌មានថាមានការអភិវឌ្ឍនៅតំបន់នេះ ពីព្រោះពួកគេសង្ឃឹមថាបានទទួលសំណងពីក្រុមហ៊ុន ឬពីរដ្ឋាភិបាល។

ម៉្យាងវិញទៀត មានការប៉ះពាល់ដល់សតិអារម្មណ៍របស់ប្រជាពលរដ្ឋ នៅភូមិស្ទឹងថ្មី (ចំណុចអន្លង់ក្រូច ចំណុចអន្លង់ឃុត ស្វាយកោង និងអូរសង្កែសី) ដោយសារខ្លាចលិចដីកសិកម្ម ដីបុស្ស ដីលំនៅដ្ឋាន ធ្វើឱ្យបាត់បង់ដីស្រែ ចំការ និងលំនៅដ្ឋានរបស់ ពួកគេទាំងនោះ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវសុំការសហការជាមួយស្ថាប័នពាក់ព័ន្ធ ទាំងអស់ដូចជា អាជ្ញាធរមូលដ្ឋាន មន្ទីរ និងក្រសួងពាក់ព័ន្ធដើម្បីជូន ដំណឹងអំពីការសាងសង់គម្រោងនេះ ក៏ដូចប្រជាជនរស់នៅខាងក្នុងតំបន់គម្រោងផងដែរ។

ក្រុមហ៊ុនបានធ្វើការផ្សព្វផ្សាយតាមរយៈក្រុមការងារសិក្សា ESIA នេះព្រមទាំងបានជូនដំណឹងដល់សាធារណជន ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋជាមុនអំពីគោលបំណងជាក់ស្តែងរបស់រាជរដ្ឋាភិបាល សម្រាប់ការអភិវឌ្ឍគម្រោងនេះនៅពេលអនាគត ព្រមទាំង បើកសិក្ខាសាលា អំពីលទ្ធផលនៃការសិក្សានេះ នៅក្រុងពោធិ៍សាត់ នាថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ ២០១២ ដើម្បីកែតម្រូវចំណុចខ្វះខាត ចន្លោះប្រហោងក្នុងវិធានការបន្ធូរបន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដោយសារការអភិវឌ្ឍគម្រោងនេះ។

ក្រុមហ៊ុនធ្វើការសហការជាមួយអាជ្ញាធរដែនដី ដើម្បីទប់ស្កាត់ការទន្ទ្រានដីព្រៃ ដែលជាកម្មសិទ្ធិសាធារណៈរបស់រដ្ឋមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន។

ក្រុមហ៊ុនត្រៀមថវិកាចំនួន ៦.៨៣៣.០១៦ដុល្លារអាមេរិកសម្រាប់សំណង និងការអភិវឌ្ឍតំបន់ថ្មីសម្រាប់អ្នកប៉ះពាល់ដោយសារ គម្រោងនេះ ចំនួន៣៤៧គ្រួសារ។ ចំពោះសំណង មាន៣ករណីគឺ ករណីទី១ សំណងជាដី ២ហ.ត ក្នុង១គ្រួសារ (គិតតាមសមាត្រនៃចំនួនដីរបស់គេ បើដីរបស់គេលើសពី២ហ.តទៅ ដីនៅសល់សំណងជាប្រាក់ បើដីរបស់គាត់តិចជាង២ហ.ត សំណង២ហ.ត) ករណីទី១នេះមាន៧៤គ្រួសារ។ ករណីទី២គឺសំណងជាប្រាក់មាន២៨០គ្រួសារ។ ករណីទី៣ គឺសំណងជាផ្ទះ មាន២៤ គ្រួសារ (ផ្ទះប៉ះពាល់សរុប ៩២ខ្នង ជារបស់ ៧៨គ្រួសារ)។ **សម្គាល់:** ករណីសំណងជាដី ផ្អែកលើលក្ខណៈវិនិច្ឆ័យ ៣ គឺ ១)សំណូមពរ របស់អ្នកប៉ះពាល់ទាំងនោះ ២) មេគ្រួសារជាជនងាយរងគ្រោះ (មេម៉ាយ ចាស់ជរា អសមត្ថភាពការងារ មានប័ណ្ណក្រីក្រ និងជនជាតិដើមភាគតិច) ៣) ប៉ះពាល់ដី កសិកម្ម ចាស់ពី៥០% រហូតដល់ ១០០%។ វិនិច្ឆ័យផ្តល់ដីគឺសមាមាត្រ ២/៣។ ចំណែកឯ សំណងជាផ្ទះ ផ្តល់អត្ថិភាពឱ្យ មេគ្រួសារជាជនងាយរងគ្រោះ រួមទាំងមាន៣លក្ខណៈវិនិច្ឆ័យផងដែរ។ឧទាហរណ៍៖ គ្រួសារ ឈ្មោះ **ឝ** ជាជនងាយរងគ្រោះដែលមានផ្ទះប៉ះពាល់ គាត់ត្រូវទទួលបានសំណងជាផ្ទះ ៨០ម$^2$ តាមជម្រើសរបស់គាត់ (ផ្ទះសំណងមាន៣ ជម្រើស) ទោះជាផ្ទះរបស់គាត់ តូច ប្រក់ស្លឹកក៏ដោយ។ ជាងនេះទៀត បើគ្រួសារអ្នកប៉ះពាល់ ស្ថិតក្នុង ២ចំណុច នៃ៣លក្ខណៈវិនិច្ឆ័យខាងលើក៏ត្រូវផ្តល់សំណងជាផ្ទះផងដែរ។ (មើលរូបផ្ទះគំរូ ខាងក្រោម៖

Draft



ជម្រើសទី១ ផ្ទះថ្មផ្ទាល់ដីប្រក់សង្កសី ទំហំ ៨០ម²



ជម្រើសទី២ ផ្ទះឈើសង់ផុតពីដីប្រក់សង្កសី ទំហំ ៨០ម²



ជម្រើសទី៣ ផ្ទះឈើសង់ផុតពីដីប្រក់សង្កសី ទំហំ ៨០ម²

ចំពោះផ្ទះដែលប៉ះពាល់ និងសងតាមតម្លៃទីផ្សារគិតជាម៉ែត្រការ៉េដែលមានបញ្ជាក់ក្នុងតារាង ៩-៣ ជំពូក៩ ចំណុច ៩.១.៣។

ចំពោះដីសហគមន៍ នៃតំបន់ការពារទាំងនោះ គឺសហគមន៍តំបន់ការពារធម្មជាតិស្រែពាំង មានសំណង ១០២,៥១៩ ដុល្លារអាមេរិក និងសហគមន៍តំបន់ការពារធម្មជាតិស្ទឹងថ្មីមានសំណង ២,៩៦៧ ដុល្លារអាមេរិក ហើយ សំណងទាំងនេះនឹងទូទាត់ក្នុងដំណាក់កាលសាងសង់គម្រោង។ សំណងទាំងនេះជួយឱ្យសហគមន៍ធ្វើការដាំឈើ និងធ្វើ ប៉ុស្តិ៍ការពារនៃតំបន់ព្រៃឈើទាំងនេះដែលនៅសល់ ឬបង្កើតជាសហគមន៍ថ្មី។

ក្រុមហ៊ុនត្រូវធ្វើផែនការបំលាស់ប្តូរលំនៅដ្ឋានរបស់ប្រជាពលរដ្ឋក្នុងតំបន់១ (តំបន់អាងទឹក) និងបង្កើតតំបន់តាំង លំនៅឋានថ្មីឱ្យបានមុនយ៉ាងតិច១ឆ្នាំ មុននឹងធ្វើការបិទទ្វារទឹក បំពេញអាងនេះ។

*<u>សម្គាល់:</u> តម្លៃសម្រាប់ការអនុវត្តផែនការបំលាស់ប្តូរលំនៅដ្ឋានរបស់ប្រជាពលរដ្ឋឆ្នាំ ២០១២ មានត្រឹមតែ៤.៤៥៦.៨១២ ដុល្លារ ប៉ុណ្ណោះ តែខែកញ្ញា ឆ្នាំ២០១៥ នេះវាកើនលើស ២,០២ដង ហើយ ឆ្នាំ ២០១៧ នេះកើនជាងឆ្នាំ២០១៥ចំនួន៣ ដង គឺ $៦.៨៣៣.០១៦ ដោយសារ ដីក្នុងតំបន់អាងត្រូវបានផ្តល់ប្លង់រឹង ដីបុស្សក្លាយជាដីចំការ លម្អិតពីតម្លៃដីតម្លៃផ្ទះ តម្លៃដំណាំ ក្នុងតារាង៩-៣។*

ជាងនេះទៅទៀត ក្រុមហ៊ុនធ្វើការគ្រោងរចនាគម្រោង ដោយគណនាគ្រឹះសំណង់ និងតួទំនប់ឱ្យបានរឹងមាំតាម លក្ខណៈបច្ចេកទេស ជាពិសេសគណនាអាយុនៃសំណង់ធ្វើអំពីបេតុងឱ្យបានយ៉ាងតិច ៩០ឆ្នាំ ក្នុងលក្ខណៈធម្មតា (ប្រសិនបើ មិនមានគ្រោះធម្មជាតិឬសង្គ្រាម)ហើយសំណង់ទំនប់វារីអគ្គិសនីនេះនិងត្រូវរកការធានារ៉ាប់រងក្រុមហ៊ុនអន្តរជាតិ ដើម្បីធានា។

Draft

ក្រុមហ៊ុនត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីទប់ស្កាត់ក្នុងការបំផុសចលនាប្រជាពលរដ្ឋ របស់ជនឆ្លៀតឱកាសក្នុង គោលបំណងទាមទារដីធ្លី និងសំណងផ្សេងៗខុសច្បាប់ ឱ្យបានទាន់ពេលវេលាពីព្រោះតំបន់គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ នេះមានប្រជាពលរដ្ឋរស់នៅក្នុងតំបន់ការពារ និងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ទាំងនោះ។

ក្រុមហ៊ុនធ្វើការសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច សង្កាត់រដ្ឋបាលព្រៃឈើប្រមោយ នៃខណ្ឌរដ្ឋបាលព្រៃឈើខេត្តពោធិ៍សាត់ មន្ត្រីឧទ្យានជាតិ ដែនជម្រកសត្វព្រៃ និងអង្គការអភិរក្សនានា ដើម្បីចាត់វិធានការទប់ស្កាត់ និងបង្កើនកម្លាំងការពារតំបន់នេះ។

ក្រុមហ៊ុនត្រូវធ្វើការសហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការ រៀបចំធ្វើផែនការដោះស្រាយផលប៉ះពាល់ និងផ្លាស់ប្តូរលំនៅដ្ឋានរបស់ប្រជាពលរដ្ឋដែលរងការប៉ះពាល់ដោយសារគម្រោងនេះ ឱ្យបានត្រឹមត្រូវតាមច្បាប់ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

### គ.២ ការរស់នៅ និងមុខរបររបស់សហគមន៍មូលដ្ឋាន

ក្នុងដំណាក់កាលរចនាគម្រោងនេះមិនប៉ះពាល់ដល់ចំណុចនេះទេ ប៉ុន្តែក្នុងដំណាក់កាលនេះត្រូវធ្វើបច្ចុប្បន្នភាពការប៉ះពាល់ដល់ប្រជាពលរដ្ឋ ដូចជាធ្វើផែនការបំលាស់ប្តូរលំនៅដ្ឋានរបស់ប្រជាពលរដ្ឋក្នុងតំបន់គម្រោង ជាពិសេសត្រូវគិតបញ្ចូលសំណងថ្លៃដីស្រែចំការ ដីបុស្ស ដីលំនៅដ្ឋាន ដំណាំ ឈើស៊ីផ្លែទាំងអស់ដែលនឹងត្រូវខូចខាតដោយសារគម្រោងនេះ ដោយត្រូវគណនាតាមតម្លៃជំនួសតាមតម្លៃទីផ្សារបច្ចុប្បន្ន។

គម្រោងនឹងមានការប៉ះពាល់ទៅដល់៩៦គ្រួសារដែលមេគ្រួសារជាជនងាយរងគ្រោះ និងប៉ះអស់ដីផលិតកម្ម លើសចាប់ពី៥០% ដល់១០០% ដែលនាំឱ្យគ្រួសារទាំងនេះងាយធ្លាក់ក្នុងភាពងាយរងគ្រោះឬភាពក្រីក្រ ដែលចុងក្រោយ នឹងក្លាយជាបន្ទុករបស់រាជរដ្ឋាភិបាល។ ***សម្គាល់:*** *យោងតាមការចុះសិក្សាជាក់ស្តែង ក្នុងតំបន់គម្រោង នាខែតុលាដល់វិច្ឆិកា ឆ្នាំ២០១៧ នេះ មានគ្រួសារងាយរងគ្រោះចំនួន៥១គ្រួសារ (មេម៉ាយ ចាស់ជរា អសមត្ថភាពការងារ មានប័ណ្ណក្រីក្រ ជនជាតិដើមភាគតិច)*។

ក្នុងផែនការបំលាស់ប្តូរលំនៅឋានរបស់ប្រជាពលរដ្ឋក្នុងតំបន់គម្រោង ត្រូវបញ្ចូល ប្រាក់ឧបត្ថម្ភផ្សេងដូចជា ប្រាក់ថ្លៃរំខាននៃការខូចខាត(ប្រាក់ជំងឺចិត្ត) ប្រាក់ថ្លៃដឹកជញ្ជូន ប្រាក់ឧបត្ថម្ភដល់មេគ្រួសារងាយរងគ្រោះ ប្រាក់ស្តារចំណូលឡើងវិញដល់៩៦គ្រួសារ ដែលប៉ះពាល់ដីកសិកម្មចាប់ពី៥០% ដល់ ១០០% នៃដីកសិកម្មរបស់គ្រួសារ។ នៅផែនការនេះត្រូវរួមបញ្ចូលតម្លៃសាងសង់ផ្ទះដំបូលសង្កសី ជញ្ជាំងឈើ ទំហំ ៨០ ម$^{2}$ សម្រាប់ឱ្យអ្នកស្ថិតក្នុងលក្ខណៈវិនិច្ឆ័យចំនួន២៤គ្រួសារ (ដូចមានចែងក្នុងចំណុច គ.១ ខាងលើ) មើលរូបផ្ទះគំរូខាងលើ។

### គ.៣ ផ្លូវគមនាគមន៍

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលនេះ អាចមានការប៉ះពាល់ និងគ្រោះថ្នាក់ដល់អ្នកសិក្សា ឬធ្វើឱ្យស្ទះការងារសិក្សាប្លង់រចនាគម្រោង ដោយសារមិនមានផ្លូវដឹកជញ្ជូនច្បាស់លាស់សម្រាប់គម្រោងនេះដែលមានចំណោតខ្លាំង ហើយឆ្លងកាត់ជ្រោះដែលមានផ្ទាំងថ្ម កន្លែងខ្លះជាល្បាក់ជ្រៅពុំអាចឆ្លងកាត់បាន។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនរកអ្នកនាំផ្លូវរស់នៅក្បែរតំបន់គម្រោង ដែលស្គាល់ភូមិសាស្ត្រច្បាស់លាស់ដែលធ្លាប់ចេញចូលតំបន់នេះ។
ក្រុមហ៊ុនត្រួសត្រាយផ្លូវ និងធ្វើស្ពានបណ្តោះ។
ក្រុមហ៊ុនជួលរថយន្តដែលមានសុវត្ថិភាពល្អក្នុងការសិក្សាគម្រោងនេះ។

### គ.៤ សុខភាពសាធារណៈ

➢ ហេតុប៉ះពាល់អវិជ្ជមាន

នៅដំណាក់កាលនេះបង្កឱ្យមានការប៉ះពាល់ដល់សុខុមាលភាពបុគ្គលិកកម្មកររបស់ក្រុមហ៊ុន មួយចំនួនដោយសារតំបន់នេះ ស្ថិត នៅក្នុងព្រៃ ដែលបង្កឱ្យមានកើតជំងឺគ្រុនចាញ់ គ្រុនសន្និ។ល។

នៅក្នុងពេលសិក្សានេះបង្កឱ្យមានការប៉ះពាល់ដល់សុខុមាលភាពបុគ្គលិកមួយចំនួន កើតជំងឺ រាគរូស ឬអាសន្នរោគ ព្រោះនៅតំបន់នេះមិនមានប្រព័ន្ធទឹកស្អាត។

ជាងនេះទៅទៀត ក្នុងដំណាក់កាលសាងសង់គម្រោង នឹងមានការបន្ទោរបង់ដាក់ទឹក និងធ្វើបង្គន់លើទឹករបស់កម្មករ ធ្វើឱ្យកម្មករផ្សេងទៀត មានជំងឺគ្រុនពោះវៀន អាសន្នរោគ រាគរូសជាដើម។ល។ ដូចនេះក្នុងនៅដំណាក់កាលរចនានេះត្រូវគិតគូរអំពីបញ្ហានេះផងដែរ។

ម៉្យាងទៀត ប្រជាពលរដ្ឋក្បែរតំបន់គម្រោងអាចឆ្លងជំងឺកាមរោគពីបុគ្គលិក-កម្មករ ដែលមកពីកន្លែងផ្សេងៗគ្នា និងជំងឺអេដស៍ជាដើម។ល។

នៅដំណាក់កាលប្រតិបត្តិគម្រោង អាចមានគ្រោះថ្នាក់ដល់ជីវិតមនុស្ស សត្វចិញ្ចឹម ដោយសារការបញ្ចេញទឹក ៤០ម$^{៣}$/វិន. ទួប៊ីនពីរ ៨០ម$^{៣}$/វិន. ក្នុងការផលិតអគ្គិសនី។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនធ្វើការអប់រំដល់ បុគ្គលិកកម្មករទាំង សុខភាពអនាម័យ ការការពារជំងឺសង្គម និងការហូបទឹកឆ្អិន។

ក្រុមហ៊ុនអប់រំបុគ្គលិកកម្មករអំពីវិធីការពារ និងការទប់ស្កាត់បញ្ហាជំងឺទាំងនេះ រាល់បីខែម្តង។

ក្រុមហ៊ុនត្រៀមថ្នាំបង្ការដើម្បីការពារ និងព្យាបាលជំងឺទាំងនោះ។

ជាងនេះទៅទៀត ក្រុមហ៊ុនសាងសង់បង្គន់ អនាម័យដោយជីកដីដាក់លូត្រឹមត្រូវ ឱ្យឆ្ងាយពីប្រភពទឹក។

ក្រុមហ៊ុនត្រូវ គ្រោងដំឡើងប្រដាប់ផ្តល់ដំណឹងប្រាប់ឱ្យដឹងមុន ១៥ ទៅ៣០នាទី ដូចជា ការបំពាក់សញ្ញាគ្រោះថ្នាក់ និងបន្លឺស៊ីរ៉ែនជាដើម នៅតំបន់ខាងក្រោមអាគារថាមពល ដែលមានមនុស្សរស់នៅ ចម្ងាយ យ៉ាងតិច ៥០គ.ម តាមដងស្ទឹង ដើម្បីឱ្យអ្នករស់នៅខាងក្រោមបានដឹង និងរត់គេច មកទីទួលសុវត្ថិភាព នៅពេលដែលបើកទឹកដំណើរការទួប៊ីនម្តងៗ (ទួប៊ីន ១ បញ្ចេញទឹក ៤០ម$^{៣}$/វិន. ទួប៊ីនពីរ ៨០ម$^{៣}$/វិន.។

### គ.៥ ហានិភ័យ

➢ ហេតុប៉ះពាល់អវិជ្ជមាន

អាចមានគ្រោះថ្នាក់ដោយសារតំបន់នោះមិនដែលស្គាល់ភូមិសាស្ត្រ ដូចជា: ជ្រោះជ្រៅ, ការបាក់ផ្ទាំងថ្មធំៗ, ចំណោតខ្ពស់ៗ បង្កឱ្យគ្រោះថ្នាក់ដោយរអិល, គ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះបង្កប់ក្នុងដីនៅតំបន់អតីតបន្ទាយទាហានដែលជាកន្លែងធ្លាប់ប្រយុទ្ធ។




គ្រាប់មីនប្រឆាំងនិងថ្មើរជើងរកឃើញដោយក្រុមការងារ

ជាងនេះទៅទៀត ការគ្រោងគម្រោងមិនត្រឹមត្រូវតាមបច្ចេកទេស បង្កហានិភ័យខ្ពស់ដូចជាបាក់ទំនប់ រអិលបាក់ភ្នំនាំឱ្យខូច ខាតទ្រព្យសម្បត្តិ និងអាយុជីវិតរបស់ប្រជាពលរដ្ឋជាដើម។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុន ត្រូវធ្វើការទាក់ទងយ៉ាងជិតស្និតជាមួយអាជ្ញាធរមូលដ្ឋាន ដោយមានការសហការជាមួយសមត្ថកិច្ច និងមជ្ឈមណ្ឌលជាតិ គ្រប់គ្រង កងកម្លាំង រក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម (NPMEC) ដើម្បីធ្វើការដោះគ្រាប់មីន និងកាកសំណល់សង្គ្រាមទាំងនេះចេញពីតំបន់គម្រោង។

Draft

ក្រុមហ៊ុនត្រូវធ្វើការសិក្សារចនាប្លង់វិស្វកម្ម និងគុណភាពការសាងសង់ ដែលអាចធានាមិនឱ្យមានការបាក់ទំនប់ និងការបាក់ភ្នំ ក្នុងតំបន់គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ ដោយរកក្រុមហ៊ុនអន្តរជាតិធ្វើការធានាគុណភាពសំណង់ ធានាក្នុងរយៈពេល ៩០ឆ្នាំ និងហានិភ័យរបស់វា។

ក្រុមហ៊ុន ត្រូវអនុវត្តទៅតាមផែនការគ្រប់គ្រងសុវត្ថិភាព និងហានិភ័យ ដូចមានចែង ក្នុងជំពូក៤ ចំណុច៤.៦.១២ ឱ្យបានជាប្រចាំ។

### ៧.៤.២ ដំណាក់កាលសាងសង់គម្រោង (Project Construction)

ក្នុងដំណាក់កាលនេះ គឺជាដំណាក់កាលមួយមានរយៈពេលរហូតដល់៤ឆ្នាំ (មិនគិតរយៈពេលគ្រោងលម្អិត) ហើយនឹងមាន សកម្មភាពសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធរបស់គម្រោងជាច្រើន ដូចជាៈ ការឈូសឆាយដី ការសាងសង់ផ្លូវចូលក្នុងការដ្ឋាន ការសាងសង់ទំនប់ សំណង់យកទឹក Tunnels អាគារផលិតថាមពលអគ្គិសនី សម្រាប់ដាក់ទួរប៊ីន អាគារការិយាល័យផ្ទះបុគ្គលិក-កម្មករជាដើម។ ព្រមទាំងមានការសាងសង់ វាលត្រង់ស្វូរ បង្គោល និងខ្សែបញ្ជូនអគ្គិសនី ពីអាគារផលិតថាមពលនៃគម្រោងវារីអគ្គិសនីនេះទៅភ្ជាប់នឹងបណ្តាញខ្សែ២៣០គ.វ៉ ពីអនុស្ថានីយអូរសោម-ខេត្តពោធិ៍សាត់ផងដែរ។ សកម្មភាពការងារទាំងនេះនឹងអាចបង្កឱ្យមានការប៉ះពាល់អវិជ្ជមានសំខាន់ៗមួយចំនួនមានដូចតទៅ ៖

**ក. ធនធានរូបសាស្ត្រ**

**ក.១ សណ្ឋានដី និងឋានលេខា**

➢ ហេតុប៉ះពាល់អវិជ្ជមាន

នៅក្នុងដំណាក់នៃការសាងសង់គម្រោងនេះ បណ្តាលឱ្យប្រែប្រួលសណ្ឋានដី និងឋានលេខាក្នុងទីតាំងសាងសង់គម្រោង ដោយសារសកម្មភាព ការឈូសឆាយ និងពង្រាបដីស្រទាប់លើ ដែលមានគម្របព្រៃដើម្បីធ្វើហេដ្ឋារចនាសម្ព័ន្ធរបស់គម្រោងដូចជា ការធ្វើផ្លូវថ្នល់ សាងសង់ ទំនប់ ប្រឡាយដោះទឹក បំពង់ទួនែល អគារថាមពល កន្លែងយកថ្ម កន្លែងយកដី កន្លែងចាក់ចោលដី និងសំណល់ថ្ម កន្លែងសាងសង់អាគារ សម្រាប់ទីស្នាក់ការ និងផ្ទះបុគ្គលិក-កម្មកររបស់ក្រុមហ៊ុន ។ល។ ការចាក់ចោលដី និងសំណល់ថ្ម ដែលយកពីការសាសង់រូងទួរនែល ក្បែរច្រាំងស្ទឹង ណាំឱ្យមានការលប់ ឬរាក់ស្ទឹង និងអន្លង់តាមពោះស្ទឹងផងដែរ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវធ្វើការជួសជុលទីតាំងយកថ្មកន្លែងយកដី និងកន្លែងចាក់ដីចោលឱ្យមានសុវត្ថិភាពល្អ ដោយដាំដើមឈើនៅ ទីនោះវិញក្រោយពេលសាងសង់រួច។ ធ្វើការដាំស្មៅនៅកន្លែង ដែលខ្លួនបានកាយជញ្ជាំងភ្នំ ឬកន្លែងចំណោតផ្សេងៗ ដើម្បីធ្វើផ្លូវ ធ្វើទំនប់ និងធ្វើហេដ្ឋារចនាគម្រោងដទៃទៀត ដើម្បីការពារការហូរច្រោះ បាក់ជញ្ជាំងភ្នំបន្ថែម។

ក្រុមហ៊ុនត្រូវជឿជាក់ថាមិនមានការចាក់ចោលដី និងសំណល់ថ្មតាមច្រាំងស្ទឹងនោះទេ ដោយមានអ្នកត្រួតពិនិត្យជាប្រចាំ។ ជាងនេះទៅទៀត ការឈូសឆាយដីធ្វើផ្លូវ ត្រូវយកសំណាលដីដែលកាយចេញទុកដាក់ ឱ្យឆ្ងាយពីអូរ ស្ទឹង និងត្រូវសម្រួលជញ្ជាំង ឱ្យមានជម្រាលតាមបទដ្ឋានប្រភេទដី និងថ្ម ដូចបានចែងក្នុង ដំណាក់កាលរចនាគម្រោង។

ម៉្យាងវិញទៀត ក្រុមហ៊ុនធ្វើការសាងសង់ពេញមួយឆ្នាំ លើកលែងតែថ្ងៃ ដែលមានភ្លៀងធ្លាក់ ដើម្បីទប់ស្កាត់ការហូរច្រោះ ដែលនាំឱ្យខូចសណ្ឋានដី។ នៅរដូវវស្សាក្រុមហ៊ុនធ្វើការសាងសង់ទំនប់ ដោយធ្វើផែនការសាងសង់ប្រចាំខែច្បាស់លាស់ ដូចជាការសង់ជញ្ជាំងបេតុង ដែលស្រោបព័ទ្ធជុំវិញទំនប់ជាមុនឱ្យបានខ្ពស់ជាងកម្ពស់ថ្ម ដែលត្រូវចាក់ក្នុងរយៈ ១ខែដើម្បីជៀសវាងការហូរច្រោះកម្ទេចថ្មចូល ស្ទឹងជាដើម។ល។

**ក.២ ប្រព័ន្ធជលសាស្ត្រ ទឹកលើដី (ប្រឡាយ- អូរ-ស្ទឹង)**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលសាងសង់នេះ បង្កឱ្យប៉ះពាល់ដល់បរិមាណធារទឹករបស់ស្ទឹងពោធិ៍សាត់ ដោយសារការទប់ទំនប់កាត់ស្ទឹងពោធិ៍សាត់ ដើម្បីធ្វើអាងតម្កល់ទឹក។ នៅខាងក្រោមតំបន់គម្រោង មានសំណង់ធារាសាស្ត្រស្ទាក់ទឹក ពីរកន្លែងកាត់ស្ទឹងពោធិ៍សាត់ គឺដំណាក់អំពិល និងចារឹក ដែលយកទឹកទៅស្រោចស្រពដីកសិកម្មក្នុងខេត្តពោធិ៍សាត់ និងបាត់ដំបង។



Draft

បន្ថែមពីលើនេះការងារសាងសង់នេះក៏ប៉ះពាល់ដល់គុណភាពទឹក ដោយសារសកម្មភាពសាងសង់ ដូចជាការលាង ថ្ម ខ្សាច់ ការហូរច្រោះជញ្ជាំងភ្នំដែលខ្លួនបានកាយ និងការចាក់សំណល់ដី ថ្ម ដែលធ្វើឱ្យទឹកស្ទឹងឡើងល្អក់ខ្លាំង។

ម៉្យាងទៀត ប៉ះពាល់ដល់គុណភាពទឹកដោយសារការបោះបង់សំណល់រឹង និងការបង្ហូរសំណល់រាវ ពីកន្លែងរស់នៅរបស់បុគ្គលិក-កម្មករគម្រោង បង្គន់ ការលេចធ្លាយប្រេងឥន្ធនៈ ប្រេងរំអិលពីគ្រឿងយន្តនានាក្នុងការដ្ឋានសាងសង់ និងការមុជទឹកសំអាតខ្លួនប្រាណរបស់បុគ្គលិក-កម្មកររាប់រយនាក់ ដែលនៅក្បែរប្រភពទឹក នឹងធ្វើឱ្យគុណភាពទឹកស្ទឹងពោធិ៍សាត់មានការថយចុះ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវសាងសង់ផ្លូវទឹកបង្វៀងការដ្ឋាន ដើម្បីផ្តល់ទឹកមក ខ្សែទឹកខាងក្រោមឱ្យបានជាធម្មតាវិញ។

ក្រុមហ៊ុនធ្វើការកាត់បន្ថយការធ្វើឱ្យល្អក់ខ្លាំងដោយសាងសង់ទំនប់បណ្តោះអាសន្ន ព័ទ្ធជុំវិញការដ្ឋានសំណង់ទំនប់។ ធ្វើការដាំស្មៅនៅកន្លែងដែលខ្លួនបានកាយជញ្ជាំងភ្នំ ឬកន្លែងចំណោតផ្សេងៗដើម្បី ធ្វើផ្លូវ ធ្វើទំនប់ និងធ្វើហេដ្ឋារចនាសម្ព័ន្ធគម្រោងដទៃទៀត ដើម្បីការពារការហូរច្រោះបាក់ជញ្ជាំងភ្នំបន្ថែម។

ក្រុមហ៊ុនត្រូវត្រួតពិនិត្យអ្នកម៉ៅការសាងសង់ទាំងអស់ ដោយជឿជាក់ថា សំណល់ ដី ថ្ម ទាំងនោះមិនបានចាក់តាមមាត់ច្រាំង ឬក្នុងស្ទឹង អូរ ក្នុងតំបន់គម្រោងឡើយ ទីតាំងចាក់សំណល់ ដីនិងថ្ម មើល គំនូរបច្ចេកទេស DRW 01។

សកម្មភាពសាងសង់ធំៗ និងមមាញឹក គឺក្រុមហ៊ុនសាងសង់នៅរដូវប្រាំង ដើម្បីកាត់បន្ថយការហូរច្រោះពីការដ្ឋានដីផ្សេងៗ ដែលហូរចូលស្ទឹង។ ចំណែកឯ នៅរដូវវស្សាវិញក្រុមហ៊ុនធ្វើការសាងសង់ទំនប់ ដោយធ្វើផែនការសាងសង់ប្រចាំខែច្បាស់លាស់ ដូចជាការសង់ជញ្ជាំងបេតុងដែលស្រោបពទ្ធ័ជុំវិញទំនប់ ជាមុនបានខ្ពស់ជាងកម្ពស់ថ្មដែលត្រូវចាក់ក្នុងរយៈ ១ខែ ដើម្បីជៀសវាង ការហូរ ច្រោះកម្ទេចថ្មចូលស្ទឹងជាដើម។

ក្រុមហ៊ុនធ្វើការអប់រំដល់បុគ្គលិកកម្មករអំពីការបោះបង់សំណល់រឹង-រាវ ជាពិសេសការកំពប់ប្រេងឥន្ធនៈ ប្រេងរំអិលនៅ លើដី ដែលបណ្តាលឱ្យខូចគុណភាពដី និងទឹកនៅក្នុងតំបន់គម្រោង។ ក្រុមហ៊ុននឹងធ្វើការណែនាំបុគ្គលិក/កម្មករគម្រោងឱ្យយល់ដឹង អំពីអនាម័យស្គាល់នូវកន្លែងទុកដាក់សម្រាម ដែលក្រុមហ៊ុនបានរៀបចំកសាងក្នុងទីតាំងស្នាក់នៅរបស់គម្រោង។

គ្រប់គ្រង និងការពារសំណល់រឹង-រាវគ្រប់ប្រភេទមិនឱ្យបោះចោល និងបង្ហូរចូលទៅក្នុង ឬក្បែរទឹកស្ទឹង ឬអូរឡើយ ដូចជាសង់បន្ទាប់ទឹក និងបង្គន់អនាម័យឆ្ងាយពីស្ទឹង និងអូរ យ៉ាងហោចណាច់ ១០០ម និងមានអាងសិបទិកត្រឹមត្រូវ មានកន្លែងទុកដាក់សំណល់រឹងល្អតាមបច្ចេកទេស ហើយត្រូវអនុវត្តទីតាមផែនការគ្រប់គ្រងសំណល់គ្រប់ប្រភេទ ដូចមានចែងក្នុងជំពូក ៤ ចំណុច ៤.៦.១១។

សាងសង់បង្គន់អនាម័យដោយជីករណ្តៅដាក់លូ ដើម្បីស្តុកលាមកមានជម្រៅពី២,៥ទៅ៣,៥ម ដើម្បីសំលាប់មេរោគ។ ចំពោះសំណល់ផ្ទះបាយវិញ គឺមិនបង្ហូរ ឬចាក់ចូលទៅក្នុងស្ទឹងពោធិ៍សាត់ទេគឺជីករណ្តៅជម្រៅ១-២ម. ទំហំ៤ទៅ៦ម² ដើម្បីធ្វើឱ្យសំណល់នោះក្លាយជាជីកំប៉ុស៍ ថែមទាំងមានធុងទុកសម្រាប់ដាក់សម្រាម និងកន្លែងដុតសម្រាមចោលដោយសុវត្ថិភាព។

**ក.៣ ការហូរច្រោះ**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ដំណាក់កាលសាងសង់នេះ អាចមានការហូរច្រោះដី ដោយសារការឈូសឆាយដីគម្របព្រៃឈើ ដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធ របស់គម្រោង ដូចជាការកាយជញ្ជាំងភ្នំធ្វើផ្លូវ ធ្វើទំនប់ ធ្វើអាគារថាមពលជាដើម ព្រោះថាតំបន់នេះជាតំបន់ខ្ពង់រាប និងភ្នំ នឹងងាយមាន ការហូរច្រោះ ដីជាពិសេសនៅរដូវវស្សា តែតំបន់នេះជាតំបន់រងនូវទឹកភ្លៀងច្រើនផងដែរ។

Draft

រីឯសកម្មភាពសាងសង់បង្កឱ្យប៉ះពាល់ដល់គុណភាពដីស្រទាប់លើនៅជុំវិញតំបន់ចោលដីស្អុយ ឬសំណល់ថ្ម ដែលធ្វើឱ្យបាត់បង់ជីជាតិរបស់ដីស្រទាប់លើនាតំបន់នោះ បណ្តាលមកពីការហូរច្រោះតំបន់ដីស្អុយ ឬសំណល់ថ្មទាំងនេះ ទៅគ្របពីលើសណ្ឋានដីតំបន់ជុំវិញនោះ។

ជាងនេះទៅទៀត នៅផ្នែកខាងក្រោមទំនប់ អាចមាន កម្ទេច កំណកដី និងថ្ម ធ្លាក់ចូលក្នុងអន្លង់ដែលមានត្រីមេពូជរស់នៅ ឬធ្វើឱ្យរាក់ បណ្តាអន្លង់ និងពោះស្ទឹងនៅក្រោមទំនប់។

- វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវធ្វើការបង្ហាប់ដី (ការងារដី)ក្នុងតំបន់សាងសង់ឱ្យបានត្រឹមត្រូវតាមបទដ្ឋានការងារបច្ចេកទេស។

ក្រុមហ៊ុនត្រូវពង្រាបដី ឬថ្មដែលចាក់ចោល ដោយយកដីមានជីជាតិលប់ពីលើរួចដាំដើមឈើឡើងវិញ ក្នុងតំបន់នេះដោយ ធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើពោធិ៍សាត់ និងអង្គការ CI។

ធ្វើការដាំស្មៅនៅកន្លែងដែលខ្លួនបានកាយជញ្ជាំងភ្នំ ឬកន្លែងចំណោតផ្សេងៗ ដើម្បីធ្វើផ្លូវ ធ្វើទំនប់ និងធ្វើហេដ្ឋារចនាសម្ព័ន្ធគម្រោងដ៏ទៃទៀត ដើម្បីការពារការហូរច្រោះបាក់ជញ្ជាំងភ្នំបន្ថែម។

ម្ចាស់គម្រោង/ អ្នកម៉ៅការទាំងអស់ ត្រូវព្យាយាមមិនឱ្យ ដី ឬថ្ម ធ្លាក់ចូលក្នុងស្ទឹង និងក្នុងអន្លង់ ដែលនៅជិតការដ្ឋានសាងសង់។ នៅពេលចប់ការសាងសង់ ម្ចាស់គម្រោងត្រូវ យកដុំថ្មធំៗចេញពីអន្លង់ទាំងនោះ វិញប្រសិនបើមានការលប់អន្លង់ទាំងនេះ និងបើកទឹកលាងកករបាតស្ទឹងនៅខាងក្រោមទំនប់ផងដែរនៅក្នុងដំណាក់កាលប្រតិបត្តិគម្រោងដំបូង។

### គ.៤ ការរញ្ជួយដី

- ហេតុប៉ះពាល់អវិជ្ជមាន

ដំណាក់កាលសាងសង់នេះអាចបង្កឡើងដោយសារ ការបំផ្ទុះផ្ទាំងថ្មនៅការដ្ឋានធ្វើទំនប់ ដែលអាចធ្វើឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋ ដែលរស់នៅជុំវិញ ឬចេញចូលតំបន់គម្រោង ដោយស្ទះផ្លូវចេញចូល ឬប៉ះពាល់ដល់សុវត្ថិភាពកម្មករ ដូចជា ការរញ្ជួយបាក់ផ្ទាំងថ្មជាដើម។ល។ ការរញ្ជួយ ដោយសារការដឹកសម្ភារសំណង់ធុនៗ (ថ្ម ខ្សាច់ ប្រើគ្រឿងរំញ័រក្នុងការបង្ហាប់បេតុង និងដឹកដុំទួប៊ីនអគ្គិសនី) ដើម្បីសាងសង់ទំនប់ សាងសង់រន្ធទូនេល និងអាគារថាមពលជាដើម។ល។

- វិធានការកាត់បន្ថយ

ក្រុមការងាររបស់ក្រុមហ៊ុនត្រូវកំណត់តំបន់គ្រោះថ្នាក់ដោយសារការផ្ទុះនេះ ឱ្យបានច្បាស់លាស់រួចដាក់ស្លាកសញ្ញាគ្រោះថ្នាក់នៅតាមព្រំប្រទល់តំបន់នេះ ដើម្បីឱ្យកម្មករនិយោជិតគម្រោង និងប្រជាពលរដ្ឋងាយឃើញ និងស្គាល់។

ការប្រើប្រាស់គ្រឿងផ្ទុះ គឺក្រុមហ៊ុនបានកំណត់កម្រិតរញ្ជួយ និងកម្លាំងបំផ្ទុះឱ្យតូច ដែលមិនប៉ះពាល់ដល់ការបាក់ផ្នែកខ្លះ នៃភ្នំ ឬផ្លូវ ដែលនៅក្បែរតំបន់បំផ្ទុះ។

ក្រុមហ៊ុនត្រូវធ្វើការផ្តល់ព័ត៌មាន ផ្សព្វផ្សាយដល់អាជ្ញាធរ និងសហគមន៍មូលដ្ឋាននូវកាលបរិច្ឆេទ និងពេលវេលាបំផ្ទុះ ដើម្បីការពារសុវត្ថិភាពដល់កម្មករនិយោជិតគម្រោង និងប្រជាពលរដ្ឋដែលរស់នៅទីនោះ។

ការបំផ្ទុះក្រុមហ៊ុននឹងធ្វើនៅពេលរសៀល (ម៉ោង ៤:០០-៥:០០ល្ងាច) ហើយមុនពេលបំផ្ទុះត្រូវផ្តល់សញ្ញាជាស៊ីរ៉ែន និងមានអ្នកត្រួតពិនិត្យ ថាមិនមានមនុស្ស នៅក្នុងតំបន់គ្រោះថ្នាក់នោះឡើយ។

រាល់សម្ភារសំណង់ធន់ធ្ងន់ ក្រុមហ៊ុនធ្វើការដោះបំបែក និងផ្ទេរចែករំលែកឱ្យងាយក្នុងការដឹកជញ្ជូនវា ទោះបីត្រូវប្រើរថយន្តដឹកច្រើនជើងក៏ដោយ។

### គ.៥ គុណភាពទឹក

- ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលសាងសង់នេះ មានការបំពុលគុណភាពទឹកស្ទឹងពោធិ៍សាត់ដោយសារ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគម្រោង បណ្តាលមកពីការខួង ឬការងារដី ការងារបេតុង ការងារបំផ្ទុះថ្មភ្នំ ការកាយជញ្ជាំងភ្នំ និងការចាក់សំណល់ដីថ្មចោល ដោយមិនបានបង្ហាប់ និងបានដាំស្មៅជាដើម។ ម៉្យាងទៀត មានការបំពុលគុណភាពទឹកពីកន្លែងលាងថ្ម ខ្សាច់ដើម្បីលាយបេតុង រួចទឹកនោះហូរចូលអូរ ស្ទឹង ព្រែក ដែលធ្វើឱ្យប៉ះពាល់ដល់ជីវិតសត្វ និងមនុស្ស ដែលប្រើប្រាស់ទឹកនេះនៅខាងក្រោមខ្សែទឹក។

ម៉្យាងទៀត ប៉ះពាល់គុណភាពទឹកស្ទឹងពោធិ៍សាត់ដោយសារសំណល់រឹង-រាវ មកពីការបោះចោលសំណល់ផ្ទះបាយ បង្គន់ ដែលសង់គ្មានបច្ចេកទេស និងការខ្វះខាតបង្គន់ អនាម័យគ្រប់គ្រាន់ សម្រាប់បុគ្គលិកកម្មករគម្រោង និងការបោះសំណល់ សម្ភារសំណង់ ដោយបុគ្គលិក-កម្មករក្រុមហ៊ុន (ការហៀរ ឬលេចជាតិប្រេងពីគ្រឿងចក្ររថយន្ត បារ៉ស៊ីម៉ងត៍ បារ ឬស្បោងច្រកសារធាតុគីមីផ្សេងទៀត។ល។)។

បន្ថែមពីលើនេះទៀតមានការហូរច្រោះដី ដោយសារការកាប់ឆ្ការនូវគម្របរុក្ខជាតិ ដូចជាការកាប់ព្រៃ ការឈូសឆាយដីធ្វើហេដ្ឋារចនាសម្ព័ន្ធគម្រោង និងការកាប់រានព្រៃឈើនៅតាមដងអូរ ឬស្ទឹង ដែលនឹងត្រូវលិចជាដើម។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនមិនឈូសឆាយទ្រង់ទ្រាយធំនៅរដូវវស្សាទេ។

ដើម្បីការពារកករដីកុំឱ្យសាយភាយចេញឆ្ងាយពីទីតាំងសាងសង់ក្រុមហ៊ុន នឹងធ្វើរបាំងការពារ។ ម៉្យាងវិញទៀត នៅកន្លែងលាងថ្មលាយបេតុងក្រុមហ៊ុនធ្វើប្រព័ន្ធកាត់បន្ថយភាពល្អក់ ដោយជីកប្រឡាយជុំវិញ រួចទឹកហូរចេញពីប្រឡាយនេះចូលទៅក្នុងអាងរងកករទី១ទំហំ១០x១០x៣ម (បណ្តោយxទទឹងxជម្រៅ) បន្ទាប់មកទឹកនេះហូរចូលអាងរងកករទី២ មានទំហំ១០x១៥x៣ម (បណ្តោយ xទទឹងxជម្រៅ)។

ក្រុមហ៊ុនធ្វើការអប់រំបុគ្គលិក-កម្មករគម្រោងឱ្យយល់ដឹងអំពីអនាម័យ មិនបន្ទោរបង់ពាសវាលពាសកាល ស្គាល់នូវកន្លែងទុក ដាក់សម្រាម ដែលក្រុមហ៊ុនបានរៀបចំកសាងក្នុងទីតាំងស្នាក់នៅរបស់គម្រោង។

ក្រុមហ៊ុនចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ក្នុងការគ្រប់គ្រងសំណល់រាវ ដោយសាងសង់បង្គន់អនាម័យបន្ទប់ទឹកឱ្យឆ្ងាយពីមាត់ស្ទឹងដោយមានអាងសិបទិកត្រឹមត្រូវ ព្រមទាំងរៀបចំប្រមូលសំណល់រឹង និងសម្រាមយកទៅចោលនៅទីតាំងដែលមានសុវត្ថិភាពល្អ មិនឱ្យប៉ះពាល់បរិស្ថានជុំវិញ មិនឱ្យបោះចោល និងបង្ហូរចូលទៅក្នុង ឬខ្សែទឹកស្ទឹង ឬព្រែកឡើយ ដោយមានកន្លែងទុកដាក់សំណល់ រឹងល្អតាមបច្ចេកទេស។

ដើម្បីធ្វើឱ្យមានប្រសិទ្ធិភាពក្នុងការគ្រប់គ្រងសំណល់រឹងនោះ ក្រុមហ៊ុនត្រូវបោះស្លាកសញ្ញានៅក្នុង និងក្បែរតំបន់គម្រោង ដោយមានអក្សរខ្មែរ និងកូរ៉េអំពីការបំពុលទឹក។

សាងសង់អាងសិបទិកតាមបច្ចេកទេសសម្រាប់ទឹកកខ្វក់ចេញពីការិយាល័យបន្ទប់ទឹក បង្គន់ ផ្ទះបុគ្គលិក ដែលស្នាក់នៅបណ្តោះ អាសន្នក្នុងពេលសាងសង់គម្រោង។

សាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈ ឱ្យបានត្រឹមត្រូវតាមបទដ្ឋានសុវត្ថិភាពដល់បរិស្ថាន និងសង្គម។

ក្រុមហ៊ុនប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និងរថយន្តដឹកជញ្ជូន ដែលមានគុណភាពល្អមិនលេចហូរជាតិប្រេង ឬខ្លាញ់លើដី និងប្រភពទឹកក្នុងតំបន់គម្រោង។

ដើម្បីការពារការហូរច្រោះ ដែលអាចធ្វើឱ្យមានការបំពុលទឹកនោះ ក្រុមហ៊ុនត្រូវដាំព្រៃឈើឡើងវិញ នៅតាមកន្លែងចាក់ ចោលដីស្មុយ ឬសំណល់ថ្ម កន្លែងយកដី និងថ្ម។ ធ្វើការដាំស្មៅនៅជញ្ជាំងភ្នំ និងនៅជញ្ជាំងកន្លែងចាក់សំណល់ដី និងថ្ម ដែលខ្លួន បានធ្វើ។

Draft

ក្រុមហ៊ុនត្រូវធ្វើការគ្រប់គ្រង និងការពារសំណល់រឹង-រាវគ្រប់ប្រភេទមិនឱ្យបោះចោលនិងបង្ហូរចូលទៅក្នុង ឬក្បែរទឹកស្ទឹង ឬព្រៃកឡើយ ដូចជាសង់បន្ទប់ទឹក និងបង្គន់អនាម័យឆ្ងាយពីស្ទឹងមានអាងសិបទិកត្រឹមត្រូវមានកន្លែងទុកដាក់សំណល់រឹងល្អតាម បច្ចេកទេស។

ក្រុមហ៊ុនត្រូវសាងសង់បង្គន់អនាម័យ ដោយជីករណ្តៅ ដាក់លូដើម្បីស្តុកលាមកមានជម្រៅពី២,៥ ទៅ៣,៥ម ដើម្បីសំលាប់មេរោគ។ ចំពោះសំណល់ផ្ទះបាយវិញ គឺមិនបង្ហូរ ឬចាក់ចូលទៅក្នុងស្ទឹងពោធិ៍សាត់ទេ គឺជីករណ្តៅជម្រៅ១-២ម. ទំហំ៤ទៅ៦ម² ដើម្បីធ្វើឱ្យសំណល់នោះក្លាយជាជីកំប៉ុស្ត៍ និងត្រូវទាំងមានធុងទុកសម្រាប់ដាក់សម្រាម និងកន្លែងដុតសម្រាមចោលដោយសុវត្ថិភាព។

ម្ចាស់គម្រោង និងអ្នកម៉ៅការទាំងអស់ ត្រូវអនុវត្តអនុវត្តជាប្រចាំនូវ ផែនការគ្រប់គ្រងសំណល់គ្រប់ប្រភេទ ដែលមានចែងក្នុងជំពូក ៤ចំណុច ៤.៦.១១។

### ក.៦ គុណភាពខ្យល់

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលសាងសង់នេះ បំពុលខ្យល់ដោយសារការដុតព្រៃឈើ ដើម្បីសំអាតការដ្ឋាន និងផ្សែងដែលបំភាយចេញពីគ្រឿងចក្រសាងសង់ រថយន្តដឹកជញ្ជូនសម្ភារ និងការបំផ្ទុះសម្រាប់ការងារសាងសង់របស់គម្រោង។

ការបំពុលខ្យល់ ដោយសារធូលីដីថ្ម ហុយចេញពីការដឹកជញ្ជូនសម្ភារសំណង់ចេញពីការកិនបំបែកថ្ម ចេញពីផ្លូវដែលមិនបានស្រោចទឹកជាប្រចាំធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់កម្មករ អ្នកធ្វើដំណើរ និងសត្វរស់នៅក្បែរនោះទៀតផង។

ម៉្យាងទៀតអាចនឹងបំពុលខ្យល់ដោយសារភ្លើងឆេះព្រៃបណ្តាលមកពីការធ្វេសប្រហែសពីបុគ្គលិកកម្មករគម្រោង។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនមិនដុតព្រៃឈើទាំងអស់ នៃតំបន់នឹងត្រូវលិចនោះទេ គឺក្រុមហ៊ុនធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ និង ក្រសួងបរិស្ថាន ដើម្បីធ្វើការសំអាតព្រៃក្នុងតំបន់ ដែលនឹងត្រូវលិច ដូចជា: ក្រសួងអាចលក់ឈើឱ្យក្រុមហ៊ុនផ្សេងដែលក្រុមហ៊ុននេះ ត្រូវកែច្នៃឈើទាំងនោះឱ្យអស់លទ្ធភាព ដែលអាចធ្វើទៅបាន ហើយបានថវិកាចូលរដ្ឋថែមទៀតផង។ ចំណែកឯ មែកឈើ អាចកែច្នៃជាធ្យូងនិងឧសឱ្យអស់លទ្ធភាព ពោលគឺដុតតែមែកឈើតូចៗ និងស្លឹកឈើប៉ុណ្ណោះ។

ចំពោះមែកឈើ ដើមឈើដែលនៅក្នុងទីជ្រលង មិនអាចយកចេញមិនបាន ត្រូវកាប់ប្រមូលដុត ជាគ្នុក ឱ្យឆ្ងាយពីព្រៃមិនទាន់កាប់ចម្ងាយយ៉ាងហោចណាស់ ពី១៥ ទៅ២០ម.។ ការដុត មែកឈើ និងដើមឈើទាំងនេះត្រូវមានការប្រុងប្រយ័ត្នពីភ្លើងអាចរាលដាលបណ្តាលឱ្យមានភ្លើងឆេះព្រៃនៅជាប់នេះ។

ក្រុមហ៊ុនប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និងរថយន្តដឹកជញ្ជូន ដែលមានការបញ្ចេញផ្សែងតិច និងមានបំពង់ស៊ីម៉ុងជិតល្អ ដើម្បីកាត់បន្ថយការបំពុលខ្យល់ ក្នុងតំបន់នោះ។

ក្រុមហ៊ុនជ្រើសរើសជាតិផ្ទុះ ដែលមិនបង្កការបំពុលខ្យល់ខ្លាំង។ ជាងនេះទៅទៀត ក្រុមហ៊ុនត្រូវត្រៀមឧបករណ៍ពន្លត់អគ្គីភ័យ និង មានកន្លែងបូមទឹកគ្រប់គ្រាន់នៅពេលមានអគ្គីភ័យ។

ធ្វើការស្រោចទឹកជាប្រចាំលើផ្លូវ ដែលខ្លួនដឹកសម្ភារ និងកន្លែងកិនថ្ម ហើយធ្វើការគ្របគម្របលើ ដី ខ្សាច់ ថ្ម ស៊ីម៉ងត៍ នៅពេលដែលរថយន្តទាំងនោះដឹកវាឆ្លងកាត់ភូមិអ្នកស្រុក ទីប្រជុំជនជាដើម។

### ក.៧ គុណភាពដី

➢ ហេតុប៉ះពាល់អវិជ្ជមាន

Draft

ក្នុងសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គម្រោងនេះ មានការបំពុលដីដោយសារការកំពប់ នៃប្រេងឥន្ធនៈ ការកំពប់ នៃសារធាតុគីមី និងសំណល់រឹង-រាវគ្រប់ប្រភេទទៅលើដីដូចជាៈ សំណល់ចេញពី ឬលេចធ្លាយពីគ្រឿងចក្រ និងរថយន្តគ្រប់ ប្រភេទ ដែលដំណើរការគម្រោងនេះ ព្រមទាំងសំណល់ចេញពីផ្ទះបាយ។

បំពុលដីដោយសារការចាក់ដីស្អុយ ឬសំណល់ថ្ម ដែលដឹកចេញពីតំបន់គម្រោងនោះ ក៏អាចនឹងបង្កឱ្យមានផលប៉ះពាល់ដល់ស្រទាប់ដីខាងលើផងដែរ។

បំពុលដីដោយសារការគ្រប់គ្រងនូវសារធាតុផ្ទុះមិនបានល្អ ធ្វើឱ្យធ្លាក់ទៅលើដី។ ការឈូសឆាយព្រៃស្រទាប់លើនៅតាមតំបន់ ទីជម្រាលធ្វើឱ្យមានការហូរច្រោះដីនៅរដូវវស្សា និងមានសំណឹកដោយសារខ្យល់នៅរដូវប្រាំងក៏បានធ្វើដីបាត់បង់គុណភាពផងដែរ។

- វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវសាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈបានត្រឹមត្រូវមិនឱ្យកំពប់ ឬជ្រាបចូលដីឡើយ។

ក្រុមហ៊ុនត្រូវពង្រាបដី ឬថ្មដែលចាក់ចោលដោយយក ដីមានជីជាតិលប់ពីលើរួចដាំដើមឈើឡើងវិញក្នុងតំបន់នេះ ដោយធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ។

ក្រុមហ៊ុនត្រូវគ្រប់គ្រងសំណល់រឹងរាវគ្រប់ប្រភេទឱ្យបានត្រឹមត្រូវដូចជាៈ ចាត់វិធានការយ៉ាងតឹងរ៉ឹងមិនឱ្យចាក់ប្រេងម៉ាស៊ីនចាស់ៗ (ប្រេងបាត) ចោលទៅលើដី។

ជាងនេះទៅទៀត ក្រុមហ៊ុនធ្វើការដាក់ទណ្ឌកម្មដល់អ្នកដែលប្រព្រឹត្តិខុស ដូចជាៈ ស្តីបន្ទោសពិន័យ ឬការបណ្តេញពីការងារជាដើម។

### **ក.៨ សំឡេង និងរំញ័រ**

- ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គម្រោង ធ្វើឱ្យរំខានដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ដែលចេញចូលទីនោះ និងពពួកសត្វព្រៃ ដែលមាននៅក្នុង និងជុំវិញទីតាំងគម្រោងដោយសារមានសំឡេង និងរំញ័រចេញពីគ្រឿងចក្ររថយន្ត ម៉ាស៊ីនគ្រប់ ប្រភេទពេលកំពុងធ្វើការងារ ការបំផ្ទុះថ្ម ការកាប់រំលំដើមឈើធំៗ។ ល។

មានការប៉ះពាល់ ដោយសារសំឡេងពីភាពខ្សៀវខ្សាររអឹងកងពី បុគ្គលិកកម្មករគម្រោង ដែលមានជាមធ្យមប្រមាណ ៤០០នាក់ ធ្វើឱ្យរំខានដល់ការរស់នៅរបស់ប្រជាពលរដ្ឋ និងពពួកសត្វព្រៃដែលមាននៅក្នុង និងជុំវិញទីតាំងគម្រោងនោះផងដែរ។

- វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវប្រើប្រាស់គ្រឿងយន្ត និងមធ្យោបាយដឹកជញ្ជូន ដែលមានសំឡេងតិច។

ក្រុមហ៊ុនកំណត់តំបន់គ្រោះថ្នាក់ដោយសារការផ្ទុះនេះឱ្យបានច្បាស់លាស់ រួចដាក់ស្លាកសញ្ញាគ្រោះថ្នាក់នៅតាមព្រំប្រទល់ តំបន់នេះ ដើម្បីឱ្យកម្មករនិយោជិតគម្រោង និងប្រជាពលរដ្ឋងាយឃើញ និងស្គាល់។

ក្រុមហ៊ុនត្រូវធ្វើការកំណត់កម្រិតរញ្ជួយ និងកម្លាំងបំផ្ទុះឱ្យតូចដែលមិនប៉ះពាល់ដល់ការបាក់ផ្ទែកខ្លះនៃភ្នំ ឬផ្លូវដែលនៅក្បែរតំបន់បំផ្ទុះ ដូចជាការចោះរន្ធបំផ្ទុះយកថ្ម ជាក្រឡាចក្រត្រង្គ ដែលមាន ពី៣២ ទៅ ៤៥ រន្ធ ចម្ងាយពីរន្ធមួយទៅរន្ធមួយ៦ម និងមានជម្រៅខួងពី ៦ទៅ៧ម។ សមាសធាតុរួមផ្សំ ដើម្បីបំផ្ទុះក្នុងមួយរន្ធគិតជាមធ្យមគឺ ការអាម៉ូញ៉ូមនីត្រាត (Ammonium Nitrate) ចំនួន ២០គ.ក្រ. ប្រេងម៉ាស៊ូត ១.៤លីត្រ. រំសេវប្រភេទតានអិមមូលសិនអិចក្លូសស៊ីវ (TAN Emulsion Explosive) ចំនួន ១ គ.ក្រ និងគីបអគ្គិសនីពន្យាពេល ១គ្រាប់។

ជាងនេះទៅទៀត ក្រុមហ៊ុនផ្តល់ព័ត៌មាន និងផ្សព្វផ្សាយដល់អាជ្ញាធរ និងសហគមន៍មូលដ្ឋាននូវកាលបរិច្ឆេទ និងពេលវេលា បំផ្ទុះដើម្បីការពារសុវត្ថិភាពដល់កម្មករនិយោជិតគម្រោង និងប្រជាពលរដ្ឋដែលចេញចូលទីនោះ។

ចំពោះការបំផ្ទុះក្រុមហ៊ុនធ្វើនៅពេលរសៀល (ម៉ោង ៤:០០-៥:០០ល្ងាច)។

ក្រុមហ៊ុនកំណត់ពេលវេលាធ្វើការតែពេលថ្ងៃប៉ុណ្ណោះ ដើម្បីកាត់បន្ថយការរំខានដល់ប្រជាពលរដ្ឋ និងសត្វព្រៃក្នុងតំបន់ គម្រោងនេះ។

ក្រុមហ៊ុនធ្វើការអប់រំដល់បុគ្គលិកកម្មករគម្រោងឱ្យចេះស្ងៀមស្ងាត់នៅពេលម៉ោងសំរាក និងនៅពេលយប់។

***សម្គាល់:*** *ក្រុម ការងារសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនេះ បានសហការជាមួយមន្ទីរពិសោធន៍នៃក្រសួងបរិស្ថានធ្វើតេស្ត សំឡេងនិងរំញ័រនៅចំណុចដែលមានសកម្មភាពមមាញឹកជាងគេមុនការសាងសង់គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ គឺនៅក្បែរផ្លូវ ជាតិលេខ៥៥ ដោយលទ្ធផលបានបង្ហាញថានៅពេលថ្ងៃសំឡេងមានកម្រិតក្រោមស្តង់ដារបស់ក្រសួងបរិស្ថាន ក៏ប៉ុន្តែនៅពេលយប់ វេលាម៉ោង ៥ ទៅ៦ព្រឹក មានការលើសស្តង់ដាតិចតួចប៉ុណ្ណោះគឺ ៥០,៦dB ហើយបើគិតជាមធ្យមមាន ៥១,១៨dB រីឯស្តង់ដាមាន ៥០dB ។ ចំណែកឯរំញ័រវិញគឺស្ថិតនៅក្រោមស្តង់ដារបស់ក្រសួងបរិស្ថានវិញ។*

## ខ. ធនធានជីវសាស្ត្រ

### ខ១. ជីវសាស្ត្រដែលរស់នៅក្នុងទឹក /មច្ឆជាតិ

- ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលសាងសង់ហេដ្ឋារចនាសម្ព័ន្ធនេះ អាចប៉ះពាល់ដល់ផ្លូវចេញចូលរបស់មច្ឆជាតិ និងជីវសាស្ត្រនៅក្នុងទឹក ដោយសារក្រុមហ៊ុនទប់ទំនប់បណ្តោះអាសន្នកាត់ស្ទឹងពោធិ៍សាត់ដើម្បីសាងសង់ទំនប់វារីអគ្គិសនីនេះ។ ម៉្យាងវិញទៀតក្រុមហ៊ុនគ្មានគម្រោងសាងសង់ជណ្តើរត្រីឬសំណង់ ដែលសម្រាប់ឱ្យត្រីឆ្លងកាត់ពីខាងក្រោម ទៅតំបន់ខាងលើទំនប់បានទេ។

បន្ថែមពីលើនេះទៅទៀត វាក៏អាចប៉ះពាល់គុណភាពទឹកស្ទឹងពោធិ៍សាត់ ធ្វើឱ្យបំពុលដល់មច្ឆជាតិ និងជីវសាស្ត្រនៅក្នុងទឹក ដោយសារការធ្វើឱ្យល្អក់ទឹកបណ្តាលមកពីសកម្មភាពសាងសង់គម្រោង កន្លែងលាងថ្ម និងបំពុលទឹកដោយសារសំណល់រឹង-រាវ ចេញពីការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគម្រោង កន្លែងចាក់សំណល់ ដី-ថ្ម និងជំរុំបុគ្គលិក-កម្មករគម្រោង។

ម៉្យាងទៀតមានការបាត់បង់ធនធានជលផល ដោយសារបុគ្គលិក-កម្មករគម្រោង ប្រព្រឹត្តបទល្មើសជលផល ដូចជាបោកគ្រាប់បែក ឬប្រើគ្រឿងផ្ទុះដើម្បីចាប់យកត្រីក្នុងស្ទឹង តាមអន្លង់ជាដើមដែលធ្វើឱ្យហិនហោចបាត់បង់ពូជត្រីក្នុងតំបន់ ដូចជា ត្រីខ្យា ត្រីទ្រនេល ត្រីពោ ត្រីគល់រាំង ត្រីកាហែ ត្រីខ្នាវ ត្រីកញ្ចនជ័យ ត្រីក្រុសភ្នំ កន្ធាយ អណ្តើកទឹក និងក្រពើភ្នំ ជាដើម។

- វិធានការកាត់បន្ថយ

ក្រុមហ៊ុនបានគ្រោងសាងសង់ ចោះរូងកាត់ភ្នំធ្វើជាផ្លូវទឹកបង្វៀងការដ្ឋានទំនប់ ដោយមានជម្រាលបាតមិនចោទដើម្បីបង្កភាពងាយស្រួលដល់ការធ្វើចរាចរនៃជីវសាស្ត្រក្នុងទឹក ពីផ្នែកខាងក្រោមការដ្ឋានទៅផ្នែកខាងលើការដ្ឋានបាន។ ម៉្យាងវិញទៀត នៅកន្លែងលាងថ្ម លាយបេតុងក្រុមហ៊ុន ធ្វើប្រព័ន្ធកាត់បន្ថយភាពល្អក់ ដោយជីកប្រឡាយជុំវិញ រួចទឹកហូរចេញពីប្រឡាយនេះចូលទៅក្នុងអាងរងកករទី១ទំហំ១០x១០x៣ម (បណ្តោយxទទឹងxជម្រៅ) បន្ទាប់មកទឹកនេះហូរចូលអាងរងកករទី២ មានទំហំ ១០x១៥x៣ម (បណ្តោយxទទឹងxជម្រៅ)។ ធ្វើការដាំស្មៅនៅកន្លែងដែលខ្លួនបានកាយជញ្ជាំងភ្នំ ឬកន្លែងចំណោទផ្សេងៗ ដើម្បីធ្វើផ្លូវ ធ្វើទំនប់ និងធ្វើហេដ្ឋារចនាសម្ព័ន្ធគម្រោងដទៃទៀត ក្នុងការពារការហូរច្រោះ បាក់ជញ្ជាំងភ្នំបន្ថែម និងការពារភាពល្អក់ខ្លាំងហូរចូលស្ទឹង។

ក៏ប៉ុន្តែក្រុមហ៊ុនមានវិធានការ ដើម្បីជំនួសសំណង់សិល្បការសម្រាប់ឱ្យត្រីឆ្លងកាត់ ដោយសហការជាមួយរដ្ឋបាលជលផលរៀបចំកម្មវិធីព្រលែងត្រីក្នុងស្ទឹងខាងក្រោមទំនប់ ក្នុងអាង ដែលពូជត្រីជាពូជមាននៅក្នុងតំបន់គម្រោង។ ***សម្គាល់:*** *ចំពោះតម្លៃនៃសំណង់ជណ្តើរត្រីឆ្លងកាត់បាន មានតម្លៃរាប់លានដុល្លារ ដែលធ្វើឱ្យតម្លៃដើមរបស់អគ្គិសនីកើនខ្ពស់ផងដែរ។ មច្ឆជាតិគ្រប់ប្រភេទ ដែលឡើងមកពីខាងក្រោមទីតាំងទំនប់មិនអាចឆ្លងកាត់ស្ទឹងតំបន់នេះទៅខាងលើទំនប់បានឡើយក្រោយពីការសាងសង់ទំនប់នេះចប់។ ម្យ៉ាងទៀត នៅខាងលើទំនប់(ក្នុងអាង) ប្រាកដជាសម្បូរត្រីដែលមានក្នុងតំបន់ ដូចមានចែងក្នុង ជំពូក៥ ចំណុច៤*

*តារាង៥-៤៥។ ប៉ុន្តែអាចបាត់បង់ត្រីមួយចំនួន ដូចជា ត្រីក្រសក់ ត្រីគល់រាំង ត្រីសណ្តាយ ត្រីឆ្តោក ត្រីរៀល ត្រីក្អែក ជាដើម ពីព្រោះវាឡើងពីបឹងទន្លេសាប។*

ក្រុមហ៊ុនត្រូវគ្រប់គ្រងសំណល់រឹងគ្រប់ប្រភេទឱ្យបានល្អ រួចយកទៅចោលនៅទីតាំង ដែលមានសុវត្ថិភាពល្អឆ្ងាយពីប្រភពទឹក។ ម្ចាស់គម្រោង និងអ្នកម៉ៅការទាំងអស់ ត្រូវអនុវត្តអនុវត្តជាប្រចាំនូវ ផែនការគ្រប់គ្រងសំណល់គ្រប់ប្រភេទ ដែលមានចែងក្នុងជំពូក ៨ចំណុច ៨.៦.១១។

អប់រំដល់បុគ្គលិកកម្មករអំពីការបោះបង់សំណល់រឹង-រាវ ជាពិសេសការកំពប់ប្រេងឥន្ធនៈ ប្រេងរំអិលនៅលើដី និងក្នុងទឹកនៅក្នុងតំបន់គម្រោង។

ម្ចាស់គម្រោង ត្រូវព្យាយាមមិនឱ្យ ដី ឬថ្មធ្លាក់ចូលក្នុងអន្លង់ ដែលនៅជិតការដ្ឋានសាងសង់។ នៅពេលចប់ការសាងសង់ម្ចាស់គម្រោងត្រូវយកដុំថ្មធំៗចេញពីអន្លង់ទាំងនោះវិញប្រសិនបើមាន និងបើកទឹកលាងកករបាតស្ទឹងនៅខាងក្រោមទំនប់ផងដែរ នៅក្នុងដំណាក់កាលប្រតិបត្តិគម្រោងដំបូង។

អប់រំដល់បុគ្គលិកកម្មករអំពីមិនឱ្យប្រព្រឹត្តបទល្មើសជលផល ដូចជាការប្រើរំសេវធ្វើគ្រឿងផ្ទុះយកទៅបោកបំផ្ទុះ ត្រីក្នុងស្ទឹង តាមអន្លង់ជ្រៅៗការឆក់ត្រី ជាដើម ហើយបើនៅតែល្មើសត្រូវមានទោសតាមច្បាប់ជាធរមាន។

ក្រុមហ៊ុនត្រូវធ្វើការសហការជាមួយមន្ទីរកសិកម្ម រុក្ខា ប្រមាញ់និងនេសាទ(ជំនាញជលផល) ដែនជម្រកសត្វព្រៃភ្នំសំកុស ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល និងអង្គការ អភិរក្សនានា ក្នុងការទប់ស្កាត់បទល្មើស ទាំងនេះ។

ក្រុមហ៊ុនត្រូវជួយឧបត្ថម្ភដល់ប្រតិបត្តិការចាប់សត្វក្រពើភ្នំចេញតំបន់ ពីទំនប់វារីអគ្គិសនី និងការដោះលែងវាទាំងនោះនៅទៅជម្រកដែលមានសុវត្ថិភាពសមស្រប។

**ខ.២ ព្រៃការពារ/ តំបន់ការពារ/ ឧទ្យានជាតិ**

➢ ហេតុប៉ះពាល់អវិជ្ជមាន

គម្រោងនេះមានផ្ទៃដីសរុប៩.៣៥៥ហ.ត. ហើយក្នុងនោះមានតំបន់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍៤១៩៩,២០ហ.ត ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល៣៩៩.៧ហ.ត និងដែនជម្រកសត្វព្រៃភ្នំសំកុស៤.៧៥៦,១ហ.ត ដែលនឹងប៉ះពាល់ដល់គម្របព្រៃឈើសរុប៦.០០៧,២៤ហ.ត បង្កឱ្យមានផលប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់នេះយ៉ាងខ្លាំងផងដែរ។

ការបំពុលបរិស្ថាននៅក្នុងតំបន់អភិរក្ស ព្រៃការពារទាំងនេះ ដូចជា ការបំពុលខ្យល់ បំពុលទឹក ដោយសារសំណល់បញ្ចោញចោលពីកន្លែងសាងសង់ និងចេញពីកន្លែងស្នាក់នៅរបស់កម្មករ-បុគ្គលិក កន្លែងស្តុកគ្រឿង និងសម្ភារសំណង់ និងពីគ្រឿងចក្រដូចបានរៀបរាប់ខាងលើ ។

អាចមានការទន្ទ្រានចូលក្នុងព្រៃតំបន់កាពារទាំងនេះ ពីសំណាក់ក្រុមកម្មករ ក្រោយពីការងារដើម្បីរកអនុផលព្រៃឈើ ឬ ចាប់សត្វ ឬការទិញលក់ ចរាចរឈើ និងសត្វព្រៃជាដើម។

អាចនឹងមានការទន្ទ្រានកាន់កាប់យកដីព្រៃការពារ ដីតំបន់អភិរក្សទាំងនេះ ពីសំណាក់ជនឆ្លៀតឱកាសដោយសារគម្រោង ធ្វើផ្លូវតន្លងខ្សែចម្លង និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់របស់គម្រោង។

➢ វិធានការកាត់បន្ថយ

ម្ចាស់គម្រោង ត្រៀមថវិកាមូលនិធិបរិស្ថាន សរុបចំនួន ៦៦៧.៦៨០ដុល្លារអាមេរិកសម្រាប់ មួយជីវិតគម្រោង ៣៥ឆ្នាំ (គ្រោងថវិការជាវដ្ត១ (រយៈពេល១០ឆ្នាំ)) ក្នុងនោះមានសម្រាប់ដាំឈើឡើងវិញ និងបង្កើតសហគមន៍ការពារអភិរក្សព្រៃឈើ និងល្បាត, សម្រាប់ការព្រែងកូនត្រី អភិរក្សជលផល និងសង្គ្រោះក្រពើត្រី/ក្រពើភ្នំ ក្នុងការស្តារបរិស្ថានធម្មជាតិឡើងវិញ (លម្អិតមើលតារាង ៨-៣, ៨-៤, ៨-៥, ៨-៦ ក្នុងជំពូក៨ ចំណុច ៨.៨)។

កំណត់ពេលវេលាធ្វើការតែពេលថ្ងៃសម្រាប់ការងារទាំងឡាយណា ដែលបង្កសំឡេង និងរំញ័រ ដើម្បីកុំឱ្យមានការរំខានឬ ផ្អើល សត្វព្រៃ ក្នុងតំបន់គម្រោង និងតំបន់ក្បែរខាង។

Draft

ក្រុមហ៊ុនកំណត់កម្រិតរញ្ជួយ និងកម្លាំងបំផ្ទុះ និងប្រើប្រាស់ម៉ាស៊ីនដែលមានសំឡេងនិងរំញ័រតិច ដើម្បីកាត់បន្ថយការរំខានដល់ពពួកសត្វព្រៃ។

ក្រុមហ៊ុនសាងសង់បង្គន់អនាម័យ និងបន្ទប់ទឹកសម្រាប់អ្នកធ្វើការទាំងអស់នៅក្នុងការដ្ឋាន និងជំរំស្នាក់នៅរបស់គម្រោង។ រៀបចំការគ្រប់គ្រងសំណល់រឹង-រាវឱ្យបានត្រឹមត្រូវមានសុវត្ថិភាពជាពិសេសមិនឱ្យបំពុលបរិស្ថានក្នុងតំបន់អភិរក្សទាំងនោះ។

ក្រុមហ៊ុនធ្វើការអប់រំ និងដាក់វិន័យដល់កម្មករគម្រោងមិនឱ្យធ្វើ ការទន្ទ្រានព្រៃក្នុងតំបន់អភិរក្សទាំងនោះ ដើម្បីចាប់ឬបរបាញ់ ចរាចរឈើ និងសត្វព្រៃដោយសហការជាមួយក្រសួងបរិស្ថាន រដ្ឋបាលព្រៃឈើ និងអង្គការអភិរក្សានានាដោយដាក់ស្លាកសញ្ញាព្រៃការពារ និងហាមបរបាញ់ជាអក្សរខ្មែរ និងកូរ៉េ ឬអង់គ្លេសឱ្យបានច្រើន ដើម្បីឱ្យប្រជាពលរដ្ឋ និងជនបរទេសងាយមើលឃើញ។

ក្រុមហ៊ុនសហការជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីការពារ ទប់ស្កាត់កុំឱ្យមានការរំលោភកាន់កាប់ដី នៅតំបន់អភិរក្សទាំងនោះ (មានលម្អិតនៅចំណុច II ស្តីពីខ្សែបញ្ជូនអគ្គិសនី) និងដាក់ប៉ាណូធំៗ របៀបរូបខាងក្រោមត្រង់ចំណុចខ.៣ ខាងក្រោម។ ជាងនេះទៅទៀត ម្ចាស់គម្រោងត្រូវសហការជាមួយសាមីក្រសួងជំនាញ (ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម) ធ្វើការ ដាក់ស្លាកសញ្ញាតំបន់ ដែលត្រូវសំអាតផ្ទៃអាងចំនួន៨.៥៩១ហ.តឱ្យច្បាស់លាស់ និងមានអ្នកល្បាតត្រួតពិនិត្យនូវសាកសញ្ញា នេះជាប្រចាំដោយជឿជាក់ថាមិនមានការកាប់ឈើលើសពីឈើពីព្រំដែលបានដាក់ស្លាកសម្គាល់នោះទេ កុំឱ្យកម្មករ ក្រុមហ៊ុនដែលម៉ៅការសំអាតអាង កាប់ឈើទន្ទ្រានចូលលើសផ្ទៃដីដែលបានកំណត់ឱ្យកាប់សំអាត។

### ខ.៣ ធនធានព្រៃឈើ និងជម្រកសត្វព្រៃ

➢ ហេតុប៉ះពាល់អវិជ្ជមាន

គម្រោងនេះប៉ះពាល់ដល់ផ្ទៃដីព្រៃឈើសរុប ៦,០០៧,២៤ ហ.ត ក្នុងនោះមាន ព្រៃស្រោង ៨៦៥,៤៦ហ.ត (មានឈើ៩៦ ប្រភេទ) ព្រៃពាក់កណ្តាលស្រោង ៨៥០,២៥ហ.ត (មានឈើ៧៦ប្រភេទ) និងព្រៃល្បោះ ៤.២៩១,៥ហ.ត (មានឈើ៨៨ប្រភេទ)។ ព្រៃឈើទាំងនេះជាជម្រកសត្វព្រៃជាច្រើនប្រភេទ ដូចមានចែងក្នុងជំពូក៥ ចំណុច ៥.១.២.១ ។

ម៉្យាងវិញទៀត អាចនឹងមានការទន្ទ្រានចាប់ដីធ្វើកម្មសិទ្ធិពីសំណាក់ជនឆ្លៀតឱកាសមួយចំនួនក្នុងព្រៃការពារដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងតំបន់ការពារ ទាំងនេះរបស់រដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន ដោយសារមានការអភិវឌ្ឍវារីអគ្គិសនីនៅតំបន់ នេះដូចជាមានផ្លូវចេញចូលល្អស្រួលធ្វើដំណើរ ប្រមោយ-ពោធិ៍សាត់ជាដើម។

បន្ថែមពីលើនេះអាចមានការទន្ទ្រានចូលព្រៃការពារក្បែរនិងជុំវិញតំបន់គម្រោង ដើម្បីរកកាប់ឈើប្រណិត (ក្រញូង បេង ជាដើម) និងឈើសំណង់គ្រប់ប្រភេទ ពីសំណាក់ជនឆ្លៀតឱកាស តាមមធ្យោបាយគ្រប់រូបភាព ពីព្រោះអាងតែខ្លួនទទួលបាននូវអាជ្ញាបណ្ណ នាំឈើចេញក្រៅតំបន់នេះពីរាជរដ្ឋាភិបាលក្នុងការសំអាតដីព្រៃឈើដែល និងត្រូវលិចក្នុងតំបន់អាងដែលមានដីព្រៃ ៥.៨៣៥,៦ហ.ត ជាដើម។

មួយវិញទៀត ការបោះបង្គោលព្រំអាង និងតំបន់ដែលត្រូវសម្អាតមិនបានត្រឹមត្រូវ នាំឱ្យមានការកាប់ឈើលើសពីទីតាំងកំណត់ ប៉ះពាល់ដល់ធនធានព្រៃឈើ និងជម្រកសត្វព្រៃបន្ថែមទៀត។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនធានាមិនកាប់ព្រៃឈើ នៅក្រៅពីទីតាំងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដែលមានបង្ហាញនៅក្នុងប្លង់រចនាគម្រោងលម្អិតឡើយ។ ម៉្យាងទៀតក្រុមហ៊ុនព្យាយាមរក្សាទុកព្រៃនៅតំបន់នេះចំនួន៤៣១,១៧ហ.ត ដោយមិនឱ្យឈូសឆាយ និងកាប់ទាំងស្រុងនោះទេពោល គឺសំអាតនៅកន្លែង ដែលសាងសង់សំណង់ជាក់ស្តែងប៉ុណ្ណោះ (ចំពោះកន្លែង ដែលត្រូវសាងសង់ទាំងនេះមើលផែលទី លេខ២ )។

ក្រុមហ៊ុនធ្វើការប្រឹក្សាជាមួយរដ្ឋបាលព្រៃឈើ អង្គការអភិរក្សនានា ដែលពាក់ព័ន្ធ និងដែនជម្រកសត្វព្រៃភ្នំសំកុសរកទីតាំងសមស្របក្នុងតំបន់ ក្បែរព្រៃដែលបាត់បង់នេះសម្រាប់ដាំឈើទុកជាជម្រកដល់សត្វព្រៃផង និងដើម្បីរក្សាលំនឹងអេកូឡូស៊ីបរិស្ថានក្នុងតំបន់នេះជាពិសេសព្រៃឈើស្រូបទាក់ទាញទឹកភ្លៀងដែលជាប្រភពសម្រាប់វារីអគ្គិសនីទៀតផង។

ក្រុមហ៊ុនធ្វើការការសហការជាមួយអន្តរក្រសួង ដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមានដែលអាចកើតមានជាយថាហេតុលើព្រៃឈើដែលនៅជាប់នឹងតំបន់គម្រោងក្នុងដំណាក់កាលនៃការសាងសង់នេះ។

ក្រុមហ៊ុនត្រូវធ្វើការសហការជាមួយអន្តរក្រសួង ក្នុងការដាក់ដេញថ្លៃប្រមូលផលអនុផលឈើ ចូលជាថវិកាជាតិ និងដើម្បីធ្វើការសំអាតព្រៃក្នុងតំបន់ដែលនឹងត្រូវលិច តំបន់ហេដ្ឋារចនាសម្ព័ន្ធ និងអាគារថាមពល ដូចជាក្រសួងអាចលក់ឈើឱ្យក្រុមហ៊ុនផ្សេងទៀត ដែលក្រុមហ៊ុននេះត្រូវកែច្នៃឈើ ទាំងនោះឱ្យអស់លទ្ធភាព ដែលអាចធ្វើទៅបានហើយបានថវិកាចូលរដ្ឋថែមទៀតផង។ ម៉្យាងទៀតនៅក្នុងតំបន់សាងសង់ហេដ្ឋារចនា សម្ព័ន្ធគម្រោង (តំបន់២)ក្រុមហ៊ុនមិនធ្វើការឈូសឆាយកាប់ព្រៃឈើទាំង ៥៥៩,៩១ហ.តនោះទេ គឺខិតខំព្យាយាមរក្សាទុកតំបន់ ព្រៃចំនួន ៤៣១,១៧ហ.ត។

ក្រុមហ៊ុន ត្រូវបោះបង្គោលព្រំ ក្នុងការកាប់សម្អាតផ្ទៃអាងឱ្យបានច្បាស់ គឺចម្ងាយ ៥០មឬ ១០០ម មួយដោយប្រើឧបករណ៍ ឋានលេខា ដើម្បីបញ្ជាក់កម្រិតនីវូអាង ១៨០ម ដែលត្រូវសម្អាតជាងវាងការកាប់ឈើលើសតំបន់កំណត់។

ម្ចាស់គម្រោង ត្រៀមថវិកាមូលនិធិបរិស្ថាន សរុបចំនួន ៦៦៧.៦៨០ដុល្លារអាមេរិកសម្រាប់ មួយជីវិតគម្រោង ៣៥ឆ្នាំ (គ្រោងថវិការជាវដ្ត១ (រយៈពេល១០ឆ្នាំ)) ក្នុងនោះមានសម្រាប់ដាំឈើឡើងវិញ និងបង្កើតសហគមន៍ការពារអភិរក្សព្រៃឈើ និងល្បាត, សម្រាប់ការព្រែងកូនត្រី អភិរក្សជលផល និងសង្គ្រោះក្រពើត្រី/ក្រពើភ្នំ ក្នុងការស្តារបរិស្ថានធម្មជាតិឡើងវិញ (លម្អិតមើលតារាង ៨-៣, ៨-៤, ៨-៥, ៨-៦ ក្នុងជំពូក៨ ចំណុច ៨.៨)។

*__សម្គាល់៖__ មូលនិធិបរិស្ថានសម្រាប់រយៈពេល៣៥ឆ្នាំ គឺ៦៦៧.៦៨០ $ និងមូលនិធិសង្គមសរុប ១៥៨.៨០០$ លម្អិតមើលតារាង ៨-៣, ៨-៤, ៨-៥, ៨-៦ ក្នុងជំពូក៨ ចំណុច ៨.៨។*

ក្រុមហ៊ុនសហការជាមួយរដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន និងអង្គការអភិរក្សនានា ក្នុងការទប់ស្កាត់ការ រានដីយកធ្វើកម្មសិទ្ធិខុសច្បាប់ ដោយបង្កើនកម្លាំងការពារ និងត្រួតពិនិត្យឱ្យបានហ្មត់ចត់។

ក្រុមហ៊ុនត្រូវដាក់ស្លាកសញ្ញា ឬសរសេរជាផ្ទាំងប៉ាណូធំដូចនៅតាមផ្លូវទៅកោះកុង ដូចជាសរសេរថា ព្រៃការពារហាមទន្ទ្រាន កាន់កាប់ធ្វើជាកម្មសិទ្ធហាមកាប់ឈើ ឬបរបាញ់ខុសច្បាប់ ជនល្មើសត្រូវជាប់ទោសដាក់គុករហូតដល់១០ឆ្នាំជាអក្សរខ្មែរ និងកូរ៉េឬអង់គ្លេសឱ្យ បានច្រើន ដើម្បីឱ្យប្រជាពលរដ្ឋ និងជនបរទេសងាយមើលឃើញក្នុងតំបន់គម្រោង។







Draft

## ខ.៤ ជីវសាស្រ្ត សត្វព្រៃ

➢ ហេតុប៉ះពាល់អវិជ្ជមាន

តំបន់គម្រោងនេះមានសត្វព្រៃជាច្រើនប្រភេទដែលរស់នៅ ហើយប្រភេទសត្វមួយចំនួនកំពុងត្រូវបានធ្វើការអភិរក្សដោយរាជរដ្ឋាភិបាល។ សត្វព្រៃ ទាំងនេះមានដូចជាៈ ថនិកសត្វចំនួន ៤៤ ប្រភេទ (ក្នុងបញ្ជីក្រហម IUCN មាន១៧ប្រភេទ), បក្សី ១២០ប្រភេទ(ក្នុងបញ្ជីក្រហម IUCN មាន១ប្រភេទ), ឧរង្គសត្វ និងថលជលិកសត្វ ៦៣ប្រភេទ(ក្នុងបញ្ជីក្រហម IUCN មាន៧ប្រភេទ), និងមច្ឆជាតិទឹកសាប៨៣ប្រភេទ (ក្នុងនោះមានក្រពើត្រីឬក្រពើភ្នំ) ក្នុងស្ទឹងពោធិ៍សាត់ ដូចមានចែង ក្នុងជំពូក៥ ចំណុច៥.២.៥។ សកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនីនេះ (លម្អិតហេដ្ឋារចនាសម្ព័ន្ធគម្រោងមានចែងក្នុងជំពូក៤)អាចមានការបាត់បង់ឬថយចុះនូវសត្វព្រៃមួយចំនួនដូចជាៈ ខ្លារខិន ទន្សោង ខ្ទីង កែះ ពង្រូលស្វាន ឈ្លូស ប្រើស ពពូកពស់ ជ្រូកព្រៃ ត្រីខ្យា ពពួកអណ្តើក ជាដើម ដោយសារបាត់ទីជម្រក ឬផ្តាច់ផ្លូវទំនាក់ទំនងរបស់វា។ *__សម្គាល់__ៈ ក្នុងពេលសិក្សានិងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនេះ (ខែកុម្ភៈ ដល់ខែកញ្ញា ឆ្នាំ២០១២ និងខែកញ្ញា ឆ្នាំ២០១៥)មិនឃើញមានដានដំរី ខ្លាធំ ខ្លារឿងមាស ខ្លាពពកទេ ប៉ុន្តែតាមការប្រឹក្សាយោបល់ ជាមួយ អ្នក ស្រុកមូលដ្ឋានដែលគាត់រស់នៅក្នុងតំបន់នេះគាត់ធ្លាប់ជួបប្រទះពួកវាទាំងនេះ ក្នុងកំឡុងឆ្នាំ២០០០ ដល់២០០៣កន្លងមក តែឥឡូវ ដោយសារក្នុងតំបន់នេះមានមនុស្សចេញចូល និងមករស់នៅកាន់តែច្រើន ធ្វើឱ្យពួកវាមិនហ៊ានមកក្បែរតំបន់នេះ។*

សកម្មភាពកាប់ឆ្ការគម្របព្រៃឈើ ការឈូសឆាយដី ការបំផ្ទុះថ្ម ការដឹកជញ្ជូនសម្ភារសាងសង់នឹងនាំឱ្យមានការភ័យខ្លាច និងបង្អាក់ការបំលាស់ទី ដល់សត្វព្រៃទាំងនោះ ជាពិសេសប្រភេទជិតផុតពូជ (តាមបញ្ជីក្រហម IUCN ពង្រួល) ប្រភេទកំពុងរងគ្រោះ (ទន្សោង ឈ្លូសយក្ស ឆ្កែព្រៃ ភេរោមច្រមុះ ទោចម្ពុជ ខ្លាត្រី) ដោយសារមានសំឡេងរំខានខ្លាំងៗ ចេញពីម៉ាស៊ីនគ្រឿងយន្តគ្រឿងផ្ទុះ សំឡេងខៀវខ្វាររបស់បុគ្គលិក-កម្មករគម្រោង និងការព័ទ្ធកាប់បំផ្លាញជម្រកវា។

ការជ្រើសរើសនូវបុគ្គលិកកម្មករជាមធ្យម ៤០០នាក់ ចូលមកធ្វើការនៅតំបន់នេះសម្រាប់ការសាងសង់គម្រោងនឹងអាចមាន សកម្មភាពបរបាញ់ឬចាប់សត្វ ឬចូលព្រៃពីសំណាក់បុគ្គលិក-កម្មករគម្រោងទាំងនោះធ្វើឱ្យផ្អើល និងបាត់បង់សត្វព្រៃទៀតផង។

ការជួញដូរសត្វព្រៃនៅតំបន់គម្រោងអាចមានការកើនឡើង ដូចជាការយកធ្វើម្ហូប ការធ្វើថ្នាំបុរាណជាដើម ។ល។ ធ្វើឱ្យហិន ហោចបាត់បង់សត្វព្រៃពីតំបន់ការពារទាំងនេះ។

- វិធានការកាត់បន្ថយ

ម្ចាស់គម្រោង ត្រៀមថវិកាមូលនិធិបរិស្ថាន សរុបចំនួន ៦៦៧.៦៨០ដុល្លារអាមេរិកសម្រាប់ មួយជីវិតគម្រោង ៣៥ ឆ្នាំ (គ្រោងថវិការជាវដ្ត១ (រយៈពេល១០ឆ្នាំ)) ក្នុងនោះមានសម្រាប់ដាំឈើឡើងវិញ និងបង្កើតសហគមន៍ការពារអភិរក្សព្រៃឈើ និងល្បាត, សម្រាប់ការព្រែងកូនត្រី អភិរក្សជលផល និងសង្គ្រោះក្រពើត្រី/ក្រពើភ្នំ ក្នុងការស្តារបរិស្ថានធម្មជាតិឡើងវិញ (លម្អិតមើលតារាង ៨-៣, ៨-៤, ៨-៥, ៨-៦ ក្នុងជំពូក៨ ចំណុច ៨.៨)។

ក្រុមហ៊ុនកំណត់ពេលវេលាធ្វើការតែពេលថ្ងៃសម្រាប់ការងារទាំងឡាយណាដែលបង្កសំឡេង និងរំញ័រ ដើម្បីកុំឱ្យមានការរំខាន ឬផ្អើលសត្វព្រៃក្នុងតំបន់គម្រោង និងតំបន់ជិតគម្រោង។

ម្ចាស់គម្រោង និងអ្នកម៉ៅការ ត្រូវបង្កលក្ខណៈ ឱ្យមានការបម្លាស់ទីរបស់សត្វព្រៃដូចជា៖ ការកាប់សម្អាតព្រៃឈើបាតអាង មិនត្រូវឱ្យកម្មករកាប់ផ្តាច់ជាគន្លងព័ទ្ធជុំវិញ (ដូចជាកោះ) ដែលបង្ខាំងសត្វព្រៃនៅកណ្តាល ពោលគឺកាប់សម្អាតឈើពីមាត់ស្ទឹងឡើងទៅលើ ដើម្បីឱ្យសត្វព្រៃអាចបម្លាស់ទីចូលទៅតំបន់ភ្នំបានផងដែរ។

ការកំណត់កម្រិតរញ្ជួយ និងកម្លាំងបំផ្ទុះ និងប្រើប្រាស់ម៉ាស៊ីន ដែលមានសំឡេងនិងរំញ័រតិចនឹងត្រូវអនុវត្ត ដើម្បីកាត់បន្ថយការរំខានដល់ពពួកសត្វព្រៃទាំងនេះ។

បន្ថែមពីលើនេះ ក្រុមហ៊ុនអប់រំ និងដាក់វិន័យដល់បុគ្គលិកកម្មករគម្រោងមិនឱ្យធ្វើការចាប់ ឬបរបាញ់សត្វព្រៃ និងធ្វើជាបរលក់ដូរសត្វព្រៃនៅក្នុងតំបន់នេះឡើយ។ ព្រមទាំងក្រុមហ៊ុនត្រូវដាក់ស្លាកសញ្ញា ឬសរសេរជាផ្ទាំងប៉ាណូធំ ដូចនៅតាមផ្លូវទៅកោះកុង ដែលសរសេរថា ព្រៃការពារ ហាមទន្ទ្រាន កាន់កាប់ធ្វើជាកម្មសិទ្ធ និងហាមបរបាញ់ ជនល្មើសត្រូវជាប់ទោសដាក់គុកហូតដល់១០ឆ្នាំ ជាអក្សរខ្មែរ និងកូរ៉េ ឬអង់គ្លេសឱ្យបានច្រើន ដើម្បីឱ្យប្រជាពលរដ្ឋ និងជនបរទេសងាយមើលឃើញក្នុងតំបន់គម្រោង។

ក្រុមហ៊ុនចូលរួមសហការជាមួយក្រសួងបរិស្ថាន រដ្ឋបាលព្រៃឈើ និងអង្គការអភិរក្សនានា ដើម្បីទប់ស្កាត់បទល្មើសសត្វព្រៃ និងព្រៃឈើ។

### គ. ធនធានសេដ្ឋកិច្ចសង្គម

### គ.១ ការប្រើប្រាស់ដី និងការតាំងលំនៅឡើងវិញ

- ហេតុប៉ះពាល់អវិជ្ជមាន

ការសាងសង់គម្រោងនេះ ប៉ះពាល់ការប្រើប្រាស់ដីរបស់ប្រជាពលរដ្ឋសរុបចំនួន២.៣២៩,២៥ហ.ត ដែលកាន់កាប់ដោយ ៣៤៧ គ្រួសារ ក្នុងនោះមាន ដីកសិកម្ម (ស្រែ និងចំការ) ចំនួន ៩៣២,១២ហ.ត, ដីលំនៅដ្ឋាន ៣៨,៤៤ហ.ត, និងដីបុស្ស ១.០៦៨,៣៩ហ.ត។

គម្រោងនេះ ក៏ធ្វើឱ្យប៉ះពាល់ដល់សហគមន៍តំបន់ការពារធម្មជាតិ២ គឺសហគមន៍តំបន់ការពារធម្មជាតិស្រែពាំង ចំនួន ៣៤១,៧៣ហ.ត ត្រូវជា ៦៨% (ផ្ទៃដីសរុប ៥០០ហ.ត) និងសហគមន៍តំបន់ការពារធម្មជាតិស្ទឹងថ្មីចំនួន៩,៨៩ហ.ត ត្រូវជា ២% (ផ្ទៃដីសរុប៤៦៣,៤ហ.ត)ផងដែរ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រៀមថវិកាចំនួន ៦.៨៣៣.០១៦ដុល្លារអាមេរិក សម្រាប់សំណង និងការអភិវឌ្ឍ តំបន់ថ្មីសម្រាប់អ្នកប៉ះពាល់ដោយសារគម្រោងនេះ ៣៤៧គ្រួសារ។ ចំពោះសំណង មាន៣ករណី ដូចមានចែងរួចមកហើយក្នុងដំណាក់កាលរចនាគម្រោង ចំណុច គ.១ ផងដែរ។

ក្រុមហ៊ុនត្រូវសហការជាមួយរដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន និងក្រសួងរៀបចំដែនដីនគរូបណីយកម្ម និងសំណង់ ដើម្បីពិនិត្យលទ្ធភាពស្នើសុំរាជរដ្ឋាភិបាលលើផ្ទៃដី និងទីតាំងដែលត្រូវផ្តល់ជូនគ្រួសារ ដែលទទួលផលប៉ះពាល់ដោយសារគម្រោងនេះ។

ក្រុមហ៊ុនត្រូវធ្វើផែនការបំលាស់ប្តូរលំនៅដ្ឋាន របស់ប្រជាពលរដ្ឋក្នុងតំបន់១ (តំបន់អាងទឹក) និងបង្កើតតំបន់តាំងលំនៅឋានថ្មី ឱ្យបានមុនយ៉ាងតិច១ឆ្នាំ មុននឹងធ្វើការបិទទ្វារទឹកបំពេញអាងនេះ។ ***សម្គាល់:*** *ក្រុមការងារ SAWAC បានសិក្សាតំបន់ ៤ ដែលជាដី ស្ថិត ក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍(ប្រមោយ)មានផ្ទៃដីចំនួន ១៧៦,៨៩ ហ.ត និងដែនជម្រកសត្វព្រៃភ្នំសំកុសចំនួន ១៣,៥៦ ហ.ត ហើយមានបំរុងទុក ៥០ ហ.ត ទៀត តែមិនបានដាក់ បញ្ចូលក្នុងផ្ទៃដី គម្រោងទេ (មើលផែនទី៣ និងទី៤) ហើយស្ថិតនៅក្បែរតំបន់គម្រោងមានលក្ខណៈ សមស្របសម្រាប់ធ្វើការតាំងលំនៅឋានថ្មី និងជាដីកសិកម្ម សម្រាប់អ្នកប៉ះពាល់ដោយសារគម្រោងទាំងនោះ។ ទីតាំងតំបន់តាំងលំនៅឋានថ្មី នេះក៏មានការ យល់ព្រមពីអ្នកប៉ះពាល់ដែលបានជួបសម្ភាស ៣១៥ គ្រួសារ (៩៦%) នៃ ៣៤៧គ្រួសារប៉ះពាល់។*

ចំពោះដីសហគមន៍ នៃតំបន់ការពារទាំងនោះ គឺសហគមន៍តំបន់ការពារធម្មជាតិស្រែពាំង មានសំណង ១០២,៥១៩ ដុល្លារអាមេរិក និងសហគមន៍តំបន់ការពារធម្មជាតិស្ទឹងថ្មីមានសំណង ២.៩៦៧ដុល្លារអាមេរិក។ សំណងទាំងនេះជួយឱ្យសហគមន៍ធ្វើការដាំឈើ និង ធ្វើប៉ុស្តិ៍ការពារនៃតំបន់ព្រៃឈើទាំងនេះដែលនៅសល់។

នៅពេលចាប់ផ្តើមការសាងសង់គម្រោង ម្ចាស់គម្រោងត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការផ្សព្វផ្សាយ ពីការដាំដំណាំ ដែលមានអាយុកាលវែង ដូចជាក្រូច ស្វាយ ធូរេន ។ល។ មិនឱ្យដាំបន្ថែម។ ក៏ប៉ុន្តែ ដំណាំមានអាយុកាលខ្លី (ដំណាំរិលល្វាច)ដូចជា ពោត សណ្តែក ល្ង ស្រូវ អាចដាំបានហើយត្រូវជូនដំណឹង ច្បាស់លាស់ នៃកាលបរិច្ឆេទនៃការបិទទឹកតម្កល់ក្នុងអាងផងដែរ។

### គ.២ ការរស់នៅ និងមុខរបររបស់សហគមន៍មូលដ្ឋាន

➢ ហេតុប៉ះពាល់អវិជ្ជមាន

ដូចបានរៀបរាប់ ក្នុងចំណុច គ.១ ខាងលើ មានប្រជាជនចំនួន ៣៤៧គ្រួសារ នឹងរងការប៉ះពាល់ដោយសារការអភិវឌ្ឍ គម្រោងវារីអគ្គិសនីនេះ ក្នុងនោះមានប្រជាជន ៩៦គ្រួសារ នឹងត្រូវបាត់បង់ចំណូល ដោយសារពួកគេបាត់បង់ដីកសិកម្មចាប់ពី ៥០% ឡើងទៅ។

ដោយសារការអភិវឌ្ឍ គម្រោងនៅតំបន់ខាងលើក្នុងស្ទឹងពោធិ៍សាត់ នឹងមានមនុស្សចេញចូលរាប់ពាន់នាក់ (បុគ្គលិក-កម្មករ គម្រោងជាមធ្យម ៤០០នាក់ រួមទាំងគ្រួសារនៃជនទាំងនោះផងដែរ) ដែលនឹងអាចមានការការនេសាទក្នុងស្ទឹង និងក្នុងអូរ ក្នុងនិងជុំវិញតំបន់គម្រោង ជាពិសេសនៅរដូវវស្សា របស់ជនចំណូលថ្មីទាំងនោះនឹងធ្វើឱ្យថយចុះទិន្នផលនេសាទ របស់អ្នកភូមិក្នុង និងក្បែរតំបន់នេះ។ ដូចគ្នាដែរចំពោះអនុផលព្រៃឈើ (ផ្សិត ឬស្សី ផ្តៅ) ក៏អាចមានការកើនឡើងពីអ្នកចំណូលថ្មីទាំងនេះ ជាពិសេសការកាប់ឈើក្រៅតំបន់ នាំឱ្យប៉ះពាល់ដល់ចំណូលអនុផលព្រៃឈើរបស់អ្នកស្រុកមូលដ្ឋាន និងព្រៃឈើ សត្វព្រៃផងដែរ។

ម៉្យាងទៀត ប្រជាពលរដ្ឋ អាចមានការប៉ះពាល់ដល់មុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ពួកគាត់ផងដែរ ព្រោះពួកគាត់មកធ្វើកម្មករឱ្យក្រុមហ៊ុនកូរ៉េ តែមិនបានទទួលប្រាក់ពលកម្មគ្រប់ចំនួនបើកប្រាក់ឈ្នួលមិនទៀងទាត់ និងមិនបើកប្រាក់ឈ្នួលឱ្យគ្រប់ចំនួនថ្ងៃ ដែលពួកគាត់បានធ្វើការ។ ម៉្យាងទៀត អាចមានការរើសអើងពូជសាសន៍ពីព្រោះគម្រោងនេះមានមេការជាជនជាតិបរទេស ហើយគ្មានអ្នកបកប្រែច្បាស់លាស់ដែលធ្វើឱ្យស្តាប់គ្នាមិនបាន អាចបង្កជាទំនាស់ រវាងកម្មករជនបរទេស និងខ្មែរ អាចក្លាយជាបទល្មើស ព្រហ្មទណ្ឌទៀតផង។

Draft

បុគ្គលិក-កម្មករ អាចនឹងរងការប៉ះពាល់ដល់មុខរបរ និងខាតពេលវេលារកទទួលទានផងដែរ ដោយសារក្រុមហ៊ុនមិនបានផ្តល់សម្ភារការពារគ្រោះថ្នាក់ដូចជាៈ មួកការពារ ស្បែកជើង ស្រោមដៃ ខោ អាវ ជាដើម។ល។ ដែលមិនអាចការពារពពួកគេបាន នៅពេលដែលមានគ្រោះថ្នាក់ការងារដោយចៃដន្យណាមួយនោះ។

ជាងនេះទៅទៀត ការបំផ្ទុះថ្មសម្រាប់បម្រើការនានា ក្នុងការសាងសង់គម្រោងនេះ អាចប៉ះពាល់ផ្លូវចេញចូលរបស់ប្រជាពលរដ្ឋក្នុងតំបន់ដោយសារថ្ម ឬដីបាក់រលំលើកំណាត់ផ្លូវ ហើយការងារនេះក៏អាចប៉ះពាល់ដល់អាយុជីវិតមនុស្សផងដែរ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវសហការជាមួយអាជ្ញាធរភូមិ ឃុំ ពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយពីផែនការអភិវឌ្ឍនេះ ជូនប្រជាពលរដ្ឋក្នុងភូមិទាំង នេះឱ្យបានដឹង និងណែនាំប្រជាពលរដ្ឋអំពីការពារគ្រោះថ្នាក់នានាដែលអាចកើតឡើងជាយថាហេតុ។

ក្រុមហ៊ុនត្រូវសហការជាមួយអាជ្ញាធរភូមិ ឃុំ ពាក់ព័ន្ធ មន្ទីរបរិស្ថាន មន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទ អង្គការអភិរក្សពាក់ព័ន្ធនានា ក្នុងការចុះបញ្ជីស្នាក់នៅជាបណ្តោះអាសន្ន ចេញប័ណ្ណសម្គាល់បុគ្គលិកកម្មករ ប័ណ្ណសម្គាល់រណាយន្ត ដើម្បីងាយស្រួលដល់ក្រុមល្បាតទប់ស្កាត់អ្នកប្រព្រឹត្តបទល្មើសព្រៃឈើ សត្វព្រៃ និងជលផល។

ក្រុមហ៊ុនត្រូវធ្វើផែនការបំលាស់ប្តូរលំនៅដ្ឋាន របស់ប្រជាពលរដ្ឋក្នុងតំបន់១(តំបន់អាងទឹក) និងបង្កើត តំបន់តាំងលំនៅឋានថ្មី ឱ្យបានមុនយ៉ាងតិច១ឆ្នាំ មុននឹងធ្វើការបិទទ្វារទឹកបំពេញអាងនេះ។ ចំពោះប្រជាជន៩៦គ្រួសារ ដែលបាត់បង់ចំណូលនោះ ក្រុមហ៊ុនមានថវិកា ចំនួន៤១៥ដុល្លារអាមេរិក/គ្រួសារ ដើម្បីបង្កើតកម្មវិធី ស្តារចំណូលគ្រួសារ ដូចជាទិញពូជដំណាំ និងមធ្យោបាយជាក់ស្តែង ដើម្បីជំនួយឱ្យពួកគាត់ស្តារចំណូលឡើងវិញក្នុងរយៈពេលអន្តរកាល១ឆ្នាំ ពេលដែលគាត់រើទៅនៅកន្លែងតាំងទីលំថ្មីនោះ (ការគ្រោងតម្លៃលម្អិតមើលក្នុងតារាង ៩-៣)។

ក្រុមហ៊ុនត្រូវផ្តល់ឱ្យអាទិភាពដល់ប្រជាពលរដ្ឋមូលដ្ឋាន ជាពិសេសអ្នកដែលប៉ះពាល់ដោយសារគម្រោង ក្នុងការជ្រើសយកកម្លាំងពលកម្មដើម្បីធ្វើជាបុគ្គលិក-កម្មករគម្រោង។

ក្រុមហ៊ុនត្រូវគោរពច្បាប់ការងាររបស់ព្រះរាជាណាចក្រកម្ពុជា ដោយជួលកម្មករធ្វើការ១ថ្ងៃ៨ម៉ោង ឬ៤៨ម៉ោងក្នុងមួយសប្តាហ៍ (មាត្រា១៣៧ នៃច្បាប់ការងារ)។ បើមានការធ្វើការថ្ងៃសំរាក ឬថ្ងៃបុណ្យ ក្រុមហ៊ុននឹងមានប្រាក់បន្ថែមជូនកម្មករ (មាត្រា ១៣៩ នៃច្បាប់ការងារ)។

ក្រុមហ៊ុនបើកប្រាក់ឈ្នួលដោយផ្ទាល់ជូនកម្មករ ជារៀងរាល់ពីរសប្តាហ៍ម្តង។

ក្រុមហ៊ុនត្រូវសម្រួលចរាចរណ៍ និងជូនព័ត៌មានជាមុននៃការបំផ្ទុះ និងអនុញ្ញាតឱ្យប្រជាជនចេញចូលតំបន់គម្រោងជាធម្មតា។

ដើម្បីការពារសុវត្ថិភាពកម្មករ ក្រុមហ៊ុនចែកជូនពួកគាត់នូវ មួកការពារ ស្បែកជើង ស្រោមដៃ ខោអាវជាដើម ព្រមទាំង ត្រួតពិនិត្យមើលពីប្រធានក្រុមក្រែងលោមានកម្មកររូបណាមិនប្រើ។ ជាងនេះទៅទៀត ក្រុមហ៊ុននឹងមានអ្នកបកប្រែភាសាគ្រប់គ្រាន់នៅការដ្ឋានដើម្បីឱ្យការងារមានភាពងាយស្រួលរវាងកម្មករខ្មែរ និងអ្នកគ្រប់គ្រងជនជាតិជនបរទេស។

ក្រុមហ៊ុននឹងធ្វើការសហការយ៉ាងជិតស្និត ជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីដោះស្រាយដោយសន្តិវិធីរាល់នូវរាល់ទំនាស់ ដែលអាចកើតឡើងជាមួយកម្មករជនបរទេស និងខ្មែរ។

### គ.៣ ប្រពៃណី វប្បធម៌ និង សាសនា

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលសាងសង់នេះ អាចមានការប៉ះពាល់ដល់ជំនឿប្រពៃណី របស់ប្រជាពលរដ្ឋនៅក្បែរតំបន់គម្រោង ដោយសារ ក្រុមហ៊ុនយកបុគ្គលិក-កម្មកររបស់ខ្លួនរហូតដល់ ៤០០នាក់ ដែលមកពីតំបន់ឆ្ងាយខុសៗគ្នា និងមានសញ្ជាតិខុសៗគ្នា។

ជាងនេះទៅទៀត នៅក្នុងតំបន់គម្រោងមានជនជាតិដើមភាគតិចព័រ១០គ្រួសារ ដែលអាចប៉ះពាល់ដល់ ទំនៀមទំលាប់របស់គាត់ផងដែរ។ *សម្គាល់៖ យោងតាមការសម្ភាសផ្ទាល់ជាមួយតំណាងមេគ្រួសាររបស់ជនជាតិភាគតិចទាំង១០គ្រួសារ បានឱ្យដឹងថា ពួកគាត់មានជំនឿ សាសនា ទំនៀមទំលាប់ ដូចជនជាតិខ្មែរក្នុងតំបន់ផងដែរ។*



Draft

- វិធានការកាត់បន្ថយ

ក្រុមហ៊ុនសិក្សាស្វែងយល់អំពីទំនៀមទំលាប់ប្រពៃណី និងជំនឿសាសនារបស់ប្រជាពលរដ្ឋ ជាពិសេសជនជាតិដើមភាគតិចព័រ ដែលរស់ក្នុង និងក្បែរតំបន់គម្រោង ហើយផ្សព្វផ្សាយ និងគោរពទៅតាមប្រពៃណីទំនៀមទំលាប់នេះ ដោយមិនធ្វើការបំពាន និងល្មើសឡើយ។

ក្រុមហ៊ុនត្រូវធ្វើការអប់រំ ណែនាំដល់បុគ្គលិក-កម្មកររបស់ខ្លួនអំពីទំនៀមទំលាប់ប្រពៃណីប្រជាពលរដ្ឋ ដែលរស់នៅដែលរស់ក្នុង និងក្បែរតំបន់គម្រោង ជាពិសេស គឺជនជាតិដើមភាគតិចព័រ។

**គ.៤ ការប្រើប្រាស់ទឹក**

- ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលសាងសង់នេះ មានការប៉ះពាល់ដល់ការប្រើប្រាស់ទឹកស្ទឹង ដោយសារសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធ របស់គម្រោង (លម្អិតហេដ្ឋារចនាគម្រោងមានចែងក្នុងជំពូក៤) និងគ្រប់គ្រងសំណល់រឹង-រាវ មិនបានល្អ ធ្វើឱ្យបំពុលដល់ប្រភពទឹក លើដី និងក្រោមដី ដែលជាប្រភពដ៏សំខាន់ក្នុងការប្រើប្រាស់ទឹកកម្មករក្នុងតំបន់។

បរិមាណធារទឹករបស់ស្ទឹងពោធិ៍សាត់ អាចនឹងប៉ះពាល់ដោយសារការសាងសង់ទប់ទំនប់កាត់ស្ទឹងពោធិ៍សាត់ដើម្បីធ្វើអាងតម្កល់ទឹក ដែលជាហេតុបង្កឱ្យមានការប្រែប្រួលប្រព័ន្ធអេកូឡូស៊ី និងប្រព័ន្ធលំហូរទឹកផ្សេងទៀត ដែលបែកចេញពីស្ទឹងនៅក្រោមទំនប់ ជាពិសេស អាចប៉ះពាល់ដល់ប្រព័ន្ធធារាសាស្ត្រ ដំណាក់ឈើក្រំ ដំណាក់អំពិល និងចារីក ដោយការខ្វះទឹកខណៈដែលទប់ស្ទឹងនេះដើម្បីសាងសង់ទំនប់មេ។ គុណភាព ទឹកក៏អាចនឹងប៉ះពាល់ផងដែរ ដោយសារសកម្មភាពសាងសង់ ដែលធ្វើឱ្យទឹកស្ទឹងមានការបំពុលជាហេតុបង្កឱ្យកម្មករ និងប្រជាពលរដ្ឋ ដែលមករកអនុផលព្រៃឈើមិនអាចប្រើទឹកនេះបាន។

សំណល់រឹង-រាវចេញពីកន្លែងរស់នៅផ្ទះបាយ និងបង្គន់អនាម័យរបស់បុគ្គលិក-កម្មករនៃគម្រោង ការលេចធ្លាយប្រេងឥន្ធនៈ និងប្រេងរំអិលពីឧបករណ៍ ឬគ្រឿងយន្តនានាក្នុងការដ្ឋានសាងសង់អាចបង្កឱ្យទឹកស្ទឹងពោធិ៍សាត់បាត់បង់គុណភាពដែរ។ ការសំអាតខ្លួនប្រាណរបស់បុគ្គលិក-កម្មកររាប់រយនាក់នៅក្នុងឬក្បែរស្ទឹង នឹងធ្វើឱ្យគុណភាពទឹកស្ទឹងពោធិ៍សាត់មានការថយចុះ និងឈានទៅដល់ការបំពុលទឹក។

- វិធានការកាត់បន្ថយ

ការឈូសឆាយទ្រង់ទ្រាយធំក្រុមហ៊ុនមិនធ្វើនៅរដូវវស្សាទេ។

ក្រុមហ៊ុនធ្វើរបាំងការពារកករដីកុំឱ្យសាយភាយចេញឆ្ងាយពីទីតាំងសាងសង់ ហើយសាងសង់បង្គន់អនាម័យ និងបន្ទប់ទឹកឱ្យបានគ្រប់គ្រាន់ទៅតាមចំនួនបុគ្គលិក-កម្មករគម្រោង (ក្នុងរយៈពេលសាងសង់អាចមានបុគ្គលិក-កម្មករអតិបរមាឡើងដល់៤០០ នាក់)។

ក្រុមហ៊ុនត្រូវធ្វើការអប់រំណែនាំ បុគ្គលិក-កម្មករគម្រោង ឱ្យយល់ដឹងអំពីអនាម័យស្គាល់នូវកន្លែងទុកដាក់សម្រាម (ដោយសសេរជា អក្សរខ្មែរ និងកូរ៉េ ឬអង់គ្លេស) ដែលក្រុមហ៊ុនបានរៀបចំកសាងក្នុងទីតាំងស្នាក់នៅ ហើយដាក់ពិន័យដល់បុគ្គលិក-កម្មករណា ដែលមិនព្រមធ្វើតាមការណែនាំទាំងនោះ។

ក្រុមហ៊ុនត្រូវចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងសំណល់រឹង-រាវ ដោយសាងសង់បង្គន់អនាម័យ ព្រមទាំងរៀបចំប្រមូលសំណល់រឹងនិងសម្រាមយកទៅចោលនៅទីតាំងដែលមានសុវត្ថិភាពគឺកន្លែងចាក់សម្រាមដែលបានកំណត់។

ជាងនេះទៅទៀត ក្រុមហ៊ុនសាងសង់កន្លែងប្រព្រឹត្តិកម្ម ដូចជាអាងសិបទិក ដើម្បីសំអាតទឹកកខ្វក់ពីការិយាល័យ ផ្ទះ បុគ្គលិក ដែលស្នាក់នៅពេលដំណើរការ និងថែទាំគម្រោង ហើយទឹកដែលបង្ហូរចេញពីអាងសំអាតនេះ នឹងមានកម្រិតតាមស្តង់ដានៃការបញ្ចេញចោលពីប្រភពបំពុលចូលទៅប្រភពទឹកសាធារណៈ ដែលមានចែងក្នុងអនុក្រឹត្យលេខ២៧អនក្រ.បក របស់រាជរដ្ឋាភិបាល។

Draft

ក្រុមហ៊ុនសាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈបានត្រឹមត្រូវតាមបទដ្ឋានសុវត្ថិភាពដល់បរិស្ថាន និងសង្គម។

ក្រុមហ៊ុនប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និងរថយន្តដឹកជញ្ជូន ដែលមានគុណភាពល្អមិនលេចហូរជាតិប្រេង ឬខ្លាញ់មកលើដី និងប្រភពទឹកក្នុងតំបន់គម្រោង។

ក្រុមហ៊ុនត្រូវពង្រាបដី និងដាំព្រៃឈើឡើងវិញ និងដាំស្មៅតាមកន្លែង ចាក់ចោលដីស្អុយ ឬសំណល់ថ្ម កន្លែងយកដី និងថ្ម ដើម្បីការពារការហូរ ច្រោះដែលអាចធ្វើឱ្យមានការបំពុលទឹក។

ក្រុមហ៊ុននឹងចោះជារូងទូនេលពង្វៀងទឹកដើម្បីធ្វើការរំដោះទឹកមកតំបន់ខាងក្រោមគម្រោង មិនឱ្យមានការប៉ះពាល់ដល់ លំហូរធារទឹកស្ទឹងនេះទេក្នុងពេលសាងសង់គម្រោងនេះ (មើលគំនូរបច្ចេកទេស DWG 03) ពោលគឺ ក្នុងដំណាក់កាលសាងសង់នេះទឹកស្ទឹងពោធិ៍សាត់មិនបានបង្ខាំងទុកឡើយ ហើយធារទឹកស្ទឹងនៅហូរជាធម្មតា។

### គ.៥ តំបន់ទេសចរណ៍/ រមណីយដ្ឋាន/ ទីកន្លែងកំសាន្ត

- ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលសាងសង់នេះ មានការប៉ះពាល់ដល់តំបន់អន្លង់ក្រពើលោកយាយស្ដើងខ្លះៗដែរ ដែលជាតំបន់ទេសចរណ៍ធម្មជាតិ ដោយសារសកម្មភាពសាងសង់ទំនប់វារីអគ្គិសនីនេះ ធ្វើឱ្យរាំងស្ទះចរាចរណ៍តាមផ្លូវលេខ៥៥ ដែលរំខានភ្ញៀវទេសចរណ៍ជាដើម។ល។

ជាងនេះទៅទៀត សំណល់រឹង-រាវចេញពីកន្លែងរស់នៅ ផ្ទះបាយរបស់បុគ្គលិក-កម្មករគម្រោង ជាកត្តាសំខាន់ក្នុងការធ្វើឱ្យប៉ះពាល់វិស័យទេសចរណ៍នេះផងដែរ។

- វិធានការកាត់បន្ថយ

វិធានការកាត់បន្ថយផលប៉ះពាល់ផ្នែកនេះ គឺធ្វើដូចក្នុងវិធានការបន្ធូរបន្ថយក្នុងចំណុច គ.៤ ខាងលើផងដែរ។

***សម្គាល់:*** *ការអភិវឌ្ឍគម្រោង ក៏ជាផ្នែកមួយយ៉ាងសំខាន់សម្រាប់បម្រើឱ្យវិស័យអេកូ-ទេសចរណ៍ និងទេសចរណ៍-បរិស្ថានដែរ ដោយគេអាច ភ្ជាប់ធ្វើដំណើរកំសាន្តពីតំបន់មាត់សមុទ្រដែនជម្រកសត្វព្រៃពាមក្រសោប ឆ្លងកាត់តំបន់ព្រៃការពារភ្នំក្រវាញភាគខាងត្បូង ភ្នំក្រវាញ ភាគកណ្ដាល ទៅដែនជម្រកសត្វព្រៃភ្នំសំកុស រហូតដល់បឹងទន្លេសាបបានយ៉ាងប្រសើរ។*

ជាងនេះទៅទៀតត្រូវដាក់បញ្ចូលក្នុងសៀវភៅបន្ទុកដែលជាឯកសារធ្វើកិច្ចសន្យាម៉ៅការបន្តទៅឱ្យក្រុមហ៊ុនផ្សេងៗ ត្រូវសំអាតទីតាំងការដ្ឋាន និងកន្លែងជំរុំស្នាក់នៅរបស់បុគ្គលិកកម្មករឱ្យបានស្អាត ដោយមានបង្កក្រប្រាក់ទុករង់ចាំក្រុមការងារអនុគណកម្មាការខេត្ត ចុះពិនិត្យរួចបានបញ្ជាក់ថាទីតាំងទាំងនោះ ស្អាតសរម្យ អាចទទួលយកបានហើយទើបបើកប្រាក់ដែលបង្កកនោះឱ្យ។

### គ.៦ ផ្លូវគមនាគមន៍

- ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលសាងសង់នេះ អាចធ្វើឱ្យប៉ះពាល់ដល់ផ្លូវជាតិលេខ៥៥ មានស្ពាន និងលូជាច្រើន ដែលចេញពីក្រុងពោធិ៍សាត់ ទៅប្រមោយទីរួមស្រុកវាលវែង ដែលឆ្នាំ២០១៧ គម្រោងស្តារផ្លូវជាតិលេខ ៥៥នេះបានសាងសង់ផ្លូវចាក់កៅស៊ូ និងមានស្ពានបេតុង ហេតុដូចនេះដោយសារសកម្មភាពសាងសង់គម្រោង និងការដឹកជញ្ជូន សម្ភារបរិក្ខារ គ្រឿងចក្រចូលទៅទីតាំងគម្រោងអាចបង្កឱ្យមានការស្រុត ឬខូចផ្លូវ ឬបាក់ស្ពាន ឬបាក់លូ ឬគ្រោះថ្នាក់ចរាចរលើទ្រូងផ្លូវ ដែលមានចំណោតឡើងចុះ និងផ្លូវកោងជាដើម។ល។

អាចប៉ះពាល់ដល់ការធ្វើដំណើរ និងដឹកជញ្ជូនប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ លើផ្លូវនេះ ដោយសារក្រុមហ៊ុនប្រើរថយន្តធំៗ ក្នុងការដឹកជញ្ជូនសម្ភារសំណង់ បរិក្ខារ និងគ្រឿងចក្រ ពីភ្នំពេញទៅតំបន់គម្រោងវារីអគ្គិសនីនេះ ដោយជាប់ផុងស្ទះផ្លូវឬធ្វើឱ្យស្ទះចរាចរណ៍ក្នុងតំបន់ទៀតផង។

Draft

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុន និងអ្នកម៉ៅការគោរពតាមច្បាប់ស្តីពីចរាចរផ្លូវគោក(ឆ្នាំ២០១៥) និងច្បាប់ស្តីពីផ្លូវថ្នល់(ឆ្នាំ២០១៤)ដោយការដឹកជញ្ជូនសម្ភារបរិក្ខារ គ្រឿងចក្រចូលទៅទីតាំងគម្រោង មិនឱ្យលើសទំងន់ ដែលក្រសួងសាធារណៈការ និងដឹកជញ្ជូនបានកំណត់។

ក្រុមហ៊ុនប្រើរថយន្តដឹកជញ្ជូនដែលមានទំហំមធ្យមដែលមិនមានការទើសទែង និងដឹកលើសទំងន់នៃសម្ភារសំណង់បរិក្ខារ ដែលធ្វើឱ្យខូចផ្លូវ និងស្ទះចរាចរលើផ្លូវជាតិលេខ ៥៥ នេះឡើយ។ ប្រសិនបើមានការខូច ថ្នល់ ស្ពាន លូ ដែលធ្វើបុគ្គលិក-កម្មករ រួមទាំងអ្នកម៉ៅការរបស់គម្រោងនេះ ម្ចាស់គម្រោងត្រូវទទួលខុសត្រូវជួសជុលឡើងវិញ។

ក្រុមហ៊ុនត្រូវធ្វើការសហកាណ៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ទីរសាធារណៈការខេត្ត ដើម្បីទប់ស្កាត់ ការដឹកទំនិញលើសទំងន់ និងរថយន្តធំៗ ដែលប្រើកង់កាច់ចង្កូតលើពី១ជួរ។

ក្រុមហ៊ុនត្រូវដាំឈើធ្វើជារបងធម្មជាតិតាមសងផ្លូវចេញចូលនិងលើដីជម្រាលដើម្បីទប់ស្កាត់ការហូរច្រោះ ការហុយធូលី សំឡេង និងធ្វើឱ្យមានសោភ័ណ្ឌភាព ទេសភាពល្អ។

**គ.៧ សុខភាពសាធារណៈ**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គម្រោង អាចបង្កឱ្យមានការប៉ះពាល់ ដល់សុខុមាលភាពបុគ្គលិក-កម្មកររបស់ក្រុមហ៊ុន ដោយសារធូលីដី ធូលីស៊ីម៉ង់ត៍ ចំហាយចេញពីការប្រើប្រាស់សារធាតុគីមីផ្សេងៗជាដើម។

ម៉្យាងទៀត អាចបង្កឱ្យមានផលប៉ះពាល់ដល់សុខភាពបុគ្គលិក-កម្មកររបស់គម្រោង ដោយសារតំបន់នេះជាតំបន់ដែលកើតជំងឺគ្រុនចាញ់។ ជាងនេះទៀត ប្រជាពលរដ្ឋនៅក្បែរតំបន់គម្រោងអាចឆ្លងជំងឺអេដស៍ ជំងឺកាមរោគ ជំងឺរបេង ជំងឺឆ្លងផ្សេងៗពីបុគ្គលិក-កម្មករគម្រោង ដែលរើសមកពីឆ្ងាយដោយក្រុមហ៊ុនផងដែរ។

អាចប៉ះពាល់ដល់សុខភាពសាធារណៈ(ប្រជាជននៅក្បែរតំបន់ និងបុគ្គលិក-កម្មករគម្រោង) ដោយសារអាចមានការប្រើប្រាស់ ឬចរាចរគ្រឿងញៀន។

អាចប៉ះពាល់ប្រជាពលរដ្ឋ និងបុគ្គលិក-កម្មករគម្រោង ដោយសារមិនចាប់អារម្មណ៍អំពីសុវត្ថិភាពការងារ។

ក្នុងតំបន់គម្រោងគ្មានប្រព័ន្ធទឹកស្អាតសម្រាប់បរិភោគទេ ដោយសារខ្វះទីផ្សារ ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនបានប្រកាន់យកការរក្សាសុវត្ថិភាពការងារជាចំបង ក្នុងសកម្មភាពការងារប្រចាំថ្ងៃ។

ក្រុមហ៊ុនផ្តល់ម៉ាស់ការពារធូលីដី មួកការពារ ស្បែកជើង ស្រោមដៃដល់បុគ្គលិក កម្មករគម្រោង និងធ្វើការស្រោចទឹកលើ ផ្លូវថ្នល់ដែលខ្លួនប្រើប្រាស់ក្នុងការសាងសង់គម្រោងនេះជាប្រចាំ។

ក្រុមហ៊ុនត្រូវសាងសង់ជំរុំស្នាក់នៅរបស់បុគ្គលិក-កម្មករគម្រោងបានសមរម្យ ដោយមានការប្រើប្រាស់ទឹកស្អាតមានបង្គន់អនាម័យ បន្ទប់ទឹកគ្រប់គ្រាន់ និងមានកម្មវិធីអប់រំសុវត្ថិភាពការងារដល់បុគ្គលិក-កម្មកររបស់គម្រោង។

ក្រុមហ៊ុនត្រូវមានគ្រូពេទ្យ ដែលមានសមត្ថភាពនៅប្រចាំការក្នុងការដ្ឋាន និងជំរុំស្នាក់នៅរបស់កម្មករ និងត្រៀមថ្នាំពេទ្យ និងបរិក្ខារគ្រប់គ្រាន់ជាប្រចាំសម្រាប់ការពិនិត្យ និងព្យាបាលជូនបុគ្គលិក-កម្មកររបស់គម្រោង ហើយមានរថយន្តសង្គ្រោះបន្ទាន់នៅពេល ដែលមានករណីគ្រោះថ្នាក់កើតឡើងជាយថាហេតុ។

ក្រុមហ៊ុនត្រូវធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិក/កម្មករ របស់ខ្លួនក្នុងការទប់ស្កាត់ជំងឺទាំងនោះកុំឱ្យឆ្លងទៅប្រជាពលរដ្ឋក្នុងតំបន់នោះ។

Draft

ក្រុមហ៊ុនត្រូវអនុវត្ត ផែនការគ្រប់គ្រងសំណល់គ្រប់ប្រភេទ, ផែនការគ្រប់គ្រងសុវត្ថិភាព និងហានិភ័យ, និងផែនការរៀបចំស្នាក់នៅ សុខភាព និងអនាម័យរបស់បុគ្គលិក-កម្មករគម្រោងឱ្យមានខ្ជាប់ខ្ជួនត្រឹមត្រូវ ដូចមានចែងក្នុងជំពូក៤ ចំណុច ៤.៦.១២, ៤.៦.១៣, និង៤.៦.១៤។

ក្រុមហ៊ុនត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ពិសេសទប់ស្កាត់ការជួញដូរ ចរាចរគ្រឿងញៀន និងមនុស្ស។ ជាងនេះទៅទៀត ក្រុមហ៊ុនត្រូវសហការជាមួយស្ថាប័នសុខាភិបាលនៅក្នុងតំបន់នេះ ដើម្បីការពារទប់ស្កាត់ជំងឺឆ្លងផ្សេងៗ ដែលកើតមានឡើងជាយថាហេតុ។

### គ.៨ សោភ័ណ្ឌភាព/ ទេសភាព

➢ ហេតុប៉ះពាល់អវិជ្ជមាន

ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគម្រោងនេះនៅតំបន់២ អាចនឹងមានការប៉ះពាល់ដល់សោភ័ណ្ឌភាពទេសភាពក្នុងតំបន់ដោយសារការកាប់ព្រៃឈើអស់ ឬការឈូសឆាយដីស្អុយឬសំណល់ថ្ម ទុកជាគំនរតាមដងផ្លូវ ការគ្រប់គ្រងសំណល់រឹង-រាវ មិនត្រឹមត្រូវ ពាសវាលពាសកាល តាមជំរុំបណ្ដោះអាសន្ន កន្លែងសង់ផ្លូវ ស្ពាន និងហេដ្ឋារចនាសម្ព័ន្ធទំនប់វារីអគ្គិសនីជាដើម។ល។

ការហុយធូលី ដោយសារការឈូសឆាយ ការបំផ្ទុះថ្ម ការដុតព្រៃសម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធជាដើម ក៏អាចធ្វើឱ្យប៉ះពាល់ដល់សោភ័ណ្ឌភាព និងទេសភាពកន្លែងនោះដែរ។

បន្ថែមពីលើនេះទៀត ការសាងសង់កន្លែងស្នាក់នៅរបស់កម្មករគ្មានរបៀប ដោយឃើញមាននៅគ្រប់ទីកន្លែង ក៏ប៉ះពាល់ ដល់សោភ័ណ្ឌភាពក្នុងតំបន់ដែរ។

មិនមានការគ្រប់គ្រងសំណល់រឹង-រាវ សម្ភារ គ្រឿងបរិក្ខារ និងឧបករណ៍ផ្សេងបានល្អនៅក្នុង និងក្បែរតំបន់គម្រោង ក៏ប៉ះពាល់ដល់ទេសភាពក្នុងតំបន់នេះផងដែរ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនមិនធ្វើការសំអាតព្រៃនៅតំបន់២នេះចំនួន ៥៥៩,៩១ហ.ត ទាំងស្រុងនោះទេ ពោលគឺសំអាតនៅកន្លែងដែលសាងសង់សំណង់ជាក់ស្តែងប៉ុណ្ណោះ (ចំពោះកន្លែងដែលនឹងត្រូវសាងសង់ទាំងនេះ នឹងធ្វើលម្អិតនៅក្នុងដំណាក់កាលគ្រោងលម្អិតរបស់គម្រោង)។ ទំហំគម្របព្រៃឈើដែលត្រូវសំអាតនៅតំបន់នេះគឺ ៤៣១,១៧ហ.ត។

ក្រុមហ៊ុនធ្វើការពង្រាបគំនរដីស្អុយតាមដងផ្លូវឱ្យបានស្មើល្អ មានការគ្រប់គ្រងសំណល់រឹងរាវឱ្យបានល្អ ដោយពេលបញ្ចប់ការដ្ឋានតាមហេដ្ឋារចនាសម្ព័ន្ធនិមួយៗ ត្រូវធ្វើការប្រមូលសំណល់រឹង ដូចជាស្បោងប្លាស្ទិក សំបកដបគ្រប់ប្រភេទ សំបកកង់ឡាន កម្ទេចបេតុង និងគ្រឿងប្លាស្ទិកគ្រប់ប្រភេទយកទៅកប់ឱ្យបានសមរម្យបានល្អ។ ម៉្យាងទៀត លូនៃបង្គន់ត្រូវលប់ឱ្យបានល្អផងដែរ។

ក្រុមហ៊ុនត្រូវធ្វើការស្រោចទឹកជាប្រចាំទៅលើផ្លូវថ្នល់ដែលខ្លួនកំពុង ប្រើប្រាស់សាងសង់គម្រោង។ ម៉្យាងទៀត ក្រុមហ៊ុននឹងប្រើប្រាស់សារធាតុផ្ទុះដែលមានភាពរំញ័រ និងរញ្ជួយ និងកំលាំងខ្ទាតថ្មតិច។

ដើម្បីរក្សាសណ្ដាប់ធ្នាប់ និងការរស់នៅស្អាត ក្រុមហ៊ុនត្រូវសាងសង់ផ្ទះសម្រាប់កម្មករបុគ្គលិកដោយមានរបៀបរាបរយនៅតាមទីកន្លែងសមស្រប ព្រមទាំងមានបង្គន់អនាម័យគ្រប់គ្រាន់ សាងសង់រាងសិបទិក ដើម្បីសំអាតទឹកគខ្វក់ ត្រូវមានកន្លែងទុកដាក់ សំណល់រឹងត្រឹមត្រូវដោយមានអ្នកទទួលខុសត្រូវច្បាស់លាស់។

រីឯសម្ភារ គ្រឿងបរិក្ខារ និងឧបករណ៍សាងសង់វិញ ក្រុមហ៊ុនត្រូវមានកន្លែង និងឃ្លាំងរក្សាទុកត្រឹមត្រូវ។

### គ.៩ ហានិភ័យ

➢ ហេតុប៉ះពាល់អវិជ្ជមាន



Draft

ក្នុងដំណាក់កាលសាងសង់នេះ អាចនឹងមានហានិភ័យ ដោយសារគ្រោះធម្មជាតិការកើតមានការរញ្ជួយដី (ដោយសារទំងន់របស់អាង) នៅក្នុងតំបន់គម្រោងទទួលរងឥទ្ធិពលពីព្យុះទីហ្វុង ឬព្យុះផ្សេងទៀត ពីឈូងសមុទ្រថៃ ឬខ្យល់កន្ត្រាក់ដែលជាហេតុបង្កឱ្យមានមហន្តរាយធំៗ ដូចជាការបាក់ទំនប់ និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គម្រោងដែលកំពុងសាងសង់ ការបាត់បង់ឬខូចខាតសម្ភារ និងគ្រឿងចក្រសាងសង់ ជាពិសេសការធ្វើឱ្យរងរបួស និងស្លាប់បាត់បង់ជីវិតដល់បុគ្គលិកកម្មករព្រមទាំងប្រជាពលរដ្ឋក្បែរខាងតំបន់គម្រោង។

អាចនឹងកើតមានការផ្ទុះសម្ភារគ្រឿងផ្ទុះឆេះប្រេងឥន្ធនៈ នៅកន្លែង ឬឃ្លាំងស្តុករបស់គម្រោង និងការឆេះព្រៃក្នុងតំបន់គម្រោង ដែលបណ្តាលមកពីការធ្វេសប្រហែស ឬអំពើភេរវកម្ម ក៏អាចបង្កឱ្យមានមហន្តរាយដល់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គម្រោង និងធនធានធម្មជាតិក្នុងតំបន់ និងអាយុជីវិតមនុស្សទៀតផង។

អាចនឹងកើតមានសង្គ្រាមឈ្លានពានលើបូរណភាពទឹកដីនៃប្រទេសកម្ពុជា ក៏ជាឧបសគ្គដល់ការងារសាងសង់គម្រោង ឬសង្គ្រាម អាចបំផ្លាញគម្រោងទាំងស្រុងក៏សឹងមាន។

➢ វិធានការកាត់បន្ថយ

ដូចបានរៀបរាប់ក្នុងដំណាក់កាលមុនសាងសង់គម្រោងរួចមកហើយក្រុមហ៊ុនត្រូវធ្វើការសិក្សារចនាប្លង់វិស្វកម្ម និងគុណភាពការសាងសង់ ដែលអាចធានាមិនឱ្យមានការបាក់ទំនប់ និងការបាក់ភ្នំ ក្នុងតំបន់គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ ដោយរកក្រុមហ៊ុនអន្តរជាតិធ្វើការធានាគុណភាពសំណង់ធានាក្នុងរយៈពេល៩០ឆ្នាំ និងហានិភ័យរបស់វា។

ក្រុមហ៊ុនត្រូវធ្វើការប្រុងប្រយ័ត្នគ្រប់វិនាទីក្នុងការការពារសុវត្ថិភាព ចំពោះគ្រឿងផ្ទុះ ការឆេះព្រៃ និងឆេះប្រេងឥន្ធនៈ ដោយធ្វើការសហប្រតិបត្តិការណ៍ជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដើម្បីទប់ស្កាត់រាល់អំពើភេរវកម្មក្នុងតំបន់គម្រោងឱ្យទាន់ពេលវេលា។

ក្រុមហ៊ុនត្រូវធ្វើការជូនដំណឹងរាល់ហេតុការណ៍ដែលអាចបង្កដល់ការបាក់ទំនប់ ការបាក់ភ្នំ ឬការរញ្ជួយដីក្នុងតំបន់គម្រោងដល់ប្រជាពលរដ្ឋទាំងនោះ ឱ្យទាន់ពេលវេលាតាមតែអាចធ្វើទៅបានបើសិនជាមានហានិភ័យកើតឡើង។

ក្រុមហ៊ុនត្រូវបង្ហូរទឹកឱ្យអស់ពីទំនប់បណ្តោះអាសន្ននៅពេលមានបញ្ហាគ្រោះថ្នាក់ ដោយចៃដន្យដូចជា ការរញ្ជួយដីសង្គ្រាម និងបាតុភូតរញ្ញប្រានមកលើទំនប់ខ្លាំង។

ក្រុមហ៊ុនត្រូវរៀបចំបំរុងទុកនូវយានយន្តសង្គ្រោះសម្ភារ និងថវិកា ដើម្បីធានាការសង្គ្រោះជាបន្ទាន់នូវហេតុការណ៍ខាងលើនេះទាន់សភាពការណ៍ និងមានប្រសិទ្ធិភាពខ្ពស់។

Draft

### ៧.៨.៣ ដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោង (Project Operation & Maintenance)

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោងនេះ គឺជាដំណាក់កាលមួយមានរយៈពេលវែងជាងគេ (គម្រោងនេះមិនទាន់ទទួលបានកិច្ចសន្យាអភិវឌ្ឍគម្រោងនេះ ជាមួយរាជរដ្ឋាភិបាលកម្ពុជាទេ)។ សកម្មភាពគម្រោងក្នុងដំណាក់កាលនេះអាចនឹងបង្កឱ្យមានការប៉ះពាល់ បរិស្ថានអវិជ្ជមានសំខាន់ៗដូចតទៅ ៖

**ក. ធនធានរូបសាស្ត្រ**

**ក.១ សណ្ឋានដី និងឋានលេខា**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោង នេះអាចនឹងមានការប៉ះពាល់ដល់សណ្ឋានដី និងឋានលេខា ដោយសារការបាក់ជញ្ជាំងដី នៅតាមដងផ្លូវ ឬកន្លែងគរសំណល់ដី និងថ្ម ដោយសារហេតុភ្លៀងខ្លាំង ធ្វើឱ្យស្ទះផ្លូវ ឬគោក ឬវាក់ផ្លូវទឹកក្នុងតំបន់ហើយបង្កឱ្យប៉ះពាល់ ដល់គុណភាពទឹកទៀតផង។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវត្រៀមគ្រឿងចក្រគ្រប់គ្រាន់សម្រាប់សំអាតដីដែលបាក់ទៅលើផ្លូវ ឬអូរ ដោយដឹកវាទៅទុកដាក់នៅកន្លែងមានសុវត្ថិភាព និងមានការបង្ហាប់ត្រឹមត្រូវតាមបច្ចេកទេសរបស់ការងារដី។ ចំណែកឯ កន្លែងដែលបាក់នេះ ត្រូវធ្វើការដាំស្មៅ ឬដើមឈើ ឬបាញ់បាយអរ ដោយមានរន្ធបង្ហូរទឹកលើជញ្ជាំងនេះត្រឹមត្រូវ។ ជាងនេះទៅទៀត ត្រូវមានអ្នកត្រួតពិនិត្យជាប្រចាំជាពិសេស នៅពេលមានភ្លៀងធ្លាក់ខ្លាំង នៅតាមដងផ្លូវនៅតាមកន្លែងដែលមានជញ្ជាំងចោទ និងមានកន្លែងចាក់ជាគំនរដីស្អុយ និងថ្មចោល។

## ក.២ ប្រព័ន្ធជលសាស្ត្រ (អូរ ស្ទឹង ព្រែក)

- ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលនេះ អាចនឹងមានផលប៉ះពាល់ ដល់ប្រព័ន្ធជលសាស្ត្រនៃស្ទឹងពោធិ៍សាត់និងខ្សែទឹកខាងក្រោម ដោយសារការបង្ខាំងទឹក ដើម្បីស្តុកទឹកទុកក្នុងអាងឱ្យបានកម្លាំងគ្រប់គ្រាន់សម្រាប់អូសទួរប៊ីនអគ្គិសនីកម្លាំងសរុប ៨០ មេហ្គាវ៉ាត់ និងការបញ្ចេញទឹក ពីទំនប់មិនគ្រប់គ្រាន់ធ្វើឱ្យប៉ះពាល់ដល់របបទឹករបស់ស្ទឹងពោធិ៍សាត់ដែលស្ថិតនៅចន្លោះទំនប់ និងអាគារ ថាមពល (ចម្ងាយប្រមាណ ៩,២គ.ម បើវាស់តាមផ្លូវទឹក)។

ការតម្កល់ទឹកក្នុងអាងដែលមានជម្រៅជ្រៅ ហើយផ្ទៃទឹកធំធ្វើឱ្យបង្កើនការជ្រាបទឹកចូលទៅក្នុងដីច្រើន ដែលធ្វើឱ្យកម្ពស់ ទឹកក្រោមដីនៅប៉ែកខាងក្រោមអាងកើនឡើងខ្ពស់ជាងស្ថានភាពដើមរបស់វាអាចនាំឱ្យខូចខាតដល់ដំណាំ របស់អ្នកស្រុក ឬរុក្ខជាតិ ផ្សេងៗ ដែលស្ថិតនៅក្បែរតំបន់គម្រោង។

ម៉្យាងទៀត អាចនឹងប្រែប្រួលរបបជលសាស្ត្ររបស់ស្ទឹងនេះ ដោយសារការបង្ហូរទឹកពីអាងស្តុកទឹកមកខាងក្រោម មិនគ្រប់គ្រាន់ដែលធ្វើឱ្យមានការខ្វះទឹកសម្រាប់ស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រដំណាក់ឈើក្រំ ដំណាក់អំពិលនិងចារឹក។

- វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវគ្រោងការគ្រប់គ្រងចាត់ចែងបញ្ចេញទឹកមានដូចតទៅ:

- តំបន់១: នៅខាងក្រោមតំបន់ទំនប់ ដល់អាគារថាមពល តាមដងស្ទឹងមានចម្ងាយប្រមាណ៩,២គ.ម។ នៅតំបន់នេះ ក្រុមហ៊ុន នឹងធ្វើការបញ្ចេញទឹកពីអាង ចំនួន ១,៣ម$^{3}$/វិន.ឥតដាច់ទាំងប្រាំង និងវស្សា។ ប៉ុន្តែនៅ២ឆ្នាំដំបូងក្នុងរយៈពេលប្រតិបត្តិ និងថែទាំគម្រោង ក្រុមហ៊ុនត្រូវធ្វើការបិទទ្វារទឹកដើម្បីបំពេញអាងក្នុងនោះនៅឆ្នាំទី១ ត្រូវការរយៈពេលពី៥ទៅ៨ខែ ក្នុងការ បំពេញទឹកក្នុងអាងឱ្យដល់នីវ៉ូ EL: ១៨០ម ដើម្បីដំណើរការទួរ២ប៊ីន (៨០ MW)។ នោះមានន័យថា ៥ខែដំបូងនៃឆ្នាំទី១នេះ មិនមានទឹកគ្រប់គ្រាន់សម្រាប់រក្សាជីវៈចំរុះនារដូវវស្សានោះទេពោល គឺមានតែ១.៣ម$^{3}$/វិន. និងលំហូរធម្មជាតិពីទឹក ភ្លៀងក្នុងតំបន់តែប៉ុណ្ណោះ។ យោងតាមលំហូរធារទឹកនៃរយៈពេលកត់ត្រា ៣០ឆ្នាំ (មើលតារាង៥-១១) បញ្ជាក់ថា នៅរដូវវស្សាចាប់ពី ខែឧសភា ដល់ខែតុលា ស្ទឹងពោធិ៍សាត់មានលំហូរ អប្បបរមា ០,៦ម$^{3}$/វិន. ហើយអតិបរមា ៣៨៩.២ ម$^{3}$/វិន.។ ដូចនេះក្នុង រយៈពេល៥ខែ ដំបូងនៃឆ្នាំទី១ ក្រុមហ៊ុនធ្វើការបញ្ចេញទឹកមកខាងក្រោមទំនប់យ៉ាងហោចណាស់ឱ្យបាន ១.៣ម$^{3}$/វិន.ដែរ។ បើធ្វើដូចនេះមានន័យថាៈ នៅរដូវវស្សា តំបន់នេះមានលំហូរ លើស ១.៣ ម$^{3}$/វិន. ហើយរដូវប្រាំង ពី ១,៣ម$^{3}$/វិន នៅរយៈពេល២ឆ្នាំដំបូង។ ចាប់ពីឆ្នាំទី៣ ទៅនឹងមានទឹកបន្ថែមនារដូវវស្សាដោយសារការហៀរទឹកចេញតាមទំនប់បង្ហៀរ។
- តំបន់២: គឺតំបន់ក្រោមអាគារថាមពល (PH) តាមដងស្ទឹងពោធិ៍សាត់មានទំនប់សំណង់ធារាសាស្ត្រដំណាក់ឈើក្រំ (កំពុងសាងសង់ចម្ងាយ៦២គ.ម) ដំណាក់អំពិល ចម្ងាយ ប្រមាណ១០៣ គ.ម ដែលទទួលយកទឹក ពីគម្រោងនេះ។ នៅដំណាក់កាលប្រតិបត្តិថែទាំគម្រោង និងមានការខ្វះទឹក នៅពេល ដែលក្រុមហ៊ុនធ្វើការបិទទំនប់ដើម្បីតម្កល់ទឹកនៅឆ្នាំទី១ ដូចនេះក្រុមហ៊ុនត្រូវព្រលែងទឹកនៅរដូវវស្សាយ៉ាងហោច ៤០ម$^{3}$/វិន. និងរដូវប្រាំង ១.៣ម$^{3}$/វិន. តាមបំពង់បង្ហូរទឹកបរិស្ថាន ពីព្រោះប្រព័ន្ធធារាសាស្ត្រនៅដំណាក់ឈើក្រំ និងអំពិលនេះ ត្រូវការទឹកស្រោចស្រពនៅរដូវវស្សា និងប្រាំង (មើលតារាង៥-១១ លំហូរធារទឹកជាមធ្យមគឺ ៤២.៤ ម$^{3}$/វិន.)។ ដូចនេះ ចំពោះការខ្វះទឹកសម្រាប់រក្សាជីវៈចំរុះ និងតម្រូវការទឹកសម្រាប់ស្រោចស្រពនោះ គឺត្រូវបានកាត់

បន្ថយអាចទទួលយកបាន បើក្រុមហ៊ុនអនុវត្តតាមការគ្រប់គ្រងទឹកខាងលើ។ នៅពេលដែលនីវ៉ូទឹកក្នុងអាងឡើងដល់កម្រិតអាចដំណើរការទួរប៊ីន នោះក្រុមហ៊ុននឹងដំណើរការទួរប៊ីន១ ដែលមានធារទឹក៤០ម$^3$/វិ. និងរហូតដល់ដំណើរការទាំង២ទួប៊ីន ដែលត្រូវបញ្ចេញធារទឹក សរុប៨០ម$^3$/វិ.។ នៅរដូវវស្សាតំបន់នេះ យ៉ាងហោចណាស់ ត្រូវព្រលែងទឹក ៤០ម$^3$/វិ. បើមិនដូច្នេះទេនោះ នឹងធ្វើឱ្យមានខ្វះខាតក្នុងការផ្គត់ផ្គង់ទឹក មកតំបន់ធារាសាស្ត្រដំណាក់ឈើក្រំ និងដំណាក់អំពិលជាមិនខាន។ ចំណែកឯ នៅរដូវប្រាំង ការផលិតអគ្គិសនីដែលដំណើរការបើកទួរប៊ីន២ មានធារទឹកសរុប ប្រមាណ៨០ម$^3$/វិ. នោះ អាចផ្តល់ទឹកគ្រាន់ ដល់ប្រព័ន្ធធារាសាស្ត្រទាំងនេះ នៅរដូវប្រាំងមិនខ្វះទឹកដូចដំណាក់កាលមុនសាងសង់គម្រោងទៀតឡើយ។ ***សម្គាល់:*** *នៅដំណាក់កាលប្រតិបត្តិថែទាំ គម្រោង នៅរដូវប្រាំង យោងតាម EDC ចង់បានអគ្គិសនី ២៤ម៉ោង លើ ៦ ខែ នៅរដូវប្រាំង នោះនឹងមានធារទឹក ៨០ម$^3$/វិ. បើប្រៀបធៀប ធារទឹកស្ទឹងពោធិ៍សាត់នៅទីតាំងទំនប់មេ មានប្រហាក់ប្រហែល ធារទឹកក្នុងខែ ឧសភា មិថុនា និងកក្កដា មើលតារាង ៥-១១។*

### ក.៣ ការហូរច្រោះ និងគុណភាពដី

➢ ហេតុប៉ះពាល់អវិជ្ជមាន

អាចមានការហូរច្រោះ រួចបណ្តាលឱ្យបាក់ដីនៅតាមជញ្ជាំងដីតាមដងផ្លូវ កន្លែងចាក់ជាគំនរថ្ម និងដីចោលធ្វើឱ្យដីបាក់នេះ ស្ទះផ្លូវ ឬស្ទះចរន្តទឹក ឬរាក់ផ្លូវទឹក ឬធ្វើឱ្យដីដែលហូរច្រោះទាំងនេះ ទៅគ្របពីលើដីមានឈើដុះធ្វើឱ្យបាត់បង់ជីវជាតិដី និងបណ្តាល ឱ្យដើមឈើទាំងនោះងាប់ដោយសារតែគល់វាត្រូវដីគ្របសង្កត់ជាដើម។ល។

ជាងនេះទៀត អាចមានការបាក់ច្រាំងស្ទឹងពោធិ៍សាត់ ដោយសារការបញ្ចេញទឹក ៨០ ម$^3$/វិនាទី បន្ថែមលើធារទឹកនីស្ទឹងនេះនៅតំបន់ខាងក្រោមអាគារថាមពលដែលស្ទឹងនេះមុនការប្រតិបត្តិគម្រោបមានធារទឹកធ្យមប្រមាណ៤២ម$^3$/វិនាទី។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវត្រៀមគ្រឿងចក្រគ្រប់គ្រាន់សម្រាប់សំអាតដីដែលបាក់ទៅលើផ្លូវ ឬអូរ ដោយដឹកវាទៅទុកដាក់នៅកន្លែងមានសុវត្ថិភាព និងមានការបង្ហាប់ត្រឹមត្រូវតាមបច្ចេកទេសរបស់ការងារដី។ ចំណែកឯ កន្លែងដែលបាក់នេះត្រូវធ្វើការដាំស្មៅ ឬ ដើមឈើ ឬបាញ់បាយអរ ដោយមានរន្ធ បង្ហូរទឹកលើជញ្ជាំងនេះត្រឹមត្រូវ។ ជាងនេះទៅទៀត ត្រូវមានអ្នកត្រួតពិនិត្យជាប្រចាំជាពិសេស នៅពេលមានភ្លៀងធ្លាក់ខ្លាំង នៅតាមដងផ្លូវ នៅតាមកន្លែងដែលមានជញ្ជាំងចោទ និងមានកន្លែងចាក់ជាគំនរដី ស្តុយ និងថ្មចោល។

ក្រុមហ៊ុនត្រូវតាមដានការហូរច្រោះបាក់ច្រាំងស្ទឹងនេះ ជាប្រចាំ ហើយបើមានការបាត់ច្រាំងបណ្តាលពីការបញ្ចេញធារទឹកនេះ ត្រូវជួលជុល និងសាសង់សំណង់ការពារច្រាំងនេះវិញ។

### ក.៤ ការរញ្ជួយដី

ក្នុងដំណាក់កាលនេះ មិនមានការរញ្ជួយដោយសារការបំផ្ទុះ ឬការដឹកវត្ថុធ្ងន់ៗ ឬការបាក់ដីទេ ប៉ុន្តែអាចកើតមានការរញ្ជួយ ដីពីធម្មជាតិ តែរាប់រយសតវត្សមកហើយប្រទេសកម្ពុជាមិនធ្លាប់ជួបប្រទះនឹងគ្រោះធម្មជាតិនេះទេ។

ទោះជាយ៉ាងនេះក៏ដោយ ការគ្រោងគម្រោង បានគិតបន្ថែមនូវកម្រិតរញ្ជួយដី ប្រភេទ IV ពោលគឺសំណង់ ទំនប់និងបំពង់ទួនេល អាចធន់និងការរញ្ជួយកម្រិត ៤-៤,៩ រិចទ័រ។

### ក.៥ គុណភាពទឹក (ទឹកលើដី /ទឹកក្រោមដី)

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោង អាចនឹងប៉ះពាល់គុណភាពទឹកលើដី ដោយសារការបញ្ចេញសំណល់រាវ-រឹង ពីកន្លែងរស់នៅរបស់បុគ្គលិកកម្មករគម្រោង បណ្តាលមកពីគុណភាពសំអាត របស់អាងសិបទិកបាត់បង់ និងការធ្វេសប្រហែសក្នុងការគ្រប់គ្រងសំណល់រឹងគ្រប់ប្រភេទ ដែលធ្លាក់ចូលក្នុងប្រព័ន្ធផ្លូវទឹកក្នុងតំបន់ធ្វើឱ្យបំពុលទឹកនៃប្រភពទាំងនោះទៀតផង។

មានការបំពុលទឹកក្នុងអាង ដោយសារការសំអាតឈើមិនទាន់ស្អាត រួចធ្វើការបិទទ្វារទឹកដើម្បីតម្កល់ទឹកផលិតអគ្គិសនី។

អាចនឹងប៉ះពាល់ដល់ការរលាយអុកស៊ីសែនរបស់ទឹក ដោយសារការស្តុកទឹក ដែលមានជម្រៅលើសពី ១៥ម ហើយនឹងធ្វើឱ្យទឹកមានក្លិនស្អុយ។ ម៉្យាងទៀត នៅពេលបង្ហូរទឹកមកខាងក្រោម ធ្វើឱ្យទឹកនេះមានក្លិនស្អុយ ដោយសារទឹកបាត់អុកស៊ីសែននេះ។

អាចធ្វើឱ្យប៉ះពាល់គុណភាពក្រោមដី ដោយសារការរលាយសារធាតុខនិកក្នុងដី នៅតំបន់អាងដែលមិនធ្លាប់លិចទឹកធ្វើឱ្យកើនឡើងនៃសារធាតុគីមីទឹកក្រោមដីនៅតំបន់នោះផងដែរ។

ការជ្រាបទឹកពីអាងស្តុកទឹកទៅក្រោមដីដែលមានក្លិនស្អុយ ដោយសារទឹកមានកម្រិតអុកស៊ីសែនរលាយទាបនឹងធ្វើឱ្យគុណភាព ទឹកក្រោមដីថយចុះ។

ការស្តុកទឹកធ្វើជាអាងដ៏ធំនេះ នឹងអាចកើតមានរុក្ខជាតិទឹក ដូចជាៈ ពើក ចក កំប្លោក និងសត្វល្អិតចង្រៃ ដូចជាមូស បាក់តេរី ដែលបង្កឱ្យមានរំហួតខ្លាំង ការបំពុលគុណភាពទឹកអាង និងការចម្លងជំងឺផ្សេងៗ ដែលកើតចេញពីប្រភពទឹកនេះ។

អាចមានការប៉ះពាល់គុណភាពទឹកស្ទឹងនេះ ដោយសារការលាងកករសម្អាតបាតអាត តាមរូងទូរនៃលពង្វៀងទឹករបស់គម្រោង។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវធ្វើការពិនិត្យ និងវិភាគគុណភាពទឹកនៅ ២ ចំណុចសំខាន់គឺ (១)-នៅក្នុងអាង (២)-ខាងក្រោមអាគារថាមពល, ឱ្យបានក្នុងមួយឆ្នាំយ៉ាងតិច ២ដង គឺធ្វើឡើងនៅខែ មិនា (រដូវប្រាំង) និងខែកញ្ញា រួចបញ្ចូលជាទិន្នន័យ (Excel) សម្រាប់ធ្វើការ វិភាគគុណភាពទឹកទៅថ្ងៃក្រោយ។

ក្រុមហ៊ុនត្រូវសាងសង់សំណង់បំបែកចរន្តទឹក ដែលនៅខាងក្រោមអគារថាមពល ដែលធ្វើឱ្យទឹកខ្ទាយឡើងហើយមានលទ្ធភាពស្រូបយកអុកស៊ីសែនបាន គ្រប់គ្រាន់ ហើយធ្វើឱ្យទឹកលែងមានក្លិនស្អុយ។

ពេលដែលបំពេញទឹកក្នុងអាងរួច ក្រុមហ៊ុនត្រូវធ្វើការសំអាតឈើដែលអណ្តែតទឹកឱ្យបានស្អាត ដោយមានកញ្ចប់ថវិកា ចំនួន ២០.០០០ ដុល្លារអាមេរិកសម្រាប់ប្រតិបត្តិការនេះមើលតារាង ៨-២។

ក្រុមហ៊ុនធ្វើការសិក្សា និងពិនិត្យតាមដានអំពីបរិមាណ/លក្ខណៈទឹកលើដី និងក្រោមដីជាប្រចាំក្នុង១ឆ្នាំ២ដងដូចការពិសោធន៍គុណភាពទឹកខាងលើដែរ។

ក្រុមហ៊ុននឹងត្រៀមបំពាក់ឧបករណ៍ និងសម្ភារ និងអ្នកឯកទេសសម្រាប់សំអាតរុក្ខជាតិទឹក និងសត្វល្អិតចង្រៃដែលនឹងអាចកើតមាននៅក្នុងអាងស្តុកទឹករបស់គម្រោងប៉ុន្មានឆ្នាំបន្ទាប់មក។

ក្រុមហ៊ុននឹងធ្វើការពិភាក្សាជាមួយក្រសួងធនធានទឹក (ផ្នែកជលសាស្ត្រ) និងក្រសួងបរិស្ថាន ដើម្បីកាត់បន្ថយផលប៉ះពាល់ដោយសារគុណភាពទឹក និងបរិមាណប្រសិនបើមានការបំពុលធ្ងន់ធ្ងរ ឬមានការខ្វះខាតទឹកមកតំបន់ខាងក្រោម។

នៅពេលដែលចាំបាច់សម្រាប់លាងកករបាតអាង គឺម្ចាស់គម្រោង នឹងធ្វើការលាងសម្អាតវានៅរដូវវស្សា ក្នុងចន្លោះខែសីហាដល់ខែវិច្ឆិកាព្រោះវាជាខែដែលស្ទឹងពោធិ៍សាត់មានទឹកច្រើនជាងគេជាមធ្យមចន្លោះពី១៤៥ទៅ៣៨៩ម³/វិនាទី។

## ខ. ធនធានជីវសាស្ត្រ

### ខ.១ ជីវសាស្ត្រដែលរស់នៅ ក្នុងទឹក/មច្ឆជាតិ

➢ ហេតុប៉ះពាល់អវិជ្ជមាន

យោងតាមការចុះសម្ភាស និងការសិក្សាចរាចរត្រីក្នុង និងជុំវិញតំបន់គម្រោង (មើលជំពូក៥ តារាង ៥-៤៥) បានបញ្ជាក់ឱ្យដឹងថា នៅស្ទឹងពោធិ៍សាត់ត្រង់តំបន់គម្រោងមានត្រី ៨៣ប្រភេទ។ ម៉្យាងទៀត ការបិទទ្វារទឹកដើម្បីតម្កល់ទឹកក្នុងអាងអាចប៉ះពាល់ដល់ប្រភេទវារីសត្វងាយរងគ្រោះថ្នាក់មួយចំនួនដូចជា អណ្តើកទឹក អណ្តើកដំបូកឬអណ្តើកព្រិច កន្ធាយ អាសុី ត្រីពោ ត្រីគល់រាំង ត្រីកាហែ ត្រីខ្យា ក្រពើភ្នំ (មានតិចតួច)ជាដើម។ល។ ដោយសារពួកវាមិនអាចឆ្លងកាត់ទំនប់ចុះឡើងបាន។ ក៏ប៉ុន្តែការបង្កើតអាងទឹកដ៏ធំនឹងមានការកើនឡើងនៃវារីសត្វផងដែរ ដូចជាសុភាសិតខ្មែរពោលថាទីណាមានទឹកគឺ ទីនោះមានត្រី។

Draft

ការបង្ហូរទឹកចេញពីអាង (តាមទួរប៊ីន) ដែលមានបរិមាណអុកស៊ីសែនរលាយក្នុងទឹកតិចធ្វើឱ្យប៉ះពាល់ដល់កត្តាជីវសាស្ត្រដែលរស់នៅក្នុងទឹក ឬមច្ឆជាតិនៅតំបន់ខាងក្រោមទំនប់មេ។

អាចធ្វើឱ្យប៉ះពាល់ដល់ការចរាចរត្រីពីខាងក្រោមទំនប់ទៅផ្នែកខាងលើទំនប់ ដែលបណ្តាលឱ្យបាត់បង់ ឬរារាំងការបង្កកំណើតរបស់ពពួកត្រីទាំងនោះផងដែរ។

អាងស្តុកទឹករបស់គម្រោងវារីអគ្គិសនីអាចនឹងកើតមានរុក្ខជាតិទឹក ដូចជាពើក ចក កំប្លោក និងសត្វល្អិតចង្រៃ ដូចជាមូស បាក់តេរីដែលបង្កឱ្យខ្វះអុកស៊ីសែនរលាយក្នុងទឹកធ្វើឱ្យវារីសត្វ ថយចុះ ឬបាត់បង់ ឬកើនឡើងនៃប្រភេទវារីសត្វថ្មីទៀត ដែលមិនធ្លាប់មានក្នុងតំបន់។

អាចនឹងមានការបំពុលទឹកដោយសំណល់រាវ-រឹងពីការិយាល័យ ផ្ទះបុគ្គលិក-កម្មករ ដែលស្នាក់នៅពីឃ្លាំងស្តុកសម្ភារ និង ពីរោងជាង។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវសហការជាមួយរដ្ឋបាលជលផល ដោយមានវិធានការព្រលែងកូនត្រី ដោយរកពូជត្រី ដែលងាយរងគ្រោះក្នុងតំបន់គម្រោង រួចយកវាទៅលែងតាមអូរ ស្ទឹង នៅក្នុងឬក្បែរតំបន់គម្រោង ជាពិសេសក្នុងស្ទឹងខាងក្រោមអាគារថាមពល ។ ***សម្គាល់:*** *ចំពោះតម្លៃនៃសំណង់ជណ្តើរ ត្រីឆ្លងកាត់បានមានតម្លៃរាប់លានដុល្លារ ដែលធ្វើឱ្យតម្លៃដើមរបស់អគ្គិសនីកើនខ្ពស់ផងដែរ។*

ក្រុមហ៊ុន ត្រូវធ្វើការសម្អាត សំណល់ថ្ម ដី ចេញពីអន្លង់ ទាំងអស់ដែលនៅខាងក្រោមទំនប់មេ ដែលខ្លួនឬអ្នកម៉ៅការសាងសង់បានធ្វេសប្រហែសឱ្យមានការលប់អន្លង់នានានៅតាមពោះស្ទឹង និងនៅឆ្នាំដំបូងក្នុងដំណាក់កាលនេះ ត្រូវព្រលែងទឹកតាម រូងទូនេលពង្រៀងទឹកសម្រាប់លាងកករដី ដែលកកនៅតាមពោះស្ទឹងខាងក្រោមទំនប់នេះ។ (អន្លង់នានាតាមពោះស្ទឹងជាជម្រករបស់ពពួកមច្ឆជាតិយ៉ាងសំខាន់)។

ក្រុមហ៊ុន ត្រូវសាងសង់សំណង់បំបែកចរន្តទឹកបន្ថែម ដែលនៅខាងក្រោមអាគារថាមពល ប្រសិនបើកម្រិតអ៊ុកស៊ីសែនរលាយ(DO) នៅមានកម្រិតទាបជាង២ម.ក្រ/ល ដែលធ្វើឱ្យទឹកខ្វាយឡើង ហើយមានលទ្ធភាពស្រូបយកអុកស៊ីសែនបានគ្រប់គ្រាន់ និងធ្វើឱ្យទឹកលែងមានក្លិនស្អុយ។

ក្រុមហ៊ុននឹងត្រៀមបំពាក់ឧបករណ៍ សម្ភារ និងអ្នកឯកទេសសម្រាប់សំអាតរុក្ខជាតិទឹក និងសត្វល្អិតចង្រៃ ដែលនឹងអាចកើតមាននៅក្នុងអាងស្តុកទឹករបស់គម្រោង បានល្អប្រសើរ។

ក្រុមហ៊ុនត្រូវថែទាំអាងប្រព្រឹត្តិកម្មសំណល់រាវសម្រាប់សំអាតទឹកកខ្វក់ពីការិយាល័យ ផ្ទះបុគ្គលិក កម្មករស្នាក់នៅឱ្យបានត្រឹមត្រូវ ហើយទឹកដែលបង្ហូរចេញពីអាងសំអាតនេះ ត្រូវមានកម្រិតតាមស្តង់ដានៃការបញ្ចេញចោលពីប្រភពបំពុលចូលទៅប្រភពទឹកសាធារណៈដែលមានចែងក្នុងអនុក្រឹត្យលេខ ២៧អនក្រ.បក របស់រាជរដ្ឋាភិបាល។

### ខ.២ ព្រៃឈើ ការពារ/ តំបន់ការពារ/ ឧទ្យានជាតិ

➢ ហេតុប៉ះពាល់អវិជ្ជមាន

តំបន់គម្រោងទំហំ ៩.៣៥៥ ហ.ត ស្ថិតនៅក្នុងតំបន់ព្រៃការពារតំបន់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ សរុបផ្ទៃដីមានចំនួន ៤.១៩៩,២ហ.ត (៤៥%) (លម្អិតមើលក្នុងជំពូក៥ ចំណុច៥.១.២.៣) ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល ៣៩៩,៧០ ហ.ត (៤%) និងតំបន់ការពារដែនជម្រកសត្វព្រៃភ្នំសំកុស ទំហំ ៤.៧៥៦,១ ហ.ត (៥១%) ហើយដែនជម្រកសត្វព្រៃភ្នំសំកុសត្រូវបានបែងចែកជា ៤តំបន់ដូចខាង ៖

| # | ប្រភេទតំបន់ | ផ្ទៃ (ហ.ត) |
|---|---|---|
| 1 | តំបន់ប្រើប្រាស់ដោយចីរភាព (តំបន់សហគមន៍ | 250.77 |
| 2 | តំបន់ការពារដោយសហគមន៍ | 106.64 |
| 3 | តំបន់អភិរក្ស | 3291.98 |
| 4 | តំបន់ស្នូល | 1171.86 |
| | **ផ្ទៃដីសរុប** | **4821.25** |

Draft

ក្នុងដំណាក់កាលប្រតិបត្តិថែទាំគម្រោងនេះ អាចនឹងមានការទន្ទ្រានចាប់ដីព្រៃក្នុងតំបន់ការពារ និងព្រៃការពារទាំងនោះ យកធ្វើកម្មសិទ្ធិពី សំណាក់បុគ្គលិក-កម្មករគម្រោង ឬជនឆ្លៀតឱកាសមួយចំនួន ដែលធ្វើឱ្យព្រៃឈើ និងសត្វព្រៃបាត់បង់។

- វិធានការកាត់បន្ថយ

ក្រុមហ៊ុនធ្វើការប្រឹក្សាជាមួយរដ្ឋបាលព្រៃឈើ ដែនជម្រកសត្វព្រៃភ្នំសំកុស និងអង្គការអភិរក្សនានា ដែលពាក់ព័ន្ធ រកទីតាំងសមស្របក្នុងតំបន់ព្រៃក្បែរតំបន់គម្រោងនេះសម្រាប់ដាំដុះឈើ ក្នុងព្រៃនេះ ទុកជាជម្រកដល់ សត្វព្រៃផង និងដើម្បីរក្សាលំនឹង អេកូឡូស៊ីបរិស្ថានក្នុងតំបន់នេះ ជាពិសេសព្រៃឈើស្រូបទាក់ទាញទឹកភ្លៀង ដែលជាប្រភពសម្រាប់វារីអគ្គិសនីទៀតផង។ **<u>បញ្ជាក់:</u>** ថវិកាសម្រាប់ដាំឈើ និងឧបត្ថម្ភអ្នកល្បាត មើលក្នុងតារាង៨-៣ ចំណុច ៨.៧។

ក្រុមហ៊ុនធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន នឹងធ្វើឡើងដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន អវិជ្ជមានដែលអាចកើតមានដោយថាហេតុលើព្រៃឈើដែលនៅជាប់ នឹងតំបន់គម្រោងក្នុងដំណាក់កាលនៃការសាងសង់នេះ។

ក្រុមហ៊ុនសហការជាមួយរដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន និងអង្គការអភិរក្សនានា ក្នុងការទប់ស្កាត់ការរាន ដីយកធ្វើកម្មសិទ្ធិខុសច្បាប់ ដោយបង្កើនកម្លាំងការពារ និងត្រួតពិនិត្យឱ្យបានហ្មត់ចត់។ ក្រុមហ៊ុនត្រូវដាក់ស្លាកសញ្ញា ឬសរសេរជាផ្ទាំងប៉ាណូធំ ដូចនៅតាមផ្លូវទៅកោះកុងដូចជាសរសេរថា " ព្រៃការពារ ហាមទន្ទ្រានកាន់កាប់ធ្វើជាកម្មសិទ្ធ ហាមកាប់ឈើ ឬបរបាញ់ខុសច្បាប់ ជនល្មើសត្រូវជាប់ទោសដាក់គុករហូតដល់១០ឆ្នាំ " ជាអក្សរខ្មែរ និងកូរ៉េ ឬអង់គ្លេសឱ្យបានច្រើន ដើម្បីឱ្យប្រជាពលរដ្ឋ និងជនបរទេស ងាយមើលឃើញក្នុងតំបន់គម្រោង។

### ខ.៣ ធនធានព្រៃឈើ និងជម្រកសត្វព្រៃ

- ហេតុប៉ះពាល់អវិជ្ជមាន

នៅក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោងនេះអាចនឹងប៉ះពាល់ដល់ជម្រកសត្វព្រៃ ដោយសារសកម្មភាពរបស់បុគ្គលិក-កម្មករទន្ទ្រានចូលព្រៃ ធ្វើការបរបាញ់ ឬដាក់អន្ទាក់សត្វ និងជួញដូរ ចរាចរឈើ និងសត្វព្រៃធ្វើឱ្យឈើ និងសត្វព្រៃទាំងនោះ ថយចុះឈានទៅរកការបាត់បង់ពូជមួយចំនួន ។

អាចនឹងមានការទន្ទ្រានកាន់កាប់ដីនៅក្នុង ឬក្បែរតំបន់គម្រោងពីសំណាក់បុគ្គលិក-កម្មករ ឬជនឆ្លៀតឱកាសនិយមមកពីខាងក្រៅធ្វើឱ្យបាត់បង់សម្បត្តិធម្មជាតិនៅតំបន់នោះ។

អាចកើតមានឡើងភ្លើងឆេះព្រៃក្បែរតំបន់គម្រោង ដោយសារបុគ្គលិក-កម្មករគម្រោង។

- វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវធ្វើការហាមឃាត់ដល់បុគ្គលិកកម្មកររបស់គម្រោងមិនឱ្យ ទន្ទ្រានកាន់កាប់ដី ឬរុករានព្រៃ និងបំផ្លាញជម្រកសត្វ ព្រៃនៅក្នុង និងក្បែរខាងតំបន់គម្រោង។

ក្រុមហ៊ុនត្រូវបញ្ជាឱ្យក្រុមការងារតាមផ្នែករបស់ខ្លួនធ្វើការអប់រំ និងហាមឃាត់ដល់បុគ្គលិក-កម្មករតាមផ្នែក ឬក្រុមរបស់ខ្លួនមិនឱ្យទន្ទ្រានចូលព្រៃ ធ្វើការបរបាញ់ ដាក់អន្ទាក់ រកឃ្មុំ ដែលអាចបង្កការឆេះព្រៃឈើ។

ក្រុមហ៊ុនត្រូវដាក់ពិន័យដល់បុគ្គលិកកម្មករណាដែលប្រព្រឹត្តិល្មើស នឹងការហាមឃាត់ខាងលើ។

ដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដែលអាចនឹងកើតឡើងដោយថាហេតុ នៅក្នុងតំបន់គម្រោងនោះ ក្រុមហ៊ុនត្រូវធ្វើការសហការជាមួយក្រសួងបរិស្ថានរដ្ឋបាលព្រៃឈើនិងអង្គការអភិរក្សនានាដើម្បីដោះស្រាយ។

ដោយឡែកចំពោះកិច្ចការពារអគ្គិភ័យ ក្រុមហ៊ុនបានបំពាក់នូវឧបករណ៍សម្ភារសម្រាប់ពន្លត់អគ្គិភ័យ/ភ្លើងឆេះព្រៃ និងប្រព័ន្ធឧបករណ៍ដែលឱ្យសញ្ញាពេលមានអគ្គិភ័យកើតមានឡើង។ ក្រុមហ៊ុន និងអ្នកម៉ៅការទាំងអស់ ត្រូវអនុវត្តជាប្រចាំនូវផែនការផែនការគ្រប់គ្រងសុវត្ថិភាព និងហានិភ័យ ដូចមានចែងក្នុងជំពូក ៤ ចំណុច ៤.៦.១២។

ជាបន្ថែម ក្រុមហ៊ុនត្រៀមមូលនិធិគ្រប់គ្រាន់ដើម្បីការពារ និងស្តារឡើងវិញនូវជម្រកសត្វព្រៃទាំងនោះដែលបាត់បង់ (ដូចជាការ ដាំឈើឡើងវិញនៅតំបន់ដែលគ្មានឈើដុះក្បែរនោះដោយធ្វើការជាមួយក្រសួងបរិស្ថាន រដ្ឋបាលព្រៃឈើ និងអង្គការអភិរក្សនានា។ <u>**បញ្ជាក់:**</u> ថវិកាសម្រាប់ដាំឈើ និងឧបត្ថម្ភអ្នកល្បាត មើលក្នុងតារាង៨-២ ចំណុច ៨.៧។

### ខ.៤ ជីវសាស្ត្រសត្វព្រៃ

➢ ហេតុប៉ះពាល់អវិជ្ជមាន

ការបាត់បង់ជម្រកព្រៃមួយចំនួនក្នុងតំបន់អាងស្តុកទឹករបស់វារីអគ្គិសនីនេះនឹងធ្វើឱ្យមានការថយចុះសត្វព្រៃមួយចំនួននៅក្នុងតំបន់គម្រោង ។

ការតម្កល់ក្នុងទឹកអាង ដែលមានផ្ទៃទឹកដ៏ធំធេងមិនអាចឱ្យសត្វព្រៃមួយចំនួនធំឆ្លងកាត់បាន ជាពិសេសការធ្វើចរាចររបស់ ត្រីក្នុងការឆ្លងកាត់ពីតំបន់ខាងក្រោមទំនប់ទៅតំបន់ខាងលើទំនប់។

ការទន្ទ្រានចូលព្រៃធ្វើការបរបាញ់ ដាក់អន្ទាក់ និងចាប់សត្វពីសំណាក់បុគ្គលិក-កម្មករ ដែលធ្វើប្រតិបត្តិការ និងថែទាំ គម្រោងក៏បណ្តាលឱ្យមានផលប៉ះពាល់ដល់សត្វព្រៃក្នុងតំបន់នេះផងដែរ ដូចជាថយចុះចំនួន និងបាត់បង់ពូជសត្វដែលកំពុងការពារដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ អង្គការអភិរក្សនានា និងក្រសួងបរិស្ថាន។

ការអភិវឌ្ឍនៅតំបន់នេះ អាចធ្វើឱ្យមានការហូរចូលជនចំណូលថ្មីមកពីតំបន់ផ្សេងៗដើម្បីទន្ទ្រានកាន់កាប់ដី និងរស់នៅទីនោះ ធ្វើឱ្យបាត់បង់ធនធានធម្មជាតិដែលជាទីជម្រកសម្រាប់បន្តពូជ និងរកចំណីរបស់សត្វក្នុងតំបន់ទាំងនោះ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រៀមមូលនិធិគ្រប់គ្រាន់ដើម្បីការពារ និងស្តារឡើងវិញនូវជម្រកសត្វព្រៃទាំងនោះដែលបាត់បង់ (ដូចជាការដាំឈើឡើងវិញនៅតំបន់ដែលគ្មានឈើដុះក្បែរៗនោះ ដោយធ្វើការជាមួយក្រសួងបរិស្ថាន រដ្ឋបាលព្រៃឈើ និងអង្គការអភិរក្សនានា។

ក្រុមហ៊ុនត្រូវសហការជាមួយដែនជម្រកសត្វព្រៃភ្នំសំកុស ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល និងរដ្ឋបាលព្រៃឈើក្នុងការអប់រំ ឱ្យស្គាល់ស្រឡាញ់និងចេះអភិរក្សសត្វព្រៃប្រភេទកំពុងរងគ្រោះថ្នាក់ មានប្រភេទជិតផុតពូជ(CR) ប្រភេទកំពុងរងគ្រោះ(EN) និងប្រភេទងាយ រងគ្រោះ(VU) ដូចជា ពង្រូល ទន្សោង ខ្ទីង កែះ ប្រើស ឈ្លូសយក្ស គេ ជាដើម។ល។

ក្រុមហ៊ុនត្រូវសហការជាមួយរដ្ឋបាលជលផល ដោយមានវិធានការព្រលែងកូនត្រី ទៅក្នុងអូរ ស្ទឹង នៅក្បែរតំបន់គម្រោង និងក្នុងអាងផងដែរ។

ក្រុមហ៊ុនត្រូវហាមឃាត់ដាច់ខាត ដល់បុគ្គលិក-កម្មកររបស់ខ្លួនក្នុងការប្រមាញ់ សត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គម្រោង។

ក្រុមហ៊ុនត្រូវអប់រំ និងដាក់វិន័យដល់បុគ្គលិក-កម្មករគម្រោងមិនឱ្យធ្វើការចាប់ ឬបរបាញ់សត្វព្រៃ និងធ្វើចរាចរលក់ដូរសត្វព្រៃនៅក្នុងតំបន់នេះឡើយ។

ដើម្បីការពារការកាន់កាប់រុករានទន្ទ្រានដីថ្មី ដែលជាព្រៃការពារ ពីជនចំណូលថ្មីទាំងនោះក្រុមហ៊ុន នឹងការសហការជាមួយអាជ្ញាធរ រដ្ឋបាលព្រៃឈើ និងស្ថាប័នមានសមត្ថកិច្ចត្រួតពិនិត្យ ដើម្បីទប់ស្កាត់បញ្ហានេះ។

Draft

### គ. ធនធានសេដ្ឋកិច្ចសង្គម

### គ.១ ការប្រើប្រាស់ដី និងការតាំងលំនៅឡើងវិញ

ក្នុងដំណាក់កាលនេះ មិនមានការប៉ះពាល់លើការប្រើប្រាស់ដី និងការរើទីតាំងលំនៅដ្ឋានរបស់ប្រជាជនទេ ពីព្រោះគម្រោង បានដោះស្រាយរួចរាល់ហើយក្នុងដំណាក់កាលសាងសង់គម្រោង។

### គ.២ ប្រពៃណី វប្បធម៌ និង សាសនា

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោងនេះអាចនឹងប៉ះពាល់ដល់ទំនៀមទំលាប់ប្រពៃប្រណីរបស់ប្រជាពលរដ្ឋ ដែលរស់នៅក្បែរតំបន់ដូចជាៈ ពួកគាត់មានជំនឿលើអារក្ស អ្នកតាព្រៃភ្នំដោយបង្កើតជាព្រៃអ្នកតាភ្នំជាដើម ដោយសារក្រុមហ៊ុននាំយកបុគ្គលិកកម្មករគម្រោងមកពីតំបន់ផ្សេងទៀត ឬជនបរទេស។

- វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវធ្វើការណែនាំអប់រំដល់បុគ្គលិក-កម្មកររបស់គម្រោង ឱ្យមានការគោរពទំនៀមទំលាប់ប្រពៃណី និងជំនឿរបស់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ព្រៃភ្នំស្ថិតនៅជុំវិញទីតាំងគម្រោង។

ជាងនេះទៅទៀត ក្រុមហ៊ុនត្រូវដាក់វិន័យដល់បុគ្គលិក-កម្មករគម្រោង ដែលបំពានលើទំនៀមទំលាប់ប្រពៃណី វប្បធម៌ និងជំនឿសាសនារបស់ប្រជាពលរដ្ឋក្នុង និងក្បែរតំបន់។

**គ.៣ ការប្រើប្រាស់ទឹក**

- ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោងនេះ អាចនឹងមានការប៉ះពាល់ដល់បរិមាណ និងគុណភាពទឹកស្ទឹងពោធិ៍សាត់នេះ ក្នុងការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋនៅតំបន់ ផ្នែកខាងក្រោម ដោយសារទឹកក្នុងអាងស្តុកមានគុណភាពមិនល្អ និងមានក្លិនស្អុយ មកពីការរលួយពីរុក្ខជាតិដែលលិចទឹក និងការខ្វះ អុកស៊ីសែនរបស់ទឹក និងជាពិសេសអាចមានការខ្វះទឹកសម្រាប់ប្រព័ន្ធស្រោចស្រព ដំណាក់អំពិល និង ចារឹក ។

ការគ្រប់គ្រងសំណល់រឹង/រាវ ដែលចេញពីការិយាល័យ ផ្ទះបុគ្គលិក/កម្មករ ឃ្លាំងស្តុកសម្ភារ រោងជាងជាដើម ដែលធ្វើឱ្យខូចដល់ប្រភពទឹកសម្រាប់ផ្គត់ផ្គង់ក្នុងតំបន់។

ម៉្យាងទៀត អាចមានការកើនឡើងនៃភ្ញៀវទេសចរជាតិ និងអន្តរជាតិដែលចង់ទៅទស្សនាកំសាន្តជ្រលងភ្នំព្រៃប្រឹក្សាស្ទឹងអូរធម្មជាតិ និងទស្សនានៅតំបន់ទំនប់វារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ និងវារីអគ្គិសនីស្ទឹងអាតៃ ក្រោយពីមានការសាងសង់រួច ពីព្រោះមានផ្លូវចេញចូលស្រួលធ្វើឱ្យអាចកើតមានការបំពុលទឹកស្ទឹង ដែលពាក់ព័ន្ធទាំងនោះដោយសារសំណល់រឹង-រាវរបស់ ភ្ញៀវទេសចរទាំងនោះ។

- វិធានការកាត់បន្ថយ

ពេលដែលបំពេញទឹកក្នុងអាងរួច ក្រុមហ៊ុនត្រូវធ្វើការសំអាតឈើដែលអណ្តែតទឹកឱ្យបានស្អាតដោយមានកញ្ចប់ថវិកាចំនួន ២០.០០០ដុល្លារអាមេរិកសម្រាប់ប្រតិបត្តិការនេះ មើលតារាង៨-២ ផ្នែក I លេខរៀង៤ ដើម្បីកុំឱ្យមានការរលួយសំបកឈើ និងឈើខូចគុណភាពទឹកក្នុងអាង។

ក្រុមហ៊ុនត្រូវសាងសង់សំណង់បំបែកចរន្តទឹកបន្ថែមទៀត ដែលនៅខាងក្រោមអាគារថាមពល ដែលធ្វើឱ្យទឹកខ្វាយឡើងហើយមានលទ្ធភាពស្រូបយកអុកស៊ីសែនបានគ្រប់គ្រាន់ និងធ្វើឱ្យទឹកលែងមានក្លិនស្អុយ ប្រសិនបើ DO មានកម្រិតតិចជាង 2mg/l នោះ។

ក្នុងដំណាក់កាលប្រតិបត្តិថែទាំគម្រោងនេះ គឺមានវិធានការដូចបានរៀបរាប់ក្នុង ចំណុច គ.៤ នៃដំណាក់កាលសាងសង់គម្រោងខាងលើរួចមកហើយ។ ជាងនេះទៅទៀត ប្រព័ន្ធស្រោចស្រពដំណាក់អំពិល និងចារឹក នឹងទទួលបានទឹកបន្ថែមពីគម្រោងនេះ យ៉ាងហោចណាស់ចំនួន ៤០ម$^{៣}$/វិន. ដែលលំហូរធម្មជាតិមានត្រឹមតែ ០,៦ ដល់ ១,៦ ម$^{៣}$/វិន. នៅរដូវប្រាំងតែប៉ុណ្ណោះ ដោយសារការបង្ហូរទឹកក្នុងការផលិតអគ្គិសនីក្នុងដំណើរការមួយទួបីន (40 MW )។

ក្រុមហ៊ុនសាងសង់ប្រព័ន្ធសំអាតទឹក ដើម្បីផ្គត់ផ្គង់ ដល់បុគ្គលិក-កម្មករគម្រោង។

ចំពោះអាងប្រព្រឹត្តកម្មសំណល់រាវសម្រាប់សំអាតទឹកកខ្វក់ពីការិយាល័យផ្ទះបុគ្គលិក-កម្មករដែលស្នាក់នៅក្រុមហ៊ុនត្រូវធ្វើការថែទាំអាងទាំងនេះ ហើយទឹកដែលបង្ហូរចេញពីអាងសំអាតនេះ ត្រូវមានកម្រិតតាមស្តង់ដានៃការបញ្ចេញចោលពីប្រភពបំពុលចូលទៅប្រភពទឹកសាធារណៈដែលមានចែងក្នុងអនុក្រឹត្យលេខ ២៧អនក្រ.បក របស់រាជរដ្ឋាភិបាល។

Draft

ក្រុមហ៊ុនត្រូវចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងសំណល់រឹង-រាវ ដោយសាងសង់បង្គន់អនាម័យព្រមទាំងរៀបចំប្រមូលសំណល់រឹង និងសម្រាមយកទៅចោលនៅទីតាំងដែលមានសុវត្ថិភាព។

ដើម្បីកែប្រែតំបន់នោះមានអនាម័យ និងបរិស្ថានល្អនោះក្រុមហ៊ុន នឹងធ្វើការសហការយ៉ាងជិតស្និតជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធសម្រាប់ការងារនេះ។

ជាងនេះទៅទៀត ក្រុមហ៊ុនវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ និងក្រុមហ៊ុនវារីអគ្គិសនីស្ទឹងអាតៃ ត្រូវសហការជាមួយក្រសួងបរិស្ថាន ព្រមទាំងក្រសួងទេសចរណ៍ និងអាជ្ញាធរក្នុងការគ្រប់គ្រងថែរក្សាអនាម័យ និងបរិស្ថានដើម្បីបង្កើតក្រុមការងារប្រមូលសម្រាមរួមមួយ ពីព្រោះគម្រោងទាំង២នេះស្ថិតក្នុងខេត្តពោធិ៍សាត់តែមួយ។

**គ.៤ តំបន់ទេចរណ៍/ រមណីដ្ឋាន/ ទីកន្លែងកំសាន្ត**

ក្នុងដំណាក់កាលនេះ មិនប៉ះពាល់ដល់ផ្នែកនេះទេពោលគឺមានផលប៉ះពាល់វិជ្ជមានទៅវិញ ដោយសារមានផ្លូវចេញចូល ស្រួលអាចជួយបង្កើតជាទេសចរណ៍ធម្មជាតិ និងអេកូទេសចរណ៍ ទៀតផង។

**គ.៥ ផ្លូវគមនាគមន៍**

- ហេតុប៉ះពាល់អវិជ្ជមាន

ដំណាក់កាលប្រតិបត្តិ និងថែទាំនេះអាចនឹងបង្កឱ្យប៉ះពាល់ ដល់ការប្រើប្រាស់ផ្លូវគមនាគមន៍របស់ប្រជាពលរដ្ឋក្បែរតំបន់គម្រោង ដូចជាការបិទផ្លូវមិនឱ្យប្រជាពលរដ្ឋចេញចូលជាដើម។

មានចរាចរណ៍កើនឡើង ធ្វើឱ្យមានការចង្អៀតលើដងផ្លូវ ការកកស្ទះចរាចរណ៍ ជាពិសេសអាចបង្កឱ្យមានគ្រោះថ្នាក់ ចរាចរដោយសារការធ្វើដំណើររបស់អ្នកទេសចរណ៍ ប្រជាពលរដ្ឋ និងបុគ្គលិក-កម្មកររបស់គម្រោងកាន់តែកើនឡើងដោយស្ថានភាព ផ្លូវតូចចង្អៀត និងមានចំណោទជាដើម។

- វិធានការកាត់បន្ថយ

នៅក្នុងដំណាក់កាលនេះក្រុមហ៊ុន ត្រូវធ្វើការចាក់កៅស៊ូលើកំណាត់ផ្លូវចាប់ពីចំណុចបំបែកនៃផ្លូវជាតិ៥៥ ដល់ទីតាំងទំនប់ ដែលមានប្រវែងសរុប ១២ គ.ម ព្រមទាំងមានការថែទាំផ្លូវ នេះជាប្រចាំទៀតផង។

ក្រុមហ៊ុនត្រូវអនុញ្ញាតឱ្យប្រជាពលរដ្ឋប្រើប្រាស់ផ្លូវ ដែលក្រុមហ៊ុនបានសាងសង់សម្រាប់បម្រើឱ្យគម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះផងដែរ។

ក្រុមហ៊ុនត្រូវដាំឈើធ្វើជារបងធម្មជាតិតាមសងផ្លូវចេញចូល និងលើដីជម្រាលដើម្បីទប់ស្កាត់ការហូរច្រោះ ការហុយធូលី សំឡេង និងធ្វើឱ្យមានសោភ័ណ្ឌភាព ទេសភាពល្អ។

ក្រុមហ៊ុនត្រូវធ្វើការសហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំដោះស្រាយចំពោះបញ្ហាផ្លូវ ដូចជាៈ ដាក់ស្លាកសញ្ញាចរាចរតាមដងផ្លូវ ធ្វើរបាំងការពារត្រង់ផ្លូវកោង មានចំណោទ និងបង្កើតប៉ុស្តិ៍ត្រួតពិនិត្យទំងន់រថយន្ត និងកម្ពស់នៃការផ្ទុកជាដើម ពីព្រោះបើផ្ទុកធ្ងន់ និងខ្ពស់ងាយធ្វើឱ្យរថយន្តងាយក្រឡាប់ និងបុកជញ្ជាំងភ្នំ។

**គ.៦ សុខភាពសាធារណៈ**

- ហេតុប៉ះពាល់អវិជ្ជមាន

គម្រោងវារីអគ្គិសនីនេះ ជាពិសេសក្នុងអាងអាចកើតមានរុក្ខជាតិទឹក ដូចជាចក កំប្លោក សារាយ ពើក និងសត្វល្អិតចង្រៃ ដូចជាមូស បាក់តេរី ឬសត្វល្អិត ដែលអាចបង្កជំងឺ និងចម្លងជំងឺទៅសត្វ និងមនុស្សបាន (Zonotic Diseases) និងជំងឺកើតឡើងពីប្រភពទឹក (Waterborn diseases)។

អាចបង្កឱ្យមានការប៉ះពាល់ដល់សុខុមាលភាពបុគ្គលិក-កម្មកររបស់ក្រុមហ៊ុន ដោយសារតំបន់នេះជាតំបន់កើតជំងឺគ្រុនចាញ់ គ្រុនសន្និ ។

ម៉្យាងវិញទៀត ដំណាក់កាលនេះ អាចបង្កឱ្យមានការប៉ះពាល់ដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់នេះ ដោយសារបុគ្គលិក-កម្មកររបស់ក្រុមហ៊ុន អាចចម្លងជំងឺផ្សេងៗដល់អ្នកភូមិក្បែរតំបន់គម្រោង ដូចជាជំងឺអេដស៍ ជំងឺកាមរោគជាដើម។ល។

រីឯការគ្រប់គ្រងសំណល់រឹង-រាវ មិនបានល្អនៅតំបន់គម្រោង ដូចជាតាមការិយាល័យ កន្លែងស្នាក់នៅបុគ្គលិកគម្រោងនោះ អាចនឹងមានការប៉ះពាល់ដល់សុខភាពសាធារណៈ ព្រមទាំងបុគ្គលិកគម្រោង។

ដំណាក់កាលនេះ ការបើកបិទ ទឹកសម្រាប់ដំណើរការផលិតអគ្គិសនីនៅរដូវប្រាំង ដែលមានធារទឹកពី៤០ ដល់ ៨០ ម$^{៣}$/វិនាទី ដែលមុនការសាងសង់គម្រោងមានតែ ០,៦ ទៅ ១,៦ម$^{៣}$/វិន. (ជាលក្ខណៈធម្មជាតិ) នាំឱ្យមានការប៉ះពាល់ ដល់ប្រជាពលរដ្ឋ អ្នកនេសាទ ឧបករណ៍នានា ដែលមាននៅក្នុងពោះស្ទឹង។ ជួនកាលអាចបណ្តាលឱ្យលិចតំបន់មួយចំនួននៅខាងក្រោម ដោយសារធារទឹក ៨០ ម$^{៣}$/វិនាទីនេះផងដែរ។

បន្ថែមពីលើនេះទៀត អាចមានគ្រោះថ្នាក់ដល់អាយុជីវិតប្រជាពលរដ្ឋ ឬទេសចរណ៍ ដែលទស្សនានៅតាមគន្លងខ្សែបញ្ជូនអគ្គិសនី ២៣០ kV ដែលងាយរងឥទ្ធិពលដែន អគ្គិសនីភ្លុចអាំងឌុចស្យុងអេឡិកត្រូស្តាទិក និងអេឡិកត្រូម៉ាញេទិក នៅពេលភ្លៀង (នៅតាមគន្លងខ្សែ៥គ.ម ពីស្ថានីយផលិតថាមពលនៃអាគារថាមពលរបស់គម្រោងនេះឆ្ពោះទៅបណ្តាញខ្សែ ២៣០គ.វ៉ អូរសោម-ពោធិ៍សាត់ ) លម្អិតជាងនេះមានចែងក្នុងចំណុច ။។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវធ្វើការពិនិត្យតាមដានគុណភាពទឹកក្នុងអាង និងក្រៅអាងឱ្យទៀងទាត់ជាប្រចាំ ប្រសិនបើគុណភាពទឹកក្នុង ឬក្រៅអាងមានការបំពុល ក្រុមហ៊ុននឹងរិះរកមធ្យោបាយដើម្បីធ្វើការកាត់បន្ថយដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ។

ក្រុមហ៊ុនត្រូវត្រៀមបំពាក់ឧបករណ៍-សម្ភារ និងអ្នកឯកទេសសម្រាប់សំអាតរុក្ខជាតិទឹក និងសត្វល្អិតចង្រៃដែលនឹងអាចកើតមាននៅក្នុងអាងស្តុករបស់គម្រោង។

ជាងនេះទៅទៀត ក្រុមហ៊ុន នឹងធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិក-កម្មករ ដើម្បីទប់ស្កាត់ជំងឺទាំងនោះកុំឱ្យកើតមាន និងឆ្លងទៅប្រជាពលរដ្ឋក្នុងតំបន់នោះ។

ក្រុមហ៊ុនត្រូវធ្វើការសហការជាមួយស្ថាប័នសុខាភិបាល ដើម្បីទប់ស្កាត់ជំងឺឆ្លង ដែលកើតឡើងជាយថាហេតុ។

ធ្វើការថែទាំអាងសិបទិកសម្រាប់ប្រព្រឹត្តិកម្មសំណល់រាវសម្រាប់សំអាតទឹកកខ្វក់ជាប្រចាំដើម្បីឱ្យវាមានសមត្ថភាពក្នុងការសំអាតទឹកសំអុយនេះឱ្យមានកម្រិតតាមស្តង់ដា នៃការបញ្ចេញចោលពីប្រភពបំពុលចូលទៅប្រភពទឹកសាធារណៈ ដែលមានចែងក្នុងអនុក្រឹត្យលេខ ២៧ អនក្រ,បក របស់រាជរដ្ឋាភិបាល។

រៀងរាល់មុនពេលបើកទឹកដំណើរការផលិតអគ្គិសនី ក្រុមហ៊ុនត្រូវផ្តល់ដំណឹងប្រាប់ឱ្យដឹងមុន ១៥ ទៅ៣០នាទី តាមការបំពាក់ឧបករណ៍ផ្តល់សញ្ញាគ្រោះថ្នាក់ និងបន្លឺស៊ីរ៉ែនជាដើម នៅតំបន់ខាងក្រោមអាគារថាមពល ដែលមានមនុស្សរស់នៅចម្ងាយ យ៉ាងតិច ៥០គ.ម តាមដងស្ទឹង ដើម្បីឱ្យអ្នករស់នៅខាងក្រោមនេះបានដឹង និងរត់គេច មកទីទួលសុវត្ថិភាព នៅពេលដែលបើកទឹកដំណើរការទួប៊ីនម្តងៗ (ទួប៊ីន ១ បញ្ចេញទឹក ៤០ម$^{៣}$/វិន. ទួប៊ីនពីរ ៨០ម$^{៣}$/វិន.។ ជាងនេះទៀត ប្រសិនបើមានការលិចលង់តំបន់កសិកម្មរបស់ប្រជាពលរដ្ឋ ឬខូចខាត ដល់ទ្រព្យសម្បត្តិ ឬដំណាំនានា ដោយសារប្រតិបត្តិគម្រោងនេះ ម្ចាស់គម្រោងជាអ្នកទទួលខុសត្រូវចេញសំណងតាមតម្លៃទីផ្សារ។ ប្រសិនបើ មន្ត្រីជំនាញ របស់ក្រសួងពាក់ព័ន្ធតម្រូវឱ្យ មានវិធានការ ការពារ កន្លែងលិច ដូចជាសាងសង់ទំនប់អមសងខាងច្រាំងស្ទឹង ម្ចាស់គម្រោងជាអ្នកទទួលខុសត្រូវចំណាយទាំងស្រុង។

សាងសង់បង្គោលឱ្យខ្ពស់ដែលធ្វើយ៉ាងណាឱ្យគម្លាតខ្សែដក់មកដីមានកម្ពស់ ១០ ម យ៉ាងតិចដើម្បីការពារកុំឱ្យមានគ្រោះ ថ្នាក់ដល់ប្រជាពលរដ្ឋ អ្នកទេសចរណ៍ និងអ្នកដំណើរនានា។

Draft

ជាងនេះទៅទៀត ក្រុមហ៊ុនត្រូវធ្វើការផ្សព្វផ្សាយជាប្រចាំអំពីគ្រោះថ្នាក់ក្នុងន័យអប់រំ និងដាក់ស្លាកជាអក្សរខ្មែរ អង់គ្លេស និង កូរ៉េមិនឱ្យមនុស្សមករស់នៅ ឬលើកបង្គោល ឬឡើងបង្គោលអគ្គិសនី ឬដាំដើមឈើ ក្នុងតំបន់គន្លងខ្សែអគ្គិសនីនេះ (មានចែងលម្អិតក្នុង ជំពូកទី៨)។

### គ.៧ សោភ័ណ្ឌភាព/ ទេសភាព

- ហេតុប៉ះពាល់អវិជ្ជមាន

នៅដំណាក់កាលប្រតិបត្តិ និងថែទាំ ការចោលសម្រាម និងការបន្ទោបង់ដោយគ្មានសណ្តាប់ធ្នាប់ពីសំណាក់ភ្ញៀវទេសចរណ៍ មកកំសាន្ត ប្រជាពលរដ្ឋ និងបុគ្គលិក-កម្មកររបស់គម្រោងធ្វើឱ្យបាត់សោភ័ណ្ឌភាពក្នុងតំបន់ ។

- វិធានការកាត់បន្ថយ

ក្រុមហ៊ុនវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ (KTC) និងក្រុមហ៊ុនវារីអគ្គិសនីស្ទឹងអាតៃ (C.H.D.) នឹងសហការជាមួយក្រសួងបរិស្ថាន ព្រមទាំងក្រសួងទេសចរណ៍ និងអាជ្ញាធរមូលដ្ឋានក្នុងការគ្រប់គ្រងថែរក្សាអនាម័យ និងបរិស្ថានដោយបង្កើតក្រុមការងារប្រមូលសម្រាមយកទៅចោលនៅទីដែលមានសុវត្ថិភាព។

### គ.៨ ហានិភ័យ

- ហេតុប៉ះពាល់អវិជ្ជមាន

នៅក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំនេះ ហានិភ័យនឹងអាចកើតមានដោយសារ ការធ្វេសប្រហែសផ្នែកសន្តិសុខ និង អំពើភេរវកម្ម ឬសង្គ្រាម។

រីឯបាតុភូតគ្រោះធម្មជាតិក៏អាចនឹងកើតមានដូចជាៈ ការរញ្ជួយដី (ដោយសារទំងន់អាងនេះ) នៅក្នុងតំបន់គម្រោង ការទទួលរងឥទ្ធិពល ពីព្យុះភ្លៀងទីហ្វុង ឬព្យុះផ្សេងទៀតពីឈូងសមុទ្រថៃ ដែលបង្កឱ្យមានមហន្តរាយធំៗដូចជាៈ ការបាក់ទំនប់ និងហេដ្ឋារចនាសម្ព័ន្ធ សំខាន់ៗរបស់គម្រោង ជាពិសេសការធ្វើឱ្យរងរបួស និងស្លាប់បាត់បង់ជីវិតដល់បុគ្គលិក-កម្មករ និងប្រជាពលរដ្ឋនៅក្នុង និងក្បែរ ខាងតំបន់គម្រោង ។

ការកើតមានការរញ្ជួយដី និងការបាក់ទំនប់ និងបាក់ភ្នំនាថ្ងៃអនាគត ដោយសារទំងន់ និងសំពាធទឹកក្នុងអាងស្តុកទឹកដែលមានចំណុះ ១.២២៦,៥ លាន ម៉ែត្រគូប ដែលនាំឱ្យខូចខាត បាត់បង់ទ្រព្យសម្បត្តិ ផ្ទះសម្បែង សត្វពាហនៈ ផលដំណាំ និងបាត់បង់អាយុជីវិតរបស់ប្រជាពលរដ្ឋ ដែលរស់នៅតាមដងស្ទឹងពោធិ៍សាត់ មានចាប់ពីចំណុចត្រពងពង្ស ឃុំប្រមោយស្រុកវាលវែង រហូតដល់ ក្រុងពោធិ៍សាត់។ ***បញ្ជាក់៖*** *ហេតុការណ៍នេះនឹងមិនមានការកើតឡើងជាដាច់ខាត ព្រោះវាជាអាយុជីវិត របស់ក្រុមហ៊ុនផងដែរ។*

ការឆេះព្រៃក្នុងតំបន់គម្រោង ដែលបណ្តាលមកពីការធ្វេសប្រហែស ឬអំពើភេរវកម្មក៏អាចបង្កឱ្យមានមហន្តរាយ/គ្រោះថ្នាក់ធំដល់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គម្រោង ធនធានធម្មជាតិក្នុងតំបន់ និងអាយុជីវិតមនុស្សទៀតផង។

ការកើតមានសង្គ្រាមឈ្លានពាន លើបូរណភាពទឹកដីនៃប្រទេសកម្ពុជា និងសង្គ្រាមផ្ទៃក្នុងក៏ជាឧបសគ្គដល់កិច្ចដំណើរការ និងថែទាំគម្រោងជួនកាលសង្គ្រាមអាចបំផ្លាញគម្រោងទាំងស្រុងទៀតផង។

- វិធានការកាត់បន្ថយ

បញ្ហាហានិភ័យដោយគ្រោះធម្មជាតិ ក្រុមហ៊ុនត្រូវធ្វើការសិក្សាតាមដានបន្ថែមទៀត នៅក្នុងដំណាក់កាលនេះលើហេតុការណ៍ប្រែប្រួលលើកត្តាធម្មជាតិ និងអត្ថសញ្ញាណនានាដែលអាចឈានទៅដល់ការបាក់ទំនប់ និងការបាក់ភ្នំក្នុងតំបន់គម្រោងវារី អគ្គិសនីស្ទឹងពោធិ៍សាត់នេះ។

រីឯបញ្ហាដែលកើតឡើងពីការធ្វេសប្រហែសផ្នែកសន្តិសុខ ឬភេរវកម្មនោះវិញ ក្រុមហ៊ុនត្រូវប្រុងប្រយ័ត្នគ្រប់វិនាទីក្នុងការ ការពារសន្តិសុខចំពោះគ្រឿងផ្ទុះនានា អគ្គិភ័យនានា និងធ្វើសហប្រតិបត្តិការណ៍ជាមួយស្ថាប័នមានសមត្ថកិច្ចដើម្បីទប់ស្កាត់រាល់ អំពើភេរវកម្មក្នុងតំបន់គម្រោង។

ម៉្យាងវិញទៀត ក្រុមហ៊ុននឹងធ្វើការផ្សព្វផ្សាយរាល់ហេតុការណ៍ ដែលអាចបង្កដល់ការបាក់ទំនប់ ការបាក់ភ្នំ ឬការរញ្ជួយដីក្នុងតំបន់គម្រោងដល់ប្រជាពលរដ្ឋដែលរស់ក្នុង និងក្បែរខាងគម្រោងនេះទាំងអស់ឱ្យបានជ្រាបហេតុការណ៍ខាងលើបានទាន់ពេលវេលាតាមតែអាចធ្វើទៅបានបើសិនជាមានហានិភ័យបែបនេះកើតឡើង។

ក្រុមហ៊ុនត្រូវបង្ហូរទឹកឱ្យអស់ពីអាងនៅពេលមានបញ្ហាគ្រោះថ្នាក់ ដោយចៃដន្យដូចជាៈ ការរញ្ជួយដី ឬសង្គ្រាម។

បន្ថែមពីលើនេះទៀត ក្រុមហ៊ុនត្រូវរៀបចំបំរុងទុកនូវក្រុមអ្នកជួយសង្គ្រោះ សម្ភារ និងថវិកាដើម្បីធានាការដោះស្រាយ ផលប៉ះពាល់ដែលនឹងអាចកើតពី មហន្តរាយខាងលើនេះទាន់សភាពការណ៍និងមានប្រសិទ្ធិភាព។

ជាទូទៅ ហានិភ័យដែលកើតឡើងពីការបាក់ទំនប់ កម្រនឹងកើតមានណាស់ ព្រោះវាទាក់ទងនិង ថវិកាក្រុមហ៊ុនផ្ទាល់ តែប្រសិនបើមានហានិភ័យនេះមែន មុនពេលដំណើការគម្រោង ក្រុមហ៊ុននឹងរកក្រុមហ៊ុនធានារ៉ាប់រងអន្តរជាតិ ធានាលើសំណង់វារីអគ្គិសនីនេះ ពេលមានហានិភ័យ នឹងសងការខូចខាត ដល់អ្នករងគ្រោះតាមស្តង់ដារអន្តរជាតិក្នុងតំបន់ ពោលគឺក្រោយពីការសាងសង់គម្រោងនេះចប់ម្ចាស់គម្រោងត្រូវរកក្រុមហ៊ុនបរទេសដើម្បីធារ៉ាប់រងលើគម្រោងនេះ។

### ៧.៤.៤ ដំណាក់កាលបិទគម្រោង (Project Closure)

ក្នុងដំណាក់កាលបិទគម្រោងរបស់ក្រុមហ៊ុន KTC នៃប្រទេសកូរ៉េនេះ នឹងធ្វើឡើងក្រោយពីចប់កិច្ចសន្យាជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្រោយពេលដំណើរការបានតាមកិច្ចសន្យាអភិវឌ្ឍគម្រោងមក (រយៈពេល៣៥ឆ្នាំ ក្រោយដំណាក់កាលសាងសង់គម្រោង) ហើយចំពោះការផ្ទេរហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនីនេះនឹងមានចែងលម្អិត នៅក្នុងកិច្ចសន្យាដូចដែលរាជរដ្ឋភិបាលបានបានធ្វើជាមួយក្រុមហ៊ុនវារីអគ្គិសនីផ្សេងៗទៀតដែរ។រាជរដ្ឋាភិបាលកម្ពុជានឹងទទួលបន្ទុកធ្វើការគ្រប់គ្រងបន្តដូចនេះសកម្មភាពបិទគម្រោងអាស្រ័យទៅនឹងរដ្ឋាភិបាលកម្ពុជាសម្រេចខ្លួនឯង ហើយសង្ឃឹមថា ក្នុងដំណាក់កាលបិទគម្រោងរបស់ក្រុមហ៊ុនកូរ៉េនេះ ពុំមានការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ដែលគួរឱ្យកត់សម្គាល់ឡើយ។ (ចំពោះបទដ្ឋានបច្ចេកទេស និងគុណភាពរបស់ហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនី ដែលនឹងត្រូវប្រគល់ជូនរាជរដ្ឋភិបាលវិញមានចែងលម្អិតក្នុងកិច្ចសន្យានោះហើយ)។

ជាងនេះទៅទៀត ក្រុមហ៊ុនត្រូវធ្វើផែនការច្បាស់លាស់នៃការជួសជុល រាល់ការខូចខាតនៃសំណង់ពាក់ព័ន្ធនានារបស់គម្រោង និងត្រូវសំអាត សំណល់រឹង-រាវ គ្រប់ប្រភេទចេញពីការដ្ឋាន កន្លែងស្នាក់នៅរបស់បុគ្គលិក-កម្មករគម្រោងរោងជាងចំណតយានយន្តឃ្លាំងផ្ទុះបាយជាដើមដោយសំណល់ទាំងនោះត្រូវធ្វើកន្លែងទុកដាក់ឱ្យមានសុវត្ថិភាពបរិស្ថានល្អ។

***<u>សម្គាល់:</u>*** *ការប្រគល់គម្រោងនេះឱ្យទៅរាជរដ្ឋាភិបាលគ្រប់គ្រងបន្ត នឹងមានបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីពិនិត្យគុណភាពសំណង់ទាំងអស់របស់គម្រោង ដូចដែលបានចែងក្នុងកិច្ចសន្យា។*

ការប៉ាន់ប្រមាណ និងកំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយត្រូវបានដកស្រង់ ចេញពីតារាង៧-៤ ដូចខាងក្រោម ៖

Draft

## ៧.៥ សង្ខេបទំហំនៃហេតុប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ

### តារាង ៧-២ ៖ តារាងសង្ខេបទំហំនៃហេតុប៉ះពាល់អវិជ្ជមាន និងវិធានការកាត់បន្ថយ

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| **១. ហេតុប៉ះពាល់បរិស្ថានក្នុងដំណាក់កាលមុនប្រតិបត្តិគម្រោង** | | | | | | |
| **១.១ ដំណាក់កាលមុនសាងសង់ (ការគ្រោងរចនាគម្រោង)** | | | | | | |
| ក.ធនធានរូបសាស្ត្រ | | | | | | |
| ក.១ សណ្ឋានដី និងឋានលេខា | • សណ្ឋានដី និងឋានលេខា គឺជាសណ្ឋាន ទ្រង់ទ្រាយ នៃផែនដី។ ការគ្រោងគម្រោងមិនបានត្រឹមត្រូវអាចមានការប៉ះពាល់ដល់សណ្ឋាន ទ្រង់ទ្រាយដីក្នុងតំបន់សាងសង់ ដូចជាការកាយជញ្ជាំងភ្នំដើម្បីពង្រាបធ្វើផ្លូវចេញចូល ការជីករណ្ដៅដីរណ្ដៅកន្លែងយកថ្ម ការចាក់គរដីស្អុយ និងថ្ម ដែលជញ្ជាំងនៃកន្លែងទាំងនេះ មិនមានជម្រាលជើងទេរច្បាស់លាស់ទៅតាមបទដ្ឋានដី និងថ្ម នាំឱ្យបាក់ដី បាក់ថ្មខូចសណ្ឋាន ទ្រង់ទ្រាយដីក្នុងតំបន់ដែលនឹងត្រូវសាងសង់។ ឧទាហរណ៍ ការជីករណ្ដៅដី ល្បាយខ្សាច់ ត្រូវមានជើងទេរនៃជញ្ជាំង ១/២ ចំពោះដីឥដ្ឋ ១/១.៥ ជាដើម។ បើមិនអញ្ចឹងទេ នាំឱ្យមានការបាក់ដី រាលទៅតំបន់ជុំវិញ។ ម្យ៉ាងទៀត ការចាក់គរសំណល់ដីនិងថ្មខ្ពស់ជាង ៣ ម វាលធ្វើឱ្យមានការបាក់កាល គំនរដីឬថ្មនោះទៅតំបន់ជុំវិញ លប់ពីលើដីមានជីជាតិ លុបគល់ឈើបណ្ដាលឱ្យងាប់ឈើនោះផងដែរ។ | | ✓ | | • គ្រោងរចនាប្លង់គម្រោងលម្អិតឱ្យមានជើងទេរ និងជម្រាលជញ្ជាំងកន្លែងកាយដី ជញ្ជាំងរណ្ដៅដីរណ្ដៅកន្លែងយកថ្ម កន្លែងចាក់ដីស្អុយនិងថ្ម ត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសរបស់ប្រភេទដីនិងថ្ម ដែលមាននៅតំបន់គម្រោងដោយខ្វះសិក្សាដី និងថ្មឱ្យបានច្បាស់លាស់ ដូចជា ដីល្បាយខ្សាច់ ត្រូវមានជើងទេរនៃជញ្ជាំង 1:2 ចំពោះដីឥដ្ឋ 1:1.5 ថ្មផុយពី 1:1 ទៅ 1:1.5 ថ្ម 1: 0.5 ទៅ 1:1 ជាដើម ដើម្បីកុំឱ្យមានការបាក់ដី ឬបាក់ថ្មលប់លើដីចាស់ដែលមានជុំវិញតំបន់នេះ។ | |
| ក.២ ប្រពន្ធ័ជលសាស្ត្រ (អូរ ស្ទឹង) | • ការគ្រោងគម្រោងមិនបានត្រឹមត្រូវ មានការប៉ះពាល់ដល់ប្រពន្ធ័ជល សាស្ត្រ និងជីវៈចំរុះក្នុងស្ទឹងពោធិ៍សាត់នៅផ្នែកខាងក្រោម កន្លែង សាងសង់ទំនប់នេះ ដោយខ្វះទឹក និងមិនបានគិតគូរអំពីការធ្វើសំណង់ បន្ថែម ដើម្បីបញ្ចេញទឹកមកខាងក្រោមតំបន់ទំនប់ទេ នៅពេល ប្រតិបត្តិ និងថែទាំគម្រោង។<br>• ប៉ះពាល់ដល់ចរាចរត្រីព្រៃបើចទឹកតាមមាត់ស្ទឹង និងសត្វទឹក ដោយសារការគ្រោងទំនប់កាត់ស្ទឹងនេះ ដោយមិនមានការបង្ហូរទឹកមកតំបន់ ខាងក្រោមទំនប់គ្រប់គ្រាន់សម្រាប់ការពារប្រព័ន្ធជីវៈចំរុះរបស់កំណាត់ ស្ទឹងនេះ ហើយនិងអាចធ្វើឱ្យបង្អាក់ ដំណើរត្រីនៅខាងក្រោមឡើង ទៅតំបន់ខាងលើដើម្បីពងកូនទៀតផង។ | | | ✓ | • ត្រូវគ្រោងរចនាប្លង់គម្រោង ឱ្យមានសំណង់ និងទ្វារទឹកដែលអាចបញ្ចេញទឹកមក ខាងក្រោមនៃទំនប់ទឹកតាំងទំនប់នេះ ដើម្បីរក្សាលំនឹងធនធានបរិស្ថានស្ទឹង ពោធិ៍សាត់ មានដូចតទៅ:<br>I. ***តំបន់១***: នៅខាងក្រោមតំបន់ទំនប់ ដល់អាគារថាមពល តាមដងស្ទឹងមានចម្ងាយប្រមាណ៩,៧គ.ម។ នៅតំបន់នេះ ក្រុមហ៊ុន នឹងធ្វើការបញ្ចេញទឹកពីអាង ចំនួន ១,៣ម៣/វិន.គតដាច់ទាំងប្រាំង និងវស្សា។ ប៉ុន្តែនៅ២ឆ្នាំដំបូង ក្នុងរយៈពេលប្រតិបត្តិ និងថែទាំគម្រោង ក្រុមហ៊ុនត្រូវធ្វើការបិទទ្វារទឹក ដើម្បីបំពេញអាងក្នុងនោះនៅឆ្នាំទី១ ត្រូវការរយៈពេលពី៥ទៅ៨ខែ ក្នុងការបំពេញទឹកក្នុងអាងឱ្យដល់នីវ៉ូ EL: ១៨០ម ដើម្បីដំណើរការទួរ២បីន (៨០ MW)។ នោះមានន័យថា ៥ខែដំបូងនៃឆ្នាំទី១នេះ មិនមានទឹកគ្រប់គ្រាន់ សម្រាប់រក្សាជីវៈចំរុះនារដូវវស្សានោះទេពោល គឺមានតែ១,៣ម៣/វិន. និងលំហូរធម្មជាតិពីទឹក ភ្លៀងក្នុងតំបន់តែប៉ុណ្ណោះ។ យោងតាមលំហូរធារទឹកនៃរយៈពេលកត់ត្រា៣០ឆ្នាំ (មើលតារាង៥-១១) បញ្ជាក់ថា នៅរដូវវស្សា | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | | | | | ចាប់ពី ខែឧសភា ដល់ខែតុលា ស្ទឹងពោធិ៍សាត់មានលំហូរ អប្បបរមា ០,៦ម៣/វិន. ហើយអតិបរមា ៣៨៩,២ ម៣/វិន.។ ដូចនេះក្នុងរយៈពេល ៥ខែ ដំបូងនៃឆ្នាំទី១ ក្រុមហ៊ុនធ្វើការបញ្ចេញទឹកមកខាងក្រោម ទំនប់យ៉ាងហោចណាស់ឱ្យ បាន ១,៣ម៣/វិន. ដែរ។ បើធ្វើដូចនេះមានន័យថាៈ នៅរដូវវស្សា តំបន់នេះមានលំហូរ លើស ១,៣ ម៣/វិន. ហើយរដូវប្រាំង ពី១,៣ម៣/វិន នៅរយៈពេល២ឆ្នាំដំបូង។ ចាប់ពីឆ្នាំទី៣ ទៅនឹងមានទឹកបន្ថែមនារដូវវស្សាដោយសារ ការហៀរទឹក ចេញតាមទំនប់បង្ហៀរ។<br>2. ***តំបន់២***: គឺតំបន់ក្រោមអាគារថាមពល (PH) តាមដងស្ទឹងពោធិ៍សាត់មានទំនប់សំណង់ធារាសាស្រ្តដំណាក់ឈើក្រំ (កំពង់សាងសង់ចម្ងាយ៦២គ.ម) ដំណាក់អំពិលចម្ងាយប្រមាណ១០៣គ.ម ដែលទទួលយកទឹក ពីគម្រោងនេះ។ នៅដំណាក់កាលប្រតិបត្តិថែទាំគម្រោង និងមានការខ្វះទឹក នៅពេល ដែលក្រុមហ៊ុនធ្វើការបិទទំនប់ដើម្បីតម្កល់ទឹកនៅឆ្នាំទី១ ដូចនេះក្រុមហ៊ុនត្រូវព្រលែងទឹកនៅរដូវវស្សាយ៉ាងហោច ៤០ ម៣/វិន. និងរដូវប្រាំង ១,៣ម៣/វិន. តាមបំពង់បង្ហូរទឹកបរិស្ថាន ពីព្រោះប្រព័ន្ធធារាសាស្រ្តនៅដំណាក់ឈើក្រំ និងដំណាក់អំពិលនេះត្រូវការទឹកស្រោចស្រពនៅរដូវវស្សា និងប្រាំង (មើលតារាង៥-១១ លំហូរធារទឹកជាមធ្យមគឺ ៤២,៤ ម៣/វិន.)។ ដូចនេះ ចំពោះការខ្វះទឹកសម្រាប់ រក្សាជីវៈចំរុះ និងតំរូវការទឹកសម្រាប់ស្រោចស្រពនោះគឺត្រូវបានកាត់បន្ថយអាចទទួលយកបាន បើក្រុមហ៊ុនអនុវត្តតាមការគ្រប់គ្រងទឹកខាងលើ។ នៅពេលដែលនីវ៉ូទឹកក្នុងអាងឡើងដល់កម្រិតអាចដំណើរការទួរប៊ីន នោះក្រុមហ៊ុន នឹងដំណើរការទួរប៊ីន១ដែលមានធារទឹក៤០ម៣/វិន. និងរហូតដល់ដំណើរការទាំង២ទួប៊ីន ដែលត្រូវបញ្ចេញធារទឹកសរុប៨០ម៣/វិន.។ នៅរដូវវស្សាតំបន់នេះយ៉ាងហោចណាស់ ត្រូវព្រលែងទឹក ៤០ម៣/វិន. បើមិនដូច្នេះទេនោះ នឹងធ្វើឱ្យមានខ្វះខាតក្នុងការផ្គត់ផ្គង់ទឹក មកតំបន់ធារាសាស្រ្តដំណាក់ឈើក្រំ និងដំណាក់អំពិលជាមិនខាន។ ចំណែកឯ នៅរដូវប្រាំង ការផលិតអគ្គិសនី ដែលដំណើរការបើកទួរប៊ីន២ មានធារទឹកសរុប ប្រមាណ៨០ម៣/វិន. នោះអាចផ្តល់ទឹកគ្រាន់ ដល់ប្រព័ន្ធធារាសាស្រ្តទាំងនេះ នៅរដូវប្រាំងមិនខ្វះទឹកដូចដំណាក់កាលមុនសាងសង់គម្រោងទៀតឡើយ។ ***សម្គាល់:*** *នៅដំណាក់កាលប្រតិបត្តិថែទាំ គម្រោង នៅរដូវប្រាំង យោងតាម EDC ចង់បានអគ្គិសនី ២៤ម៉ោង លើ៦ខែ នៅរដូវប្រាំង នោះនឹងមានធារទឹក៨០ម៣/វិន. បើប្រៀបធៀប ធារទឹកស្ទឹងពោធិ៍សាត់នៅទីតាំងទំនប់មេ មានប្រហាក់ប្រហែលធារទឹកក្នុងខែ ឧសភា មិថុនា និងកក្កដា មើលតារាង៥-១១។* | |
| គ.៣ ការហូរច្រោះ: | • ការហូរច្រោះដីពុំមានទេ ដោយសារក្រុមហ៊ុនពុំបានឈូសឆាយ និង ពង្រាបដីដើម្បីសិក្សាឡើយ។ ប៉ុន្តែបើគម្រោងមិនរៀបចំប្លង់នៃការ ជីកដីធ្វើជើងទេមិនត្រឹមត្រូវនោះ ពេលសាងសង់គម្រោង នាំឱ្យមានការ បាក់ជញ្ជាំងដី ធ្វើឱ្យស្ទះការងារសាងសង់ និងអាចនាំគ្រោះថ្នាក់ដល់ បនុស្ស សត្វ ទៀតផង។ | ✓ | | | • ត្រូវគ្រោងការងារដី ដូចជាការកាយយជញ្ជាំងភ្នំធ្វើផ្លូវ ធ្វើហេដ្ឋារចនាសម្ព័ន្ធវារី អគ្គិសនីដទៃទៀត ត្រូវមានជើងទេត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស និងមាន ដាក់របាំងការពារបាក់ដីនៅតាមដងផ្លូវដែលមានចំណោតខ្ពស់ រួមទាំងបាញ់បាយអ នៅជញ្ជាំងចំណោតខ្ពស់ៗតាំងនោះទៀតផង។ | |

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | • មានផលប៉ះពាល់ខ្លះៗ បណ្តាលមកពីការហៀរ ឬកំពប់ប្រេង និងការបោះសំណល់ផ្សេងៗដោយបុគ្គលិក/កម្មកររបស់គម្រោងក្នុងពេល សិក្សានោះ។ | | | | • ត្រូវមានការស្តុកប្រេងឥន្ធនៈ ឱ្យបានត្រឹមត្រូវតាមបទដ្ឋានសុវត្ថិភាព ដល់បរិស្ថាន ដោយប្រើប្រាស់ម៉ាស៊ីន គ្រឿងចក្រ និងរថយន្តដឹកជញ្ជូន ដែលមានគុណភាពល្អ មិនលេចហូរប្រេងមកលើដីក្នុងតំបន់គម្រោងឡើយ។<br>• ត្រូវគ្រប់គ្រងសំណល់ប្រេងឱ្យបានត្រឹមត្រូវ។ រីឯសំណល់រឹងចេញ ពីកន្លែងស្នាក់នៅរបស់កម្មករ/បុគ្គលិកវិញក្រុមហ៊ុនរៀបចំធុងសម្រាម និងរៀបចំ កន្លែងទុកដាក់សម្រាមនៅ ទីតាំងដែលមានសុវត្ថិភាពល្អ។ | |
| ក.៤ ការរញ្ជួយដី មិនហែនប្រើគ្រឿនផ្ទុះ ឬដឹកសម្ភារធ្ងន់ៗ ដែលនាំឱ្យមានការរញ្ជួយទេ។ ប៉ុន្តែត្រូវគ្រោងគ្រឿងផ្ទុះ ដែលមានសំឡេងការរញ្ជួយតិច និងមានកន្លែងទុកដាក់ ដោយមានដាក់បារដើឥព័ទ្ធជុំវិញ ការពារពេលមានគ្រោះថ្នាក់ចៃដន្យ ណាមួយនោះ។ គម្រោងត្រូវគ្រោងកម្មករយាម(សន្តិសុខ) ឱ្យបានហ្មត់ចត់ ជៀសវាងការលួច ឬបាត់បង់គ្រឿនផ្ទុះ ដែលនាំឱ្យកើតមានការប្រើប្រាស់ ជាតិផ្ទុះខុសច្បាប់ នឹងអាចបង្កឱ្យមានអសន្តិសុខសង្គម និងមានការបាត់បង់អាយុជីវិតមនុស្ស និងសត្វផងដែរ។ | | | | | | |
| ក.៥ គុណភាពទឹក (ទឹកលើដីនិងក្រោមដី) | • មានផលប៉ះពាល់តិចតួច ដោយសារការបង្ហូរសំណល់រាវចេញ ពីផ្ទះបាយនិងការបន្ទោបង់របស់បុគ្គលិក-កម្មករគម្រោងចូលក្នុងទឹក។ តែពេលសាងសង់គម្រោងបុគ្គលិក-កម្មករហូតដល់ ៤០០នាក់ អាចបំពុលគុណភាពទឹក ដោយសារ សំណល់រឹង-រាវ ការបោកគក់ ការចុះងូត ឬបង្ហូរទឹកចូលស្ទឹងដោយផ្ទាល់។ | ✓ | | | • សាងសង់បង្គន់អនាម័យ ដោយជីករណ្តៅដាក់លូមានជម្រៅពី២,៥ ទៅ៣,៥ម ដើម្បីសំលាប់មេរោគ។ ចំពោះសំណល់ផ្ទះបាយវិញ គឺជីករណ្តៅជម្រៅ១-២ម ទំហំ៤-៦ម២ ដើម្បីធ្វើឱ្យសំណល់នោះក្លាយជាជីកំប៉ុស បានថែមទាំងមាន ធុងទុកសម្រាប់ដាក់សម្រាម និងកន្លែងដុតសម្រាមចោលដោយ សុវត្ថិភាព។<br>• ធ្វើការណែនាំបុគ្គលិក/កម្មករគម្រោង ឱ្យយល់ដឹងអំពីអនាម័យស្គាល់នូវកន្លែង ទុកដាក់សម្រាម ដែលក្រុមហ៊ុនបានរៀបចំកសាង ក្នុងទីតាំងស្នាក់នៅរបស់ គម្រោង។ | |
| ក. ៦ គុណភាពខ្យល់ | • មានការបំពុលតិចតួច ដោយសារមានផ្សែងដែលចេញ ពីគ្រឿងយន្ត ដែលយកមកសិក្សាគម្រោង ដូចជា ម៉ាស៊ីនខួងដីសម្រាប់សិក្សាអំពីគ្រឹះ ទំនប់ រថយន្ត ម៉ូតូ ជាដើម សម្រាប់ដឹកជញ្ជូនជាដើម។ | ✓ | | | • ប្រើម៉ាស៊ីន និងគ្រឿងយន្ត ដែលមានគុណភាពល្អ និងមានបំពង់ស៊ីម៉ុងសម្បុកជិតល្អ ដើម្បីកាត់បន្ថយការបញ្ចេញ ផ្សែង។<br>• ប្រើប្រេងឥន្ធនៈដែលមានគុណភាពដែលមានចំហេះសប់ឥតនាំឱ្យមានផ្សែងតិច។ | |
| ក. ៧ គុណភាពដី | • មានការបំពុលតិចតួចបណ្តាលមកពីការហៀរ ឬកំពប់ប្រេង និងការ បោះសំណល់ផ្សេងៗ ដោយបុគ្គលិក/កម្មកររបស់គម្រោងក្នុងពេល សិក្សានោះ។ | ✓ | | | • ស្តុកប្រេងឥន្ធនៈ ឱ្យបានត្រឹមត្រូវតាមបទដ្ឋានសុវត្ថិភាពដល់បរិស្ថាន ដោយប្រើប្រាស់ម៉ាស៊ីន គ្រឿងចក្រ និងរថយន្តដឹកជញ្ជូនដែលមានគុណភាពល្អ មិនលេចហូរប្រេងមកលើដីក្នុងតំបន់គម្រោងឡើយ។<br>• គ្រប់គ្រងសំណល់ប្រេងឱ្យបានត្រឹមត្រូវ។ រីឯសំណល់រឹងចេញ ពីកន្លែង ស្នាក់នៅរបស់កម្មករ/បុគ្គលិកវិញក្រុមហ៊ុន រៀបចំធុងសម្រាម និងរៀប ចំកន្លែងទុកដាក់សម្រាមនៅទីតាំងដែលមានសុវត្ថិភាពល្អ។ | |
| ក. ៨ សំឡេង និងរំញ័រ | • មានការប៉ះពាល់តិចតួច ដោយសារមានការខួងដីសម្រាប់សិក្សាអំពី គ្រឹះទំនប់ ហើយសកម្មភាពនៃការខួងដីនេះ ត្រូវការកម្មករជាច្រើន នាំបង្កឱ្យមានសំឡេងអ៊ូអរ និងសម្ទឹកសំឡេងម៉ាស៊ីនបង្កឱ្យមានការ រំខានដល់សត្វព្រៃ។ | ✓ | | | • ប្រើម៉ាស៊ីនខួងដីដែលមានកម្រិតរញ្ជួយ និងសំឡេងតិច ដើម្បីកាត់បន្ថយសំឡេង និងរំញ័រ ដែលរំខានដល់សត្វព្រៃ។<br>• មិនធ្វើការពេលយប់ទេ ដើម្បីកាត់បន្ថយការរំខានដល់សត្វព្រៃ។ | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | | | | | • អប់រំកម្មកររបស់គម្រោងមិនឱ្យមានការស្រែក ឬជដេកគ្លាខ្លាំងៗ រំខានដល់សត្វ ព្រៃ។ | |
| ខ. ធនធានជីវសាស្ត្រ | | | | | | |
| ខ.១ ជីវសាស្ត្រដែលរស់ នៅក្នុងទឹក/មច្ឆជាតិ | • យោងតាមគម្រោងប្លង់សម្រាប់ការសាងសង់ទំនប់វារីអគ្គិសនីស្ទឹងពោធិ៍សាត់នេះ គឺពុំមានរចនាប្លង់គម្រោងសម្រាប់ឱ្យត្រីឆ្លងកាត់នោះទេ ដែលជាហេតុធ្វើឱ្យមានបញ្ហាប៉ះពាល់ដល់ចរាចរត្រី និងកន្ទាយនៅពេលដែលគម្រោងទាំងមូលនឹងសាងសង់ និងដំណើរការ។ តាមអន្លង់មួយ ចំនួន ដូចជាអន្លង់ជ្រៃ អន្លង់បឹងជាដើមមានក្រពើក្អុំរស់នៅ ដូចនេះ ពេលសាងសង់ និងតម្កល់ទឹកក្នុងអាងមានផលប៉ះពាល់ដល់ក្រពើ ទាំងនេះ។<br>• ប៉ះពាល់ ដល់ពពួកមច្ឆជាតិ ដោយសារ ការចាក់សំណល់ដី ថ្ម ចូលក្នុងស្ទឹង ធ្វើលប់អន្លង់ដែលជាជម្រករបស់ពពួកវា និងបំពុលគុណភាពទឹក ដោយសារដី ថ្ម ទាំងនេះផងដែរ។ | | ✓ | | • ត្រូវរកវិធានការ ដើម្បីជំនួសសំណង់សិល្បការសម្រាប់ឱ្យត្រីឆ្លងកាត់នេះ ដោយបង្កើតស្ថាននីយចិញ្ចឹមត្រី (រើសពូជក្នុងតំបន់) និងមូនិធិសម្រាប់សង្គ្រោះក្រពើភ្នំ រួចធ្វើការព្រលែងត្រីទាំងនេះចូលក្នុងអូរស្ទឹងធម្មជាតិ ដែលមានលក្ខណៈទីជម្រក ប្រហាក់ប្រហែលគ្នា ដោយធ្វើការសហការជាមួយរដ្ឋបាលជលផល។<br>*(សម្គាល់: ចំពោះតម្លៃនៃសំណង់សម្រាប់ត្រីឆ្លងកាត់បានមានតម្លៃរាប់លាន ដុល្លារ ដែលធ្វើឱ្យតម្លៃដើមរបស់អគ្គិសនីកើនខ្ពស់ផងដែរ ធ្វើឱ្យប៉ះពាល់ដល់តម្លៃ អគ្គិសនីរបស់អ្នកប្រើប្រាស់)។*<br>• ម្ចាស់គម្រោង ត្រូវដាក់បញ្ចូលក្នុងកិច្ចសន្យាម៉ៅការសងសង់ (ចោះរូងទុនេល សាងសង់អាគារថាមពល។ល។) ដោយមិនឱ្យយកសំណល់ ថ្ម ដី ចាក់តាមមាត់ច្រាំង នៃស្ទឹងពោធិ៍សាត់ នាំឱ្យលប់អន្លង់នានា និងប៉ះពាល់គុណភាពទឹក ប៉ះពាល់ដល់ជីវៈរស់នៅក្នុងទឹក មច្ឆជាតិជាដើម។ ទីតាំងចាក់សំណល់ ដីនិងថ្ម មានចែងក្នុង ជំពូក៤ចំណុច ៤.៣ និងផែនទី ៣ ត្រូវគ្រោងឱ្យឆ្ងាយពីមាត់ច្រាំងស្ទឹងយ៉ាងហោចណាស់១៥០ម ផងដែរ។ | |
| ខ.២ ព្រៃការពារ/តំបន់ការពារ/ឧទ្យានជាតិ | • ការគ្រោងរចនាគម្រោងដូចជាប្លង់សម្រាប់សាងសង់ទំនប់ទឹក អាងទឹក អាគារថាមពល បំពង់ទុនេល និងហេដ្ឋារចនាសម្ព័ន្ធនានារបស់គម្រោងវារីអគ្គិសនីពោធិ៍សាត់១នេះ ស្ថិតក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍(ប្រមោយ) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ៥.១៩៩,២ហ.ត, ស្ថិតនៅក្នុងតំបន់ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល ៣៩,៧០ហ.ត និងដែនជម្រកសត្វព្រៃភ្នំសំកុសរបស់ក្រសួងបរិស្ថានប្រមាណ ៤.៧៥៦,១ហ.ត សកម្មភាពសិក្សាគម្រោងនៅក្នុងដំណាក់កាលមុនសាងសង់គម្រោងនេះ មានការប៉ះពាល់ដល់ព្រៃការពារនេះខ្លះៗដែរ ដោយសារតែសកម្ម ភាពសិក្សាគម្រោង ដូចជាការកាប់ព្រៃឈើធ្វើផ្លូវចូល (មិនលួសឆាយ ទេ) ការខួងសិក្សា ដី ថ្ម ដើម្បីត្រៀសំណង់ ការវាស់ចារទឹកការធ្វើ ឋានលេខាជាដើម។<br>• សកម្មភាពសិក្សា គម្រោងនិងបង្កឱ្យមានផលប៉ះពាល់ដល់អេកូឡូស៊ី ដូចជា: សំឡេងពីគ្រឿងចក្រ ភាពខ្ញៀវខ្ញារ នៃក្រុមបុគ្គលិក-កម្មករ ការទន្ទ្រានចូលក្នុងព្រៃពីក្រុមបុគ្គលិក-កម្មករក្រោយពីការងារ ដើម្បីរកអនុផលព្រៃឈើ ឬចាប់សត្វ | | ✓ | | • បានគិតគូរយ៉ាងហ្មត់ចត់ អំពីករណីនៃការគ្រោងគម្រោងនេះ ដោយធ្វើការប្រៀបធៀប ៣ករណីទៅនឹងតម្លៃសេដ្ឋកិច្ច រួមទាំងបរិស្ថាន និងគ្រោងហេដ្ឋារចនា សម្ព័ន្ធគម្រោងមួយចំនួន ដូចជាការជ្រើសយកវិធីចោះរន្ធទុនេលក្រោមដី ដោយ មិនប្រើការជីកប្រឡាយនាំទឹក ដែលធ្វើឱ្យបាត់បង់គម្របព្រៃឈើច្រើន។ ក្រុមហ៊ុន បានដាក់បញ្ជា ឱ្យកាប់តែព្រៃក្នុងកន្លែងសាងសង់ហេដ្ឋារចនាសម្ព័ន្ធគម្រោងជាក់ ស្តែងប៉ុណ្ណោះ ទោះបីជាខ្លួនបានគ្រោងព្រំប្រទល់តំបន់នោះក៏ដោយ។<br>• កំណត់ពេលវេលាធ្វើការតែពេលថ្ងៃ សម្រាប់ការងារទាំងឡាយណាដែល បង្កសំឡេងនិងរំញ័រ ដើម្បីកុំឱ្យមានការរំខាន ឬផ្អើលសត្វព្រៃក្នុងតំបន់ គម្រោង និងតំបន់ក្បែរខាង។ រីឯខ្សែបញ្ជូនអគ្គិសនី ២៣០kV ប្រវែងប្រមាណ៥គ.ម. វិញ (មានលម្អិតនៅជំពូក៨ ស្តីពីខ្សែបញ្ជូនអគ្គិសនី)។<br>• បានគិតគូរយ៉ាងហ្មត់ចត់ អំពីករណីនៃការគ្រោងគម្រោងនេះ ដោយធ្វើការប្រៀបធៀប ៣ ករណីទៅនឹងតម្លៃសេដ្ឋកិច្ច រួមទាំងបរិស្ថាន និងគ្រោងហេដ្ឋារចនាសម្ព័ន្ធគម្រោងមួយចំនួន ដូចជាការជ្រើសយកវិធីចោះរន្ធទុនេលក្រោមដី ដោយមិនប្រើការ ជីក | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | ឬការជួញដូរសត្វព្រៃសម្រាប់ធ្វើម្ហូប និងកាប់ឈើលក់ឱ្យឈ្មួញជាដើម។ល។<br>• បានគ្រោងសំណង់ទំនប់ និងទួនែល អាគារថាមពល ផ្លូវចូល អាងទឹក ដូចជាគ្រោងការតម្លល់ទឹកនៅអាង កម្រិតនីវ៉ូធម្មតា១៨០ម តំបន់នេះ យើងដាក់ជាតំបន់១ ដើម្បីងាយស្រួលសិក្សាដែលមានផ្ទៃក្រឡាមាន៨.៥៩១ហ.ត ដែលក្នុងនោះមានព្រៃស្រោង ៧៣៥ហ.ត ព្រៃពាក់កណ្តាលស្រោង៨៥០,២៥ហ.ត ហ.ត និងព្រៃល្បោះ ៤.២៥៣ហ.ត ចំណែកឯ តំបន់២,៣ និង៤ មានចែងក្នុងជំពូក ៥ ចំណុច ៥.១.២.១ព្រៃឈើ។ | | | | ប្រឡាយនាំទឹក ដែលធ្វើឱ្យបាត់បង់គម្របព្រៃឈើច្រើន។ បានដាក់បញ្ជាឱ្យកាប់តែព្រៃក្នុងកន្លែងសាងសង់ហេដ្ឋារចនាសម្ព័ន្ធគម្រោង ជាក់ស្តែងប៉ុណ្ណោះ ទោះបីជាខ្លួនបានគ្រោងព្រំប្រទល់តំបន់នោះក៏ដោយ (មើលផែនទី ៥ ក្នុងឧបសម្ព័ន្ធ ៨)។<br>• បានកំណត់ពេលវេលាធ្វើការ តែពេលថ្ងៃសម្រាប់ការងារទាំងឡាយណា ដែលបង្កសំឡេង និងរំញ័រ ដើម្បីកុំឱ្យមានការរំខាន ឬផ្អើលសត្វព្រៃក្នុងតំបន់គម្រោង និងតំបន់ក្បែរខាង។<br>• ធ្វើការអប់រំដល់កម្មករគម្រោងមិនឱ្យធ្វើការទន្រ្ទានព្រៃ ក្នុងតំបន់គម្រោងដើម្បីចាប់ ឬបរបាញ់សត្វព្រៃ ឬជួញដូរសត្វព្រៃសម្រាប់ធ្វើម្ហូប និងកាប់ព្រៃឈើលក់ឱ្យឈ្មួញឡើយ ហើយដាក់វិន័យយ៉ាងតឹងរ៉ឹងដល់ពួកគេ ដែលប្រព្រឹត្តខុសទៅនឹងបម្រាមនេះ។<br>• រោងស្បៀង និងម្ហូបអាហារក្រុមហ៊ុនមិនទិញសាច់សត្វព្រៃទេ ឬម្ហូបអាហារណាដែលពាក់ព័ន្ធសត្វព្រៃ។ ក្រុមហ៊ុននាំស្បៀងពីទីរួមស្រុកវាលវែង ឬពីក្រុងពោធិ៍សាត់។<br>• ធ្វើការអប់រំដល់បុគ្គលិក-កម្មករគម្រោងឱ្យយល់ពីច្បាប់ នៃការគ្រប់គ្រងថែរក្សាធនធាន និង សត្វព្រៃនៅក្នុងតំបន់ការពារ (ដែនជម្រកសត្វព្រៃ និងឧទ្យានជាតិ) និងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍។<br>**បញ្ជាក់:** ព្រៃឈើនៅក្នុងតំបន់គម្រោងសរុបមាន ៦.៤៣៨,៤១ហ.ត ហើយប៉ះពាល់តែ ៦,០០៧,២៤ហ.ត តែប៉ុណ្ណោះ ដែលក្នុង នោះមាន ព្រៃស្រោង ៨៦៥,៤៦ហ.ត ព្រៃពាក់កណ្តាលស្រោង ៩៧៩,១៥ហ.ត និងព្រៃល្បោះ ៤.២៩១.៥ហ.ត (តំបន់អាង មានព្រៃស្រោង ៧៣៥ហ.ត ព្រៃពាក់កណ្តាលស្រោង ៨៥០,២៥ហ.ត និងព្រៃល្បោះ ៤.២៥៣ហ.ត ត្រូវធ្វើការកាប់ចេញ និងដាក់ដេញថ្លៃឈើនៅក្នុងអាងដោយយកចំរៃកាចូលជាចំរៃការជូ។ ចំណែកឯដីព្រៃឈើនៅក្នុងតំបន់ហេដ្ឋារចនា សម្ព័ន្ធគម្រោងដទៃទៀត ដូចមានបង្ហាញក្នុងតារាង ៥-៩, ៥-១០, ៥-១១, ៥-១២ ក្នុងជំពូក៥ មិនចាំបាច់កាប់ទាំងអស់នោះទេ ពោលគឺក្រុមហ៊ុន ត្រូវកាប់សំអាតនៅកន្លែងធ្វើផ្លូវចេញចូល ពេលសាងសង់គម្រោង និងសង់កន្លែងស្នាក់នៅកន្លែងចាក់សំណល់ដី និងថ្ម កន្លែងលាយបេតុង ជាដើម តែប៉ុណ្ណោះ។<br>***សម្គាល់:*** *- ការចាត់ចែងកាប់សំអាតឈើរបៀបនេះអាច នឹងត្រូវបានកាត់បណ្ដោយការកាប់រានដីព្រៃឈើបានប្រមាណជា៤៣១,១៧ហ.ត ក្នុងតំបន់គម្រោង។*<br>*- ដង់ស៊ីតេមាឌជាមធ្យមដែលសិក្សាដោយក្រុមការងារ SAWAC មានព្រៃស្រោង (ø≥300mm) ២២,៦៣ម៉ែ/ហ.ត ព្រៃពាក់កណ្តាល ស្រោង(ø≥300mm) ៣៣,៨១ ម៉ែ/ហ.ត និងព្រៃល្បោះ(ø≥300mm) ៤៧,៣៦ម៉ែ/ហ.ត ហើយដង់ស៊ីតេមាឌឈើជាមធ្យម សម្រាប់ មុខឈើ ø≥100mm គឺ ៥១,៥៦ ម៉ែ/ហ.ត លម្អិតមើលជំពូក ៥ ចំណុច ៥.១.២.១ ព្រៃឈើ។* | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| ខ.៣ ធនធានព្រៃឈើ និងជម្រកសត្វព្រៃ | • អាចប៉ះពាល់ដល់ធនធានព្រៃឈើខ្លះដែរ ដោយសារការកាប់កូនឈើ ធ្វើស្ពាន និងរានព្រៃ ធ្វើផ្លូវចូលទៅសិក្សាគម្រោង។ អាចរំខានដល់ជម្រក សត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គម្រោង ដោយសារសកម្មភាព សិក្សាគម្រោង។<br>• អាចមានការបរបាញ់ ឬជួញដូរសត្វព្រៃ និងកាប់ឈើខុសច្បាប់ពី សំណាក់កម្មករគម្រោង ដែលធ្វើប៉ះពាល់ដល់ជម្រកសត្វព្រៃ។<br>• ផ្ទៃដីគម្រោងមាន ៩.៣៥៥ហ.ត ហើយក្នុងមានព្រៃឈើប៉ះពាល់ ដល់ ៦.០០៧.២៤ហ.ត ក្នុងការសាងសង់ហេដ្ឋារចនាគម្រោងវារីអគ្គិសនីនេះ នៅដំណាក់កាលសាងសង់។ ហេតុដូចច្នេះហើយ ក្រុមហ៊ុនត្រូវត្រៀម ទាក់ទងនិងស្ថាប័ន មន្ទីរ និងក្រសួងពាក់ព័ន្ធ សម្រាប់ធ្វើការកាប់ សំអាតព្រៃឈើទាំងនោះចេញ ហើយឈើនៅក្នុងអាងដាក់ដេញថ្លៃ ជាសាធារណៈ ដោយយកថវិកាចូលរដ្ឋ។<br>• ការបោះបង្គោលព្រំអាង និងតំបន់ដែលត្រូវសម្អាតមិនបានត្រឹមត្រូវ នាំឱ្យមានការកាប់ឈើលើសពីទីតាំងកំណត់ នាំឱ្យប៉ះពាល់ដល់ធនធានព្រៃឈើ និងជម្រកសត្វព្រៃបន្ថែមទៀត។ | | | ✓ | • ត្រូវសុំការអនុញ្ញាតពីរដ្ឋបាលព្រៃឈើ ដើម្បីកាប់ឆ្ការព្រៃឈើធ្វើផ្លូវ និងប្រើប្រាស់ ឈើសម្រាប់សាងសង់ស្ពានឆ្លងកាត់បណ្តោះអាសន្ន។<br>• ធ្វើការបោះជំរុំការងារនៅនឹងកន្លែង ជៀសវាងការដឹកសម្ភារការងារ ចុះឡើង បង្កការរំខានដល់ការរស់នៅរបស់ សត្វព្រៃ ។<br>• ត្រូវកំណត់ពេលវេលាធ្វើការតែពេលថ្ងៃ ដើម្បីមិនឱ្យរំខានសត្វព្រៃ។<br>• ត្រូវធ្វើការសហការជាមួយជំនាញរដ្ឋបាលព្រៃឈើ ជួយណែនាំដល់បុគ្គលិក-កម្មករគម្រោងឱ្យមានការ យល់ដឹង អំពីការ ការពារ និងអភិរក្សព្រៃឈើ និងសត្វព្រៃ។<br>• ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថាន ដើម្បីកាប់ឈើក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំសំកុស ដែលមានដីព្រៃឈើ ២៩១០.៧៥ហ.ត និងតំបន់ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាលចំនួន១៣៧.១៤ហ.ត ក្នុងដំណាក់កាលសាងសង់គម្រោង។<br>• ត្រូវសុំការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ដើម្បីកាប់ឈើក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍២៩៥៩,៣៥ហ.ត ក្នុងដំណាក់កាលសាងសង់គម្រោង។<br>• ធ្វើការសហការជាមួយជំនាញរដ្ឋបាលព្រៃឈើ ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល និងដែនជម្រកសត្វព្រៃភ្នំសំកុស ដើម្បីទប់ស្កាត់បញ្ជើសព្រៃឈើ និងសត្វព្រៃ។<br>• ធ្វើលក្ខខណ្ឌការងារឱ្យអ្នកម៉ៅការសម្អាតអាងដោយមានការបោះបង្គោលព្រំ ក្នុងការកាប់សម្អាតផ្ទៃអាងឱ្យបានច្បាស់ គឺចម្ងាយពីគ្នា៥០មឬ១០០មមួយដោយប្រើឧបករណ៍ឋានលេខា ដើម្បីបញ្ជាក់កម្រិតនីវ៉ូអាង ១៨០ម ដែលត្រូវសម្អាតជៀសវាងការកាប់ឈើលើសតំបន់កំណត់។ | |
| ខ.៤ ជីវសាស្ត្រសត្វព្រៃ | • មានការប៉ះពាល់ដល់ជីវសាស្ត្រសត្វព្រៃខ្លះដែរ ដោយសារសកម្មភាព សិក្សាគម្រោង។<br>• អាចមានការបរបាញ់ ឬជួញដូរសត្វព្រៃ និងកាប់ឈើខុសច្បាប់ពី សំណាក់កម្មករគម្រោង និងអ្នកចំណូលថ្មី។<br>• តំបន់គម្រោង គឺស្ថិតក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំសំកុស ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល និងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដូចនេះក្រុមហ៊ុនធ្វើការទំនាក់ទំនងជាមួយមន្ទីរ ស្ថាប័ន និងក្រសួងពាក់ពន្ធ័ ជាមុនក្នុងដំណាក់ កាលមុនពេលសាងសង់ គម្រោងនេះ។ ដូចនេះមានការប៉ះពាល់ដល់តំបន់ការពារទាំងនេះដែលមានសត្វរស់នៅច្រើន(ដូចមានចែងក្នុងជំពូក៥ខាងលើ) ដោយសារការរុករាន របស់អ្នកចំណូលថ្មី។<br>• ក្នុងដំណាក់កាលសាងសង់គម្រោង មានសកម្មភាពកាប់ឆ្ការគម្របព្រៃឈើ ការឈូសឆាយដី ការបំផ្ទុះថ្ម ការដឹកជញ្ជូនសម្ភារសាងសង់នឹងនាំឱ្យមានការភ័យខ្លាច និងបង្អាក់ការបំលាស់ទី ដល់សត្វព្រៃទាំងនោះ ជាពិសេសប្រភេទជិតផុតពូជ (តាមបញ្ជីក្រហម IUCN ពង្រួល) ប្រភេទកំពុងរងគ្រោះ (ទន្សោង | | | ✓ | • ត្រូវបោះជំរុំការងារនៅនឹងកន្លែង ជៀសវាងការដឹកសម្ភារការងារចុះឡើងបង្ក ការរំខានដល់ការរស់នៅរបស់សត្វព្រៃ។<br>• ត្រូវកំណត់ពេលវេលាធ្វើការតែពេលថ្ងៃ ដើម្បីមិនឱ្យរំខានសត្វព្រៃ។<br>• ត្រូវធ្វើការសហការ ជាមួយជំនាញរដ្ឋបាលព្រៃឈើ ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល និងដែនជម្រកសត្វព្រៃភ្នំសំកុស ជួយណែនាំដល់បុគ្គលិក-កម្មករគម្រោង ឱ្យមានការយល់ដឹងអំពីការ ការពារ និងថែរក្សាសត្វព្រៃ។<br>• ចំពោះម្ហូបអាហារមិនទិញសាច់សត្វព្រៃទេ ឬម្ហូបអាហារណា ដែលពាក់ព័ន្ធ សត្វព្រៃ។ ក្រុមហ៊ុនទិញ និងនាំស្បៀងពីក្រុងពោធិ៍សាត់ ឬទីរួមស្រុកវាលវែង ដើម្បីផ្គត់ផ្គង់ការដ្ឋាន។<br>• គ្រោងថវិកាការពារបរិស្ថានសរុបចំនួន ៨.៦៩៩.៣៧៦ដុល្លារអាមេរិក ដើម្បីការពារបរិស្ថាន រួមទាំងការឧបត្ថម្ភដល់អ្នកល្បាត ការព្រែងកូនត្រីដែលងាយរងគ្រោះថ្នាក់ និងមានមូលនិធិសង្គ្រោះគ្រពើភ្នំ ការដោះស្រាយផលប៉ះពាល់ដីធ្លី ផ្ទះសម្បែងជាដើម។ល។ (លម្អិតមើលតារាង៨-៣, ៨-៤, ៨-៥, ៨-៦)។<br>• ធ្វើលក្ខខណ្ឌការងារឱ្យអ្នកម៉ៅការ ត្រូវបង្កលក្ខណៈឱ្យមានការបម្លាស់ទីរបស់សត្វព្រៃ | |

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | ឃ្លូសយក្ស ផ្លែព្រៃ គេភោមច្រមុះ ទោចម្លុជ ខ្លាត្រី) ដោយសារមានសំឡេងរំខានខ្លាំងៗ ចេញពីម៉ាស៊ីនគ្រឿងយន្តគ្រឿងធុះ សំឡេងខ្សឹបខ្សាវរបស់បុគ្គលិក-កម្មករគម្រោង និងការព័ទ្ធកាប់បំផ្លាញជម្រកវា។ | | | | ដូចជា៖ ការកាប់សម្អាតព្រៃឈើបាតអាង គឺកាប់សម្អាតឈើពីមាត់ស្ទឹងឡើងទៅលើ ដើម្បីឱ្យសត្វព្រៃអាចបម្លាស់ទីចូលទៅតំបន់ភ្នំបានផង និងមិនត្រូវឱ្យកម្មករកាប់ផ្តាច់ជាគន្លងព័ទ្ធជុំវិញ (ដូចជាកោះ) ដែលបង្ខាំងសត្វព្រៃនៅកណ្តាលនោះទេ។ | |
| គ. ធនធានសេដ្ឋកិច្ចសង្គម | | | | | | |
| គ.១ ការប្រើប្រាស់ដី និង ការតាំងលំនៅដ្ឋាន ឡើងវិញ | • ការអភិវឌ្ឍគម្រោងវារីអគ្គិសនីនេះ ត្រូវការផ្ទៃដីសរុប ៩.៣៥៥ហ.ត ដែលចែកជា៤តំបន់គឺ តំបន់១ ជាតំបន់អាង ដែលមានផ្ទៃដី ៨.៥៩១ហ.ត ក្នុងនោះមានការប៉ះពាល់ការប្រើប្រាស់ ដីរបស់ប្រជាពលរដ្ឋចំនួន២.៣២៩,២៥ហ.ត (ដីកសិកម្ម ៩៣២.១២ហ.ត ដីបុស្ស១.០៦៨,៣៩ហ.ត និងដីលំនៅដ្ឋាន៣៨,៤៤ហ.ត) ជារបស់៣៤៧គ្រួសារ។<br>• តំបន់១ជាតំបន់អាងនេះ ក៏មានការប៉ះពាល់ដីសហគមន៍តំបន់ការពារធម្មជាតិស្រែពាំង ៣៤១,៧៣ហ.ត ត្រូវជា ៦៨% (ផ្ទៃដីសរុប ៤៩៩ហ.ត) និងដីសហគមន៍តំបន់ការពារធម្មជាតិស្ទឹងថ្មី ៩,៨៩ហ.តត្រូវជា ២% (ផ្ទៃដីសរុប ៤៦៣,៤ហ.ត) ផងដែរ។ ចំណែកឯ តំបន់២ តំបន់៣ និងតំបន់៤ មិនមានការប៉ះពាល់ដល់ដីប្រជាពលរដ្ឋទេ។ អាចនឹងមានអ្នកឆ្លៀតឱកាសមកពីខាងក្រៅមកចាប់ដីបោះតាំងលំនៅឋានថ្មីនៅក្នុងតំបន់គម្រោងបន្ទាប់ពី ទទួលព័ត៌មានថាមានការអភិវឌ្ឍ នៅតំបន់នេះពីព្រោះពួកគេសង្ឃឹមថាបានទទួលសំណងពីក្រុមហ៊ុន ឬពីរដ្ឋាភិបាល។<br>• មានការប៉ះពាល់ដល់សតិអារម្មណ៍របស់ប្រជាពលរដ្ឋ នៅភូមិស្ទឹង ថ្មី (ចំណុចអន្លង់ក្រូច ចំណុចអន្លង់យួត ស្វាយកោង និងអូរសង្ស៊ី) ដោយសារខ្លាចលិចដីកសិកម្ម ដីបុស្ស ដីលំនៅដ្ឋាន ធ្វើឱ្យបាត់បង់ ដីស្រែ ចំការ និងលំនៅដ្ឋានរបស់ពួកគេទាំងនោះ។ | | | ✓ | • សុំការសហការជាមួយស្ថាប័នពាក់ព័ន្ធទាំងអស់ដូចជា អាជ្ញាធរមូលដ្ឋាន មន្ទីរ និងក្រសួងពាក់ព័ន្ធ ដើម្បីជូនដំណឹងអំពីការសាងសង់គម្រោងនេះ ក៏ដូចជា ប្រជាពលរដ្ឋរស់នៅខាងក្នុងតំបន់គម្រោងផងដែរ។<br>• ធ្វើការផ្សព្វផ្សាយតាមរយៈក្រុមការងារសិក្សា ESIAនេះ ព្រមទាំងបានជូន ដំណឹងដល់សាធារណជន ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋជាមុន អំពីគោលបំណងជាក់ស្តែងរបស់រាជរដ្ឋាភិបាល សម្រាប់ការអភិវឌ្ឍគម្រោងនេះ នៅពេល អនាគតព្រមទាំងបើកសិក្ខាសាលា អំពីលទ្ធផលនៃការសិក្សានេះនៅក្រុង ពោធិ៍សាត់ នាថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១២ ដើម្បីកែតំរូវចំណុចខ្វះខាត ចន្លោះប្រហោងក្នុងវិធានការបន្ធូរបន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដោយសារការអភិវឌ្ឍគម្រោងនេះ។<br>• ធ្វើការសហការជាមួយអាជ្ញាធរដែនដី ដើម្បីទប់ស្កាត់ការទន្ទ្រានដីព្រៃ ដែលជាកម្មសិទ្ធិសាធារណៈរបស់រដ្ឋ មកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន។<br>• ត្រៀមថវិកាចំនួន ៦.៨៣៣.០១៦ដុល្លារអាមេរិក សម្រាប់សំណង និងការ អភិវឌ្ឍន៍តំបន់ថ្មីសម្រាប់អ្នកប៉ះពាល់ ដោយសារគម្រោងនេះ៣៤៧គ្រួសារ។ ចំពោះសំណងមាន៣ករណីគឺ ករណីទី១ សំណងជាដី ២ហ.ត ក្នុង១គ្រួសារ (គិតតាមសមាត្រនៃចំនួនដីរបស់គេ បើដីរបស់គេលើសពី២ហ.តទៅ ដីនៅសល់សំណងជាប្រាក់ បើដីរបស់គាត់តិចជាង២ហ.ត សំណង២ហ.ត) ករណីទី១នេះមាន៧៤គ្រួសារ។ ករណីទី២គឺសំណងជាប្រាក់មាន២៨០គ្រួសារ។ ករណីទី៣ គឺសំណងជាផ្ទះ មាន២៤ គ្រួសារ (ផ្ទះប៉ះពាល់សរុប ៩២ខ្នង ជារបស់ ៧៨គ្រួសារ)។ សម្គាល់:ករណីសំណងជាដី ផ្អែកលើលក្ខណៈវិនិច្ឆ័យ ៣ គឺ ១)សំណូមពរ របស់អ្នកប៉ះពាល់ទាំងនោះ ២) មេគ្រួសារជាជនងាយរងគ្រោះ (មេម៉ាយ ចាស់ជរា អសមត្ថភាពការងារ មានប័ណ្ណក្រីក្រ និងជនជាតិដើមភាគតិច) ៣) ប៉ះពាល់ដី កសិកម្ម ចាស់ពី៥០% រហូតដល់ ១០០%។ វិនិច្ឆ័យផ្តល់ដីគឺសមាមាត្រ ២/៣។ ចំណែកឯ សំណងជាផ្ទះ ផ្តល់អត្ថិភាពឱ្យ មេគ្រួសារជាជនងាយរងគ្រោះ រួមទាំងមាន៣លក្ខណៈវិនិច្ឆ័យផងដែរ។ឧទាហរណ៍៖ គ្រួសារ ឈ្មោះ ក ជាជនងាយរងគ្រោះដែលមានផ្ទះប៉ះពាល់ គាត់ត្រូវទទួលបានសំណងជាផ្ទះ ៤០ម២ តាមជម្រើសរបស់គាត់ (ផ្ទះសំណងមាន៣ ជម្រើស) ទោះជាផ្ទះរបស់គាត់ តូច ប្រក់ស្លឹកក៏ដោយ។ ជាងនេះទៀត បើគ្រួសារអ្នកប៉ះពាល់ ស្ថិតក្នុង ២ចំណុច នៃ៣លក្ខណៈវិនិច្ឆ័ | |

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | | | | | យខាងលើក៏ត្រូវផ្តល់សំណងជាផ្ទះផងដែរ។<br>• ផ្ទះដែលប៉ះពាល់ និងសងតាមតម្លៃទីផ្សារ គិតជាម៉ែត្រការ៉េ ដែលមានបញ្ជាក់ក្នុងតារាង ៩-៣ ជំពូក៩ ចំណុច ៩.១.៣។<br>• ចំពោះដីសហគមន៍ នៃតំបន់ការពារទាំងនោះ៖ គឺសហគមន៍តំបន់ការពារធម្មជាតិស្រែពាំង មានសំណង ១០២,៥១៩ ដុល្លារអាមេរិក និងសហគមន៍តំបន់ការពារធម្មជាតិស្ទឹងថ្មីមានសំណង ២.៩៦៧ ដុល្លារអាមេរិក ហើយសំណងទាំងនេះនឹងទូទាត់ក្នុងដំណាក់កាលសាងសង់គម្រោង។ សំណងទាំងនេះជួយឱ្យសហគមន៍ធ្វើការដាំឈើ និងធ្វើប៉ុស្តិ៍ការពារនៃតំបន់ព្រៃឈើទាំងនេះដែលនៅសល់។<br>• ត្រូវធ្វើផែនការបំលាស់ប្តូរលំនៅដ្ឋាន របស់ប្រជាពលរដ្ឋក្នុងតំបន់១ (តំបន់អាងទឹក) និងបង្កើតតំបន់តាំងលំនៅឋានថ្មី ឱ្យបានមុនយ៉ាងតិច១ឆ្នាំ មុននឹងធ្វើការបិទ ទ្វារទឹកបំពេញអាងនេះ។ ***សម្គាល់:*** *តម្លៃសម្រាប់ការអនុវត្តផែនការបំលាស់ប្តូរលំនៅដ្ឋានរបស់ប្រជាពលរដ្ឋឆ្នាំ ២០១២ មានត្រឹមតែ៤.៨៥៦.៨១២ ដុល្លារ ប៉ុណ្ណោះ តែខែកញ្ញា ឆ្នាំ ២០១៥ នេះវាកើនលើស ២,០២ដង ហើយ ឆ្នាំ ២០១៧ នេះកើនជាងឆ្នាំ២០១៥ ចំនួន៣ ដង គឺ $៦.៨៣៣.០១៦ដោយសារ ដីក្នុងតំបន់អាងត្រូវបានផ្តល់ប្លង់រឹង ដីបុស្សក្លាយជាដីចំការ លម្អិតពីតម្លៃដីតម្លៃផ្ទះ តម្លៃដំណាំ ក្នុងតារាង ៩-៣។*<br>• ធ្វើការគ្រោងរចនាគម្រោង ដោយគណនាគ្រឹះសំណង់ និងតួទំនប់ឱ្យបានរឹងមាំ តាមលក្ខណៈបច្ចេកទេស ជាពិសេសគណនាអាយុនៃសំណង់ធ្វើអំពីបេតុង ឱ្យបានយ៉ាងតិច ៩០ឆ្នាំ ក្នុងលក្ខណៈធម្មតា (ប្រសិនបើមិនមានគ្រោះធម្មជាតិ ឬសង្គ្រាម) ហើយសំណង់ទំនប់វារីអគ្គិសនីនេះ និងត្រូវរកការធានារ៉ាប់រងពី ក្រុមហ៊ុនអន្តរជាតិ ដើម្បីធានា<br>• សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីទប់ស្កាត់ក្នុងការបំផុសចលនា ប្រជាពលរដ្ឋរបស់ជនឆ្លៀតឱកាស ក្នុងគោលបំណងទាមទារដីធ្លី និងសំណង ផ្សេងៗខុសច្បាប់ ឱ្យបានទាន់ពេលវេលាពីព្រោះតំបន់ គម្រោងវារីអគ្គិសនីស្ទឹង ពោធិ៍សាត់១នេះ មានប្រជាពលរដ្ឋរស់នៅក្នុងតំបន់ការពារ និងព្រៃការពារ ទាំងនោះ។<br>• ធ្វើការសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច សង្កាត់រដ្ឋបាលព្រៃឈើ ប្រមោយនៃខណ្ឌរដ្ឋបាលព្រៃឈើពោធិ៍សាត់ មន្ត្រីឧទ្យានជាតិ ដែនជម្រកសត្វព្រៃ និងអង្គការអភិរក្សនានា ដើម្បី ចាត់វិធានការទប់ស្កាត់ និងបង្កើនកម្លាំងការពារតំបន់នេះ។<br>• ធ្វើការសហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការ រៀបចំធ្វើផែនការ ដោះស្រាយផលប៉ះពាល់ និងផ្លាស់ប្តូរលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ ដែលរងការប៉ះពាល់ដោយសារគម្រោងនេះ ឱ្យបានត្រឹមត្រូវតាមច្បាប់ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ | |
| គ.២ ការរស់នៅ និង មុខរបររបស់ សហគមន៍ មូល | • ក្នុងដំណាក់កាលរចនាគម្រោងនេះមិនប៉ះពាល់ដល់ចំណុចនេះទេ ប៉ុន្តែក្នុងដំណាក់កាលនេះត្រូវធ្វើបច្ចុប្បន្នភាពការប៉ះពាល់ដល់ប្រជាពលរដ្ឋ ដូចជាធ្វើផែនការបំលាស់ប្តូរលំនៅដ្ឋានរបស់ប្រជាពលរដ្ឋក្នុងតំបន់គម្រោង ជាពិសេសត្រូវគិតបញ្ចូលសំណងថ្លៃដីស្រែចំការ ដីបុស្ស ដីលំនៅដ្ឋាន ដំណាំ ឈើស៊ីផ្លែទាំងអស់ដែលនឹងត្រូវខូចខាតដោយសារគម្រោងនេះ ដោយត្រូវគណនាតាមតម្លៃជំនួសតាមតម្លៃទីផ្សារបច្ចុប្បន្ន។ | | | | | |

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| ដ្ឋាន | • គម្រោងនិងមានការប៉ះពាល់ទៅដល់៩៦គ្រួសារដែលមេគ្រួសារជាជនងាយរងគ្រោះ និងប៉ះអស់ដីផលិតកម្ម លើសចាប់ពី៥០% ដល់១០០% ដែលនាំឱ្យគ្រួសារទាំងនេះងាយធ្លាក់ក្នុងភាពងាយរងគ្រោះ ឬភាពក្រីក្រ ដែលចុងក្រោយ នឹងក្លាយជាបន្ទុករបស់រាជ្ជាភិបាល។ ***សម្គាល់:*** *យោងតាមការចុះសិក្សាជាក់ស្តែង ក្នុងតំបន់គម្រោង នាខែកញ្ញា ឆ្នាំ២០១៧ នេះ មានគ្រួសារងាយរងគ្រោះចំនួន៩១គ្រួសារ (មេម៉ាយ ចាស់ជរា អសមត្ថភាពការងារ មានប័ណ្ណក្រីក្រ ជនជាតិដើមភាគតិច)។*<br>• ក្នុងផែនការបំលាស់ប្តូរលំនៅដ្ឋានរបស់ប្រជាពលរដ្ឋក្នុងតំបន់គម្រោង ត្រូវបញ្ចូល ប្រាក់ឧបត្ថម្ភផ្សេងដូចជា ប្រាក់ថ្លៃខាននៃការខូចខាត(ប្រាក់ជំងឺចិត្ត) ប្រាក់ថ្លៃដឹកជញ្ជូន ប្រាក់ឧបត្ថម្ភដល់មេគ្រួសារងាយរងគ្រោះ ប្រាក់ស្តារចំណូលឡើងវិញរបស់គ្រួសារដែលប៉ះពាល់ដីកសិកម្មចាប់ពី៥០% ដល់ ១០០% នៃដីកសិកម្មរបស់គ្រួសារ។ នៅផែនការនេះត្រូវរួមបញ្ចូលតម្លៃសាងសង់ផ្ទះដំបូលសង្កសី ជញ្ជាំងឈើ ទំហំ ៨០ ម២ សម្រាប់ឱ្យអ្នកស្ថិតក្នុងលក្ខណ:វិនិច្ឆ័យចំនួន២៨គ្រួសារ (ដូចមានចែងក្នុងចំណុច គ.១ ខាងលើ) | | | | | |
| គ.៣ ផ្លូវគមនាគមន៍ | • អាចមានការប៉ះពាល់ និងគ្រោះថ្នាក់ដល់អ្នកសិក្សា ឬធ្វើឱ្យស្ទះ ការងារសិក្សាប្លង់រចនាគម្រោង ដោយសារមិនមានផ្លូវដឹកជញ្ជូន ច្បាស់លាស់សម្រាប់គម្រោងនេះ ដែលមានចំណោទខ្លាំង ហើយឆ្លង កាត់ជ្រោះ ដែលមានថ្មាំងថ្មកន្លែងខ្លះជា ល្បាក់ជ្រៅពុំអាចឆ្លង កាត់បាន។ | | ✓ | | • រកអ្នកនាំផ្លូវរស់នៅក្បែរតំបន់គម្រោង ដែលស្គាល់ភូមិសាស្ត្រច្បាស់លាស់ ដែលធ្លាប់ចេញចូលតំបន់នេះ។<br>• ត្រួសត្រាយផ្លូវ និងធ្វើស្ពានបណ្តោះ។<br>• ជួលរថយន្តដែលមានសុវត្ថិភាពល្អក្នុងការសិក្សាគម្រោងនេះ។ | |
| គ.៤ សុខភាពសាធារណ: | • បង្កឱ្យមានការប៉ះពាល់ដល់សុខុមាលភាពបុគ្គលិកកម្មកររបស់ក្រុមហ៊ុនមួយចំនួនដោយសារតំបន់នេះស្ថិត នៅក្នុងព្រៃ ដែលបង្កឱ្យមាន កើតជំងឺគ្រុនចាញ់ គ្រុនសន្និបាត។ល។<br>• បង្កឱ្យមានការប៉ះពាល់ដល់សុខុមាលភាពបុគ្គលិកមួយចំនួនកើត ជំងឺរាគរូសឬរាគសន្លរោគ ព្រោះនៅតំបន់នេះមិនមានប្រព័ន្ធទឹក ស្អាត។<br>• ដោយសារការបន្ទោរបង់ដាក់ទឹក និងធ្វើបង្គន់លើទឹករបស់កម្មករ ធ្វើឱ្យកម្មករផ្សេងទៀត មានជំងឺគ្រុនពោះវៀន រាគសន្លរោគ រាគ រូស។ល។<br>• ដំណាក់កាលសាងសង់គម្រោង នឹងមានការបន្ទោរបន្ទោរបង់ដាក់ទឹក និងធ្វើបង្គន់លើទឹករបស់កម្មករធ្វើឱ្យកម្មករផ្សេងទៀត មានជំងឺគ្រុនពោះវៀន រាគសន្លរោគ រាគរូសជាដើម។ល។ ដូចនេះក្នុងនៅដំណាក់កាលរចនានេះ ត្រូវគិតគូរអំពីបញ្ហានេះផងដែរ។<br>• ប្រជាពលរដ្ឋក្បែរតំបន់គម្រោងអាចឆ្លង ជំងឺកាមរោគពីបុគ្គលិក-កម្មករ ដែលមកពីកន្លែងផ្សេងៗ និងជំងឺអេដស៍ជាដើម។<br>• នៅដំណាក់កាលប្រតិបត្តិគម្រោង អាចមានគ្រោះថ្នាក់ដល់ជីវិតមនុស្ស សត្វចិញ្ចឹម ដោយសារការបញ្ចេញទឹក ៤០ម៣/វិន. ទួប៊ីនពីរ ៨០ម៣/វិន. ក្នុងការផលិតអគ្គិសនី។ | | ✓ | | • ធ្វើការអប់រំដល់ បុគ្គលិកកម្មករទាំង សុខភាពអនាម័យ ការការពារជំងឺសង្គម និងការហូបទឹកឆ្អិន។<br>• អប់រំបុគ្គលិកកម្មករអំពីវិធីការពារ និងការទប់ស្កាត់បញ្ហាជំងឺទាំងនេះ រាល់បី ខែម្តង។<br>• ត្រៀមថ្នាំបង្ការដើម្បីកំពារ និងព្យាបាលជំងឺទាំងនោះ។<br>• សាងសងបង្គន់អនាម័យដោយជីកដីដាក់លូត្រឹមត្រូវឱ្យឆ្ងាយពីប្រភពទឹក។<br>• គ្រោងដំឡើងប្រដាប់ផ្តល់ដំណឹងប្រាប់ឱ្យដឹងមុន ១៥ ទៅ៣០នាទី ដូចជា ការបំពាក់សញ្ញាគ្រោះថ្នាក់ និងបន្លឺស៊ីរ៉ែនជាដើម នៅតំបន់ខាងក្រោមអាគារថាមពល ដែលមានមនុស្សរស់នៅ ចម្ងាយ យ៉ាងតិច ៥០គ.មតាមដងស្ទឹង ដើម្បីឱ្យអ្នករស់នៅខាងក្រោមបានដឹង និងរត់គេច មកទីទួលសុវត្ថិភាព នៅពេលដែលបើកទឹកដំណើរការទួប៊ីនម្តងៗ (ទួប៊ីន១ បញ្ចេញទឹក៤០ម$^{៣}$/វិន. ទួប៊ីនពីរ ៨០ម$^{៣}$/វិន.។ | |
| គ.៥ហានិភ័យ (Risk) | • អាចមានគ្រោះថ្នាក់ដោយសារតំបន់នោះមិន ដែលស្គាល់ភូមិសាស្ត្រ ដូចជា: ជ្រោះជ្រៅ, ការបាក់ផ្ទាំងថ្មធំៗ, ចំណោទខ្ពស់ៗ បង្កឱ្យ គ្រោះថ្នាក់ដោយរអិល, គ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ បង្កប់ ក្នុងដីនៅតំបន់អតីតបន្ទាយទាហាន។ | | | ✓ | • ត្រូវធ្វើការទាក់ទងយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន ដោយមានការសហការជាមួយសមត្ថកិច្ច និងមជ្ឈមណ្ឌលជាតិ គ្រប់គ្រង កងកម្លាំង រក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម (NPMEC) ដើម្បីធ្វើការដោះគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះទាំងនេះចេញពីតំបន់គម្រោង។ | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | • ការគ្រោងគម្រោងមិនត្រឹមត្រូវតាមបច្ចេកទេស បង្កហានិភ័យ ខ្ពស់ ដូចជាបាក់ទំនប់ រអិលបាក់ភ្នំ នាំឱ្យខូចខាតទ្រព្យសម្បត្តិ និងអាយុ ជីវិតរបស់ប្រជាពលរដ្ឋជាដើម។ | | | | • ក្រុមហ៊ុនត្រូវធ្វើការសិក្សាចេនាប្លង់វិស្វកម្ម និងគុណភាពការសាងសង់ ដែលអាចធានាមិនឱ្យមានការបាក់ទំនប់ និងការបាក់ភ្នំ ក្នុងតំបន់គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ នេះ ដោយរកក្រុមហ៊ុនអន្តរជាតិធ្វើការធានាគុណភាពសំណង់ធានាក្នុងរយៈពេល៩០ ឆ្នាំ និងហានិភ័យរបស់វា។<br>• ត្រូវអនុវត្តទៅតាមផែនការគ្រប់គ្រងសុវត្ថិភាព និងហានិភ័យ ដូចមានចែង ក្នុងជំពូក ៤ ចំណុច ៤.៦.១២ ឱ្យបានជាប្រចាំ។ | |
| **១.២ ដំណាក់កាលសាងសង់គម្រោង** (Project Construction) | | | | | | |
| ក. ធនធានរូបសាស្ត្រ | | | | | | |
| ក.១ សណ្ឋានដី និង ឋានលេខា | • បណ្ដាលឱ្យប្រែប្រួលសណ្ឋានដី និងឋានលេខាក្នុងទីតាំងគម្រោង ដោយសារសកម្មភាពការឈូសឆាយ និងពង្រាបដីស្រទាប់លើ ដែលមាន គម្របព្រៃដើម្បីធ្វើហេដ្ឋារចនាសម្ព័ន្ធរបស់គម្រោងដូចជា ការធ្វើផ្លូវថ្នល់ សាងសង់ទំនប់ប្រឡាយដោះទឹក បំពង់ទុនេល អាគារថាមពល កន្លែងយកថ្ម កន្លែងយកដី កន្លែងចាក់ចោលដី និង សំណល់ថ្ម កន្លែង សាងសង់អាគារ សម្រាប់ទីស្នាក់ការ និងផ្ទះបុគ្គលិក-កម្មករ របស់ក្រុមហ៊ុន។ល។<br>• ការចាក់ចោលដី និងសំណល់ថ្ម ដែលយកពីការសាសង់រូងទូនែល ក្បែរច្រាំងស្ទឹង ណាំឱ្យមានការលប់ ឫរាក់ស្ទឹងនិងអន្លង់តាមពោះស្ទឹងផងដែរ។ | | | ✓ | • ត្រូវធ្វើការជួសជុលទីតាំងយកថ្មកន្លែងយកដី និងកន្លែងចាក់ដីចោលឱ្យ មានសុវត្ថិភាពល្អ ដោយដាំដើមឈើនៅ ទីនោះវិញក្រោយពេលសាងសង់ រួច។ ធ្វើការដាំស្មៅនៅកន្លែងដែលខ្លួនបានកាយជញ្ជាំងភ្នំ ឬកន្លែងចំណោទ ផ្សេងៗ ដើម្បីធ្វើផ្លូវ ធ្វើទំនប់ និងធ្វើហេដ្ឋារចនាគម្រោងដទៃទៀត ដើម្បីការពារការហូរច្រោះ បាក់ជញ្ជាំងភ្នំបន្ថែម។<br>• ត្រូវជឿជាក់ថាមិនមានការចាក់ចោលដី និងសំណល់ថ្មតាមច្រាំងស្ទឹងនោះទេ ដោយមានអ្នកត្រួតពិនិត្យជាប្រចាំ។ ជាងនេះទៅទៀត ការឈូសឆាយដីធ្វើផ្លូវ ត្រូវយកសំណាលដីដែលកាយចេញទុកដាក់ ឱ្យឆ្ងាយពីអូរ ស្ទឹង និងត្រូវសម្រួលជញ្ជាំង ឱ្យមានជម្រាលតាមបទដ្ឋានប្រភេទដី និងថ្ម ដូចបានចែងក្នុង ដំណាក់កាលចេនាគម្រោង។<br>• ធ្វើការសាងសង់ពេញមួយឆ្នាំលើកលែងតែថ្ងៃដែលមានភ្លៀងធ្លាក់ ដើម្បីទបស្កាត់ការហូរច្រោះ ដែលនាំឱ្យខូច សណ្ឋានដីនៅរដូវវស្សា។ នៅរដូវវស្សាក្រុមហ៊ុនធ្វើការសាងសង់ទំនប់ ដោយធ្វើផែនការសាងសង់ប្រចាំខែច្បាស់លាស់ ដូចជាការសង់ ជញ្ជាំងបេតុង ដែលស្រោបពទ្ធ័ជុំវិញទំនប់ជាមុនឱ្យបានខ្ពស់ជាងកម្ពស់ថ្មដែល ត្រូវចាក់ក្នុងរយៈ១ខែ ដើម្បីជៀសវាងការហូរច្រោះកម្ទេចថ្មចូលស្ទឹង ជា ដើម។ | |
| ក.២ ប្រព័ន្ធជលសាស្ត្រ ទឹកលើដី (ប្រឡាយ- អូរ- ស្ទឹង) | • បង្កឱ្យប៉ះពាល់ដល់បរិមាណធារទឹករបស់ស្ទឹងពោធិ៍សាត់ ដោយសារការទប់ទំនប់កាត់ស្ទឹងពោធិ៍សាត់ ដើម្បីធ្វើអាងតម្កល់ទឹក។ នៅខាងក្រោមតំបន់គម្រោង មានសំណង់ធារាសាស្ត្រស្នាក់ទឹកពីរ កន្លែងគាត់ស្ទឹងពោធិ៍សាត់ គឺ ដំណាក់អំពិល និងចារិក ដែលយក ទឹកទៅស្រោចស្រពដីកសិកម្មក្នុងខេត្តពោធិ៍សាត់ និងបាត់ដំបង។<br>• ការងារសាងសង់នេះក៏ប៉ះពាល់ដល់គុណភាពទឹក ដោយសារ សកម្មភាពសាងសង់ ដូចជាការលាងថ្ម ខ្សាច់ ការហូរច្រោះ ជញ្ជាំងភ្នំដែលខ្លួនបានកាយ និងការចាក់សំណល់ដី ថ្ម ដែលធ្វើឱ្យទឹកស្ទឹងឡើងល្អក់ខ្លាំង។<br>• ប៉ះពាល់ដល់គុណភាពទឹកដោយសារ ការបោះបង់សំណល់រឹង និងការបង្ហូរ | | ✓ | | • បានសាងសង់ផ្លូវទឹកបង្វៀងការដ្ឋានដើម្បីផ្ដល់ទឹកមក ខ្សែទឹកខាងក្រោម ឱ្យបានជាធម្មតាវិញ។<br>• ធ្វើការកាត់បន្ថយការធ្វើឱ្យល្អក់ខ្លាំងដោយ សាងសង់ទំនប់បណ្ដោះអាសន្ន ព័ទ្ធជុំវិញការដ្ឋានសំណង់ទំនប់។ ធ្វើការដាំស្មៅនៅកន្លែងដែលខ្លួនបានកាយ ជញ្ជាំងភ្នំ ឬកន្លែងចំណោទផ្សេងៗដើម្បី ធ្វើផ្លូវ ធ្វើទំនប់ និងធ្វើហេដ្ឋា រចនាសម្ព័ន្ធគម្រោងដទៃទៀត ដើម្បីការពារការហូរច្រោះ បាក់ជញ្ជាំងភ្នំ បន្ថែម។<br>• ត្រួតពិនិត្យអ្នកម៉ៅការសាងសង់ទាំងអស់ ដោយជឿជាក់ថា សំណល់ ដី ថ្ម ទាំងនោះមិនបានចាក់តាមមាត់ច្រាំង ឬក្នុងស្ទឹង អូរ ក្នុងតំបន់គម្រោងឡើយ ទីតាំងចាក់សំណល់ដីនិងថ្ម មើល គំនូរបច្ចេកទេស DRW 01។ | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | សំណល់រាវពីកន្លែងរស់នៅរបស់ បុគ្គលិក-កម្មករ នៃគម្រោង បង្ហូរ ការលេចធ្លាយប្រេងឥន្ធនៈ និងប្រេងរំអិលពីគ្រឿង យន្តនានាក្នុងការដ្ឋានសាងសង់ និងការមុជទឹកសំអាតខ្លួនប្រាណ របស់បុគ្គលិក-កម្មកររាប់រយនាក់ ដែលនៅក្បែរប្រភពទឹក នឹងធ្វើឱ្យ គុណភាពទឹកស្ទឹងពោធិ៍សាត់មានការថយចុះ។ | | | | • សកម្មភាពសាងសង់ធំៗ និងមមាញឹក គឺសាងសង់នៅរដូវប្រាំង ដើម្បីកាត់ បន្ថយការហូរច្រោះពីការដ្ឋានដីផ្សេងៗ ដែលហូរចូលស្ទឹង។ ចំណែកឯ នៅរដូវវស្សាវិញក្រុមហ៊ុនធ្វើការសាងសង់ទំនប់ ដោយធ្វើផែនការសាង សង់ប្រចាំខែច្បាស់លាស់ ដូចជាការសង់ជញ្ជាំងបេតុងដែល ស្រោបពទ្ធ័ជុំវិញ ទំនប់ជាមុនបានខ្ពស់ជាងកម្ពស់ថ្ម ដែលត្រូវចាក់ក្នុងរយៈ១ខែ ដើម្បីជៀសវាង ការហូរច្រោះកម្ទេចថ្មចូលស្ទឹងជាដើម។<br>• ធ្វើការអប់រំដល់បុគ្គលិកកម្មករអំពីការបោះបង់សំណល់រឹង-រាវ ជាពិសេស ការកំពប់ប្រេងឥន្ធនៈ ប្រេងរំអិលនៅលើដី ដែលបណ្តាលឱ្យខូចគុណភាពដី និងទឹកនៅក្នុងតំបន់គម្រោង។ ក្រុមហ៊ុន នឹងធ្វើការណែនាំបុគ្គលិក/កម្មករ គម្រោងឱ្យយល់ដឹងអំពីអនាម័យ ស្គាល់នូវកន្លែងទុកដាក់សម្រាម ដែលក្រុមហ៊ុនបានរៀបចំកសាងក្នុងទីតាំងស្នាក់នៅរបស់គម្រោង។<br>• គ្រប់គ្រង និងការពារសំណល់រឹង-រាវគ្រប់ប្រភេទមិនឱ្យបោះចោល និងបង្ហូរ ចូលទៅក្នុងឬក្បែរទឹកស្ទឹង ឬអូរឡើយ ដូចជាសង់បន្ទាប់ទឹក និងបង្គន់ អនាម័យឆ្ងាយពីស្ទឹងនិងអូរយ៉ាងហោចណាស់១០០ម និងមានរោងសិបទឹកត្រឹមត្រូវ មានកន្លែងទុកដាក់សំណល់រឹងល្អតាមបច្ចេកទេស ហើយត្រូវអនុវត្តទីតាមផែនការគ្រប់គ្រងសំណល់គ្រប់ប្រភេទដូចមានចែង ក្នុងជំពូក៤ ចំណុច ៤.៦.១១។<br>• សាងសង់បង្គន់អនាម័យ ដោយជីករណ្តៅ ដាក់លូជម្រៅពី ២,៥ ទៅ ៣,៥ម ដើម្បីសំលាប់មេរោគ។ ចំពោះសំណល់ផ្ទះបាយវិញ គឺជីករណ្តៅជម្រៅ១-២ម. ទំហំ៤ទៅ៦ម² ដើម្បីធ្វើឱ្យសំណល់នោះក្លាយជាជីកំប៉ុស្ត៍ បានថែម ទាំងមានធុងទុកសម្រាប់ដាក់សម្រាម និងកន្លែងដុតសម្រាមចោល ដោយ សុវត្ថិភាព។ | |
| ក.៣ ការហូរច្រោះ និងគុណភាពដី | • អាចមានការហូរច្រោះដី ដោយសារការឈូសឆាយដីគម្របព្រៃឈើ ដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គម្រោង ដូចជា ការកាយ ជញ្ជាំងភ្នំធ្វើផ្លូវ ធ្វើទំនប់ ធ្វើអាគារថាមពលជាដើម ព្រោះថាតំបន់ នេះជាតំបន់ខ្ពង់រាប និងភ្នំនឹងងាយមានការហូរច្រោះ ដីជាពិសេស នៅរដូវវស្សា តែតំបន់នេះជាតំបន់រងនូវទឹកភ្លៀងច្រើនផងដែរ។<br>• រីឯសកម្មភាពសាងសង់បង្កឱ្យប៉ះពាល់ដល់គុណភាពដីស្រទាប់លើនៅជុំវិញតំបន់ចោលដីស្តុយឬសំណល់ថ្ម ដែលធ្វើឱ្យបាត់បង់ជីជាតិ របស់ដីស្រទាប់លើនាតំបន់នោះបណ្តាលមកពីការហូរច្រោះតំបន់ដីស្តុយ ឬសំណល់ថ្មនេះទៅគ្របពីលើសណ្ឋានដីតំបន់ជុំវិញនោះ។<br>• នៅផ្នែកខាងក្រោមទំនាប់ អាចមាន កម្ទេច កំណកដី និងថ្ម ធ្លាក់ចូលក្នុងអន្លង់ដែលមាន ត្រីមេពូជរស់នៅ ឬធ្វើឱ្យរាក់ បណ្តាអន្លង់ និងពោះស្ទឹងនៅក្រោមទំនប់។ | | | ✓ | • ត្រូវធ្វើការបង្ហាប់ដី (ការងារដី)ក្នុងតំបន់សាងសង់ឱ្យបានត្រឹមត្រូវតាម បទដ្ឋានការងារបច្ចេកទេស។<br>• ត្រូវពង្រាបដី ឬថ្មដែលចាក់ចោល ដោយយកដីមានជីជាតិលប់ពីលើរួចដាំ ដើមឈើឡើងវិញក្នុងតំបន់នេះដោយ ធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ។<br>• ធ្វើការដាំស្មៅនៅកន្លែងដែលខ្លួនបានកាយជញ្ជាំងភ្នំ ឬកន្លែងចំណោទផ្សេងៗ ដើម្បីធ្វើផ្លូវ ធ្វើទំនប់ និងធ្វើហេដ្ឋារចនាសម្ព័ន្ធ គម្រោងដទៃទៀត ដើម្បីការពារ ការហូរច្រោះបាក់ជញ្ជាំងភ្នំបន្ថែម។<br>• ត្រូវព្យាយាមមិនឱ្យ ដី ឬដុំថ្មធ្លាក់ចូលក្នុងអន្លង់ ដែលនៅជិតការដ្ឋានសាងសង់។ នៅពេលចប់ការសាងសង់ ម្ចាស់គម្រោងត្រូវ យកដុំថ្មធំៗចេញពីអន្លង់ទាំងនោះ និងបើកទឹកលាងកករបាតស្ទឹងផងដែរនៅក្នុងដំណាក់កាលប្រតិបត្តិគម្រោងដំបូង។ | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| ក.៤ ការរញ្ជួយដី | • អាចបង្កឡើងដោយសារការបំផ្ទុះផ្ទាំងថ្មនៅការដ្ឋានធ្វើទំនប់ ដែលអាច ធ្វើឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋដែលរស់នៅជុំវិញ ឬចេញចូលតំបន់គម្រោង ដោយស្ទះ ផ្លូវចេញចូល និងសំណង់ ឬប៉ះពាល់ដល់សុវត្ថិភាពកម្មករ ដូចជា ការរញ្ជួយបាក់ផ្ទាំងថ្មជាដើម។ល។ ការរញ្ជួយ ដោយសារការដឹក សម្ភារសំណង់ធ្ងន់ៗ (ថ្ម ខ្សាច់ ប្រើគ្រឿងរំញ័រក្នុងការបង្ហាប់បេតុង និងដឹកដុំទួប៊ីនអគ្គិសនី)ក្នុងការសាងសង់ ទំនប់សាងសង់រន្ធទុរនេល អាគារថាមពលជាដើម។ | | | ✓ | • បានកំណត់តំបន់គ្រោះថ្នាក់ ដោយសារការផ្ទុះនេះច្បាស់លាស់ រួចដាក់ស្លាកសញ្ញាគ្រោះថ្នាក់ នៅតាមព្រំប្រទល់តំបន់នេះ ដើម្បីឱ្យកម្មករ និយោជិត គម្រោង និងប្រជាពលរដ្ឋងាយឃើញ និងស្គាល់។<br>• ការប្រើប្រាស់គ្រឿងផ្ទុះ គឺបានកំណត់កម្រិតរញ្ជួយ និងកម្លាំងបំផ្ទុះឱ្យតូច ដែលមិនប៉ះពាល់ដល់ការបាក់ផ្នែកខ្លះនៃភ្នំ ឬផ្លូវដែលនៅក្បែរតំបន់ បំផ្ទុះ។<br>• ត្រូវធ្វើការផ្តល់ព័ត៌មាន ផ្សព្វផ្សាយដល់អាជ្ញាធរ និងសហគមន៍មូលដ្ឋាននូវកាលបរិច្ឆេទ និងពេលវេលាបំផ្ទុះ ដើម្បីការពារសុវត្ថិភាពដល់កម្មករ និយោជិតគម្រោង និងប្រជាពលរដ្ឋដែលរស់នៅទីនោះ។<br>• ការបំផ្ទុះក្រុមហ៊ុននឹងធ្វើនៅពេលរសៀល (ម៉ោង៤:០០-៥:០០ល្ងាច) ហើយមុនពេលបំផ្ទុះត្រូវផ្តល់សញ្ញាជាស៊ីរ៉ែន និងមានអ្នកត្រួតពិនិត្យ ថាមិនមានមនុស្ស នៅក្នុងតំបន់គ្រោះថ្នាក់នោះឡើយ។<br>• រាល់សម្ភារសំណង់ធន់ធ្ងន់ ធ្វើការដោះបំបែក និងផ្ទេរចែករំលែកឱ្យងាយក្នុង ការដឹកជញ្ជូនវា ទោះបីត្រូវប្រើរថយន្ត ដឹកច្រើនជើងក៏ដោយ។ | |
| ក.៥ គុណភាពទឹក | • មានការបំពុលទឹកស្ទឹងពោធិ៍សាត់ ដោយសារ ការសាង សង់ហេដ្ឋារចនាសម្ព័ន្ធគម្រោង បណ្តាលមកពីការខួង ឬការងារដី ការងារបេតុង ការងារបំផ្ទុះថ្មភ្នំ ការកាយជញ្ជាំងភ្នំ និងការចាក់ សំណល់ដី ថ្ម ចោល ដោយមិនបានបង្ហាប់ និងបានដាំស្មៅជាដើម។ មានការគុណភាពទឹកពីកន្លែងលាងថ្ម ខ្សាច់ដើម្បីលាយបេតុងរួច ទឹកនោះហូរ ចូលអូរ ស្ទឹង ព្រែក ដែលធ្វើឱ្យប៉ះពាល់ ដល់ជីវិតសត្វ និងមនុស្ស ដែលប្រើប្រាស់ទឹកនេះនៅខាងក្រោម ខ្សែទឹក។<br>• ប៉ះពាល់គុណភាពទឹកស្ទឹងពោធិ៍សាត់ដោយសារសំណល់រឹង-រាវ មកពីការបោះចោលសំណល់ផ្ទះបាយ បង្គន់ ដែលសង់គ្មាន បច្ចេកទេស និងការខ្វះខាតបង្គន់អនាម័យគ្រប់គ្រាន់ សម្រាប់បុគ្គលិក កម្មករគម្រោង និងការបោះសំណល់សម្ភារសំណង់ ដោយ បុគ្គលិក-កម្មករក្រុមហ៊ុន (ការហៀរ ឬលេចជាតិប្រេងពីគ្រឿង ចក្ររថយន្ត បាវស៊ីម៉ងត៍ បាវ ឬស្បោងច្រកសារធាតុគីមីផ្សេង ទៀត។ល។)។<br>• មានការហូរច្រោះដី ដោយសារការកាប់ឆ្ការនូវគម្របរុក្ខជាតិ ដូចជា ការកាប់ព្រៃ ការបោសសម្អាតដីធ្វើហេដ្ឋារចនាសម្ព័ន្ធគម្រោង និងការ កាប់រានព្រៃឈើនៅតាមដងអូរឬស្ទឹងដែលនឹងត្រូវលិចជាដើម។ | | | ✓ | • មិនឈូសឆាយទ្រង់ទ្រាយធំនៅរដូវវស្សាទេ។<br>• ដើម្បីការពារកករដីកុំឱ្យសាយភាយចេញឆ្ងាយពីទីតាំងសាងសង់ ក្រុមហ៊ុន នឹងធ្វើរបាំងការពារ។<br>• កន្លែងលាងថ្មលាយបេតុងក្រុមហ៊ុនធ្វើប្រព័ន្ធកាត់បន្ថយកាពល្អក់ ដោយជីក ប្រឡាយជុំវិញ រួចទឹកហូរចេញពីប្រឡាយនេះចូលទៅក្នុងអាងរងកករទី១ ទំហំ១០x១០x៣ម. (បណ្តោយxទទឹងxជម្រៅ) បន្ទាប់មកទឹកនេះហូរចូលអាង រងកករទី២មានទំហំ១០x១៥x៣ម (បណ្តោយxទទឹងxជម្រៅ)។<br>• ធ្វើការអប់រំបុគ្គលិក-កម្មករគម្រោងឱ្យយល់ដឹងអំពីអនាម័យ មិនបន្ទោបង់ ពាសវាលពាសកាល ស្គាល់នូវកន្លែងទុកដាក់សម្រាមដែលក្រុមហ៊ុនបានរៀប ចំកសាងក្នុងទីតាំងស្នាក់នៅរបស់គម្រោង។<br>• ចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងសំណល់រាវ ដោយសាងសង់បង្គន់អនាម័យ បន្ទប់ទឹកឱ្យឆ្ងាយពីមាត់ស្ទឹងដោយមានអាងសិបទិកត្រឹម ត្រូវព្រមទាំងរៀបចំប្រមូលសំណល់រឹង និងសម្រាមយកទៅចោលនៅទីតាំង ដែលមានសុវត្ថិភាពល្អ មិនឱ្យប៉ះពាល់បរិស្ថានជុំវិញ មិនឱ្យបោះចោល និងបង្ហូរចូលទៅក្នុង ឬក្បែរទឹកស្ទឹង ឬព្រែកឡើយ ដោយមានកន្លែងទុកដាក់ សំណល់ រឹងល្អតាមបច្ចេកទេស។<br>• ដើម្បីធ្វើឱ្យមានប្រសិទ្ធិភាពក្នុងការគ្រប់គ្រងសំណល់រឹងនោះត្រូវបោះស្លាកសញ្ញានៅក្នុង និងក្បែរតំបន់គម្រោង ដោយមានអក្សរខ្មែរ និងរូបរំអិតពីការ បំពុលទឹក។<br>• សាងសង់អាងសិបទិកតាមបច្ចេកទេសសម្រាប់ទឹកកខ្វក់ ចេញពីការិយាល័យ បន្ទប់ទឹក បង្គន់ ផ្ទះបុគ្គលិក ដែលស្នាក់នៅបណ្តោះអាសន្នក្នុងពេលសាងសង់ គម្រោង។ | |



Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | | | | | • សាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវតាមបទដ្ឋានសុវត្ថិភាពដល់បរិស្ថាន និងសង្គម។<br>• ប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និងរថយន្តដឹកជញ្ជូន ដែលមានគុណភាពល្អ មិនលេចហូរជាតិប្រេង ឬខ្លាញ់ មកលើដី និងប្រភពទឹកក្នុងតំបន់គម្រោង។<br>• ដើម្បីការពារការហូរច្រោះដែលអាចធ្វើឱ្យមានការបំពុលទឹកនោះ ត្រូវដាំ ព្រៃឈើឡើងវិញនៅតាមកន្លែងចាក់ចោលដីស្អុយ ឬសំណល់ថ្ម កន្លែងយក ដី និងថ្ម។ ធ្វើការដាំស្មៅនៅជញ្ជាំងភ្នំ និងនៅជញ្ជាំងកន្លែងចាក់សំណល់ដី និងថ្ម ដែលខ្លួនបានធ្វើ។<br>• ត្រូវធ្វើការគ្រប់គ្រង និងការពារសំណល់រឹង-រាវគ្រប់ប្រភេទមិនឱ្យបោះ ចោល និងបង្ហូរចូលទៅក្នុងឬក្បែរទឹកស្ទឹង ឬព្រែកឡើយ ដូចជាសង់បន្ទប់ទឹក និងបង្គន់អនាម័យឆ្ងាយពីស្ទឹង មានអាងសិបទិកត្រឹមត្រូវមានកន្លែងទុក ដាក់សំណល់រឹងល្អតាមបច្ចេកទេស។<br>• ត្រូវសាងសង់បង្គន់អនាម័យ ដោយជីករណ្តៅ ដាក់លូដើម្បីស្តុកលាមកមាន ជម្រៅពី ២,៥ ទៅ ៣,៥ម ដើម្បីសំលាប់មេរោគ។ ចំពោះសំណល់ផ្ទះបាយវិញ គឺមិនបង្ហូរ ឬចាក់ចូលទៅក្នុងស្ទឹងពោធិ៍សាត់ទេគឺជីករណ្តៅជម្រៅ១-២ម. ទំហំ៤ ទៅ៦ម² ដើម្បីធ្វើឱ្យសំណល់នោះក្លាយជាជីកំប៉ុស៍បានថែមទាំង មានធុងទុកសម្រាប់ដាក់សម្រាម និងកន្លែងដុតសម្រាមចោលដោយសុវត្ថិភាព។<br>• ម្ចាស់គម្រោង និងអ្នកម៉ៅការទាំងអស់ ត្រូវអនុវត្តអនុវត្តជាប្រចាំនូវ ផែនការគ្រប់គ្រងសំណល់គ្រប់ប្រភេទ ដែលមានចែងក្នុងជំពូក ៤ចំណុច ៤.៦.១១។ | |
| ក.៦ គុណខ្យល់ | • ការបំពុលខ្យល់ដោយសារការដុតព្រៃឈើ ដើម្បីសំអាតការដ្ឋាន និង ផ្សែងដែលបំភាយចេញពីគ្រឿងចក្រសាងសង់រថយន្តដឹកជញ្ជូន សម្ភារ និងការបំផ្ទុះសម្រាប់ការងារសាងសង់របស់គម្រោង។<br>• ការបំពុលខ្យល់ដោយសារធូលីដីថ្ម ហុយចេញពីការដឹកជញ្ជូន សម្ភារសំណង់ចេញពីការកិនបំបែកថ្ម ចេញពីផ្លូវដែលមិនបាន ស្រោចទឹកជាប្រចាំ ធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់កម្មករ អ្នក ធ្វើដំណើរ និងសត្វរស់នៅក្បែរនោះទៀតផង។<br>• អាចនឹងបំពុលខ្យល់ដោយសារភ្លើងឆេះព្រៃ បណ្តាលមកពីការធ្វេស ប្រហែសពីបុគ្គលិកកម្មករគម្រោង។ | | | ✓ | • មិនដុតព្រៃឈើទាំងអស់នៃតំបន់នឹងត្រូវលិចនោះទេ គឺក្រុមហ៊ុនធ្វើការ សហការជាមួយរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន ដើម្បីធ្វើការសំអាត ព្រៃក្នុងតំបន់ដែលនឹងត្រូវលិចដូចជា: ក្រសួងអាចលក់ឈើឱ្យក្រុមហ៊ុនផ្សេង ដែលក្រុមហ៊ុននេះត្រូវកែច្នៃឈើទាំងនោះឱ្យអស់លទ្ធភាព ដែលអាចធ្វើទៅបានហើយបានថវិកាចូលរដ្ឋថែមទៀតផង។<br>• មែកឈើ អាចកែច្នៃជាធ្យូងនិងឧសឱ្យអស់លទ្ធភាព ពោលគឺដុតតែមែកឈើតូចៗ និងស្លឹកឈើប៉ុណ្ណោះ។<br>• ចំពោះមែកឈើ ដើមឈើដែលនៅក្នុងទីជ្រលង មិនអាចយកចេញមិនបាន ត្រូវកាប់ប្រមូលដុត ជាគ្នក ឱ្យឆ្ងាយពីព្រៃមិនទាន់កាប់ ចម្ងាយយ៉ាងហោចណាស់ពី១៥ ទៅ២០ ម.។ ការដុត មែកឈើ និងដើមឈើទាំងនេះត្រូវមានការប្រុងប្រយ័ត្នពីភ្លើងអាចរាលដាល បណ្តាលឱ្យមានភ្លើងឆេះព្រៃនៅជាប់នេះ។<br>• ប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និងរថយន្តដឹកជញ្ជូន ដែលមានការបញ្ចេញផ្សែងតិច និងមានបំពង់ស៊ីម៉ុងជិតល្អ ដើម្បីកាត់បន្ថយការបំពុលខ្យល់ ក្នុងតំបន់នោះ។<br>• ជ្រើសរើសជាតិផ្ទុះដែលមិនបង្កការបំពុលខ្យល់ខ្លាំង។<br>• បានត្រៀមឧបករណ៍ពន្លត់អគ្គិភ័យ និងមានកន្លែងបូមទឹកគ្រប់គ្រាន់នៅពេល មានអគ្គិភ័យ។ | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | | | | | • ធ្វើការស្រោចទឹកជាប្រចាំលើផ្លូវដែលខ្លួនដឹកសម្ភារ និងកន្លែងកិនថ្ម ហើយ ធ្វើការគ្របគម្របលើដី ខ្សាច់ ថ្ម ស៊ីម៉ង់ត៍ នៅពេលដែលរថយន្តទាំងនោះដឹក វាឆ្លងកាត់ភូមិអ្នកស្រុក ទីប្រជុំជនជាដើម។ | |
| ក.៧ គុណភាពដី | • ក្នុងសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធ របស់គម្រោងនេះមាន ការបំពុលដីដោយសារការកំពប់ នៃប្រេងឥន្ធនៈ ការកំពប់នៃសារ ធាតុគីមី និងសំណល់រឹង-រាវគ្រប់ប្រភេទទៅលើដីដូចជាៈ សំណល់ចេញពី ឬលេចធ្លាយពីគ្រឿងចក្រ និងរថយន្តគ្រប់ ប្រភេទ ដែលដំណើរការគម្រោងនេះ ព្រមទាំងសំណល់ចេញពី ផ្ទះបាយ។<br>• បំពុលដីដោយសារការចាក់ដីស្អុយឬសំណល់ថ្មដែលដឹកចេញពីតំបន់ គម្រោងនោះ ក៏អាចនឹងបង្កឱ្យកេនផលប៉ះពាល់ដល់ស្រទាប់ដីខាងលើ ផងដែរ<br>• បំពុលដីដោយសារការគ្រប់គ្រងនូវសារធាតុផ្ទុះមិនបានល្អធ្វើឱ្យធ្លាក់ ទៅលើដី។ ការឈូសឆាយព្រៃស្រទាប់លើនៅតាមតំបន់ទីជម្រាល ធ្វើឱ្យមានការហូរច្រោះដីនៅរដូវវស្សា និងមានសំណើកដោយ សារខ្យល់នៅរដូវប្រាំងក៏បានធ្វើដីបាត់បង់គុណភាពផងដែរ។ | | | ✓ | • ត្រូវសាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈបានត្រឹមត្រូវមិនឱ្យកំពប់ ឬជ្រាបចូល ដីឡើយ។<br>• ត្រូវពង្រាបដី ឬថ្មដែលចាក់ចោលដោយយកដីមានជីជាតិលប់ពីលើរួចដាំដើមឈើឡើងវិញក្នុងតំបន់នេះ ដោយធ្វើការសហការ ជាមួយរដ្ឋបាលព្រៃឈើ។<br>• ត្រូវគ្រប់គ្រងសំណល់រឹងរាវគ្រប់ប្រភេទឱ្យបានត្រឹមត្រូវដូចជាៈចាត់វិធាន ការណ៍យ៉ាងតឹងរ៉ឹងមិនឱ្យចាក់ប្រេង ម៉ាស៊ីនចាស់ៗ(ប្រេងបាត) ចោលទៅ លើដី។<br>• ធ្វើការដាក់ទណ្ឌកម្មដល់អ្នកដែលប្រព្រឹត្តិខុស ដូចជាៈ ស្តីបន្ទោស ពិន័យ ឬការបណ្តេញពីការងារជាដើម។ | |
| ក.៨ សំឡេង និងរំញ័រ | • ក្នុងដំណាក់កាលនេះធ្វើឱ្យរំខាន ដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ដែលចេញចូលទីនោះ និងពពួកសត្វព្រៃដែលមាននៅក្នុង និងជុំវិញទីតាំងគម្រោង ដោយសារមានសំឡេង និងរំញ័រចេញពី គ្រឿងចក្ររថយន្ត ម៉ាស៊ីនគ្រប់ប្រភេទពេលកំពុងធ្វើការងារ ការបំផ្ទុះថ្ម ការកាប់រំលំដើមឈើធំៗ។ ល។<br>• មានការប៉ះពាល់ដោយសារសំឡេងពីភាពឡូឡាអឺងកងពី បុគ្គលិក កម្មករគម្រោង ដែលមានជាមធ្យមប្រមាណ៤០០នាក់ ធ្វើឱ្យរំខាន ដល់ការរស់នៅរបស់ប្រជាពលរដ្ឋ និងពពួកសត្វព្រៃ ដែលមាននៅក្នុង និងជុំវិញទីតាំងគម្រោង | | | ✓ | • ត្រូវប្រើប្រាស់គ្រឿងយន្ត និងមធ្យោបាយដឹកជញ្ជូនដែលមានសំឡេងតិច។<br>• កំណត់តំបន់គ្រោះថ្នាក់ដោយសារការផ្ទុះនេះឱ្យបានច្បាស់លាស់ រួចដាក់ ស្លាកសញ្ញាគ្រោះថ្នាក់នៅតាមព្រំប្រទល់តំបន់នេះ ដើម្បីឱ្យកម្មករ និយោជិត គម្រោង និងប្រជាពលរដ្ឋងាយឃើញ និងស្គាល់។<br>• ធ្វើការកំណត់កម្រិតវញ្ញយ និងកម្លាំងបំផ្ទុះឱ្យតូចដែលមិនប៉ះពាល់ដល់ការបាក់ផ្ទៃខ្លះនៃភ្នំឬផ្លូវដែលនៅក្បែរតំបន់ផ្ទុះដូចជាការចោះរន្ធបំផ្ទុះយកថ្ម ជាក្រឡាចត្រង្គ ដែលមានពី៣២ទៅ៤៥រន្ធ ចម្ងាយពីរន្ធមួយទៅរន្ធមួយ៦ម និងមានជម្រៅខួងពី ៦ទៅ៧ម។ | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | នោះផងដែរ។ | | | | សមាសធាតុរួមផ្សំ ដើម្បីបំផ្ទុះក្នុងមួយរន្ធគិតជាមធ្យមគឺ ការអាម៉ូញ៉ូមនីត្រាត (Ammonium Nitrate) ចំនួន ២០គ.ក្រ, ប្រេងម៉ាស៊ូត ១,៨លីត្រ, វ៉ាសេវប្រភេទតានអិមមូលសិនអិចក្លូសស៊ីវ (TAN Emulsion Explosive) ចំនួន ១ គ.ក្រ និងគីបអគ្គិសនីពន្យាពេល ១គ្រាប់។<br>• ផ្តល់ព័ត៌មាន និងផ្សព្វផ្សាយដល់អាជ្ញាធរ និងសហគមន៍មូលដ្ឋាននូវកាលបរិច្ឆេទ និងពេលវេលា បំផ្ទុះដើម្បីការពារសុវត្ថិភាពដល់កម្មករនិយោជិត គម្រោង និងប្រជាពលរដ្ឋដែលចេញចូលទីនោះ។<br>• ចំពោះការបំផ្ទុះក្រុមហ៊ុនធ្វើនៅពេលសៀល(ម៉ោង៤:០០៥:០០ល្ងាច)។<br>• កំណត់ពេលវេលាធ្វើការតែពេលថ្ងៃប៉ុណ្ណោះ ដើម្បីកាត់បន្ថយការរំខាន ដល់ប្រជាពលរដ្ឋ និងសត្វព្រៃក្នុងតំបន់គម្រោងនេះ។<br>• ធ្វើការអប់រំដល់បុគ្គលិកកម្មករគម្រោងឱ្យចេះស្ងៀមស្ងាត់ នៅពេលម៉ោង សំរាក និងនៅពេលយប់។<br>• សម្គាល់៖ក្រុមការងារសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនេះបាន សហការជាមួយមន្ទីរពិសោធន៍នៃក្រសួងបរិស្ថាន ធ្វើតេស្តសំឡេង និងរំញ័រនៅ ចំណុច ដែលមានសកម្មភាពមមាញឹកជាងគេមុនការ សាងសង់ទំនប់វារីអគ្គិសនី ស្ទឹងពោធិ៍សាត់១ នេះ គឺនៅក្បែរផ្លូវជាតិលេខ៥៥ ដោយលទ្ធផលបានបង្ហាញថា នៅពេលថ្ងៃសំឡេងមានកម្រិតក្រោមស្តង់ដារបស់ក្រសួងបរិស្ថាន ក៏ប៉ុន្តែនៅពេល យប់វេលាម៉ោង៥ ទៅ៦ព្រឹក មានការលើសស្តង់ដាតិចតួចប៉ុណ្ណោះគឺ ៥០,៦dB ហើយបើគិតជាមធ្យមមាន ៥១,១៨dB រីឯស្តង់ដារមាន ៥០dB។ ចំណែកឯ រំញ័រវិញ គឺស្ថិតនៅក្រោមស្តង់ដារបស់ក្រសួងបរិស្ថានវិញ។ | |
| ខ. ធនធានជីវសាស្ត្រ | | | | | | |
| ខ.១. ជីវសាស្ត្រដែល រស់នៅក្នុងទឹក/មច្ឆជាតិ | • អាចប៉ះពាល់ដល់ផ្លូវចេញចូលរបស់មច្ឆជាតិ និងជីវសាស្ត្រនៅក្នុង ទឹក ដោយសារក្រុមហ៊ុនទប់ទំនប់បណ្តោះអាសន្ន កាត់ស្ទឹងពោធិ៍សាត់ ដើម្បីសាងសង់ទំនប់វារីអគ្គិសនីនេះ។ ក្រុមហ៊ុនគ្មានគម្រោង សាងសង់ជណ្តើរត្រី ឬសំណង់ដែលសម្រាប់ឱ្យត្រីឆ្លងកាត់ពីខាងក្រោម ទៅតំបន់ខាងលើទំនប់បានទេ។<br>• អាចប៉ះពាល់គុណភាពទឹកស្ទឹងពោធិ៍សាត់ ធ្វើឱ្យបំពុលដល់មច្ឆជាតិ និងជីវសាស្ត្រនៅក្នុងទឹក ដោយសារការធ្វើឱ្យល្អក់ទឹកបណ្តាលមក ពីសកម្មភាពសាងសង់គម្រោង កន្លែងលាងថ្ម និងបំពុលទឹកដោយ សារសំណល់រឹង-រាវចេញពីការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគម្រោង កន្លែងចាក់សំណល់ ដី-ថ្ម និងជំរុំបុគ្គលិក-កម្មករគម្រោង។ | | | ✓ | • បានគ្រោងសាងសង់ចោះរូងកាត់ភ្នំធ្វើជាផ្លូវទឹកបង្វៀងការដ្ឋានទំនប់ ដោយមានជម្រាលបាតមិនចោទ ដើម្បីបង្កភាពងាយស្រួលដល់ការធ្វើចរាចរ នៃជីវសាស្ត្រក្នុងទឹកពីផ្នែកខាងក្រោមការដ្ឋានទៅផ្នែកខាងលើការដ្ឋានបាន។ នៅកន្លែងលាងថ្ម លាយបេតុងក្រុមហ៊ុន ធ្វើប្រព័ន្ធកាត់បន្ថយភាពល្អក់ ដោយជីកប្រឡាយជុំវិញ រួចទឹកហូរចេញពីប្រឡាយ នេះចូលទៅក្នុងអាង រងកករទី១ ទំហំ១០x១០x៣ម.(បណ្តោយxទទឹងxជម្រៅ) បន្ទាប់មកទឹក នេះហូរចូលអាងរងកករទី២ មានទំហំ១០x១៥x៣ម (បណ្តោយxទទឹងxជម្រៅ)។ ធ្វើការដាំស្មៅនៅកន្លែងដែលខ្លួនបានកាយជញ្ជាំងភ្នំ ឬកន្លែងចំណោតផ្សេងៗ ដើម្បីធ្វើផ្លូវ ធ្វើទំនប់ និងធ្វើហេដ្ឋារចនាសម្ព័ន្ធគម្រោង ដទៃទៀត ដើម្បីការពារការហូរច្រោះ បាក់ជញ្ជាំងភ្នំបន្ថែម និងការពារ ភាពល្អក់ខ្លាំងហូរចូលស្ទឹង។<br>• មានវិធានការដើម្បីជំនួសសំណង់សិប្បការសម្រាប់ឱ្យត្រីឆ្លងកាត់ ដោយសហការជាមួយ | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | • មានការបាត់បង់ធនធានជលផល ដោយសារបុគ្គលិក-កម្មករគម្រោង ប្រព្រឹត្តបទល្មើសជលផល ដូចជា បោកគ្រាប់បែក ឬប្រើគ្រឿងផ្ទុះ ដើម្បីចាប់យកត្រីក្នុងស្ទឹង តាមអន្លង់ជាដើមដែលធ្វើឱ្យហិនហោច បាត់បង់ពូជត្រីក្នុងតំបន់ ដូចជា ត្រីខ្សា ត្រីទ្រនេល ត្រីពោ ត្រីគល់ រាំង ត្រីកាហែ ត្រីខ្នាវ ត្រីកញ្ជនជ័យ ត្រីក្រុស ភ្នំកន្ទាយ អណ្តើក ទឹក និងក្រពើភ្នំ ជាដើម។ | | | | រដ្ឋបាលជលផល រៀបចំកម្មវិធីព្រលែងត្រីក្នុងស្ទឹងខាងក្រោមទំនប់ និងអាង ដោយព្រលែងពូជត្រីដែលមាននៅក្នុងគម្រោង។ ***សម្គាល់:*** *ចំពោះតម្លៃនៃសំណង់ជណ្តើរត្រីឆ្លងកាត់បានមានតម្លៃរាប់លានដុល្លារ ដែលធ្វើឱ្យតម្លៃដើមរបស់អគ្គិសនីកើនខ្ពស់ផងដែរ។ មច្ឆជាតិគ្រប់ប្រភេទ ដែលឡើងមកពីខាងក្រោមទីតាំងទំនប់មិនអាចឆ្លងកាត់ស្ទឹងតំបន់នេះទៅខាងលើទំនប់បានឡើយក្រោយពីការសាងសង់ទំនប់នេះចប់។ ម្យ៉ាងទៀតនៅខាងលើទំនប់ (ក្នុងអាង) ប្រភេទជាសម្បូរត្រីដែលមានក្នុងតំបន់ ដូចមានចែងក្នុងជំពូក៥ ចំណុច៤ តារាង៥-៤៥។ ប៉ុន្តែអាចបាត់បង់ត្រីមួយចំនួន ដូចជា ត្រីក្រសក់ ត្រីគល់រាំង ត្រីសណ្តាយ ត្រីឆ្ពោក ត្រីរៀល ត្រីក្អែក ជាដើម ពីព្រោះវាឡើងពីបឹងទន្លេសាប។*<br>• គ្រប់គ្រងសំណល់រឹងគ្រប់ប្រភេទឱ្យបានល្អរួចយកទៅចោលនៅទីតាំងដែល មានសុវត្ថិភាពឆ្ងាយពីប្រភពទឹក។ ម្ចាស់គម្រោង និងអ្នកម៉ៅការទាំងអស់ ត្រូវអនុវត្តជាប្រចាំនូវផែនការគ្រប់គ្រងសំណល់គ្រប់ប្រភេទ ដែលមានចែងក្នុងជំពូក ៤ចំណុច ៤.៦.១១។<br>• អប់រំដល់បុគ្គលិក កម្មករ អំពីការបោះបង់សំណល់រឹង-រាវ ជាពិសេសការ កំពប់ប្រេងឥន្ធនៈ ប្រេងរំអិលនៅលើដី និងក្នុងទឹកនៅក្នុងតំបន់គម្រោង។<br>• ព្យាយាមមិនឱ្យ ដី ឬថ្មធ្លាក់ចូលក្នុងអន្លង់ ដែលនៅជិតការដ្ឋានសាងសង់។ នៅពេលចប់ការសាងសង់ ម្ចាស់គម្រោងត្រូវ យកដុំថ្មធំៗចេញពីអន្លង់ទាំងនោះវិញ ប្រសិនបើមាន និងបើកទឹកលាងកករបាតស្ទឹងនៅខាងក្រោមទំនប់ផងដែរ នៅក្នុងដំណាក់កាលប្រតិបត្តិគម្រោងដំបូង។<br>• អប់រំដល់បុគ្គលិកកម្មករអំពីមិនឱ្យប្រព្រឹត្តបទល្មើសជលផល ដូចជាការប្រើ រំសេវធ្វើគ្រឿងផ្ទុះយកទៅបោកបំផ្ទុះ ត្រីក្នុងស្ទឹង តាមអន្លង់ជ្រៅៗការឆក់ត្រី ជាដើម ហើយបើនៅតែល្មើសត្រូវមានទោសតាមច្បាប់ជាធរមាន។<br>• ត្រូវធ្វើការសហការជាមួយមន្ទីរកសិកម្ម រុក្ខា ប្រមាញ់និងនេសាទ(ជំនាញជលផល) ដែនជម្រកសត្វព្រៃភ្នំសំកុស និងអង្គការអភិរក្សនានា ក្នុងការទប់ស្កាត់បទល្មើសទាំងនេះ។<br>• ក្រុមហ៊ុន ត្រូវជួយឧបត្ថម្ភដល់ប្រតិបត្តិការចាប់សត្វក្រពើភ្នំចេញតំបន់ ពីទំនប់វារីអគ្គិសនី និងការដោះលែងវាទាំងនោះនៅទៅជម្រកដែលមានសុវត្ថិភាពសមស្រប។ | |
| ខ.២ ព្រៃការពារ/តំបន់ ការពារ/ឧទ្យាន ជាតិ | • គម្រោងនេះមានផ្ទៃដីសរុប៩.៣៥៥ហ.ត. ហើយក្នុងនោះមានតំបន់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ៤១៩៩,២០ហ.ត ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល ៣៩៩.៧ ហ.ត និងដែនជម្រកសត្វព្រៃភ្នំសំកុស ៤.៧៥៦,១ហ.ត ដែលនឹងប៉ះពាល់ដល់គម្របព្រៃឈើសរុប ៦.០០៧,២៤ហ.ត បង្កឱ្យមានផលប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់នេះយ៉ាងខ្លាំងផងដែរ។ ការបំពុលបរិស្ថាននៅក្នុងតំបន់អភិរក្ស ព្រៃការពារទាំងនេះ ដូចជា ការបំពុលខ្យល់ បំពុលទឹក ដោយសារសំណល់បញ្ចោញចោល ពីកន្លែងសាងសង់ និងចេញពីកន្លែងស្នាក់ | | | ✓ | • ត្រៀមថវិកាមូលនិធិបរិស្ថាន សរុបចំនួន៦៦៧.៦៨០ដុល្លារអាមេរិកសម្រាប់ មួយជីវិតគម្រោង ៣៥ឆ្នាំ (គ្រោងថវិកាវដ្តទី១ (រយៈពេល១០ឆ្នាំ)) ក្នុងនោះមានសម្រាប់ដាំឈើឡើងវិញ និងបង្កើតសហគមន៍ការពារអភិរក្សព្រៃឈើ និងល្បាត, សម្រាប់ការព្រៃងកូនត្រី អភិរក្សជលផល និងសង្គ្រោះក្រពើត្រី/ក្រពើភ្នំ ក្នុងការស្តារបរិស្ថានធម្មជាតិឡើងវិញ (លម្អិតមើលតារាង៨-៣, ៨-៤, ៨-៥, ៨-៦ ក្នុងជំពូក៨ ចំណុច ៨.៨)។<br>• កំណត់ពេលវេលាធ្វើការតែពេលថ្ងៃសម្រាប់ការងារទាំងឡាយណា ដែលបង្ក សំឡេង និងរំញ័រ ដើម្បីកុំឱ្យមានការរំខាន ឬផ្អើលសត្វព្រៃក្នុងតំបន់គម្រោង និងតំបន់ក្បែរខាង។ | |

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | នៅរបស់កម្មករ-បុគ្គលិក កន្លែងស្តុកគ្រឿង និងសម្ភារសំណង់ និងពីគ្រឿងចក្រ។<br>• អាចមានការទន្ទ្រានចូលក្នុងព្រៃនៃតំបន់ការពារទាំងនេះ ពីសំណាក់ ក្រុមកម្មករ ក្រោយពីការងារដើម្បីរកអនុផលព្រៃឈើ ឬចាប់សត្វ ឬការទិញលក់ ចរាចរ ឈើ និងសត្វព្រៃជាដើម។<br>• អាចនឹងមានការទន្ទ្រានកាន់កាប់យកដីព្រៃការពារដីតំបន់អភិរក្ស ទាំងនេះពី សំណាក់ជនឆ្លៀតឱកាសដោយសារគម្រោង ធ្វើផ្លូវតន្លង ខ្សែបណ្តូង និងការ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់របស់គម្រោង។ | | | | • កំណត់កម្រិតរញ្ជួយ និងកម្លាំងបំផ្ទុះ និងប្រើប្រាស់ម៉ាស៊ីនដែលមានសំឡេង និងរំញ័រតិច ដើម្បីកាត់បន្ថយការរំខាន ដល់ពពួកសត្វព្រៃ។<br>• សាងសង់បង្គន់អនាម័យ និងបន្ទប់ទឹកសម្រាប់អ្នកធ្វើការទាំងអស់នៅក្នុងការ ដ្ឋាន និង ជំរុំស្នាក់នៅរបស់គម្រោង។ រៀបចំការគ្រប់គ្រងសំណល់រឹង-រាវឱ្យ បានត្រឹមត្រូវមានសុវត្ថិភាពជាពិសេសមិនឱ្យបំពុលបរិស្ថានក្នុងតំបន់អភិរក្ស ទាំងនោះ។<br>• ធ្វើការអប់រំនិងដាក់វិន័យដល់កម្មករគម្រោងមិនឱ្យធ្វើ ការទន្ទ្រានព្រៃក្នុងតំបន់ អភិរក្សទាំងនោះ ដើម្បីចាប់ ឬបរបាញ់ ចរាចរឈើ និងសត្វព្រៃដោយ សហការ ជាមួយក្រសួងបរិស្ថាន រដ្ឋបាលព្រៃឈើ និងអង្គការអភិរក្សនានា។ ដោយដាក់ស្លាកសញ្ញាព្រៃការពារ និងហាមបរបាញ់ ជាអក្សរខ្មែរ និងកូរ៉េ ឬអង់គ្លេស ឱ្យបានច្រើនដើម្បីឱ្យប្រជាពលរដ្ឋ និងជន បរទេសងាយមើលឃើញ។<br>• សហការជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីការពារ ទប់ស្កាត់កុំឱ្យមានការរំលោភ កាន់កាប់ដី នៅតំបន់អភិរក្សទាំងនោះ (មាន លម្អិតនៅចំណុច II ស្តីពីខ្សែបញ្ជូនអគ្គិសនី) និងដាក់ប៉ាណូធំៗរបៀបរូបខាង ក្រោម ត្រង់ចំណុច ខ.៣ ខាងក្រោម។ ម្ចាស់គម្រោងត្រូវសហការ ជាមួយសាមីក្រសួងជំនាញ (ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម) ធ្វើការដាក់ ស្លាកសញ្ញា តំបន់ដែលត្រូវសំអាត ផ្ទៃអាងចំនួន៨.៥៩១ ហ.តឱ្យច្បាស់លាស់ និងមានអ្នកល្បាតត្រួតពិនិត្យនូវសាកសញ្ញា នេះជាប្រចាំដោយជឿជាក់ថាមិនមានការកាប់ឈើលើសពីលើពីព្រំដែលបានដាក់ស្លាកសម្គាល់នោះទេកុំឱ្យកម្មករ ក្រុមហ៊ុន ដែលម៉ៅការសំអាតអាង កាប់ឈើទន្ទ្រានចូលលើសផ្ទៃដី ដែលបានកំណត់ឱ្យ កាប់សំអាត។ | |
| ខ.៣ ធនធានព្រៃឈើ និងជម្រកសត្វព្រៃ | • ប៉ះពាល់ដល់ផ្ទៃដីព្រៃឈើសរុប ៦,០០៧,២៤ហ.ត ក្នុងនោះមាន ព្រៃស្រោង ៨៦៥,៤៦ហ.ត(មានឈើ៥៦ប្រភេទ) ព្រៃពាក់កណ្តាលស្រោង៨៥០,២៥ហ.ត (មានឈើ៧៦ប្រភេទ) និងព្រៃល្បោះ៤.២៩១,៥ហ.ត(មានឈើ៨៨ប្រភេទ)។ ព្រៃឈើ ទាំងនេះជាជម្រកសត្វព្រៃជាច្រើនប្រភេទ ដូចមានចែងក្នុងជំពូក៥ ចំណុច៥.១.២.១ ។<br>• អាចនឹងមានការទន្ទ្រានចាប់ដីធ្វើកម្មសិទ្ធិ ពីសំណាក់ជនឆ្លៀតឱកាស មួយចំនួនក្នុងព្រៃការពារ ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងតំបន់ការពារទាំងនេះរបស់រដ្ឋបាល ព្រៃឈើ តំបន់អភិរក្សនានា និងក្រសួងបរិស្ថាន ដោយ សារមានការអភិវឌ្ឍវារីអគ្គិសនីនៅតំបន់នេះដូចជាមានផ្លូវចេញ ចូលល្អស្រួលធ្វើដំណើរប្រហោយ-ពោធិ៍សាត់ជាដើម។<br>• អាចមានការទន្ទ្រានចូលព្រៃការពារក្បែរតំបន់គម្រោង ដើម្បីរក កាប់ឈើប្រណិត (ក្រញូង បេង ជាដើម) និងឈើសំណង់គ្រប់ ប្រភេទ ពីសំណាក់ជនឆ្លៀតឱកាស តាមមធ្យោបាយគ្រប់រូបភាព ពីព្រោះអាងតែខ្លួនទទួលបាននូវ | | | ✓ | • ជានាទិនកាប់ព្រៃឈើនៅក្រៅពីទីតាំងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដែលមាន បង្ហាញនៅក្នុងប្លង់រចនាគម្រោងលម្អិតឡើយ។ ម៉្យាងទៀតក្រុមហ៊ុន ព្យាយាម រក្សាទុកព្រៃនៅតំបន់នេះចំនួន៤៣១,១៧ហ.ត ដោយមិនឱ្យឈូសឆាយ និងកាប់ទាំងស្រុង នោះទេ ពោលគឺសំអាតនៅកន្លែង ដែលសាងសង់សំណង់ជាក់ស្តែងប៉ុណ្ណោះ (ចំពោះកន្លែងដែលត្រូវសាងសង់ទាំងនេះ មើលផែលទីលេខ ២ )។<br>• ធ្វើការប្រឹក្សាជាមួយរដ្ឋបាលព្រៃឈើ អង្គការអភិរក្សនានា ដែលពាក់ព័ន្ធ និងដែនជម្រកសត្វព្រៃភ្នំសំកុសរកទីតាំងសមស្រប ក្នុងតំបន់ ក្បែរព្រៃដែលបាត់បង់នេះ សម្រាប់ដាំឈើទុកជាជម្រកដល់សត្វព្រៃផង និងដើម្បីរក្សាលំនឹងអេកូឡូស៊ី បរិស្ថានក្នុងតំបន់នេះជាពិសេសព្រៃឈើ ស្រូបទាក់ទាញទឹកភ្លៀង ដែលជាប្រភពសម្រាប់វារីអគ្គិសនីទៀតផង។<br>• ធ្វើការការសហការជាមួយអន្តរក្រសួង ដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដែលអាចកើតមានជាយថាហេតុ លើព្រៃឈើ ដែលនៅជាប់នឹងតំបន់គម្រោងក្នុងដំណាក់កាលនៃការសាងសង់ នេះ។ | |

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | រាជបណ្ណ៍ នាំឈើចេញក្រៅ តំបន់នេះពីរាជរដ្ឋាភិបាលក្នុងការសំអាតដីព្រៃឈើដែល និងត្រូវលិចក្នុងតំបន់អាងដែលមានដីព្រៃ៥.៨៣៥,៦ហ.តជាដើម។<br>• ការបោះបង្គោលព្រំអាង និងតំបន់ដែលត្រូវសម្អាតមិនបានត្រឹមត្រូវ នាំឱ្យមានការកាប់ឈើលើសពីទីតាំងកំណត់ ប៉ះពាល់ដល់ធនធានព្រៃឈើ និងជម្រកសត្វព្រៃបន្ថែមទៀត។ | | | | • ធ្វើការសហការជាមួយអន្តរក្រសួង ក្នុងការដាក់ដេញថ្លៃប្រមូលផល អនុផលឈើ ចូលជាថវិកាជាតិ និងដើម្បីធ្វើការ សំអាតព្រៃក្នុងតំបន់ដែលនឹងត្រូវលិច តំបន់ហេដ្ឋារចនាសម្ព័ន្ធ និងអាគារថាមពល ដូចជាក្រសួងអាចលក់ឈើឱ្យក្រុមហ៊ុនផ្សេងទៀត ដែលក្រុមហ៊ុននេះ ត្រូវកែច្នៃឈើ ទាំងនោះឱ្យអស់លទ្ធភាពដែលអាចធ្វើទៅ បានហើយបានថវិកាចូលរដ្ឋថែមទៀតផង។ ម៉្យាងទៀត នៅក្នុងតំបន់សាងសង់ហេដ្ឋារចនាសម្ព័ន្ធគម្រោង(តំបន់២) ក្រុមហ៊ុនមិនធ្វើការឈូសឆាយកាប់ព្រៃឈើទាំង ៥៥៩,៩១ហ.ត នោះទេ គឺខិតខំព្យាយាមរក្សាទុកតំបន់ព្រៃចំនួន ៤៣១,១៧ហ.ត។<br>• ត្រូវបោះបង្គោលព្រំ ក្នុងការកាប់សម្អាតផ្ទៃអាងឱ្យបានច្បាស់ គឺចម្ងាយ៥០មឬ១០០មមួយ ដោយប្រើឧបករណ៍ ឋានលេខា ដើម្បីបញ្ជាក់កម្រិតនីវ៉ូអាង១៨០ម ដែលត្រូវសម្អាត ជាងវាងការកាប់ឈើលើសតំបន់កំណត់។<br>• ត្រៀមថវិកា មូលនិធិបរិស្ថាន សរុបចំនួន ៦៦៧.៦៨០ដុល្លារអាមេរិកសម្រាប់ មួយជីវិតគម្រោង ៣៥ឆ្នាំ (គ្រោងថវិការជាវដ្ត១ (រយៈពេល១០ឆ្នាំ)) ក្នុងនោះមានសម្រាប់ដាំឈើឡើងវិញ និងបង្កើតសហគមន៍ការពារអភិរក្សព្រៃឈើ និងល្បាត, សម្រាប់ការព្រៃងកូនត្រី អភិរក្សជលផល និងសង្គ្រោះក្រពើត្រី/ក្រពើភ្នំ ក្នុងការស្តារបរិស្ថានធម្មជាតិឡើងវិញ (លម្អិតមើលតារាង ៨-៣, ៨-៤,៨-៥, ៨-៦ ក្នុងជំពូក៨ ចំណុច ៨.៨)។<br>***សម្គាល់៖*** *មូលនិធិបរិស្ថានសម្រាប់រយៈពេល៣៥ឆ្នាំ គឺ៦៦៧.៦៨០ $ និងមូលនិធិសង្គមសរុប ១៥៨.៨០០$ លម្អិតមើលតារាង ៨-៣ ក្នុងជំពូក៨ ចំណុច ៨.៨។*<br>• សហការជាមួយរដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន និងអង្គការអភិរក្សនានា ក្នុងការទប់ស្កាត់ការរានដីយកធ្វើកម្មសិទ្ធិខុសច្បាប់ ដោយបង្កើនកម្លាំងការពារ និងត្រួតពិនិត្យឱ្យបានហ្មត់ចត់។<br>• ត្រូវដាក់ស្លាកសញ្ញា ឬសរសេរជាផ្ទាំងប៉ាណូធំដូចនៅតាមផ្លូវទៅកោះកុង ដូចជាសរសេរថា ព្រៃការពារហាមទន្ទ្រាន កាន់កាប់ធ្វើជាកម្មសិទ្ធហាម កាប់ឈើ ឬបរបាញ់ខុសច្បាប់ ល្មើសត្រូវជាប់ទោសដាក់គុកហូតដល់១០ឆ្នាំ ជាអក្សរខ្មែរ និងកូរ៉េ ឬអង់គ្លេសឱ្យបានច្រើន ដើម្បីឱ្យប្រជាពលរដ្ឋ និងជន បរទេសងាយមើលឃើញក្នុងតំបន់គម្រោង។ | |
| ខ.៤ ជីវសាស្ត្រសត្វ ព្រៃ | • មានសត្វព្រៃជាច្រើនប្រភេទដែលរស់នៅ ហើយប្រភេទសត្វមួយចំនួនកំពុងត្រូវបានធ្វើការអភិរក្សដោយរាជរដ្ឋាភិបាល។ សត្វព្រៃ ទាំងនេះមានដូចជា: ថនិកសត្វចំនួន ៤៤ ប្រភេទ (ក្នុងបញ្ជីក្រហម IUCN មាន១៧ប្រភេទ), បក្សី ១២០ប្រភេទ(ក្នុងបញ្ជីក្រហម IUCN មាន១ប្រភេទ), ឧរង្គសត្វ និងថលជលិកសត្វ ៦៣ប្រភេទ(ក្នុងបញ្ជីក្រហម IUCN មាន៧ប្រភេទ), និងមច្ឆជាតិទឹកសាប ៨៣ប្រភេទ (ក្នុងនោះមានក្រពើត្រីឬក្រពើភ្នំ) ក្នុងស្ទឹងពោធិ៍សាត់ ដូចមានចែងក្នុងជំពូក៥ ចំណុច៥.២.៥។ សកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិស | | | ✓ | • ត្រៀមថវិកា មូលនិធិបរិស្ថាន សរុបចំនួន ៦៦៧.៦៨០ដុល្លារអាមេរិកសម្រាប់ មួយជីវិតគម្រោង ៣៥ឆ្នាំ (គ្រោងថវិការជាវដ្ត១ (រយៈពេល១០ឆ្នាំ)) ក្នុងនោះមានសម្រាប់ដាំឈើឡើងវិញ និងបង្កើតសហគមន៍ការពារអភិរក្សព្រៃឈើ និងល្បាត, សម្រាប់ការព្រៃងកូនត្រី អភិរក្សជលផល និងសង្គ្រោះក្រពើត្រី/ក្រពើភ្នំ ក្នុងការស្តារបរិស្ថានធម្មជាតិឡើងវិញ (លម្អិតមើលតារាង៨-៣ ក្នុងជំពូក៨ ចំណុច ៨.៨)។<br>• កំណត់ពេលវេលាធ្វើការតែពេលថ្ងៃសម្រាប់ការងារទាំងឡាយណា ដែលបង្ក សំឡេង និងរំញ័រ ដើម្បីកុំឱ្យមានការរំខាន ឬផ្អើលសត្វព្រៃក្នុងតំបន់គម្រោង និងតំបន់ក្បែរខាង។ | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | នីនេះ (លម្អិតហេដ្ឋារចនាសម្ព័ន្ធគម្រោងមានចែងក្នុងជំពូក៤) អាចមានការបាត់បង់ឬថយចុះនូវសត្វព្រៃមួយចំនួនដូចជា: ខ្លាខិន ទន្សោង ខ្ទីង គែះ ពង្រូល ស្វាន ឈ្លូស ប្រើស ពពួកពស់ ជ្រូកព្រៃ ត្រីខ្យា ពពួកអណ្តើក ជាដើម ដោយសារបាត់ទីជម្រក ឬផ្តាច់ផ្លូវទំនាក់ទំនងរបស់វា។<br>*សម្គាល់: ក្នុងពេលសិក្សានិងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនេះ (ខែកុម្ភៈ ដល់ខែកញ្ញា ឆ្នាំ២០១២ និងខែកញ្ញា ឆ្នាំ២០១៥)មិនឃើញមានដានដំរី ខ្លាធំ ខ្លាលឿងមាស ខ្លាពពកទេ ប៉ុន្តែតាមការប្រឹក្សាយោបល់ជាមួយ អ្នក ស្រុកមូលដ្ឋាន ដែលគាត់រស់នៅក្នុងតំបន់នេះគាត់ធ្លាប់ជួបប្រទះពួកវាទាំងនេះ ក្នុងកំឡុងឆ្នាំ២០០០ ដល់២០០៣កន្លងមក តែឥឡូវ ដោយសារក្នុងតំបន់នេះមានមនុស្សចេញចូល និងមករស់នៅកាន់តែច្រើន ធ្វើឱ្យពួកវាមិនហ៊ានមកក្បែរតំបន់នេះ។*<br>• សកម្មភាពកាប់ឆ្ការគម្របព្រៃឈើ ការឈូសឆាយដី ការបំផ្ទុះថ្ម ការដឹកជញ្ជូនសម្ភារសាងសង់នឹងនាំឱ្យមានការភ័យខ្លាច និងបង្អាក់ការបំលាស់ទី ដល់សត្វព្រៃទាំងនោះ ជាពិសេសប្រភេទជិតផុតពូជ (តាមបញ្ជីក្រហម IUCN ពង្រូល) ប្រភេទកំពុងរងគ្រោះ (ទន្សោង ឈ្លូសយក្ស ឆ្កែព្រៃ កេរោមច្រមុះ ទោចម្តង ខ្លាត្រី) ដោយសារមានសំឡេងរំខានខ្លាំងៗ ចេញពីម៉ាស៊ីនគ្រឿងយន្តគ្រឿងផ្ទុះ សំឡេងខ្សៀវខ្សាររបស់បុគ្គលិក-កម្មករគម្រោង និងការព័ទ្ធកាប់បំផ្លាញជម្រកវា។<br>• ការជ្រើសរើសនូវបុគ្គលិកកម្មករជាមធ្យម ៤០០នាក់ចូលមក ធ្វើការនៅតំបន់នេះ សម្រាប់ការសាងសង់គម្រោងនឹងអាចមាន សកម្មភាព បរបាញ់ឬចាប់សត្វ ឬចូលព្រៃ ពីសំណាក់បុគ្គលិក-កម្មករគម្រោងទាំងនោះ ធ្វើឱ្យផ្អើលនិងបាត់បង់សត្វព្រៃទៀតផង។<br>• ការជួញដូរសត្វព្រៃនៅតំបន់គម្រោងអាចមានការកើនឡើង ដូចជា ការយកធ្វើម្ហូប ការធ្វើថ្នាំបុរាណជាដើម។ល។ ធ្វើឱ្យហិនហោច បាត់បង់សត្វព្រៃពីតំបន់ការពារទាំងនេះ។ | | | | • បង្កលក្ខណៈ ឱ្យមានការបម្លាស់ទីរបស់សត្វព្រៃដូចជា៖ ការកាប់សម្អាតព្រៃឈើបាតអាង មិនត្រូវឱ្យកម្មករកាប់ផ្តាច់ជាគន្លងព័ទ្ធជុំវិញ (ដូចជាកោះ) ដែលបង្ខាំងសត្វព្រៃនៅកណ្តាល ពេលគឺកាប់សម្អាតឈើពីមាត់ស្ទឹងឡើងទៅលើ ដើម្បីឱ្យសត្វព្រៃអាចបម្លាស់ទីចូលទៅតំបន់ភ្នំបានផងដែរ។<br>• កំណត់ពេលវេលាធ្វើការតែពេលថ្ងៃសម្រាប់ការងារទាំងឡាយណា ដែលបង្ក សំឡេង និងរំញ័រ ដើម្បីកុំឱ្យមានការរំខាន ឬផ្អើលសត្វព្រៃក្នុងតំបន់គម្រោង និងតំបន់ជិតគម្រោង។<br>• ការកំណត់កម្រិតរញ្ជួយ និងកម្លាំងបំផ្ទុះ និងប្រើប្រាស់ម៉ាស៊ីន ដែលមានសំឡេង និងរំញ័រតិចនឹងត្រូវអនុវត្តន៍ ដើម្បីកាត់បន្ថយការរំខានដល់ពពួកសត្វព្រៃ ទាំងនេះ។<br>• អប់រំ និងដាក់វិន័យដល់បុគ្គលិកកម្មករគម្រោងមិនឱ្យធ្វើការចាប់ ឬបរបាញ់ សត្វព្រៃ និងធ្វើចរាចរ លក់ដូរសត្វព្រៃនៅក្នុងតំបន់នេះឡើយ។ ព្រមទាំង ក្រុមហ៊ុន ត្រូវដាក់ស្លាកសញ្ញា ឬសរសេរជាផ្ទាំងប៉ាណូធំ ដូចនៅតាមផ្លូវទៅ កោះកុង ដែលសរសេរថា ព្រៃការពារហាមទន្រ្ទាន កាន់កាប់ធ្វើជាកម្មសិទ្ធ និងហាមបរបាញ់ ជនល្មើសត្រូវជាប់ទោសដាក់គុករហូតដល់១០ឆ្នាំ ជាអក្សរខ្មែរ និងកូរ៉េ ឬអង់គ្លេសឱ្យបានច្រើន ដើម្បីឱ្យប្រជាពលរដ្ឋ និងជនបរទេសងាយ មើលឃើញក្នុងតំបន់គម្រោង។<br>• ចូលរួមសហការជាមួយក្រសួងបរិស្ថាន រដ្ឋបាលព្រៃឈើ និងអង្គការអភិរក្សនានា ដើម្បីទប់ស្កាត់បទល្មើសសត្វព្រៃ និងព្រៃឈើ។ | |
| គ. ធនធានសេដ្ឋកិច្ចសង្គម | | | | | | |
| គ.១ ការប្រើប្រាស់ដី និងការតាំងលំនៅឡើងវិញ | • ប៉ះពាល់ការប្រើប្រាស់ដីរបស់ប្រជាពលរដ្ឋសរុបចំនួន២.៣២៩,២៥ហ.ត ដែលកាន់កាប់ដោយ៣៤៧គ្រួសារ ក្នុងនោះមានដីកសិកម្ម (ស្រែ និងចំការ) ចំនួន៩៣២,១២ហ.ត. ដីលំនៅដ្ឋាន ៣៨,៤៤ហ.ត. និងដីបុស្ស១.០៦៨,៣៩ ហ.ត។<br>• គម្រោងនេះក៏ធ្វើឱ្យប៉ះពាល់ដល់សហគមន៍តំបន់ការពារធម្មជាតិ២ គឺសហគមន៍តំបន់ការពារធម្មជាតិស្រែពាំងចំនួន៣៤១,៧៣ហ.ត និងសហគមន៍តំបន់ | | | ✓ | • ត្រៀមថវិកាចំនួន៦.៨៣៣.០១៦ដុល្លារអាមេរិក សម្រាប់សំណង និងការអភិវឌ្ឍ តំបន់ថ្មីសម្រាប់អ្នក ប៉ះពាល់ដោយសារគម្រោងនេះ ៣៤៧គ្រួសារ។ ចំពោះសំណង មាន ៣ករណី ដូចមានចែងរួចមកហើយក្នុងដំណាក់កាលរចនាគម្រោងចំណុច គ.១ ផងដែរ។<br>**សម្គាល់:** ករណីសំណង ទាំងនេះផ្អែកលើសំណូមរបស់អ្នកប៉ះពាល់ទាំងនោះ។<br>• ត្រូវសហការជាមួយរដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន និងក្រសួងរៀបចំដែនដីនគរូបណីយកម្ម និងសំណង់ ដើម្បីពិនិត្យលទ្ធភាពស្នើសុំរាជរដ្ឋាភិបាល លើផ្ទៃដី និងទីតាំងដែល | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | ការពារធម្មជាតិស្ទឹងថ្មី ចំនួន ៩,៨៩ហ.ត។ | | | | ត្រូវផ្តល់ជូនគ្រួសារដែលទទួលផលប៉ះពាល់ដោយសារគម្រោងនេះ។<br>• ត្រូវធ្វើផែនការបំលាស់ប្តូរលំនៅដ្ឋាន របស់ប្រជាពលរដ្ឋក្នុងតំបន់១ (តំបន់អាងទឹក) និងបង្កើតតំបន់តាំងលំនៅឋានថ្មី ឱ្យបានមុនយ៉ាងតិច១ឆ្នាំ មុននឹងធ្វើការបិទ ទ្វារទឹកបំពេញអាងនេះ។ ***សម្គាល់:*** *ក្រុមការងារ SAWAC បានសិក្សា តំបន់ ៤ ដែលជាដីស្ថិតក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍(ប្រមោយ) មានផ្ទៃដីចំនួន ១៧៦,៨៩ ហ.ត និងដែនជម្រកសត្វព្រៃភ្នំសំកុស ចំនួន ១៣,៥៦ ហ.ត ហើយមានបំរុងទុក ៥០ហ.ត ទៀត តែមិនទាន់ដាក់បញ្ចូលក្នុងផ្ទៃដីគម្រោងទេ (មើលផែនទី១) ហើយស្ថិតនៅក្បែរតំបន់គម្រោង មានលក្ខណៈសមស្របសម្រាប់ធ្វើការតាំងលំនៅឋានថ្មី និងជាដីកសិកម្មសម្រាប់អ្នកប៉ះពាល់ដោយសារ គម្រោងទាំងនោះ។ ទីទីតាំងតំបន់តាំងលំនៅឋានថ្មីនេះក៏មានការ យល់ព្រមពីអ្នកប៉ះពាល់ដែលបានជួបសម្ភាស ៣១៥ គ្រួសារ (៩៦%) នៃ ៣៤៧គ្រួសារប៉ះពាល់។*<br>• ចំពោះដីសហគមន៍នៃតំបន់ការពារទាំងនោះ គឺសហគមន៍តំបន់ការពារធម្មជាតិ ស្រែពាំងមានសំណង១១០២,៥១៩ ដុល្លារអាមេរិក និងសហគមន៍តំបន់ការពារ ធម្មជាតិស្ទឹងថ្មីមានសំណង២.៩៦៧ដុល្លារអាមេរិក។ សំណងទាំងនេះជួយ ឱ្យសហគមន៍ធ្វើការដាំឈើ និងធ្វើប៉ុស្តិ៍ការពារនៃតំបន់ព្រៃទាំងនេះដែលនៅសល់។<br>• នៅពេលចាប់ផ្តើមការសាងសង់គម្រោង ម្ចាស់គម្រោងត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការផ្សព្វផ្សាយ ពីការដាំដំណាំ ដែលមានអាយុកាលវែង ដូចជាក្រូច ស្វាយ ធូរេន ។ល។ មិនឱ្យដាំបន្ថែម។ ក៏ប៉ុន្តែ ដំណាំមានអាយុកាលខ្លី (ដំណាំរៀលហូច)ដូចជាពោត សណ្តែក ល្ង ស្រូវ អាចដាំបាន ហើយត្រូវជូនដំណឹង ច្បាស់លាស់ នៃកាលបរិច្ឆេទ នៃការបិទទឹកតម្កល់ក្នុងអាងផងដែរ។ | |
| គ.២ ការរស់នៅ និង មុខរបររបស់សហគមន៍ មូលដ្ឋាន | • មានប្រជាជនចំនួន ៣៤៧គ្រួសារ នឹងរងការប៉ះពាល់ដោយសារការ អភិវឌ្ឍន៍គម្រោងវារីអគ្គិសនីនេះ ក្នុងនោះមានប្រជាជន ៩៦គ្រួសារ នឹងត្រូវបាត់បង់ចំណូល ដោយសារពួកគេបាត់បង់ដីកសិកម្មចាប់ពី ៥០% ឡើងទៅ។<br>• ការអភិវឌ្ឍគម្រោងនៅតំបន់ខាងលើក្នុងស្ទឹងពោធិ៍សាត់ នឹងមាន មនុស្សចេញចូលរាប់ពាន់នាក់(បុគ្គលិក-កម្មករ គម្រោង ជាមធ្យម ៤០០នាក់ រួមទាំងគ្រួសារនៃជនទាំងនោះទេ) ដែលនឹង អាចមាន ការការនេសាទក្នុងស្ទឹង និងក្នុងអូរក្នុង និងជុំវិញតំបន់ គម្រោង ជាពិសេសនៅរដូវវស្សារបស់ជនចំណូលថ្មីទាំងនោះនឹងធ្វើ ឱ្យ ថយចុះទិន្នផលនេសាទរបស់អ្នកភូមិក្នុង និងក្បែរតំបន់នេះ។<br>• ដូចគ្នាដែរចំពោះអនុផលព្រៃឈើ (ផ្សិត ឬស្សី ផ្តៅ) ក៏អាចមានការកើនឡើងពីអ្នកចំណូលថ្មីទាំងនេះ ជាពិសេសការកាប់ឈើក្រៅតំបន់ នាំឱ្យប៉ះពាល់ដល់ចំណូលអនុផលព្រៃឈើរបស់អ្នកស្រុកមូលដ្ឋាននិងព្រៃឈើ សត្វព្រៃផងដែរ។ | | | ✓ | • សហការជាមួយអាជ្ញាធរភូមិ ឃុំ ពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយពីផែនការអភិវឌ្ឍ នេះជូនប្រជាពលរដ្ឋក្នុងភូមិទាំង នេះឱ្យបានដឹង និងណែនាំប្រជាពលរដ្ឋ អំពី ការពារគ្រោះថ្នាក់នានាដែលអាចកើតឡើងជាយថាហេតុ។<br>• សហការជាមួយអាជ្ញាធរភូមិ ឃុំ ពាក់ព័ន្ធ មន្ទីរបរិស្ថាន មន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទ អង្គការអភិរក្សពាក់ព័ន្ធនានា ក្នុងការចុះបញ្ជីស្នាក់នៅជាបណ្តោះអាសន្ន ចេញប័ណ្ណសម្គាល់បុគ្គលិកកម្មករ ប័ណ្ណសម្គាល់យានយន្ត ដើម្បីងាយស្រួលដល់ក្រុមល្បាតទប់ស្កាត់អ្នកប្រព្រឹត្តបទល្មើសព្រៃឈើ សត្វព្រៃ និងជលផល។<br>• ត្រូវធ្វើផែនការបំលាស់ប្តូរលំនៅដ្ឋានរបស់ប្រជាពលរដ្ឋក្នុងតំបន់១ (តំបន់អាងទឹក) និងបង្កើតតំបន់តាំងលំនៅឋានថ្មី ឱ្យបានមុនយ៉ាងតិច១ឆ្នាំ មុននឹងធ្វើការ បិទទ្វារទឹកបំពេញអាងនេះ។ ចំពោះប្រជាជន៩៦គ្រួសារដែលបាត់បង់ចំណូលនោះ ក្រុមហ៊ុនផ្តល់ថវិកា ចំនួន៤១៥ដុល្លារអាមេរិក/គ្រួសារ ដើម្បីបង្កើតកម្មវិធី ស្តារចំណូលគ្រួសារ ដូចជាទិញពូជដំណាំ និងមធ្យោបាយជាក់ស្តែង ដើម្បីជំនួយឱ្យពួកគាត់ស្តារចំណូលឡើងវិញ | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | • ប្រជាពលរដ្ឋ អាចមានការប៉ះពាល់ដល់មុខរបរចិញ្ចឹមជីវិតប្រចាំ ថ្ងៃរបស់ពួកគាត់ផងដែរ ព្រោះពួកគាត់ មកធ្វើ កម្មករឱ្យក្រុមហ៊ុន ក្មេរ តែមិនបានទទួលប្រាក់ពលកម្មគ្រប់ចំនួន បើកប្រាក់ឈ្នួលមិន ទៀងទាត់ និងមិនបើកប្រាក់ឈ្នួល ឱ្យគ្រប់ចំនួនថ្ងៃ ដែលពួកគាត់ បានធ្វើការ។ អាចមានការរើសអើងពូជសាសន៍ពីព្រោះគម្រោងនេះ មានមេការជាជនជាតិបរទេស ហើយគ្មានអ្នកបកប្រែច្បាស់លាស់ ដែលធ្វើឱ្យស្តាប់គ្នាមិនបានបង្កជាទំនាស់ រវាងកម្មករជនបរទេស និងខ្មែរ អាចក្លាយជាបទ ល្មើសព្រហ្មទណ្ឌទៀតផង។<br>• ប្រជាពលរដ្ឋអាចនឹងរងការប៉ះពាល់ដល់មុខរបរ និងខាតពេលវេលា រកទទួលទានផងដែរ ដោយសារក្រុមហ៊ុនមិនបានផ្តល់សម្ភារ ការពារគ្រោះថ្នាក់ ដូចជាៈ មួកការពារ ស្បែកជើង ស្រោមដៃ ខោអាវជាដើម។ល។ ដែលមិនអាចការពារពួកគេបាននៅពេល ដែលមានគ្រោះថ្នាក់ការងារដោយចៃដន្យណាមួយនោះ។<br>• ការបំផ្ទុះថ្ម សម្រាប់បម្រើការនានា អាចប៉ះពាល់ផ្លូវចេញ ចូលរបស់ ប្រជាពលរដ្ឋក្នុងតំបន់ ដោយសារថ្ម ឬដីធ្លាក់រលំលើកំណាត់ផ្លូវ ហើយការងារនេះក៏អាចប៉ះពាល់ដល់អាយុជីវិតមនុស្សផងដែរ។ | | | | ក្នុងរយៈពេលអន្តរកាល១ឆ្នាំ ពេលដែលគាត់រើទៅនៅកន្លែងតាំងទីលំថ្មីនោះ (ការគ្រោងតម្លៃលម្អិតមើលក្នុងតារាង ៩-៣ )។<br>• ផ្តល់ឱ្យអាទិភាពដល់ប្រជាពលរដ្ឋមូលដ្ឋានជាពិសេសអ្នកដែលប៉ះពាល់ដោយសារគម្រោងក្នុងការជ្រើសយក កម្លាំងពលកម្មដើម្បីធ្វើជាបុគ្គលិក/ កម្មករគម្រោង។<br>• ត្រូវគោរពច្បាប់ការងាររបស់ព្រះរាជាណាចក្រកម្ពុជា ដោយជួលកម្មករធ្វើការ១ថ្ងៃ ៨ ម៉ោង ឬ៤៨ ម៉ោងក្នុងមួយ សប្តាហ៍ (មាត្រា១៣៧ នៃច្បាប់ការងារ)។ បើមានការធ្វើការថ្ងៃសំរាក ឬថ្ងៃបុណ្យ ក្រុមហ៊ុននឹងមានប្រាក់បន្ថែមជូន កម្មករ (មាត្រា១៣៩ នៃច្បាប់ការងារ)។<br>• បើកប្រាក់ឈ្នួលដោយផ្ទាល់ជូនកម្មករ ជារៀងរាល់ពីរសប្តាហ៍ម្តង។<br>• សម្រួលចរាចរ និងជូនព័ត៌មានជាមុននៃការបំផ្ទុះ និងអនុញ្ញាតឱ្យប្រជាជន ចេញចូលតំបន់គម្រោងជាធម្មតា។<br>• ដើម្បីការពារសុវត្ថិភាពកម្មករ ក្រុមហ៊ុនចែកជូនពួកគាត់នូវ មួកការពារ ស្បែកជើង ស្រោមដៃ ខោអាវជាដើម ព្រមទាំង ត្រួតពិនិត្យមើលពីប្រធាន ក្រុមក្រែងលោមានកម្មកររូបណាមិនប្រើ។ ក្រុមហ៊ុននឹងមានអ្នកបកប្រែ ភាសាគ្រប់គ្រាន់នៅការដ្ឋាន ដើម្បីឱ្យការងារមានភាពងាយស្រួលរវាង កម្មករខ្មែរ និងអ្នកគ្រប់គ្រងជនជាតិជនបរទេស។<br>• នឹងធ្វើការសហការយ៉ាងជិតស្និតជាមួយអាជ្ញាធរមូលដ្ឋានដើម្បីដោះស្រាយ ដោយសន្តិវិធីរាល់នូវរាល់ទំនាស់ដែលអាចកើតឡើងជាមួយកម្មករ ជនបរទេស និងខ្មែរ។ | |
| គ.៣ ប្រពៃណី វប្បធម៌ និង សាសនា | • អាចមានការប៉ះពាល់ដល់ជំនឿប្រពៃណីរបស់ប្រជាពលរដ្ឋនៅក្បែរតំបន់គម្រោង ដោយសារក្រុមហ៊ុនយកបុគ្គលិក-កម្មកររបស់ខ្លួនរហូតដល់៤០០នាក់ ដែលមកពីតំបន់ឆ្ងាយខុសៗគ្នា និងមានសញ្ជាតិខុសៗគ្នា។<br>• នៅក្នុងតំបន់គម្រោងមានជនជាតិដើមភាគតិចព័រ១០គ្រួសារ ដែលអាចប៉ះពាល់ដល់ ទំនៀមទំលាប់របស់គាត់ផងដែរ។ ***សម្គាល់៖*** *យោងតាមការសម្ភាសផ្ទាល់ជាមួយតំណាងមេគ្រួសាររបស់ជនជាតិភាគតិចទាំង១០គ្រួសារ បានឱ្យដឹងថា ពួកគាត់មានជំនឿសាសនា ទំនៀមទំលាប់ ដូចជណជាតិខ្មែរក្នុងតំបន់ផងដែរ។* | | ✓ | | • សិក្សាស្វែងយល់អំពីទំនៀមទំលាប់ប្រពៃណី និងជំនឿសាសនារបស់ប្រជារដ្ឋពលជាពិសេសជនជាតិដើមភាគតិចព័រ ដែលរស់ក្នុង និងក្បែរតំបន់គម្រោង ហើយផ្សព្វផ្សាយ និងគោរពទៅតាមប្រពៃណីទំនៀមទំលាប់នេះដោយមិនធ្វើការបំពាននិងល្មើសឡើយ។<br>• ធ្វើការអប់រំ ណែនាំដល់បុគ្គលិក-កម្មកររបស់ខ្លួនអំពីទំនៀមទំលាប់ ប្រពៃណីប្រជាពលរដ្ឋ ដែលរស់នៅក្បែរតំបន់គម្រោង ជាពិសេស គឺជនជាតិដើមភាគតិចព័រ។<br>• បន្ថែមពីលើនេះទៀត ក្រុមហ៊ុនអប់រំណែនាំដល់បុគ្គលិក-កម្មកររបស់ខ្លួនដែល ជាជនជាតិខ្មែរ និងបរទេសមិនឱ្យងូតទឹកស្រាត នៅតាមដងអូរ ឬស្ទឹងឡើយ និងដាក់ពិន័យបើសិនមិនគោរព។ | |
| គ.៤ ការប្រើប្រាស់ទឹក | • មានការប៉ះពាល់ដល់ការប្រើប្រាស់ទឹកស្ទឹង ដោយសារសកម្មភាព សាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គម្រោង និងគ្រប់គ្រងសំណល់ រឹង-រាវមិនបានល្អធ្វើឱ្យបំពុលដល់ប្រភពទឹកលើដី និងក្រោមដី ដែលជាប្រភពដ៏សំខាន់ក្នុងការប្រើប្រាស់ទឹកកម្មករក្នុងតំបន់។<br>• បរិមាណជាទឹករបស់ស្ទឹងពោធិ៍សាត់អាចនឹងប៉ះពាល់ដោយសារការទប់ទំនប់ | | | ✓ | • ការឈូសឆាយទ្រង់ទ្រាយធំក្រុមហ៊ុនមិនធ្វើនៅរដូវវស្សាទេ។<br>• ធ្វើរបាំងការពារកករដីកុំឱ្យសាយភាយចេញឆ្ងាយពីទីតាំងសាងសង់ ហើយសាងសង់បង្គន់អនាម័យ និងបន្ទប់ទឹកឱ្យបានគ្រប់គ្រាន់ ទៅតាមចំនួនបុគ្គលិក-កម្មករគម្រោង (ក្នុងរយៈពេលសាងសង់អាចមានបុគ្គលិក-កម្មករអតិ បរមាឡើងដល់ ៤០០នាក់)។<br>• ធ្វើការអប់រំណែនាំបុគ្គលិក-កម្មករគម្រោង ឱ្យយល់ដឹងអំពីអនាម័យស្គាល់នូវកន្លែង | |

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | កាត់ស្ទឹងពោធិ៍សាត់ ដើម្បីធ្វើរាំងតម្លល់ទឹក ដែលជាហេតុបង្កឱ្យមានការប្រែប្រួលប្រព័ន្ធអេកូឡូស៊ី និងប្រព័ន្ធលំហូរទឹក ផ្សេងទៀតដែលបែកចេញពីស្ទឹងនៅក្រោមទំនប់ ជាពិសេសអាចប៉ះ ពាល់ដល់ប្រព័ន្ធធារាសាស្ត្រដំណាក់លើក្រាំ ដំណាក់អំពិល និងចារឹកដោយខ្វះទឹក ខណៈដែលទប់ស្ទឹងនេះ ដើម្បីសាងសង់ទំនប់មេ។ គុណភាពទឹកក៏ អាចនឹងប៉ះពាល់ផងដែរ ដោយសារសកម្មភាពសាងសង់ ដែលធ្វើឱ្យទឹកស្ទឹងមានការបំពុលជាហេតុបង្កឱ្យកម្មករ និងប្រជាពលរដ្ឋ ដែលមករកអនុផលព្រៃឈើមិនអាចប្រើទឹកនេះបាន។<br>• សំណល់រឹង-រាវចេញពីកន្លែងរស់នៅផ្ទះបាយ និងបង្គន់អនាម័យរបស់បុគ្គលិក-កម្មករនៃគម្រោង ការលេចធ្លាយប្រេង ឥន្ធនៈ និងប្រេងរំអិលពីឧបករណ៍ ឬគ្រឿងយន្តនានាក្នុងការដ្ឋាន សាងសង់អាចបង្កឱ្យទឹកស្ទឹងពោធិ៍សាត់បាត់បង់គុណភាពដែរ។ ការសំអាតខ្លួនប្រាណរបស់បុគ្គលិក-កម្មកររាប់រយនាក់នៅក្នុង ឬ ក្បែរស្ទឹង នឹងធ្វើឱ្យគុណភាពទឹកស្ទឹងពោធិ៍សាត់មានការថយចុះ និងឈានទៅដល់ការបំពុលទឹក។ | | | | ទុកដាក់សម្រាម (ដោយសសេរជា អក្សរខ្មែរ និងគូរ៉េ ឬអង់គ្លេស) ដែលក្រុមហ៊ុនបានរៀបចំកសាងក្នុងទីតាំងស្នាក់នៅ ហើយដាក់ពិន័យដល់ បុគ្គលិក-កម្មករណា ដែលមិនព្រមធ្វើតាមការណែនាំ។<br>• ត្រូវចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ក្នុងការគ្រប់គ្រងសំណល់រឹង-រាវ ដោយសាងសង់បង្គន់អនាម័យ ព្រមទាំងរៀបចំប្រមូលសំណល់រឹង និងសម្រាមយកទៅចោលនៅទីតាំងដែលមានសុវត្ថិភាព គឺកន្លែងចាក់សម្រាម ដែលបានកំណត់។<br>• សាងសង់កន្លែងប្រព្រឹត្តិកម្ម ដូចជារាងសិបទិក ដើម្បីសំអាតទឹកកខ្វក់ពី ការិយាល័យ ផ្ទះ បុគ្គលិក ដែលស្នាក់នៅពេលដំណើរការ និងថែទាំគម្រោង ហើយទឹកដែលបង្ហូរចេញពីរាងសំអាតនេះ នឹងមានកម្រិតតាមស្តង់ដានៃ ការបញ្ចេញចោលពីប្រភពបំពុលចូលទៅប្រភពទឹកសាធារណៈ ដែលមានចែងក្នុងអនុក្រឹត្យលេខ២៧ អនក្រ.បករបស់រាជរដ្ឋាភិបាល។<br>• សាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈបានត្រឹមត្រូវតាមបទដ្ឋានសុវត្ថិភាព ដល់បរិស្ថាន និងសង្គម។<br>• ប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និងរថយន្តដឹកជញ្ជូន ដែលមានគុណភាពល្អ មិនលេចហូរជាតិប្រេង ឬខ្លាញ់មក លើដី និងប្រភពទឹកក្នុងតំបន់គម្រោង។<br>• ត្រូវពង្រាបដី និងដាំព្រៃឈើឡើងវិញ និងដាំស្មៅតាមកន្លែង ចាក់ចោលដី ស្អុយ ឬសំណល់ថ្ម កន្លែងយកដី និងថ្ម ដើម្បីការពារការហូរ ច្រោះដែលអាចធ្វើឱ្យមានការបំពុលទឹក។<br>• ចោះជារូងទុនេល ដើម្បីធ្វើការរំដោះទឹកមកតំបន់ខាងក្រោមគម្រោង មិនឱ្យមានការប៉ះពាល់ដល់លំហូរធារា ទឹកស្ទឹងនេះទេក្នុងពេលសាងសង់ គម្រោងនេះ (មើលគំនូរបច្ចេកទេស DWG 03) ពោលគឺ ក្នុងដំណាក់កាលសាងសង់នេះទឹកស្ទឹងពោធិ៍សាត់មិនបានបង្ខាំងទុកឡើយ ហើយធារទឹកស្ទឹងនៅហូរជាធម្មតា។ | |
| គ.៥ តំបន់ទេសចរណ៍/រមណីយដ្ឋាន/ទីកន្លែង កំសាន្ត | • ប៉ះពាល់ដល់តំបន់អន្លង់ក្រពើលោកយាយស្តើងខ្លះៗដែរដែលជាតំបន់ទេសចរណ៍ធម្មជាតិ ដោយសារសកម្មភាពសាងសង់ទំនប់វារីអគ្គិសនីនេះធ្វើឱ្យរាំងស្ទះចរាចរណ៍តាមផ្លូវលេខ៥៥ ដែលរំខានភ្ញៀវទេសចរណ៍ជាដើម។ល។<br>• សំណល់រឹង-រាវ ចេញពីកន្លែងរស់នៅផ្ទះបាយរបស់បុគ្គលិក-កម្មករគម្រោងជាកត្តាសំខាន់ក្នុងការធ្វើឱ្យប៉ះពាល់វិស័យទេសចរណ៍ នេះដែរ។ | | ✓ | | • វិធានការកាត់បន្ថយផលប៉ះពាល់ផ្នែកនេះ គឺធ្វើដូចក្នុងវិធានការបន្ធូរបន្ថយ ក្នុងចំណុច គ.៤ ខាងលើផងដែរ។<br>**សម្គាល់:** *ការធ្វើផ្លូវចូលតំបន់គម្រោង ជាផ្នែកមួយយ៉ាងសំខាន់ សម្រាប់បម្រើឱ្យវិស័យអេកូ-ទេសចរណ៍ និងទេសចរណ៍-បរិស្ថាន ដោយគេអាចភ្ជាប់ពីតំបន់មាត់សមុទ្រ ដែនជម្រកសត្វ ព្រៃពាមក្រសោប ឆ្លងកាត់តំបន់ព្រៃការពារភ្នំក្រវាញភាគខាងត្បូង ភ្នំក្រវាញភាគកណ្តាល ទៅដែនជម្រកសត្វព្រៃភ្នំសំកុស ដល់បឹងទន្លេសាបបាន យ៉ាងប្រសើរ។*<br>• ត្រូវដាក់បញ្ចូលក្នុងសៀវភៅបន្ទុក ដែលជាឯកសារធ្វើកិច្ចសន្យាម៉ៅការបន្ត ទៅឱ្យក្រុមហ៊ុនផ្សេងៗ ត្រូវសំអាតទីតាំងការដ្ឋាន និងកន្លែងជំរុំស្នាក់នៅរបស់ បុគ្គលិក-កម្មករឱ្យបានស្អាតដោយមានបង្អុកប្រាក់ទុករង់ចាំក្រុមការងារ អនុគណកម្មការខេត្តចុះ ពិនិត្យ | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | | | | | រួចបានបញ្ជាក់ថា ទីតាំងទាំងនោះស្អាតសម្បេ អាចទទួលយកបានហើយទើបបើកប្រាក់ដែលបង្កកនោះឱ្យ។ | |
| គ.៦ ផ្លូវគមនាគមន៍ | • អាចប៉ះពាល់ដល់ផ្លូវជាតិលេខ៥៥ មានស្ពាន និងលូជាច្រើន ដែលចេញពីក្រុងពោធិ៍សាត់ ទៅប្រហោយទីរួមស្រុកវាលវែង ដែលឆ្នាំ២០១៧ គម្រោងស្តារផ្លូវជាតិលេខ ៥៥នេះបានសាងសង់ផ្លូវចាក់កៅស៊ូ និងមានស្ពានបេតុង ហេតុដូចនេះ ដោយសារសកម្មភាពសាងសង់គម្រោង និងការដឹកជញ្ជូន សម្ភារបរិក្ខារ គ្រឿងចក្រចូលទៅទីតាំងគម្រោងអាចបង្កឱ្យមានការស្រុត ឬខូចផ្លូវ ឬការបាក់ស្ពាន ឬបាក់លូ ឬគ្រោះថ្នាក់ចរាចរលើ ទ្រូងផ្លូវ ដែលមានចំណោទឡើងទួល និងផ្លូវកោងចាដើម។ ល។<br>• អាចប៉ះពាល់ដល់ការធ្វើដំណើរ និងដឹកជញ្ជូនប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ លើផ្លូវនេះ ដោយសារក្រុមហ៊ុន ប្រើរថយន្តធំៗក្នុងការដឹកជញ្ជូនសម្ភារសំណង់បរិក្ខារ និងគ្រឿងចក្រ ពីភ្នំពេញទៅតំបន់គម្រោងវារីអគ្គិសនីស្ទឹងនេះ ដោយជាប់ផុង ស្ទះផ្លូវ ធ្វើឱ្យស្ទះចរាចរ ក្នុងតំបន់ទៀតផង។ | | ✓ | | • ក្រុមហ៊ុន និងអ្នកម៉ៅការគោរពតាមច្បាប់ស្តីពីចរាចរផ្លូវគោក (ឆ្នាំ ២០១៥) និងច្បាប់ស្តីពីផ្លូវថ្នល់ (ឆ្នាំ២០១៤) ដោយការដឹកជញ្ជូនសម្ភារបរិក្ខារ គ្រឿងចក្រចូលទៅទីតាំងគម្រោងមិនឱ្យលើសទំងន់ ដែលក្រសួងសាធារណៈការ និងដឹកជញ្ជូនបានកំណត់។<br>• ប្រើរថយន្តដឹកជញ្ជូនដែលមានទំហំមធ្យមដែលមិនមានការទើសទែង និងដឹកលើសទំងន់នៃសម្ភារសំណង់បរិក្ខារ ដែលធ្វើឱ្យខូចផ្លូវ និងស្ទះចរាចរលើផ្លូវ ជាតិលេខ ៥៥ នេះ។ ប្រសិនបើមានការខូច ថ្នល់ ស្ពាន លូ ដែលធ្វើបុគ្គលិក-កម្មករ រួមទាំងអ្នកម៉ៅការរបស់គម្រោងនេះ ម្ចាស់គម្រោងត្រូវទទួលខុសត្រូវជួលជុលឡើងវិញ។<br>• ត្រូវធ្វើការសហកាណ៍ជាមួយអាជ្ញាធរមូលដាន និងមន្ទីរសាធារណៈការខេត្ត ដើម្បីទប់ស្កាត់ការដឹកទំនិញលើទំងន់ និងរថយន្តធំៗ ដែលច្រើកងកាច់ចង្កូត លើពី១ផ្លូវ។<br>• ត្រូវដាំឈើធ្វើជារបងធម្មជាតិតាមសងផ្លូវចេញចូល និងលើដីជម្រាល ដើម្បីទប់ស្កាត់ការហូរច្រោះ ការហុយធូលី សំឡេង និងធ្វើឱ្យមានសោភ័ណ្ឌភាព ទេសភាពល្អ។ | |
| គ.៧ សុខភាពសាធារណៈ | • អាចបង្កឱ្យមានការប៉ះពាល់ដល់សុខុមាលភាព បុគ្គលិក-កម្មកររបស់ ក្រុមហ៊ុន ដោយសារធូលីដី ធូលីស៊ីម៉ង់ត៍ ចំហាយចេញពីការប្រើប្រាស់សារធាតុគីមីជាដើម។<br>• អាចបង្កឱ្យមានផលប៉ះពាល់ដល់សុខភាព បុគ្គលិក-កម្មកររបស់គម្រោង ដោយសារតំបន់នេះជាតំបន់ដែលកើតជំងឺគ្រុនចាញ់។ ប្រជាពលរដ្ឋនៅក្បែរតំបន់គម្រោងអាចឆ្លងជំងឺអេដស៍ ជំងឺកាមរោគ ជំងឺរបេង ជំងឺឆ្លងផ្សេងៗពីបុគ្គលិក-កម្មករគម្រោង ដែលរើសមកពីឆ្ងាយដោយក្រុមហ៊ុនផងដែរ។<br>• អាចប៉ះពាល់ដល់សុខភាពសាធារណៈ (ប្រជាជនក្បែរតំបន់និងបុគ្គលិក-កម្មករគម្រោង) ដោយសារអាចមានការប្រើប្រាស់ ឬចរាចរ គ្រឿងញៀន។<br>• អាចប៉ះពាល់ប្រជាពលរដ្ឋ និងបុគ្គលិក-កម្មករគម្រោង ដោយសារមិនចាប់អារម្មណ៍អំពីសុវត្ថិភាពការងារ។<br>• ក្នុងតំបន់គម្រោងគ្មានប្រព័ន្ធទឹកស្អាតសម្រាប់បរិភោគទេដោយសារខ្វះទីផ្សារ។ | | | ✓ | • ប្រកាន់យកការរក្សាសុវត្ថិភាពការងារជាចំបង ក្នុងសកម្មភាពការងារប្រចាំថ្ងៃ។<br>• ផ្តល់ម៉ាស់ការពារធូលីដី មួកការពារ ស្បែកជើង ស្រោមដៃដល់បុគ្គលិក កម្មករគម្រោង និងធ្វើការស្រោចទឹកលើផ្លូវថ្នល់ដែលខ្លួនប្រើប្រាស់ក្នុងការសាងសង់គម្រោងនេះជាប្រចាំ។<br>• សាងសង់ជំរំស្នាក់នៅរបស់បុគលិក-កម្មករគម្រោងបានសមរម្យ ដោយមានការផ្គត់ផ្គង់ទឹកស្អាតមានបង្គន់ អនាម័យ បន្ទប់ទឹកគ្រប់គ្រាន់ និងមានកម្មវិធីអប់រំសុវត្ថិភាពការងារដល់បុគ្គលិក-កម្មកររបស់គម្រោង។<br>• មានគ្រូពេទ្យដែលមានសមត្ថភាពនៅប្រចាំការក្នុងការដ្ឋាន និងជំរុំស្នាក់នៅរបស់កម្មករ និងត្រៀមថ្នាំពេទ្យ និងបរិក្ខារគ្រប់គ្រាន់ជាប្រចាំសម្រាប់ការពិនិត្យ និងព្យាបាលជូនបុគ្គលិក-កម្មកររបស់គម្រោង ហើយមានរថយន្តសង្គ្រោះ បន្ទាន់នៅពេលដែលមានករណីគ្រោះថ្នាក់កើតឡើងជាយថាហេតុ។<br>• ត្រូវធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិក/កម្មកររបស់ខ្លួនក្នុងការទប់ស្កាត់ ជំងឺទាំងនោះកុំឱ្យឆ្លងទៅប្រជាពលរដ្ឋក្នុងតំបន់នោះ។<br>• អនុវត្ត ផែនការគ្រប់គ្រងសំណល់គ្រប់ប្រភេទ, ផែនការគ្រប់គ្រងសុវត្ថិភាព និងហានិភ័យ, និងផែនការរៀបចំស្នាក់នៅ សុខភាព និងអនាម័យរបស់បុគ្គលិក-កម្មករគម្រោងឱ្យមានខ្ជាប់ខ្ជួនត្រឹមត្រូវ ដូចមានចែងក្នុងជំពូក៤ ចំណុច ៤.៦.១២, ៤.៦.១៣, និង ៤.៦.១៤។<br>• ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ពិសេសទប់ស្កាត់ការជួញដូរ | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | | | | | ចរាចរគ្រឿងយាន្ត និងមនុស្ស។ ត្រូវសហការជាមួយ ស្ថាប័នសុខាភិបាលនៅក្នុងតំបន់នេះ ដើម្បីការពារទប់ស្កាត់ជំងឺឆ្លងផ្សេងៗ ដែលកើតមានឡើងជាយថាហេតុ។ | |
| គ.៨ សោភ័ណ្ឌភាព/ទេសភាព | • អាចនឹងមានការប៉ះពាល់ដល់សោភ័ណ្ឌភាពទេសភាពក្នុងតំបន់ដោយសារការកាប់ព្រៃឈើអស់ ឬការឈូសឆាយដីស្ទុយឬសំណល់ថ្ម ទុក ជាគំនរតាមដងផ្លូវ ការបោះចោលការសំណល់រឹង-រាវ មិនត្រឹមត្រូវ ពាសវាលពាសកាល តាមជំរុំ បណ្តោះអាសន្ន កន្លែងសង់ផ្លូវ ស្ពាន និងហេដ្ឋារចនាសម្ព័ន្ធទំនប់វារីអគ្គិសនីជាដើម។ល។<br>• ការហុយធូលី ដោយសារការឈូសឆាយ ការបំផ្ទុះថ្ម ការដុតព្រៃ សម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធជាដើម ក៏អាចធ្វើឱ្យប៉ះពាល់ ដល់សោភ័ណ្ឌភាព និងទេសភាពកន្លែងនោះដែរ។<br>• ការសាងសង់កន្លែងស្នាក់នៅរបស់កម្មករគ្មានរបៀប ដោយឃើញមាននៅគ្រប់ទីកន្លែងក៏ប៉ះពាល់ដល់សោភ័ណ្ឌភាពក្នុងតំបន់ដែរ។<br>• មិនមានការគ្រប់គ្រងសំណល់រឹង-រាវ សម្ភារ គ្រឿងបរិក្ខារ និងឧបករណ៍ផ្សេងបានល្អនៅក្នុង និងក្បែរតំបន់គម្រោង។ | | | ✓ | • មិនធ្វើការសំអាតព្រៃនៅតំបន់២នេះចំនួន ៥៥៩,៩១ហ.ត ទាំងស្រុងនោះទេ ពោលគឺសំអាតនៅកន្លែងដែលសាងសង់សំណង់ជាក់ស្តែងប៉ុណ្ណោះ (ចំពោះកន្លែងដែលនឹងត្រូវសាងសង់ទាំងនេះ នឹងធ្វើលម្អិតនៅក្នុងដំណាក់កាល គ្រោងលម្អិតរបស់គម្រោង)។ ទំហំគម្របព្រៃឈើដែលត្រូវសំអាតនៅតំបន់នេះគឺ ៤៣១,១៧ហ.ត។<br>• ធ្វើការពង្រាបគំនរដីស្ទុយតាមដងផ្លូវឱ្យបានស្មើល្អ មានការគ្រប់គ្រងសំណល់រឹងរាវឱ្យបានល្អដោយពេលបញ្ចប់ការដ្ឋានតាមហេដ្ឋារចនាសម្ព័ន្ធ នីមួយៗត្រូវធ្វើការប្រមូលសំណល់រឹង ដូចជាស្បោងប្លាស្ទិក សំបកដប គ្រប់ប្រភេទ សំបកកំប៉ុង កម្ទេចបេតុង និងគ្រឿងប្លាស្ទិក គ្រប់ប្រភេទយកទៅកប់ឱ្យបានសមរម្យបានល្អ។ លូនៃបង្គន់ត្រូវលប់ឱ្យបានល្អផងដែរ។<br>• ត្រូវធ្វើការស្រោចទឹកជាប្រចាំទៅលើផ្លូវថ្នល់ដែលខ្លួនកំពុង ប្រើប្រាស់សាងសង់គម្រោង។ ប្រើប្រាស់សារធាតុផ្ទុះដែលមានភាពរញ្ជួយ រញ្ជួយ និងកំលាំងខ្ទាតថ្មតិច។<br>• ដើម្បីរក្សាសណ្តាប់ធ្នាប់ និងការរស់នៅស្អាត ក្រុមហ៊ុនសាងសង់ផ្ទះសម្រាប់ កម្មករ-បុគ្គលិកដោយមានរបៀបរៀបរយនៅតាមទីកន្លែង សមស្របព្រមទាំងមានបង្គន់ អនាម័យគ្រប់គ្រាន់ សាងសងអាងសិបទិក ដើម្បីសំអាតទឹកកខ្វក់ មានកន្លែងទុកដាក់សំណល់ រឹងត្រឹមត្រូវដោយមានអ្នកទទួលខុសត្រូវច្បាស់លាស់។<br>• រីឯសម្ភារ គ្រឿងបរិក្ខារ និងឧបករណ៍សាងសង់វិញក្រុមហ៊ុនមានកន្លែង និងឃ្លាំងរក្សាទុកត្រឹមត្រូវ។ | |
| គ.៩ ហានិភ័យ | • អាចនឹងមានហានិភ័យ ដោយសារគ្រោះធម្មជាតិការកើតមានការរញ្ជួយដី (ដោយអំងន់អាង) នៅក្នុងតំបន់គម្រោងការទទួលរង ឥទ្ធិពលពីព្យុះទីហ្វុង ឬ ព្យុះផ្សេងទៀត ពីឈូងសមុទ្រថៃឬខ្យល់កន្ត្រាក់ ដែលជាហេតុបង្កឱ្យមានមហន្តរាយធំៗ ដូចជា ការបាក់ទំនប់ និងហេដ្ឋារចនាសម្ព័ន្ធ សំខាន់ៗរបស់គម្រោងដែលកំពុងសាងសង់ ការបាត់បង់ ឬខូចខាត សម្ភារ និងគ្រឿងចក្រសាងសង់ ជាពិសេសការធ្វើឱ្យរងរបួស និង ស្លាប់បាត់បង់ជីវិតដល់បុគ្គលិកកម្មករព្រមទាំងប្រជាពលរដ្ឋ ក្បែរ ខាងតំបន់គម្រោង។<br>• អាចនឹងកើតមានការផ្ទុះសម្ភារគ្រឿងផ្ទុះឆេះប្រេងឥន្ធនៈ នៅកន្លែង ឬឃ្លាំងស្តុករបស់គម្រោងនិងការឆេះព្រៃក្នុងតំបន់គម្រោង ដែលបណ្តាល មកពីការធ្វេសប្រហែសឬអំពើភេវរកម្មក៏អាចបង្កឱ្យមានមហន្តរាយ ដល់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គម្រោង និងធន ធានធម្មជាតិក្នុង តំបន់ និងអាយុជីវិតមនុស្សទៀតផង។ | | | ✓ | • ធ្វើការសិក្សាចនាប្លង់វិស្វកម្ម និងគុណភាពការសាងសង់ ដែលអាចធានាមិន ឱ្យមានការបាក់ទំនប់ និងការបាក់ភ្នំក្នុងតំបន់គម្រោងវារីអគ្គិសនី ស្ទឹងពោធិ៍សាត់ ១នេះ ដោយរកក្រុមហ៊ុនអន្តរជាតិធ្វើការធានាគុណភាពសំណង់ធានាក្នុង រយៈពេល៩០ឆ្នាំ និងហានិភ័យរបស់វា។<br>• ធ្វើការប្រុងប្រយ័ត្នគ្រប់វិនាទីក្នុងការការពារសុវត្ថិភាព ចំពោះគ្រឿងផ្ទុះ ការ ឆេះព្រៃ និងឆេះប្រេងឥន្ធនៈ ដោយធ្វើការសហប្រតិបត្តិការណ៍ជាមួយ ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដើម្បីទប់ស្កាត់រាល់អំពើភេវរកម្មក្នុងតំបន់គម្រោងឱ្យទាន់ពេលវេលា។<br>• នឹងធ្វើការជូនដំណឹងរាល់ហេតុការណ៍ដែលអាចបង្កដល់ការបាក់ទំនប់ការបាក់ភ្នំ ឬការរញ្ជួយដីក្នុងតំបន់គម្រោងដល់ ប្រជាពលរដ្ឋទាំងនោះទាន់ពេលវេលា តាមតែអាចធ្វើទៅបានបើសិនជាមានហានិភ័យកើតឡើង។<br>• បង្ហូរទឹកឱ្យអស់ពីទំនប់បណ្តោះអាសន្ននៅពេលមានបញ្ហាគ្រោះថ្នាក់ ដោយចៃដន្យ ដូចជាការរញ្ជួយដីសង្គ្រាម និងបាតុភូតរញ្ជួយប្រាំមកលើទំនប់ខ្លាំង។ | |

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | • អាចនឹងកើតមានសង្គ្រាមឈ្លានពានលើបូរណភាពទឹកដី នៃប្រទេស កម្ពុជាក៏ជាឧបសគ្គដល់ការងារសាងសង់គម្រោង ឬសង្គ្រាមអាច បំផ្លាញគម្រោងទាំងស្រុងក៏សឹងមាន។ | | | | • នឹងរៀបចំបំរុងទុកនូវយានយន្តសង្គ្រោះសម្ភារ និងថវិកា ដើម្បីធានាការសង្គ្រោះជាបន្ទាន់នូវហេតុការខាងលើនេះទាន់សភាពការណ៍ និងមានប្រសិទ្ធិភាពខ្ពស់។ | |
| **២. ដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោង** | | | | | | |
| ក. ធនធានរូបសាស្ត្រ | | | | | | |
| ក.១ សណ្ឋានដី និង ឋានលេខា | • នេះអាចនឹងមានការប៉ះពាល់ដល់សណ្ឋានដី និងឋានលេខា ដោយសារ ការកាត់ជញ្ជាំងដី នៅតាមដងផ្លូវ ឬកន្លែងគរសំណល់ដី និងថ្ម ដោយសារមានភ្លៀងខ្លាំង ធ្វើឱ្យស្រុះផ្លូវ ឬបាក់ ឬកាត់ផ្លូវទឹក ក្នុងតំបន់ ហើយបង្កឱ្យប៉ះពាល់ដល់គុណភាពទឹកទៀតផង។ | | | ✓ | • ត្រូវត្រៀមគ្រឿងចក្រគ្រប់គ្រាន់សម្រាប់សំអាតដីដែលបាក់ទៅលើផ្លូវ ឬអូរ ដោយដឹកវាទៅទុកដាក់នៅកន្លែងមានសុវត្ថិភាព និងមានការបង្ហាប់ត្រឹមត្រូវ តាមបច្ចេកទេសរបស់ការងារដី។ ចំណែកឯកន្លែងដែលបាក់នេះ ត្រូវធ្វើការដាំស្មៅ ឬដើមឈើ ឬបាញ់បាយអរ ដោយមានរទេះបង្ហូរទឹកលើជញ្ជាំងនេះត្រឹមត្រូវ។ ត្រូវមានអ្នកត្រួតពិនិត្យជាប្រចាំជាពិសេស នៅពេលមានភ្លៀងធ្លាក់ ខ្លាំង នៅតាមដងផ្លូវនៅតាមកន្លែងដែលមានជញ្ជាំងចោទ និងមានកន្លែងចាក់ ជាតំនរដីស្អុយ និងថ្មចោល។ | |
| ក.២ ប្រព័ន្ធជលសាស្ត្រ (អូរ ស្ទឹង ព្រែក) | • អាចនឹងមានផលប៉ះពាល់ដល់ប្រព័ន្ធជលសាស្ត្រ នៃស្ទឹងពោធិ៍សាត់ និងខ្សែទឹកខាងក្រោម ដោយសារការបង្ហាំងទឹក ដើម្បីស្តុកទឹកទុក ក្នុងអាងឱ្យបានកម្លាំងគ្រប់គ្រាន់សម្រាប់រុសទួរប៊ីនអគ្គិសនីកម្លាំងសរុប ៨០មេហ្គាវ៉ាត់ និងការបញ្ចេញទឹកពីទំនប់មិនគ្រប់គ្រាន់ធ្វើឱ្យប៉ះពាល់ដល់របបទឹករបស់ស្ទឹងពោធិ៍សាត់ដែល ស្ថិតនៅចន្លោះទំនប់ និងអាគារថាមពល (ចម្ងាយប្រមាណ ៩,២គ.មបើវាស់តាមផ្លូវទឹក)។<br>• ការតម្កល់ទឹកក្នុងអាង ដែលមានជម្រៅជ្រៅ ហើយផ្ទៃទឹកធំធ្វើឱ្យ បង្កើនការជ្រាបទឹកចូលទៅក្នុងដីច្រើន ដែលធ្វើឱ្យកម្ពស់ទឹក ក្រោមដីនៅប៉ែកខាងក្រោមអាងកើនឡើងខ្ពស់ជាងស្ថានភាពដើម របស់វាអាចនាំឱ្យខូចខាតដល់ដំណាំរបស់អ្នកស្រុក ឬរុក្ខជាតិផ្សេងៗ ដែលស្ថិតនៅក្បែរតំបន់គម្រោង។<br>• អាចនឹងប្រែប្រួលរបបជលសាស្ត្ររបស់ស្ទឹងនេះ ដោយសារ ការបង្ហូរ ទឹកពីអាងស្តុកទឹកមកខាងក្រោម មិនគ្រប់គ្រាន់ ដែលធ្វើឱ្យមាន ការខ្វះទឹកសម្រាប់ស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រដំណាក់ឈើក្រំ ដំណាក់អំពិល និងចារ៉ែក។ | | | ✓ | • ត្រូវគ្រោងការគ្រប់គ្រងចាត់ចែងបញ្ចេញទឹកមានដូចតទៅ:<br>-តំបន់១: នៅខាងក្រោមតំបន់ទំនប់ ដល់អាគារថាមពល តាមដងស្ទឹងមានចម្ងាយប្រមាណ ៩,២គ.ម។ នៅតំបន់នេះ ក្រុមហ៊ុន នឹងធ្វើការបញ្ចេញទឹកពីអាង ចំនួន ១,៣ម$^3$/វិន. គតដាច់ទាំងប្រាំង និងវស្សា។ ប៉ុន្តែនៅ២ឆ្នាំដំបូងក្នុងរយៈពេលប្រតិបត្តិ និងថែទាំគម្រោង ក្រុមហ៊ុនត្រូវធ្វើការបិទទ្វារទឹកដើម្បីបំពេញអាងក្នុងនោះនៅឆ្នាំទី១ ត្រូវការរយៈពេលពី៥ទៅ៨ខែ ក្នុងការបំពេញទឹកក្នុងអាងឱ្យដល់នីវ៉ូ EL: ១៨០ម ដើម្បីដំណើរការទួរប៊ីន (៨០ MW)។ នោះមានន័យថា ៥ខែដំបូងនៃឆ្នាំទី១នេះ មិនមានទឹកគ្រប់គ្រាន់សម្រាប់រក្សាជីវៈចំរុះនារដូវវស្សានោះទេពោល គឺមានតែ ១,៣ម$^3$/វិន. និងលំហូរធម្មជាតិពីទឹក ភ្លៀងក្នុងតំបន់តែប៉ុណ្ណោះ។ យោងតាមលំហូរជាទឹកនៃរយៈពេលកត់ត្រា ៣០ឆ្នាំ (មើលតារាង ៥-១១) បញ្ជាក់ថា នៅរដូវវស្សាចាប់ពី ខែឧសភាដល់ខែតុលា ស្ទឹងពោធិ៍សាត់មានលំហូរអប្បបរមា ០,៦ម$^3$/វិន. ហើយអតិបរមា ៣៨៩,២ ម$^3$/វិន.។ ដូចនេះក្នុងរយៈពេល ៥ខែ ដំបូងនៃឆ្នាំទី១ ក្រុមហ៊ុនធ្វើការបញ្ចេញទឹកមកខាងក្រោមទំនប់យ៉ាងហោចណាស់ឱ្យបាន១,៣ម$^3$/វិន.ដែរ។ បើធ្វើដូចនេះមានន័យថា: នៅរដូវវស្សា តំបន់នេះមានលំហូរលើស ១,៣ ម$^3$/វិន. ហើយរដូវប្រាំងពី១,៣ម$^3$/វិន នៅរយៈពេល២ឆ្នាំដំបូង។ ចាប់ពីឆ្នាំទី៣ ទៅនឹងមានទឹកបន្ថែមនារដូវវស្សាដោយសារ ការហៀរទឹកចេញតាមទំនប់បង្ហៀរ។<br>-តំបន់២: គឺតំបន់ក្រោមអាគារថាមពល (PH) តាមដងស្ទឹងពោធិ៍សាត់មានទំនប់សំណង់ធារាសាស្ត្រដំណាក់ឈើក្រំ (កំពុងសាងសង់ចម្ងាយ៦២គ.ម) ដំណាក់អំពិលចម្ងាយ | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | | | | | ប្រមាណ១០៣ គ.ម ដែលទទួលយកទឹក ពីគម្រោងនេះ។ នៅដំណាក់កាលប្រតិបត្តិថែទាំគម្រោង និងមានការខ្វះទឹកនៅពេល ដែលក្រុមហ៊ុនធ្វើការបិទទំនប់ដើម្បីតម្កល់ទឹកនៅឆ្នាំទី១ ដូចនេះក្រុមហ៊ុនត្រូវព្រលែងទឹកនៅរដូវវស្សាយ៉ាងហោច ៤០ ម^៣/វិន. និងរដូវប្រាំង ១,៣ម^៣/វិន. តាមបំពង់បង្ហូរទឹកបរិស្ថាន ពីព្រោះប្រព័ន្ធធារាសាស្ត្រនៅដំណាក់ឈើក្រំ និងអំពិលនេះត្រូវការទឹកស្រោចស្រពនៅរដូវវស្សា និងប្រាំង (មើលតារាង ៥-១១ លំហូរធារទឹកជាមធ្យមគឺ ៤២,៤ ម^៣/វិន.)។ ដូចនេះ ចំពោះការខ្វះទឹកសម្រាប់ រក្សាជីវៈចំរុះ និងតំរូវការទឹកសម្រាប់ស្រោចស្រពនោះ គឺត្រូវបានកាត់បន្ថយ អាចទទួលយកបានបើក្រុមហ៊ុនអនុវត្តតាម ការគ្រប់គ្រងទឹកខាងលើ។ នៅពេលដែលនីវ៉ូទឹកក្នុងអាងឡើងដល់កម្រិតអាចដំណើរការទួរប៊ីន នោះក្រុមហ៊ុន នឹងដំណើរការទួរប៊ីន១ មានធារទឹក៤០ម^៣/វិន. និងរហូតដល់ដំណើរការទាំង២ទួប៊ីន ដែលត្រូវបញ្ចេញធារទឹក សរុប៨០ម^៣/វិន.។ នៅរដូវវស្សាតំបន់នេះ យ៉ាងហោចណាស់ ត្រូវព្រលែងទឹក ៤០ម^៣/វិន. បើមិនដូច្នេះទេនោះ នឹងធ្វើឱ្យមានខ្វះខាតក្នុងការផ្គត់ផ្គង់ទឹកមកតំបន់ធារាសាស្ត្រដំណាក់ឈើក្រំ និងដំណាក់អំពិលជាមិនខាន។ ចំណែកឯ នៅរដូវប្រាំង ការផលិតអគ្គិសនី ដែលដំណើរការបើកទួរប៊ីន២ មានធារទឹកសរុបប្រមាណ៨០ម^៣/វិន. នោះ អាចផ្តល់ទឹកគ្រាន់ ដល់ប្រព័ន្ធធារាសាស្ត្រទាំងនេះ នៅរដូវប្រាំងមិនខ្វះទឹកដូចដំណាក់កាលមុនសាងសង់គម្រោងទៀតឡើយ។ ***សម្គាល់:*** *នៅដំណាក់កាលប្រតិបត្តិថែទាំ គម្រោង នៅរដូវប្រាំង យោងតាម EDC ចង់បានអគ្គិសនី ២៤ម៉ោង លើ ៦ ខែ នៅរដូវប្រាំង នោះនឹងមានធារទឹក ៨០ម៣/វិន. បើប្រៀបធៀប ធារទឹកស្ទឹងពោធិ៍សាត់នៅទីតាំងទំនប់មេ មានប្រហាក់ប្រហែល ធារទឹកក្នុងខែ ឧសភា មិថុនា និងកក្កដា មើលតារាង៥-១១។* | |
| គ.៣ ការហូរច្រោះ និងគុណភាពដី | • អាចមានការហូរច្រោះ រួចបណ្តាលឱ្យបាក់ដីនៅតាមជញ្ជាំងដី តាមដងផ្លូវ កន្លែងចាក់ជាគំនរថ្ម និងដីចោលធ្វើឱ្យដីបាក់នេះ ស្ទះផ្លូវ ឬស្ទះចរន្តទឹក ឬរាក់ផ្លូវទឹក ឬធ្វើឱ្យដីដែល ហូរច្រោះទាំង នេះទៅគ្របពីលើដីមានឈើដុះធ្វើឱ្យបាត់បង់ដីជាតិដី និងបណ្តាល ឱ្យដើមឈើទាំងនោះងាប់ដោយសារតែគល់វាត្រូវដីគ្របសង្កត់ជាដើម។ល។<br>• អាចមានការបាក់ច្រាំងស្ទឹងពោធិ៍សាត់ ដោយសារការបញ្ចេញទឹក៨០ម^៣/វិនាទីបន្ថែមលើធារទឹកនីស្ទឹងនេះនៅតំបន់ខាងក្រោមអាគារថាមពល ដែលស្ទឹងនេះមុនការប្រតិបត្តិគម្រោងមានធារទឹកធម្មប្រមាណ៤២ម^៣/វិនាទី។ | | ✓ | | • ត្រូវត្រៀមគ្រឿងចក្រគ្រប់គ្រាន់សម្រាប់សំអាតដីដែលបាក់ ទៅលើផ្លូវ ឬ អូរដោយដឹកវាទៅទុកដាក់នៅកន្លែងមានសុវត្ថិភាព និងមានការបង្ហាប់ ត្រឹមត្រូវតាមបច្ចេកទេសរបស់ការងារដី។ ចំណែកឯកន្លែងដែលបាក់ នេះត្រូវធ្វើការដាំស្មៅ ឬដើមឈើ ឬបាញ់បាយអរ ដោយមានទ្វេបង្ហូរ ទឹកត្រឹមត្រូវលើជញ្ជាំងនេះត្រឹមត្រូវ។ ត្រូវមានអ្នកត្រួតពិនិត្យជាប្រចាំ ជាពិសេស នៅពេលមានភ្លៀងធ្លាក់ខ្លាំង នៅតាមដងផ្លូវ នៅតាមកន្លែង ដែលមានជញ្ជាំងចោទ និងមានកន្លែងចាក់ជាគំនរដី ស្មួយ និងថ្មចោល។<br>• តាមដានការហូរច្រោះបាក់ច្រាំងស្ទឹងនេះ ជាប្រចាំ ហើយបើមានការបាក់ច្រាំងបណ្តាលពីការបញ្ចេញធារទឹកនេះ ត្រូវជួលជុល និងសាសង់សំណង់ការពារច្រាំងនេះវិញ។ | |
| គ.៤ ការរញ្ជួយដី ៖ មិនមានការរញ្ជួយដោយសារការបំផ្ទុះ ឬការដឹកវត្ថុធ្ងន់ៗ ឬការបាក់ដីទេ ប៉ុន្តែអាចកើតមានការរញ្ជួយដីពីធម្មជាតិ តែរាប់រយសតវត្សមកហើយប្រទេសកម្ពុជាមិនធ្លាប់ជួបប្រទះនឹងគ្រោះធម្មជាតិ នេះទេ។ ទោះជាយ៉ាងនេះក៏ដោយ ការគ្រោងគម្រោង បានគិតបន្ថែមនូវកម្រិតរញ្ជួយដី ប្រភេទ IV ពោលគឺសំណង់ ទំនប់និងបំពង់ទុយោ អាចធន់និងការរញ្ជួយកម្រិត ៤-៤,៩ រិចទ័រ។ | | | | | | |

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| ក.៥ គុណភាពទឹក (ទឹកលើដី/ទឹកក្រោមដី) | • អាចនឹងប៉ះពាល់គុណភាពទឹកលើដី ដោយសារការបញ្ចេញសំណល់ រាវ-រឹងពីកន្លែងរស់នៅរបស់បុគ្គលិកកម្មករគម្រោង បណ្តាលមកពីគុណភាពសំអាតរបស់អាងសិបទឹកបាត់បង់ និងការធ្វេសប្រហែស ក្នុងការគ្រប់គ្រងសំណល់រឹងគ្រប់ប្រភេទ ដែលធ្លាក់ចូលក្នុងប្រព័ន្ធផ្លូវ ទឹកក្នុងតំបន់ធ្វើឱ្យបំពុលទឹកនៃប្រភពទាំងនោះទៀតផង។<br>• បានការបំពុលទឹកក្នុងអាង ដោយសារការសំអាតឈើមិនទាន់ស្អាត រួចធ្វើការបិទទ្វារទឹកដើម្បីតម្កល់ទឹកផលិតអគ្គិសនី។<br>• អាចនឹងប៉ះពាល់ដល់ការលាយអុកស៊ីសែនរបស់ទឹក ដោយសារការ ស្តុកទឹកដែលមានជម្រៅលើសពី ១៥ម. ហើយនឹងធ្វើឱ្យទឹកមានក្លិន ស្អុយ។ នៅពេលបង្ហូរទឹកមកខាងក្រោម ធ្វើឱ្យទឹកនេះមានក្លិនស្អុយ ដោយទឹកបាត់អុកស៊ីសែននេះ។<br>• អាចធ្វើឱ្យប៉ះពាល់គុណភាពក្រោមដីដោយសារការលាយសារធាតុ ខនិកក្នុងដីនៅតំបន់អាង ដែលមិនធ្លាប់លិចទឹកធ្វើឱ្យកើនឡើងនៃសារធាតុគីមីទឹកក្រោមដីនៅតំបន់នោះផងដែរ។<br>• ការជ្រាបទឹកពីអាងស្តុកទឹកទៅក្រោមដីដែលមានក្លិនស្អុយ ដោយ សារ ទឹកមានកម្រិតអុកស៊ីសែនលាយទាបនឹងធ្វើឱ្យគុណភាពទឹក ក្រោម ដីថយចុះ។<br>• ការស្តុកទឹកធ្វើជាអាងដ៏ធំនេះ នឹងអាចកើតមានរុក្ខជាតិទឹក ដូច ជា: ពើក ចក កំប្លោក និងសត្វល្អិតចង្រៃ ដូចជា មូស បាក់តេរី ដែលបង្កឱ្យមានរំហូតខ្លាំង ការបំពុលទឹកអាង និងការ ចម្លងជំងឺផ្សេងៗ ដែលកើតចេញពីប្រភពទឹកនេះ។<br>• អាចមានការប៉ះពាល់គុណភាពទឹកស្ទឹងនេះ ដោយសារការលាងកករសម្អាតបាតអាត តាមរូងទុនៃលពង្វៀងទឹករបស់គម្រោង។ | | | ✓ | • ត្រូវធ្វើការពិនិត្យ និងវិភាគគុណភាពទឹកនៅ ២ ចំណុចសំខាន់គឺ (១)-នៅ ក្នុងអាង (២)-ខាងក្រោមអាគារថាមពល, ឱ្យបានក្នុងមួយឆ្នាំយ៉ាងតិច ២ដង គឺធ្វើឡើងនៅខែ មិនា (រដូវប្រាំង) និងខែកញ្ញា រួចបញ្ចូលជាទិន្នន័យ (Excel) សម្រាប់ធ្វើការវិភាគគុណភាពទឹកទៅថ្ងៃក្រោយ។<br>• ត្រូវសាងសង់សំណង់បំបែកចរន្តទឹកដែលនៅខាងក្រោមអាគារថាមពល ដែលធ្វើឱ្យទឹកខ្វាយឡើងហើយ មានលទ្ធភាពស្រូបយកអុកស៊ីសែន បានគ្រប់គ្រាន់ ហើយធ្វើឱ្យទឹកលែងមានក្លិនស្អុយ។<br>• ពេលដែលបំពេញទឹកក្នុងអាងរួច ក្រុមហ៊ុនត្រូវធ្វើការសំអាតឈើដែល អណ្តែតទឹកឱ្យបានស្អាត ដោយមានកញ្ចប់ថវិកាចំនួន ២០.០០០ ដុល្លារ រ អាមេរិកសម្រាប់ប្រតិបត្តិការនេះមើលតារាង៨-៣ចំណុចលេខរៀងទី៤។<br>• ធ្វើការសិក្សា និងពិនិត្យតាមដានអំពីបរិមាណ/លក្ខណៈទឹកលើដី និងក្រោមដីជាប្រចាំក្នុង១ឆ្នាំ២ដង ដូចការពិសោធន៍គុណភាពទឹកខាងលើ ដែរ។<br>• នឹងត្រៀមបំពាក់ឧបករណ៍ និងសម្ភារ និងអ្នកជំនាញសម្រាប់សំអាត រុក្ខជាតិទឹក និងសត្វល្អិតចង្រៃ ដែលនឹងអាចកើតមាននៅក្នុងអាងស្តុក ទឹករបស់គម្រោង។<br>• នឹងធ្វើការពិភាក្សាជាមួយក្រសួងធនធានទឹក (ផ្នែកជលសាស្ត្រ) និង ក្រសួងបរិស្ថាន ដើម្បីកាត់បន្ថយផលប៉ះពាល់ ដោយសារគុណភាពទឹក និងបរិមាណប្រសិនបើមានការបំពុលធ្ងន់ធ្ងរ ឬមានការខ្វះខាតទឹកមក តំបន់ខាងក្រោម។<br>• នៅពេលដែលចាំបាច់សម្រាប់លាងកករបាតអាង គឺម្ចាស់គម្រោង នឹងធ្វើការលាងសម្អាតវានៅរដូវវស្សា ក្នុងចន្លោះ ខែសីហា ដល់ខែវិច្ឆិកា ព្រោះវាជាខែដែលស្ទឹងពោធិ៍សាត់មានទឹកច្រើនជាងគេ ជាមធ្យមចន្លោះពី១៤៥ ទៅ៣៨៩ ម³/វិនាទី។ | |
| ខ. ធនធានជីវសាស្ត្រ | | | | | | |
| ខ.១ ជីវសាស្ត្ររស់នៅក្នុងទឹក/មច្ឆជាតិ | • តាមការចុះសម្ភាស និងការសិក្សាចរាចរត្រីក្នុង និងជុំវិញតំបន់គម្រោងបានបញ្ជាក់ឱ្យដឹងថា នៅស្ទឹងពោធិ៍សាត់ត្រង់តំបន់គម្រោង មានត្រី៨៣ប្រភេទ។ ការបិទទ្វារទឹកដើម្បីតម្កល់ទឹកក្នុងអាងអាចប៉ះពាល់ដល់ប្រភេទវារីសត្វងាយរងគ្រោះថ្នាក់មួយចំនួន ដូចជា អណ្តើកដំបូក ឬអណ្តើកព្រុច អណ្តើកទឹក កន្ធាយ អាស៊ី ត្រីពោ ត្រីគល់រាំង ត្រីកាហែ ត្រីខ្យា ក្រពើភ្នំ (មានតិចតួច)ជាដើម ។ល។ ដោយសារពួកវាមិនអាចឆ្លងកាត់ទំនប់ចុះឡើងបាន។ ប៉ុន្តែ ការបង្កើតអាងទឹកដ៏ធំអាចមានការកើនឡើងនៃវារីសត្វផងដែរ ដូច ជាសុភាសិតខ្មែរពោលថាទីណាមានទឹកគឺ ទីនោះមានត្រី។<br>• ការបង្ហូរទឹកចេញពីអាង (តាមទួរប៊ីន) ដែលមានបរិមាណអុកស៊ី សែនលាយ | | | ✓ | • សហការជាមួយរដ្ឋបាលជលផល ដោយមានវិធានការព្រលែងកូនត្រី ដោយកេពូជត្រីដែលងាយរងគ្រោះក្នុងតំបន់គម្រោង រួចយកវាទៅ លែងតាមអូរ ស្ទឹង នៅក្នុងឬក្បែរតំបន់គម្រោង ជាពិសេសក្នុងស្ទឹងខាងក្រោមអាគារថាមពល។ (***សម្គាល់:*** *ចំពោះតម្លៃនៃសំណង់ជណ្តើរត្រីឆ្លងកាត់បានមានតម្លៃរាប់លានដុល្លារ ដែលធ្វើឱ្យតម្លៃ ដើមរបស់អគ្គិសនីកើនខ្ពស់ផងដែរ*)។<br>• ធ្វើការសម្អាត សំណល់ថ្ម ដី ចេញពីអន្លង់ ទាំងអស់ដែលនៅខាងក្រោមទំនប់មេ ដែលខ្លួនឬអ្នកម៉ៅការសាងសង់បានធ្វេសប្រហែសឱ្យមានការលប់អន្លង់នានានៅតាមពោះស្ទឹង និងនៅឆ្នាំដំបូងក្នុងដំណាក់កាលនេះ ត្រូវព្រលែងទឹកតាមរូងទុនៃលពង្វៀងទឹកសម្រាប់ លាងកករដី ដែលកកនៅតាមពោះស្ទឹង ខាងក្រោមទំនប់នេះ។ (អន្លង់នានា | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | ក្នុងទឹកតិចធ្វើឱ្យប៉ះពាល់ដល់កត្តាជីវសាស្ត្រ ដែលរស់ នៅក្នុងទឹក ឬមច្ឆជាតិនៅតំបន់ខាងក្រោមទំនប់បេ។<br>• អាចធ្វើឱ្យប៉ះពាល់ដល់ការចរាចរត្រី ពីខាងក្រោមទំនប់ទៅផ្នែក ខាងលើទំនប់ដែលបណ្ដាលឱ្យបាត់បង់ ឬរារាំងការបង្កកំណើត របស់ពពួកត្រីទាំងនោះ។<br>• អាងស្ដុកទឹករបស់គម្រោងវារីអគ្គិសនីអាចនឹងកើតមានរុក្ខជាតិទឹក ដូចជាពើកចក កំប្លោក និងសត្វល្អិតចង្រៃ ដូចជាមូស បាក់តេរី ដែលបង្កឱ្យខ្វះអុកស៊ីសែនរលាយក្នុងទឹកធ្វើឱ្យវារីសត្វ ថយចុះ ឬ បាត់បង់ ឬកើនឡើងនៃប្រភេទវារីសត្វថ្មីទៀត ដែលមិនធ្លាប់មាន ក្នុងតំបន់។<br>• អាចនឹងមានការបំពុលទឹកដោយសំណល់រាវ-រឹង ពីការិយាល័យ ផ្ទះបុគ្គលិក-កម្មករ ដែលស្នាក់នៅពីឃ្លាំងស្តុកសម្ភារ និងពីរោង ជាង។ | | | | តាមពោះស្ទឹងជាជម្រករបស់ពពួកមច្ឆជាតិយ៉ាងសំខាន់)។<br>• សាងសង់សំណង់បំបែកចរន្តទឹកបន្ថែម ដែលនៅខាងក្រោមអាគារថាមពល ប្រសិនបើកម្រិតអុកស៊ីសែនរលាយ (DO) នៅមានកម្រិតទាបជាង២ម.ក្រ/ល ដែលធ្វើឱ្យទឹកខ្វាយឡើង ហើយមានលទ្ធភាពស្រូបយកអុកស៊ីសែនបានគ្រប់គ្រាន់ និងធ្វើឱ្យទឹកលែងមានក្លិនស្អុយ។<br>• ត្រៀមបំពាក់ឧបករណ៍ សម្ភារ និងអ្នកឯកទេសសម្រាប់សំអាត រុក្ខជាតិទឹក និងសត្វល្អិតចង្រៃ ដែលនឹងអាចកើតមាននៅក្នុងអាងស្ដុក ទឹករបស់គម្រោងបានល្អប្រសើរ។<br>• ថែទាំអាងប្រព្រឹត្តកម្មសំណល់រាវសម្រាប់សំអាតទឹកកខ្វក់ពីការិយាល័យ ផ្ទះបុគ្គលិកកម្មករស្នាក់នៅ ឱ្យបានត្រឹមត្រូវ ហើយទឹកដែលបង្ហូរចេញពីអាងសំអាតនេះ ត្រូវមានកម្រិតតាមស្តង់ដានៃការបញ្ចេញចោលពីប្រភពបំពុលចូលទៅប្រភពទឹកសាធារណៈ ដែលមានចែងក្នុងអនុក្រឹត្យលេខ ២៧អនក្រ.បក របស់រាជរដ្ឋាភិបាល។ | |
| ខ.២ ព្រៃឈើការពារ/ តំបន់ការពារ/ ឧទ្យានជាតិ | • តំបន់គម្រោងទំហំ ៩.៣៥៥ហ.ត ស្ថិតនៅក្នុងតំបន់ឧទ្យានជាតិជួរភ្នំក្រវាញកណ្ដាល ៣៩៩.៧០ហ.ត(៤%) តំបន់ការពារដែនជម្រកសត្វព្រៃភ្នំសំកុស ទំហំ ៤.៧៥៦.១ហ.ត (៥១%) និងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ សរុបផ្ទៃដីមានចំនួន ៤.១៩៩.២ហ.ត (៤៥%) (លម្អិតមើលក្នុងជំពូក៥ ចំណុច ៥.១.២.៥) និង ។<br>• អាចនឹងមានការទន្ទ្រានចាប់ដីព្រៃក្នុងតំបន់ការពារ និងព្រៃការពារទាំងនោះ យកធ្វើកម្មសិទ្ធិពីសំណាក់បុគ្គលិក-កម្មករគម្រោង ឬជនឆ្លៀតឱកាសមួយចំនួន ដែលធ្វើឱ្យព្រៃឈើ និងសត្វព្រៃ បាត់បង់។ | | | ✓ | • ធ្វើការប្រឹក្សាជាមួយរដ្ឋបាលព្រៃឈើ ដែនជម្រកសត្វព្រៃភ្នំសំកុស អង្គការ អភិរក្សនានា និងអង្គការនានា ដែលពាក់ព័ន្ធរកទីតាំងសមស្របក្នុងតំបន់ព្រៃក្បែរតំបន់គម្រោងនេះ សម្រាប់ដាំជួសឈើ ក្នុងព្រៃនេះ ទុកជាជម្រកដល់ សត្វព្រៃផង និងដើម្បីរក្សាលំនឹងអេកូឡូស៊ីបរិស្ថាន ក្នុងតំបន់នេះ ជាពិសេសព្រៃឈើស្របទាក់ទាញទឹកភ្លៀង ដែលជាប្រភពសម្រាប់វារីអគ្គិសនីទៀតផង។ <u>*បញ្ជាក់:*</u> *ថវិកាសម្រាប់ដាំឈើ និងឧបត្ថម្ភអ្នកល្បាតមើលក្នុងតារាង៨-៣ ចំណុច ៨.៨។*<br>• ធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន នឹងធ្វើឡើង ដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមានដែលអាចកើត មានជាយថាហេតុ លើព្រៃឈើដែលនៅជាប់នឹងតំបន់គម្រោងក្នុងដំណាក់កាលនៃការសាងសង់នេះ។<br>• សហការជាមួយរដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន និងអង្គការអភិរក្សនានា ក្នុងការទប់ស្កាត់ការរានដីយកធ្វើកម្មសិទ្ធិខុសច្បាប់ ដោយបង្កើនកម្លាំងការពារ និងត្រួតពិនិត្យឱ្យបានហ្មត់ចត់។<br>• ត្រូវដាក់ស្លាកសញ្ញា ឬសរសេរជាផ្ទាំងប៉ាណូធំ ដូចនៅតាមផ្លូវទៅកោះកុង ដូចជាសរសេរថា «ព្រៃការពារ ហាមទន្ទ្រានកាន់កាប់ធ្វើជាកម្មសិទ្ធ ហាមកាប់ឈើ ឬបរបាញ់ខុសច្បាប់ ត្រូវជាប់ទោសដាក់គុករហូតដល់ ១០ឆ្នាំ» ជាអក្សរខ្មែរ និងកូរ៉េ ឬអង់គ្លេសឱ្យបានច្រើន ដើម្បីឱ្យប្រជាពលរដ្ឋ និងជនបរទេស ងាយមើលឃើញក្នុងតំបន់គម្រោង។ | |
| ខ.៣ ធនធានព្រៃឈើ និងជម្រកសត្វព្រៃ | • អាចនឹងប៉ះពាល់ដល់ជម្រកសត្វព្រៃ ដោយសារសកម្មភាពរបស់ បុគ្គលិក-កម្មករទន្ទ្រានចូលព្រៃ ធ្វើការបរបាញ់ ឬដាក់អន្ទាក់សត្វ និងជួញដូរ ចរាចរឈើ និងសត្វព្រៃ ធ្វើឱ្យឈើ និងសត្វព្រៃទាំង នោះថយចុះឈានទៅរកការបាត់បង់ពូជមួយចំនួន។ | | | ✓ | • ត្រូវធ្វើការហាមឃាត់ដល់បុគ្គលិកកម្មកររបស់គម្រោងមិនឱ្យ ទន្ទ្រានកាន់កាប់ដី ឬរុករានព្រៃ និងបំផ្លាញជម្រកសត្វព្រៃនៅក្នុង និងក្បែរខាង តំបន់គម្រោង។<br>• ត្រូវបញ្ជាឱ្យក្រុមការងារតាមផ្នែករបស់ខ្លួនធ្វើការអប់រំ និងហាមឃាត់ ដល់បុគ្គលិក-កម្មករតាមផ្នែក ឬក្រុមរបស់ខ្លួនមិនឱ្យទន្ទ្រានចូលព្រៃ ធ្វើការបរបាញ់ ដាក់អន្ទាក់ រកឃ្មុំ | |

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | • អាចនឹងមានការទន្ទ្រានកាន់កាប់ដីនៅក្នុង ឬក្បែរតំបន់គម្រោងពី សំណាក់បុគ្គលិក-កម្មករ ឬជនឆ្លៀតឱកាសនិយមមកពី ខាងក្រៅ ធ្វើឱ្យបាត់បង់សម្បត្តិធម្មជាតិនៅតំបន់នោះ។<br>• អាចកើតមានឡើងភ្លើងឆេះព្រៃក្បែរតំបន់គម្រោង ដោយសារ បុគ្គលិក-កម្មករគម្រោង។ | | | | ដែលអាចបង្កការឆេះព្រៃឈើ។<br>• ត្រូវដាក់ពិន័យដល់បុគ្គលិកកម្មករណាដែលប្រព្រឹត្តិល្មើស និងការហាម ឃាត់ខាងលើ។<br>• ដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដែលអាចនឹងកើតឡើង ជាយថាហេតុនៅក្នុងតំបន់គម្រោងនោះ ក្រុមហ៊ុនត្រូវធ្វើការសហការ ជាមួយក្រសួងបរិស្ថាន រដ្ឋបាលព្រៃឈើ និងអង្គការអភិរក្សនានា ដើម្បីដោះស្រាយ។<br>• ចំពោះកិច្ចការពារអគ្គិភ័យ ក្រុមហ៊ុនបានបំពាក់នូវឧបករណ៍ សម្ភារ សម្រាប់ពន្លត់អគ្គិភ័យ/ភ្លើងឆេះព្រៃ និងប្រព័ន្ធឧបករណ៍ដែលឱ្យសញ្ញា ពេលមានអគ្គិភ័យកើតមានឡើង។ ក្រុមហ៊ុន និងអ្នកម៉ៅការ ទាំងអស់ ត្រូវអនុវត្តជាប្រចាំនូវផែនការផែនការគ្រប់គ្រងសុវត្ថិភាព និងហានិភ័យ ដូចមានចែងក្នុងជំពូក ៤ ចំណុច ៤.៦.១២។<br>• ត្រៀមមូលនិធិគ្រប់គ្រាន់ដើម្បីការពារ និងស្តារឡើងវិញនូវជម្រកសត្វព្រៃ ទាំងនោះដែលបាត់បង់ (ដូចជាការដាំឈើឡើងវិញនៅតំបន់ដែលគ្មាន ឈើដុះក្បែរនោះដោយធ្វើការជាមួយ ក្រសួងបរិស្ថាន រដ្ឋបាលព្រៃឈើ និងអង្គការអភិរក្សនានា។<br>***បញ្ជាក់:*** *ថវិកាសម្រាប់ដាំឈើ និង ឧបត្ថម្ភអ្នកល្បាត ក្នុងតារាង៤-៣ ចំណុច ៤.៧។* | |
| ខ.៤ ជីវសាស្ត្រសត្វព្រៃ | • ការបាត់បង់ជម្រកព្រៃមួយចំនួនក្នុងតំបន់អាងស្តុកទឹករបស់វារីអគ្គិសនីនេះ នឹងធ្វើឱ្យមានការថយចុះសត្វព្រៃមួយចំនួននៅ ក្នុងតំបន់គម្រោង ។<br>• ការតម្កល់ក្នុងអាង ដែលមានផ្ទៃទឹកដ៏ធំធេងមិនអាចឱ្យសត្វព្រៃ មួយចំនួនធំឆ្លងកាត់បាន ជាពិសេសការធ្វើចរាចររបស់ត្រីក្នុងការ ឆ្លងកាត់ពីតំបន់ខាងក្រោមទំនប់ទ ទៅតំបន់ខាងលើទំនប់។<br>• ការទន្ទ្រានចូលព្រៃធ្វើការបរបាញ់ ដាក់អន្ទាក់ និងចាប់សត្វពី សំណាក់បុគ្គលិក-កម្មករ ដែលធ្វើប្រតិបត្តិការ និងថែទាំគម្រោងក៏ បណ្តាលឱ្យមានផលប៉ះពាល់ដល់សត្វព្រៃ ក្នុងតំបន់នេះផងដែរ ដូចជាថយចុះចំនួន និងបាត់បង់ពូជសត្វដែលកំពុងការពារ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ អង្គការអភិរក្សនានា និងក្រសួងបរិស្ថាន។<br>• ការអភិវឌ្ឍនៅតំបន់នេះអាច ធ្វើឱ្យមានការហូរចូលជនចំណូលថ្មី មកពីតំបន់ផ្សេងៗ ដើម្បីទន្ទ្រានកាន់កាប់ដី និងរស់នៅទីនោះធ្វើឱ្យ បាត់បង់ធនធានធម្មជាតិ ដែលជាទីជម្រកសម្រាប់បន្តពូជ និងរកចំណី របស់សត្វក្នុងតំបន់ទាំងនោះ។ | | | ✓ | • ត្រៀមមូលនិធិគ្រប់គ្រាន់ ដើម្បីការពារ និងស្តារឡើងវិញនូវជម្រកសត្វ ព្រៃទាំងនោះដែលបាត់បង់ (ដូចជាការដាំឈើឡើងវិញនៅតំបន់ដែល គ្មានឈើដុះក្បែរនោះដោយធ្វើការជាមួយក្រសួងបរិស្ថាន រដ្ឋបាលព្រៃឈើ និងអង្គការអភិរក្សនានា។<br>• សហការជាមួយដែនជម្រកសត្វព្រៃភ្នំសំកុស ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល និងរដ្ឋបាលព្រៃឈើក្នុងការអប់រំ ឱ្យស្គាល់ ស្រឡាញ់និងចេះអភិរក្សសត្វព្រៃ ប្រភេទកំពង់រងគ្រោះថ្នាក់ មានប្រភេទជិតផុតពូជ(CR) ប្រភេទកំពុងរងគ្រោះ(EN) និងប្រភេទងាយរងគ្រោះ(VU) ដូចជាពង្រូល ទន្សោង ខ្ទីង កែះ ប្រើស ឈ្លូសយក្ស ផ្តៃព្រៃគេជាដើម។ល។<br>• តសហការជាមួយរដ្ឋបាលជលផល ដោយមានវិធានការព្រលែងកូនត្រីទៅ ក្នុងអូរ ស្ទឹងនៅក្បែរតំបន់គម្រោង និងក្នុងអាងផងដែរ។<br>• ហាមឃាត់ដាច់ខាតដល់បុគ្គលិក/កម្មកររបស់ខ្លួនក្នុងការប្រមាញ់ សត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គម្រោង។<br>• ត្រូវអប់រំ និងដាក់វិន័យដល់បុគ្គលិក/កម្មករគម្រោងមិនឱ្យធ្វើការចាប់ ឬបរបាញ់សត្វព្រៃ និងធ្វើចរាចរលក់ដូរសត្វ ព្រៃនៅក្នុងតំបន់នេះឡើយ។<br>• ដើម្បីការពារការកាន់កាប់រុករានទន្ទ្រានដីថ្មី ដែលជាព្រៃការពារពីជនចំណូលថ្មីទាំងនោះ ក្រុមហ៊ុននឹងការសហការជាមួយ អាជ្ញាធររដ្ឋបាលព្រៃឈើ និងស្ថាប័នមានសមត្ថកិច្ចត្រួតពិនិត្យដើម្បីទប់ស្កាត់បញ្ហានេះ។ | |
| គ. ធនធានសេដ្ឋកិច្ចសង្គម | | | | | | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| **គ.១ ការប្រើប្រាស់ដី និងការតាំងលំនៅឡើងវិញ:** មិនមានការប៉ះពាល់លើការប្រើប្រាស់ដី និងការរើទីតាំងលំនៅដ្ឋានរបស់ប្រជាជនទេ ពីព្រោះគម្រោង បានដោះស្រាយរួចរាល់ហើយក្នុងដំណាក់កាលសាងសង់គម្រោង។ | | | | | | |
| **គ.២ ការរស់នៅ និងមុខរបររបស់សហគមន៍មូលដ្ឋាន:** មិនមានការប៉ះពាល់លើចំណុចនេះទេ ពីព្រោះគម្រោងបានដោះស្រាយរួចរាល់ហើយក្នុងដំណាក់កាល សាងសង់គម្រោង។ | | | | | | |
| គ.៣ ប្រពៃណី វប្បធម៌ និងសាសនា | • អាចនឹងប៉ះពាល់ដល់ទំនៀមទំលាប់ប្រពៃណី របស់ប្រជាពលរដ្ឋ ដែលរស់នៅក្បែរតំបន់ដូចជាៈ ពួកគាត់មានជំនឿលើអារក្សអ្នកតា ព្រៃភ្នំដោយបង្កើតជាព្រៃអ្នកតាភ្នំជាដើម ដោយសារក្រុមហ៊ុននាំ យកបុគ្គលិកកម្មករគម្រោងមកពីតំបន់ផ្សេងទៀតឬពីបរទេស។ | ✓ | | | • ត្រូវធ្វើការណែនាំអប់រំដល់បុគ្គលិក-កម្មករ របស់គម្រោងឱ្យមានការគោរពទំនៀមទំលាប់ប្រពៃណី និងជំនឿរបស់ប្រជាពលរដ្ឋរស់នៅក្នុង តំបន់ព្រៃភ្នំស្ថិតនៅជុំវិញទីតាំងគម្រោង។<br>• ត្រូវដាក់វិន័យដល់បុគ្គលិក-កម្មករគម្រោង ដែលបំពានលើទំនៀម ទំលាប់ប្រពៃណី វប្បធម៌ និងជំនឿសាសនារបស់ប្រជាពលរដ្ឋក្នុង និងក្បែរតំបន់។ | |
| គ.៤ ការប្រើប្រាស់ទឹក | • អាចនឹងមានការប៉ះពាល់ដល់បរិមាណ និងគុណភាពទឹកស្ទឹង ពោធិ៍សាត់នេះ ក្នុងការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋនៅតំបន់ ផ្នែកខាងក្រោម ដោយសារទឹកក្នុងអាងស្តុកមានគុណភាពមិនល្អ និងមានក្លិនស្អុយ មកពីការរលួយពីរុក្ខជាតិដែលលិចទឹក និងការខ្វះ អុកស៊ីសែនរបស់ទឹក និងជាពិសេសអាចមានការខ្វះទឹកសម្រាប់ប្រព័ន្ធ ស្រោចស្រពដំណាក់អាំពិល និងចារីក។<br>• ការគ្រប់គ្រងសំណល់រឹង/រាវ ដែលចេញពីការិយាល័យ ផ្ទះ បុគ្គលិក/កម្មករ ឃ្លាំងស្តុកសម្ភារ រោងជាងជាដើម ដែលធ្វើឱ្យ ខូចដល់ប្រភពទឹកសម្រាប់ផ្គត់ផ្គង់ក្នុងតំបន់។<br>• អាចមានការកើនឡើងនៃភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដែល ចង់ទៅទស្សនាកំសាន្តជ្រលងភ្នំ ព្រៃព្រឹក្សា ស្ទឹងអូរធម្មជាតិ និង ទស្សនានៅតំបន់ទំនប់វារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ និងវារីអគ្គិសនីស្ទឹងអាតៃ ក្រោយពីមានការសាងសង់រួច ពីព្រោះមានផ្លូវ ចេញចូលស្រួល ធ្វើឱ្យអាចកើតមានការបំពុលទឹកស្ទឹងដែលពាក់ព័ន្ធទាំងនោះ ដោយសារសំណល់រឹង-រាវ របស់ភ្ញៀវទេសចរណ៍ទាំងនោះ។ | | ✓ | | • ពេលដែលបំពេញទឹកក្នុងអាងរួចត្រូវធ្វើការសំអាតឈើដែលអណ្តែត ទឹកឱ្យបានស្អាត ដោយមានកញ្ចប់ថវិកាចំនួន ២០.០០០ដុល្លារអាមេរិក សម្រាប់ប្រតិបត្តិការនេះ មើលតារាង៨-២ ផ្នែក! លេខរៀង៤ ដើម្បីកុំឱ្យ មានការរលួយសំបកឈើ និងឈើខូចគុណភាពទឹកក្នុងអាង។<br>• សាងសង់សំណង់បំបែកចរន្តទឹក ដែលនៅខាងក្រោមអាគារថាមពល ដែលធ្វើឱ្យទឹកខ្វាយឡើង ហើយមានលទ្ធភាពស្រូបយកអុកស៊ីសែន បានគ្រប់គ្រាន់ និងធ្វើឱ្យទឹកលែងមានក្លិនស្អុយ។<br>• ក្នុងដំណាក់កាលនេះ គឺមានវិធានការដូចបានរៀបរាប់ក្នុងចំណុច គ.៤ នៃដំណាក់កាលសាងសង់គម្រោង ខាងលើរួចមកហើយ។ ប្រព័ន្ធស្រោចស្រព ដំណាក់អំពិលនិងចារីកនឹងទទួលបានទឹកបន្ថែមពីគម្រោងនេះយ៉ាងហោច ណាស់ចំនួន ៤០ម៉ែ/វិន. ដែលលំហូរធម្មជាតិមានត្រឹមតែ ០,៦ ដល់ ១,៦ម៉ែ/វិន. នៅរដូវប្រាំងតែប៉ុណ្ណោះ ដោយសារការបង្ហូរទឹកក្នុង ការផលិតអគ្គិសនីក្នុងដំណើរការមួយទួរប៊ីន (៤០ MW)។<br>• សាងសង់ប្រព័ន្ធសំអាតទឹក ដើម្បីផ្គត់ផ្គង់ ដល់បុគ្គលិក-កម្មករគម្រោង។<br>• អាងប្រព្រឹត្តកម្មសំណល់រាវសម្រាប់សំអាតទឹកកខ្វក់ពីការិយាល័យ ផ្ទះបុគ្គលិ-កម្មករដែលស្នាក់នៅ និងធ្វើការថែទាំអាងទាំងនេះ ហើយទឹកដែលបង្ហូរចេញពីអាងសំអាតនេះ ត្រូវមានកម្រិតតាមស្តង់ដា នៃការបញ្ចោញចោលពីប្រភពបំពុល ចូលទៅប្រភពទឹកសាធារណៈ ដែលមានចែងក្នុងអនុក្រឹត្យលេខ២៧ អនក្រ.បករបស់រាជរដ្ឋាភិបាល។<br>• ត្រូវចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងសំណល់រឹង-រាវ ដោយសាងសង់បង្គន់អនាម័យ ព្រមទាំងរៀបចំប្រមូលសំណល់រឹង និងសម្រាមយកទៅចោលនៅទីតាំងដែលមានសុវត្ថិភាព។<br>• ដើម្បីកែប្រែតំបន់នោះមានអនាម័យ និងបរិស្ថានល្អនោះ ក្រុមហ៊ុន នឹងធ្វើការសហការយ៉ាងជិតស្និតជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័ន ពាក់ព័ន្ធសម្រាប់ការងារនេះ។<br>• ក្រុមហ៊ុនវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ និងក្រុមហ៊ុនវារីអគ្គិសនីស្ទឹងអាតៃ ត្រូវសហការ | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | | | | | ជាមួយក្រសួងបរិស្ថាន ព្រមទាំងក្រសួងទេសចរណ៍ និងអាជ្ញាធរក្នុងការគ្រប់គ្រងដែនជម្រកសត្វព្រៃ/ព្រៃអភិរក្ស... ថៃរក្សាអនាម័យ និងបរិស្ថាន ដើម្បីបង្កើត ក្រុមការងារ ប្រមូលសម្រាមរួមមួយ ពីព្រោះគម្រោងទាំង២នេះស្ថិតក្នុង ខេត្តពោធិ៍សាត់តែមួយ។ | |
| គ.៥ តំបន់ទេសចរណ៍/រមណីដ្ឋាន/ទីកន្លែងកំសាន្ត ក្នុងដំណាក់កាលនេះមិនប៉ះពាល់ដល់ ផ្ទៃកនេះទេពោលគឺមានផលប៉ះពាល់វិជ្ជមានទៅវិញ ដោយសារមានផ្លូវចេញចូល ស្រួលអាចបង្កើតជាទេសចរណ៍ធម្មជាតិ និងអេកូទេសចរណ៍ទៀតផង។ | | | | | | |
| គ.៦ ផ្លូវគមនាគមន៍ | • អាចនឹងបង្កឱ្យប៉ះពាល់ ដល់ការប្រើប្រាស់ផ្លូវគមនាគមន៍របស់ ប្រជាពលរដ្ឋក្បែរតំបន់គម្រោង ដូចជាការបិទផ្លូវ មិនឱ្យប្រជាពល រដ្ឋចេញចូលជាដើម។<br>• មានចរាចរណ៍កើនឡើងធ្វើឱ្យមានការចង្អៀតលើដងផ្លូវការកកស្ទះចរាចរណ៍ ជាពិសេសអាចបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍ដោយសារការធ្វើដំណើររបស់ អ្នកទេសចរណ៍ ប្រជាពលរដ្ឋ និងបុគ្គលិក-កម្មកររបស់គម្រោងកាន់តែកើនឡើង ដោយស្ថានភាពផ្លូវតូច ចង្អៀត និងមានចំណោទជាដើម។ | | ✓ | | • ត្រូវធ្វើការចាក់កៅស៊ូលើកំណាត់ផ្លូវ ចាប់ពីចំណុចបំបែកនៃផ្លូវជាតិ៥៥ ដល់ទីតាំងទំនប់ និងអាគារថាមពល ដែលមានប្រវែងសរុប១២គ.ម ព្រមទាំងមានការថែទាំផ្លូវ នេះជាប្រចាំទៀតផង។<br>• ត្រូវអនុញ្ញាតឱ្យប្រជាពលរដ្ឋប្រើប្រាស់ផ្លូវ ដែលក្រុមហ៊ុនបានសាងសង់ សម្រាប់បម្រើឱ្យគម្រោងវារីអគ្គិសនីស្ទឹង ពោធិ៍សាត់១នេះផងដែរ។<br>• ត្រូវធ្វើការសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំដោះស្រាយ ចំពោះបញ្ហាផ្លូវ ដូចជាៈ ដាក់ស្លាកសញ្ញា ចរាចរតាមដងផ្លូវ ធ្វើរបាំងការពារ ត្រង់ផ្លូវកោង មានចំណោត និងបង្កើតប៉ុស្តិ៍ត្រួតពិនិត្យទំងន់រថយន្ត និងកម្ពស់ នៃការផ្ទុកជាដើម ពីព្រោះបើផ្ទុកធ្ងន់ និងខ្ពស់ងាយធ្វើឱ្យ រថយន្តងាយក្រឡាប់ និងបុកជញ្ជាំងភ្នំ។<br>• ត្រូវដាំឈើធ្វើជារបងធម្មជាតិតាមសងផ្លូវចេញចូល និងលើដីជម្រាល ដើម្បីទប់ស្កាត់ការហូរច្រោះ ការហុយធូលី សំឡេង និងធ្វើឱ្យមានសោភ័ណ្ឌភាព ទេសភាពល្អ។ | |

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| គ.៧ សុខភាពសាធារណៈ | • នៅក្នុងអាងអាចកើតមានរុក្ខជាតិទឹក ដូចជាចក កំប្លោក សារាយ ពើក និងសត្វល្អិតចង្រៃ ដូចជាមូស បាក់តេរី ឬសត្វល្អិត ដែលអាចបង្កជំងឺ និងចម្លងជំងឺទៅសត្វ(Zonotic Diseases) និងមនុស្សបានជាពិសេសជំងឺកើតឡើងពី ប្រភពទឹក (Waterborn diseases)។<br>• អាចបង្កឱ្យមានការប៉ះពាល់ដល់សុខុមាលភាព បុគ្គលិក-កម្មករ របស់ក្រុមហ៊ុន ដោយសារតំបន់នេះជាតំបន់កើតជំងឺគ្រុនចាញ់ គ្រុនសន្ធំ ។<br>• អាចបង្កឱ្យមានការប៉ះពាល់ដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់នេះ ដោយសារបុគ្គលិក-កម្មកររបស់ក្រុមហ៊ុនអាចចម្លងជំងឺផ្សេងៗដល់អ្នកភូមិក្បែរតំបន់គម្រោង ដូចជាជំងឺអេដស៍ ជំងឺកាមរោគ ។ល។<br>• ការគ្រប់គ្រងសំណល់រឹង-រាវ មិនបានល្អនៅតំបន់គម្រោង ការិយាល័យ កន្លែងស្នាក់នៅបុគ្គលិក គម្រោងនោះអាចនឹងមានការ ប៉ះពាល់ដល់សុខភាពសាធារណៈ ព្រមទាំងបុគ្គលិកគម្រោង។<br>• ការបើកបិទ ទឹកសម្រាប់ដំណើរការផលិតអគ្គិសនីនៅវដ្តប្រាំង ដែលមានធារទឹកពី ៤០ ដល់ ៨០ ម៉ែ/វិនាទី ដែលមុនការសាងសង់គម្រោងមានតែ ០.៦ ទៅ ១.៦ម៉ែ/វិន. (ជាលក្ខណៈធម្មជាតិ) នាំឱ្យមានការប៉ះពាល់ដល់ប្រជាពលរដ្ឋ អ្នកនេសាទ ឧបករណ៍នានា ដែលមាននៅក្នុងពោះស្ទឹង។ ជួនកាលអាច បណ្តាលឱ្យលិច តំបន់មួយចំនួននៅខាងក្រោម ដោយសារធារទឹក ៨០ ម៉ែ/វិនាទី នេះផងដែរ។<br>• អាចមានគ្រោះថ្នាក់ដល់អាយុជីវិតប្រជាពលរដ្ឋ ឬទេសចរណ៍ ដែលទស្សនានៅតាមគន្លងខ្សែបញ្ជូនអគ្គិសនី ២៣០kV ដែលងាយរង ឥទ្ធិពលដែនអគ្គិសនី ភ្លុចរាំងឧចស្បងអេឡិកត្រូស្តាទិក និងអេឡិកត្រូម៉ាញេទិកនៅពេលភ្លៀង (នៅតាមគន្លងខ្សែ៩គ.ម ពីស្ថានីយផលិតថាមពលនៃអាគារថាមពលរបស់គម្រោងនេះឆ្ពោះ ទៅបណ្តាញខ្សែ២៣០គ.វ៉ អូរសោម-ពោធិ៍សាត់)។ | | | ✓ | • ត្រូវធ្វើការពិនិត្យតាមដាន គុណភាពទឹកក្នុងអាង និងក្រៅអាងឱ្យទៀងទាត់ជាប្រចាំ ប្រសិនបើគុណភាពទឹកក្នុង ឬក្រៅអាងមានការបំពុល ក្រុមហ៊ុននឹងរិះរកមធ្យោបាយ ដើម្បីធ្វើការកាត់បន្ថយដោយសហការណ៍ ជាមួយស្ថាប័នពាក់ពន្ធ័។<br>• ត្រូវត្រៀមបំពាក់ឧបករណ៍-សម្ភារ និងអ្នកឯកទេសសម្រាប់សំអាត រុក្ខជាតិទឹក និងសត្វល្អិតចង្រៃដែលនឹងអាចកើតមាននៅក្នុងអាងស្តុក របស់គម្រោង។<br>• នឹងធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិក-កម្មករ ដើម្បីទប់ស្កាត់ជំងឺ ទាំងនោះកុំឱ្យកើតមាន និងឆ្លងទៅប្រជាពលរដ្ឋក្នុងតំបន់នោះ។<br>• ត្រូវធ្វើការសហការជាមួយស្ថាប័នសុខាភិបាល ដើម្បីទប់ស្កាត់ជំងឺ ឆ្លង ដែលកើតឡើងជាយថាហេតុ។<br>• ធ្វើការថែទាំអាងសិបទិក សម្រាប់ប្រព្រឹត្តិកម្មសំណល់រាវសម្រាប់សំអាត ទឹកកខ្វក់ជាប្រចាំ ដើម្បីឱ្យវាមានសមត្ថភាពក្នុងការសំអាតទឹកសំអុយនេះ ឱ្យមានកម្រិតតាមស្តង់ដានៃការបញ្ចេញចោលពីប្រភពបំពុលចូលទៅ ប្រភពទឹកសាធារណៈ ដែលមានចែងក្នុងអនុក្រិត្យលេខ ២៧អនក្រ.បក របស់រាជរដ្ឋាភិបាល។<br>• មុនពេលបើកទឹកដំណើរការផលិតអគ្គិសនី ត្រូវផ្តល់ដំណឹងប្រាប់ឱ្យដឹងមុន១៥ ទៅ៣០ នាទី តាមការការបំពាក់ឧបករណ៍ផ្តល់សញ្ញាគ្រោះថ្នាក់ និងបន្លឺស៊ីរ៉ែនជាដើម នៅតំបន់ខាងក្រោមអាគារថាមពល ដែលមានមនុស្សរស់នៅ ចម្ងាយ យ៉ាងតិច ៥០គ.ម តាមដងស្ទឹង ដើម្បីឱ្យអ្នករស់នៅខាងក្រោមនេះបានដឹង និងរត់គេច មកទីទួលសុវត្ថិភាព នៅពេលដែលបើកទឹកដំណើរការទួប៊ីនម្តងៗ (ទួប៊ីន១ បញ្ចេញទឹក៤០ម៉ែ/វិន. ទួប៊ីនពីរ ៨០ម៉ែ/វិន.។ ប្រសិនបើមានការលិចលង់តំបន់កសិកម្មរបស់ប្រជាពលរដ្ឋ ឬខូចខាតដល់ទ្រព្យសម្បត្តិ ឬដំណាំនានា ដោយសារប្រតិបត្តិគម្រោងនេះ ម្ចាស់គម្រោងជាអ្នកទទួលខុសត្រូវចេញសំណងតាមតម្លៃទីផ្សារ។ ប្រសិនបើ មន្ត្រីជំនាញ របស់ក្រសួងពាក់ព័ន្ធតម្រូវឱ្យ មានវិធានការការពារ កន្លែងលិច ដូចជាសាងសង់ទំនប់អមសងខាងច្រាំងស្ទឹង ម្ចាស់គម្រោងជាអ្នកទទួលខុសត្រូវចំណាយទាំងស្រុង។<br>• សាងសង់បង្គោលឱ្យខ្ពស់ ដែលធ្វើយ៉ាងណាឱ្យគម្លាតខ្សែដក់មកដីមាន កម្ពស់១០ម យ៉ាងតិច ដើម្បីការពារកុំឱ្យមានគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋ អ្នកទេសចរណ៍ និងអ្នកដំណើរនានា។<br>• ត្រូវធ្វើការផ្សព្វផ្សាយជាប្រចាំអំពីគ្រោះថ្នាក់ក្នុងន័យអប់រំ និងដាក់ ស្លាកជា អក្សរខ្មែរ អង់គ្លេស និងរូបមិនឱ្យមនុស្សមករស់នៅ ឬលើកបង្គោល ឬ ឡើងបង្គោលអគ្គិសនី ឬ ដាំដើមឈើ ក្នុងតំបន់គន្លងខ្សែអគ្គិសនីនេះ ។ | |
| គ.៨ សោភ័ណ្ឌភាព/ទេសភាព | • ការចោលសម្រាម និងការបន្ទោបង់ដោយគ្មានសណ្តាប់ធ្នាប់ពី សំណាក់ភ្ញៀវទេសចរណ៍ មកកំសាន្ត ប្រជាពលរដ្ឋ និងបុគ្គលិក-កម្មកររបស់គម្រោងធ្វើឱ្យបាត់សោភ័ណ្ឌភាពក្នុងតំបន់។ | | ✓ | | • ក្រុមហ៊ុនវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ (KTC) និងក្រុមហ៊ុនវារី អគ្គិសនីស្ទឹងអាតៃ (C.H.D.) នឹងសហការជាមួយក្រសួងបរិស្ថាន ព្រមទាំងក្រសួងទេសចរណ៍ និងអាជ្ញាធរមូលដ្ឋានក្នុងការគ្រប់គ្រង ថែរក្សាអនាម័យ និងបរិស្ថានដោយបង្កើតក្រុមការងារ | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | | | | | ប្រមូលសម្រាម យកទៅចោលនៅទី ដែលមានសុវត្ថិភាព។ | |
| គ.៩. ហានិភ័យ | • ហានិភ័យនឹងអាចកើតមានដោយសារ ការធ្វេសប្រហែសផ្នែក សន្តិសុខ និងអំពើភេរវកម្ម ឬសង្គ្រាម។<br>• រីឯបាតុភូតគ្រោះធម្មជាតិក៏អាចនឹងកើតមានដូចជាៈ ការរញ្ជួយដី នៅក្នុងតំបន់គម្រោងការទទួលរងឥទ្ធិពលពីព្យុះភ្លៀង ទីហ្វុង ឬព្យុះផ្សេងទៀតពីឈូងសមុទ្រថៃ ដែលបង្កឱ្យមាន មហន្តរាយធំៗដូចជាៈ ការបាក់ទំនប់ និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គម្រោង ជាពិសេសការធ្វើឱ្យរងរបួស និងស្លាប់បាត់ បង់ជីវិតដល់បុគ្គលិក-កម្មករ និងប្រជាពលរដ្ឋនៅក្នុង និងក្បែរ ខាងតំបន់គម្រោង ។<br>• ការកើតមានការរញ្ជួយដី និងការបាក់ទំនប់ និងបាក់ភ្នំនាថ្ងៃអនាគត ដោយសារទំងន់ និងសំពាធទឹកក្នុងរាងស្តុកទឹកដែល មានចំណុះ១.២២៦,៩លានម៉ែត្រគូប ដែលនាំឱ្យខូចខាត បាត់បង់ទ្រព្យសម្បត្តិ ផ្ទះសម្បែង សត្វពាហនៈ ផលដំណាំ និងបាត់បង់អាយុជីវិតរបស់ប្រជាពលរដ្ឋ ដែលរស់នៅតាមដងស្ទឹងពោធិ៍សាត់ មានចាប់ពីចំណុចត្រពងពង្ស ឃុំប្រមោយស្រុកវាលវែង រហូតដល់ឃុំកញ្ជរ ស្រុកកណ្តៀងខេត្តពោធិ៍សាត់ជាប់មាត់បឹងទន្លេសាប។ ***បញ្ជាក់៖*** *ហេតុការណ៍នេះនឹងមិនមានការកើតឡើងជាដាច់ខាត ព្រោះវាជាអាយុជីវិត របស់ក្រុមហ៊ុនផងដែរ។*<br>• ការឆេះព្រៃក្នុងតំបន់គម្រោងដែលបណ្តាលមកពីការធ្វេសប្រហែស ឬអំពើភេរវកម្មក៏អាចបង្កឱ្យមានមហន្តរាយ/គ្រោះថ្នាក់ធំដល់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គម្រោង ធនធានធម្មជាតិក្នុងតំបន់ និងអាយុជីវិតមនុស្សទៀតផង។<br>• ការកើតមានសង្គ្រាមឈ្លានពានលើបូរណភាពទឹកដី នៃប្រទេសកម្ពុជា និងសង្គ្រាមផ្ទៃក្នុងក៏ជាឧបសគ្គដល់កិច្ចដំណើរការ និងថែទាំ គម្រោងជូនកាលសង្គ្រាមអាចបំផ្លាញគម្រោងទាំងស្រុងទៀតផង។ | | | ✓ | • ត្រូវធ្វើការសិក្សាតាមដានបន្ថែមទៀត នៅក្នុងដំណាក់កាលនេះ លើហេតុការណ៍ប្រែប្រួលលើកត្តាធម្មជាតិ និងអត្តសញ្ញាណនានា ដែលអាចឈានទៅដល់ការបាក់ទំនប់ និងការបាក់ភ្នំក្នុងតំបន់គម្រោងវារី អគ្គិសនីស្ទឹងពោធិ៍សាត់នេះ។<br>• រីឯបញ្ហាដែលកើតឡើងពីការធ្វេសប្រហែសផ្នែកសន្តិសុខ ឬភេរវកម្មនោះវិញ ក្រុមហ៊ុនត្រូវប្រុងប្រយ័ត្នគ្រប់វិធានការក្នុងការការពារសន្តិសុខចំពោះគ្រឿងផ្ទុះនានាអគ្គិភ័យនានា និងធ្វើសហប្រតិបត្តិការណ៍ ជាមួយស្ថាប័នមានសមត្ថកិច្ច ដើម្បីទប់ស្កាត់រាល់អំពើភេរវកម្មក្នុងតំបន់គម្រោង។<br>• នឹងធ្វើការផ្សព្វផ្សាយរាល់ហេតុការណ៍ ដែលអាចបង្កដល់ការបាក់ទំនប់ ការបាក់ភ្នំ ឬការរញ្ជួយដី ក្នុងតំបន់គម្រោងដល់ប្រជាពលរដ្ឋដែលរស់ក្នុង និងក្បែរខាងគម្រោងនេះទាំងអស់ឱ្យបានជ្រាបហេតុការណ៍ខាងលើបានទាន់ពេលវេលាតាមតែអាចធ្វើទៅបាន បើសិនជាមានហានិភ័យបែបនេះ កើតឡើង។<br>• ត្រូវបង្ហូរទឹកឱ្យអស់ពីអាងនៅពេលមានបញ្ហាគ្រោះថ្នាក់ ដោយចៃដន្យ ដូចជាៈ ការរញ្ជួយដី ឬសង្គ្រាម។<br>• ត្រូវរៀបចំបំរុងទុកនូវក្រុមអ្នកជួយសង្គ្រោះ សម្ភារ និងថវិកាដើម្បី ធានាការដោះស្រាយផលប៉ះពាល់ដែលនឹងអាចកើតពី មហន្តរាយខាងលើនេះ ទាន់សភាពការណ៍និងមានប្រសិទ្ធិភាព។<br>• ជាទូទៅ ហានិភ័យដែលកើតឡើងពីការបាក់ទំនប់ កម្រនឹងកើតមានណាស់ ព្រោះវាទាក់ទងនិងថវិកាក្រុមហ៊ុនផ្ទាល់ តែប្រសិនបើមានហានិភ័យនេះមែនក្រុមហ៊ុន រកក្រុមហ៊ុនធានារ៉ាប់រងអន្តរជាតិ សងការខូចខាត ដល់អ្នករងគ្រោះ តាមស្តង់ដារអន្តរជាតិក្នុងតំបន់ពោលគឺក្រោយពីការសាងសង់គម្រោងនេះ ចប់ម្ចាស់គម្រោងត្រូវរកក្រុមហ៊ុនបរទេសដើម្បីធានារ៉ាប់រងលើគម្រោងនេះ។ | |

## ៣. ដំណាក់កាលបិទគម្រោង

ក្នុងដំណាក់កាលបិទគម្រោងរបស់ក្រុមហ៊ុនKTC នៃប្រទេសកូរ៉េនេះនឹងធ្វើឡើងក្រោយពីចប់កិច្ចសន្យាជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្រោយពេលដំណើរការបានតាមកិច្ចសន្យាអភិវឌ្ឍគម្រោងមក (ជាទូទៅរយៈពេល៣០ឆ្នាំ ក្រោយដំណាក់កាលសាងសង់គម្រោង)ហើយចំពោះការផ្ទេរហេដ្ឋារចនាសម្ព័ន្ធ វារីអគ្គិសនីនេះនឹងមានចែងលម្អិតនៅក្នុងកិច្ចសន្យា។ រាជរដ្ឋាភិបាលកម្ពុជានឹងទទួលបន្ត ធ្វើការគ្រប់គ្រងបន្ត ដូចនេះសកម្មភាពបិទគម្រោងអាស្រ័យទៅនឹងរដ្ឋាភិបាលកម្ពុជាសម្រេចខ្លួន ឯងហើយសង្ឃឹមថាក្នុងដំណាក់កាលបិទ គម្រោងរបស់ ក្រុមហ៊ុនកូរ៉េនេះពុំមានការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ ដែលគួរឱ្យកត់សម្គាល់ឡើយ។ (ចំពោះបទដ្ឋានបច្ចេកទេស និងគុណភាពរបស់ហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនីដែលនឹងត្រូវប្រគល់ជូនរាជរដ្ឋាភិបាលវិញមានចែងលម្អិតក្នុង កិច្ចសន្យានោះហើយ)។

ជាងនេះទៅទៀតក្រុមហ៊ុនត្រូវធ្វើផែនការច្បាស់លាស់ នៃការជុសជុលរាល់ការខូចខាតនៃសំណង់ពាក់ព័ន្ធនានា របស់គម្រោង និងត្រូវសំអាតសំណល់រឹង-រាវ គ្រប់ប្រភេទចេញពីការដ្ឋាន កន្លែងស្នាក់នៅរបស់បុគ្គលិក-កម្មករ គម្រោង រោងជាង ចំណត យានយន្ត ឃ្លាំង ផ្ទះបាយជាដើម ដោយសំណល់ទាំងនោះត្រូវធ្វើកន្លែងទុកដាក់ឱ្យមានសុវត្ថិភាពបរិស្ថានល្អ។

## ៧.៦ ហេតុប៉ះពាល់បរិស្ថានសំខាន់ៗ និងវិធានការកាត់បន្ថយ នៃប្រព័ន្ធខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០គ.វ៉

**មូលដ្ឋានគ្រឹះសម្រាប់ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសំខាន់ៗ និងឯកសារបច្ចេក និងសកម្មភាពសិក្សាសម្រាប់ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសំខាន់ៗ:**

គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ នៅស្រុកវាលវែង ខេត្តពោធិ៍សាត់នេះ នឹងត្រូវផលិតថាមពលអគ្គិសនី ដោយប្រើចរន្តទឹក បានក្នុង១ឆ្នាំ ប្រមាណ៣៦៧,១២លាន kWh ហើយថាមពលដែលផលិតបាននេះ ត្រូវការសាងសង់ខ្សែបញ្ជូនអគ្គិសនីតង់ស្យុង ខ្ពស់២៣០គ.វ៉ ពីវារអាគារថាមពល មកតភ្ជាប់បណ្តាញជាមួយនិង ខ្សែ២៣០គ.វ៉ អូរសោម-ខេត្តពោធិ៍សាត់ ដែលមានប្រវែងប្រមាណ ៥គ.ម និងមានចំនួនប៉មបង្គោលដែក ចំនួន១៣ បង្គោល។

យោងតាម Feasibility Study របស់គម្រោងវារីអគ្គិសនីពោធិ៍សាត់១ ផ្អែកប្រព័ន្ធខ្សែបញ្ជូនតង់ស្យុងខ្ពស់របស់ក្រុមហ៊ុននិងការសិក្សាជាក់ស្តែងក្នុងការអង្កេតសិក្សាស្រាវជ្រាវ និងការប្រជុំពិភាក្សាជាមួយសហគមន៍/ប្រជាពលរដ្ឋមូលដ្ឋាន អង្គការនានា និងស្ថាប័នជាប់ទាក់ទងនឹងគម្រោងគ្រប់ជាន់ថ្នាក់ លើទីតាំងគម្រោង និងហេដ្ឋារចនាសម្ព័ន្ធគម្រោង ការងារសាងសង់គម្រោង និងកិច្ចដំណើរការរបស់វា ដើម្បីធ្វើការប៉ាន់ប្រមាណ ស្វែងរក និងវាយតម្លៃហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងបរិស្ថានសង្គមពេញលេញ ក្នុងដំណាក់កាលរចនាគម្រោង (Project Design) សាងសង់ (Project Construction) ប្រតិបត្តិ និងថែទាំគម្រោង (Project Operation & Maintenance) ហើយនិងដំណាក់កាលបិទគម្រោង (Project Closure)។ ហេតុប៉ះពាល់ បរិស្ថានទាំងនោះ ត្រូវរកវិធានការកាត់បន្ថយ និងធ្វើផែនការគ្រប់គ្រងបរិស្ថាននៃដំណាក់កាលរបស់គម្រោងទាំងនោះដោយមានការអនុវត្ត ពីម្ចាស់គម្រោងរួមកិច្ចសហការត្រួតពិនិត្យពីបណ្តាស្ថាប័ន និងអង្គភាព ជំនាញពាក់ព័ន្ធ ដូចជាមន្ទីរបរិស្ថានខេត្ត មន្ទីរធនធានទឹក និងឧតុនិយមខេត្ត មន្ទីររ៉ែ និងថាមពលខេត្ត មន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត មន្ទីរកសិកម្ម រុក្ខា ប្រមាញ់និងនេសាទ(ជំនាញព្រៃឈើ និងជលផល) ខេត្ត អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ តាមរយៈការគ្រប់គ្រង នៃខ្សែបណ្តោយពីក្រសួង សាមុីនីមួយៗ។

ផ្អែកទៅស្តង់ដាបច្ចេកទេសអគ្គិសនីរបស់ក្រសួងរ៉ែ និងថាមពល ដែលបានកំណត់ផ្អែកលើស្ថានភាពជាក់ស្តែងមួយចំនួន និងផ្អែកលើមូលដ្ឋាន នៃការសិក្សាជាក់ស្តែងលើហេតុប៉ះពាល់ នៃការសាងសង់ខ្សែបញ្ជូនតង់ស្យុងខ្ពស់២៣០គ.វ៉ របស់គម្រោងនេះមាន ដូចខាងក្រោម ៖

- ការរស់នៅរបស់ប្រជាពលរដ្ឋ និងដើមឈើ ដែលមានកម្ពស់ខ្ពស់ជាង៣ម៉ែត្រ ស្ថិតនៅក្រោមគន្លងខ្សែគិតពីអក្សនៃបង្គោលខ្សែចំលងអគ្គិសនីនេះចំនួន១៥ម៉ែត្រ សងខាងនឹងត្រូវចាត់ទុកថាការរស់នៅរបស់ប្រជាពលរដ្ឋ រួមទាំងលំនៅដ្ឋាន និងដើមឈើទាំងនោះ នឹងត្រូវប៉ះពាល់អវិជ្ជមាន ជាមួយសំណង់ខ្សែបញ្ជូនតង់ស្យុងខ្ពស់២៣០គ.វ៉ ខាងលើនេះ។
- ដីធ្លី (ដីកសិកម្ម ដីលំនៅដ្ឋាន ដីត្រៀមបំរុងទុក ដែលជាកម្មសិទ្ធរបស់ឯកជន, កម្មសិទ្ធឯកជនរបស់រដ្ឋ និងជាកម្មសិទ្ធ សាធារណៈរបស់រដ្ឋ) ដែលចាត់ទុកមានផលប៉ះពាល់អវិជ្ជមាននោះ គឺជាប្រភេទដីស្ថិតនៅទីតាំងសាងសង់បង្គោលទ្រខ្សែ អគ្គិសនីចំនួន១៣បង្គោល ដែលមួយបង្គោលត្រូវការផ្ទៃដីទំហំ ១៥ម. x ១៥ម.។

  ក្នុងទំហំ ១៥ម គុណ ១៥ ម =២២៥ម$^{២}$ ។




Draft

## រូបភាពការប៉ះពាល់ដោយសារខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់

ដើម្បីសម្រួល និងជំនួយការសិក្សា វ.ហ.ប ក្រុមការងារ SAWAC បានយកគោលការណ៍ណែនាំ វ.ហ.ប របស់ធនាគារអភិវឌ្ឍន៍អាស៊ីតែក្នុងការប្រើប្រាស់តារាង Checklist (យកតែទំរង់គំរូនៃក្រដាសនេះប៉ុណ្ណោះ) សម្រាប់ដំណើរ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនេះ ពីព្រោះវាជួយកណត់គោលដៅក្នុងការសិក្សាឱ្យបានច្បាស់លាស់។

ជាមួយគ្នានេះដែរ ក្រុមការងារនេះបានធ្វើតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន នៃប្រកាសស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ លេខៈ៣៧៦ ប្រក ប.ស្ត ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ ផងដែរ។

ក្រុមការងារ SAWAC បានប្រើប្រាស់នូវតារាង Checklist ទាំងពីរខាងលើនេះ សម្រាប់ដំណើរវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញលើគម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ដូចខាងក្រោមៈ

**តារាង ៧-៣: តារាង Checklist សម្រាប់កំណត់ផលប៉ះពាល់ និងមិនប៉ះពាល់ដោយខ្សែបញ្ជូនអគ្គិសនីអគ្គិសនីតង់ស្យុងខ្ពស់ របស់ADB**

| ក. ទីតាំងគម្រោង:<br><br>តើតំបន់គម្រោងនៅក្នុងឬក្បែរតំបន់បរិស្ថានសំខាន់ៗដូចខាងក្រោមដែរ ឬទេ? | មាន | គ្មាន | កត់សម្គាល់ |
|---|---|---|---|
| • ទីតាំងមរតកវប្បធម៌ | | ✓ | នៅក្នុងតំបន់ប្រពន្ធ័ខ្សែនេះ គ្មានតំបន់ប្រាសាទបុរាណ ឬកន្លែង មរតក វប្បធម៌នោះទេ ។ |
| • តំបន់ការពារ/អភិរក្ស | ✓ | | តំបន់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ចំនួន ១៣.៦៤ ហ.ត ។ |
| • តំបន់ដីសើម | | ✓ | នៅក្នុងតំបន់គម្រោងគ្មាន តំបន់ដីសើម ឬវាលភក់ ដែលសំខាន់ៗ ដែលរងផលប៉ះពាល់ដោយសារគម្រោងនោះទេ។ |
| • កោងកាង | | ✓ | នៅក្នុងតំបន់គម្រោងគ្មានតំបន់ព្រៃកោងកាង ដែលរង ផលប៉ះពាល់ ដោយសារគម្រោងនោះទេ ។ |
| • មាត់ពាម (តំបន់ទឹកភ្លាវ) | | ✓ | នៅក្នុងតំបន់ប្រពន្ធ័ខ្សែនេះ គ្មានតំបន់មាត់ពាម ដែល រង ផលប៉ះពាល់នោះទេ ។ |
| • តំបន់ទ្រនាប់នៃតំបន់ការពារ/អភិរក្ស (ព្រៃសហគមន៍) | | ✓ | នៅក្នុងតំបន់ប្រពន្ធ័ខ្សែនេះគ្មានតំបន់រងផលប៉ះពាល់ ដល់តំបន់ ព្រៃសហគមន៍នោះទេ ។ |
| • តំបន់ពិសេសសម្រាប់ការពារ/អភិរក្សជីវចម្រុះ | ✓ | | តំបន់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ចំនួន ១៣.៦៤ ហ.ត ។ |
| ខ. ផលប៉ះពាល់បរិស្ថានសំខាន់ៗ<br><br>តើគម្រោងនឹងបង្កឱ្យ...... | | | |
| • មានទីតាំងស្ថិតនៅតំបន់ប្រវត្តិសាស្ត្រ/វប្បធម៌ និងធ្វើឱ្យបាត់បង់ សោភណ្ឌ័ភាពទេសភាព ហើយមានបញ្ហាញសំណល់ច្រើនដែរ ឬទេ? | | ✓ | មិនតំបន់ប្រវត្តិសាស្ត្រ/វប្បធម៌ នឹងត្រូវប៉ះពាល់នោះទេ។ |
| • ការតន្ទ្រានចូលតំបន់ប្រពន្ធ័អេកូឡូស៊ីសំខាន់ៗ (ដូចជាតំបន់ការពារ អភិរក្ស) ដែរឬទេ? | ✓ | | តំបន់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ |
| • ការសាងសង់មានការប៉ះពាល់ផ្លូវទឹកសំខាន់ៗ ដែលធ្វើឱ្យប្រែប្រួលដល់ប្រព័ន្ធជលសាស្ត្រដោយបង្កើនល្បាប់ដោយសារការហូរច្រោះនៃកន្លែងសារសង់ ដែរទេ? | ✓ | | អាចមានការហូរច្រោះនៅពេលធ្វើការសាងសង់ បង្គោល និងកន្លែងដាក់គ្រង់ស្គរ ។ |
| • មានការខូចខាតដល់តំបន់ដែលងាយរងគ្រោះតាមតំបន់ឆ្នេរ/ដែន ជម្រកសត្វសមុទ្រដោយសារការសង់ខ្សែដាក់ក្នុងសមុទ្រ ដែរឬទេ? | | ✓ | មិនមានតំបន់ឆ្នេរ ស្ថិតនៅក្នុងតំបន់ ឬ នៅក្បែរ នោះទេ។ |
| • មានការខូចខាតដល់គុណភាពទឹកលើដី ទឹកក្រោមដី ដោយសារសំណល់ រឹង រាវ ដែលបញ្ចេញពីកន្លែង ការដ្ឋានសាងសង់ដែរទេ? | ✓ | | អាចមានការប៉ះពាល់ដល់គុណភាពទឹកលើដីនិងក្រោមដី ដោយសារការគ្រប់គ្រងសំណល់រឹង រាវ មិនបាន ល្អ ជាពិសេស គ្មាន ឬខ្វះបង្គន់អនាម័យ ត្រឹមត្រូវតាមបច្ចេកទេស ក្នុងពេលសាងសង់គម្រោង។ |

| ក. ទីតាំងគម្រោង:<br><br>តើតំបន់គម្រោងនៅក្នុងឬក្បែរតំបន់បរិស្ថានសំខាន់ៗដូចខាងក្រោមដែរ ឬទេ? | មាន | គ្មាន | កត់សម្គាល់ |
|---|---|---|---|
| • ការបង្កើនការបំពុលខ្យល់ដោយសារ ការងារយកថ្ម ការងារដី (ការកិនថ្ម ការជីកដី ការចាក់បំពេញដី) ដែរឬទេ? | ✓ | | អាចមានការប៉ះពាល់ដល់គុណភាពខ្យល់ ក្នុងការសាងសង់ គម្រោង ដោយសារខ្វះបច្ចេកទេស ឬមិនគោរព តាមបទដ្ឋានបច្ចេកទេសនៃការងារទាំងនោះ។ |
| • តើមានការបំពុលដោយសារធាតុគីមី ដោយសារការប្រើសារធាតុនេះ សម្រាប់ការសំអាតព្រៃឈើ ដើមឈើ និងរុក្ខជាតិក្នុងការសាងសង់នេះ ដែរឬទេ? | | ✓ | ក្រុមហ៊ុនមិនប្រើសារធាតុគីមីក្នុងការសំអាតព្រៃឈើ ដើមឈើ និងដំណាំទេ ក្នុងការសាងសង់គម្រោងនេះទេ។ |
| • តើមានការបញ្ចោញសំឡេងរំញ័រដោយសារការបំផ្ទុះ និងការងារ ស៊ីវិលផ្សេងៗទៀត ដែរឬទេ? | ✓ | | អាចមានការរំខានដោយសំឡេង និងរំញ័រចេញមកពីការសាងសង់ គម្រោងនេះ(គ្រឿងចក្ររថយន្តកម្មករគម្រោង)។ |
| • តើមានការបំលាស់ប្តូរលំនៅដ្ឋានដោយមិនស្មគ្រ័ចិត្តរបស់ប្រជាពលរដ្ឋ ដែរឬទេ? | | ✓ | គ្មានការប៉ះពាល់ដល់លំនៅដ្ឋាន ឬដីកសិកម្មរបស់ប្រជាពលរដ្ឋនោះទេ ។ |
| • តើមានការទំនាស់សង្គមដែលទាក់ទងទៅនឹងកម្រិតជីវភាពរស់នៅធម្មតា របស់ប្រជាពលរដ្ឋ ដោយសារការរាំងស្ទះផ្លូវធ្លាប់ធ្វើចរាចរដែរឬទេ ? | | ✓ | |
| • តើអាចកើតមានគ្រោះថ្នាក់ចរាចរ ដោយសារ ការបើកបរដឹកជញ្ជូនសម្ភារក្នុងការសាងសង់ដែរឬទេ? | ✓ | | អាចនឹងកើតមានគ្រោះថ្នាក់ចរាចរដោយការធ្វេសប្រហែស ក្នុងការបើកបរ ដឹកជញ្ជូន សម្ភារសំណង់ និងសម្ភាររបស់ គម្រោងផ្សេងៗ។ |
| • តើមានការខ្វះអនាម័យ និងការខ្វះការគ្រប់គ្រងការសំណល់រឹង-រាវ នៅកន្លែងការដ្ឋានសាងសង់ ដែលធ្វើឱ្យប៉ះពាលដល់សុខភាពបុគ្គលិក-កម្មករ ហើយកើតមានការចំលងរោគទៅប្រជាជនមូលដ្ឋានឬទេ? | ✓ | | អាចនឹងមានការប៉ះពាល់ដល់សុខភាពបុគ្គលិក-កម្មករ ប្រជាពលរដ្ឋ ក្នុងតំបន់គម្រោងដោយសារ ការមិនយក ចិត្តទុកដាក់ ឬធ្វេសប្រហែសពីក្រុមហ៊ុនក្នុងការអប់រំ អនាម័យ ការត្រួតពិនិត្យសុខភាព និងការបំពាក់ ឧបករណ៍ដែលជាមធ្យោបាយបម្រើឱ្យសុខភាពសាធារណៈ ។ល។ |
| • តើមានការបង្កលក្ខណៈងាយស្រួលដល់ជម្រកមូស ដែលជាប្រភពចម្លងរោគដែរឬទេ? | ✓ | | អាចនឹងមានការប៉ះពាល់ដល់សុខភាពកម្មករ ឬប្រជាពលរដ្ឋក្នុងតំបន់គម្រោង ដោយសារការមិនយកចិត្តទុកដាក់ ឬធ្វេសប្រហែសពីក្រុមហ៊ុនក្នុងការអប់រំអនាម័យធ្វើឱ្យមានកន្លែងដក់ទឹកនៅក្នុងការដ្ឋានសំណង់។ |
| • តើមានការជំលៀសប្រជាពលរដ្ឋ ដោយខានពុំបានចេញពីចំណើខ្សែអគ្គិសនីនេះដែរឬទេ? (គិតពីអក្សបណ្តោលអគ្គិសនីចេញម្ខាង១៥ម សរុប ៣០ម) | | ✓ | គ្មានមានផ្ទះ និងដីប្រជាពលរដ្ឋរស់នៅក្នុងតំបន់នេះទេ។ |
| • តើមានការប៉ះពាល់ដីប្រើប្រាស់របស់ប្រជាពលរដ្ឋ ដោយសារការរស់នៅ ការដាំដំណាំយុទ្ធសាស្ត្រនៅក្រោមគន្លងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ គ វ៉ គិតពីអក្សបណ្តោលអគ្គិសនិចេញម្ខាងខាង១៥ម និងប៉ះដីប្រើប្រាស់ដោយ សារការសាងសង់បង្គោល ដែរឬទេ ? | | ✓ | គ្មានការប្រើប្រាស់ដីរបស់ប្រជាពលរដ្ឋក្រោមគន្លងខ្សែ នេះទេ ។ |
| • តើមានការប៉ះពាល់ផ្លូវ និងស្ទឹង ដោយសារ ខ្សែបញ្ជូនតង់ស្យុងខ្ពស់ | | ✓ | គ្មានការប៉ះពាល់ដល់ចរាចរតាមផ្លូវ ឬខ្សែឆ្លង កាត់ចរាចរ |

| ក. ទីតាំងគម្រោង:<br>តើតំបន់គម្រោងនៅក្នុងឬក្បែរតំបន់បរិស្ថានសំខាន់ៗដូចខាងក្រោមដែរ ឬទេ? | មាន | គ្មាន | កត់សម្គាល់ |
|---|---|---|---|
| ២៣០គ.វ៉ ឆ្លងកាត់ជិតពីអក្សបង្គោល អគ្គិសនីម្ខាង១៥ម ដែរឬទេ? | | | ឆ្លងទឹកនោះទេ។ |
| • តើមានការប៉ះពាល់ដល់បរិស្ថាន ដែលទាក់ទងទៅនិងការថែទាំ បណ្តាញខ្សែនេះដែរ ឬទេ? | ✓ | | អាចមានការប៉ះពាល់ដល់បរិស្ថានធម្មជាតិ និងសង្គម ដោយសារការធ្វេសប្រហែសក្នុង ការគ្រប់គ្រងសំណល់រឹង-រាវ ដែលចេញពីកន្លែងរស់នៅ និង ការធ្វេសប្រហែសឱ្យដើមឈើដុះខ្ពស់ ជាងកម្ពស់៣ម នាំឱ្យមាន គ្រោះថ្នាក់ដល់សត្វព្រៃ និងមនុស្ស។ |
| • តើមានបំពាក់ឧបករណ៍ការពារ ដែរឬទេ ក្នុងករណីខ្សែនេះកាត់តាមតំបន់អភិរក្ស ? | ✓ | | កន្លែងដាក់ត្រង់ស្វូរ មានបំពាក់ ប្រព័ន្ធផ្តាច់អគ្គិសនី ដោយស្វ័យប្រវត្តិដើម្បីការពារមិនឱ្យមានការទុស្សេ ដាច់ខ្សែអគ្គិសនី បង្កគ្រោះថ្នាក់ដល់មនុស្ស-សត្វ ឡើយ។ |
| • តើគ្រប់មធ្យោបាយ និងឧបករណ៍ ក្នុងការថែរទាំគម្រោងនេះមាន គ្រោះថ្នាក់ ដែរឬទេ ? | ✓ | | អាចមានគ្រោះថ្នាក់ក្នុងការ ថែទាំគម្រោង ដូចជាការជួសជុលខ្សែត្រង់ស្វូរ ទូរបញ្ជារប្រពន្ធ័អេឡិចត្រូនិកជាដើម ។ល។ |
| • តើមានគ្រោះថ្នាក់ដល់សុខភាពប្រជាពលរដ្ឋ ដោយសារដែនអេឡិចត្រូម៉ាញ៉េទិក អេឡិចត្រូស្តាទិក ដែលស្ថិតនៅក្រោមខ្សែ និង ជិតបង្គោលអគ្គិសនី ដែរឬទេ? | ✓ | | អាចមានគ្រោះថ្នាក់ដល់អ្នករស់នៅក្រោមចំណីខ្សែនេះ(១៥ម សងខាងអក្សបង្គោលអគ្គិសនី) នៅពេលអាកាស ធាតុសើម និងពេលមានភ្លៀងធ្លាក់ ដោយសារ ដែន អគ្គិសនីទាំងនេះ (ប្រសិនទៅថ្ងៃអនាគតមានអ្នកមក រស់នៅខុសច្បាប់)។ |
| • តើមានការបំពុលដោយសារធាតុគីមី ដែលប្រើប្រាស់សម្រាប់បង្អាក់ កុំឱ្យព្រៃឈើ ឬដំណាំរុក្ខជាតិ លូតបានខ្ពស់ ដែរឬទេ? | | ✓ | ក្រុមហ៊ុនមិនប្រើសារធាតុគីមីក្នុងការបង្អាក់ការលូត លាស់របស់ដើមឈើ និង រុក្ខជាតិនានានោះទេ។ |

## ៧.៧ ហេតុប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗនិងវិធានការកាត់បន្ថយនៃប្រព័ន្ធខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០គ.វ៉

### ៧.៧.១ ដំណាក់កាលមុនសាងសង់គម្រោង (រចនាគម្រោង) (Project Design)

ប្រព័ន្ធខ្សែអគ្គិសនីតង់ស្យុងខ្ពស់២៣០ គ.វ៉ មានប្រវែងប្រមាណ៥គ.ម ដែលក្រុមការងារ SAWAC កំណត់ជាតំបន់ ២ តំបន់នេះមានក្រឡាផ្ទៃ១៣.៦៤ ម² ស្ថិតក្នុងព្រៃការពាររបស់សង្កាត់រដ្ឋបាលព្រៃឈើប្រមោយ។ ខ្សែនោះវាមាន តួនាទីសំខាន់ណាស់ ក្នុងការនាំអគ្គិសនីពីអាគារថាមកតភ្ជាប់ជាមួយខ្សែបណ្តាញ ២៣០គ.វ៉ អូរសោម-ពោធិ៍សាត់ ត្រង់ចំណុចប្រកព្រាលនៃភូមិស្ទឹងថ្មី ឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ផលប៉ះពាល់អវិជ្ជមានដែលនឹងកើតចេញពីសកម្មភាពគម្រោងតាមដំណាក់កាលនីមួយៗ មានពិពណ៌នាតាមលំដាប់លំដោយខាងក្រោមនេះ។ ***បញ្ជាក់:*** *ចំពោះខ្សែបញ្ជូនអគ្គិសនីតង់ខ្ពស់២៣០គ.វ៉ នេះគឺមិនប៉ះពាល់ដល់បរិស្ថាន និងសង្គមធ្ងន់ធ្ងរទេ គឺប៉ះព្រៃស្រោងចំនួន១១.៣១ហ.ត និងព្រៃពាក់កណ្តាលស្រោង១,០៧ហ.ត ហើយដីនៅសល់០.៧៥ហ.តទៀតគឺ ដីផ្លូវរទេះ និងអូរ។*

### ក. ធនធានរូបសាស្ត្រ

សកម្មភាពការងារក្នុងដំណាក់កាលនេះគឺជាការសិក្សាលើស្ថានភាពជាក់ស្តែង ដើម្បីកំណត់ឱ្យបាននូវគន្លងខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ទីតាំងបង្គោលអគ្គិសនី ទីតាំងផលិតថាមពលវារីអគ្គិសនី និងសណ្ឋានដីនៅតាមទីតាំងគន្លងខ្សែគិតពីទីតាំងអាគារថាមពលដល់ខ្សែពីអូរសោម-ពោធិ៍សាត់ត្រង់បង្គោលអគ្គិសនីនៅចំណុចប្រកពាល ហើយការវិភាគ និងគំនូសប្លង់បច្ចេកទេសភាគច្រើន គឺធ្វើនៅ ប្រទេសកូរ៉េ។ ដូចនេះការប៉ះពាល់បរិស្ថានរូបសាស្ត្រ គឺពុំមានការប៉ះពាល់ ឡើយ។

## ខ. ធនធានជីវសាស្ត្រ

### ខ.១ តំបន់អភិរក្សព្រៃឈើ /ដែនជម្រកសត្វព្រៃ /ឧទ្យានជាតិ

➢ ហេតុប៉ះពាល់អវិជ្ជមាន

នៅក្នុងដំណាក់គ្រោងរចនានេះ អាចរំខានដល់ជម្រកសត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គម្រោង ដែលស្ថិតនៅក្នុងតំបន់ព្រៃការពាររបស់សង្កាត់រដ្ឋបាលព្រៃឈើប្រមោយខ្លះៗ ដែរដោយសារសកម្មភាពសិក្សាដូចជា មានសំឡេងអ៊ូអរ ការត្រួសត្រាយព្រៃ ធ្វើដំណើរខួងដីក្នុងការសិក្សាជាដើម។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនកំណត់ពេលវេលាធ្វើការតែពេលថ្ងៃ ដើម្បីមិនឱ្យរំខានសត្វព្រៃទេ។

ក្រុមហ៊ុនធ្វើការទំនាក់ទំនងជាមួយអជ្ញាធរមូលដ្ឋាន និងជំនាញពាក់ព័ន្ធ ដើម្បីចុះធ្វើការសិក្សានេះ ជៀសវាងការធ្វើឱ្យរំខាន ទីជម្រករបស់សត្វព្រៃ។

ក្រុមហ៊ុនត្រាយតែមែកឈើតូចៗ ដើម្បីធ្វើដំណើរចូលកន្លែងសិក្សា ដើម្បីទុកឱ្យព្រៃនោះអាចលូតលាស់ឡើងវិញ (តាមលក្ខណៈបច្ចេកទេសក្នុងការថែរក្សាព្រៃ ការត្រាយមែកឈើ អាចធ្វើឱ្យដើមលូតលាស់ប្រសើរជាងមុន)។

### ខ.២ ព្រៃឈើ និងជម្រកសត្វព្រៃ

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្រុមការងារសិក្សារបស់គម្រោង អាចរំខានដល់ជម្រកសត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គម្រោង ដោយសារការត្រួសត្រាយ ព្រៃ និងសំឡេងអ៊ូអររបស់បុគ្គលិក-កម្មករ ក្នុងការធ្វើដំណើរសិក្សា នៅទីតាំងមួយចំនួនតាមគន្លងខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០គ.វ៉ គឺពីអាគារថាមពល ឆ្ពោះទៅបង្គោលរបស់បណ្តាញខ្សែ២៣០គ.វ៉ អូរសោម-ពោធិ៍សាត់។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនកំណត់ពេលវេលាធ្វើការតែពេលថ្ងៃ ដើម្បីមិនឱ្យមានការរំខានដល់សត្វព្រៃឡើយ។

ក្រុមហ៊ុនធ្វើការសហការជាមួយអាជ្ញាធរមូលដ្ឋាន និងជំនាញពាក់ព័ន្ធក្នុងការសិក្សានេះ ដោយមិនឱ្យរំខានជម្រក និងការរស់នៅរបស់វានោះទេ។

ក្រុមហ៊ុនត្រាយតែមែកឈើតូចៗ សម្រាប់ធ្វើដំណើរចូលកន្លែងសិក្សាតែប៉ុណ្ណោះ ដើម្បីទុកឱ្យព្រៃនោះអាចលូតលាស់ឡើងវិញ ។

### ខ.៣ ជីវសាស្ត្រសត្វព្រៃ

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលរចនាគម្រោងនេះ អាចប៉ះពាល់ដល់ជីវសាស្ត្រសត្វព្រៃខ្លះដែរ ដោយសារសកម្មភាពសិក្សាគម្រោងនេះ គឺធ្វើឱ្យ ផ្អើលសត្វពេលដែលដើរសិក្សាតំរង់ទិស រកទីតាំងគម្រោង។ ម៉្យាងទៀតអាចមានការបរបាញ់ ដាក់អន្ទាក់សត្វព្រៃ ពីសំណាក់កម្មករ និយោជិតរបស់គម្រោង ។

តំបន់គម្រោងនេះមានសត្វព្រៃជាច្រើនប្រភេទដែលរស់នៅហើយ ប្រភេទសត្វមួយចំនួន កំពុងត្រូវបានធ្វើការអភិរក្ស។ ក្រុមការងារបានសិក្សាឃើញថា ថនិកសត្វមានចំនួន ៤៥ប្រភេទ បក្សី១០១ប្រភេទ ឧរង្គសត្វ-កង្កែប ៥៤ប្រភេទ មច្ឆជាតិ ទឹកសាប ៨៣ប្រភេទ ដូចមានចែងក្នុងជំពូក៥ ចំណុច៥.១.២.២ខាងលើនេះ។ សកម្មភាពសាងសង់ប្រព័ន្ធខ្សែអគ្គិសនីនេះអាចមានការប៉ះពាល់សត្វព្រៃ ខ្លះដែរ ដូចជា ស្វា ទោច ឈ្លូស ពពួកពស់ អណ្តើករស់នៅលើគោកជ្រូកព្រៃជាដើម ដោយសារបាត់ទីជម្រក ឬផ្តាច់ ផ្លូវទំនាក់ទំនង របស់វាជាពិសេស ពពួកស្វា ទោច អាចត្រូវឆក់ស្លាប់ ដោយសារខ្សែអគ្គិសនី ដែលមានតង់ស្យុងខ្ពស់នេះនៅពេលប្រតិបត្តិគម្រោង។

Draft

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនធ្វើការសិក្សាតែពេលថ្ងៃ ដើម្បីមិនឱ្យរំខានសត្វព្រៃទេ ពីព្រោះសត្វព្រៃភាគច្រើនរកស៊ីពេលយប់។

ក្រុមហ៊ុនត្រូវធ្វើការអប់រំដល់បុគ្គលិក និយោជិត កម្មកររបស់ខ្លួនមិនឱ្យសំលាប់សត្វព្រៃទេ ហើយមានការដាក់ពិន័យទៀតផង។

ម្ចាស់គម្រោង ត្រូវសហការយ៉ាងជិតស្និតជាមួយអាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធដើម្បីទប់ស្កាត់អ្នកប្រព្រឹត្តល្មើសបទល្មើសព្រៃឈើ និងសត្វព្រៃ។

ក្រុមហ៊ុនត្រូវគ្រោងបំពាក់គ្រឿងការពារសត្វព្រៃ និងមនុស្សមិនឱ្យឡើងបង្គោលអគ្គិសនី និងធ្វើការថែទាំជាប្រចាំនូវមែកឈើដើម្បីការ ពារពពួកសត្វទាំងនោះលោតតោងខ្សែនេះ ដែលធ្វើឱ្យពួកវាឆក់ស្លាប់ ជាពិសេសអាចដល់មានការដាច់ខ្សែអគ្គិសនីនេះទៀតផង។




Draft

រូបទី៣: បន្ទះដែកអ៊ីណុក ការពារសត្វ និងមនុស្សឡើង

**គ. ធនធានសេដ្ឋកិច្ចសង្គម**

**គ.១ ការប្រើប្រាស់ដី និងការតាំងលំនៅដ្ឋានឡើងវិញ**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលរចនាគម្រោងនេះ មិនមានការប៉ះពាល់ត្រង់ចំណុចនេះទេពីព្រោះ គ្មានប្រជាពលរដ្ឋរស់នៅក្នុងតំបន់ ហើយក៏គ្មានការប្រើប្រាស់ដីរបស់ប្រជាពលរដ្ឋតាមគន្លងខ្សែនេះដែរ។

**គ.២ ការប្រើប្រាស់ទឹក**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលរចនាគម្រោងនេះ ប៉ះពាល់ដល់សុខភាពអ្នកសិក្សាគម្រោង ដោយសារតំបន់នេះគ្មានផ្សារសម្រាប់លក់ទឹក សម្រាប់ផឹក ហើយក៏ជាតំបន់ព្រៃភ្នំមានភូមិប្រជាជនតិចតួចប៉ុណ្ណោះដែរ។

ចំណែកឯការសិក្សាគម្រោងនេះ មានការប៉ះពាល់តិចតួចដល់ប្រភពទឹក ដោយសារការបោះសម្រាមពីអ្នកសិក្សាទាំងនោះ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនធ្វើការផ្គត់ផ្គង់ទឹកផឹក ឱ្យបានទាន់ពេលវេលាដល់ក្រុមសិក្សា និងពន្យល់ អប់រំអ្នកទាំងនោះមិនឱ្យផឹកទឹកនៅបើការ ផ្គត់ផ្គង់ទឹកស្អាតមិនទាន់ ពោលគឺទឹកដែលដងពីរអូរ ឬស្ទឹងក្នុងតំបន់ត្រូវដាំពុះជាមុនសិនទើបផឹកបាន។

អប់រំផ្សព្វផ្សាយដល់អ្នកសិក្សាគម្រោងទាំងនោះ មិនឱ្យបោះសម្រាមពាសវាលពាសកាល សម្រាមត្រូវដាក់ក្នុងរណ្តៅរួចកប់វា ឱ្យបានល្អ ជៀសវាងបោះចោលក្នុង ឬក្បែរប្រភពទឹក។

**គ.៣ តំបន់ទេសចរណ៍**

ក្នុងដំណាក់កាលនេះ មិនប៉ះពាល់ដល់ផ្នែកនេះទេ ពីព្រោះតំបន់នេះមិនមានផ្លូវចេញចូលសម្រាប់អ្នកទេសចរណ៍ទេ ម្យ៉ាងទៀត ក្រុមអ្នកសិក្សាគម្រោងមានគ្នាយ៉ាងច្រើនបំផុត១៥ នាក់ប៉ុណ្ណោះ។

**គ.៤ ផ្លូវគមនាគមន៍**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលនេះ អាចមានការប៉ះពាល់ និងគ្រោះថ្នាក់ដល់អ្នកសិក្សាឬធ្វើឱ្យស្ទះការងារសិក្សាប្លង់រចនាគម្រោង ដោយសារ ស្ថានភាពផ្លូវធ្វើចរាចរទ្រុឌទ្រោម តូចចង្អៀត ផ្លូវចំណោតខ្លាំង ហើយកន្លែងខ្លះ គ្មានផ្លូវចូលសិក្សាទៀតផង។

ការប៉ះពាល់ដល់ព្រៃឈើដោយសារការធ្វើផ្លូវ និងគន្លងខ្សែអគ្គិសនី ច្រើនសាំញ៉ាំ ដែលបង្កឱកាសឱ្យជនខិលខូចកាប់ឈើ និង ដឹកជញ្ជូនឈើបានដោយងាយស្រួល។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនរកអ្នកនាំផ្លូវដែលស្គាល់ភូមិសាស្ត្រច្បាស់លាស់ក្នុងមូលដ្ឋានតំបន់គម្រោង។

ក្រុមហ៊ុនធ្វើការទំនាក់ទំនងជាមួយមន្ទីររ៉ែ និងថាមពលខេត្តពោធិ៍សាត់ និងមន្ទីរពាក់ព័ន្ធ ដើម្បីរកមធ្យោបាយចូលទៅទីតាំងគម្រោង ដោយសុវត្ថិភាពក្នុងការសិក្សានេះ។

ក្រុមហ៊ុនធ្វើការសិក្សារកផ្លូវរទេះចាស់ៗ ហើយគ្រោងគន្លងខ្សែអគ្គិសនីឱ្យស្របតាមបណ្តោយផ្លូវ (ចេញពីអ័ក្សផ្លូវចាប់ពី ៧០ម -១០០ម) ទោះជាផ្លូវនោះវាងក៏ដោយ ដើម្បីកាត់បន្ថយការកាប់ព្រៃឈើបន្ថែមលើកលែងតែកន្លែងខ្លះៗ ដែលស្ថិតនៅក្នុងអាង ឬក្នុងស្ទឹង។

**គ.៥ សុខភាពសាធារណៈ**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលរចនាគម្រោងនេះ អាចបង្កឱ្យមានការប៉ះពាល់ដល់សុខុមាលភាពបុគ្គលិក-កម្មករ របស់ក្រុមហ៊ុន ដោយសារ តំបន់គម្រោងជាតំបន់កើតជំងឺគ្រុនចាញ់ គ្រុនសន្និ។ល។ បន្ថែមពីនេះទៀត តំបន់ខ្លះ នៃតំបន់គម្រោងមានគ្រាប់មីន និងមានដាក់អន្ទាក់សត្វ ហើយមានពពួកសត្វសាហាវ និងអសិរពិស ជាពិសេសដោយសារជនប្រដាប់អាវុធអនាធិបតេយ្យ ដើរបរបាញ់សត្វ កាប់ឈើខុសច្បាប់ ដែលអាចធ្វើឱ្យក្រុមសិក្សាគម្រោងមានគ្រោះថ្នាក់ដល់ជីវិតផងដែរ។

***សម្គាល់:*** *នៅពេលក្រុមការងារ SAWAC ធ្វើការសិក្សាព្រៃឈើក្នុងតំបន់គម្រោង មានជនប្រដាប់អាវុធបានបាញ់សំដៅមកក្រុមការងារពីចម្ងាយ តែសំណាងល្អ មិនមានប៉ះ ពាល់ ឬគ្រោះថ្នាក់អ្វីទេ ដល់ នណាម្នាក់ទេ ហើយក្រុមការងារបានរាយការណ៍ទៅ អាជ្ញាធរមូលដ្ឋាន និងឧទ្យានុរក្សពីបញ្ហានេះផងដែរ។*

ជាងនេះទៅទៀត អាចមានការប៉ះពាល់ដល់អាយុជីវិតមនុស្សសត្វ ដោយសារការគ្រោងគម្រោងមិនបានល្អ ដូចជាការបាក់ឬរលំ ការដាច់ខ្សែអគ្គិសនី បណ្តាឱ្យឆក់ ឆេះ ស្លាប់មនុស្សក៏សឹងមានផងដែរ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនធ្វើការអប់រំសុខភាពអនាម័យដល់ក្រុមសិក្សាគម្រោង ដូចជាការណែនាំឱ្យពួកគេចេះត្រៀមទឹកបរិសុទ្ធ និងអាហារ ថ្នាំពេទ្យ ឧបករណ៍ស្នាក់នៅមានសុវត្ថិភាពតាមខ្លួន នៅពេលចូលព្រៃសិក្សា។

ក្រុមហ៊ុនធ្វើការទាក់ទងយ៉ាងជិតស្និតជាមួយអាជ្ញាធរមានសមត្ថកិច្ច ប្រជាពលរដ្ឋមូលដ្ឋាន និងអង្គភាពបោសសំអាតមីន ដើម្បីធ្វើការបង្ហាញតំបន់មានគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះទាំងឡាយ ដែលបន្សល់ទុកពីសម័យសង្គ្រាម។

ក្រុមហ៊ុនបានរកអ្នកនាំផ្លូវ ដែលស្គាល់ភូមិសាស្ត្រច្បាស់លាស់ក្នុងមូលដ្ឋានតំបន់គម្រោង និងកម្លាំងប្រដាប់អាវុធមូលដ្ឋាន ដើម្បីការពារសន្តិសុខ ជៀសវាងមានគ្រោះថ្នាក់ដល់ក្រុមការងារសិក្សាគម្រោង ដោយសារ គ្រាប់មីន អន្ទាក់សត្វ សត្វសាហាវ សត្វអសិរពិស និងជនប្រដាប់អាវុធអនាធិបតេយ្យ ដែលចូលទៅបាញ់សត្វ ឬកាប់ឈើខុសច្បាប់។ ក្រុមហ៊ុនត្រូវត្រៀមថ្នាំបង្ការ ដើម្បីការពារជំងឺគ្រុនចាញ់ គ្រុនសន្និ របួស សត្វទិច ឬខាំ និងថ្នាំការពារពស់ចឹកដល់ ក្រុមការងារសិក្សារួមទាំងកម្មករគម្រោង របស់ខ្លួនឱ្យបានគ្រប់គ្រាន់ ពីព្រោះតំបន់គម្រោងសម្បូរសត្វអសិរពិស (ពស់ពិសគ្រប់ប្រភេទស្រាំងឌីម៉ាល់ជាដើម)។

ក្រុមហ៊ុនត្រូវគ្រោងគម្រោងដោយគិតអំពីល្បឿនខ្យល់ព្យុះ ខ្យល់កន្ត្រាក់ ធ្វើឱ្យបង្គោលរឹងមាំ និងខ្សែដក់ ធ្វើយ៉ាងណាឱ្យមានគំលាតពីដីលើសពី៨ម។



រូបទី ៤: កម្ពស់អប្បបរមានៃខ្សែចម្លងតង់ស្យុងខ្ពស់

| តង់ស្យុង | កំពស់ |
|---|---|
| 115 | 7.0 ឬច្រើនជាង |
| 230 | 7.7 ឬច្រើនជាង |

## គ.៦ សោភ័ណ្ឌភាព និង ទេសភាព

ក្នុងដំណាក់កាលនេះមិនប៉ះពាល់ដល់ផ្នែកនេះទេ ពីព្រោះ សកម្មភាពសិក្សាមិន មានសកម្មភាពធំដុំ (សិក្សាតំរង់ទិសបង្គោល ធ្វើឋានលេខាជាដើម) ដែលធ្វើឱ្យខូចសោភ័ណ្ឌភាព ឬទេសភាពក្នុងតំបន់ឡើយ។

## គ.៧ ហានិភ័យ

➢ ហេតុប៉ះពាល់អវិជ្ជមាន

នៅក្នុងដំណាក់កាលនៃការសិក្សានេះ អាចមិនបានគិតអំពីកត្តាប្រែប្រួលអាកាសធាតុ ដូចជាការកើនឡើងនូវកំដៅព្យុះជាដើម អាចធ្វើឱ្យគុណភាពសំណង់ នៃប្រព័ន្ធខ្សែអគ្គិសនីមិនរឹងមាំតាមការគ្រោងទុក។

ក្រុមសិក្សារបស់ក្រុមហ៊ុនអាចមានគ្រោះថ្នាក់ ដោយសារលក្ខណៈភូមិសាស្ត្រស្មុគស្មាញ ដូចជាមានគ្រាប់មីន និង យុទ្ធភណ្ឌ មិនទាន់ផ្ទុះបង្កប់ក្នុងដី ក្នុងសម័យសង្គ្រាម និងជនអនាធិបតេយ្យប្រើអាវុធខុសច្បាប់។

អាចគ្រោះថ្នាក់ដោយសារសត្វសាហាវ ដូចជា ខ្លាឃ្មុំ ពស់ពីស ខ្លា ដែលមាននៅក្នុងតំបន់គម្រោងនេះ។

➢ វិធានការកាត់បន្ថយ

ការរចនាគម្រោងវាសំខាន់ណាស់សម្រាប់ដំណាក់កាលគម្រោងក្រោយៗទៀត ដូចនេះក្នុងដំណាក់កាលនេះ នឹងធ្វើការគ្រោង រចនានូវហេដ្ឋារចនាសម្ព័ន្ធខ្សែបញ្ជូនអគ្គិសនីនេះមានដូចតទៅៈ

- គន្លងខ្សែគឺ ១៥មសងខាងពីអ័ក្សបង្គោលហ្វែមដែក (សរុប ៣០ម)
- ទំហំផ្ទៃដីសម្រាប់ធ្វើគ្រឹះបង្គោលអគ្គិសនីគឺ ១៥ម x ១៥ម
- ចំនួនបង្គោលអគ្គិសនីគឺ១៣ បង្គោលហ្វែមដែក ហើយចម្ងាយប្រឡោះពីបង្គោលមួយទៅបង្គោលមួយទៀត គឺ ៣០០ ទៅ៥០០ម។ កម្ពស់របស់បង្គោលគឺ ចាប់ពី ២០ម ទៅ ៤០ម ប្រែប្រួលទៅតាមសណ្ឋានដី។
- សម្ភារសំណង់ មានគុណភាពតាមស្តង់ដារអន្តរជាតិ ធន់នឹងការប្រែប្រួលអាកាសធាតុ និងធានាដល់ការប្រើប្រាស់ប្រព័ន្ធខ្សែអគ្គិសនីនេះ តាមការគ្រោងទុកតាមកិច្ចសន្យា របស់ក្រុមហ៊ុន ជាមួយរាជរដ្ឋាភិបាលកម្ពុជា។

ចំពោះបញ្ហាមីន និងគ្រាប់មិនទាន់ផ្ទុះ នោះក្រុមហ៊ុនត្រូវធ្វើការទាក់ទងយ៉ាងជិតស្និតជាមួយអាជ្ញាធរមានសមត្ថកិច្ច ប្រជាពលរដ្ឋមូលដ្ឋាន កងកម្លាំងយោធាភូមិភាគទី៣ និងកងកម្លាំងបោសសំអាតគ្រាប់មីនក្នុងការបង្ហាញតំបន់មានគ្រាប់មីន និងគ្រាប់មីនមិនទាន់ផ្ទុះទាំងនេះដែលមានក្នុងសម័យសង្គ្រាមសព្វថ្ងៃ(២០១២)។

ចំពោះបញ្ហាការពារសត្វសាហាវ ដូចជា ខ្លាឃ្មុំ ពស់ ខ្លា នោះ ក្រុមហ៊ុនធ្វើដំណើររួមគ្នា និងសហការជាមួយកម្លាំងប្រដាប់អាវុធ និងអ្នកនាំផ្លូវនៅមូលដ្ឋាន ដើម្បីការពារនៅពេលជួបប្រទះហេតុការណ៍ ដែលបង្កឡើងដោយសត្វសាហាវ និងជនខិលខូចខាងលើនេះ។

### ៧.៧.២ ដំណាក់កាលសាងសង់គម្រោង (Project Construction)

ក្នុងដំណាក់កាលនេះ គឺជាដំណាក់កាលមួយមានរយៈពេលរហូតដល់២ឆ្នាំ ហើយនឹងមានសកម្មភាពសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធរបស់គម្រោងជាច្រើន ដូចជា ការឈូសឆាយដី ការសាងសង់ផ្លូវចូលក្នុងការដ្ឋាន សាងសង់ប្រព័ន្ធខ្សែអគ្គិសនី អាគារ ការិយាល័យ និងផ្លូវចូលផ្ទះបុគ្គលិក-កម្មករ។ ព្រមទាំងមានការសាងសង់ បង្គោលអគ្គិសនី និងខ្សែ២៣០ គ.វ៉ តភ្ជាប់ទៅបណ្ដាញខ្សែ២៣០គ.វ៉ អូរសោម-ពោធិ៍សាត់។ សកម្មភាពការងារទាំងនេះនឹង អាចបង្កឱ្យមានការប៉ះពាល់អវិជ្ជមានសំខាន់ៗ មួយចំនួន មានដូចតទៅ៖

#### ក. ធនធានរូបសាស្ត្រ

#### ក.១ សណ្ឋានដី និងឋានលេខា

➢ ហេតុប៉ះពាល់អវិជ្ជមាន

នៅក្នុងដំណាក់នៃការសាងសង់គម្រោងនេះ បណ្ដាលឱ្យមានការប្រែប្រួលសណ្ឋានដី និងឋានលេខា ជាមធ្យមក្នុងទីតាំងគម្រោង ដោយសារសកម្មភាពឈូសឆាយធ្វើផ្លូវចូល និងពង្រាបដីស្រទាប់លើ ការជីកយកដី និងថ្ម ដើម្បីធ្វើការសាងសង់ប្រព័ន្ធខ្សែអគ្គិសនីដូចជា សាងសង់បង្គោលអគ្គិសនី និងការដំឡើងខ្សែជាដើម។

➢ វិធានការកាត់បន្ថយ

ការយកដី ខ្សាច់ និងថ្ម ក្រុមហ៊ុនធ្វើការសហការជាមួយស្ថាប័នមានសមត្ថកិច្ច ដោយកំណត់ទីតាំងយកដី ថ្ម និងខ្សាច់រួមមួយនៅកន្លែងយកដី ថ្ម និងខ្សាច់នៃការសាងសង់ទំនប់វារីអគ្គិសនី។ នៅពេលចប់ការសាងសង់កន្លែងយកដី ថ្ម និងខ្សាច់

Draft

នេះ ក្រុមហ៊ុនត្រូវឈូសឆាយសំអាត ពង្រាបឱ្យស្មើ និងចាក់ដីពីលើហើយធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ ដើម្បីដាំឈើឡើងវិញដោយជ្រើសរើសពូជឈើក្នុងតំបន់។

ក្រុមហ៊ុន ត្រូវធ្វើការសាងសង់ជាទ្រង់ទ្រាយធំតែរដូវប្រាំង ដើម្បីទប់ស្កាត់ការហូរច្រោះ ដែលនាំឱ្យខូចសណ្ឋានដីនៅរដូវវស្សា។

ក្រុមហ៊ុនជីកគ្រឹះ ហើយត្រូវពង្រាបដីវិញ និងមានការដាំស្មៅថែមទៀត នៅទីតាំងសាងសង់បង្គោល ឱ្យរក្សាបាននូវសណ្ឋានដី ឱ្យមានស្ថានភាពដូចដើម។ ជាងនេះទៅទៀត នៅតាមផ្លូវចូល ក្រុមហ៊ុនត្រូវធ្វើជើងទេរនៃជញ្ជាំងដី ហើយនៅតាមចិញ្ចើមផ្លូវចូល សងខាងត្រូវកាយប្រឡាយទឹក ដើម្បីដោះទឹកផង និងដើម្បីកាត់បន្ថយភាពល្អក់នៅពេលមានភ្លៀងធ្លាក់ផង។

**ក.២ ប្រព័ន្ធជលសាស្ត្រ ទឹកលើដី (ប្រឡាយ- អូរ-ស្ទឹង)**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ដំណាក់កាលសាងសង់នោះប៉ះពាល់ដល់គុណភាពទឹក ដោយសារសកម្មភាពសាងសង់ ដែលបណ្ដាលមកពីការហូរច្រោះ ដីស្អុយតាមបង្គោលអគ្គិសនី តាមផ្លូវចូលទៅសាងសង់បង្គោល ហូរចូលទៅក្នុងប្រឡាយ-អូរ-ស្ទឹង ដែលស្ថិតក្បែរកន្លែងសាង សង់នោះ។

អាចប៉ះពាល់ដល់គុណភាពទឹកប្រឡាយ-អូរ-ស្ទឹង ដោយសារការបោះបង់សំណល់រឹង និងការបង្ហូរសំណល់រាវ ចេញពីបន្ទប់ទឹក បង្គន់ក្នុងប្រភពទឹកធម្មជាតិ បង្គន់នៅកន្លែងស្នាក់នៅ ឬការិយាល័យ ផ្ទះបាយ ការលេចធ្លាយប្រេងឥន្ទនៈ និងប្រេង រំអិលពីគ្រឿងយន្តនានាក្នុងការដ្ឋានសាងសង់ និងការមុជទឹកសំអាតខ្លួនប្រាណ ការបោកគក់របស់បុគ្គលិក-កម្មករ ការបន្ទោរបង់ទៅក្នុងប្រឡាយ-អូរ-ស្ទឹងទាំងនោះ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុន ត្រូវធ្វើការកាត់បន្ថយការធ្វើឱ្យល្អក់ខ្លាំងដោយយកដីស្អុយ ដែលនៅក្បែរប្រភពទឹកចេញ និងកិនបង្ហាប់ដី ដាំស្មៅនៅកន្លែងដែលបានសាងសង់បង្គោលរួចហើយ ឱ្យបានមុនពេលរដូវភ្លៀងធ្លាក់។

ក្រុមហ៊ុនអនុវត្តសកម្មភាពសាងសង់ធំៗគឺធ្វើនៅរដូវប្រាំង ដើម្បីកាត់បន្ថយការហូរច្រោះពីការដ្ឋានដីផ្សេងៗ ដែលអាចហូរចូលស្ទឹង។

ក្រុមហ៊ុននឹងអប់រំដល់បុគ្គលិក-កម្មករអំពីការបោះបង់សំណល់រឹង ឬបង្ហូរសំណល់រាវ ជាពិសេសការកំពប់ប្រេងឥន្ទនៈ ប្រេងរំអិលនៅលើដី ដែលបណ្ដាលឱ្យខូចគុណភាពដី និងទឹកនៅក្នុងតំបន់គម្រោង។ ហាមបុគ្គលិក-កម្មករគម្រោងមិនឱ្យមាន ការបន្ទោរបង់ ឬសង់បង្គន់នៅក្នុងប្រភពទឹកធម្មជាតិ ឬប្រភពទឹកសាធារណៈក្នុងតំបន់គម្រោងឡើយ។

ក្រុមហ៊ុនធ្វើការគ្រប់គ្រង និងការពារសំណល់រឹង-រាវ គ្រប់ប្រភេទមិនឱ្យបោះចោលសំណល់រឹង និងបង្ហូរ សំណល់រាវចូលទៅក្នុង ឬក្បែរប្រភពទឹកធម្មជាតិឡើយ ដោយសង់បន្ទប់ទឹក និងបង្គន់អនាម័យ (ដោយមានអាងសិបទិកត្រឹមត្រូវ)ឱ្យឆ្ងាយពីប្រភពទឹកធម្មជាតិ និងមានកន្លែងទុកដាក់សំណល់រឹងឱ្យបានល្អតាមបច្ចេកទេស ដោយមិនបំពុលបរិស្ថាន នៅតំបន់នោះឡើយ។

**ក.៣ ការហូរច្រោះ**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ដំណាក់កាលសាងសង់នេះ បង្កឱ្យមានការហូរច្រោះដី ដោយសារការឈូសឆាយដីស្រទាប់លើ ដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធ របស់គម្រោង (ផ្លូវចូល បង្គោលអគ្គិសនី និងដំឡើងខ្សែអគ្គិសនី) ដោយសារការធ្វេសប្រហែសមិនគោរពតាមបទដ្ឋានការងារដី ដែលធ្វើឱ្យមាន ការហូរច្រោះដី ពិសេសនៅរដូវវស្សា។



Draft

ម៉្យាងទៀតបង្កឱ្យប៉ះពាល់ដល់គុណភាពដីស្រទាប់លើនៅជុំវិញតំបន់បង្គោលអគ្គិសនី និងកន្លែងកាយដីទូលធ្វើផ្លូវចូលដោយចោលដីស្អុយ (ដីដែលជីកពីស្រទាប់ក្រោមគ្មានជីជាតិ) ទាំងនោះគ្របលើដីក្នុងទីតាំងសាងសង់នោះ ធ្វើឱ្យបាត់បង់ជីជាតិរបស់ដី ស្រទាប់លើ នៅតំបន់នោះហើយអាចបណ្តាលឱ្យមានការហូរច្រោះ ដីស្អុយនេះ ទៅគ្របពីលើសណ្ឋានដីតំបន់ជុំវិញនោះ ឬហូរចូលប្រភពទឹកប្រើប្រាស់ទៀតផង។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនធ្វើការបង្ហាប់ដីក្នុងតំបន់សាងសង់ឱ្យបានត្រឹមត្រូវតាមបទដ្ឋានការងារបច្ចេកទេស។

ក្រុមហ៊ុនត្រូវពង្រាបដី ឬថ្មដែលចាក់ចោល ដោយយកដីមានជីជាតិលប់ពីលើ ឱ្យបានប្រហាក់ប្រហែលស្ថានភាពដើម។

ក្រុមហ៊ុនត្រូវដាំស្មៅនៅតាមបង្គោលអគ្គិសនី ដែលមិនមានស្មៅ ឬឈើដុះ ដើម្បីការពារការហូរច្រោះដី ដែលគ្មានជីជាតិទៅលើកន្លែងផ្សេងទៀតដោយធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ។

**ក.៤ ការរញ្ជួយដី**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ដំណាក់កាលសាងសង់នេះបង្កឱ្យមានការរញ្ជួយតិចតួច ដោយសារការ ដឹកសម្ភារសំណង់ធុនធ្ងន់ៗ និងការបន្ទុះថ្មសម្រាប់សាងសង់ បង្គោលអគ្គិសនីជាដើម ដែលអាចបង្កឱ្យមានការបាក់ជញ្ជាំង ដី ឬប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ឬសំណង់សាធារណៈ និងឯកជន ដែលមិនមានសភាពរឹងមាំ ឬចាស់ទ្រុឌទ្រោមដែលនៅក្បែរៗនោះ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនធ្វើការដោះបំបែកនៃគ្រឿនបង្គំរបស់បង្គោលអគ្គិសនី គ្រង់ស្ទ័រម៉ាទ័រ។ល។ ហើយធ្វើការដឹកជញ្ជូនមិនឱ្យលើសទំងន់ដែលកាត់បន្ថយភាពរញ្ជួយ និងមិនឱ្យខូចផ្លូវ បាក់ស្ពាន និងលូទៀតផង។

**ក.៥ គុណភាពទឹក (លើដី/ ក្រោមដី)**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលសាងសង់នេះ មានការបំពុលគុណភាពទឹកប្រឡាយ-អូរ-ស្ទឹង ដោយសារការសាងសង់បង្គោលអគ្គិសនី និងការងារសាងសង់ដទៃទៀត បណ្តាលមកពីការខួង ឬការងារដី ការងារបេតុង និងការងារគ្រឹះ ដែលការដ្ឋានសាងសង់នេះស្ថិតនៅជិតប្រភពទឹកទាំងនេះ។

ម៉្យាងទៀតប៉ះពាល់គុណភាពទឹកធម្មជាតិ ដោយសារសំណល់រឹង-រាវ ចេញពីកន្លែងស្នាក់នៅ ដូចជា ចេញពីផ្ទះបាយ បន្ទប់ទឹក បង្គន់នៅកន្លែងស្នាក់នៅ ឬការិយាល័យ ហើយកន្លែងខ្លះសង់បង្គន់ក្នុង និងក្បែរប្រភពទឹកធម្មជាតិ និងការបោះសំណល់រឹងដោយបុគ្គលិក-កម្មកររបស់ក្រុមហ៊ុន មានសម្ភារសំណង់ ដូចជាបាវស៊ីម៉ងត៍ បាវ ឬស្បោងច្រកជាដើម ការលេចធ្លាយ សំណល់រាវ ដូចជាការហៀរ ឬលេចជាតិប្រេងពីគ្រឿងចក្ររថយន្ត សារធាតុគីមីផ្សេងទៀត។ល។ ទៅក្នុងប្រភពទឹកធម្មជាតិនៃតំបន់គម្រោងនេះ។

បន្ថែមពីលើនេះទៀតអាចនឹងមានការហូរច្រោះដី ដោយសារការកាប់ឆ្ការនូវគម្របរុក្ខជាតិ ដូចជាការកាប់ព្រៃ ៣០ម .តាម គន្លងខ្សែ ការងារដីដែលមិនបានពង្រាបដីស្អុយ និងមិនបានគ្រប់គ្រងការងារដីទាំងនេះ ឱ្យបានល្អនៅតាមបទដ្ឋានបច្ចេកទេស ដែលហេតុនាំឱ្យមានការហូរច្រោះដីទៅក្នុងប្រឡាយ-អូរ-ស្ទឹង នៅរដូវវស្សា។

បន្ថែមពីលើនេះទៀត អាចនឹងបំពុលទឹកដោយសារការប្រើប្រាស់សារធាតុគីមី ដើម្បីសំលាប់ព្រៃឈើ ឬបង្អាក់ការលូតលាស់របស់ដើមឈើ។

➢ វិធានការកាត់បន្ថយ

ការឈូសឆាយទ្រង់ទ្រាយធំក្រុមហ៊ុនមិនធ្វើនៅរដូវវស្សាទេ។

ក្រុមហ៊ុនធ្វើការអប់រំបុគ្គលិក-កម្មករគម្រោងឱ្យយល់ដឹងអំពីអនាម័យ ស្គាល់នូវកន្លែងទុកដាក់សម្រាម ដែលក្រុមហ៊ុនបានរៀបចំកសាងក្នុងទីតាំងស្នាក់នៅរបស់គម្រោង។ ហាមមិនឱ្យបន្ទោរបង់ និងសង់បង្គន់ក្នុងប្រភពទឹកធម្មជាតិ ឬសាធារណៈឡើយត្រូវដាក់ពិន័យដល់បុគ្គលិក-កម្មករណាមិនអនុវត្តតាមការណែនាំនេះ។

ក្រុមហ៊ុនចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងសំណល់រឹង-រាវ ដោយសាងសង់បង្គន់អនាម័យ បន្ទប់ទឹក ផ្ទះបាយឱ្យបានឆ្ងាយពីមាត់ប្រឡាយ-អូរ-ស្ទឹង ព្រមទាំងរៀបចំប្រមូលសំណល់រឹង និងសម្រាមយកទៅចោលនៅទីតាំងដែលមានសុវត្ថិភាពល្អមិនឱ្យប៉ះពាល់បរិស្ថានជុំវិញ។

ក្រុមហ៊ុនធ្វើការបោះស្លាកសញ្ញាតំបន់គម្រោង ដោយមានអក្សរខ្មែរ និងកូរ៉េឬអង់គ្លេសអំពីការបំពុលទឹក។

ក្រុមហ៊ុនសាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវតាមបទដ្ឋានសុវត្ថិភាពដល់បរិស្ថាន និងសង្គម។

ក្រុមហ៊ុនត្រូវប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និងរថយន្តដឹកជញ្ជូន ដែលមានគុណភាពល្អមិនលេចហូរជាតិប្រេង ឬខ្លាញ់មកលើដី និងប្រភពទឹកក្នុងតំបន់គម្រោង។

ក្រុមហ៊ុនត្រូវដាំស្មៅតាមកន្លែងដែលសាងសង់បង្គោលរួចហើយ និងដាំស្មៅនៅកន្លែងដែលកាប់សំអាតគន្លង ដែលគ្មានស្មៅ ឬឈើដុះ ដើម្បីការពារការហូរច្រោះ និងគុណភាពទឹក។

ក្រុមហ៊ុនមិនប្រើសារធាតុគីមីផ្សេងៗក្នុងការសំអាត ឬបង្អាក់ការលូតលាស់របស់ឈើនោះទេ។

### គ.៦ គុណភាពខ្យល់

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលសាងសង់នេះ មានការបំពុលខ្យល់ដោយសារការដុតព្រៃឈើ ដើមឈើ កម្ទេចឈើ ដើម្បីសំអាតការដ្ឋាន និងនៅតាមគន្លងខ្សែ ហើយផ្សែងដែលបំភាយចេញពីគ្រឿងចក្រសាងសង់ និងរថយន្តដឹកជញ្ជូនសម្ភារសម្រាប់ការងារសាងសង់ និងការហុយធូលីដីពីមធ្យោបាយដឹកជញ្ជូនទាំងនេះរបស់គម្រោង។

ម្យ៉ាងទៀតអាចនឹងបំពុលខ្យល់ដោយសារភ្លើងឆេះព្រៃបណ្តាលមកពីការធ្វេសប្រហែសពីបុគ្គលិក-កម្មករគម្រោង។

បន្ថែមពីលើនេះទៀត អាចនឹងបំពុលខ្យល់ដោយសារការប្រើប្រាស់សារធាតុគីមី ដើម្បីសំលាប់ព្រៃឈើ ឬបង្អាក់ការលូតលាស់របស់ដើមឈើ ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនមិនដុតព្រៃឈើក្នុងតំបន់ ដែលត្រូវសំអាតតាមគន្លងខ្សែ៣០ម.នេះទេ គឺក្រុមហ៊ុនធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ ដើម្បីត្រួតពិនិត្យទំហំដើមឈើសម្រាប់ដេញថ្លៃ និងឈើមួយចំនួនអាចយកមកកែច្នៃសម្រាប់ប្រើប្រាស់។

ក្រុមហ៊ុនប្រើប្រាស់ម៉ាស៊ីន គ្រឿងចក្រ និងរថយន្តដឹកជញ្ជូនដែលមានការបញ្ចេញផ្សែងតិច ដើម្បីកាត់បន្ថយការបំពុលខ្យល់ក្នុងតំបន់នោះ។

ក្រុមហ៊ុនត្រៀមឧបករណ៍ពន្លត់អគ្គិភ័យ និងមានកន្លែងបូមទឹកគ្រប់គ្រាន់នៅពេលមានអគ្គិភ័យ។

ធ្វើការអប់រំបុគ្គលិក-កម្មករគម្រោង មិនឱ្យចោលភ្លើងបារី ឬអង្កត់ភ្លើង ជាដើម ទៅក្នុងព្រៃបណ្តាលឱ្យកើតមានភ្លើងឆេះព្រៃ ក្នុងតំបន់គម្រោង និងឱ្យមានការប្រុងប្រយ័ត្នជានិច្ច ហើយថែមទាំងម្ចាស់ការក្នុងការពន្លត់ភ្លើង ទៅតាមលទ្ធភាពដែលអាចពន្លត់បាន។ ជាងនេះទៅទៀតបុគ្គលិក-កម្មករគម្រោង ត្រូវចូលរួមយ៉ាងសកម្មក្នុងការរាយការណ៍ និងពន្លត់ភ្លើងឆេះព្រៃនេះ។

ក្រុមហ៊ុនមិនប្រើប្រាស់សារធាតុគីមីផ្សេងៗក្នុងការសំអាតព្រៃឈើ ដើមឈើនៅតាមគន្លងខ្សែនោះទេ។

### គ.៧ គុណភាពដី

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធខ្សែអគ្គិសនីមានការបំពុលដី ដោយសារការកំពប់នៃប្រេងឥន្ធនៈ ការកំពប់ នៃសារធាតុគីមី និងសំណល់រឹង-រាវគ្រប់ប្រភេទទៅលើដី ដូចជាៈ សំណល់ចេញពី ឬលេចធ្លាយពីគ្រឿងចក្រ និងរថយន្តគ្រប់ប្រភេទក្នុងដំណើរការគម្រោងនេះ ព្រមទាំងសំណល់ចេញពីផ្ទះបាយផងដែរ។



Draft

បង្កឱ្យប៉ះពាល់ដល់គុណភាពដីស្រទាប់លើនៅជុំវិញទីតាំងបង្គោលអគ្គិសនី ដោយសារចោលដីស្អុយ (ដីដែលជីកពីស្រទាប់ក្រោម គ្មានជីជាតិ) នៅជុំវិញទីតាំងនោះ។

អាចនឹងមានការបំពុលដីដោយសារការប្រើប្រាស់សារធាតុគីមី ផ្សេងៗក្នុងការសំអាត ឬបង្អាក់ការលូតលាស់របស់ឈើធ្លាក់ទៅលើដី។

ការឈូសកាប់ព្រៃស្រទាប់លើ ដើម្បីធ្វើការសាងសង់ស្ថានីយផលិតថាមពល និងការធ្វើផ្លូវចូល ធ្វើឱ្យមានការហូរច្រោះដីនៅរដូវវស្សា និងមានសំណឹកដោយសារខ្យល់ និងកំដៅថ្ងៃនៅរដូវប្រាំងនឹងធ្វើឱ្យបាត់បង់គុណភាពដីនៅក្នុងតំបន់គម្រោងផងដែរ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនសាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវមិនឱ្យកំពប់ ឬជ្រាបចូលដីទេ។

ក្រុមហ៊ុនពង្រាបដី ឬថ្មដែលចាក់ចោល ដោយយកដីមានជីវជាតិលប់ពីលើ រួចដាំស្មៅឡើងវិញ ក្នុងតំបន់សាងសង់បង្គោល អគ្គិសនីនេះ (១៥ X ១៥ម)។ ជាងនេះទៅទៀតក្រុមហ៊ុនត្រូវធ្វើជញ្ជាំងផ្លូវឱ្យមានជើងទេរត្រឹមត្រូវ ជៀសវាងការបាក់ដីនៅពេលមានភ្លៀងធ្លាក់ពីព្រោះតំបន់នេះមានភ្លៀងច្រើន។

ក្រុមហ៊ុនត្រូវគ្រប់គ្រងសំណល់រឹង-រាវគ្រប់ប្រភេទឱ្យបានត្រឹមត្រូវ ដូចជា ៖ ចាត់វិធានការយ៉ាងតឹងរ៉ឹងមិនឱ្យចាក់ប្រេងម៉ាស៊ីនចាស់ៗ (ប្រេងបាត)ចោលទៅលើដី។

ក្រុមហ៊ុនត្រូវដាក់ពិន័យដល់អ្នកដែលប្រព្រឹត្តខុសខាងលើនេះ ដូចជា ស្តីបន្ទោស ឬការបណ្តេញពីការងារជាដើម។

ក្រុមហ៊ុនមិនប្រើសារធាតុគីមីផ្សេងៗក្នុងការសំអាតឬ បង្អាក់ការលូតលាស់របស់ឈើនោះទេ។

ក្រុមហ៊ុនសាងសង់របងជុំវិញស្ថានីយផលិតថាមពល រួចដាំស្មៅ ធ្វើផ្លូវតូចៗក្នុងបរិវេណកន្លែងដាក់គ្រង់ស្វូម៉ាទ័រ និងមានប្រព័ន្ធលូការពារការហូរច្រោះដើម្បីថែរក្សាគុណភាពដីក្នុងតំបន់គម្រោងឱ្យបានល្អ។

ក្រុមហ៊ុនត្រូវដាំស្មៅនៅតាមគន្លងខ្សែដែលមិនមានស្មៅ ឬឈើដុះ ក្នុងតំបន់ដីសារធារណៈ ឯកជនរបស់រដ្ឋដោយសហការយ៉ាងជិតស្និទ្ធិជាមួយរដ្ឋបាលព្រៃឈើក្នុងតំបន់។

### ក.៨ សំឡេងនិងរំញ័រ

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធខ្សែអគ្គិសនីមានការបំពុលបរិស្ថានដោយសំឡេង និងរំញ័រតិចតួចដោយសារ ការដឹកជញ្ជូនសម្ភារសំណង់ បង្គោលអគ្គិសនី ខ្សែអគ្គិសនីជាដើម។ល។ ដោយសារការគ្រឿងចក្រ ម៉ាស៊ីនភ្លើង និងរថយន្តគ្រប់ប្រភេទដោយសារការប្រើគ្រឿងផ្ទុះក្នុងដំណើរការគម្រោងនេះ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនប្រើគ្រឿងចក្រម៉ាស៊ីនភ្លើង និងរថយន្តមានគុណភាពល្អ មិនមានសំឡេងនិងរំញ័រខ្លាំង។ **សម្គាល់**:ជាក់ស្តែងក្រុមការងារ សិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនេះបានសហការជាមួយមន្ទីរពិសោធ៍នៃក្រសួងបរិស្ថានធ្វើតេស្តសំឡេង និងរំញ័រនៅចំណុច ដែលមានសកម្មភាពមមាញឹកជាងគេក្បែរតំបន់គម្រោង គឺស្ថិតនៅចំណុចស្រែពាំងក្បែរផ្លូវជាតិលេខ៥៥ លទ្ធផលបានបង្ហាញថានៅពេលថ្ងៃសំឡេងមានកម្រិតក្រោមស្តង់ដារបស់ក្រសួងបរិស្ថាន តែនៅពេលយប់លើសស្តង់ដាតិចតួចប៉ុណ្ណោះ គឺនៅម៉ោង៥ ទៅ៦ ភ្លឺ ប៉ុន្តែជាមធ្យមមានតែ ៤៩,១ dB ក្រោមស្តង់ដា (៥០ dB)។ ចំណែកឯរំញ័រវិញគឺស្ថិតនៅក្រោមស្តង់ដា របស់ក្រសួងបរិស្ថាន។

## ខ. ធនធានជីវសាស្ត្រ

### ខ.១ ជីវសាស្ត្រ ដែលរស់នៅក្នុងទឹក/មច្ឆជាតិ

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលសាងសង់នេះ អាចប៉ះពាល់គុណភាពទឹកប្រឡាយ-អូរ-ស្ទឹង នៅក្បែរការដ្ឋានសាងសង់បង្គោលអគ្គិសនី និងអនុស្ថានីយពោធិ៍សាត់ ដោយសារការងារដី ការងារបេតុង ដែលមានដីស្អុយ (ដីដែលជីកពីស្រទាប់ក្រោមគ្មានជីវជាតិ) ហូរច្រោះដោយសារទឹកភ្លៀង និងការបោះចោលនូវសម្ភារសំណង់ ធ្វើឱ្យល្អក់ទឹកបណ្តាលឱ្យពុលដល់មច្ឆជាតិ និងជីវសាស្ត្រនៅក្នុងប្រភពទឹកធម្មជាតិទាំងនេះ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវដាំស្មៅតាមកន្លែងដែលសាងសង់បង្គោលរួចហើយ និងដាំស្មៅនៅកន្លែងកាប់សំអាតគន្លងដែលគ្មានស្មៅ ឬឈើដុះ ដើម្បីការពារការហូរច្រោះ ដែលអាចធ្វើឱ្យមានការបំពុលទឹក។

ក្រុមហ៊ុនធ្វើការអប់រំដល់បុគ្គលិក-កម្មករអំពីការបោះបង់សំណល់រឹង-រាវ ជាពិសេសការកំពប់ប្រេងឥន្ធនៈ ប្រេងរំអិល នៅលើដី និងក្នុងទឹកនៅក្នុងតំបន់គម្រោង។

ក្រុមហ៊ុនត្រូវគ្រប់គ្រងសំណល់រឹងគ្រប់ប្រភេទនៅទីតាំងដែលមានសុវត្ថិភាព។

### ខ.២ ព្រៃឈើការពារ/ តំបន់ការពារ/ ឧទ្យានជាតិ

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលសាងសង់នេះមានការប៉ះពាល់ ដល់តំបន់ការពារសង្កាត់រដ្ឋបាលព្រៃឈើប្រមោយ ដែលមានគម្របព្រៃឈើ ចំនួន១៣,៦ គឺជាព្រៃស្រោង ហើយព្រៃនេះ ក៏មានសត្វព្រៃ ជាច្រើនទៀតរស់នៅផងដែរ។

ជាងនេះទៅទៀត អាចមានការចូលទន្ទ្រានរានដីកាប់ព្រៃឈើយកធ្វើជាកម្មសិទ្ធខុសច្បាប់ ពីជនឆ្លៀតឱកាស។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុននឹងបង់ថវិកាមូលនិធិបរិស្ថាន និងសង្គមសរុប ៤៧៣,៥០០ ដុល្លារអាមេរិក (វគ្គ១ រយៈពេល ១០ឆ្នាំ ក្នុងតំណាក់កាលប្រតិបត្តិគម្រោង សម្រាប់ដាំឡើងវិញ និងបង្កើតសហគមន៍អភិរក្សព្រៃឈើ និងឧបត្ថម្ភអ្នកល្បាត (១០នាក់) ដែលសរុបថវិកាចំនួន ៣៩១.០០០ដុល្លារអាមេរិក។ (មើលជំពូក ចំណុច ៨.៨ តារាង៨-៣ មូលនិធិបរិស្ថាន និងសង្គម ចំណុច ៨.៨)។

ក្រុមហ៊ុនត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលព្រៃឈើដំឡើងស្លាក ប៉ាណូធំៗដូចជាសរសេរថា ព្រៃការពារហាមទន្ទ្រានកាន់កាប់ធ្វើជាកម្មសិទ្ធ ហាមកាប់ឈើ ឬបរបាញ់ ឬដាក់អន្ទាក់សត្វព្រៃខុសច្បាប់ ជនល្មើសត្រូវដាក់គុករហូតដល់ ១០ឆ្នាំជាដើម ហើយដាក់ដំឡើងវាឱ្យបានយ៉ាងតិច៤កន្លែងក្នុងតំបន់គម្រោង។

### ខ.៣ ធនធានព្រៃឈើ និងជម្រកសត្វព្រៃ

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលសាងសង់នេះ មានការប៉ះពាល់ដល់ផ្ទៃដីព្រៃឈើសរុប១៣,៦ហ.ត ដោយសារការសាងសង់បង្គោលអគ្គិសនី ខ្សែបញ្ជូនតង់ស្យុងខ្ពស់២៣០គ.វ៉ ពីអាគារថាមពល មកខ្សែរបស់ក្រុមហ៊ុន Cambodia Power grid (CPG) ប្រវែង៥គ.ម។ ព្រៃឈើទាំងនេះ ជាជម្រកសត្វព្រៃជាច្រើនប្រភេទ ក្នុងតំបន់គម្រោងដូចមានចែងក្នុងជំពូក៥ ចំណុច៥.១.២.២ ខាងលើនេះ។



Draft

ក្នុងសកម្មភាពសាងសង់នេះ ធ្វើឱ្យរំខានដល់ការរស់នៅរបស់ពពួកសត្វព្រៃ ដែលមាននៅក្នុង និងជុំវិញទីតាំងគម្រោង ដោយសារមានសំឡេងនិងរំញ័រចេញពីគ្រឿងចក្រ រថយន្តម៉ាស៊ីនគ្រប់ប្រភេទ ពេលកំពុងធ្វើការងារការសាងសង់គម្រោង។ល។

អាចមានការប៉ះពាល់ដោយសាររំញ័រដោយសារការដឹកជញ្ជូន សម្ភារគម្រោងធ្ងន់ៗ ក្នុងការសាងសង់នេះ។

ម៉្យាងទៀត អាចនឹងមានការប៉ះពាល់ដល់ព្រៃឈើ ក៏ដូចជាជម្រកសត្វព្រៃ ដោយសារការប្រើប្រាស់ថ្នាំគីមី ដើម្បីសំអាត ឬ បង្អាក់ការលូតលាស់របស់ឈើក្នុងការសាងសង់គម្រោងនេះ។

មានការប៉ះពាល់ព្រៃឈើ និងជម្រកសត្វព្រៃ ដោយសារការរំលោភចូលតំបន់ព្រៃការពារ ឬតំបន់អភិរក្ស ដោយសារក្រុមហ៊ុន ដែលបានអាជ្ញាបណ្ណកាប់សំអាតឈើក្នុងតំបន់គម្រោងប្រើប្រាស់មធ្យោបាយគ្រប់រូបភាព ដើម្បីឆ្លៀតឱកាស គេងចំណេញដូចជា ប្រមូលទិញ ក្រញូង ឬឈើប្រណិតផ្សេងៗពីប្រជាជនជាដើម ពីព្រោះខ្លួនទទួលបាននូវអាជ្ញា បណ្ណនាំឈើចេញមកក្រៅតំបន់ រីឯប្រជាជនគ្មានសិទ្ធិដឹកឈើទាំងនោះចេញទេធ្វើឱ្យព្រៃឈើក្នុង ឬក្បែរតំបន់ រងការរុករាន និងបំផ្លាញខូចជម្រកសត្វព្រៃទៀតផង។

- វិធានការកាត់បន្ថយ

ក្រុមហ៊ុនសូមធានាមិនកាប់ព្រៃឈើនៅក្រៅពីទីតាំងសាងសង់ បង្គោលអគ្គិសនី និងតាមចំណីខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០គ.វ៉ ដូចដែលមានបង្ហាញនៅក្នុងប្លង់រចនាគម្រោងលម្អិតឡើយ។

ក្រុមហ៊ុនធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន ដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមានដែល នឹងកើតមានឡើងជាយថាហេតុលើព្រៃឈើដែលនៅជាប់នឹងតំបន់គម្រោងក្នុងដំណាក់កាលនៃការសាងសង់ប្រព័ន្ធខ្សែអគ្គិសនីទាំងនេះ។

ក្រុមហ៊ុនធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន ដើម្បីធ្វើការសំអាតព្រៃតាមចំណីគន្លងខ្សែ ២៣០គ.វ៉ ទទឹង៣០ម (១៥មសងខាងអក្សបង្គោលមើលរូបទី៣) និងពិនិត្យបរិមាណ និងគុណភាពឈើសម្រាប់ធ្វើការដេញថ្លៃ រកចំណូលថវិកាជូនរដ្ឋ ទៅតាមលទ្ធភាពអាចធ្វើបាន។

ក្រុមហ៊ុនសហការជាមួយស្ថាប័នជំនាញ ឬអង្គភាពជំនាញមូលដ្ឋានក្នុងការថែរក្សា ការពារព្រៃឈើ និងជម្រកសត្វព្រៃនៅក្នុង និងក្បែរតំបន់គម្រោងទៅតាមផែនការគ្រប់គ្រងធនធានបរិស្ថានដោយបង្កើតក្រុមល្បាត ដើម្បីត្រួតពិនិត្យ និងការពារធនធានបរិស្ថានទាំងនោះឱ្យមានប្រសិទ្ធភាពដោយមានកញ្ចប់ថវិកាក្នុងផ្នែកនេះចំនួន ៣៥២.៦៦៧ ដុល្លារអាមេរិក។ (មើលតារាង ៨-៣ ចំណុច ៨.៨)។

ក្រុមហ៊ុនប្រើប្រាស់គ្រឿងយន្ត និងមធ្យោបាយដឹកជញ្ជូនមានគុណភាពល្អ ដើម្បីកាត់បន្ថយនូវសំឡេង និងរំញ័ររំខាន ដល់សត្វព្រៃ។

ក្រុមហ៊ុនកំណត់ពេលវេលាធ្វើការតែពេលថ្ងៃប៉ុណ្ណោះ ដើម្បីកាត់បន្ថយការរំខានដល់សត្វព្រៃក្នុងតំបន់គម្រោងនេះ។

ក្រុមហ៊ុនធ្វើការអប់រំដល់បុគ្គលិកកម្មករគម្រោងឱ្យចេះស្ងៀមស្ងាត់នៅពេលម៉ោងសំរាក និងនៅពេលយប់។

ក្រុមហ៊ុនមិនប្រើសារធាតុគីមីផ្សេងៗក្នុងការសំអាត ឬបង្អាក់ការលូតលាស់របស់ឈើនោះទេ។

### ខ.៤ ជីវសាស្ត្រ សត្វព្រៃ

- ហេតុប៉ះពាល់អវិជ្ជមាន

ការកាប់ឆ្ការព្រៃឈើ តាមគន្លងខ្សែអគ្គិសនីទទឹង៣០ម ការដឹកជញ្ជូនសម្ភារ សាងសង់ នឹងនាំឱ្យមានការភ័យខ្លាចដល់សត្វព្រៃ ទាំងនោះ ដោយសារហេតុសំឡេងនិងរំញ័ររំខានខ្លាំងៗ ចេញពីម៉ាស៊ីន គ្រឿងយន្ត និងសំឡេងរបស់បុគ្គលិក-កម្មករគម្រោង នៅពេលកំពុងសាងសង់។

មានសកម្មភាពបរបាញ់ឬចាប់សត្វ ឬចូលព្រៃពីសំណាក់បុគ្គលិក-កម្មករគម្រោងទាំងនោះធ្វើឱ្យផ្ញើលនិងបាត់បង់សត្វព្រៃ។

មានការជួញដូរសត្វព្រៃនៅតំបន់គម្រោងពីសំណាក់ឈ្មួញកណ្តាលនៅតំបន់គម្រោង។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនកំណត់ពេលវេលាធ្វើការតែពេលថ្ងៃសម្រាប់ការងារទាំងឡាយណា ដែលបង្កសំឡេង និងរំញ័រ ដើម្បីកុំឱ្យមានការរំខាន ឬ ផ្អើលសត្វព្រៃក្នុងតំបន់គម្រោង និងតំបន់ជិតគម្រោង។

ក្រុមហ៊ុនប្រើប្រាស់គ្រឿងយន្ត និងមធ្យោបាយដឹកជញ្ជូនមានគុណភាពល្អ ដើម្បីកាត់បន្ថយនូវសំឡេង និងរំញ័ររំខានដល់សត្វព្រៃ ។

ក្រុមហ៊ុនត្រូវអប់រំ និងដាក់វិន័យដល់បុគ្គលិកកម្មករគម្រោងមិនឱ្យធ្វើការចាប់ ឬបរបាញ់សត្វព្រៃ និងធ្វើចរាចរលក់ដូរសត្វព្រៃ នៅក្នុងតំបន់នេះឡើយ។

ក្រុមហ៊ុនត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលព្រៃឈើដំឡើងស្លាកប៉ាណូធំៗ ដូចជាសរសេរថា ព្រៃការពារ ហាមទន្ទ្រានកាន់កាប់ធ្វើជាកម្មសិទ្ធ ហាមកាប់ឈើ ឬបរបាញ់ ឬដាក់អន្ទាក់សត្វព្រៃខុសច្បាប់ ជនល្មើសត្រូវដាក់គុករហូតដល់១០ ឆ្នាំ ជាដើមហើយដាក់ដំឡើងវាឱ្យបានយ៉ាងតិច៤កន្លែងក្នុងតំបន់គម្រោង។

ក្រុមហ៊ុនត្រូវចូលរួមសហការជាមួយរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន ដើម្បីទប់ស្កាត់បទល្មើសសត្វព្រៃ និងព្រៃឈើ។

ក្រុមហ៊ុនត្រូវដំឡើងគំលាតកម្ពស់ខ្សែឱ្យមានសុវត្ថិភាពល្អ ដល់ពពួកបក្សីធំៗ និងដាក់បន្ទះថាសអ៊ីណុកតាមជើងទាំងបួនរបស់បង្គោលអគ្គិសនីនីមួយៗ ការពារមនុស្ស និងសត្វឡើង តាមការគ្រោងទុកខាងលើ។

**គ. ធនធានសេដ្ឋកិច្ចសង្គម**

**គ.១ ការប្រើប្រាស់ដី និងការតាំងលំនៅដ្ឋានឡើងវិញ**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ដំណាក់កាលសាងសង់គម្រោងនោះ តាមគន្លងខ្សែ ២៣០គ.វ៉ប្រវែង៥គ.ម (ទទឹងសរុប ៣០ម) និងចំណុចសាងសង់បង្គោលចំនួន១៣ គ្មានការប៉ះពាល់ដល់ ដីកសិកម្ម ឬការប្រើប្រាស់ដីរបស់ប្រជាពលរដ្ឋនោះទេ។

**គ.២ ការរស់នៅ និងមុខរបររបស់សហគមន៍មូលដ្ឋាន**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ប្រជាពលរដ្ឋនៅចំណុចទួលគ្រួស ទួលកោះ តាំងយ៉ ក្នុងភូមិស្ទឹងថ្មី ដែលរកអនុផលព្រៃឈើក្នុងតំបន់គម្រោងនេះមាន ការភ័យខ្លាចអំពី សុវត្ថិភាព ដោយខ្លាចឆក់ និងមានគ្រោះថ្នាក់ដោយសារចរន្តអគ្គិសនី និងរលំបង្គោលអគ្គិសនី។

ប្រជាពលរដ្ឋនៅភូមិរស់នៅក្នុង និងក្បែរតំបន់គម្រោង មានការព្រួយបារម្ភអំពី ការជ្រើសកម្មករគម្រោង ដោយមិនយកពួកគាត់ យកអ្នកពីចម្ងាយវិញ។

អាចនឹងមានការរើសអើងពូជសាស្ត្ររវាងបុគ្គលិកបរទេស និងកម្មករខ្មែរ ដោយបុគ្គលិកទាំងនោះធ្វើបាប បង្ខំធ្វើការងារជាទំងន់ហួសកម្លាំង ពោលគឺពួកគេមិនដឹងអំពីច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនជ្រើសរើសបុគ្គលិក-កម្មករជាមធ្យម៤០០នាក់ សម្រាប់គម្រោងទាំងមូល ក្នុងនោះប្រជាពលរដ្ឋមូលដ្ឋានចំនួន៣០០នាក់ និងបុគ្គលិក-កម្មករ បរទេសចំនួន១០០នាក់។

ក្រុមហ៊ុនធ្វើការផ្សព្វផ្សាយ និងអប់រំបុគ្គលិកបរទេសទាំងអស់របស់ខ្លួនឱ្យបានយល់ដឹងអំពី ច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជាដោយឱ្យពួកគេចេះគោរពច្បាប់នេះ។ ម៉្យាងទៀត ក្រុមហ៊ុនធ្វើការសហការយ៉ាងជិតស្និតជាមួយអាជ្ញាធរ និងស្ថាប័នពាក់ពន្ធ័ក្នុងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់។

ក្រុមហ៊ុន ត្រូវដំឡើងបង្គោលអគ្គិសនីឱ្យរឹងមាំតាមបច្ចេកទេស ដោយធានាមិនឱ្យរលំនៅពេលមានព្យុះភ្លៀងធម្មតា ជាពិសេស ការរឹតប៊ូឡុង ខ្ចៅទាំងអស់របស់បង្គោលអគ្គិសនី។ ម៉្យាងទៀត កម្ពស់កន្លែងដក់របស់ខ្សែតង់ស្យុងខ្ពស់ពីដីមិនតិចជាង៨ម (បទដ្ឋានរបស់អាជ្ញាធរអគ្គិសនីកម្ពុជាមិនតិចជាង៧.៧ម)តាមការគ្រោងទុកខាងលើ។

**គ.៣ ប្រពៃណី វប្បធម៌ និងសាសនា**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលសាងសង់នេះ អាចមានការប៉ះពាល់ដល់ជំនឿប្រពៃណីរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់ដោយសារក្រុមហ៊ុន យកបុគ្គលិក-កម្មកររបស់ខ្លួន ដែលមកពីតំបន់ឆ្ងាយខុសៗគ្នា និងមានសញ្ជាតិខុសៗគ្នា។

អាចប៉ះពាល់ដល់កន្លែងសក្ការៈបូជាទាំងឡាយដូចជា ព្រៃអ្នកតា ឬទីទួល ព្រៃកប់ខ្មោចសំណាក់ម្ចាស់ទឹកដីក្នុងតំបន់។ល។ ដោយសារគម្រោងធ្វើការកាប់ឆ្ការដីព្រៃឈើ ដើម្បីសាងសង់ប្រព័ន្ធខ្សែអគ្គិសនីនេះ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវសិក្សាស្វែងយល់អំពីប្រពៃណី និងជំនឿសាសនារបស់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសប្រជាពលរដ្ឋរស់នៅ ភូមិស្ទឹងថ្មីទាំងមូល និងគោរពទៅតាមប្រពៃណី ទំនៀមទំលាប់នេះដោយមិនធ្វើការបំពាន និងល្មើសឡើយ ។

ក្រុមហ៊ុនត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីធ្វើការអប់រំ និងណែនាំដល់បុគ្គលិក-កម្មកររបស់ខ្លួនអំពីទំនៀមទំលាប់ប្រពៃណីប្រជាពលរដ្ឋកម្ពុជា ជាពិសេសទំនៀមទំលាប់ប្រពៃណីប្រជាពលរដ្ឋនៅ ភូមិពាក់ព័ន្ធទាំងអស់ជាមួយគម្រោង។

ក្រុមហ៊ុនត្រូវសហការជាមួយរដ្ឋអំណាចមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធដើម្បីបង្កើត និងអភិរក្សកន្លែងសក្ការៈបូជាទាំងឡាយ ដែលបាត់បង់នោះឡើងវិញដូចដែលមានកន្លងមកនៅភូមិរបស់គាត់។

**គ.៤ ការប្រើប្រាស់ទឹក**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលសាងសង់នេះ មានការប៉ះពាល់ដល់ការប្រើប្រាស់ទឹកប្រឡាយ-អូរ-ស្ទឹង ដោយសារសកម្មភាពសាងសង់ផ្លូវចូល បង្គោលអគ្គិសនីរបស់គម្រោង និងការគ្រប់គ្រងសំណល់រឹង-រាវមិនបានល្អ ធ្វើឱ្យបំពុលដល់ប្រភពទឹកលើដី និងក្រោមដី ដែលជា ប្រភពដ៏សំខាន់ក្នុងការផ្គត់ផ្គង់ទឹករបស់ប្រជាពលរដ្ឋផ្នែកខាងក្រោមខ្សែទឹក។

សំណល់រាវចេញពីបង្គន់ បន្ទប់ទឹក និងផ្ទះបាយ ការបន្ទោរបង់ក្នុងប្រភពទឹកធម្មជាតិរបស់បុគ្គលិក-កម្មករគម្រោង ការសំអាតខ្លួនប្រាណរបស់ពួកគេក្នុងប្រឡាយ-អូរ-ស្ទឹង ការលេចធ្លាយប្រេងឥន្ធនៈ និងប្រេងរំអិលពីឧបករណ៍ ឬគ្រឿងយន្តនានា ក្នុងការដ្ឋានសាងសង់ធ្លាក់ចូលទៅក្នុងប្រឡាយ-អូរ-ស្ទឹង នឹងបង្កឱ្យមានការបំពុលទឹកប្រឡាយ-អូរ-ស្ទឹងទាំងនោះ ពីព្រោះការដ្ឋានសាងសង់មានរយៈពេលយូរខែ។

➢ វិធានការកាត់បន្ថយ

ការឈូសឆាយទ្រង់ទ្រាយធំ ក្រុមហ៊ុនមិនធ្វើនៅរដូវវស្សាទេ។

ក្រុមហ៊ុនត្រូវធ្វើរបាំងការពារ កករដីកុំឱ្យសាយភាយចេញឆ្ងាយពីទីតាំងសាងសង់ ហើយសាងសង់បង្គន់អនាម័យ និងបន្ទប់ទឹកឱ្យបានគ្រប់គ្រាន់ទៅតាមចំនួនបុគ្គលិក-កម្មករគម្រោង ឱ្យបានឆ្ងាយពីប្រភពទឹកយ៉ាងតិច ២០០ម។

ក្រុមហ៊ុនត្រូវធ្វើការអប់រំណែនាំបុគ្គលិក-កម្មករគម្រោង មិនឱ្យមានការបន្ទោរបង់ក្នុងប្រភពទឹកធម្មជាតិ ឬសាធារណៈឡើយ និងឱ្យយល់ដឹងអំពីអនាម័យស្គាល់នូវកន្លែងទុកដាក់សម្រាម ដែលក្រុមហ៊ុនបានរៀបចំកសាងក្នុងទីតាំងស្នាក់នៅហើយដាក់ពិន័យដល់ បុគ្គលិក-កម្មករណាដែលមិនព្រមធ្វើតាមការណែនាំ។



Draft

ក្រុមហ៊ុនត្រូវចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងសំណល់រឹង-រាវ ដោយសាងសង់បង្គន់អនាម័យព្រមទាំងរៀបចំប្រមូលសំណល់រឹង និងសម្រាមយកទៅចោលនៅទីតាំងដែលមានសុវត្ថិភាព។

នៅការដ្ឋានសាងសង់អាគារថាមពល (វាលគ្រង់ស្វរ) ក្រុមហ៊ុនសាងសង់អាងសិបទិកទំនើប ដែលអាចសំអាតទឹកកខ្វក់ ចេញពីការិយាល័យ និងកន្លែងស្នាក់នៅឱ្យបានល្អប្រសើរ។

ក្រុមហ៊ុនសាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវតាមបទដ្ឋានសុវត្ថិភាពដល់បរិស្ថាន និងសង្គម។

ក្រុមហ៊ុនប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និងរថយន្តដឹកជញ្ជូន ដែលមានគុណភាពល្អមិនលេចហូរជាតិប្រេង ឬខ្លាញ់មកលើដី និងប្រភពទឹកក្នុងតំបន់គម្រោង។

ក្រុមហ៊ុនត្រូវពង្រាបដី និងដាំស្មៅតាមកន្លែងដែលសង់គ្រឹះបង្គោលអគ្គិសនី (ព្រោះមានដីស្អុយគ្មានដីជាតិស្មៅមិនដុះនាំឱ្យមានការហូរច្រោះបំពុលគុណភាពទឹក) ដើម្បីការពារការហូរច្រោះ ដែលអាចធ្វើឱ្យមានការបំពុលទឹក។

**គ.៥ តំបន់ទេសចរណ៍/ រមណីយដ្ឋាន/ ទីកន្លែងកំសាន្ត**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលសាងសង់គម្រោងនេះ មិនមានការប៉ះពាល់ដល់តំបន់ទេសចរណ៍ និងទីកន្លែងកំសាន្តរបស់តំបន់នេះទេ ក៏ប៉ុន្តែ ប៉ះពាល់ដល់អ្នកទេសចរណ៍ដែលចង់មើលការសាងសង់គម្រោង ឬទៅមើល អន្លង់ផ្សេងៗក្នុងស្ទឹងនេះ ដោយសារ សកម្មភាពសាងសង់ប្រពន្ធ័ខ្សែ២៣០គ.វ៉ ជាពិសេសដោយសារសម្រាមផ្ទះបាយ ដូចជាសំបកដបគ្រប់ប្រភេទ ស្បោង ប្លាស្ទិក ក្រណាត់ខោអាវគ្រប់ ប្រភេទ សំបកកង់រថយន្តគ្រប់ប្រភេទជាដើម។ល។ ដែលធ្វើឱ្យតំបន់ និងទីកន្លែងនេះកខ្វក់ទៀតផង។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុន ត្រូវធ្វើការគ្រប់គ្រងសំណល់រឹង-រាវគ្រប់ប្រភេទឱ្យបានត្រឹមត្រូវ មានរណ្តៅកប់សម្រាមឱ្យបានសមរម្យ។ ត្រូវធ្វើការអប់រំដល់បុគ្គលិក-កម្មករគម្រោងទាំងអស់ ឱ្យចេះដឹងអំពីអនាម័យ និងបរិស្ថានស្អាត ដោយមិនបោះសម្រាមចោលពាសវាលពាសកាល។

ជាងនេះទៅទៀត ត្រូវដាក់បញ្ចូលក្នុងសៀវភៅបន្ទុក ដែលជាឯកសារធ្វើកិច្ចសន្យាម៉ៅការបន្តទៅឱ្យក្រុមហ៊ុនផ្សេងៗត្រូវសំអាតទីតាំងការដ្ឋាន និងកន្លែងជំរុំស្នាក់នៅរបស់បុគ្គលិក-កម្មករឱ្យបានស្អាត ដោយមានបង្កក់ប្រាក់ទុករង់ចាំក្រុមការងារអនុគណ កម្មការខេត្តចុះពិនិត្យរួច បានបញ្ជាក់ថាទីតាំងទាំងនោះស្អាតសរម្យ អាចទទួលយកបានហើយទើបបើកប្រាក់ដែលបង្កកនោះឱ្យ។

**គ.៦ ផ្លូវគមនាគមន៍**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលសាងសង់នេះ មានការប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធ ដែលមានស្រាប់ក្នុងតំបន់គម្រោងនេះ ដោយសារសកម្ម ភាពសាងសង់គម្រោង និងការដឹកជញ្ជូនឧបករណ៍-សម្ភារបរិក្ខាអគ្គិសនី ដែលមានទំងន់រាប់តោនចូលទៅទីតាំងគម្រោងបណ្តាលឱ្យមាន ការស្រុត ឬខូចផ្លូវ ការបាក់ស្ពាន ការកកស្ទះចរាចរ ឬគ្រោះថ្នាក់ចរាចរលើទ្រូងផ្លូវដែលមានចំណោតឡើងទួល និងផ្លូវកោង។ ល។

អាចមានគ្រោះថ្នាក់ចរាចរនៅពេលដែលដំឡើងខ្សែអគ្គិសនីកាត់ ផ្លូវលំ ជនបទ (ផ្លូវរទេះ ឬផ្លូវដែលក្រុមហ៊ុនបានសង់) ដោយសារ កម្ពស់ខ្សែមិនទាន់ទាញ បានដល់ចំណុចកម្ពស់ដែលបានគ្រោង ទាក់អ្នកធ្វើដំណើរបង្កជាគ្រោះថ្នាក់ដល់អ្នកធ្វើចរាចរណ៍ជាដើម។ល។

➢ វិធានការកាត់បន្ថយ

ធ្វើការកែលំអផ្លូវដែលមានស្រាប់ និងសាងសង់ផ្លូវថ្មី ទៅកាន់ទីតាំងគម្រោង ដែលអាចធានាដល់ការប្រើប្រាស់របស់គម្រោង ហើយធ្វើការពិភាក្សាជាមួយស្ថាប័នជំនាញ ក្នុងការដឹកជញ្ជូនសម្ភារធ្ងន់ៗ។

ក្រុមហ៊ុនត្រូវធ្វើការអប់រំដល់បុគ្គលិកដែលបញ្ជាគ្រឿងចក្រ និងយានយន្តទាំងអស់ត្រូវធ្វើការប្រុងប្រយ័ត្នគ្រប់ពេលវេលា ហើយក្រុមហ៊ុនធានានូវសុវត្ថិភាពក្នុងការដឹកជញ្ជូនល្បឿនបើកបរមិនឱ្យលើសពី៣០គ.ម ក្នុង១ម៉ នៅក្នុងតំបន់ភូមិ និងទីប្រជុំជន មិនឱ្យលើស១០គ.ម ក្នុង ១ម៉ោង ទេ) និងដើម្បីបញ្ចៀសគ្រោះថ្នាក់ចរាចរនានា។

ក្រុមហ៊ុនត្រូវធ្វើការជួសជុលស្ពានដែលមានស្រាប់ ដើម្បីធានាលើការដឹកជញ្ជូន និងប្រើប្រាស់ប្រភេទយានយន្តដែលមិន បង្កឱ្យបាក់ស្ពានដែលមានស្រាប់ទាំងនោះ។

ក្រុមហ៊ុនត្រូវសហការជាមួយមន្ទីរពាក់ព័ន្ធ ធ្វើការដោះស្រាយសម្រួលចរាចរក្នុងតំបន់មានការកកស្ទះ និងកន្លែងបត់ចូលការដ្ឋាន និងសម្រួលចរាចរនៅពេលដឹកជញ្ជូនត្រង់ស្ទូរ។

ក្រុមហ៊ុនត្រូវធ្វើការជួសជុលផ្លូវក្នុងតំបន់គម្រោងឱ្យបានល្អ និងធ្វើការថែរក្សាផ្លូវដែលខ្លួនបានប្រើប្រាស់ជាប្រចាំ។

នៅគ្រប់ចំណុចដែលខ្សែនេះឆ្លងកាត់ផ្លូវថ្នល់ក្រុមហ៊ុន ត្រូវគ្រោងជំឡើងកម្ពស់ខ្សែទាបបំផុតពីដី១៥ម (ស្តង់ដាអគ្គិសនី១៤,២ម) ហើយនឹងអនុវត្តការជំឡើងខ្សែអគ្គិសនីនេះភ្លាមៗ គឺមិនបន្លាយខ្សែឆ្លងកាត់ផ្លូវចោលនោះទេ។ ជាងនេះទៅទៀត ត្រូវធ្វើរបាខ្ពស់ (កម្ពស់យ៉ាងតិច ៦ម) ដើម្បីទ្រខ្សែអគ្គិសនីនៅពេលដែលជំឡើងខ្សែអគ្គិសនីកាត់ផ្លូវ ទោះជាផ្លូវរបស់ខ្លួនក៏ដោយ។ ទន្ទឹមនឹងនេះដែរ ក្រុមហ៊ុនត្រូវធ្វើ សេចក្តីជូនដំណឹងទៅអាជ្ញាធរ និងដាក់ស្លាកប្រកាសអំពីការដ្ឋានកំពុងសាងសង់ចម្ងាយពីការដ្ឋាន១០០ម និងស្នើសុំឱ្យ មានសមត្ថកិច្ច ផ្នែកចរាចរមកជួយធ្វើអន្តរាគមន៍ នៅពេលជំឡើងខ្សែអគ្គិសនីនេះ ជៀសវាងកើតមានគ្រោះថ្នាក់ ទាក់ខ្សែនេះ។

**គ.៧ សុខភាពសាធារណៈ**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ការងារសាងសង់គ្រឹះបង្គោល ការឈូសឆាយដី កសាងផ្លូវ និងដឹកជញ្ជូនសម្ភារសំណង់ អាចបង្កឱ្យម្យានការប៉ះពាល់ដល់សុខុមាលភាពបុគ្គលិក-កម្មកររបស់ក្រុមហ៊ុន និងប្រជាពលរដ្ឋមួយចំនួនចូលទៅតំបន់គម្រោងដោយ សារធូលីដី ធូលីស៊ីម៉ងត៍ ចំហាយ ចេញពីការប្រើប្រាស់សារធាតុគីមីជាដើម។

ដំណាក់កាលសាងសង់នេះ បង្កឱ្យមានផលប៉ះពាល់ដល់សុខភាពបុគ្គលិក-កម្មកររបស់ គម្រោងដោយសារតំបន់ខ្លះនៃគម្រោងនេះ ជាតំបន់ដែលកើតជំងឺគ្រុនចាញ់ និងគ្រុនសន្និ។ ម៉្យាងទៀត ប្រជាពលរដ្ឋនៅក្បែរតំបន់គម្រោងដូចជាប្រជាពលរដ្ឋរស់នៅ ភូមិស្ទឹងថ្មី ទាំងមូលអាចឆ្លងជំងឺអេដស៍ ជំងឺកាមរោគ ជំងឺរបេង ជំងឺឆ្លងផ្សេងៗ ពីបុគ្គលិក-កម្មករគម្រោង ដែលជ្រើសរើសមកពីឆ្ងាយដោយក្រុមហ៊ុនផងដែរ។

អាចប៉ះពាល់ដល់សុខភាពសាធារណៈ (ប្រជាពលរដ្ឋក្នុងតំបន់និងបុគ្គលិក-កម្មករគម្រោង) ដោយសារការប្រើប្រាស់ ឬ ចរាចរគ្រឿងញៀន។

អាចប៉ះពាល់ប្រជាពលដ្ឋ និងបុគ្គលិក-កម្មករគម្រោង ដោយសារមិនចាប់អារម្មណ៍អំពីសុវត្ថិភាពការងារ។

ក្នុងតំបន់គម្រោងនៅកន្លែងគ្មានប្រភពទឹកស្អាតសម្រាប់បរិភោគទេ ក្រុមហ៊ុនត្រូវខួងអណ្តូងទឹកស្អាតគ្រប់គ្រាន់នៅតាមជំរុំកម្មកររស់នៅបណ្តោះអាសន្នទាំងនោះ។

អាចមានគ្រោះថ្នាក់ដល់កម្មករជំឡើងខ្សែ និងបង្គោលដោយសារការធក់ (ទោះបីជាមិនទាន់ភ្ជាប់ចរន្តក៏ដោយ) ដោយសារ រន្ទះពីព្រោះខ្សែនេះមានចម្ងាយប្រមាណ ៥គ.ម ដូចនេះបើមានអាកាសធាតុមិនល្អបណ្តាលឱ្យមានរន្ទះកន្លែងណាមួយនោះចរន្តអគ្គិសនីនឹងស្រូបចូលតាមខ្សែ ឬបង្គោលធ្វើឆក់អ្នក ដែលប៉ះផ្ទាល់ទៅលើខ្សែ ឬបង្គោលដែកនេះ។



Draft

អាចមានប្រជាពលរដ្ឋ ឬជនណាម្នាក់ឡើងបង្គោលអគ្គិសនី អាចបណ្តាលឱ្យមានគ្រោះថ្នាក់ធ្លាក់ ឬមានការឆក់ (ទោះបីជា មិនទាន់ ភ្ជាប់ចរន្តក៏ដោយ)។

អាចនឹងមានការផ្ទុះស្សេខ្សែអគ្គិសនី រវាងខ្សែតង់ស្យុងខ្ពស់កំពង់ជំឡើង និងខ្សែតង់ស្យុងមធ្យមប៉ះគ្នា។

- វិធានការកាត់បន្ថយ

ក្រុមហ៊ុនប្រកាន់យកការរក្សាសុវត្ថិភាពការងារជាចំបង ក្នុងសកម្មភាពការងារប្រចាំថ្ងៃ។

ដើម្បីការពារសុខភាព ដែលបណ្តាលមកពីធូលីដី ក្នុងការងារសាងសង់គ្រឹះបង្គោល ការឈូស ឆាយដីកសាងផ្លូវ និងដឹកជញ្ជូនសម្ភារសំណង់ ក្រុមហ៊ុនត្រូវត្រៀមផ្តល់ម៉ាស់ការពារធូលីដី និងធ្វើការស្រោចទឹកលើផ្លូវថ្នល់ជាប្រចាំ មិនឱ្យប៉ះពាល់ការហុយធូលីដី ធ្វើឱ្យប៉ះពាល់សុខភាពបុគ្គលិក-កម្មករគម្រោង និងសាធារណជន ដែលធ្វើដំណើរឆ្លងកាត់ការដ្ឋានសាងសង់ឡើយ។

ត្រូវសាងសង់ជំរុំស្នាក់នៅរបស់បុគ្គលិក-កម្មករគម្រោងឱ្យបានសមរម្យ ដោយមានការផ្គត់ផ្គង់ទឹកស្អាត មានបង្គន់អនាម័យ បន្ទប់ទឹកគ្រប់គ្រាន់ និងមានកម្មវិធីអប់រំសុវត្ថិភាពការងារដល់បុគ្គលិក-កម្មកររបស់គម្រោង។

ក្រុមហ៊ុន ជ្រើសរើសគ្រូពេទ្យ ដែលមានសមត្ថភាពនៅប្រចាំការក្នុងការដ្ឋាន និងជំរុំស្នាក់នៅរបស់កម្មករ និងត្រៀមថ្នាំពេទ្យ និងបរិក្ខារគ្រប់គ្រាន់ជាប្រចាំសម្រាប់ការពិនិត្យ និងព្យាបាលជូនបុគ្គលិក-កម្មកររបស់គម្រោង ហើយមានរថយន្តសង្គ្រោះបន្ទាន់នៅពេល ដែលមានករណីគ្រោះថ្នាក់កើតឡើងជាយថាហេតុ។

ក្រុមហ៊ុន ត្រូវធ្វើការអប់រំសុខភាពអនាម័យ ដល់បុគ្គលិក-កម្មកររបស់ខ្លួនក្នុងការទប់ស្កាត់ជំងឺទាំងនោះ កុំឱ្យឆ្លងទៅប្រជាពលរដ្ឋក្នុងតំបន់នោះ។

ក្រុមហ៊ុន ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ពិសេសទប់ស្កាត់ការជួញដូរចរាចរគ្រឿងញៀន និង មនុស្ស។

ក្នុងពេលសាងសង់ក្រុមហ៊ុនមានដំឡើងខ្សែការពាររន្ទះ និងប្រព័ន្ធសុវត្ថិភាពការពារឆក់ នៅពេលដែលកើតមានចរន្តអគ្គិសនីដោយចៃដន្យ ដែលបណ្តាលមកពីអាកាសធាតុ។

ក្រុមហ៊ុន ត្រូវសហការជាមួយការិយាល័យសុខាភិបាលស្រុកនៅក្នុងតំបន់នេះ ដើម្បីការពារទប់ស្កាត់ជំងឺឆ្លងផ្សេងៗ ដែលកើតមានឡើងជាយថាហេតុ។

ក្រុមហ៊ុន ត្រូវសាងសង់គ្រឿងការពារសត្វ-មនុស្ស ភ្ជាប់នឹងបង្គោលអគ្គិសនីទាំងបួនកុំឱ្យសត្វ-មនុស្សឡើងបាន និងមានដាក់ស្លាកសញ្ញាហាមឃាត់ ភ្លាមៗមុននឹង បញ្ចប់សាងសង់បង្គោលមួយ រួចហើយទៅសាងសង់បង្គោលមួយទៀតតាមការគ្រោងខាងលើ។

Draft







រូបទី៥: បន្ទះដែកអ៊ីណុក ការពារសត្វ និងមនុស្សឡើង

ក្រុមហ៊ុនត្រូវដំឡើងខ្សែនៅគ្រប់ចំណុច នៅពេលដែលមានខ្សែតង់ស្យុងមធ្យមដទៃទៀត ឆ្លងកាត់ពីលើគ្នាដោយធានាសុវត្ថិភាពកុំឱ្យមានការឆ្លងចរន្តធ្វើឱ្យផ្ទុះដាច់ខ្សែ អាចធ្វើឱ្យប៉ះពាល់ដល់អាយុជីវិតមនុស្ស។ ***សម្គាល់***៖ នៅខែកញ្ញា ឆ្នាំ ២០១៥នេះ នៅតំបន់គម្រោងមិនទាន់មាន ខ្សែអគ្គិសនីតង់ស្យុងមធ្យម នៅឡើយទេ។

**គ.៨ សោភ័ណ្ឌភាព/ ទេសភាព**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ការសាងសង់បង្គោល និងខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់នេះ មានការប៉ះពាល់ដល់សោភ័ណ្ឌភាពទេសភាពក្នុងតំបន់គម្រោង ដោយសារការដំឡើងបង្គោលមិនមានការរត់ត្រង់គ្នា ឬកម្ពស់មិនស្មើគ្នាជាដើម។ល។

ម៉្យាងទៀត អាចនឹងបង្កផលប៉ះពាល់ដល់សោភ័ណ្ឌភាពដល់តំបន់ការពារ និងអភិរក្សទាំងនោះដែរ ដោយសារការរៀបចំបង្គោល និងខ្សែបញ្ជូនតង់ស្យុងខ្ពស់២៣០គ.វ៉នេះ មិនរត់តាមជួរល្អ និងកាប់ឆ្ការព្រៃឈើក្នុងតំបន់នេះ។

ការហុយធូលី ដោយសារការដឹកការដុតព្រៃសម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធជាដើម ក៏អាចធ្វើឱ្យប៉ះពាល់ដល់សោភ័ណ្ឌភាព និងទេសភាពកន្លែងនោះដែរ។

ការបោះសំណល់រឹង-រាវគ្រប់ប្រភេទ ដូចជាសំបកកង់ឡាន សំបកដប ស្បោងប្លាស្ទិកគ្រប់ប្រភេទ ក្រណាត់ខោ អាវ សំណល់បេតុង។ល។ ធ្វើឱ្យកខ្វក់តំបន់នេះ ដោយសំណល់ទាំងនេះមិនងាយនឹងរលាយទេ។

➢ វិធានការកាត់បន្ថយ

ការសាងសង់បង្គោល និងខ្សែអគ្គិសនីនេះ ក្រុមហ៊ុនធ្វើការតំរង់ទិស និងកំណត់កម្ពស់ទៅតាមស្ថានភាពដី (កម្ពស់ចាប់ពី២០-៤០ម) ឱ្យបានសមស្របដើម្បីរំលេចនូវសោភ័ណ្ឌភាព នៃប្រព័ន្ធខ្សែអគ្គិសនីនេះ។ ម៉្យាងទៀតក្រុមហ៊ុននឹងសំអាតព្រៃទៅតាមទំហំកំណត់នៃចំណីគន្លងខ្សែអគ្គិសនី (ម្ខាង១៥ម ពីអក្សបង្គោលអគ្គិសនី) និងកាត់តំរឹមដើមឈើ

តាមគន្លងខ្សែអគ្គិសនីនេះឱ្យបានស្មើល្អ ដើម្បីធ្វើឱ្យប្រព័ន្ធខ្សែអគ្គិសនីកាន់តែមានសោភ័ណ្ឌភាព ថែមទៀតជាពិសេសការពារពពួកសត្វាលោតតោងទៀតផង។

ក្រុមហ៊ុនត្រូវធ្វើគន្លងខ្សែនាំអគ្គិសនី ឱ្យបានត្រង់ល្អ ដើម្បីមើលទៅរត់ត្រង់ជួរគ្នា។

ក្រុមហ៊ុនត្រូវធ្វើការស្រោចទឹកជាប្រចាំទៅលើផ្លូវថ្នល់ដែលខ្លួនកំពុង ប្រើប្រាស់សាងសង់គម្រោង។

**គ.៩ ហានិភ័យ**

- ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលសាងសង់នេះ អាចនឹងមានហានិភ័យ ដោយសារគ្រោះធម្មជាតិ ការកើតមានការរញ្ជួយដី នៅក្នុងតំបន់គម្រោងការទទួលរងឥទ្ធិពលពីព្យុះទីហ្វុង ឬព្យុះផ្សេងទៀត ដែលជាហេតុបង្កឱ្យមានមហន្តរាយធំៗរលំបាក់ ឬដាច់ខ្សែអគ្គិសនី និងការខូចហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គម្រោង ដែលកំពុងសាងសង់ ការបាត់បង់ ឬខូចខាតសម្ភារ និងគ្រឿងចក្រ សាងសង់ ជាពិសេសការធ្វើឱ្យរងរបួស និងស្លាប់បាត់បង់ជីវិត ដល់បុគ្គលិកកម្មករ ព្រមទាំងប្រជាពលរដ្ឋនៅក្នុង/ក្បែរខាងតំបន់គម្រោង។

អាចនឹងកើតមានការផ្ទុះសម្ភារ គ្រឿងផ្ទុះ ឆេះប្រេងឥន្ធនៈ នៅកន្លែង ឬឃ្លាំងស្តុករបស់គម្រោង និងការឆេះព្រៃក្នុងតំបន់គម្រោង ដែលបណ្តាលមកពីការធ្វេសប្រហែស ឬអំពើភេរវកម្ម ក៏អាចបង្កឱ្យមានមហន្តរាយដល់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គម្រោង និងធនធានធម្មជាតិក្នុងតំបន់ និងអាយុជីវិតមនុស្សទៀតផង ។

អាចនឹងកើតមានសង្គ្រាមឈ្លានពានលើបូរណភាពទឹកដីនៃប្រទេសកម្ពុជា ក៏ជាឧបសគ្គ ដល់ការងារសាងសង់គម្រោង ឬសង្គ្រាមអាចបំផ្លាញគម្រោងទាំងស្រុងក៏សឹងមាន។

- វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវប្រុងប្រយ័ត្នគ្រប់វិនាទី ក្នុងការការពារសុវត្ថិភាព ចំពោះគ្រឿងផ្ទុះ ការឆេះព្រៃ និងឆេះប្រេងឥន្ធនៈ ដោយធ្វើការសហប្រតិបត្តិការណ៍ជាមួយស្ថាប័នពាក់ព័ន្ធ និងសហការជាមួយអាជ្ញាធរមូលដ្ឋាន។

ក្រុមហ៊ុន ត្រូវសហការជាមួយរដ្ឋអំណាចមូលដ្ឋាន ដើម្បីទប់ស្កាត់រាល់អំពើភេរវកម្មក្នុងតំបន់គម្រោង ឱ្យទាន់ពេលវេលា។

បណ្តាញព័ត៌មានរបស់ក្រុមហ៊ុន ត្រូវធ្វើការជូនដំណឹងរាល់ហេតុការណ៍កើតឡើង ដោយសារហានិភ័យបង្កឡើងដោយគ្រោះ ធម្មជាតិទាំងនោះជាបន្ទាន់ទៅដល់បុគ្គលិកកម្មករក៏ដូចប្រជាពលរដ្ឋនៅក្បែគម្រោងនោះឱ្យទាន់ពេលវេលា។

ក្រុមហ៊ុនត្រូវរៀបចំបំរុងទុកនូវយានយន្តសង្គ្រោះ សម្ភារ និងថវិកាដើម្បីធានាការសង្គ្រោះជាបន្ទាន់នូវហេតុការខាងលើនេះទាន់សភាពការណ៍ និងមានប្រសិទ្ធិភាពខ្ពស់។

### ៧.៧.៣ ដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោង (Project Operation & Maintenance)

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោងនេះគឺជាដំណាក់កាលមួយមានរយៈពេលវែងជាងគេ (គម្រោងនេះមិនទាន់ទទួលបានកិច្ចសន្យាអភិវឌ្ឍគម្រោងពីរាជរដ្ឋាភិបាល)នៅឡើយទេ។ សកម្មភាពគម្រោងក្នុងដំណាក់កាលនេះអាចនឹងបង្កឱ្យមានការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ ដូចតទៅ ៖

**ក. ធនធានរូបសាស្ត្រ**

**ក.១ ការហូរច្រោះ**

- ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោង អាចមានការហូរច្រោះ នាំឱ្យខូចគុណភាពដី នៅតាមទីជម្រាលជើងទេរ នៃជញ្ជាំងភ្នំ ឬដីទួលតាមដងផ្លូវចូលសាងសង់បង្គោលអគ្គិសនី ហើយផ្លូវនេះប្រើប្រាស់សម្រាប់ការថែទាំគម្រោង។

ការបាក់ដីនៅតាមកន្លែង ទាំងនេះ ដោយសារទឹកភ្លៀងខ្លាំង ធ្វើឱ្យស្ទះផ្លូវ ឬបាត់បង់ជីជាតិដីនៅតំបន់នេះ ដោយសារដីនេះគ្របពីលើ។

អាចនឹងមានការបំពុលដីដោយសារការលេចធ្លាយ ឬកំពប់ប្រេងគ្រប់ប្រភេទ ឬសំណល់រឹង-រាវគ្រប់ប្រភេទ ដែលក្រុមហ៊ុនយកមកដំណើរការថែទាំគម្រោងនេះ។

- វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវមានអ្នកត្រួតពិនិត្យជាប្រចាំ នៅតាមផ្លូវចូលទៅបង្គោលអគ្គិសនី ជាពិសេសនៅតាមជញ្ជាំងភ្នំខ្ពស់ៗ ប្រសិនបើ មានការបាក់ ត្រូវកាយដីនោះចេញជាបន្ទាន់ រួចយកទៅចាក់នៅកន្លែងមានសុវត្ថិភាព មិនប៉ះពាល់ដល់បរិស្ថាន ហើយត្រូវដាំស្មៅ នៅកន្លែងបាក់នេះឡើងវិញ ដើម្បីការពារការហូរច្រោះទៀត។

ម៉្យាងទៀត ក្រុមហ៊ុនត្រូវធ្វើការគ្រប់គ្រង់សំណល់រឹង-រាវគ្រប់ប្រភេទឱ្យបានល្អ មិនចោលពាសវាលពាសកាល ដោយមាន កន្លែងទុកដាក់ត្រឹមត្រូវ។ ជាងនេះទៅទៀតក្រុមហ៊ុនត្រូវធ្វើការប្រមូលសំណល់រឹង-រាវគ្រប់ប្រភេទចេញពីទីតាំងការដ្ឋាននានាកន្លែង ស្នាក់នៅរបស់បុគ្គលិក-កម្មករ ដែលបានមកបោះទីតាំងក្នុងពេលសាងសង់គម្រោងឱ្យបានស្អាត។

**ក.២ គុណភាពទឹក (លើដី និងក្រោមដី )**

- ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោង អាចនឹងប៉ះពាល់គុណភាពទឹកលើដី និងក្រោមដី ដោយសារការប្រើប្រាស់សារ ធាតុគីមី ដើម្បីបង្អាក់ការលូតលាស់របស់ដើមឈើក្នុងពេលដំណើរការគម្រោងនេះ។

អាចនឹងមានការបំពុលទឹកដោយសារការលេចធ្លាយ ឬកំពប់ប្រេងគ្រប់ប្រភេទ ដែលក្រុមហ៊ុនយកមកដំណើរការថែទាំ គម្រោងនេះរួចហូរចូលទៅក្នុងប្រភពទឹកធម្មជាតិក្បែរនោះ។

- វិធានការកាត់បន្ថយ

ក្រុមហ៊ុនមិនត្រូវប្រើប្រាស់សារធាតុគីមី ដើម្បីសំអាត ឬបង្អាក់ការលូតលាស់របស់ដើមឈើនោះទេ។

ក្រុមហ៊ុនត្រូវសាងសង់សំណង់រណ្តៅបេតុងពីក្រោមត្រង់ស្វូ ការពារការលេចធ្លាយ ឬកំពប់ប្រេង ដែលប្រើសម្រាប់ត្រង់ស្វូ ទាំងនោះ។ ចំពោះប្រេងដែលចាស់ៗ ឬប្រេងដែលមាននៅក្នុងរណ្តៅ ក្រុមហ៊ុននឹងយកទៅលក់ឱ្យសិប្បកម្មកែច្នៃប្រេងខ្មៅ (ប្រេង ដែលប្តូរពីម៉ាស៊ីនភ្លើង ឬគ្រឿងយន្ត) ក្នុងស្រុកធ្វើជាគ្រឿងចំហេះផ្សេងៗ។

ក្រុមហ៊ុនត្រូវធ្វើការគ្រប់គ្រងយានយន្តគ្រប់ប្រភេទមិនឱ្យលេចធ្លាយប្រេងដែលជាហេតុនាំឱ្យមានការបំពុលទឹកនេះទេ។

**ក.៣ គុណភាពខ្យល់**

- ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោង អាចមានការបំពុលខ្យល់ដោយសារ ក្លិនមិនល្អចេញពីសំណល់រឹង-រាវ សំណល់ពីផ្ទះបាយ ឃ្លាំងស្តុកប្រេង កន្លែងបង្គន់ កន្លែងបង្ហូរទឹកសំអុយចោលជាដើម។

- វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវមានអ្នកត្រួតពិនិត្យជាប្រចាំនៅតាមទីតាំងដាក់សម្រាម កន្លែងបង្ហូរសំណល់រាវពីបង្គន់ ពីបន្ទប់ទឹក ដោយជឿជាក់ថាសំណល់រឹង-រាវទាំងអស់នោះត្រូវបានទុកដាក់ត្រឹមត្រូវមិនមានជះក្លិនមិនល្អនោះទេ។ ប្រសិនបើអាងសិបទិកបាត់បង់សមត្ថភាព ឬពេញត្រូវធ្វើការជួសជុល និងបូមសំអាតជាបន្ទាន់។



Draft

## ខ. ធនធានជីវសាស្ត្រ

### ខ.១ ព្រៃឈើការពារ/តំបន់ការពារ /ឧទ្យានជាតិ

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់ប្រតិបត្តិ និងថែទាំនេះក៏អាចប៉ះពាល់ដល់តំបន់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដោយសារមានការទន្ទ្រានរានព្រៃយកដីធ្វើកម្មសិទ្ធិខុសច្បាប់ព្រោះមានផ្លូវចេញចូលក្នុងតំបន់ស្រួលពីសំនាក់ជនឆ្លៀតឱកាសមួយចំនួន។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនធ្វើការសហការជាមួយអាជ្ញាធរ និងរដ្ឋបាលព្រៃឈើថែទាំស្លាកប៉ាន់ណូ ដែលបានដំឡើងនេះ ជាប្រចាំដើម្បីឱ្យជន ឱកាសនិយមទាំងនោះបានឃើញ បើល្មើសនឹងត្រូវជាប់គុករហូតដល់១០ឆ្នាំ។ ជាងនេះទៅទៀត នៅតាមបង្គោលអគ្គិសនី ២៣០គ.វ៉ និមួយៗក៏ត្រូវដាក់ស្លាកនេះដែរ។ ក្រុមហ៊ុនមានកញ្ចប់ថវិកាចំនួន២៥.០០០ដុល្លារអាមេរិកសម្រាប់ការអប់រំផ្សព្វផ្សាយបរិស្ថាន (មើលក្នុងតារាង ៨-២)។

### ខ.៣ ធនធានព្រៃឈើ និងជម្រកសត្វព្រៃ

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់ប្រតិបត្តិ និងថែទាំនេះក៏អាចនឹងប៉ះពាល់ដល់ធនធានព្រៃឈើ ដែលជាជម្រកសត្វព្រៃច្រើនប្រភេទដូចមានចែង ក្នុងជំពូក៥ ចំណុច ៥.១.២.១ ដោយសកម្មភាពកាប់សំអាតមែក ឬដើមឈើតាមគន្លងខ្សែអគ្គិសនីនេះ ដោយមិនឱ្យខ្ពស់ជាង៣ម។

ម្យ៉ាងទៀតអាចកើតមានឡើងភ្លើងឆេះព្រៃក្បែរតំបន់គម្រោង ដោយសារការទុស្សេខ្សែអគ្គិសនី ឬធ្លាក់ផ្កាភ្លើង (មែកឈើដុះ លូតទៅប៉ះដែនរបស់ខ្សែអគ្គិសនី នារដូវប្រាំងស្ងួត) ទៅលើព្រៃឈើ នឹងបណ្តាលឱ្យមានការឆេះព្រៃកើតឡើង។

➢ វិធានការកាត់បន្ថយ

ការកាប់សំអាតមែក ឬដើមឈើនេះ គឺក្រុមហ៊ុននឹងកាប់តែក្នុងទំហំ នៃចំណីគន្លងខ្សែអគ្គិសនី (ម្ខាង១៥ម សរុប ៣០ម)តែ ប៉ុណ្ណោះ ហើយនឹងសហការថែរក្សាព្រៃឈើសងខាងចំណីគន្លងខ្សែអគ្គិសនីនេះ ជាមួយមន្ត្រីជំនាញព្រៃឈើឱ្យបានល្អប្រសើរ។

ការថែទាំ និងកាប់សំអាតមែក ឬដើមឈើក្រោមគន្លងខ្សែអគ្គិសនីនេះ គឺក្រុមហ៊ុនធ្វើតែពេលថ្ងៃតែប៉ុណ្ណោះ ជៀសវាងការរំខានដល់សត្វព្រៃ ពីព្រោះនៅពេលយប់ សត្វព្រៃភាគច្រើនរកស៊ី និងមួយចំនួនទៀតដេកនៅព្រៃក្បែរៗតំបន់ខ្លះនៃគម្រោងនេះ។

ក្រុមហ៊ុនធ្វើការអប់រំ និងហាមឃាត់ដល់បុគ្គលិក-កម្មកររបស់គម្រោង មិនឱ្យទន្ទ្រានចូលព្រៃ ធ្វើការបរបាញ់ ឬដាក់អន្ទាក់ ឬជួញដូរសត្វព្រៃនោះឡើយ។

ក្រុមហ៊ុនត្រូវដាក់ពិន័យដល់បុគ្គលិក-កម្មករណា ដែលប្រព្រឹត្តល្មើសនឹងការហាមឃាត់ខាងលើ។

ក្រុមហ៊ុនត្រូវធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាននិងរដ្ឋអំណាចមូលដ្ឋាន ដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដែលកើតឡើងជាយថាហេតុនៅក្នុងតំបន់គម្រោង។

ក្រុមហ៊ុនត្រូវរៀបចំប្រព័ន្ធផ្តល់ព័ត៌មាន នៅតាមចំណុចសំខាន់មួយចំនួន ដែលមានបុគ្គលិកព័ត៌មានគម្រោង មន្ត្រីជំនាញពាក់ព័ន្ធ និងរដ្ឋអំណាចមូលដ្ឋាន សហការគ្នាទប់ស្កាត់ភ្លើងឆេះព្រៃ និងមានប្រព័ន្ធផ្តាច់ចរន្តអគ្គិសនីស្វ័យប្រវត្តិ នៅពេលមានហេតុការណ៍ទុស្សេខ្សែអគ្គិសនី និងភ្លើងឆេះព្រៃកើតឡើង។



Draft

### ខ.៤ ជីវសាស្ត្រសត្វព្រៃ

➢ ហេតុប៉ះពាល់អវិជ្ជមាន

ការទន្ទ្រានចូលព្រៃធ្វើការបរបាញ់ ដាក់អន្ទាក់ និងចាប់សត្វពីសំណាក់បុគ្គលិក-កម្មករ ដែលធ្វើប្រតិបត្តិការ និងថែទាំ គម្រោង និងអ្នកក្រៅ ធ្វើឱ្យបាត់បង់សត្វព្រៃក្នុងតំបន់គម្រោងគួរឱ្យព្រួយបារម្ភ។

អាចមានការឆក់ដល់មនុស្ស-សត្វ ជាពិសេសពពួកសត្វស្វា និងទោច ដោយសារសត្វនេះចូលចិត្តឡើងបង្គោលអគ្គិសនី។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវហាមឃាត់ដាច់ខាតដល់បុគ្គលិក-កម្មករ របស់ខ្លួនក្នុងការប្រមាញ់ ឬជួញដូរសត្វព្រៃនៅក្នុង និងក្បែរខាង តំបន់គម្រោង។

ក្រុមហ៊ុនត្រូវធ្វើការអប់រំ និងដាក់វិន័យដល់បុគ្គលិក-កម្មករគម្រោងមិនឱ្យធ្វើការចាប់ ឬបរបាញ់សត្វព្រៃ និងធ្វើចរាចរ លក់ដូរសត្វព្រៃនៅក្នុងតំបន់នេះឡើយ។

ក្រុមហ៊ុនត្រូវសង់គ្រឿងការពារមនុស្ស-សត្វទៅនឹងបង្គោលទាំងបួនដើម្បីការពារកុំឱ្យមនុស្ស-សត្វឡើងបាន។

## គ. ធនធានសេដ្ឋកិច្ចសង្គម

### គ.១ ការប្រើប្រាស់ដី និងការតាំងលំនៅឋានដ្ឋានឡើងវិញ

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលនេះ អាចមានការទន្ទ្រានកាន់កាប់ដីពីអ្នកមកពីខាងក្រៅ និងជនឱកាសនិយមប្រើមធ្យោបាយគ្រប់រូបភាព ដើម្បីចាប់យកដីនៃតំបន់ព្រៃការពារនេះ គួរឱ្យព្រួយបារម្ភពីព្រោះគម្រោងមានផ្លូវចេញចូលស្រួល បច្ចុប្បន្នគ្មានផ្ទះប្រជាជនរស់នៅ ក្រោមគន្លងនៃខ្សែនេះទេ (ខ្សែ២៣០គ.វ៉ មិនទាន់បានសាងសង់នៅឡើយ ការសិក្សាយកតាមចំណុចយាមកា ដែលចែងក្នុងជំពូក៤ ចំណុច៤.៣) ដូចបានរៀបរាប់ខាងលើរួចមកហើយ។ ហេតុដូច្នេះ ហើយក្រោយពីការសង់គម្រោង នេះរួចនឹងមានការសង់លំនៅដ្ឋាន និងសំណង់ផ្សេងៗទៀតនៅក្រោមគន្លងនេះមិនខានឡើយ ដែលធ្វើឱ្យក្រុមហ៊ុន និងអាជ្ញាធរមូលដ្ឋានពិបាកដោះស្រាយ ពីព្រោះកម្ពស់ខ្សែមផ្ទាល់ដី យ៉ាងហោចណាស់ក៏សរសរដំបូលមានកម្ពស់ពី៣,៥ម ទៅ៤ម ដែរ លើសពីនេះអ្នក ស្រុកទាំងនេះ មានដំឡើងអង់តែន ឬលើកបង្គោលផ្សេងៗ ដែលមានកម្ពស់ខ្ពស់ជា៣ម ដែលនឹងធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពរបស់ពួកគេ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវដាក់ស្លាកតំបន់ដីចំណីគន្លងខ្សែ ២៣០គ.វ៉នេះ នៅតាមបង្គោលអគ្គិសនីនៅចន្លោះរៀងរាល់២បង្គោល ម្តងនៃខ្សែ២៣០គ.វ៉នេះ ដើម្បីឱ្យប្រជាជនបានដឹង និងឃើញ ដូចក្រសួងសាធារណៈការ ដែលបានដាក់តាមផ្លូវជាតិនានា។ ***សម្គាល់:*** *ក្នុងពេលចុះសិក្សាផលប៉ះពាល់តាមគន្លងខ្សែនេះ ក្រុមការងារ SAWAC បានធ្វើការជូនដំណឹង និងពន្យល់ដល់អ្នកភូមិពាក់ព័ន្ធអំពីចំណីគន្លង ខ្សែនេះ និងអំពីសុវត្ថិភាព មិនឱ្យមានការសាងសង់សំណង់ ផ្សេងដែលមានកម្ពស់ខ្ពស់ជាង៣ម ក្រោមគន្លងខ្សែនេះផងដែរ។*

### គ.៣ ប្រពៃណី វប្បធម៌ និងសាសនា

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោងនេះ អាចនឹងប៉ះពាល់ដល់ទំនៀមទំលាប់ប្រពៃប្រណីរបស់ប្រជាពលរដ្ឋដែលរស់នៅ ក្បែរតំបន់គម្រោង ដោយសារក្រុមហ៊ុននាំយកបុគ្គលិក-កម្មករគម្រោងមកពីតំបន់ផ្សេងទៀត ឬជនបរទេស។



Draft

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវធ្វើការណែនាំអប់រំដល់ បុគ្គលិក-កម្មកររបស់គម្រោងឱ្យមានការគោរពទំនៀមទំលាប់ប្រពៃណី និងជំនឿរបស់ប្រជាពលរដ្ឋរស់នៅជុំវិញក្នុងតំបន់ទីតាំងគម្រោង។

ក្រុមហ៊ុនត្រូវដាក់វិន័យដល់បុគ្គលិក-កម្មករគម្រោង ដែលបំពានលើទំនៀមទំលាប់ប្រពៃណីវប្បធម៌ និងជំនឿសាសនារបស់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសប្រជាពលរដ្ឋដែលរស់ក្បែរតំបន់គម្រោងដូចជា ភូមិស្ទឹងថ្មីទាំងមូលដើម។

**គ.៤ ប្រពន្ធ័ផ្គត់ផ្គង់ទឹក**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោងនេះ អាចនឹងមានការប៉ះពាល់ដល់ការប្រើប្រាស់ទឹករបស់បុគ្គលិក-កម្មករគម្រោង ដោយនៅតំបន់គម្រោងពុំទាន់មានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតទេ។

ការគ្រប់គ្រងសំណល់រាវ ដែលចេញពីបង្គន់ បន្ទប់ទឹក ផ្ទះបាយ ការបន្ទោរបង់ក្នុងប្រភពទឹកធម្មជាតិ ឃ្លាំងស្តុកសម្ភារ រោងជាងជាដើម ដែលធ្វើឱ្យខូចដល់ប្រភពទឹកសម្រាប់ផ្គត់ផ្គង់ក្នុងតំបន់។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវរៀបចំប្រព័ន្ធទឹកស្អាតសម្រាប់ផ្គត់ផ្គង់ទឹកស្អាតក្នុងការប្រើប្រាស់របស់បុគ្គលិក-កម្មករឱ្យមានលក្ខណៈល្អប្រសើរ។

នៅអនុស្ថានីយពោធិ៍សាត់ក្រុមហ៊ុនត្រូវសាងសង់អាងសិបទិកទំនើប និងថែទាំវាជាប្រចាំសម្រាប់សំអាតសំណល់រាវ ឬទឹកកខ្វក់ ដែលចេញពីបង្គន់ បន្ទប់ទឹក ផ្ទះបាយ ឃ្លាំងសម្ភារ ដើម្បីរក្សាគុណភាពទឹកលើដី និងក្រោមដីជុំវិញតំបន់នោះ។

អប់រំណែនាំបុគ្គលិក-កម្មករគម្រោង ឱ្យយល់ដឹងអំពីអនាម័យមិនឱ្យមានការបន្ទោរបង់ក្នុងប្រភពទឹកធម្មជាតិ ឬសាធារណៈ ឡើយស្គាល់នូវកន្លែងទុកដាក់សម្រាម ដែលក្រុមហ៊ុនបានរៀបចំកសាងក្នុងទីតាំងស្នាក់នៅ ហើយដាក់ពិន័យដល់បុគ្គលិក-កម្មករណា ដែលមិនព្រមធ្វើតាមការណែនាំ។

ក្រុមហ៊ុនត្រូវចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងសំណល់រឹង-រាវ ដោយសាងសង់បង្គន់អនាម័យ ព្រមទាំងរៀបចំប្រមូលសំណល់រឹង និងសម្រាមយកទៅចោល នៅទីតាំងដែលមានសុវត្ថិភាព។

ក្រុមហ៊ុនត្រូវធ្វើការសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធដើម្បីកែប្រែតំបន់គម្រោងឱ្យមានអនាម័យ និង បរិស្ថានល្អ។

**គ.៥ តំបន់ទេសចរណ៍/ រមណីយដ្ឋាន/ ទីកន្លែងកំសាន្ត**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោងនេះ អាចនឹងមានការប៉ះពាល់ដល់តំបន់នេះដែលជាតំបន់ទេសចរណ៍-បរិស្ថាន ឬអេកូ-ទេសចរណ៍ ដោយសារការប្រមូលសំណល់រឹង-រាវ គ្រប់ប្រភេទ ដូចជា សំបកកង់ឡាន ស្បោងប្លាស្ទិក ក្រណាត់ សំបកដប គ្រប់ប្រភេទ មិនបានស្អាតតាមការដ្ឋានសាងសង់បង្គោលនៅតាមទីតាំងបោះជំរុំស្នាក់នៅបណ្តោះអាសន្ន កន្លែងបង្គន់ បន្ទប់ទឹក ផ្ទះបាយ ឃ្លាំងស្តុកសម្ភារៈ រោងជាងជាដើមដែលធ្វើឱ្យកខ្វក់តំបន់នេះ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុន ត្រូវធ្វើការប្រមូលសម្រាម សំណល់រឹង-រាវទាំងអស់នោះ ឱ្យបានស្អាតពីទីតាំងដូចបាន រៀបរាប់ខាងលើរួចសំណល់ នេះត្រូវដឹកយកទៅដាក់ក្នុងរណ្តៅសុវត្ថិភាព (ឆ្ងាយពីប្រភពទឹក) រួចកប់វាឱ្យបានត្រឹមត្រូវ។ ចំណែកឯង

Draft

ការដ្ឋាន ឬទីតាំងបោះ ជំរុំស្នាក់នៅបណ្តោះអាសន្ន និងទីតាំងផ្សេងៗទៀតរបស់អ្នកម៉ៅការបន្ត ក្រុមហ៊ុនក៏ត្រូវទទួលខុសត្រូវក្នុងការសំអាតផងដែរ។

**គ.៦ ផ្លូវគមនាគមន៍**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ការកកចង្អៀតលើដងផ្លូវ និងបង្កឱ្យមានគ្រោះថ្នាក់ ដោយសារសកម្មភាពថែទាំគម្រោង និងការធ្វេសប្រហែសក្នុងការបើកបរ របស់បុគ្គលិក-កម្មករគម្រោង។

អាចនឹងធ្វើឱ្យមានការខូចខាតផ្លូវ ដោយសារការថែទាំគន្លងខ្សែអគ្គិសនីនេះ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុន ត្រូវធ្វើការសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីសម្រួលចរាចរណ៍នៅពេលដែលមានការថែទាំគន្លងខ្សែម្តងៗ។

ក្រុមហ៊ុនត្រូវធ្វើការថែទាំជួសជុលផ្លូវ ឬពង្រីកផ្លូវដើម្បីធានាសុវត្ថិភាព និងសម្រួលចរាចរក្នុងតំបន់គម្រោងឱ្យបានល្អប្រសើរ។

ក្រុមហ៊ុនត្រូវជ្រើសរើសអ្នកបើកបរអាជីពដែលមានបទពិសោធន៍ និងមានស្មារតីល្អ។

**គ.៧ សុខភាពសាធារណៈ**

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោង អាចបង្កឱ្យមានការប៉ះពាល់ដល់សុខុមាលភាព របស់ប្រជាពលរដ្ឋក្នុងតំបន់នេះ ដោយសារបុគ្គលិក-កម្មកររបស់ក្រុមហ៊ុនអាចចម្លងជំងឺផ្សេងៗដល់អ្នកភូមិ ដូចជាជំងឺអេដស៍ ជំងឺកាមរោគ។ល។

ម៉្យាងទៀតអាចមានការប៉ះពាល់ដល់សុខភាពសាធារណៈ ដោយសារការគ្រប់គ្រងសំណល់រឹង-រាវមិនបានល្អ។

អាចមានគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស នៅធ្វើដំណើរកាត់តាមគន្លងខ្សែបញ្ជូនអគ្គិសនី២៣០kV នេះដោយសារការរងឥទ្ធិពល ដែនអគ្គិសនីភ្លុចអាំងឌុចស្យុងអេឡិកត្រូស្តាទិក និងអេឡិកត្រូម៉ាញេទិកនៅតាមគន្លងខ្សែ៥គ.ម ឬឆ្លងចរន្តតាមដើមឈើដែលមាន មែកវាទោរទៅប៉ះចូលក្នុងដែនអគ្គិសនីទាំងនេះ។

➢ វិធានការកាត់បន្ថយ

ធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិក-កម្មករ ដើម្បីទប់ស្កាត់ជំងឺអេដស៍ និងជំងឺកាមរោគ កុំឱ្យកើតមាននិងឆ្លងទៅ ប្រជាពលរដ្ឋក្បែរតំបន់គម្រោងនេះ។

ក្រុមហ៊ុនត្រូវធ្វើការពិនិត្យតាមដានគុណភាពទឹកសំអុយដែលបញ្ចេញពីការិយាល័យ ឃ្លាំងសម្ភារ និងកន្លែងស្នាក់នៅរបស់ បុគ្គលិក-កម្មករជាប្រចាំ ប្រសិនបើគុណភាពទឹក ដែលបញ្ចេញទៅក្រៅនេះមានការបំពុល ក្រុមហ៊ុននឹងរិះរកមធ្យោបាយ ដើម្បីធ្វើការកាត់បន្ថយ ដោយសហការជាមួយស្ថាប័នពាក់ពន្ធ័។

ក្រុមហ៊ុនត្រូវធ្វើការសហការជាមួយស្ថាប័នសុខាភិបាល ដើម្បីទប់ស្កាត់ជំងឺឆ្លង ដែលកើតឡើងជាយថាហេតុ។

ក្រុមហ៊ុនត្រូវគ្រប់គ្រងសំណល់ រឹង-រាវឱ្យបានល្អ តាមបទដ្ឋានបច្ចេកទេស។

ក្រុមហ៊ុនត្រូវត្រួតពិនិត្យស្ថានភាពខ្សែអគ្គិសនី ជាពិសេសចំណុចខ្សែដក់មកដីមានកម្ពស់៩មយ៉ាងតិច និងកន្លែងខ្សែឆ្លងកាត់ ផ្លូវ១៥ម យ៉ាងតិចនៅពេលមានអាកាសធាតុ មិនល្អកើតឡើងម្តងៗ ហើយត្រូវសំអាតដើមឈើជាប្រចាំដោយមិនឱ្យវាលូតលើសពី កម្ពស់៣មឡើយ។



Draft

ក្រុមហ៊ុនត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈអំពីគ្រោះថ្នាក់ ដែលបណ្តាលមកពីការរស់នៅក្រោម ឬលើកបង្គោលលោហៈក្នុងចំណីខ្សែអគ្គិសនី ឬឡើងបង្គោលអគ្គិសនី និងហាមឃាត់ដាច់ខាត នូវទង្វើខាងលើ និងតម្លើងរូបភាពផ្សព្វផ្សាយផងដែរ។




### គ.៨ សោភ័ណ្ឌភាព/ទេសភាព

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោងនេះ អាចនឹងមានការប៉ះពាល់ដល់តបំន់នេះ ដូចចំណុចគ.៥ដែរ គឺប៉ះពាល់ដោយ សារការប្រមូលសំណល់រឹង-រាវគ្រប់ប្រភេទ ដូចជា សំបកកង់ឡាន ស្បោងប្លាស្ទិក ក្រណាត់ សំបកដប គ្រប់ប្រភេទមិនបានស្អាត តាមការដ្ឋានសាងសង់បង្គោល នៅតាមទីតាំងបោះជំរុំស្នាក់នៅបណ្តោះអាសន្ន កន្លែងបង្គន់ បន្ទប់ទឹក ផ្ទះបាយ ឃ្លាំងស្តុកសម្ភារ រោងជាងជាដើម ដែលធ្វើឱ្យកខ្វក់តំបន់នេះ ដែលមានទេសភាពស្អាត។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវធ្វើការប្រមូលសម្រាម សំណល់ រឹង-រាវទាំងអស់នោះ ឱ្យបានស្អាតពីទីតាំងដូចបានរៀបរាប់ខាងលើ រួចសំណល់ នេះត្រូវដឹកយកទៅដាក់ក្នុងរណ្តៅសុវត្ថិភាព (ឆ្ងាយពីប្រភពទឹក) រួចកប់វាឱ្យបានត្រឹមត្រូវ។ ចំណែកឯ ការដ្ឋាន ឬទីតាំងបោះជំរុំ ស្នាក់នៅបណ្តោះអាសន្ន និងទីតាំងផ្សេងៗទៀត របស់អ្នកម៉ៅការបន្ត ក្រុមហ៊ុនក៏ត្រូវទទួលខុសត្រូវក្នុងការសំអាតផងដែរ។

### គ.៩ ហានិភ័យ

➢ ហេតុប៉ះពាល់អវិជ្ជមាន

នៅក្នុងដំណាក់កាលនេះហានិភ័យដោយសារគ្រោះធម្មជាតិ ការធ្វេសប្រហែសផ្នែកសន្តិសុខ និងអំពើភេរវកម្ម ឬសង្គ្រាម។

ការកើតមានការរញ្ជួយដី នៅក្នុងតំបន់គម្រោង ការទទួលរងឥទ្ធិពលពីព្យុះភ្លៀងទីហ្វុង ឬព្យុះផ្សេងទៀត អាចបង្កឱ្យមានមហន្តរាយធំៗ ដូចជាការបាក់រលំបង្គោល ដាច់ខ្សែ និងការខូចប្រព័ន្ធខ្សែអគ្គិសនីសំខាន់ៗរបស់គម្រោង ជាពិសេស ការធ្វើឱ្យរងរបួស និងស្លាប់បាត់បង់ជីវិតដល់បុគ្គលិក-កម្មករ និងប្រជាពលរដ្ឋនៅក្នុង និងក្បែរខាងតំបន់គម្រោង។

ការឆេះព្រៃក្នុងតំបន់គម្រោងដែលបណ្តាលមកពីការធ្វេសប្រហែសបច្ចេកទេស ឬទុស្សេខ្សែអគ្គិសនី ឬអំពើភេរវកម្ម ក៏អាច បង្កឱ្យមានមហន្តរាយ/គ្រោះថ្នាក់ធំដល់ប្រព័ន្ធខ្សែអគ្គិសនីសំខាន់ៗរបស់គម្រោងធនធានធម្មជាតិក្នុងតំបន់ និងអាយុជីវិតមនុស្សទៀត ផង។

ការកើតមានសង្គ្រាមឈ្លានពានលើបូរណភាពទឹកដី នៃប្រទេសកម្ពុជា និងសង្គ្រាមផ្ទៃក្នុងក៏ជាឧបសគ្គដល់កិច្ចដំណើរការ និងថែទាំគម្រោងផងដែរ ជូនកាលសង្គ្រាមអាចបំផ្លាញគម្រោងទាំងស្រុងតែម្តង។

Draft

- វិធានការកាត់បន្ថយ

ក្រុមហ៊ុនមានផែនការត្រួតពិនិត្យនិងប្រមូលព័ត៌មានជាប្រចាំដើម្បីថែទាំប្រព័ន្ធខ្សែអគ្គិសនីឱ្យបានគង់វង្សនិងសុវត្ថិភាព។

ក្រុមហ៊ុនត្រូវបំពាក់ប្រពន្ធ័ផ្តាច់អគ្គិសនីដោយស្វ័យប្រវត្តិ ដើម្បីផ្តាច់ចរន្តអគ្គិសនីឱ្យទាន់ពេលវេលាការពារអាយុជីវិតមនុស្ស-សត្វ។

ក្រុមហ៊ុនត្រូវប្រុងប្រយ័ត្នគ្រប់វិនាទីក្នុងការការពារសន្តិសុខចំពោះគ្រឿងអាចផ្ទុះនានា អគ្គិភ័យនានា និងធ្វើសហប្រតិបត្តិការណ៍ ជាមួយស្ថាប័នមានសមត្ថកិច្ច ដើម្បីទប់ស្កាត់រាល់អំពើភេរវកម្មក្នុងតំបន់គម្រោង។

ធ្វើការផ្សព្វផ្សាយរាល់ហេតុការណ៍ដែលអាចបង្កដល់ការបាក់រលំបង្គោលអគ្គិសនី ការដាច់ខ្សែ ដោយសារគ្រោះធម្មជាតិ ដល់បុគ្គលិក-កម្មករគម្រោង និងប្រជាពលរដ្ឋ ដែលត្រូវឆ្លងកាត់តាមគន្លងខ្សែអគ្គិសនីនេះឱ្យបានជ្រាបហេតុការណ៍ខាងលើបានទាន់ពេលវេលា តាមតែអាចធ្វើទៅបាន បើសិនជាមានហានិភ័យបែបនេះកើតឡើង។

រៀបចំបំរុងទុកនូវក្រុមអ្នកជួយសង្គ្រោះសម្ភារ និងថវិកា ដើម្បីធានាការដោះស្រាយផលប៉ះពាល់ ដែលនឹងអាចកើតពីមហន្តរាយខាងលើនេះបានទាន់សភាពការណ៍ និងមានប្រសិទ្ធិភាព។

### ៧.៧.៤ ដំណាក់កាលបិទគម្រោង (Project Closure)

ក្នុងដំណាក់កាលបិទគម្រោង របស់ក្រុមហ៊ុនរបស់ប្រទេសកូរ៉េ នឹងធ្វើឡើងក្រោយពីចប់កិច្ចសន្យាជាមួយរាជរដ្ឋាភិបាលកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា នឹងទទួលបន្ទុកធ្វើការគ្រប់គ្រងបន្ត ដូចនេះសកម្មភាពបិទគម្រោង អាស្រ័យទៅនឹងរដ្ឋាភិបាលកម្ពុជា សម្រេចខ្លួនឯង ហើយសង្ឃឹមថា ក្នុងដំណាក់កាលបិទគម្រោងរបស់ក្រុមហ៊ុនចិននេះ ពុំមានការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ដែល គួរឱ្យកត់សម្គាល់ឡើយ។ (ចំពោះបទដ្ឋានបច្ចេកទេស និងគុណភាពរបស់ប្រព័ន្ធខ្សែអគ្គិសនីនេះ នឹងត្រូវប្រគល់ជូនរាជរដ្ឋាភិបាលវិញ មានចែងលម្អិតក្នុងកិច្ចសន្យារួចអស់ហើយ) ។

ក្រុមហ៊ុនត្រូវធ្វើការសំអាតសំណល់រឹង-រាវ គ្រប់ប្រភេទចេញពីទីតាំង សំណង់ហេដ្ឋារចនាសម្ព័ន្ធគម្រោងវារីអគ្គិសនីនេះទាំងអស់ កន្លែងការិយាល័យ កន្លែងស្នាក់នៅ ឃ្លាំង រោងជាង ចំណតរថយន្ត ជាពិសេសនៅកន្លែងចាក់សម្រាម និងកន្លែងបង្ហូរទឹកស្អុយ។

ការប៉ាន់ប្រមាណ និងកំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយត្រូវបានដកស្រង់ចេញពីតារាង ៧-៤ ដូចខាងក្រោម:

Draft

## ៧.៨ ការសង្ខេបទំហំនៃហេតុប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ នៃប្រព័ន្ធខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០គ.វ៉

### តារាង ៧-៤: តារាងសង្ខេបទំហំនៃហេតុប៉ះពាល់អវិជ្ជមាន និងវិធានការកាត់បន្ថយ នៃប្រព័ន្ធខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០គ.វ៉

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| **១. ហេតុប៉ះពាល់បរិស្ថានក្នុងដំណាក់កាលមុនប្រតិបត្តិគម្រោង** | | | | | | |
| **១.១ ដំណាក់កាលមុនសាងសង់ ( ការរៀបចំរចនាគម្រោង )** | | | | | | |
| ក.ធនធានរូបសាស្ត្រ | | | | | | |
| សកម្មភាពការងារ គឺជាការសិក្សាលើស្ថានភាពជាក់ស្តែង ដើម្បីកំណត់ឱ្យបាននូវគន្លងខ្សែបញ្ជូនអគ្គិសនី តង់ស្យុងខ្ពស់ ទីតាំងបង្គោលអគ្គិសនី ទីតាំងផលិតថាមពលវារីអគ្គិសនី និងសណ្ឋានដីនៅតាមទីតាំងគន្លងខ្សែ គិតពីទីតាំង អាគារថាមពល ដល់ខ្សែពីអូរសោម-ពោធិ៍សាត់ត្រង់បង្គោលអគ្គិសនីនៅចំណុចច្រកពាល ហើយការវិភាគ និងគំនូសប្លង់បច្ចេកទេសភាគច្រើន គឺធ្វើនៅ ប្រទេសកូរ៉េ។ ដូចនេះការប៉ះពាល់បរិស្ថានរូបសាស្ត្រ គឺពុំមានការប៉ះពាល់ឡើយ។ | | | | | | |
| ខ. ធនធានជីវសាស្ត្រ | | | | | | |
| ខ.១ ជីវសាស្ត្ររស់នៅក្នុងទឹក/ មច្ឆជាតិ មិនមានការប៉ះពាល់ដល់ផ្នែកនេះក្នុងដំណាក់កាលនេះ។ | | | | | | |
| ខ.២ តំបន់អភិរក្សព្រៃឈើ /ដែនជម្រកសត្វព្រៃ /ឧទ្យានជាតិ | • អាចរំខានដល់ជម្រកសត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គម្រោង ដែល ស្ថិតនៅក្នុងតំបន់ព្រៃការពារ របស់សង្កាត់រដ្ឋបាលព្រៃឈើប្រហោយ ខ្លះៗដែរដោយសារសកម្មភាពសិក្សា ដូចជា មានសំឡេងអ៊ូអរ ការ ត្រួសត្រាយព្រៃ ធ្វើដំណើរខ្វះខ្វងដីក្នុងការសិក្សាជាដើម។ | ✓ | | | • កំណត់ពេលវេលាធ្វើការតែពេលថ្ងៃ ដើម្បីមិនឱ្យរំខានសត្វព្រៃទេ។<br>• ធ្វើការទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន និងជំនាញពាក់ព័ន្ធដើម្បីចុះធ្វើការ សិក្សានេះ ជៀសវាងការធ្វើឱ្យរំខាន ទីជម្រករបស់សត្វព្រៃ។<br>• ក្រោយតែបែកឈើតូចៗ ដើម្បីធ្វើដំណើរចូលកន្លែងសិក្សា ដើម្បីទុកឱ្យព្រៃ នោះអាចលូតលាស់ឡើងវិញ (តាមលក្ខណៈបច្ចេកទេសក្នុងការថែរក្សា ព្រៃការក្រោយមែកឈើ អាចធ្វើឱ្យដើមលូតលាស់ប្រសើរជាងមុន)។ | |
| ខ.៣ ព្រៃឈើ និង ជម្រក សត្វព្រៃ | • អាចរំខានដល់ជម្រកសត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គម្រោង ដោយ សារការត្រួសត្រាយព្រៃ និងសំឡេងអ៊ូអររបស់បុគ្គលិក-កម្មករក្នុងការធ្វើដំណើរសិក្សា នៅទីតាំងមួយចំនួនតាមគន្លងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០គ.វ៉ គឺពីអាគារថាមពលឆ្ពោះទៅបង្គោលរបស់បណ្តាញខ្សែ២៣០គ.វ៉អូរសោម-ពោធិ៍សាត់។ | | ✓ | | • កំណត់ពេលវេលាធ្វើការតែពេលថ្ងៃ ដើម្បីមិនឱ្យមានការរំខានដល់សត្វព្រៃ ឡើយ។<br>• ធ្វើការសហការជាមួយអាជ្ញាធរមូលដ្ឋាន និងជំនាញពាក់ព័ន្ធក្នុងការសិក្សា នេះដោយមិនឱ្យរំខានជម្រក និងការរស់ នៅរបស់វានោះទេ។<br>• ក្រោយតែមែកឈើតូចៗសម្រាប់ធ្វើដំណើរចូលកន្លែងសិក្សាតែប៉ុណ្ណោះ ដើម្បី ទុកឱ្យព្រៃនោះអាចលូតលាស់ឡើងវិញ។ | |
| ខ.៤ ជីវសាស្ត្រសត្វព្រៃ | • អាចប៉ះពាល់ដល់ជីវសាស្ត្រសត្វព្រៃខ្លះដែរ ដោយសារសកម្មភាពសិក្សាគម្រោងនេះ គឺធ្វើឱ្យផ្អើលសត្វពេលដែលដើរសិក្សាតម្រង់ទិសរកទីតាំងគម្រោង។ អាចមានការបបាញ់ ដាក់អន្ទាក់សត្វព្រៃពី | ✓ | | | • ធ្វើការសិក្សាតែពេលថ្ងៃដើម្បីមិនឱ្យរំខានសត្វព្រៃទេ ពីព្រោះសត្វព្រៃភាគច្រើន រកស៊ីពេលយប់។<br>• ធ្វើការរបរំដែល់បុគ្គលិក និយោជិត កម្មកររបស់ខ្លួនមិនឱ្យសំលាប់សត្វព្រៃទេ ហើយមាន | |

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | សំណាក់ កម្មករនិយោជិតរបស់គម្រោង ។<br>• តំបន់គម្រោងនេះមានសត្វព្រៃជាច្រើនប្រភេទដែលរស់នៅហើយ ប្រភេទសត្វមួយចំនួនកំពុងត្រូវបានធ្វើការអភិរក្ស។ ក្រុមការងារបានសិក្សាឃើញថា ថនិកសត្វមានចំនួន៤៤ប្រភេទ បក្សី ១២០ប្រភេទ ឧរង្គសត្វ-កង្កែប ៦៣ប្រភេទ មច្ឆជាតិ ទឹកសាប ៨៣ប្រភេទ ដូចមានចែងក្នុងជំពូក៥ ចំណុច៥.១.២.២ខាងលើនេះ។ សកម្មភាពសាងសង់ប្រព័ន្ធខ្សែអគ្គិសនីនេះ អាចមានការប៉ះពាល់សត្វព្រៃ ខ្លះដែរ ដូចជា ស្វា ទោច ឈ្លូស ពពួកពស់ អណ្ដើករស់នៅលើគោក ជ្រូកព្រៃ ជាដើម ដោយសារបាត់ទីជម្រក ឬផ្ដាច់ ផ្លូវទំនាក់ទំនង របស់វាជាពិសេស ពពួកស្វា ទោច អាចត្រូវឆក់ស្លាប់ដោយសារខ្សែអគ្គិសនីដែលមានតង់ស្យុងខ្ពស់នេះនៅពេលប្រតិបត្តិគម្រោង។ | | | | ការដាក់ពិន័យទៀតផង។<br>• សហការយ៉ាងជិតស្និតជាមួយអាជ្ញាធរ និងសមត្ថកិច្ចពាក់ពន្ធ័ ដើម្បីទប់ស្កាត់ អ្នកប្រព្រឹត្តល្មើសបទល្មើសព្រៃឈើ និងសត្វព្រៃ។<br>• ក្រុមហ៊ុន ត្រូវគ្រោងបំពាក់គ្រឿងការពារសត្វព្រៃ និងមនុស្សមិនឱ្យឡើងបង្គោលអគ្គិសនី និងធ្វើការថែទាំជាប្រចាំនូវមែកឈើ ដើម្បីការពារពពួកស្វាទាំងនោះ លោតតោងខ្សែរនេះ ដែលធ្វើឱ្យពួកវាឆក់ស្លាប់ជាពិសេសអាចដល់មានការដាច់ខ្សែអគ្គិសនីនេះទៀតផង។ | |
| **គ. ធនធានសេដ្ឋកិច្ចសង្គម** | | | | | | |
| គ.១ការប្រើប្រាស់ដី និងការតាំងលំនៅដ្ឋាន ឡើងវិញ | • មិនមានការប៉ះពាល់ត្រង់ចំណុចនេះទេ ពីព្រោះគ្មានប្រជាពលរដ្ឋ រស់នៅក្នុងតំបន់ ហើយក៏គ្មានការប្រើប្រាស់ដីរបស់ប្រជាពលរដ្ឋ តាមគន្លងខ្សែនេះដែរ។ | | ✓ | | | |
| **គ.២ ការរស់នៅ និងមុខរបររបស់សហគមន៍មូលដ្ឋាន** ក្នុងដំណាក់កាលនេះមិនប៉ះពាល់ដល់ផ្នែកនេះទេ។ | | | | | | |
| **គ.៣ ប្រពៃណី វប្បធម៌ និងសាសនា** ក្នុងដំណាក់កាលនេះមិនប៉ះពាល់ដល់ផ្នែកនេះទេ។ | | | | | | |
| គ.៤ការប្រើប្រាស់ទឹកស្អាត | • ប៉ះពាល់ដល់សុខភាពអ្នកសិក្សាគម្រោង ដោយសារតំបន់នេះគ្មានផ្សារ សម្រាប់លក់ទឹកសម្រាប់ផឹក ហើយក៏ជាតំបន់ព្រៃភ្នំមានភូមិប្រជាជន តិច តូចប៉ុណ្ណោះដែរ។<br>• មានការប៉ះពាល់តិចតួចដល់ប្រភពទឹក ដោយសារការបោះសម្រាមពីអ្នកសិក្សាទាំងនោះ។ | ✓ | | | • ធ្វើការផ្គត់ផ្គង់ទឹកផឹក ឱ្យបានទាន់ពេលវេលាដល់ក្រុមសិក្សា និងពន្យល់អប់រំ អ្នកទាំងនោះ មិនឱ្យផឹកទឹកនៅបើការ ផ្គត់ផ្គង់ទឹកស្អាតមិនទាន់ ពេលគឺទឹក ដែលដងពីអូរ ឬស្ទឹងក្នុងតំបន់ត្រូវដាំពុះជាមុនសិនទើបផឹកបាន។<br>• អប់រំផ្សព្វផ្សាយដល់អ្នកសិក្សាគម្រោងទាំងនោះ មិនឱ្យបោះសម្រាមពាសវាលពាសកាល សម្រាមត្រូវដាក់ក្នុងរណ្ដៅរួចកប់វា ឱ្យបានល្អជៀសវាងបោះចោល ក្នុង ឬក្បែរប្រភពទឹក។ | |
| **គ.៥ តំបន់ទេសចរណ៍** ក្នុងដំណាក់កាលនេះមិនប៉ះពាល់ដល់ផ្នែកនេះទេ ពីព្រោះតំបន់នេះមិនមានផ្លូវចេញចូលសម្រាប់អ្នកទេសចរណ៍ទេ ម៉្យាងទៀត ក្រុមអ្នកសិក្សាគម្រោងមានគ្នាយ៉ាងច្រើនបំផុត ១៥ នាក់ប៉ុណ្ណោះ។ | | | | | | |
| គ.៦ ផ្លូវគមនាគមន៍ | • អាចមានការប៉ះពាល់ និងគ្រោះថ្នាក់ដល់អ្នកសិក្សា ឬធ្វើឱ្យស្ទះការងារ សិក្សាប្លង់ទីតាំងគម្រោង ដោយសារ ស្ថានភាពផ្លូវធ្វើចរាចរ ទ្រុឌទ្រោម តូចចង្អៀត ផ្លូវចំណោតខ្លាំង ហើយកន្លែងខ្លះ គ្មានផ្លូវចូល | | ✓ | | • រកអ្នកនាំផ្លូវដែលស្គាល់ភូមិសាស្ត្រច្បាស់លាស់ក្នុងមូលដ្ឋានតំបន់គម្រោង។<br>• ធ្វើការទំនាក់ទំនងជាមួយមន្ទីររ៉ែ និងថាមពលខេត្តពោធិ៍សាត់ និង មន្ទីរពាក់ព័ន្ធ ដើម្បីរកមធ្យោបាយចូលទៅទីតាំងគម្រោងដោយសុវត្ថិភាពក្នុង ការសិក្សានេះ។ | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | សិក្សាទៀតផង។<br>• ការប៉ះពាល់ដល់ព្រៃឈើដោយសារការធ្វើផ្លូវ និងគន្លងខ្សែអគ្គិសនីច្រើនសំញាំ ដែលបង្កឱកាសឱ្យជនខិលខូចកាប់ឈើ និងដឹកជញ្ជូនឈើបានដោយងាយស្រួល។ | | | | • ធ្វើការសិក្សាផ្លូវទេះចាស់ៗ ហើយគ្រោងគន្លងខ្សែអគ្គិសនីឱ្យស្របតាម បណ្តោយផ្លូវ (ចេញពីអ័ក្សផ្លូវចាប់ពី ៧០ម-១០០ម) ទោះជាផ្លូវនោះវាង ក៏ដោយ ដើម្បីកាត់បន្ថយការកាប់ព្រៃឈើបន្ថែមលើកលែងតែកន្លែងខ្លះៗ ដែលស្ថិតនៅក្នុងអាង ឬក្នុងស្ទឹង។ | |
| ក.៧សុខភាពសាធារណៈ | • អាចបង្កឱ្យមានការប៉ះពាល់ដល់សុខុមាលភាព បុគ្គលិក-កម្មកររបស់ក្រុមហ៊ុន ដោយសារតំបន់គម្រោងជាតំបន់កើតជំងឺគ្រុនចាញ់ គ្រុនសន្និបាត។ តំបន់ខ្លះនៃតំបន់គម្រោង មានគ្រាប់មីន និងមានជាក់អន្ទាក់ សត្វ ហើយមានពពួកសត្វសាហាវ និងអសិរពិស ជាពិសេសដោយសារជនប្រដាប់អាវុធអនាធិបតេយ្យ ដើរបរបាញ់សត្វ កាប់ឈើខុសច្បាប់ ដែលអាចធ្វើឱ្យក្រុមសិក្សាគម្រោងមាន គ្រោះថ្នាក់ដល់ជីវិត ផងដែរ។ សម្គាល់: នៅពេលក្រុមការងារ SAWAC ធ្វើការសិក្សា ព្រៃឈើក្នុងតំបន់គម្រោង មានជនប្រដាប់អាវុធបានបាញ់សំដៅមក ក្រុមការងារពីចម្ងាយ តែសំណាងល្អមិនមានប៉ះពាល់ ឬគ្រោះថ្នាក់ អ្វីទេដល់នណាម្នាក់ទេ ហើយក្រុមការងារបានរាយការណ៍ទៅ អាជ្ញាធរមូលដ្ឋាន និងឧទ្យានុរក្សពីបញ្ហានេះផងដែរ។<br>• ជាងនេះទៅទៀត អាចមានការប៉ះពាល់ដល់អាយុជីវិតមនុស្ស សត្វ ដោយសារការគ្រោងគម្រោងមិនបានល្អ ដូចជាការបាក់ឫរលំ ការដាច់ខ្សែអគ្គិសនី បណ្តាឱ្យឆក់ ឆេះ ស្លាប់មនុស្សក៏សឹងមានផងដែរ។ | | ✓ | | • ធ្វើការអប់រំសុខភាពអនាម័យដល់ក្រុមសិក្សាគម្រោង ដូចជាការណែនាំឱ្យពួក គេចេះត្រៀមទឹកបរិសុទ្ធ និងអាហារ ថ្នាំពេទ្យ ឧបករណ៍ស្នាក់នៅមាន សុវត្ថិភាពតាមខ្លួននៅពេលចូលព្រៃសិក្សា។<br>• ធ្វើការទាក់ទងយ៉ាងជិតស្និតជាមួយអាជ្ញាធរមានសមត្ថកិច្ច ប្រជាពលរដ្ឋ មូលដ្ឋាននិងអង្គភាពបោសសំអាតមីន ដើម្បីធ្វើការបង្ហាញតំបន់មានគ្រាប់ មីននិងគ្រាប់មិនទាន់ផ្ទុះទាំងឡាយដែលបន្សល់ទុកពីសម័យសង្គ្រាម។<br>• រកអ្នកនាំផ្លូវ ដែលស្គាល់ភូមិសាស្ត្រច្បាស់លាស់ក្នុងមូលដ្ឋានតំបន់គម្រោង និងកម្លាំងប្រដាប់អាវុធមូលដ្ឋាន ដើម្បីការពារសន្តិសុខ ជៀសវាងមាន គ្រោះថ្នាក់ ដល់ក្រុមការងារសិក្សាគម្រោង ដោយសារគ្រាប់មីន អន្ទាក់សត្វ សត្វសាហាវ សត្វអសិរពិស និងជនប្រដាប់អាវុធអនាធិបតេយ្យ ដែលចូល ទៅបាញ់សត្វឬកាប់ឈើខុសច្បាប់។ក្រុមហ៊ុនបានត្រៀមថ្នាំបង្ការ ដើម្បីការពារ ជំងឺគ្រុនចាញ់ គ្រុនសន្និ របួស សត្វទិច ឬខាំ និងថ្នាំការពារពស់ចឹក ដល់ក្រុម ការងារសិក្សារួមទាំងកម្មករគម្រោង របស់ខ្លួនឱ្យបានគ្រប់គ្រាន់ ពីព្រោះតំបន់គម្រោងសម្បូរសត្វអសិរពិស (ពស់ពិសគ្រប់ប្រភេទ ស្រាំង ឱម៉ាល់ជាដើម)។<br>• ក្រុមហ៊ុន ត្រូវគ្រោងគម្រោងដោយគិតអំពីល្បឿនខ្យល់ព្យុះ ខ្យល់កន្ត្រាក់ ធ្វើឱ្យបង្គោលរឹងមាំ និងខ្សែដក់ដោយធ្វើយ៉ាងណាឱ្យមានគំលាតពីដីលើសពី៨ម។ | |
| ក.៨ សោភ័ណ្ឌភាព និង ទេសភាព មិនប៉ះពាល់ដល់ផ្នែកនេះទេ ពីព្រោះ សកម្មភាពសិក្សាមិន មានសកម្មភាពធំដុំ (សិក្សាតំរង់ទិសបង្គោល ធ្វើឋានលេខាជាដើម) ដែលធ្វើឱ្យខូចសោភ័ណ្ឌភាព ឬទេសភាពក្នុងតំបន់ឡើយ។ | | | | | | |
| ក.៩ ហានិភ័យ | • អាចមិនបានគិតអំពីកត្តាប្រែប្រួលអាកាសធាតុ ដូចជាការកើន ឡើងនូវកំដៅកម្រិត ព្យុះជាដើម អាចធ្វើឱ្យគុណភាពសំណង់នៃ ប្រព័ន្ធខ្សែអគ្គិសនីមិនរឹងមាំតាមការគ្រោងទុក។<br>• អាចមានគ្រោះថ្នាក់ ដោយសារលក្ខណៈភូមិសាស្ត្រស្មុគស្មាញ ដូចជា មានគ្រាប់មីន និងយុទ្ធភណ្ឌ មិនទាន់ផ្ទុះបង្កប់ក្នុងដី ក្នុងសម័យសង្គ្រាម និងជនអនាធិបតេយ្យប្រើអាវុធខុសច្បាប់។<br>• អាចគ្រោះថ្នាក់ដោយសារសត្វសាហាវ ដូចជា ខ្លាឃ្មុំ ពស់ពិស ខ្លា ដែលមាននៅក្នុងតំបន់គម្រោងនេះ។ | | | ✓ | • នឹងធ្វើការគ្រោង រចនានូវហេដ្ឋារចនាសម្ព័ន្ធខ្សែបញ្ជូនអគ្គិសនីនេះមានដូចតទៅ:<br>• គន្លងខ្សែគឺ ១៥មសងខាងពីអ័ក្សបង្គោលហ្វែមដែក (សរុប ៣០ម)<br>• ទំហំផ្ទៃដីសម្រាប់ធ្វើគ្រឹះបង្គោលអគ្គិសនីគឺ ១៥ម x ១៥ម<br>• ចំនួនបង្គោលអគ្គិសនីគឺ ១៣ បង្គោលហ្វែមដែក ហើយចម្ងាយប្រវែង ពីបង្គោលមួយទៅបង្គោលមួយទៀត គឺ ៣០០ទៅ៥០០ម។ កម្ពស់ របស់បង្គោលគឺ ចាប់ពី២០មទៅ៤០ម ប្រែប្រួលទៅតាមសណ្ឋានដី។<br>• សម្ភារសំណង់ មានគុណភាពតាមស្តង់ដារអន្តរជាតិ ធន់នឹងការប្រែ ប្រួលអាកាសធាតុ និងធានាដល់ការប្រើប្រាស់ ប្រព័ន្ធខ្សែអគ្គិសនីនេះ តាមការគ្រោងទុកតាមកិច្ចសន្យារបស់ក្រុមហ៊ុន ជាមួយរាជរដ្ឋា ភិបាលកម្ពុជា។<br>• ចំពោះបញ្ហាមីន និងគ្រាប់មិនទាន់ផ្ទុះនោះត្រូវធ្វើការទាក់ទងយ៉ាងជិតស្និត ជាមួយអាជ្ញា | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | | | | | ធរមានសមត្ថកិច្ចប្រជាពលរដ្ឋមូលដ្ឋាន កងកម្លាំងយោធា ភូមិភាគទី៣ និងកងកម្លាំងបោសសំអាតគ្រាប់មីន ក្នុងការបង្ហាញតំបន់ មានគ្រាប់មីន និងគ្រាប់មិន ទាន់ផ្ទុះទាំងនេះ ដែលមានក្នុងសម័យសង្គ្រាម សព្វថ្ងៃ(២០១២)។<br>• ចំពោះបញ្ហាការពារសត្វសាហាវ ដូចជា ខ្លាឃ្មុំ ពស់ ខ្លានោះ ក្រុមហ៊ុនធ្វើ ដំណើររួមគ្នា និងសហការជាមួយកម្លាំង ប្រដាប់អាវុធ និងអ្នកនាំផ្លូវនៅ មូលដ្ឋាន ដើម្បីការពារនៅពេលជួបប្រទះហេតុការណ៍ ដែលបង្កឡើង ដោយសត្វសាហាវ និងជនខិលខូចខាងលើនេះ។ | |
| **១.២ ដំណាក់កាលសាងសង់គម្រោង (Project Construction)** | | | | | | |
| ក. ធនធានរូបសាស្ត្រ | | | | | | |
| ក.១ សណ្ឋានដី និងឋានលេខា | • មានការប្រែប្រួលសណ្ឋានដី និងឋានលេខា ជាមធ្យមក្នុងទីតាំងគម្រោង ដោយសារសកម្មភាពឈូសឆាយធ្វើផ្លូវចូល និងពង្រាបដីស្រទាប់លើ ការជីកយកដី និងថ្ម ដើម្បីធ្វើការសាងសង់ប្រព័ន្ធខ្សែអគ្គិសនីដូចជាសាងសង់បង្គោលអគ្គិសនីនិងការដំឡើងខ្សែជាដើម។ | | ✓ | | • ការយកដី ខ្សាច់ និងថ្ម ធ្វើការសហការជាមួយស្ថាប័នមានសមត្ថកិច្ច ដោយ កំណត់ទីតាំងយកដី ថ្ម និងខ្សាច់ រួមមួយនៅកន្លែងយកដី ថ្ម និងខ្សាច់ នៃការសាងសង់ទំនប់វារីអគ្គិសនី។ នៅពេលចប់ការសាងសង់កន្លែង យកដី ថ្ម និងខ្សាច់នេះត្រូវឈូសឆាយសំអាតពង្រាបឱ្យស្មើ និងចាក់ដីពីលើ ហើយធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ ដើម្បីដាំឈើឡើងវិញ ដោយជ្រើសរើសពូជឈើក្នុងតំបន់។<br>• ធ្វើការសាងសង់ជាទ្រង់ទ្រាយជំរែរជួរប្រាំង ដើម្បីទប់ស្កាត់ការហូរច្រោះ ដែល នាំឱ្យខូចសណ្ឋានដីនៅរដូវវស្សា។<br>• ជីកគ្រឹះ ហើយពង្រាបដីវិញ និងមានការដាំស្មៅថែមទៀតនៅទីតាំងសាង សង់បង្គោល ឱ្យរក្សាបាននូវសណ្ឋានដី ឱ្យមានស្ថានភាពដូចដើម។ នៅតាម ផ្លូវចូលត្រូវធ្វើជើងទេរនៃជញ្ជាំងដី ហើយនៅតាម ចិញ្ចើមផ្លូវចូលសងខាង ត្រូវកាយប្រលាយទឹក ដើម្បីដោះទឹកផង និងដើម្បីកាត់បន្ថយភាពល្អក់ នៅពេលមានភ្លៀងធ្លាក់ផង។ | |
| ក.២ ប្រព័ន្ធជលសាស្ត្រ ទឹកលើដី (ប្រឡាយ- អូរ-ស្ទឹង) | • ប៉ះពាល់ដល់គុណភាពទឹក ដោយសារសកម្មភាពសាងសង់ដែលបណ្តាលមកពីការហូរច្រោះដីស្អុយតាមបង្គោលអគ្គិសនី តាមផ្លូវចូលទៅសាងសង់បង្គោល ហូរចូលទៅក្នុងប្រឡាយ-អូរ-ស្ទឹង ដែល ស្ថិតក្បែរកន្លែងសាង សង់នោះ។<br>• អាចប៉ះពាល់ដល់គុណភាពទឹកប្រឡាយ-អូរ-ស្ទឹង ដោយសារការបោះបង់សំណល់រឹង និងការបង្ហូរសំណល់រាវ ចេញពីបន្ទប់ ទឹកបង្គន់ក្នុងប្រភពទឹកធម្មជាតិ បង្អន់នៅកន្លែងស្នាក់នៅ ឬការិយាល័យ ផ្ទះបាយ ការលេចធ្លាយប្រេងឥន្ធនៈ និងប្រេងរំអិលពីគ្រឿង យន្តនានាក្នុងការដ្ឋានសាងសង់ និងការមុជទឹកសំអាតខ្លួនប្រាណ ការបោកគក់របស់បុគ្គលិក-កម្មករ ការបន្ទោរបង់ទៅក្នុងប្រឡាយ-អូរ-ស្ទឹងទាំង | | ✓ | | • ធ្វើការកាត់បន្ថយការធ្វើឱ្យល្អក់ខ្លាំងដោយយកដីស្អុយ ដែលនៅក្បែរប្រភព ទឹកចេញ និងកិនបង្ហាប់ដី ដាំស្មៅនៅកន្លែង ដែលបានសាងសង់បង្គោលរួច ហើយឱ្យបានមុនពេលរដូវភ្លៀងធ្លាក់។<br>• សកម្មភាពសាងសង់ធំៗគឺធ្វើនៅរដូវប្រាំងដើម្បីកាត់បន្ថយការហូរច្រោះពីការដ្ឋានដីផ្សេងៗ ដែលអាចហូរចូលស្ទឹង។<br>• និងអប់រំដល់បុគ្គលិក-កម្មករអំពីការបោះបង់សំណល់រឹង ឬបង្ហូរ សំណល់រាវ ជាពិសេសការកំពប់ប្រេងឥន្ធនៈ ប្រេងរំអិលនៅលើ ដីដែល បណ្តាលឱ្យខូចគុណភាពដី និងទឹកនៅក្នុងតំបន់គម្រោង។ ហាមបុគ្គលិក-កម្មករគម្រោង មិនឱ្យមានការបន្ទោរបង់ ឬសង់បង្គន់នៅក្នុងប្រភពទឹក ធម្មជាតិ ឬប្រភពទឹកសាធារណៈក្នុងតំបន់គម្រោងឡើយ។<br>• ធ្វើការគ្រប់គ្រង និងការពារសំណល់រឹង-រាវគ្រប់ប្រភេទ មិនឱ្យបោះចោល សំណល់រឹង និង | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | នោះ។ | | | | បង្ហូរសំណល់រាវ ចូលទៅក្នុង ឬក្បែរប្រភពទឹក ធម្មជាតិឡើយ ដោយសង់បន្ទប់ទឹក និងបង្គន់អនាម័យ (ដោយមានរាង សិបទិកត្រឹមត្រូវ) ឱ្យឆ្ងាយពីប្រភពទឹកធម្មជាតិ និងមានកន្លែងទុកដាក់ សំណល់រឹងឱ្យបានល្អតាមបច្ចេកទេស ដោយមិនបំពុលបរិស្ថាននៅតំបន់នោះឡើយ។ | |
| ក.៣ ការហូរច្រោះ និងគុណភាពដី | • បង្កឱ្យមានការហូរច្រោះដី ដោយសារការឈូសឆាយដីស្រទាប់លើ ដើម្បី សាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គម្រោង (ផ្លូវចូល បង្គោលអគ្គិសនី និងដំឡើងខ្សែអគ្គិសនី ដោយសារការច្វេសប្រហែសមិនគោរពតាមបទដ្ឋាន ការងារដី ដែលធ្វើឱ្យមាន ការហូរច្រោះដីពិសេសនៅរដូវវស្សា។<br>• បង្កឱ្យប៉ះពាល់ដល់គុណភាពដីស្រទាប់លើនៅជុំវិញតំបន់បង្គោលអគ្គិសនី និងកន្លែងកាយដីទូលផ្លូវចូល ដោយចោលដីស្អុយ (ដីដែលជីកពី ស្រទាប់ក្រោមគ្មានជីជាតិ)ទាំងនោះ គ្របលើដីក្នុងទីតាំងសាងសង់ នោះធ្វើឱ្យបាត់បង់ជីជាតិរបស់ដី ស្រទាប់លើនៅតំបន់នោះហើយ អាចបណ្តាលឱ្យមានការហូរច្រោះ ដីស្អុយនេះទៅគ្របពីលើ សណ្ឋានដីតំបន់ជុំវិញនោះ ឬហូរចូល ប្រភពទឹកប្រើ ប្រាស់ទៀតផង។ | | ✓ | | • ធ្វើការបង្ហាប់ដីក្នុងតំបន់សាងសង់ឱ្យ បានត្រឹមត្រូវតាមបទដ្ឋានការងារ បច្ចេកទេស។<br>• ត្រូវពង្រាបដី ឬថ្មដែលចាក់ចោល ដោយយកដីមានជីជាតិលប់ពីលើឱ្យ បានប្រហាក់ប្រហែលស្ថានភាពដើម។<br>• ត្រូវដាំស្មៅនៅតាមបង្គោលអគ្គិសនីដែលមិនមានស្មៅ ឬឈើដុះ ដើម្បីការពារ ការហូរច្រោះដី ដែលគ្មានជីជាតិទៅលើកន្លែងផ្សេងទៀត ដោយធ្វើការ សហការជាមួយរដ្ឋបាលព្រៃឈើ។ | |
| ក.៤ ការរញ្ជួយដី | • បង្កឱ្យមានការរញ្ជួយតិចតួច ដោយសារការដឹកសម្ភារសំណង់ធ្ងន់ៗ និងការបន្ទុះថ្មសម្រាប់សាងសង់បង្គោលអគ្គិសនីជាដើម ដែលអាចបង្កឱ្យ មានការបាក់ជញ្ជាំងដី ឬប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ឬសំណង់ សាធារណៈ និងឯកជន ដែលមិនមានសភាពរឹងមាំ ឬចាស់ទ្រុឌទ្រោម ដែលនៅក្បែរៗនោះ។ | | ✓ | | • ធ្វើការដោះបំបែកនៃគ្រឿនបង្គំរបស់បង្គោលអគ្គិសនីគ្រង់ស្វ័រម៉ាទ័រ។ល។ ហើយ ធ្វើការដឹកជញ្ជូនមិនឱ្យលើសទំងន់ ដែលកាត់បន្ថយភាពរញ្ជួយ និងមិនឱ្យ ខូចផ្លូវ បាក់ស្ពាន និងលូទៀតផង។ | |
| ក.៥ គុណភាពទឹក (លើដី/ក្រោមដី) | • មានការបំពុលគុណភាពទឹកប្រឡាយ-អូរ-ស្ទឹង ដោយសារការ សាងសង់បង្គោលអគ្គិសនី និងការងារសាងសង់ផ្សេងទៀត បណ្តាល មកពីការខួង ឬការងារដី ការងារបេតុង និងការងារគ្រឹះ ដែលការ ដ្ឋានសាងសង់នេះ ស្ថិតនៅជិត ប្រភពទឹកទាំងនេះ។<br>• ប៉ះពាល់គុណភាពទឹកធម្មជាតិ ដោយសារសំណល់រឹង-រាវ ចេញពីកន្លែងស្នាក់នៅ ដូចជា ចេញពីផ្ទះបាយ បន្ទប់ទឹកបង្គន់ នៅកន្លែងស្នាក់នៅ ឬការិយាល័យ ហើយកន្លែងខ្លះសង់បង្គន់ក្នុង និងក្បែរប្រភពទឹកធម្មជាតិ និងការបោះសំណល់រឹង ដោយ បុគ្គលិក-កម្មកររបស់ក្រុមហ៊ុន មានសម្ភារសំណង់ ដូចជាបាវ ស៊ីម៉ងត៍ បាវ ឬស្បោង | ✓ | | | • ការឈូសឆាយទ្រង់ទ្រាយធំក្រុមហ៊ុនមិនធ្វើនៅរដូវវស្សាទេ។<br>• ធ្វើការអប់រំបុគ្គលិក-កម្មករគម្រោងឱ្យយល់ដឹងអំពីអនាម័យ ស្គាល់នូវកន្លែង ទុកដាក់ សម្រាម ដែលក្រុមហ៊ុនបានរៀបចំកសាងក្នុងទីតាំង ស្នាក់នៅរបស់ គម្រោង។ ហាមមិនឱ្យបន្ទោរបង់ និងសង់បង្គន់ក្នុងប្រភពទឹកធម្មជាតិឬ សាធារណៈឡើយត្រូវដាក់ ពិន័យដល់បុគ្គលិក-កម្មករណាមិនអនុវត្តតាម ការណែនាំនេះ។<br>• ចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងសំណល់រឹង-រាវ ដោយសាងសង់បង្គន់អនាម័យ បន្ទប់ទឹក ផ្ទះបាយឱ្យបានឆ្ងាយពីមាត់ ប្រឡាយ-អូរ-ស្ទឹង ព្រមទាំងរៀបចំប្រមូលសំណល់រឹងនិងសម្រាមយកទៅចោលនៅទីតាំង ដែលមានសុវត្ថិភាពល្អ មិនឱ្យប៉ះពាល់បរិស្ថានជុំវិញ។ | |

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | ច្រកជាដើម ការលេចធ្លាយ សំណល់រាវ ដូចជាការហៀរ ឬលេចជាតិប្រេងពីគ្រឿងចក្រយន្ត សារធាតុគីមី ផ្សេងទៀត។ល។ ទៅក្នុងប្រភពទឹកធម្មជាតិ នៃតំបន់គម្រោងនេះ។<br>• អាចនឹងមានការហូរច្រោះដី ដោយសារការកាប់ឆ្ការនូវគម្របរុក្ខជាតិ ដូចជាការកាប់ព្រៃ ៣០ម.តាមគន្លងខ្សែ ការងារដីដែលមិនបានពង្រាបដីស្អុយ និងមិនបានគ្រប់គ្រងការងារដីទាំងនេះ ឱ្យបានល្អនៅតាមបទដ្ឋានបច្ចេកទេស ដែលហេតុនាំឱ្យមានការហូរច្រោះដីទៅ ក្នុងប្រឡាយ-អូរ-ស្ទឹង នៅរដូវវស្សា។<br>• អាចនឹងបំពុលទឹក ដោយសារការប្រើប្រាស់សារធាតុគីមី ដើម្បីសម្លាប់ព្រៃឈើ ឬបង្អាក់ការលូតលាស់របស់ដើមឈើ។ | | | | • ធ្វើការបោះស្លាកសញ្ញាតំបន់គម្រោង ដោយមានអក្សរខ្មែរ និងរូបថ្មអង់គ្លេស អំពីការបំពុលទឹក។<br>• សាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈ ឱ្យបានត្រឹមត្រូវតាមបទដ្ឋានសុវត្ថិភាពដល់បរិស្ថាន និងសង្គម។<br>• ត្រូវប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និងរថយន្តដឹកជញ្ជូន ដែលមានគុណភាព ល្អមិនលេចហូរជាតិប្រេង ឬធ្លាញ់មក លើដី និងប្រភពទឹកក្នុងតំបន់គម្រោង។<br>• ត្រូវដាំស្មៅតាមកន្លែងដែលសាងសង់បង្គោលរួចហើយ និងដាំស្មៅ នៅកន្លែងដែលកាប់សំអាតគន្លង ដែលគ្មានស្មៅ ឬឈើដុះ ដើម្បីការពារការហូរច្រោះ និងគុណភាពទឹក។<br>• មិនប្រើសារធាតុគីមីផ្សេងៗក្នុងការសំអាត ឬបង្អាក់ការលូតលាស់របស់ ឈើនោះទេ។ | |
| ក.៦ គុណភាពខ្យល់ | • មានការបំពុលខ្យល់ដោយសារការដុតព្រៃឈើ ដើមឈើ កម្ទេចឈើ ដើម្បីសំអាតការដ្ឋាន និងនៅតាមគន្លងខ្សែ ហើយផ្សែង ដែលបំភាយចេញពីគ្រឿងចក្រសាងសង់ និងរថយន្តដឹកជញ្ជូនសម្ភារសម្រាប់ការងារសាងសង់ និងការហុយធូលីដីពីមធ្យោបាយ ដឹកជញ្ជូន ទាំងនេះរបស់គម្រោង។<br>• អាចនឹងបំពុលខ្យល់ដោយសារភ្លើងឆេះព្រៃ បណ្តាលមកពីការធ្វេសប្រហែសពីបុគ្គលិក-កម្មករគម្រោង។<br>• អាចនឹងបំពុលខ្យល់ ដោយសារការប្រើប្រាស់សារធាតុគីមី ដើម្បីសម្លាប់ព្រៃឈើ ឬបង្អាក់ការលូតលាស់របស់ដើមឈើ ។ | | ✓ | | • មិនដុតព្រៃឈើក្នុងតំបន់ដែលត្រូវសំអាតតាមគន្លងខ្សែ៣០ម.នេះទេ គឺក្រុមហ៊ុនធ្វើការសហការជាមួយរដ្ឋបាល ព្រៃឈើ ដើម្បីត្រួតពិនិត្យទំហំដើមឈើ សម្រាប់ដេញថ្លៃ និងឈើមួយចំនួនអាចយកមកកែច្នៃសម្រាប់ប្រើប្រាស់។<br>• ប្រើប្រាស់ម៉ាស៊ីន គ្រឿងចក្រ និងរថយន្តដឹកជញ្ជូន ដែលមានការបញ្ចេញផ្សែង តិច ដើម្បីកាត់បន្ថយការបំពុលខ្យល់ ក្នុងតំបន់នោះ។<br>• ត្រៀមឧបករណ៍ពន្លត់អគ្គិភ័យ និងមានកន្លែងបូមទឹកគ្រប់គ្រាន់នៅ ពេល មានអគ្គិភ័យ។<br>• ធ្វើការអប់រំបុគ្គលិក-កម្មករគម្រោង មិនឱ្យចោលភ្លើងបារី ឬអង្កត់ភ្លើង ជាដើម ទៅក្នុងព្រៃ បណ្តាលឱ្យកើតមានភ្លើងឆេះព្រៃ ក្នុងតំបន់គម្រោង និងឱ្យមានការ ប្រុងប្រយ័ត្នជានិច្ច ហើយថែមទាំងម្ចាស់ការក្នុងការពន្លត់ភ្លើង ទៅតាមលទ្ធភាព ដែលអាចពន្លត់បាន។ បុគ្គលិក-កម្មករគម្រោង ត្រូវចូលរួមយ៉ាងសកម្ម ក្នុងការរាយការណ៍ និងពន្លត់ភ្លើងឆេះព្រៃនេះ។<br>• មិនប្រើប្រាស់សារធាតុគីមីផ្សេងៗក្នុងការសំអាតព្រៃឈើ ដើមឈើនៅតាម គន្លងខ្សែនោះទេ។ | |
| ក.៧ គុណភាពដី | • មានការបំពុលដី ដោយសារការកំពប់នៃប្រេងឥន្ធនៈ ការកំពប់នៃសារធាតុគីមី និងសំណល់រឹង-រាវគ្រប់ប្រភេទទៅលើដី ដូចជា: សំណល់ចេញពីឬលេចធ្លាយពីគ្រឿងចក្រ និងរថយន្តគ្រប់ប្រភេទក្នុងដំណើរការគម្រោងនេះ ព្រមទាំងសំណល់ចេញពីផ្ទះ បាយផងដែរ។<br>• បង្កឱ្យប៉ះពាល់ដល់គុណភាពដីស្រទាប់លើនៅជុំវិញទីតាំងបង្គោលអគ្គិសនី ដោយសារចោលដីស្អុយ (ដីដែលជីកពីស្រទាប់ក្រោមគ្មានជីជាតិ) នៅ ជុំវិញទីតាំងនោះ។<br>• អាចនឹងមានការបំពុលដីដោយសារការប្រើប្រាស់សារធាតុគីមីផ្សេងៗ | | ✓ | | • សាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវមិនឱ្យកំពប់ ឬជ្រាបចូល ដីទេ។<br>• ពង្រាបដី ឬថ្មដែលចាក់ចោល ដោយយកដីមានជីជាតិលប់ពីលើ រួចដាំស្មៅ ឡើងវិញក្នុងតំបន់សាងសង់បង្គោលអគ្គិសនីនេះ (១៥x១៥ម)។ ត្រូវធ្វើជញ្ជាំង ផ្លូវឱ្យមានជើងទេរត្រឹមត្រូវជៀសវាងការបាក់ដីនៅពេលមានភ្លៀងធ្លាក់ពីព្រោះ តំបន់នេះមានភ្លៀងច្រើន។<br>• ត្រូវគ្រប់គ្រងសំណល់រឹង-រាវគ្រប់ប្រភេទឱ្យបានត្រឹមត្រូវដូចជា ៖ ចាត់វិធានការយ៉ាងតឹងរ៉ឹងមិនឱ្យចាក់ប្រេងម៉ាស៊ីនចាស់ៗ (ប្រេងបាត) ចោល ទៅលើដី។<br>• ត្រូវដាក់ពិន័យដល់អ្នកដែលប្រព្រឹត្តខុសខាងលើនេះ ដូចជា ស្តីបន្ទោស ឬការ បណ្តេញពីការងារជាដើម។ | |

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | ក្នុងការសំអាត ឬបង្ហាក់ការលូតលាស់របស់ឈើ ធ្លាក់ទៅ លើដី។<br>• ការឈូសកាប់ព្រៃស្រទាប់លើ ដើម្បីធ្វើការសាងសង់ស្ថានីយផលិតថាមពល និងការធ្វើផ្លូវចូល ធ្វើឱ្យមានការហូរច្រោះដី នៅរដូវវស្សា និងមានសំណើក ដោយសារខ្យល់ និងកំដៅថ្ងៃនៅរដូវប្រាំងនឹងធ្វើ ឱ្យបាត់បង់គុណភាពដីនៅក្នុងតំបន់គម្រោងផងដែរ។ | | | | • មិនប្រើសារធាតុគីមីផ្សេងៗក្នុងការសំអាតឬ បង្អាក់ការលូតលាស់របស់ឈើ នោះទេ។<br>• សាងសង់របងជុំវិញស្ថានីយផលិតថាមពលរួចដាំស្មៅធ្វើផ្លូវតូចៗក្នុងបរិវេណ កន្លែងដាក់គ្រឿងស្ព័រម៉ាទ័រ និងមានប្រព័ន្ធលូការពារការហូរច្រោះ ដើម្បីថែ រក្សាគុណភាពដីក្នុងតំបន់គម្រោងឱ្យបានល្អ។<br>• ត្រូវដាំស្មៅនៅតាមគន្លងខ្សែដែលមិនមានស្មៅ ឬឈើដុះ ក្នុងតំបន់ដី សាធារណៈ ឯកជនរបស់រដ្ឋដោយសហការយ៉ាងជិតស្និទ្ធិជាមួយរដ្ឋបាលព្រៃឈើក្នុង តំបន់។ | |
| ក.៨ សំឡេងនិងរំញ័រ | • មានការបំពុលបរិស្ថានដោយសំឡេងនិងរំញ័រតិចតួច ដោយសារ ការដឹកជញ្ជូនសម្ភារសំណង់ បង្គោលអគ្គិសនី ខ្សែអគ្គិសនីជាដើម។ល។ ដោយសារ ការគ្រឿងចក្រ ម៉ាស៊ីនភ្លើង និងរថយន្តគ្រប់ប្រភេទ ដោយសារ ការប្រើគ្រឿងផ្ទុះ ក្នុងដំណើរការគម្រោងនេះ។ | ✓ | | | • ប្រើគ្រឿងចក្រ ម៉ាស៊ីនភ្លើង និងរថយន្តមានគុណភាពល្អ មិនមានសំឡេង និងរំញ័រខ្លាំង។<br>***សម្គាល់:*** *ជាក់ស្តែងក្រុមការងារសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនេះបានសហការជាមួយមន្ទីរពិសោធន៍នៃក្រសួងបរិស្ថាន ធ្វើតេស្ត សំឡេងនិងរំញ័រនៅចំណុចដែលមានសកម្មភាពមមាញឹកជាងគេ ក្បែរតំបន់គម្រោង ស្ថិតនៅចំណុចស្រែពាំង ក្បែរផ្លូវជាតិលេខ៥៥ លទ្ធផល បានបង្ហាញថានៅពេលថ្ងៃសំឡេងមានកម្រិតក្រោមស្តង់ដារបស់ក្រសួងបរិស្ថាន តែនៅពេលយប់ លើសស្តង់ដាតិចតួចប៉ុណ្ណោះ គឺនៅម៉ោង៥ ទៅ ៦ ភ្លឺ ប៉ុន្តែជាមធ្យមមានតែ ៤៩.១dB ក្រោមស្តង់ដា (៥០dB)។ ចំណែកឯរំញ័រវិញ គឺស្ថិតនៅក្រោម ស្តង់ដារបស់ក្រសួងបរិស្ថាន។* | |
| ខ. ធនធានជីវសាស្រ្ត | | | | | | |
| ខ.១ ជីវសាស្រ្ត ដែលរស់នៅក្នុងទឹក/មច្ឆជាតិ | • អាចប៉ះពាល់គុណភាពទឹកប្រឡាយ-អូរ-ស្ទឹង នៅក្បែរការដ្ឋានសាងសង់បង្គោលអគ្គិសនី និងអនុស្ថានីយពោធិ៍សាត់ ដោយសារការងារដី ការងារបេតុង ដែលមានដីស្អុយ (ដីដែលជីកពីស្រទាប់ក្រោមគ្មានជីជាតិ)ហូរច្រោះ ដោយសារទឹកភ្លៀង និងការបោះចោលនូវសម្ភារសំណង់ ធ្វើឱ្យល្អក់ទឹកបណ្តាលឱ្យពុលដល់មច្ឆជាតិ និងជីវសាស្រ្តនៅក្នុងប្រភពទឹកធម្មជាតិទាំងនេះ។ | | ✓ | | • ត្រូវដាំស្មៅតាមកន្លែងដែលសាងសង់បង្គោលរួចហើយ និងដាំស្មៅនៅកន្លែងដែល កាប់សំអាតគន្លងដែលគ្មានស្មៅ ឬឈើដុះ ដើម្បីការពារការហូរច្រោះ ដែល អាចធ្វើឱ្យមានការបំពុលទឹក។<br>• ធ្វើការអប់រំដល់បុគ្គលិក-កម្មករអំពីការបោះបង់សំណល់រឹង-រាវ ជាពិសេស ការកំពប់ប្រេងឥន្ធនៈ ប្រេងរំអិល នៅលើដី និងក្នុងទឹកនៅក្នុងតំបន់គម្រោង។<br>• ត្រូវគ្រប់គ្រងសំណល់រឹងគ្រប់ប្រភេទនៅទីតាំងដែលមានសុវត្ថិភាព។ | |
| ខ.២ ព្រៃឈើការពារ/តំបន់ការពារ/ ឧទ្យានជាតិ | • មានការប៉ះពាល់ដល់តំបន់ការពារសង្កាត់រដ្ឋបាលព្រៃឈើប្រមោយ ដែលមានគម្របព្រៃឈើ ចំនួន១៣,៦ គីជាព្រៃស្រោង ហើយព្រៃនេះក៏មានសត្វព្រៃ ជាច្រើនទៀតរស់នៅផងដែរ។<br>• អាចមានការចូលទន្រ្ទានរានដីកាប់ព្រៃឈើយកធ្វើជាកម្មសិទ្ធខុសច្បាប់ពីជនឆ្លៀតឱកាស។ | | | ✓ | • ក្រុមហ៊ុននឹងបង់ថវិកាមូលនិធីបរិស្ថាន និងសង្គមសរុប ៤៧៣,៥០០ ដុល្លាអាមេរិក (វគ្គ១ រយៈពេល ១០ឆ្នាំ ក្នុងតំណាក់កាលប្រតិបត្តិគម្រោង សម្រាប់ដាំឡើងវិញ និងបង្កើតសហគមន៍អភិរក្សព្រៃឈើ និងឧបត្ថម្ភអ្នកល្បាត (១០នាក់) ដែលសរុបថវិកាចំនួន ៣៩១.០០០ដុល្លារអាមេរិក។ (មើលជំពូក ចំណុច ៨.៨ តារាង៨-៣ មូលនិធិបរិស្ថាន និងសង្គម ចំណុច ៨.៨)។<br>• ក្រុមហ៊ុនត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលព្រៃឈើដំឡើងស្លាក ប៉ាណូធំៗ ដូចជាសរសេរថា ព្រៃការពារហាមទន្រ្ទានកាន់កាប់ធ្វើជាកម្មសិទ្ធ ហាមកាប់ឈើ ឬបរបាញ់ ឬដាក់អន្ទាក់សត្វព្រៃខុសច្បាប់ ជនល្មើសត្រូវដាក់គុកហូតដល់ ១០ឆ្នាំជាដើម | |

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | | | | | ហើយដាក់ជំឡើងវាឱ្យបានយ៉ាងតិច៤កន្លែងក្នុងតំបន់គម្រោង។ | |
| ខ.៣ ធនធានព្រៃឈើ និងជម្រកសត្វព្រៃ | • មានការប៉ះពាល់ដល់ផ្ទៃដីព្រៃឈើសរុប ១៣.៦ហ.ត ដោយសារការសាងសង់បង្គោលអគ្គិសនី ខ្សែបញ្ជូនតង់ស្យុងខ្ពស់២៣០គ.វ៉ ពីអាគារ ថាមពល មកខ្សែរបស់ក្រុមហ៊ុន Cambodia Power grid (CPG) ប្រវែង ៥ គ.ម។ ព្រៃឈើទាំងនេះ ជាជម្រកសត្វព្រៃជាច្រើនប្រភេទ ក្នុងតំបន់គម្រោងដូចមានចែងក្នុងជំពូក៥ចំណុច៥.១.២.២ ខាងលើនេះ។<br>• ធ្វើឱ្យរំខានដល់ការរស់នៅរបស់ពពួកសត្វព្រៃ ដែលមាននៅក្នុង និងជុំវិញទីតាំងគម្រោង ដោយសារហេនសំឡេងនិងរំញ័រចេញពីគ្រឿងចក្រ រថយន្តម៉ាស៊ីនគ្រប់ប្រភេទ ពេលកំពុងធ្វើការងារការសាងសង់គម្រោង ។ល។<br>• អាចមានការប៉ះពាល់ដោយសាររំញ័រ ដោយសារ ការដឹកជញ្ជូនសម្ភារគម្រោងធ្ងន់ៗ ក្នុងការសាងសង់នេះ។<br>• អាចនឹងមានការប៉ះពាល់ដល់ព្រៃឈើ ក៏ដូចជាជម្រកសត្វព្រៃ ដោយសារការប្រើប្រាស់ថ្នាំគីមី ដើម្បីសំអាត ឬបង្អាក់ការលូតលាស់របស់ឈើក្នុងការសាងសង់គម្រោងនេះ។<br>• មានការប៉ះពាល់ព្រៃឈើ និងជម្រកសត្វព្រៃ ដោយសារ ការរំលោភចូល តំបន់ព្រៃការពារ ឬតំបន់អភិរក្ស ដោយសារ ក្រុមហ៊ុន ដែលបានអាជ្ញា បណ្ណ័កាប់សំអាតឈើក្នុងតំបន់គម្រោងប្រើប្រាស់មធ្យោបាយគ្រប់រូបភាព ដើម្បីឆ្លៀតឱកាសកេងចំណេញ ដូចជា ប្រមូលទិញ ក្រញូង ឬឈើ ប្រណិតផ្សេងៗពីប្រជាជនជាដើម ពីព្រោះខ្លួនទទួលបាននូវអាជ្ញាបណ្ណ័ នាំយកចេញមកក្រៅតំបន់ រីឯប្រជាជន គ្មានសិទ្ធិដឹកឈើទាំងនោះ ចេញទេធ្វើឱ្យព្រៃឈើក្នុង ឬក្បែរតំបន់រងការរុករាន និងបំផ្លាញខូច ជម្រកសត្វព្រៃទៀតផង។ | | | ✓ | • សូមធានាមិនកាប់ព្រៃឈើនៅក្រៅពីទីតាំងសាងសង់បង្គោលអគ្គិសនី និងតាម ចំណាំខ្សែបញ្ជូនតង់ស្យុងខ្ពស់២៣០គ.វ៉ដូចដែលមានបង្ហាញនៅក្នុងប្លង់រចនាគម្រោងលម្អិតឡើយ។<br>• ធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន ដើម្បីកាត់បន្ថយ ហេតុប៉ះពាល់បរិស្ថានអវិជ្ជមានដែល នឹងកើតមានឡើងជាយថាហេតុលើព្រៃ ឈើ ដែលនៅជាប់នឹងតំបន់គម្រោងក្នុងដំណាក់កាល នៃការសាងសង់ប្រព័ន្ធខ្សែ អគ្គិសនីទាំងនេះ។<br>• ធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន ដើម្បីធ្វើការ សំអាតព្រៃតាមចំណីគន្លងខ្សែ ២៣០គ.វ៉ ទទឹង៣០ម (១៥មសងខាងអក្ស័ បង្គោលមើលរូបទី៣) និងពិនិត្យបរិមាណ និងគុណភាពឈើ សម្រាប់ធ្វើការ ដេញថ្លៃរកចំណូល ចរិកាជូនរដ្ឋ ទៅតាមលទ្ធភាពអាចធ្វើបាន។<br>• សហការជាមួយស្ថាប័នជំនាញ ឬអង្គភាពជំនាញមូលដ្ឋាន ក្នុងការថែរក្សា ការពារព្រៃឈើ និងជម្រកសត្វព្រៃ នៅក្នុង និងក្បែរតំបន់គម្រោង ទៅតាមផែន ការគ្រប់គ្រងធនធានបរិស្ថាន ដោយបង្កើតក្រុមល្បាត ដើម្បីត្រួតពិនិត្យ និងការ ពារធនធានបរិស្ថានទាំងនោះឱ្យមានប្រសិទ្ធភាពដោយ មានកញ្ចប់ថវិកាក្នុង ផ្នែកនេះចំនួន៣៥២.៦៦៧ដុល្លារ អាមេរិក។<br>• ប្រើប្រាស់គ្រឿងយន្ត និងមធ្យោបាយដឹកជញ្ជូនមានគុណភាពល្អ ដើម្បីកាត់បន្ថយនូវសំឡេង និងរំញ័ររំខានដល់សត្វព្រៃ។<br>• កំណត់ពេលវេលាធ្វើការតែពេលថ្ងៃប៉ុណ្ណោះ ដើម្បីកាត់បន្ថយការរំខានដល់ សត្វព្រៃក្នុងតំបន់គម្រោងនេះ។<br>• ធ្វើការអប់រំដល់បុគ្គលិកកម្មករគម្រោង ឱ្យចេះស្ងៀមស្ងាត់នៅពេលម៉ោង សំរាក និងនៅពេលយប់។<br>• មិនប្រើសារធាតុគីមីផ្សេងៗក្នុងការសំអាត ឬបង្អាក់ការលូតលាស់របស់ឈើ នោះទេ។ | |
| ខ.៤ ជីវសាស្ត្រសត្វព្រៃ | • ការកាប់ឆ្ការព្រៃឈើ តាមគន្លងខ្សែអគ្គិសនីទទឹង៣០ម ការដឹកជញ្ជូនសម្ភារសាងសង់ នឹងនាំឱ្យមានការភ័យខ្លាចដល់សត្វព្រៃ ទាំងនោះ ដោយសារហេនសំឡេងនិងរំញ័ររំខានខ្លាំងៗ ចេញពីម៉ាស៊ីន គ្រឿងយន្ត និងសំឡេងរបស់បុគ្គលិក-កម្មករគម្រោង នៅពេលកំពុងសាងសង់។<br>• មានសកម្មភាពបរបាញ់ឬចាប់សត្វ ឬចូលព្រៃពីសំណាក់បុគ្គលិក-កម្មករគម្រោងទាំងនោះធ្វើឱ្យផ្អើល និងបាត់បង់សត្វព្រៃ។ | | | ✓ | • កំណត់ពេលវេលាធ្វើការតែពេលថ្ងៃសម្រាប់ការងារទាំងឡាយណា ដែលបង្ក សំឡេងនិងរំញ័រ ដើម្បីកុំឱ្យមានការរំខាន ឬផ្អើលសត្វព្រៃក្នុងតំបន់គម្រោង និង តំបន់ជិតគម្រោង។<br>• ត្រូវបំពាក់គ្រឿងការពារសត្វព្រៃ និងមនុស្សមិនឱ្យឡើងបង្គោលអគ្គិសនី និងធ្វើ ការថែទាំជាប្រចាំនូវមែកឈើដើម្បីការពារពពួកស្វា ទាំងនោះលោតតោងខ្សែនេះ ដែលធ្វើឱ្យពួកវាឆក់ស្លាប់ជាពិសេសអាចដល់មានការដាច់ខ្សែអគ្គិសនីនេះ ទៀតផង។<br>• ប្រើប្រាស់គ្រឿងយន្ត និងមធ្យោបាយដឹកជញ្ជូនមានគុណភាពល្អ ដើម្បីកាត់បន្ថយនូវសំឡេង និងរំញ័ររំខានដល់សត្វព្រៃ ។ | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | • មានការជួញដូរសត្វព្រៃនៅតំបន់គម្រោងពីសំណាក់ឈ្មួញកណ្តាលនៅតំបន់គម្រោង។ | | | | • ត្រូវអប់រំ និងដាក់វិន័យដល់បុគ្គលិកកម្មករគម្រោងមិនឱ្យធ្វើការចាប់ ឬបរបាញ់ សត្វព្រៃ និងធ្វើចរាចរលក់ដូរសត្វព្រៃ នៅក្នុងតំបន់នេះឡើយ។<br>• ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលព្រៃឈើដំឡើងស្លាក ប៉ាណូធំៗដូចជាសរសេរថា " ព្រៃការពារ ហាមទន្ទ្រានកាន់កាប់ធ្វើជាកម្មសិទ្ធ ហាមកាប់ឈើ ឬបរបាញ់ ឬដាក់អន្ទាក់សត្វព្រៃខុសច្បាប់ ជនល្មើសត្រូវដាក់ គុករហូតដល់ ១០ឆ្នាំ " ជាដើម ហើយដាក់ដំឡើងវាឱ្យបាន យ៉ាងតិច៤កន្លែង ក្នុងតំបន់គម្រោង។<br>• ត្រូវចូលរួមសហការជាមួយរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន ដើម្បីទប់ ស្កាត់បទល្មើសសត្វព្រៃ និងព្រៃឈើ។<br>• ក្រុមហ៊ុនត្រូវដំឡើងគំលាតកម្ពស់ខ្សែឱ្យមានសុវត្ថិភាពល្អ ដល់ពពួកបក្សីធំៗ និងដាក់បន្ទះជាសអ៊ីណុកតាមជើង ទាំងបួនរបស់បង្គោលអគ្គិសនីនីមួយៗ ការពារមនុស្ស និងសត្វឡើង តាមការគ្រោងទុកខាងលើ។។ | |
| គ. ធនធានសេដ្ឋកិច្ចសង្គម | | | | | | |
| គ.១ ការប្រើប្រាស់ដី និងការតាំងលំនៅដ្ឋាន ឡើងវិញ | • តាមគន្លងខ្សែ ២៣០គ.វ៉ប្រវែង៥គ.ម (ទទឹងសរុប៣០ម) និងចំណុចសាងសង់ បង្គោលចំនួន១៣ គ្មានការប៉ះពាល់ដល់ ដីកសិកម្ម ឬការប្រើប្រាស់ដីរបស់ប្រជាពលរដ្ឋនោះទេ។ | | ✓ | | | |
| គ.២ ការរស់នៅ និងមុខរបររបស់សហគមន៍មូលដ្ឋាន | • ប្រជាពលរដ្ឋនៅភូមិចំណុចទួលគ្រួស ទួលកកោះ តាំងយ៉ៃ ក្នុងភូមិស្ទឹងថ្មី ដែលរកអនុផលព្រៃឈើក្នុងតំបន់គម្រោងនេះ មានការភ័យខ្លាចអំពី សុវត្ថិភាព ដោយខ្លាចឆក់ និងមានគ្រោះថ្នាក់ដោយសារចរន្តអគ្គិសនី និងរលំបង្គោលអគ្គិសនី។<br>• ប្រជាពលរដ្ឋនៅភូមិរស់នៅក្នុង និងក្បែរតំបន់គម្រោងមានការព្រួយបារម្ភអំពីការជ្រើសកម្មករគម្រោង ដោយមិនយកពួកគាត់ យកអ្នកពីចម្ងាយវិញ។<br>• អាចនឹងមានការរើសអើងពូជសាស្ត្ររវាងបុគ្គលិកបរទេស និងកម្មករខ្មែរ ដោយបុគ្គលិកទាំងនោះធ្វើបាប បង្ខំធ្វើការងារ ជាទំងន់ ហួសកម្លាំង ពោលគឺពួកគេមិនដឹងអំពីច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា។ | | ✓ | | • ជ្រើសរើសបុគ្គលិក-កម្មករជាមធ្យម ៤០០នាក់ សម្រាប់គម្រោងទាំងមូល ក្នុងនោះ ប្រជាពលរដ្ឋមូលដ្ឋាន ចំនួន៣០០នាក់ និងបុគ្គលិក-កម្មករបរទេសចំនួន ១០០នាក់។<br>• ធ្វើការផ្សព្វផ្សាយ និងអប់រំបុគ្គលិកបរទេសទាំងអស់របស់ខ្លួនឱ្យបានយល់ដឹង អំពីច្បាប់ការងារនៃព្រះរាជាណាចក្រ កម្ពុជាដោយឱ្យពួកគេចេះគោរពច្បាប់ នេះ។ ធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរ និងស្ថាប័នពាក់ពន្ធ័ ក្នុងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់។<br>• ដំឡើងបង្គោលអគ្គិសនីឱ្យរឹងមាំ តាមបច្ចេកទេសដោយធានាមិនឱ្យរលំនៅពេលមានព្យុះភ្លៀងធម្មតា ជាពិសេសការរើតប៊ូឡុង ខ្មៅទាំងអស់របស់បង្គោលអគ្គិសនី។ កម្ពស់កន្លែងដក់របស់ខ្សែតង់ស្យុងខ្ពស់ពីដីមិនតិច ជាង៨ម (បទដ្ឋានរបស់អាជ្ញាធរអគ្គិសនីកម្ពុជាមិនតិចជាង៧.៧ម)តាមការគ្រោងទុកខាងលើ។ | |
| គ.៣ ប្រពៃណី វប្បធម៌ និងសាសនា | • អាចមានការប៉ះពាល់ដល់ជំនឿ ប្រពៃណីរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់ដោយសារ ក្រុមហ៊ុនយកបុគ្គលិក-កម្មកររបស់ខ្លួន ដែល មកពីតំបន់ឆ្ងាយខុសៗគ្នា និងមានសញ្ជាតិខុសៗគ្នា។ | | ✓ | | • ត្រូវសិក្សាស្វែងយល់អំពីប្រពៃណី និងជំនឿសាសនារបស់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសប្រជាពលរដ្ឋរស់នៅ ភូមិស្ទឹងថ្មីទាំងមូល និងគោរពទៅតាម ប្រពៃណី ទំនៀមទំលាប់នេះ ដោយមិនធ្វើការបំពាន និងល្មើសឡើយ ។ | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | • អាចប៉ះពាល់ដល់កន្លែងសក្ការៈបូជាទាំងឡាយដូចជា ព្រៃអ្នកតា ឬទីទួល ព្រៃកប់ខ្មោចសំណាក់ម្ចាស់ទឹកដីក្នុងតំបន់។ល។ ដោយសារគម្រោង ធ្វើការកាប់ឆ្ការដីព្រៃឈើ ដើម្បីសាងសង់ប្រព័ន្ធខ្សែអគ្គិសនីនេះ។ | | | | • ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីធ្វើការអប់រំ និងណែនាំដល់ បុគ្គលិក-កម្មកររបស់ខ្លួនអំពីទំនៀម ទំលាប់ប្រពៃណីប្រជាពលរដ្ឋកម្ពុជា ជាពិសេសទំនៀមទំលាប់ប្រពៃណីប្រជាពលរដ្ឋនៅ ភូមិពាក់ព័ន្ធទាំងអស់ ជាមួយគម្រោង។<br>• ត្រូវសហការជាមួយរដ្ឋអំណាចមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធដើម្បីបង្កើត និងអភិរក្សកន្លែងសក្ការៈបូជាទាំងឡាយ ដែលបាត់បង់នោះឡើងវិញ ដូច ដែលមានគន្លងមកនៅភូមិរបស់គាត់។ | |
| គ.៤ ការប្រើប្រាស់ទឹក | • ពានការប៉ះពាល់ដល់ការប្រើប្រាស់ទឹកប្រឡាយ-អូរ-ស្ទឹង ដោយសារសកម្មភាពសាងសង់ផ្លូវចូល បង្គោលអគ្គិសនីរបស់គម្រោង និងការគ្រប់គ្រងសំណល់រឹង-រាវមិនបានល្អ ធ្វើឱ្យបំពុលដល់ប្រភពទឹកលើ ដី និងក្រោមដី ដែលជាប្រភពដ៏សំខាន់ក្នុងការផ្គត់ផ្គង់ទឹករបស់ ប្រជាពលរដ្ឋផ្នែកខាងក្រោមខ្សែទឹក។<br>• សំណល់រាវចេញពីបង្គន់ បន្ទប់ទឹក និងផ្ទះបាយ ការបន្ទោរ បង់ក្នុងប្រភពទឹកធម្មជាតិ របស់បុគ្គលិក-កម្មករគម្រោង ការសំអាតខ្លួនប្រាណរបស់ពួកគេក្នុងប្រឡាយ-អូរ-ស្ទឹង ការលេចធ្លាយ ប្រេងឥន្ធនៈ និងប្រេងរំអិលពីឧបករណ៍ ឬគ្រឿងយន្តនានា ក្នុងការដ្ឋានសាងសង់ ធ្លាក់ចូលទៅក្នុងប្រឡាយ-អូរ-ស្ទឹង នឹងបង្កឱ្យមានការបំពុលទឹកប្រឡាយ-អូរ-ស្ទឹងទាំងនោះ ពីព្រោះការដ្ឋានសាងសង់មានរយៈពេលយូរខែ។ | | ✓ | | • ការឈូសឆាយទ្រង់ទ្រាយធំ ក្រុមហ៊ុនមិនធ្វើនៅរដូវវស្សាទេ។<br>• ត្រូវធ្វើរបាំងការពារកករដីកុំឱ្យសាយភាយចេញឆ្ងាយពីទីតាំងសាងសង់ហើយសាងសង់បង្គន់អនាម័យ និងបន្ទប់ទឹកឱ្យបានគ្រប់គ្រាន់ទៅតាមចំនួនបុគ្គលិក -កម្មករគម្រោង ឱ្យបានឆ្ងាយពីប្រភពទឹកយ៉ាងតិច ២០០ម។<br>• ត្រូវធ្វើការអប់រំណែនាំបុគ្គលិក-កម្មករគម្រោង មិនឱ្យមានការបន្ទោរបង់ក្នុង ប្រភពទឹកធម្មជាតិ ឬសាធារណៈឡើយ និងឱ្យយល់ដឹងអំពីអនាម័យស្គាល់នូវ កន្លែងទុកដាក់សម្រាមដែលក្រុមហ៊ុនបានរៀបចំកសាងក្នុងទីតាំងស្នាក់នៅ ហើយដាក់ពិន័យដល់បុគ្គលិក-កម្មករណាដែលមិនព្រមធ្វើតាមការណែនាំ។<br>• ត្រូវចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងសំណល់រឹង-រាវ ដោយ សាងសង់បង្គន់អនាម័យ ព្រមទាំងរៀបចំប្រមូលសំណល់រឹង និងសម្រាមយក ទៅចោលនៅទីតាំងដែលមានសុវត្ថិភាព។<br>• នៅការដ្ឋានសាងសង់អាគារថាមពល (វាលគ្រង់ស្វា) ក្រុមហ៊ុនសាងសង់អាងសិបទិកទំនើបដែលអាចសំអាតទឹកកខ្វក់ចេញពីការិយាល័យ និងកន្លែងស្នាក់នៅឱ្យបានល្អប្រសើរ។<br>• សាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវតាមបទដ្ឋានសុវត្ថិភាព ដល់បរិស្ថាន និងសង្គម។<br>• ប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និងរថយន្តដឹកជញ្ជូន ដែលមានគុណភាពល្អមិន លេចហូរជាតិប្រេង ឬធ្លាញ់មកលើដី និងប្រភពទឹកក្នុងតំបន់គម្រោង។<br>• ត្រូវពង្រាបដី និងដាំស្មៅតាមកន្លែងដែលសង់គ្រឹះបង្គោលអគ្គិសនី (ព្រោះមានដី ស្មុយគ្មានជីជាតិស្មៅមិនដុះនាំឱ្យមានការហូរច្រោះបំពុលគុណភាពទឹក) ដើម្បីការពារការហូរច្រោះដែលអាចធ្វើឱ្យមានការបំពុលទឹក។ | |
| គ.៥ តំបន់ទេសចរណ៍/រមណីយដ្ឋាន/ទីកន្លែងកំសាន្ត | • មិនមានការប៉ះពាល់ដល់តំបន់ទេសចរណ៍ និងទីកន្លែងកំសាន្តរបស់តំបន់នេះទេ តែប៉ុន្តែប៉ះពាល់ដល់អ្នកទេសចរណ៍ដែលចង់មើលការសាងសង់គម្រោងឬទៅមើលអន្លង់ផ្សេងៗក្នុងស្ទឹងនេះ ដោយសារសកម្មភាព សាងសង់ប្រព័ន្ធខ្សែ២៣០គ.វ៉ ជាពិសេសដោយសារសម្រាមផ្ទះ បាយដូចជាសំបកដបគ្រប់ប្រភេទ ស្បោង ប្លាស្ទិក | ✓ | | | • ត្រូវធ្វើការគ្រប់គ្រងសំណល់រឹង-រាវគ្រប់ប្រភេទ ឱ្យបានត្រឹមត្រូវមានរណ្តៅកប់ សម្រាមឱ្យបានសមរម្យ។ ត្រូវធ្វើការអប់រំដល់បុគ្គលិក-កម្មករគម្រោងទាំងអស់ ឱ្យចេះដឹងអំពីអនាម័យ និងបរិស្ថានស្អាត ដោយមិនបោះសម្រាមចោលពាសវាល ពាសកាល។<br>• ត្រូវដាក់បញ្ចូលក្នុងសៀវភៅបន្ទុក ដែលជាឯកសារធ្វើកិច្ចសន្យាម៉ៅការបន្ត ទៅឱ្យក្រុមហ៊ុនផ្សេងៗ ត្រូវសំអាតទីតាំងការដ្ឋាន និងកន្លែងជំរុំស្នាក់នៅរបស់ បុគ្គលិក-កម្មករឱ្យបានស្អាត | |



Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | ក្រណាត់ ខោអាវ គ្រប់ប្រភេទ សំបកកង់រថយន្តគ្រប់ប្រភេទជាដើម ។ល។ ដែលធ្វើ ឱ្យតំបន់ និងទីកន្លែងនេះកខ្វក់ទៀតផង។ | | | | ដោយមានបង្អកប្រាក់ទុករង់ចាំក្រុមការងារអនុគណៈកម្មការខេត្តចុះពិនិត្យរួច បានបញ្ជាក់ថាទីតាំងទាំងនោះស្អាតសរម្យ អាចទទួល យកបានហើយទើបបើកប្រាក់ ដែលបង្អកនោះឱ្យ។ | |
| គ.៦ ផ្លូវគមនាគមន៍ | • មានការប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ក្នុងតំបន់គម្រោងនេះដោយសារសកម្មភាពសាងសង់គម្រោង និងការដឹកជញ្ជូនឧបករណ៍ -សម្ភារបរិក្ខារអគ្គិសនី ដែលមានទំងន់រាប់តោនចូលទៅទីតាំង គម្រោងបណ្តាលឱ្យមានការស្រុត ឬខូចផ្លូវ ការបាក់ស្ពាន ការកកស្ទះ ចរាចរ ឬគ្រោះថ្នាក់ចរាចរលើទ្រូងផ្លូវដែលមានចំណោតឡើងទួល និងផ្លូវកោង។ ល។<br>• អាចមានគ្រោះថ្នាក់ចរាចរនៅពេលដែលដំឡើងខ្សែអគ្គិសនីកាត់ ផ្លូវលំ ជនបទ (ផ្លូវទេះ ឬផ្លូវដែលក្រុមហ៊ុនបានសង់) ដោយសារ កម្ពស់ខ្សែ មិនទាន់ទាញ បានដល់ចំណុចកម្ពស់ដែលបានគ្រោង ទាក់អ្នកធ្វើដំណើរ បង្កជាគ្រោះថ្នាក់ដល់អ្នកធ្វើចរាចរណ៍ជាដើម។ល។ | | ✓ | | • ធ្វើការកែលំអផ្លូវដែលមានស្រាប់និងសាងសង់ផ្លូវថ្មី ទៅកាន់ទីតាំងគម្រោង ដែលអាចធានាដល់ការប្រើប្រាស់របស់គម្រោង ហើយធ្វើការពិភាក្សាជាមួយ ស្ថាប័នជំនាញ ក្នុងការដឹកជញ្ជូនសម្ភារធ្ងន់ៗ។<br>• ត្រូវធ្វើការអប់រំដល់បុគ្គលិកដែលបញ្ជាគ្រឿងចក្រ និងយានយន្តទាំងអស់ត្រូវ ធ្វើការប្រុងប្រយ័ត្នគ្រប់ពេលវេលា ហើយក្រុមហ៊ុនធានានូវសុវត្ថិភាពក្នុងការ ដឹកជញ្ជូនល្បឿនបើកបរមិនឱ្យលើសពី៣០គ.មក្នុង១ម៉ោង នៅក្នុងតំបន់ភូមិ និងទីប្រជុំជនមិនឱ្យលើស១០គ.មក្នុង១ម៉ោង១០) និងដើម្បីបញ្ចៀសគ្រោះ ថ្នាក់ចរាចរនានា។<br>• ត្រូវធ្វើការជួសជុលស្ពានដែលមានស្រាប់ដើម្បីធានាលើការដឹកជញ្ជូននិងប្រើ ប្រាស់ប្រភេទយានយន្តដែលមិនបង្កឱ្យបាក់ស្ពាន ដែលមានស្រាប់ទាំងនោះ។<br>• ត្រូវសហការជាមួយមន្ទីរពាក់ព័ន្ធ ធ្វើការដោះស្រាយសម្រួលចរាចរក្នុងតំបន់ មានការកកស្ទះ និងកន្លែងបត់ចូលការដ្ឋាន និងសម្រួលចរាចរនៅពេលដឹកជញ្ជូន គ្រប់ស្ពាន។<br>• ត្រូវធ្វើការជួសជុលផ្លូវក្នុងតំបន់គម្រោងឱ្យបានល្អ និងធ្វើការថែរក្សាផ្លូវដែល ខ្លួនបានប្រើប្រាស់ជាប្រចាំ។<br>• នៅគ្រប់ចំណុចដែលខ្សែនេះឆ្លងកាត់ផ្លូវថ្នល់ក្រុមហ៊ុនត្រូវគ្រោងដំឡើងកម្ពស់ខ្សែទាបបំផុតពីដី១៥ម (ស្តង់ដារអគ្គិសនី១៤,២ម) ហើយនឹងអនុវត្តការដំឡើង ខ្សែអគ្គិសនីនេះភ្លាមៗ គឺមិនបន្ធូរខ្សែឆ្លងកាត់ផ្លូវចោលនោះទេ។ ធ្វើរបាខ្ពស់ (កម្ពស់យ៉ាងតិច ៦ម)ដើម្បីទ្រខ្សែអគ្គិសនី នៅពេលដែលដំឡើងខ្សែអគ្គិសនីកាត់ ផ្លូវទោះជាផ្លូវរបស់ខ្លួនក៏ដោយ។ ត្រូវធ្វើសេចក្តីជូនដំណឹងទៅអាជ្ញាធរ និងដាក់ ស្លាកប្រកាសអំពីការដ្ឋានកំពុងសាងសង់ចម្ងាយពីការដ្ឋាន១០០ម និងស្នើសុំឱ្យ មានសមត្ថកិច្ច ផ្នែកចរាចរមកជួយធ្វើអន្តរាគមន៍ នៅពេលដំឡើងខ្សែអគ្គិសនី នេះជៀសវាងកើតមានគ្រោះថ្នាក់ ទាក់ខ្សែនេះ។ | |
| គ.៧ សុខភាពសាធារណៈ | • អាចបង្កឱ្យមានការប៉ះពាល់ដល់សុខុមាលភាពបុគ្គលិក-កម្មកររបស់ក្រុមហ៊ុន និងប្រជាពលរដ្ឋមួយចំនួន ចូលទៅតំបន់គម្រោង ដោយសារ ធូលីដី ធូលីស៊ីម៉ងត៍ ចំហាយចេញពីការប្រើប្រាស់សារធាតុគីមី ជាដើម។<br>• បង្កឱ្យមានផលប៉ះពាល់ដល់សុខភាពបុគ្គលិក-កម្មកររបស់គម្រោង ដោយ សារតំបន់ខ្លះនៃគម្រោងនេះ ជាតំបន់ដែលកើតជំងឺគ្រុនចាញ់ និងគ្រុនសន្និ។ ប្រជាពលរដ្ឋនៅក្បែរតំបន់គម្រោងដូចជាប្រជាពលរដ្ឋរស់នៅ ភូមិស្ទឹងថ្មី ទាំងមូលអាចឆ្លងជំងឺអេដស៍ ជំងឺកាមរោគ ជំងឺ | | ✓ | | • ប្រកាន់យកការរក្សាសុវត្ថិភាពការងារជាចំបង ក្នុងសកម្មភាព ការងារប្រចាំថ្ងៃ។<br>• ដើម្បីការពារសុខភាព ដែលបណ្តាលមកពីធូលីដីក្នុងការងារសាងសង់គ្រឹះ បង្ហោល និងអនុស្ថានីយពោធិ៍សាត់ ការឈូសឆាយដីកសាងផ្លូវ និងដឹកជញ្ជូន សម្ភារសំណង់ ក្រុមហ៊ុនត្រូវត្រៀមផ្តល់ម៉ាស់ការពារធូលីដី និងធ្វើការស្រោច ទឹកលើផ្លូវថ្នល់ជាប្រចាំ មិនឱ្យប៉ះពាល់ការហុយធូលីដី ធ្វើឱ្យប៉ះពាល់សុខភាព បុគ្គលិក-កម្មករគម្រោង និងសាធារណជន ដែលធ្វើដំណើរឆ្លងកាត់ការដ្ឋានសាង សង់ឡើយ។<br>• ត្រូវសាងសង់ជំរំស្នាក់នៅរបស់បុគ្គលិក-កម្មករគម្រោងឱ្យបានសមរម្យ ដោយ មានការផ្គត់ផ្គង់ទឹកស្អាត មានបង្គន់អនាម័យ បន្ទប់ទឹកគ្រប់គ្រាន់ និងមានកម្ម វិធីអប់រំសុវត្ថិភាពការងារ | |

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | របេង ជំងឺ ឆ្លងផ្សេងៗពីបុគ្គលិក-កម្មករគម្រោង ដែលជ្រើសរើសមកពីឆ្ងាយ ដោយ ក្រុមហ៊ុនផងដែរ។<br>• អាចប៉ះពាល់ដល់សុខភាពសាធារណៈ (ប្រជាពលរដ្ឋក្នុងតំបន់ និងបុគ្គលិក-កម្មករគម្រោង) ដោយសារការប្រើប្រាស់ ឬចរាចរគ្រឿងញៀន។<br>• អាចប៉ះពាល់ប្រជាពលរដ្ឋ និងបុគ្គលិក-កម្មករគម្រោង ដោយសារមិនចាប់អារម្មណ៍អំពីសុវត្ថិភាពការងារ។<br>• ក្នុងតំបន់គម្រោង នៅកន្លែងគ្មានប្រភពទឹកស្អាតសម្រាប់បរិភោគទេ ក្រុមហ៊ុនត្រូវខ្វះអណ្តូងទឹកស្អាតគ្រប់គ្រាន់ នៅតាមជំរំកម្មកររស់នៅបណ្តោះអាសន្នទាំងនោះ។<br>• អាចមានគ្រោះថ្នាក់ដល់កម្មករដំឡើងខ្សែ និងបង្គោលដោយសារ ការធក់(ទោះបីជាមិនទាន់ភ្ជាប់ចរន្តក៏ដោយ) ដោយសាររន្ទះពីព្រោះ ខ្សែនេះមានចម្ងាយប្រហាណ៥គ.ម ដូចនេះបើមានអាកាសធាតុមិន ល្អ បណ្តាលឱ្យមានរន្ទះកន្លែងណាមួយនោះចរន្ត អគ្គិសនីនឹងស្រូបចូលតាមខ្សែ ឬបង្គោលធ្វើធក់អ្នក ដែលប៉ះផ្ទាល់ទៅលើខ្សែ ឬបង្គោលដែកនេះ។<br>• អាចមានប្រជាពរដ្ឋ ឬជនណាម្នាក់ឡើងបង្គោលអគ្គិសនី អាចបណ្តាលឱ្យ មានគ្រោះថ្នាក់ធ្លាក់ ឬមានការធក់ (ទោះបីជាមិនទាន់ភ្ជាប់ចរន្តក៏ ដោយ)។<br>• អាចនឹងមានការផ្ទះស្សែខ្សែអគ្គិសនី រវាងខ្សែតង់ស្យុងខ្ពស់ កំពុងដំឡើង និងខ្សែតង់ស្យុងមធ្យមប៉ះគ្នា។ | | | | ដល់បុគ្គលិក-កម្មកររបស់គម្រោង។<br>• ជ្រើសរើសគ្រូពេទ្យដែលមានសមត្ថភាពនៅប្រចាំការក្នុងការដ្ឋាន និងជំរុំស្នាក់ នៅរបស់កម្មករ និងត្រៀមថ្នាំពេទ្យ និងបរិក្ខារគ្រប់គ្រាន់ជាប្រចាំសម្រាប់ការ ពិនិត្យ និងព្យាបាលជូនបុគ្គលិក-កម្មកររបស់គម្រោង ហើយមានរថយន្តសង្គ្រោះ បន្ទាន់នៅពេល ដែលមានករណីគ្រោះថ្នាក់កើតឡើងជាយថាហេតុ។<br>• ត្រូវធ្វើការអប់រំសុខភាពអនាម័យ ដល់បុគ្គលិក-កម្មកររបស់ខ្លួនក្នុងការទប់ស្កាត់ ជំងឺទាំងនោះកុំឱ្យឆ្លងទៅប្រជាពល រដ្ឋក្នុងតំបន់នោះ។<br>• ត្រូវសហការណ៍ជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ពិសេសទប់ស្កាត់ ការជួញដូរ ចរាចរគ្រឿងញៀន និងមនុស្ស។<br>• មានដំឡើងខ្សែការពាររន្ទះ និងប្រពន្ធ័សុវត្ថិភាពការពារធក់ នៅពេលដែលកើត មានចរន្តអគ្គិសនី ដោយចៃដន្យ ដែលបណ្តាលមកពីអាកាសធាតុ។<br>• ត្រូវសហការជាមួយការិយាល័យសុខាភិបាលស្រុកនៅក្នុងតំបន់នេះ ដើម្បីការពារទប់ស្កាត់ជំងឺឆ្លងផ្សេងៗ ដែល កើតមានឡើងជាយថាហេតុ។<br>• ត្រូវសាងសង់គ្រឿងការពារសត្វ-មនុស្ស ភ្ជាប់នឹងបង្គោលអគ្គិសនីទាំងបួនកុំឱ្យសត្វ-មនុស្សឡើងបាន និងមានដាក់ស្លាកសញ្ញាហាមឃាត់ ភ្លាមៗមុននឹង បញ្ចប់សាងសង់បង្គោលមួយ រួចហើយទៅសាងសង់បង្គោលមួយទៀត។<br>• ក្រុមហ៊ុនត្រូវដំឡើងខ្សែនៅគ្រប់ចំណុច នៅពេលដែលមានខ្សែតង់ស្យុងមធ្យមដទៃទៀតឆ្លងកាត់ពីលើគ្នាដោយ ធានាសុវត្ថិភាពកុំឱ្យមានការឆ្លងចរន្តធ្វើឱ្យផ្ទុះដាច់ខ្សែ អាចធ្វើឱ្យប៉ះពាល់ដល់អាយុជីវិតមនុស្ស។ ***សម្គាល់៖*** *នៅខែកញ្ញា ឆ្នាំ២០១៥នេះនៅតំបន់គម្រោងមិនទាន់មាន ខ្សែអគ្គិសនីតង់ស្យុងមធ្យម នៅឡើយទេ។* | |
| គ.៨ សោភ័ណ្ឌភាព/ទេសភាព | • មានការប៉ះពាល់ដល់សោភ័ណ្ឌភាពទេសភាព ក្នុងតំបន់គម្រោងដោយសារការដំឡើងបង្គោលមិនមានការរត់ត្រង់គ្នា ឬកម្ពស់មិនស្មើគ្នា ជាដើម។ល។<br>• អាចនឹងបង្កផលប៉ះពាល់ដល់សោភ័ណ្ឌភាពដល់តំបន់ការពារ និងអភិរក្សទាំងនោះដែរ ដោយសារការរៀបចំបង្គោល និងខ្សែបញ្ជូនតង់ស្យុងខ្ពស់២៣០គ.វ៉នេះមិនរត់តាមជួរល្អ និងកាប់ឆ្ការព្រៃឈើ ក្នុងតំបន់នេះ។<br>• ការហុយធូលីដោយសារការដឹកការដុតព្រៃសម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធជាដើម ក៏អាចធ្វើឱ្យប៉ះពាល់ដល់សោភ័ណ្ឌភាព និងទេសភាព កន្លែងនោះដែរ។<br>• ការបោះសំណល់រឹង-រាវគ្រប់ប្រភេទ ដូចជាសំបកកង់ឡាន សំបក | | ✓ | | • ធ្វើការតម្រង់ទិស និងកំណត់កម្ពស់ទៅតាមស្ថានភាពដី (កម្ពស់ចាប់ពី២០-៤០ម) ឱ្យបានសមស្រប ដើម្បីរំលេចនូវសោភ័ណ្ឌភាព នៃប្រព័ន្ធខ្សែអគ្គិសនីនេះ។ នឹងសំអាតព្រៃទៅតាមទំហំ កំណត់នៃចំណីតន្លងខ្សែអគ្គិសនី (ម្ខាង១៥ មពីអក្សបង្គោលអគ្គិសនី) និងកាត់តំរឹមដើមឈើតាមគន្លងខ្សែអគ្គិសនីនេះឱ្យបានស្មើល្អដើម្បីធ្វើឱ្យប្រព័ន្ធខ្សែអគ្គិសនី កាន់តែមានសោភ័ណ្ឌភាពថែមទៀត ជាពិសេសការពារពពកស្វាលោតតោងទៀតផង។<br>• ត្រូវធ្វើគន្លងខ្សែនាំអគ្គិសនី ឱ្យបានត្រង់ល្អ ដើម្បីមើលទៅរត់ត្រង់ជួរគ្នា។<br>• ត្រូវធ្វើការស្រោចទឹកជាប្រចាំទៅលើផ្លូវថ្នល់ដែលខ្លួនកំពុង ប្រើប្រាស់សាងសង់ គម្រោង។ | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | ដប ស្បោងប្លាស្ទិកគ្រប់ប្រភេទ ក្រណាត់ខោអាវ សំណល់បេតុង ។ល។ ធ្វើឱ្យកខ្វក់តំបន់នេះ ដោយសំណល់ទាំងនេះ មិនងាយ និងរលាយទេ។ | | | | | |
| ក.៩ ហានិភ័យ | • អាចនឹងមានហានិភ័យ ដោយសារគ្រោះធម្មជាតិ ការកើតមានការរញ្ជួយដី នៅក្នុងតំបន់គម្រោងការទទួលរងឥទ្ធិពល ពីព្យុះទីហ្វុង ឬព្យុះផ្សេងទៀត ដែលជាហេតុបង្កឱ្យមានមហន្តរាយ ធំៗរលំបាក់ ឬដាច់ខ្សែអគ្គិសនី និងការខូចហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ របស់គម្រោង ដែលកំពុងសាងសង់ ការបាត់បង់ ឬខូចខាតសម្ភារ និងគ្រឿងចក្រ សាងសង់ ជាពិសេសការធ្វើឱ្យរងរបួស និងស្លាប់បាត់បង់ជីវិតដល់បុគ្គលិកកម្មករ ព្រមទាំងប្រជាពលរដ្ឋនៅក្នុង/ក្បែរខាងតំបន់គម្រោង។<br>• អាចនឹងកើតមានការផ្ទុះសម្ភារ គ្រឿងផ្ទុះ ឆេះប្រេងឥន្ធនៈនៅ កន្លែង ឬឃ្លាំងស្តុករបស់គម្រោង និងការឆេះព្រៃក្នុងតំបន់គម្រោង ដែលបណ្តាលមកពីការធ្វេសប្រហែស ឬអំពើភេរវកម្ម ក៏អាចបង្កឱ្យមានមហន្តរាយដល់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គម្រោងនិង ធនធានធម្មជាតិក្នុងតំបន់ និងអាយុជីវិតមនុស្សទៀតផង។<br>• អាចនឹងកើតមានសង្គ្រាមឈ្លានពានលើបូរណភាពទឹកដីនៃ ប្រទេសកម្ពុជា ក៏ជាឧបសគ្គដល់ការងារសាងសង់គម្រោង ឬសង្គ្រាមអាចបំផ្លាញគម្រោងទាំងស្រុងក៏សឹងមាន។ | | | ✓ | • ធ្វើការសាងសង់តាមការសិក្សារចនាប្លង់វិស្វកម្ម ដែលមានកម្រិតស្តង់ដាអន្តរជាតិ និងសម្ភារសំណង់ធន់នឹងការ ប្រែប្រួលអាកាសធាតុ ហើយធានា គុណភាព និងការប្រើប្រាស់ ដែលក្រុមហ៊ុនបានចុះកិច្ចសន្យាជាមួយរាជរដ្ឋា ភិបាលកម្ពុជា។<br>• ត្រូវប្រុងប្រយ័ត្នគ្រប់វិនាទី ក្នុងការការពារសុវត្ថិភាព ចំពោះគ្រឿងផ្ទុះការ ឆេះព្រៃ និងឆេះប្រេងឥន្ធនៈ ដោយធ្វើការសហប្រតិបត្តិការណ៍ជាមួយ ស្ថាប័នពាក់ព័ន្ធ និងសហការជាមួយអាជ្ញាធរមូលដ្ឋាន។<br>• ត្រូវសហការជាមួយរដ្ឋអំណាចមូលដ្ឋាន ដើម្បីទប់ស្កាត់រាល់អំពើភេរវកម្មក្នុង តំបន់គម្រោងឱ្យទាន់ពេលវេលា។<br>• បណ្តាញព័ត៌មានរបស់ក្រុមហ៊ុនត្រូវធ្វើការជូនដំណឹងរាល់ហេតុការណ៍កើតឡើងដោយសារហានិភ័យបង្កឡើងដោយគ្រោះ ធម្មជាតិទាំងនោះជាបន្ទាន់ទៅដល់ បុគ្គលិកកម្មករក៏ដូចប្រជាពលរដ្ឋនៅក្បែរគម្រោងនោះឱ្យទាន់ពេលវេលា។<br>• ត្រូវរៀបចំបំរុងទុកនូវយានយន្តសង្គ្រោះ សម្ភារ និងថវិកាដើម្បីធានាការសង្គ្រោះ ជាបន្ទាន់នូវហេតុការខាងលើ នេះទាន់សភាពការណ៍ និងមានប្រសិទ្ធិភាពខ្ពស់។ | |
| **២. ដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោង** (Project Operation & Maintenance | | | | | | |
| ក. ធនធានរូបសាស្ត្រ | | | | | | |
| ចំពោះចំណុច ក.១ សណ្ឋានដី និងឋានលេខ, ក.២ ប្រព័ន្ធជលសាស្ត្រ, **មិនមានការប៉ះពាល់ទេក្នុងដំណាក់កាលនេះ ពីព្រោះ ប្រព័ន្ធខ្សែបញ្ជូនអគ្គិសនី ទាំងនេះត្រូវបានសាងសង់រួចរាល់ហើយ។** | | | | | | |
| ក.៣ ការហូរច្រោះ និងគុណភាពដី | • អាចមានការហូរច្រោះ នាំឱ្យខូចគុណភាពដី នៅតាមទីជម្រាលចើងទេរ នៃជញ្ជាំងភ្នំ ឬដីទួលតាមដងផ្លូវចូលសាងសង់បង្គោលអគ្គិសនី ហើយផ្លូវ នេះប្រើប្រាស់សម្រាប់ការថែទាំគម្រោង។ ការបាក់ដីនៅតាមកន្លែងទាំង នេះដោយសារទឹកភ្លៀងខ្លាំង ធ្វើឱ្យស្ទះផ្លូវ ឬបាត់បង់ដីជាតិដីនៅតំបន់ នេះដោយសារដីនេះគ្របពីលើ។<br>• អាចនឹងមានការបំពុលដីដោយសារការលេចធ្លាយ ឬកំពប់ប្រេងគ្រប់ | | ✓ | | • ត្រូវមានអ្នកត្រួតពិនិត្យជាប្រចាំ នៅតាមផ្លូវចូលទៅបង្គោលអគ្គិសនី ជាពិសេស នៅតាមជញ្ជាំងភ្នំខ្ពស់ៗ ប្រសិនបើមានការបាក់ ត្រូវកាយដីនោះចេញជា បន្ទាន់រួចយកទៅចាក់នៅកន្លែងមានសុវត្ថិភាព មិនប៉ះពាល់ដល់បរិស្ថាន ហើយត្រូវដាំស្មៅ នៅកន្លែងបាក់នេះឡើងវិញ ដើម្បីការពារការហូរច្រោះ ទៀត។<br>• ត្រូវធ្វើការគ្រប់គ្រងសំណល់រឹង-រាវគ្រប់ប្រភេទឱ្យបានល្អ មិនចោលពាសវាលពាសកាល ដោយមានកន្លែងទុកដាក់ត្រឹមត្រូវ។ ត្រូវធ្វើការប្រមូលសំណល់រឹង-រាវគ្រប់ប្រភេទចេញពី | |

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | ប្រភេទ ឬសំណល់រឹង-រាវគ្រប់ប្រភេទ ដែលក្រុមហ៊ុនយកមកដំណើរការថែទាំគម្រោងនេះ។ | | | | ទីតាំងការដ្ឋាននានាកន្លែង ស្នាក់នៅរបស់បុគ្គលិក-កម្មករ ដែលបានមកបោះទីតាំងក្នុងពេលសាងសង់គម្រោងឱ្យបានស្អាត។ | |
| ក.៤ ការរញ្ជួយដី មិនអាចប៉ះពាល់ដល់ចំណុចនេះទេ ពីព្រោះការដឹកសម្ភារធុនធំៗ និងការប្រើគ្រឿងផ្ទុះមិនមានទៀតទេ។ | | | | | | |
| ក.៥ គុណភាពទឹក (លើដី និងក្រោមដី ) | • អាចនឹងប៉ះពាល់គុណភាពទឹកលើដី និងក្រោមដី ដោយសារការប្រើប្រាស់សារធាតុគីមី ដើម្បីបង្អាក់ការលូតលាស់របស់ដើមឈើក្នុងពេល ដំណើរការគម្រោងនេះ។<br>• អាចនឹងមានការបំពុលទឹកដោយសារការលេចធ្លាយ ឬកំពប់ប្រេងគ្រប់ប្រភេទ ដែលក្រុមហ៊ុនយកមកដំណើរការថែទាំ គម្រោងនេះរួចហូរចូលទៅក្នុងប្រភពទឹកធម្មជាតិក្បែរនោះ។ | | ✓ | | • មិនត្រូវប្រើប្រាស់សារធាតុគីមីដើម្បីសំអាត ឬបង្អាក់ការលូតលាស់របស់ ដើមឈើនោះទេ។<br>• ត្រូវសាងសង់សំណង់រណ្តៅបេតុងពីក្រោមគ្រង់ស្តូរ ការពារការលេចធ្លាយ ឬកំពប់ប្រេង ដែលប្រើសម្រាប់គ្រង់ស្តូរ ទាំងនោះ។ ចំពោះប្រេងដែលចាស់ៗ ឬប្រេងដែលមាននៅក្នុងរណ្តៅ ក្រុមហ៊ុននឹងយកទៅលក់ ឱ្យសិប្បកម្មកែច្នៃ ប្រេងខ្មៅ (ប្រេង ដែលប្តូរពីម៉ាស៊ីនភ្លើង ឬគ្រឿងយន្ត) ក្នុងស្រុកធ្វើជា គ្រឿង ចំហេះផ្សេងៗ។<br>• ត្រូវធ្វើការគ្រប់គ្រងយានយន្តគ្រប់ប្រភេទមិនឱ្យលេចធ្លាយប្រេង ដែលជា ហេតុនាំឱ្យមានការបំពុលទឹកនេះទេ។ | |
| ក.៦ គុណភាពខ្យល់ | • អាចមានការបំពុលខ្យល់ដោយសារ ក្លិនមិនល្អចេញពីសំណល់រឹង-រាវ សំណល់ពីផ្ទះបាយ ឃ្លាំងស្តុកប្រេង កន្លែងបង្គន់ កន្លែងបង្ហូរទឹកសំអុយ ចោលជាដើម។ | ✓ | | | • ត្រូវមានអ្នកត្រួតពិនិត្យជាប្រចាំនៅតាមទីតាំងដាក់សម្រាម កន្លែងបង្ហូរសំណល់ រាវពីបង្គន់ ពីបន្ទប់ទឹកដោយជៀជាកថាសំណល់រឹង-រាវទាំងអស់នោះត្រូវបាន ទុកដាក់ត្រឹមត្រូវមិនមានជះក្លិនមិនល្អនោះទេ។ ប្រសិនបើអាងសិបទិក បាត់បង់សមត្ថភាព ឬពេញត្រូវធ្វើការជួសជុល និងបូមសំអាតជាបន្ទាន់។ | |
| ក.៧ គុណភាពដី ចំណុចនេះមានដូច ចំណុច ក.៣ ដែរ ហើយវិធានការកាត់បន្ថយ ក៏មានដូចគ្នាផងដែរ។ | | | | | | |
| ក.៨ សំឡេងនិងរំញ័រ គ្មានការបំពុលដោយសំឡេងនិង រំញ័រទៀតទេក្នុងដំណាក់កាលនេះ។ | | | | | | |
| ខ. ធនធានជីវសាស្ត្រ | | | | | | |
| ខ.១ ជីវសាស្ត្ររស់នៅក្នុងទឹក/ មច្ឆជាតិ ដំណាក់កាលនេះមិនមានការប៉ះពាល់ធនធាននេះទេ។ | | | | | | |
| ខ.២ព្រៃឈើការពារ/តំបន់ការពារ/ឧទ្យានជាតិ | • អាចប៉ះពាល់ដល់តំបន់ព្រៃការពារ សង្កាត់រដ្ឋបាលព្រៃឈើប្រមោយ ដោយសារមានការ ទន្ទ្រានកាន់ព្រៃយកដីធ្វើកម្មសិទ្ធិខុសច្បាប់ព្រោះ មានផ្លូវចេញចូលក្នុងតំបន់ ស្រួលពីសំណាក់ជន ឆ្លៀតឱកាសមួយចំនួន។ | | | ✓ | • ធ្វើការសហការជាមួយអាជ្ញាធរ និងរដ្ឋបាលព្រៃឈើថែទាំស្លាកប៉ាន់ណូ ដែល បានដំឡើងនេះជាប្រចាំ ដើម្បីឱ្យជនឱកាសនិយមទាំងនោះបានឃើញបើ ល្មើស នឹងត្រូវជាប់គុករហូតដល់១០ឆ្នាំ។ នៅតាមបង្គោលអគ្គិសនី២៣០គ.វ៉នីមួយៗ ក៏ត្រូវដាក់ស្លាកនេះដែរ។ ក្រុមហ៊ុនមានកញ្ចប់ថវិកាចំនួន ២៥.០០០ដុល្លារអាមេរិកសម្រាប់ការអប់រំផ្សព្វផ្សាយបរិស្ថាន។ | |
| ខ.៣ ធនធានព្រៃឈើ និងជម្រកសត្វព្រៃ | • អាចនឹងប៉ះពាល់ដល់ធនធានព្រៃឈើ ដែលជាជម្រកសត្វព្រៃច្រើនប្រភេទដូចមានចែង ក្នុងជំពូក៥ចំណុច ៥.១.២.១ ដោយសកម្មភាព | | ✓ | | • ការកាប់សំអាតមែក ឬដើមឈើនេះ គឺនឹងកាប់តែក្នុងទំហំនៃចំណីគន្លងខ្សែ អគ្គិសនី(ម្ខាង ១៥ម សរុប៣០ម) តែប៉ុណ្ណោះ ហើយនឹងសហការថែរក្សាព្រៃឈើ សងខាងចំណីគន្លងខ្សែ | |



Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | កាប់សំអាតមែក ឬដើមឈើតាមគន្លងខ្សែអគ្គិសនីនេះ ដោយមិន ឱ្យខ្ពស់ជាង៣ម។<br>• អាចកើតមានឡើង ភ្លើងឆេះព្រៃក្បែរតំបន់គម្រោង ដោយសារការទុស្សេខ្សែអគ្គិសនី ឬធ្លាក់ផ្កាភ្លើង (មែកឈើជះ លូតទៅប៉ះដែនរបស់ខ្សែអគ្គិសនីនាវដូវប្រាំងស្ងួត) ទៅលើព្រៃឈើនិងបណ្តាលឱ្យមានការឆេះព្រៃកើតឡើង។ | | | | អគ្គិសនីនេះ ជាមួយមន្រ្តីជំនាញព្រៃឈើឱ្យបាន ល្អប្រសើរ។<br>• ការថែទាំ និងកាប់សំអាតមែក ឬដើមឈើក្រោមគន្លងខ្សែអគ្គិសនីនេះ គឺធ្វើតែ ពេលថ្ងៃតែប៉ុណ្ណោះ ជៀសវាងការរំខានដល់សត្វព្រៃ ពីព្រោះនៅពេលយប់ សត្វព្រៃភាគច្រើនរកស៊ី និងមួយចំនួនទៀតដេកនៅព្រៃក្បែរៗតំបន់ខ្លះនៃគម្រោង នេះ។<br>• ធ្វើការអប់រំ និងហាមឃាត់ដល់បុគ្គលិក-កម្មកររបស់គម្រោងមិនឱ្យទន្រ្ទាន ចូលព្រៃ ធ្វើការបរបាញ់ ឬដាក់អន្ទាក់ ឬជួញដូរសត្វព្រៃនោះឡើយ។<br>• ត្រូវដាក់ពិន័យដល់បុគ្គលិក-កម្មករណាដែលប្រព្រឹត្តល្មើសនឹងការហាមឃាត់ ខាងលើ។<br>• ត្រូវធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន និងរដ្ឋអំណាច មូលដ្ឋានដើម្បីកាត់បន្ថយហេតុប៉ះពាល់ បរិស្ថានអវិជ្ជមាន ដែលកើតឡើងជាយថា ហេតុនៅក្នុងតំបន់គម្រោង។<br>• ត្រូវរៀបចំប្រព័ន្ធផ្តល់ព័ត៌មាន នៅតាមចំណុចសំខាន់មួយចំនួន ដែលមានបុគ្គលិក ព័ត៌មានគម្រោង មន្រ្តីជំនាញពាក់ព័ន្ធ និងរដ្ឋអំណាចមូលដ្ឋាន សហការគ្នាទប់ ស្កាត់ ភ្លើងឆេះព្រៃ និងមានប្រព័ន្ធផ្តាច់ចរន្តអគ្គិសនីស្វ័យប្រវត្តិ នៅពេលមាន ហេតុការណ៍ទុស្សេខ្សែអគ្គិសនី និងភ្លើងឆេះព្រៃកើតឡើង។ | |
| ខ.៤ ជីវសាស្រ្តសត្វព្រៃ | • ការទន្រ្ទានចូលព្រៃធ្វើការបរបាញ់ ដាក់អន្ទាក់ និងចាប់សត្វពីសំណាក់បុគ្គលិក-កម្មករ ដែលធ្វើប្រតិបត្តិការ និងថែទាំគម្រោង និងអ្នកក្រៅ ធ្វើឱ្យបាត់បង់សត្វព្រៃក្នុងតំបន់គម្រោងគួរឱ្យព្រួយបារម្ភ។<br>• អាចមានការឆក់ដល់បនុស្ស-សត្វ ជាពិសេសពពួកសត្វស្វា និងទោច ដោយសារសត្វនេះចូលចិត្តឡើងបង្គោលអគ្គិសនី។ | | | ✓ | • ត្រូវហាមឃាត់ដាច់ខាតដល់បុគ្គលិក-កម្មករ របស់ខ្លួនក្នុងការប្រមាញ់ ឬជួញដូរសត្វព្រៃនៅក្នុង និងក្បែរខាង តំបន់គម្រោង។<br>• ត្រូវធ្វើការអប់រំ និងដាក់វិន័យដល់បុគ្គលិក-កម្មករគម្រោងមិនឱ្យធ្វើការចាប់ ឬបរបាញ់សត្វព្រៃ និងធ្វើចរាចរលក់ដូរសត្វព្រៃនៅក្នុងតំបន់នេះឡើយ។<br>• ត្រូវសង់គ្រឿងការពារមនុស្ស-សត្វទៅនឹងបង្គោលទាំងបួនដើម្បីការពារកុំ ឱ្យមនុស្ស-សត្វឡើងបាន។ | |
| គ. ធនធានសេដ្ឋកិច្ចសង្គម | | | | | | |
| គ.១ ការប្រើប្រាស់ដី និងការតាំងលំនៅឋានដ្ឋាន ឡើងវិញ | • អាចមានការទន្រ្ទានកាន់កាប់ដីពីអ្នកមកពីខាងក្រៅ និងជនឱកាសនិយមប្រើមធ្យោបាយគ្រប់រូបភាព ដើម្បីចាប់យកដីនៃតំបន់ព្រៃការពារនេះគួរឱ្យព្រួយបារម្ភ ពីព្រោះគម្រោងមានផ្លូវចេញចូលស្រួល បច្ចុប្បន្នគ្មានផ្ទះប្រជាជនរស់នៅ ក្រោមគន្លងនៃខ្សែនេះទេ (ខ្សែ ២៣០គ.វ៉ មិនទាន់បានសាងសង់នៅឡើយ ការសិក្សាយកតាមចំណុចយាម កាដែលចែងក្នុងជំពូក៤ចំណុច៤.៣) ដូចបានរៀបរាប់ខាងលើរួច មកហើយ។ ហេតុដូច្នេះ ហើយក្រោយពីការសង់គម្រោងនេះរួចនឹង មានការសង់លំនៅដ្ឋាន និងសំណង់ផ្សេងៗទៀតនៅក្រោមគន្លងនេះ មិនខានឡើយ ដែលធ្វើឱ្យក្រុមហ៊ុន និងអាជ្ញាធរមូល | | | ✓ | • ត្រូវដាក់ស្លាកតំបន់ដីចំណីគន្លងខ្សែ២៣០គ.វ៉នេះ នៅតាមបង្គោលអគ្គិសនីនៅ ចន្លោះរៀងរាល់២បង្គោលម្តង នៃខ្សែ២៣០គ.វ៉នេះ ដើម្បីឱ្យប្រជាជនបានដឹង និងឃើញ ដូចក្រសួងសាធារណការ ដែលបានដាក់តាមផ្លូវជាតិនានា។ សម្គាល់: ក្នុងពេលចុះសិក្សាផលប៉ះពាល់តាមគន្លងខ្សែនេះ ក្រុមការងារ SAWACបានធ្វើ ការជូនដំណឹង និងពន្យល់ដល់អ្នកភូមិពាក់ព័ន្ធអំពីចំណីគន្លងខ្សែនេះ និងអំពីសុវត្ថិភាព មិនឱ្យមានការសាងសង់សំណង់ផ្សេងដែលមានកម្ពស់ខ្ពស់ជាង ៣ម ក្រោមគន្លងខ្សែនេះផងដែរ។ | |



Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | ដ្ឋានពិបាក ដោះស្រាយ ពីព្រោះកម្ពស់ខ្នងថ្នាល់ដី យ៉ាងហោចណាស់ក៏សរសរដំបូល មានកម្ពស់ពី៣,៥ម ទៅ៤មដែរ លើសពីនេះអ្នកស្រុកទាំងនេះ មានដំឡើងអង់តែន ឬលើកបង្គោលផ្សេងៗ ដែលមានកម្ពស់ខ្ពស់ ជា៣ម ដែលនឹងធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពរបស់ពួកគេ។ | | | | | |
| គ.២ ការរស់នៅ និងមុខរបររបស់សហគមន៍មូលដ្ឋាន មិនប៉ះពាល់ដល់មុខរបរប្រជាពលរដ្ឋទេក្នុងដំណាក់កាលនេះ។ | | | | | | |
| គ.៣ ប្រពៃណី វប្បធម៌ និងសាសនា | • អាចនឹងប៉ះពាល់ដល់ទំនៀមទំលាប់ប្រពៃប្រណីរបស់ប្រជាពលរដ្ឋ ដែល រស់នៅក្បែរតំបន់គម្រោង ដោយសារក្រុមហ៊ុននាំយកបុគ្គលិក-កម្មករ គម្រោងមកពីតំបន់ផ្សេងទៀត ឬជនបរទេស។ | ✓ | | | • ត្រូវធ្វើការណែនាំអប់រំដល់បុគ្គលិក-កម្មកររបស់គម្រោង ឱ្យមានការគោរព ទំនៀមទំលាប់ប្រពៃណី និងជំនឿរបស់ប្រជាពលរដ្ឋរស់នៅជុំវិញក្នុងតំបន់ ទីតាំងគម្រោង។<br>• ត្រូវដាក់វិន័យដល់បុគ្គលិក-កម្មករគម្រោង ដែលបំពានលើទំនៀមទំលាប់ប្រពៃ ណីវប្បធម៌ និងជំនឿសាសនារបស់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសប្រជាពលរដ្ឋ ដែលរស់ក្បែរតំបន់គម្រោងដូចជា ភូមិស្ទឹងថ្មីទាំងមូលដើម។ | |
| គ.៤ ប្រពន្ធ័ផ្គត់ផ្គង់ទឹក ស្អាត | • អាចនឹងមានការប៉ះពាល់ដល់ការប្រើប្រាស់ទឹករបស់បុគ្គលិក-កម្មករគម្រោង ដោយនៅតំបន់គម្រោងពុំទាន់មានប្រពន្ធ័ផ្គត់ផ្គង់ទឹកស្អាតទេ។<br>• ការគ្រប់គ្រងសំណល់រាវ ដែលចេញពីបង្គន់ បន្ទប់ទឹក ផ្ទះបាយ ការបន្ទោរបង់ក្នុងប្រភពទឹកធម្មជាតិ ឃ្លាំងស្តុក សម្ភារ រោងជាងជាដើម ដែលធ្វើឱ្យខូចដល់ប្រភពទឹកសម្រាប់ផ្គត់ផ្គង់ក្នុងតំបន់។ | | ✓ | | • ត្រូវរៀបចំប្រព័ន្ធទឹកស្អាតសម្រាប់ផ្គត់ផ្គង់ទឹកស្អាតក្នុងការប្រើប្រាស់របស់បុគ្គលិក-កម្មករឱ្យមានលក្ខណៈល្អ ប្រសើរ។<br>• នៅអនុស្ថានីយពោធិ៍សាត់ក្រុមហ៊ុនត្រូវសាងសង់អាងសិបទិកទំនើប និងថៃ ទាំងជាប្រចាំសម្រាប់សំរាតសំណល់រាវ ឬទឹកកខ្វក់ ដែលចេញពីបង្គន់ បន្ទប់ទឹក ផ្ទះបាយ ឃ្លាំងសម្ភារ ដើម្បីរក្សាគុណភាពទឹកលើដី និងក្រោមដី ជុំវិញតំបន់នោះ។<br>• អប់រំណែនាំបុគ្គលិក-កម្មករគម្រោង ឱ្យយល់ដឹងអំពីអនាម័យមិនឱ្យមានការ បន្ទោរបង់ក្នុងប្រភពទឹកធម្មជាតិ ឬសាធារណៈឡើយស្គាល់នូវកន្លែងទុកដាក់ សម្រាម ដែលក្រុមហ៊ុនបានរៀបចំកសាងក្នុងទីតាំងស្នាក់នៅ ហើយដាក់ពិន័យ ដល់បុគ្គលិក-កម្មករណា ដែលមិនព្រមធ្វើតាមការណែនាំ។<br>• ត្រូវចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងសំណល់រឹង-រាវ ដោយ សាងសង់បង្គន់អនាម័យព្រមទាំង រៀបចំប្រមូលសំណល់រឹង និងសម្រាមយក ទៅចោល នៅទីតាំងដែលមានសុវត្ថិភាព។<br>• ត្រូវធ្វើការសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ដើម្បីកែ ប្រែតំបន់គម្រោងឱ្យមានអនាម័យ និងបរិស្ថានល្អ។ | |
| គ.៥ តំបន់ទេសចរណ៍/ រមណីយដ្ឋាន/ ទីកន្លែង កំសាន្ត | • អាចនឹងមានការប៉ះពាល់ដល់តំបន់នេះ ដែលជាតំបន់ទេសចរណ៍-បរិស្ថាន ឬអេកូ-ទេសចរណ៍ ដោយសារការប្រមូលសំណល់រឹង-រាវគ្រប់ប្រភេទ ដូចជា សំបកកង់ឡាន ស្បោងប្លាស្ទិក ក្រណាត់ សំបកជ័រគ្រប់ប្រភេទ មិនបានស្អាតតាមការដ្ឋានសាងសង់ បង្គោលនៅ | | ✓ | | • ត្រូវធ្វើការប្រមូលសម្រាម សំណល់រឹង-រាវទាំងអស់នោះឱ្យបានស្អាតពីទីតាំង ដូចបានរៀបរាប់ខាងលើរួចសំនល់ នេះត្រូវដឹកយកទៅដាក់ក្នុងរណ្តៅសុវត្ថិភាព (ឆ្ងាយពីប្រភពទឹក) រួចកប់វាឱ្យបានត្រឹមត្រូវ។ ចំណែកឯការដ្ឋាន ឬ ទីតាំងបោះជំរុំស្នាក់នៅបណ្តោះអាសន្ន និងទីតាំងផ្សេងៗទៀត របស់អ្នកម៉ៅ ការបន្ត ក្រុមហ៊ុនក៏ត្រូវទទួលខុសត្រូវក្នុងការ | |

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | តាមទីតាំងបោះជំរុំស្នាក់នៅបណ្ដោះអាសន្ន កន្លែងបង្គន់ បន្ទប់ទឹក ផ្ទះបាយ ឃ្លាំងស្តុកសម្ភារ រោងជាងជាដើម ដែលធ្វើឱ្យកខ្វក់តំបន់នេះ។ | | | | សំអាតផងដែរ។ | |
| គ.៦ ផ្លូវគមនាគមន៍ | • ការកកស្ទះចរាចរណ៍លើដងផ្លូវ និងបង្កឱ្យមានគ្រោះថ្នាក់ ដោយសារសកម្មភាពថែទាំគម្រោង និងការធ្វេសប្រហែសក្នុងការបើកបររបស់បុគ្គលិក -កម្មករគម្រោង។<br>• អាចនឹងធ្វើឱ្យមានការខូចខាតផ្លូវដោយសារការថែទាំគន្លងខ្សែអគ្គិសនីនេះ។ | | ✓ | | • ត្រូវធ្វើការសហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីសម្រួលចរាចរណ៍នៅពេល ដែលមានការថែទាំគន្លងខ្សែម្ដងៗ។<br>• ត្រូវធ្វើការថែទាំជួសជុលផ្លូវ ឬពង្រីកផ្លូវដើម្បីធានាសុវត្ថិភាព និងសម្រួលចរាចរ ក្នុងតំបន់គម្រោងឱ្យបានល្អប្រសើរ។<br>• ត្រូវជ្រើសរើសអ្នកបើកបរអាជីពដែលមានបទពិសោធន៍ និងមានស្មារតីល្អ។ | |
| គ.៧ សុខភាពសាធារណៈ | • អាចបង្កឱ្យមានការប៉ះពាល់ដល់សុខុមាលភាព របស់ប្រជាពលរដ្ឋក្នុងតំបន់នេះ ដោយសារបុគ្គលិក-កម្មកររបស់ក្រុមហ៊ុនអាចចម្លង ជំងឺផ្សេងៗដល់អ្នកភូមិ ដូចជាជំងឺអេដស៍ ជំងឺកាមរោគ។ល។<br>• អាចមានការប៉ះពាល់ដល់សុខភាពសាធារណៈ ដោយសារការគ្រប់គ្រងសំណល់រឹង-រាវមិនបានល្អ។<br>• អាចមានគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស នៅធ្វើដំណើរកាត់តាមគន្លង ខ្សែបញ្ជូនអគ្គិសនី២៣០kV នេះដោយសារការរងឥទ្ធិពលដែនអគ្គិសនីភ្លូច អាំងឌុចស្យុងអេឡិកត្រូស្តាទិក និងអេឡិកត្រូម៉ាញេទិកនៅតាម គន្លងខ្សែ៥គ.ម ឬឆ្លងចរន្តតាមដើមឈើដែលមានមែកវាទោទៅ ប៉ះចូលក្នុងដែនអគ្គិសនីទាំងនេះ។ | | | ✓ | • ធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិក-កម្មករ ដើម្បីទប់ស្កាត់ជំងឺអេដស៍ និងជំងឺកាមរោគកុំឱ្យកើតមាននិងឆ្លងទៅប្រជាពលរដ្ឋក្បែរតំបន់គម្រោងនេះ<br>• ត្រូវធ្វើការពិនិត្យតាមដានគុណភាពទឹកស៊ំអុយ ដែលបញ្ចេញពីការិយាល័យ ឃ្លាំងសម្ភារ និងកន្លែងស្នាក់នៅរបស់បុគ្គលិក-កម្មករជាប្រចាំ ប្រសិនបើគុណភាពទឹក ដែលបញ្ចេញទៅក្រៅនេះមានការបំពុល ក្រុមហ៊ុននឹងវិធានការធ្លោបាយ ដើម្បី ធ្វើការកាត់បន្ថយដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ។<br>• ត្រូវធ្វើការសហការជាមួយស្ថាប័នសុខាភិបាល ដើម្បីទប់ស្កាត់ជំងឺឆ្លង ដែល កើតឡើងជាយថាហេតុ។<br>• ត្រូវគ្រប់គ្រងសំណល់ រឹង-រាវឱ្យបានល្អ តាមបទដ្ឋានបច្ចេកទេស។<br>• ត្រូវត្រួតពិនិត្យស្ថានភាពខ្សែអគ្គិសនី ជាពិសេសចំណុចខ្សែដក់មកដីមានកម្ពស់ ៩មយ៉ាងតិចនិងកន្លែងខ្សែឆ្លងកាត់ផ្លូវ១៥ម យ៉ាងតិចនៅពេលមានអាកាស ធាតុមិនល្អកើតឡើងម្ដងៗ ហើយត្រូវសំអាតដើមឈើជាប្រាំដោយមិនឱ្យវា លូតលើសពី កម្ពស់៣មឡើយ។<br>• ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈអំពីគ្រោះថ្នាក់ ដែលបណ្ដាលមកពីការរស់ នៅក្រោម ឬលើកបង្គោលលោហៈ ក្នុងចំណីខ្សែអគ្គិសនី ឬឡើងបង្គោលអគ្គិសនី និងហាមឃាត់ដាច់ខាត នូវទង្វើខាងលើ។ | |
| គ.៨ សោភ័ណ្ឌភាព/ទេសភាព | • អាចនឹងមានការប៉ះពាល់ដល់តំបន់នេះ ដូចចំណុចគ.៥ដែរ គឺប៉ះពាល់ ដោយសារការប្រមូលសំណល់រឹង-រាវគ្រប់ប្រភេទ ដូចជា សំបកកង់ ឡាន សៀងប្លាស្ទិក ក្រណាត់ សំបកដប គ្រប់ប្រភេទមិនបានស្អាត តាមការដ្ឋានសាងសង់បង្គោល នៅតាមទីតាំងបោះជំរុំស្នាក់នៅ បណ្ដោះអាសន្ន កន្លែងបង្គន់ បន្ទប់ទឹក ផ្ទះបាយ ឃ្លាំងស្តុកសម្ភារ រោងជាងជាដើម ដែលធ្វើឱ្យកខ្វក់តំបន់នេះ ដែលមានទេសភាព ស្អាត។ | | ✓ | | • ត្រូវធ្វើការប្រមូលសម្រាម សំណល់រឹង-រាវទាំងអស់នោះឱ្យបានស្អាតពីទីតាំង និងត្រូវដឹកយកទៅដាក់ក្នុងរណ្ដៅសុវត្ថិភាព (ឆ្ងាយពីប្រភពទឹក) រួចកប់វា ឱ្យបានត្រឹមត្រូវ។ ចំណែកងការដ្ឋាន ឬទីតាំងបោះជំរុំស្នាក់នៅបណ្ដោះ អាសន្ន និងទីតាំងផ្សេងៗទៀត របស់អ្នកម៉ៅការបន្ត ក្រុមហ៊ុនក៏ត្រូវទទួល ខុសត្រូវក្នុងការសំអាតផងដែរ។ | |

Draft

| ធនធានបរិស្ថាន | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| ធ.៩ ហានិភ័យ | • ដោយសារគ្រោះធម្មជាតិ ការធ្វេសប្រហែសផ្នែកសន្តិសុខ និងអំពើភេរវកម្ម ឬសង្គ្រាម។<br>• ការកើតមានការរញ្ជួយដី នៅក្នុងតំបន់គម្រោង ការទទួលរងឥទ្ធិពលពីព្យុះភ្លៀងទឹកហ្វ ឬព្យុះផ្សេងទៀត អាចបង្កឱ្យ មានមហន្តរាយធំៗ ដូចជាការបាក់រលំបង្គោល ដាច់ខ្សែ និងការខូច ប្រព័ន្ធខ្សែអគ្គិសនីសំខាន់ៗរបស់គម្រោង ជាពិសេសការធ្វើឱ្យរងរបួស និងស្លាប់ បាត់បង់ជីវិតដល់បុគ្គលិក-កម្មករ និងប្រជាពលរដ្ឋនៅក្នុង និងក្បែរខាងតំបន់គម្រោង។<br>• ការឆេះព្រៃក្នុងតំបន់គម្រោង ដែលបណ្តាលមកពីការធ្វេសប្រហែស បច្ចេកទេស ឬទុស្សេខ្សែអគ្គិសនី ឬអំពើភេរវកម្មក៏អាច បង្កឱ្យមានមហន្តរាយ/គ្រោះថ្នាក់ធំដល់ប្រព័ន្ធខ្សែអគ្គិសនីសំខាន់ៗរបស់គម្រោង ធនធានធម្មជាតិក្នុងតំបន់ និងអាយុជីវិតមនុស្សទៀតផង។<br>• ការកើតមានសង្គ្រាមឈ្លានពានលើបូរណភាពទឹកដីនៃប្រទេសកម្ពុជា និងសង្គ្រាមផ្ទៃក្នុងក៏ជាឧបសគ្គដល់កិច្ចដំណើរការ និងថែទាំ គម្រោងផងដែរជួនកាលសង្គ្រាមអាចបំផ្លាញគម្រោងទាំងស្រុងតែម្តង។ | | | ✓ | • មានផែនការត្រួតពិនិត្យ និងប្រមូលព័ត៌មានជាប្រចាំ ដើម្បីថែទាំប្រព័ន្ធខ្សែអគ្គិសនី ឱ្យបានគង់វង្ស និងសុវត្ថិភាព។<br>• ត្រូវបំពាក់ប្រពន្ធ័ផ្តាច់អគ្គិសនីដោយស្វ័យប្រវត្តិ ដើម្បីផ្តាច់ចរន្តអគ្គិសនីឱ្យទាន់ពេល វេលាការពារអាយុជីវិតមនុស្ស-សត្វ។<br>• ត្រូវប្រុងប្រយ័ត្នគ្រប់វិនាទីក្នុងការការពារសន្តិសុខ ចំពោះគ្រឿងអាចផ្ទុះនានា អគ្គិភ័យនានា និងធ្វើសហប្រតិបត្តិការណ៍ ជាមួយស្ថាប័នមាន សមត្ថកិច្ចដើម្បី ទប់ស្កាត់រាល់អំពើភេរវកម្មក្នុងតំបន់គម្រោង។<br>• ធ្វើការផ្សព្វផ្សាយរាល់ហេតុការណ៍ ដែលអាចបង្កដល់ការបាក់រលំបង្គោលអគ្គិសនី ការដាច់ខ្សែ ដោយសារគ្រោះធម្មជាតិ ដល់ បុគ្គលិក-កម្មករគម្រោង និងប្រជាពលរដ្ឋ ដែលត្រូវឆ្លងកាត់តាមគន្លងខ្សែអគ្គិសនីនេះ ឱ្យបានជ្រាបហេតុការណ៍ខាងលើ បានទាន់ពេលវេលាតាមតែអាចធ្វើទៅបាន បើសិនជាមានហានិភ័យបែបនេះ កើតឡើង។<br>• រៀបចំបំរុងទុកនូវក្រុមអ្នកជួយសង្គ្រោះសម្ភារ និងថវិកា ដើម្បីធានាការ ដោះស្រាយផលប៉ះពាល់ ដែលនឹងអាចកើតពីមហន្តរាយខាងលើនេះបាន ទាន់សភាពការណ៍ និងមានប្រសិទ្ធិភាព។ | |

៣. ដំណាក់កាលបិទគម្រោង (**Project Closure**)

ក្នុងដំណាក់កាលបិទគម្រោងរបស់ក្រុមហ៊ុនរបស់ប្រទេសកូរ៉េ នឹងធ្វើឡើងក្រោយពីចប់កិច្ចសន្យាជាមួយរាជរដ្ឋាភិបាលកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា នឹងទទួលបន្តធ្វើការគ្រប់គ្រងបន្ត ដូចនេះសកម្មភាពបិទគម្រោង អាស្រ័យ ទៅនឹងរដ្ឋាភិបាលកម្ពុជាសម្រេចខ្លួនឯងហើយសង្ឃឹមថាក្នុងដំណាក់កាលបិទគម្រោងរបស់ក្រុមហ៊ុនចិននេះពុំមានការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ដែលគួរឱ្យកត់សម្គាល់ឡើយ។ (ចំពោះបទដ្ឋានបច្ចេកទេស និងគុណភាពរបស់ប្រព័ន្ធខ្សែ អគ្គិសនីនេះ និងត្រូវប្រគល់ជូនរាជរដ្ឋាភិបាលវិញ មានចែងលម្អិតក្នុងកិច្ចសន្យារួចអស់ហើយ)។

ក្រុមហ៊ុនត្រូវធ្វើការសំអាតសំណល់រឹង-រាវគ្រប់ប្រភេទចេញពីទីតាំង សំណង់ហេដ្ឋារចនាសម្ព័ន្ធគម្រោងវារីអគ្គិសនីនេះ ទាំងអស់កន្លែងការិយាល័យ កន្លែងស្នាក់នៅ ឃ្លាំង រោងជាង ចំណតរថយន្ត ជាពិសេសនៅកន្លែងចាក់ សម្រាម និងកន្លែងបង្គន់ទឹកស្អុយ។

## ៧.៩ បណ្តុំនៃហេតុប៉ះពាល់អវិជ្ជមាន

ស្ទឹងពោធិ៍សាត់មានប្រវែងសរុប ២៤៩គម គិតចាប់ពីស្ទឹងឫស្សីនៅផ្នែកខាងលើ ដល់បឹងទន្លេសាប (វាស់តាមផែនទី)។ បើគិតពីទីតាំងទំនប់វារីអគ្គិសនីនេះដល់បឹងទន្លេសាបស្ទឹងនេះមានប្រវែង១៦៣គ.ម។ យោងតាមការសិក្សា ខែកញ្ញា ឆ្នាំ២០១៥ នៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនេះ របស់គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ នៅស្រុកវាលវែងនេះបង្ហាញថា នៅតាមផ្ទៃរងទឹកភ្លៀងនៃទឹកនេះ មានគម្រោង ធារាសាស្រ្ត រាប់ពីខ្សែទឹកខាងលើទៅខ្សែទឹកខាងក្រោម ដូចជា ប្រព័ន្ធធារាសាស្រ្តដំណាក់ឈើក្រំ (សាងសង់ ឆ្នាំ២០១៧) ប្រព័ន្ធធារាសាស្រ្តដំណាក់អំពិល ប្រព័ន្ធធារាសាស្រ្តចារិក និងនៅតាមដៃស្ទឹងពោធិ៍សាត់ ក្នុងស្រុកក្រវាញ មានទំនប់៣ និងទំនប់៥ ផងដែរ។ ការធ្វើបារ៉ាស់ ឬសំណង់បញ្ចាល់ទឹកស្ទឹង ចូលប្រឡាយមេ និងទំនប់ទឹកបម្រុងទឹកទុក ដើម្បីស្រោចស្រពដីកសិកម្ម ក្នុងខេត្តពោធិ៍សាត់ និងបាត់ដំបង នោះ នាំឱ្យមានការបន្តុំការប៉ះពាល់ដូចតទៅ:

ក. ជលសាស្រ្ត

របបទឹកស្ទឹងពោធិ៍សាត់គឺទាក់ទងទៅនិងទឹកភ្លៀង ដែលធ្លាក់ក្នុងតំបន់ផ្ទៃរងទឹកភ្លៀងរបស់វា ដូចនេះការទប់ធ្វើវារីអគ្គិសនី ការបញ្ចាល់ទឹក យកទឹកចែកចាយ ដើម្បីស្រោចស្រពដីកសិកម្ម មានការប្រែប្រួលរបបទឹកស្ទឹងនេះ រំពឹងថាមានការប៉ះពាល់អវិជ្ជមានកម្រិតមធ្យម ពីព្រោះ នៅរដូវវស្សា (រដូវភ្លៀងខ្លាំង) នាំឱ្យមានទឹកជំនន់ លិចច្រាំងសងខាង តាមតំបន់មាត់ស្ទឹងនេះ ដល់បឹងទន្លេសាបចំណុចចុងផ្តល់ ចម្ងាយប្រមាណ៣០គ.ម ពីក្រុងពោធិ៍សាត់ ហើយនៅរដូវប្រាំងវិញ ទឹកស្ទឹងពោធិ៍សាត់មានកម្រិតទាប ជួនកាលមិនមានទឹកគ្រប់គ្រាន់ សម្រាប់ផ្គត់ផ្គង់ទឹកស្អាតនៅរដ្ឋករទឹកក្រុងពោធិ៍សាត់ផងដែរ បើគ្មានគម្រោងទាំងនេះទេ (កំឡុងឆ្នាំ ១៩៨០ដល់ ឆ្នាំ២០០២)។

ការសាងសង់ទំនប់ទាំងនោះឡើង ធ្វើមានការប្រែប្រួល របបទឹក នៅតំបន់ខាងក្រោមដូចជា នៅរដូវវស្សា មានទឹកជំនន់ធ្លាប់ហៀរច្រាំង ទៅជាពាបច្រាំង (មិនលិចច្រាំង) ហើយនៅរដូវប្រាំងមានទឹក ច្រើនជាងមិនមានគម្រោងទាំងនេះ ដោយសារការព្រលែងទឹកចុះមកក្រោម ដើម្បីប្រើប្រាស់។

ម្យ៉ាងទៀត មានគម្រោងទាំងនេះបណ្តាលឱ្យ ល្បាប់ខ្សាច់ (ខ្សាច់សម្រាប់សំណង់) ដែលធ្លាប់តែកក នៅក្រុងពោធិ៍សាត់ បាត់បង់ គឺមាននៅ ផ្នែកខាងលើ នៃស្ពានដែកស្រុកក្រវាញ ខាងលើសំណង់ធារាសាស្រ្តដំណាក់អំពិល។ ល្បាប់ខ្សាច់ទាំងនេះ និងមានការថយចុះជាលំដាប់ នៅពេលគម្រោងទាំងអស់ បានសាងសង់ចប់។

ខ. គុណភាពទឹក

គុណភាពទឹកស្ទឹងពោធិ៍សាត់ និងមានការថយចុះ រំពឹងថាមានការប៉ះពាល់អវិជ្ជមានកម្រិតមធ្យម ដោយសារការប្រើប្រាស់ជី និងថ្នាំកសិកម្មមិនបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពីការអភិវឌ្ឍតំបន់ស្រោចស្រព នៃគម្រោងធារាសាស្រ្ត ដំណាក់ឈើក្រំ ដំណាក់អំពិល និងចារីក ដែលស្ថិតនៅខាងក្រោម ទំនប់វារីអគ្គិសនីនេះ។

គ. ធនធានមច្ឆជាតិ

យោងតាមការសិក្សាមច្ឆជាតិ នៅផ្នែកខាងលើពី ចំណុច ប្រសព្វស្ទឹងពោធិ៍សាត់ និងអូរសង្កសី ដល់ព្រំប្រទល់ ស្រុកក្រវាញ ចំណុច ពងពង្ស ខែកញ្ញា ឆ្នាំ២០១២ នៅ ក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ របស់គម្រោងវារីនេះ និងការសិក្សាមច្ឆជាតិ នៅផ្នែកខាងក្រោមពី ចំណុច សំណង់ធារាសាស្រ្តដំណាក់អំពិល ដល់សំណង់ធារាសាស្រ្តចារីក ខែធ្នូ ឆ្នាំ២០១៣ នៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ របស់គម្រោងធ្វើឱ្យប្រសើរឡើងវិញផ្លូវជាតិលេខ៥ (កំណាត់ផ្លូវពីធ្លាម្អមដល់បាត់ដំបង) បានបង្ហាញថា ផ្នែកខាងក្រោម សំណង់ធារាសាស្រ្ត ចារីក មិនមានត្រីខ្យា ត្រីទ្រនែល ត្រីអណ្តែងងាំង ត្រីការមៀបឬត្រីស្នុក ត្រីកាហែលឿង ចំណែកឯ ផ្នែកខាងលើ (ពីអូរសង្កសីដល់ ពងពង្ស) មិនឃើញមាន ត្រីលេញ ត្រីរៀលអង្កាម ត្រីកេស ត្រីក្រាញ់ ត្រីអណ្តាតឆ្កែ ត្រីឈ្មៀត ត្រីក្រាយ ជាដើម។ ដូចនេះការ

ធ្វើទំនប់ និងសំណង់ធារាសាស្ត្រកាត់ស្ទឹងពោធិ៍សាត់នាំឱ្យមានការបាត់ត្រីមួយចំនួន នៅផ្នែកខាងលើ និងផ្នែកខាងក្រោម ដូចបានរៀបរាប់ខាងលើស្រាប់។

ឃ. ធនធានព្រៃឈើ និងសត្វព្រៃ

ការអភិវឌ្ឍគម្រោងវារីអគ្គិសនី គម្រោងធារាសាស្ត្រទាំងនេះ បណ្តាលឱ្យមានបណ្តុំហេតុប៉ះពាល់អវិជ្ជមានដល់ព្រៃឈើ និងសត្វព្រៃ រំពឹងថាមានការប៉ះពាល់អវិជ្ជមានកម្រិតខ្លាំង ដោយសារការគម្រោង នីមួយៗត្រូវការប្រើប្រាស់ដីព្រៃធំ និងមានការរានដីព្រៃធ្វើកសិកម្មពីអ្នកស្រុកមូលដ្ឋាន និងអ្នកចំណូលថ្មីផងដែរ។

ង. វិធានការកាត់បន្ថយ

- ចំពោះរបបជលសាស្ត្ររបស់ស្ទឹង គួរគិតពិចារណាអំពីលំហូរទឹក(លំហូរទឹកបរិស្ថាន)ជាប្រចាំដើម្បីរក្សាលំនឹងបរិស្ថាន នៅខាងក្រោមទំនប់ ឬសំណង់ទាំងនោះ យ៉ាងហោចណាស់ដាក់បំពង់ ដែលអាចបង្ហូរធារទឹកចេញ ស្មើនិងធារទឹកអប្បរមា នៅកន្លែងសាងសង់ រយៈពេលខ្លួប លើសពី១០ឆ្នាំទៅ។
- រាល់គម្រោងទាំងនេះ ត្រូវគិតគូរពីការលាងឬបងហូរល្បាប់ខ្សាច់ ដែលមាននៅផ្នែកខាងលីសំណង់ ដោយគិតពីប្រភេទ និងសំណង់សិល្បៈការ សម្រាប់ដោះល្បាប់ទាំងនោះចេញ បើមិនអញ្ចឹងទេ ខ្សាច់នេះនឹងនាំឱ្យ រាក់ប្រឡាយ រាក់ស្ទឹង អាងមិនខានឡើយ។
- រាល់គម្រោងទាំងនេះ ត្រូវគិតគូរពីការអភិរក្សា ព្រៃឈើ និងសត្វព្រៃ ដោយកំណត់ផែនការថ្នាក់ជាតិក្នុងការគ្រប់គ្រងអាងស្ទឹងពោធិ៍សាត់ ដូចជាការពារ តំបន់ដែលបានតំណត់អភិរក្សព្រៃឈើ និងសត្វព្រៃ ដោយទប់ស្កាត់បទល្មើសព្រៃឈើ និងសត្វព្រៃឱ្យបានម៉ដ្ឋចត់បំផុត បើមិនដូច្នោះទេនឹងបាត់បង់ប្រភពទឹកស្ទឹងនេះជាក់ជាមិនខាន ព្រោះព្រៃឈើជាប្រភពទឹកភ្លៀង។
- រាល់គម្រោងគួរគិតពិចារណាអំពីថវិកា សម្រាប់ធ្វើការព្រលែងកូនត្រីមេពូជខាងក្រោម និងខាងលើសំណង់ទាំងនោះផងដែរ ដោយធ្វើការសហការណ៍ជាមួយមន្ត្រីជំនាញ នៃក្រសួងពាក់ព័ន្ធ។
- ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរសហការគ្នាក្នុងការផ្សព្វផ្សាយកសិកម្ម ដូចជាការប្រើប្រាស់ ជី និងថ្នាំកសិកម្ម ឱ្យមានប្រសិទ្ធិភាពខ្ពស់ មិនប៉ះពាល់ដល់បរិស្ថាន។ ផ្សព្វផ្សាយ ថ្នាំពុលកម្មណាដែល ក្រសួងបានហាមឃាត់ និងពីផលវិបាកនៃការប្រើប្រាស់វាផងដែរ។
- រាជរដ្ឋាភិបាលកម្ពុជា គួរគិតគូរពីផែនការមេសម្រាប់គ្រប់គ្រងអាងស្ទឹងពោធិ៍សាត់ឱ្យមានចីរភាព យូរអង្វែងទៅថ្ងៃខាងមុខទៀត។

## ៧.១០ ហេតុប៉ះពាល់បរិស្ថានវិជ្ជមានសំខាន់ៗ សម្រាប់ទំនប់វារីអគ្គិសនី

### ៧.១០.១ ធនធានរូបសាស្ត្រ និងបរិស្ថាន

ក. ជលសាស្ត្រ

ការទប់ទំនប់កាត់ស្ទឹងពោធិ៍សាត់របស់គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ នៅស្រុកវាលវែងនេះអាចជួយបន្ថយជំនន់ធំៗដោយសារព្យុះភ្លៀងទីហ្វុងក្នុងតំបន់ភ្នំក្រវាញនេះបានមួយផ្នែក ស្ទើរតែជារៀងរាល់ឆ្នាំនៅតំបន់ស្ទឹងពោធិ៍សាត់តែងតែទទួលនូវទឹកជំនន់នៃស្ទឹងនេះ។ ហេតុដូចនេះហើយបើមានទឹកជំនន់ដើមរដូវវស្សា អាចទប់បានមួយផ្នែកធំព្រោះអាងមានទំហំធំសម្រាប់ផ្ទុកទឹកតែបើជំនន់ចុងរដូវវស្សានោះ អាចទប់បានមួយផ្នែកតូចប៉ុណ្ណោះ។ អ្នកភូមិនៅតាមដងស្ទឹងនេះតែងតែជួបបញ្ហានេះជារៀងរាល់ឆ្នាំ ជាពិសេសក្រុងពោធិ៍សាត់តែម្តង។

ការប្រលែងបញ្ចេញទឹកពីទំនប់មេ មកខាងក្រោមជាមធ្យម១.៣ម$^3$/វិនាទីនៅរដូវប្រាំង ធ្វើឱ្យកំណាត់ស្ទឹងពោធិ៍សាត់ពីទំនប់ មកដល់អាគារថាមពលមានទឹកគ្រប់គ្រាន់សម្រាប់រក្សាជីវៈចំរុះរបស់កំណាត់ នៃស្ទឹងនេះ។ បន្ថែមពីនេះ នារដូវប្រាំងធ្វើឱ្យប្រព័ន្ធ ធារាសាស្ត្រ ដំណាក់ឈើក្រំ (មានផែកការសាងសង់) ដំណាក់អំពិល និងចារឹក ទទួលបានទឹកបន្ថែមទៀតពីការបង្ហូរទឹកចេញតាមទួរប៊ីន យ៉ាងហោចណាស់ចំនួន១ ដែលមាន ធារទឹកប្រមាណ ៤០ម$^3$/វិន. (បើដំណើរ

ការទាំង២ទួប៊ីននោះមាន ៨០ម³/វិន.) ***សម្គាល់:*** *តាមការគ្រោងរចនាដំបូងនេះ មិនឃើញមានសំណង់បញ្ចេញ ទឹកសម្រាប់រក្សាជីវៈចំរុះនៃកំណាត់ស្ទឹងពោធិ៍សាត់ចាប់ ពីទំនប់មកអាគារថាមពលទេ។ ដូចនេះ ក្រុមហ៊ុនគួរពិចារណាធ្វើសំណង់ បង្ហូរទឹកយ៉ាងតិច១.៣ ម³/វិន.សម្រាប់រក្សា ជីវៈចំរុះនេះ ដើម្បីធ្វើឱ្យកំណាត់ស្ទឹងនេះរស់ឡើងវិញ ផងដែរ។*

### ខ. មច្ឆជាតិ

បរិមាណដ៏ធំធេងនៃអាងទឹកនេះ អាចបង្កលក្ខខណ្ឌសមស្របសម្រាប់ការអភិរក្ស រួមទាំងការអនុវត្តកិច្ចការពារបរិស្ថាន ដូចដែលបានចែងក្នុងរបាយការណ៍នេះ និងធ្វើឱ្យការកើនឡើងនៃប្រភេទត្រី និងវារីសត្វ មួយចំនួនធំក្នុងតំបន់ស្ទឹង និងអាងនេះ ដូចពាក្យស្លោកខ្មែរយើងពោលថា " ទីណាមានទឹកទីនោះមានត្រី "។

## ៧.១០.២ ធនធានសេដ្ឋកិច្ច និងសង្គម

### ក. ថាមពលអគ្គិសនី

គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់នេះ មានអនុភាពសរុប ៨០មេហ្គាវ៉ាត់ (MW) ហើយការផលិតថាមពលជាមធ្យមក្នុង១ឆ្នាំ អាចស្មើនឹង ៣៦៧,១២ ជីហ្គាវ៉ាត់ម៉ោង (GWh) គឺប្រមាណជា៣៧% នៃថាមពលអគ្គិសនី ដែលប្រទេសកម្ពុជាផលិតបានសរុបនៅឆ្នាំ២០១០ (៩៦៨,៣៦ លានគីឡូវ៉ាត់ម៉ោង(kWh)មិនរាប់បញ្ចូលថាមពលនាំចូលពីប្រទេសជិតខាង គឺប្រទេសថៃ និង វៀតណាមទេ)។ ដោយសារគម្រោងវារីអគ្គិសនីនេះនឹងផ្តល់ថាមពលអគ្គិសនីយ៉ាងចំបងដូចមានបង្ហាញជូនខាងលើនេះ វាអាចឆ្លើយតបដ៏មានប្រសិទ្ធភាព ចំពោះដំណោះស្រាយប្រភពអគ្គិសនីសម្រាប់តំបន់ពោធិ៍សាត់ និងកំពង់ឆ្នាំងក្នុងរយៈពេលមធ្យម ឬអាចនិយាយបានថា ប្រទេសកម្ពុជា នឹងមានថាមពលអគ្គិសនីប្រហែលជិតមួយភាគភាគបីបន្ថែមទៀត នៃកម្លាំងថាមពលអគ្គិសនីផលិតសរុបក្នុងឆ្នាំ២០១០ (គិតតែ ចំពោះគម្រោងនេះតែប៉ុណ្ណោះ មិនបានរួមបញ្ចូលនៃគម្រោងផ្សេងទៀតទេ)។

គម្រោងវារីអគ្គិសនីនេះ នឹងផ្តល់ស្ថេរភាពក្នុងការផ្គត់ផ្គង់អគ្គិសនី ដល់អ្នកប្រើប្រាស់តាមរោងចក្រឧស្សាហកម្មនានា លំនៅដ្ឋាន ទីសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជា ដើម្បីរំដោះភាពក្រីក្ររបស់ប្រជាជនក្នុងតំបន់គម្រោង និងទូទាំងប្រទេស ព្រមទាំងធ្វើឱ្យសង្គមជាតិរីកចំរើនលើគ្រប់វិស័យ ប្រៀបដូចជាមនុស្សលោកយើងបើអត់បាយគឺ គ្មានថាមពលសម្រាប់ធ្វើការងារ រីឯប្រទេស បើគ្មានថាមពលមិនអាចអភិវឌ្ឍឱ្យរីកចំរើនបានទេ។

### ខ. ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់

គម្រោងនេះបានសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅក្នុងតំបន់នេះ ដូចជានឹងសាងសង់ផ្លូវចូលទៅគម្រោងវារីអគ្គិសនីនេះ មានប្រវែងសរុបប្រមាណ៣០គ.ម ក្នុងនោះក្រុមហ៊ុន នឹងធ្វើការ សាងសង់ស្ពានកាត់ស្ទឹងពោធិ៍សាត់មួយផងដែរទៀត។ បន្ថែមពីលើនេះទៀត ក្រុមហ៊ុន នឹងសាងសង់ផ្លូវ និងស្ពានចេញចូលទៅអាគារថាមពល និងទំនប់ ដែលងាយស្រួលឱ្យទេសចរណ៍ជាតិ និងអន្តរជាតិ ចេញចូលតំបន់នោះទៀតផង។ល។ ក្រៅពីហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យសាធារណជន គម្រោងមានសាងសង់ អាគារស្នាក់នៅឱ្យបុគ្គលិក កម្មករ ការិយាល័យ សួនច្បារ និងបង្គន់អនាម័យ បន្ទប់ទឹកសម្រាប់ការប្រើប្រាស់របស់បុគ្គលិកគម្រោង និងធ្វើឱ្យមានសោភ័ណ្ឌភាពដល់តំបន់គម្រោងទាំងមូលទៀតផង ។

### គ. ការប្រើប្រាស់ដី/តម្លៃដី និងទេសចរណ៍

ដោយសារឥទ្ធិពលនៃការអភិវឌ្ឍគម្រោង និងហេដ្ឋារចនាសម្ព័ន្ធរបស់វា អាចនឹងធ្វើឱ្យមានការកែប្រែតំបន់នេះ ឱ្យទៅជាតំបន់ទេសចរណ៍ធម្មជាតិ ឬអេកូធម្មជាតិ ដែលកំពុងពេញនិយមលើពិភពលោក ដែលបច្ចុប្បន្ននេះ(២០១៧) មិនទាន់មានការ អភិវឌ្ឍនៅឡើយ ចាប់ពីតំបន់មាត់សមុទ្រស្រុកមណ្ឌលសីមា ខេត្តកោះកុង ទៅស្រុកវាលវែង ខេត្តពោធិ៍សាត់ ដោយឆ្លងកាត់ដែន ជម្រកសត្វព្រៃពាមក្រសោប តំបន់ព្រៃការពារដងទង់ ភ្នំក្រវាញខាងត្បូង ភ្នំក្រវាញកណ្តាល ដែនជម្រកសត្វព្រៃភ្នំសំកុស រួចភ្ជាប់ដល់ បឹងទន្លេសាបទៀតផង ដែលមានទេសភាពល្អត្រកាល បរិយាកាសត្រជាក់បរិសុទ្ធនាតំបន់នៃជួរភ្នំក្រវាញនេះ។

ម៉្យាងទៀត ដោយសារហេដ្ឋារចនាសម្ព័ន្ធរបស់គម្រោងអាចទាក់ទាញអ្នកទេសចរណ៍ជាតិ និងអន្តរជាតិមកទស្សនានៅក្នុងតំបន់គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ ហើយវារីអគ្គិសនីស្ទឹងអាតៃ និងភ្ជាប់ទៅវារីអគ្គិសនីស្ទឹងឬស្សីជ្រុំ រួមទាំងតំបន់ក្បែរខាងរបស់វាទាំងនេះ ទៅថ្ងៃអនាគតយ៉ាងសន្ទឹកសន្ទាប់ទៀតផង ហើយនឹងធ្វើឱ្យខេត្តកោះកុង និងពោធិ៍សាត់ទាំងមូលក្លាយជាប៉ូលអេកូទេសចរណ៍យ៉ាងសំខាន់មួយសម្រាប់ប្រទេសកម្ពុជាយើងផងដែរ។

**ឃ. ផ្តល់ការងារ និងលើស្ទួយជីវភាព**

គម្រោងផ្តល់ការងារដល់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ក្នុងពេលសាងសង់គម្រោងនេះគ្រោងជ្រើស បុគ្គលិក-កម្មករជាមធ្យមចំនួនប្រហែលជា ៣០០ នាក់។

គម្រោងនឹងមានការជ្រើសរើសអ្នកឯកទេស និងកម្មករជនជាតិខ្មែរមួយចំនួនទៀតនៅពេលប្រតិបត្តិការ និងថែទាំថែមទៀតផង។

គម្រោងបានបង្កើតប្រាក់ចំណូលដល់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋានតាមរយៈចូលបម្រើការងារជាបុគ្គលិកកម្មករទាំងពេលសាងសង់ និងពេលប្រតិបត្តិ និងថែទាំ។ ដោយសារឥទ្ធិពលនៃការអភិវឌ្ឍគម្រោង និងហេដ្ឋារចនាសម្ព័ន្ធ របស់វាអាចបង្កើនចំណូលដល់ប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋានតាមរយៈទេសចរណ៍ជាតិ និងអន្តរជាតិមកកាន់ខេត្តពោធិ៍សាត់ និងការទស្សនាទំនប់វារីអគ្គិសនីនេះទៀតផង។

**ង. ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ**

គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ នឹងផ្តល់ស្ថេរភាពក្នុងការផ្គត់ផ្គង់អគ្គិសនីដល់ការអភិវឌ្ឍលើគ្រប់វិស័យរាប់តាំង ពីការប្រើប្រាស់សម្រាប់បំភ្លឺតាមលំនៅដ្ឋានទីក្រុង ការបម្រើឱ្យវិស័យកសិកម្ម វិស័យទេសចរណ៍ ជាពិសេសវិស័យសិប្បកម្ម និងឧស្សាហកម្ម ដែលជាគ្រឹះដ៏រឹងមាំក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ជាពិសេសធ្វើឱ្យធានាបាននូវតម្លៃអគ្គិសនីថោក មានស្ថេរភាពក្នុង ការប្រើប្រាស់ និងឯករាជ្យក្នុងការផ្គត់ផង់អគ្គិសនីរបស់កម្ពុជាទៀតផង។

ម៉្យាងវិញទៀត គម្រោងមានការបង់ផ្ទាល់ចូលចំណូលថវិកាជាតិ ដោយសារក្រុមហ៊ុននឹងត្រូវបង់ពន្ធអាករលើការនាំចូលប្រេង ឥន្ធនៈសម្រាប់ប្រើប្រាស់ក្នុងការសាងសង់ ពន្ធកាត់ទុក ពន្ធលើប្រាក់ចំណេញ និងពន្ធអាករផ្សេងៗទៀត ក្នុងរយៈពេលប្រតិបត្តិ និងថែទាំ គម្រោងទៅតាមកិច្ចសន្យារវាងក្រុមហ៊ុនជាមួយរាជរដ្ឋាភិបាលកម្ពុជា។

## ៧.១១ ហេតុប៉ះពាល់បរិស្ថានវិជ្ជមានសំខាន់ៗ សម្រាប់ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០ kV

៧.១១.១ ធនធានរូបសាស្ត្រ និងបរិស្ថាន

- **កាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិក**

ស្ថានភាពបច្ចុប្បន្ន នៅតាមបណ្តាលខេត្ត ស្រុក និងឃុំមួយចំនួនធំ ក៏ដូចជានៅទីរួមស្រុក វាលវែង ប្រមោយ ភាគច្រើន គឺប្រើចរន្តអគ្គិសនី ចេញពីកម្លាំងម៉ាស៊ីនដើរដោយឥន្ធនៈ (Fuel) និងត្បូងថ្ម (Coal) ដែលបានបញ្ចេញឧស្ម័ន កាបូនម៉ូណូអុក ស៊ីត (CO) និងកាបូនឌីអុកស៊ីត ឬកាបូនិច ($CO_2$) ជាប្រភពបង្កឱ្យមានឧស្ម័នផ្ទះកញ្ចក់ ដែលធ្វើឱ្យផែនដីឡើងកំដៅ ហើយក៏បានបំពុលខ្យល់ផងដែរ ដែលពិភពលោកកំពុងព្រួយបារម្ភ។ ដូច្នេះនៅពេលដែលគម្រោងបានសាងសង់រួចហើយចាប់ផ្តើមប្រតិបត្តិ និងថែទាំនោះ វានឹងជួយកាត់បន្ថយបញ្ហានេះបានខ្លះៗផងដែរ ព្រោះវាប្រើចរន្តទឹក មិនប្រើប្រេង ឬឧស្ម័នឡើយ។

៧.១១.២ ធនធានសេដ្ឋកិច្ច និងសង្គម

- **ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងការអភិវឌ្ឍសេដ្ឋកិច្ច**

គម្រោងខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០kV ពីអាគារថាមពល ទៅភ្ជាប់ជាមួយបណ្តាញខ្សែអូរសោម-ខេត្តពោធិ៍សាត់ របស់ក្រុមហ៊ុន CPG នឹងមានការផ្គត់ផ្គង់អគ្គិសនីបន្ថែមទៀតទៅកាន់ខេត្តកំពង់ស្ពឺ កណ្តាល កំពង់ឆ្នាំង

ពោធិ៍សាត់ បាត់ដំបង និងរាជធានីភ្នំពេញ តាមរយៈគម្រោងខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០kV ពីអនុស្ថានីយអូរសោម-ពោធិ៍សាត់ និងគម្រោងភ្នំពេញ-បាត់ដំបង ដើម្បីឆ្លើយតប ទៅនឹងតំរូវការក្នុងការអភិវឌ្ឍជាបណ្តាញអគ្គិសនី ដ៏មានប្រសិទ្ធភាពសម្រាប់ប្រទេសជាតិ។

ស្របទៅនឹងនយោបាយកាត់បន្ថយភាពក្រីក្រ របស់រាជរដ្ឋាភិបាលកម្ពុជាគម្រោងនេះ នឹងធ្វើឱ្យប្រជាពលរដ្ឋមានលទ្ធភាពប្រើប្រាស់អគ្គិសនីនេះមានតម្លៃថោកក្នុងការងារកសិកម្ម ដូចជាការងារស្រោចស្រពដំណាំស្រូវ និងចំការជាដើម។ ជាងនេះទៅទៀត ប្រជាពលរដ្ឋក៏អាចមានជីវភាពល្អប្រសើរថែមទៀត នៅពេលពួកគាត់មានថាមពលនេះដើម្បីការងារសិប្បកម្មនានា ដូចជា ចំលាក់ តម្បាញ។ល។ ហើយក៏ជាការទាក់ទាញឱ្យមានរោងចក្រ ឧស្សាហកម្មខ្នាតធំ និងតូចកើតមាននៅតាមតំបន់ ដែលបណ្តាញនេះ ឆ្លងកាត់ ហើយអាចបង្កើនការងារ ក៏ដូចជាចំណូលបន្ថែមជូនប្រជាពលរដ្ឋផងដែរ។

ម៉្យាងវិញទៀត គម្រោងមានការបង់ផ្ទាល់ចូលចំណូលថវិកាជាតិ ដោយសារក្រុមហ៊ុននឹងត្រូវបង់ពន្ធអាករលើការនាំចូលប្រេង ឥន្ធនៈ សម្រាប់ប្រើប្រាស់ក្នុងការសាងសង់ ពន្ធកាត់ទុក ពន្ធលើប្រាក់ចំណេញ និងពន្ធអាករផ្សេងៗទៀត ក្នុងរយៈពេលប្រតិបត្តិ និង ថែទាំគម្រោងទៅតាមកិច្ចសន្យារវាងក្រុមហ៊ុនជាមួយរាជរដ្ឋាភិបាលកម្ពុជា។

- **ការប្រើប្រាស់ដី/តម្លៃដី និងទេសចរណ៍**

ដោយសារឥទ្ធិពលនៃការអភិវឌ្ឍគម្រោង និងហេដ្ឋារចនាសម្ព័ន្ធរបស់វាអាចនឹងធ្វើឱ្យដីក្បែរតំបន់គម្រោងមានតម្លៃខ្ពស់ ជាពិសេសការប្រើប្រាស់ដីសម្រាប់វិស័យឧស្សាហកម្ម កសិកម្មទំនើប និងទេសចរណ៍។ នៅតាមតំបន់មួយចំនួនដែលមានខ្សែបញ្ជូនអគ្គិសនី តង់ស្យុងខ្ពស់២៣០kV នេះឆ្លងកាត់។ ដូច្នេះប្រជាពលរដ្ឋអាចកែប្រែតំបន់មួយចំនួន ឱ្យទៅជាតំបន់ទេសចរណ៍ប្រចាំភូមិ ឃុំ របស់ ពួកគេទៅតាមលទ្ធភាពដែលគេអាចធ្វើបាន។ ជាងនេះទៅទៀត ការអភិវឌ្ឍផ្លូវចូលសម្រាប់សាងសង់គម្រោងនេះ បានភ្ជាប់ចរាចរណ៍ កោះកុង-ពោធិ៍សាត់ ដែលអាចឱ្យគេបង្កើតទេសចរណ៍-បរិស្ថាន ឬអេកូ-ទេសចរណ៍ ដោយភ្ជាប់តំបន់មាត់សមុទ្រ ភាគនិរតី នៃប្រទេសកម្ពុជា កាត់តាមព្រៃកោងកាង នៃដែនជម្រកសត្វព្រៃពាមក្រសោប ព្រៃការពារដងទង់ ភ្នំក្រវាញខាងត្បូង ក្រវាញកណ្តាល ដល់ដែនជម្រកសត្វព្រៃភ្នំសំកុស រួចគេអាចភ្ជាប់ទៅបឹងទន្លេសាប ហើយឆ្លងចូលទៅអង្គរវត្ត ខេត្តសៀមរាបទៀតផង។

- **ផ្តល់ការងារ និងលើកស្ទួយជីវភាព** (Employment and increase living standard)

តាមរយៈគម្រោងនេះបានផ្តល់ការងារដល់ប្រជាពលរដ្ឋកម្ពុជាផងដែរ ដូចជាក្នុងដំណាក់កាលសាងសង់គម្រោងត្រូវជ្រើសរើស បុគ្គលិក-កម្មករគម្រោង៤០០នាក់ (រួមទាំងការសាងសង់ទំនប់វារីអគ្គិសនីទាំងមូល) ក្នុងនោះប្រជាពលរដ្ឋក្នុងមូលដ្ឋានចំនួន៣០០នាក់ និងបុគ្គលិក-កម្មករបរទេសចំនួន១០០នាក់។ រីឯក្នុង ដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោងនឹងត្រូវជ្រើសរើសបុគ្គលិក-កម្មករ ចំនួន១៣នាក់ ក្នុងនោះប្រជាពលរដ្ឋមូលដ្ឋាន សរុប០៦នាក់ និងបុគ្គលិក-កម្មករបរទេស ០៧នាក់។

គម្រោងនេះ នឹងមានការបណ្តុះបណ្តាលមន្ត្រីជំនាញកម្ពុជា សម្រាប់បន្តដំណើរការក្រោយពីក្រុមហ៊ុនបញ្ចប់កិច្ចសន្យាជាមួយរាជរដ្ឋាភិបាល។

គម្រោងនឹងបង្កើតប្រាក់ចំណូលដល់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋាន តាមរយៈការចូល បម្រើការងារជាបុគ្គលិក-កម្មករ ទាំងពេលសាងសង់ និងពេលប្រតិបត្តិការ-ថែទាំ។

Draft